# សៀវភៅណែនាំសង្គមស៊ីវិល

## ស្តីពី

## ការបំពេញការងារជាមួយនឹងកម្មវិធីសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ

*"នេះជាសំណៅបកប្រែក្រៅផ្លូវការ ពីសំណៅដើមជាភាសាអង់គ្លេសរបស់អង្គការសហប្រជាជាតិ។ សំណៅបកប្រែក្រៅផ្លូវការនេះ រៀបចំដោយគម្រោងមួយរបស់គណកម្មាការអ្នកច្បាប់អន្តរជាតិ (ICJ) ក្រោមការជំនួយថវិកាពីការិល័យបរទេស និង រដ្ឋាភិបាលនៃចក្រភពអង់គ្លេស"។*

# សៀវភៅណែនាំសង្គមស៊ីវិល

## ស្ដីពី

## ការបំពេញការងារជាមួយនឹងកម្មវិធីសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ

បុរីញូវយ៉ក និងរដ្ឋធានីហ្សឺណែវ ឆ្នាំ២០០៨

*ការកំណត់ឈ្មោះ និងចំណងជើងនានាដែលបានប្រើប្រាស់ និងការបង្ហាញព័ត៌មាននៅក្នុងការបោះពុម្ពផ្សាយនេះពុំមែនជាទស្សនៈរបស់លេខាធិការដ្ឋាននៃអង្គការសិទ្ធិមនុស្សពាក់ព័ន្ធនឹងស្ថានការណ៍គតិយុត្តនៃប្រទេស ដែនដី ទីក្រុង ឬ តំបន់ណាមួយ ឬ អាជ្ញាធរនៃប្រទេស ដែនដី ទីក្រុង ឬ តំបន់ណាមួយ ឬ ពាក់ព័ន្ធនឹងការកំណត់ព្រំដែន ឬ ព្រំប្រទល់នោះដែរ។*

HR/PUB/06/10/Rev.1

សៀវភៅណែនាំនេះត្រូវបានបោះពុម្ពឡើងក្រោមជំនួយហិរញ្ញវត្ថុពីអង្គការ Rights & Democracy។

# បុព្វកថា

ការនិពន្ធបុព្វកថានៅក្នុង*សៀវភៅណែនាំ*នេះគឺជាការងារមួយក្នុងចំណោមការងារដំបូងរបស់ខ្ញុំក្នុងនាមជាឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សថ្មីមួយរូប។ ខ្ញុំគិតថា ខ្ញុំគួរសរសេរវាឡើងដោយសារវាជាឱកាសដំបូងឲ្យខ្ញុំបង្ហាញអារម្មណ៍ជឿជាក់យ៉ាងមុតមាំក្នុងមុខតំណែងថ្មីនៃជីវិតការងាររបស់ខ្ញុំ ពោលគឺ ការជឿជាក់ថា សង្គមស៊ីវិលមានសមត្ថភាពក្នុងការនាំឲ្យមានការផ្លាស់ប្តូរ។ ជាការពិតណាស់ គ្មាននរណាម្នាក់អាចមើលរំលងការចូលរួមចំណែករបស់សង្គមស៊ីវិលចំពោះការអភិវឌ្ឍបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ការតស៊ូមតិ និងដំណើរការយន្តការសិទ្ធិមនុស្សដែលត្រូវបានយកមកពិភាក្សានៅក្នុង*សៀវភៅណែនាំ*នេះ។ សព្វថ្ងៃនេះ ការយល់ឃើញរបស់សង្គមស៊ីវិល ចំណេះដឹងជាក់ស្តែង និងអាហារូបករណ៍បានដើរតួនាទីយ៉ាងសំខាន់ជម្រុញឲ្យមានចលនាសិទ្ធិមនុស្សដើម្បីស្វែងរកយុត្តិធម៌ និងសមភាពសម្រាប់យើងគ្រប់គ្នា។

ជាក់ស្តែង កិច្ចសហប្រតិបត្តិការណ៍នៃការិយាល័យរបស់ខ្ញុំជាមួយនឹងសង្គមស៊ីវិលនៅតែជាយុទ្ធសាស្ត្រអាទិភាពមួយដោយសារថាវាពង្រឹងគោលដៅរួមរបស់យើង ជួយដោះស្រាយកង្វល់ឲ្យគ្នាទៅវិញទៅមក និងគាំទ្របេសកកម្ម និងគំនិតផ្តួចផ្តើមការិយាល័យរបស់ខ្ញុំទាំងនៅទីស្នាក់ការកណ្តាល និងនៅតាមទីស្នាក់ការតាមមូលដ្ឋានជាក់ស្តែង។

ការចូលរួមចំណែករបស់តួអង្គសង្គមស៊ីវិលក៏បានធ្វើឲ្យការងាររបស់អ្នកជំនាញឯករាជ្យកាន់តែរីកចម្រើនដែលពួកគេសុទ្ធសឹងជាសមាជិកនៃយន្តការសិទ្ធិមនុស្សដែលបានបង្កើតឡើងជាយូរណាស់មកហើយ ដូចជា គណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស និងយន្តការនីតិវិធីពិសេស។ អ្វីដែលសំខាន់នោះគឺ ឥទ្ធិពល និងចំណេះដឹងរបស់ពួកគេបានជួយឲ្យដំណើរការកើតឡើងនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស ដែលជាស្ថាប័នអន្តររដ្ឋាភិបាលមួយមកជំនួសគណកម្មការសិទ្ធិមនុស្សនៅក្នុងខែមិថុនា ឆ្នាំ២០០៦។

អ្នកការពារសិទ្ធិមនុស្ស អង្គការមិនមែនរដ្ឋាភិបាល និងភាគីសង្គមស៊ីវិលពាក់ព័ន្ធទាំងអស់ផ្សេងទៀតបំពេញការងារសិទ្ធិមនុស្សក្នុងវិធីច្រើនរបៀប ពោលគឺ តាមរយៈការចែករំលែកព័ត៌មាន ការតស៊ូមតិ និងពិនិត្យពិច័យការអនុវត្តសិទ្ធិមនុស្ស ការធ្វើរបាយការណ៍អំពីការរំលោភនានា ការជួយជ្រោមជ្រែងដល់ជនរងគ្រោះនៃការបំពារបំពាន និងការធ្វើយុទ្ធនាការដើម្បីបង្កើតបទដ្ឋានសិទ្ធិមនុស្សថ្មីៗតាមរយៈការស្វែងយល់សហគមន៍ និងទីស្នាក់ការតាមមូលដ្ឋានជាក់ស្តែង។ ពួកគេផ្តល់សម្លេងជូនអ្នកគ្មានអំណាចនៅតាមទីវេទិកានានាដែលជនរងគ្រោះមិនអាចនៅឆ្ងាយពីជនរងគ្រោះ រួមមាន វេទិកា និងយន្តការសិទ្ធិមនុស្សអន្តរជាតិ។ វាបង្ហាញច្បាស់ណាស់ថា តួអង្គសង្គមស៊ីវិលចាំបាច់ត្រូវយល់ដឹង និងសិក្សាស៊ីជម្រៅលើនីតិវិធីបំពេញការងាររបស់ស្ថាប័នសិទ្ធិមនុស្សជាតិ តំបន់ និងអន្តរជាតិ។ *សៀវភៅណែនាំនេះ*មានគោលបំណងជួយសម្រួលការខិតខំប្រឹងប្រែងលំបាកបែបនេះ។

ជាចុងក្រោយ ខ្ញុំសូមអនុញ្ញាតគូសបញ្ជាក់ថា ការចេញផ្សាយ*សៀវភៅណែនាំ*នេះគាប់ជួននឹងទិវារំលឹកខួបទី៦០ឆ្នាំនៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស។ សេចក្តីសន្យាផ្តល់យុត្តិធម៌ សេចក្តីថ្លៃថ្នូរ និងសិទ្ធិមនុស្សសម្រាប់យើងគ្រប់គ្នានៅក្នុងសេចក្តីប្រកាសនេះនៅពុំទាន់សម្រេចបានទាំងស្រុងនៅឡើយ។

យើងត្រូវបន្តខិតខំបន្ថែមទៀតដើម្បីគោលការណ៍នៃសេចក្តីប្រកាសជាសាកលនេះសម្រេចបាននូវផ្លែផ្កាជូនដល់សហគមន៍ផ្សេងៗគ្នាដែលយើងបម្រើ។ ខ្ញុំសង្ឃឹមថា *សៀវភៅណែនាំ*នេះនឹងយកមកប្រើប្រាស់ដើម្បីជួយសម្រួលឲ្យតួអង្គសង្គមស៊ីវិលយល់ដឹងអំពីការប្រើប្រាស់ប្រព័ន្ធសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ។ *សៀវភៅណែនាំ*នេះមានលក្ខណៈសាមញ្ញមែនប៉ុន្តែជាធនធានដ៏មានតម្លៃចំពោះកិច្ចខិតខំរួមគ្នារបស់យើងដើម្បីឲ្យសម្រេចបាននូវសិទ្ធិមនុស្ស សេចក្តីថ្លៃថ្នូ និងសមភាពជាសាកល។

*(ហត្ថលេខា)*

Navanethem Pillay

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

## មាតិកា


ទំព័រ

បុព្វកថា

អក្សរកាត់ និងពាក្យបំព្រួញ

សេចក្តីផ្តើម

| | |
|---|---|
| I | សេចក្តីផ្តើមស្តីពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស |
| II | អាហារូបករណ៍ និងកម្មវិធីបណ្តុះបណ្តាលនៃការិយាល័យ OHCHR |
| III | ឯកសារបោះពុម្ពផ្សាយ និងឯកសារធនធាននៃការិយាល័យ OHCHR |
| IV | គណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស |
| V | ក្រុមប្រឹក្សាសិទ្ធិមនុស្ស |
| VI | យន្តការនីតិវិធីពិសេស |
| VII | យន្តការពិនិត្យរបាយការណ៍ជាសាកលតាមកាលកំណត់ |
| VIII | ការដាក់បណ្តឹងចោទប្រកាន់ការរំលោភសិទ្ធិមនុស្ស |
| IX | មូលនិធិ និងជំនួយ |

# អក្សរកាត់ និងពាក្យបំព្រួញ

| | |
|---|---|
| ACT | គម្រោង "រួមគ្នាជួយសហគមន៍" |
| CAT | អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬ ទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬ បន្ថោកបន្ទាប |
| CEDAW | អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ |
| CRC | អនុសញ្ញាស្តីពីសិទ្ធិកុមារ |
| ECOSOC | ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម |
| ICCPR | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ |
| ICERD | អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ |
| ICESCR | កតិកាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ |
| ICRMW | អនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍គ្រប់រូបនិង សមាជិកគ្រួសាររបស់ពួកគេ |
| LDC | ប្រទេសអភិវឌ្ឍន៍តិចតួច |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NHRI | ស្ថាប័នសិទ្ធិមនុស្សជាតិ |
| OHCHR | ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស |
| OPCAT | ពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬ ទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬ បន្ថោកបន្ទាប |
| UNDEF | អង្គការមូលនិធិប្រជាធិបតេយ្យនៃអង្គការសហប្រជាជាតិ |
| UNDP | កម្មវិធីអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ |
| UNESCO | អង្គការសិក្សាវិទ្យាសាស្ត្រអប់រំ និងវប្បធម៌នៃអង្គការសហប្រជាជាតិ |
| UNITAR | ស្ថាប័នទទួលបន្ទុកបណ្តុះបណ្តាល និងស្រាវជ្រាវនៃអង្គការសហប្រជាជាតិ |
| UPR | យន្តការពិនិត្យរបាយការណ៍ជាសាកលតាមកាលកំណត់ |

# សេចក្ដីផ្ដើម

អំពី *សៀវភៅណែនាំ*

*សៀវភៅណែនាំសង្គមស៊ីវិលស្ដីពីការបំពេញការងារជាមួយនឹងកម្មវិធីសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ៖* ត្រូវបានរៀបចំឡើងសម្រាប់តួអង្គសង្គមស៊ីវិលដែលចូលរួមចំណែកជារៀងរាល់ថ្ងៃនៅគ្រប់ទីកន្លែងដើម្បីលើកកម្ពស់ ការពារ និងធ្វើឲ្យសិទ្ធិមនុស្សមានការរីកចម្រើន។

*សៀវភៅណែនាំ*នេះបាននិពន្ធក្រោយការសិក្សាស្ទង់ពីអ្នកប្រើប្រាស់*សៀវភៅណែនាំ*ដែលបានបោះពុម្ពលើកទីមួយ ពោលគឺ *សៀវភៅណែនាំអង្គការ NGO (ឆ្នាំ២០០៦)៖ ការបំពេញការងារជាមួយនឹងការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស*។ សៀវភៅបោះពុម្ពលើកទីពីរនេះត្រូវបានធ្វើបច្ចុប្បន្នភាព និងកែសម្រួលយ៉ាងហ្មត់ចត់ ហើយផ្ដោតចំបងលើគណកម្មាធិការ និងយន្តការសិទ្ធិមនុស្សនៃអង្គការសហប្រជាតិព្រមទាំងពន្យល់អំពីរបៀបដែលតួអង្គសង្គមស៊ីវិលរួមទាំងអង្គការមិនមែនរដ្ឋាភិបាលផងដែរ (អង្គការ NGO) ចូលរួមបំពេញការងារជាមួយនឹងគណកម្មាធិការ និងយន្តការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ។ ការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (ការិយាល័យ OHCHR) សង្ឃឹមថា *សៀវភៅណែនាំ*នេះនឹងផ្ដល់លទ្ធភាពឲ្យបុគ្គលកាន់តែច្រើនទទួលបាន និងទាមទារនូវសិទ្ធិមនុស្សរបស់ខ្លួនតាមរយៈគណកម្មាធិការ និងយន្តការទាំងនេះ។

តើអ្វីទៅដែលហៅថាតួអង្គសង្គមស៊ីវិល?

យោងតាមគោលបំណងនៃ*សៀវភៅណែនាំ*នេះ តួអង្គសង្គមស៊ីវិលគឺជាបុគ្គលដែលស្ម័គ្រចិត្តចូលរួមជាមួយនឹងសាធារណជន និងធ្វើសកម្មភាពលើផលប្រយោជន៍ គោលបំណង ឬ តម្លៃរួមគ្នាស្របតាមគោលបំណងនៃអង្គការសហប្រជាតិ។ *សៀវភៅណែនាំ*នេះណែនាំដល់តួអង្គសង្គមស៊ីវិលអំពីការលើកកម្ពស់ និងការការពារសិទ្ធិមនុស្សជាសាកល ឧទាហរណ៍៖

- អ្នកការពារសិទ្ធិមនុស្ស
- អង្គការសិទ្ធិមនុស្ស (អង្គការ NGO សមាគម និងក្រុមជនរងគ្រោះ)
- អង្គការដែលផ្ដោតលើបញ្ហាពាក់ព័ន្ធ
- សម្ព័ន្ធ និងបណ្ដាញ (សិទ្ធិស្ត្រី សិទ្ធិកុមារ សិទ្ធិបរិស្ថាន)
- ជនពិការ និងអង្គការតំណាងពួកគេ
- ក្រុមសហគមន៍មូលដ្ឋាន (ប្រជាជនដើមភាគតិច ប្រជាជនភាគតិច)
- ក្រុមជំនឿសាសនា (វិហារ ក្រុមសាសនា)

- សហជីព (សហជីពព្រមទាំងសមាគមវិជ្ជាជីវៈដូចជាសមាគមអ្នកកាសែត គណៈមេធាវី សមាគមចៅក្រម/ព្រះរាជអាជ្ញា សមាគមនិស្សិត)
- ក្រុមចលនាសង្គម (ក្រុមចលនាសន្តិភាព ក្រុមចលនានិស្សិត ក្រុមចលនាគាំទ្រប្រជាធិបតេយ្យ)
- គណៈវិជ្ជាជីវៈដែលចូលរួមចំណែកផ្ទាល់ដើម្បីទទួលបានសិទ្ធិមនុស្ស (បុគ្គលិកមនុស្សធម៌ មេធាវី បណ្ឌិត និងបុគ្គលិកវេជ្ជសាស្ត្រ)
- សាច់ញាតិជនរងគ្រោះ និង
- ស្ថាប័នសាធារណៈដែលធ្វើសកម្មភាពលើកកម្ពស់សិទ្ធិមនុស្ស (សាលារៀន សាកលវិទ្យាល័យ អង្គការស្ថាប័នស្រាវជ្រាវ)។

សង្គមស៊ីវិលរឹងមាំ និងស្វយ័តមួយដែលអាចដំណើរប្រតិបត្តិការដោយសេរី ព្រមទាំងមានការយល់ដឹង និងជំនាញទាក់ទងនឹងសិទ្ធិមនុស្សគឺជាសមាសធាតុសំខាន់មួយក្នុងការធានាឲ្យបាននូវការការពារសិទ្ធិមនុស្សប្រកបដោយចេរភាពនៅថ្នាក់ជាតិ។ ដូច្នេះ តួអង្គសង្គមស៊ីវិលគឺជាដៃគូសំខាន់នៅក្នុងប្រព័ន្ធសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ។

ទោះបីជាតួអង្គចូលរួមចំណែកយ៉ាងសំខាន់លើការលើកកម្ពស់ និងការពារសិទ្ធិមនុស្សក៏ដោយ ក៏ស្ថាប័ន្ធសិទ្ធិមនុស្សជាតិ (ស្ថាប័ន NHRIs) ពុំបានយកមកពិពណ៌នានៅក្នុង*សៀវភៅណែនាំ*នេះទេ។ ព័ត៌មាន និងឯកសារធនធានអំពីស្ថាប័ន NHRIs អាចរកមើលបាននៅក្នុងគេហទំព័រនៃការិយាល័យ OHCHR។ យើងខ្ញុំក៏សូមអញ្ជើញមិត្តអ្នកអានធ្វើការទាក់ទងជាមួយនឹងអង្គភាពស្ថាប័នជាតិនៃការិយាល័យ OHCHR តាមរយៈអ៊ីមែល niu@ohchr.org។

# មាតិកានៃសៀវភៅណែនាំ

*សៀវភៅណែនាំ*នេះស្វាគមន៍ជំបូងជាមួយនឹងសេចក្តីផ្តើមស្តីពីការិយាល័យ OHCHR (ជំពូក I) អាហារូបករណ៍ និងកម្មវិធីបណ្តុះបណ្តាល (ជំពូក II) និងឯកសារបោះពុម្ពផ្សាយ និងឯកសារធនធាន (ជំពូក III) ហើយបន្ទាប់មកនឹងបង្ហាញអំពីគណកម្មាធិការ និងយន្តការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ព្រមទាំងនីតិវិធីក្នុងការប្រើប្រាស់គណៈកម្មាធិការ និងយន្តការទាំងនេះ។ ជំពូកផ្សេងទៀតរួមមាន៖

- គណៈកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស (ជំពូក IV)
- ក្រុមប្រឹក្សា និងយន្តការសិទ្ធិមនុស្ស រួមទាំង គណកម្មាធិការប្រឹក្សាយោបល់ វេទិកាសង្គម វេទិកាស្តីពីជនជាតិភាគតិច យន្តការអ្នកជំនាញទទួលបន្ទុកសិទ្ធិជនជាតិដើមភាគតិច ក្រុមការងារទូទៅទទួលបន្ទុកសិទ្ធិទទួលបានការអភិវឌ្ឍន និងយន្តការជាច្រើនទៀតទាក់ទងនឹងសេចក្តីប្រកាស និងផែនការសកម្មភាពទីក្រុង Durban (ជំពូក V)។
- យន្តការនីតិវិធីពិសេស (ជំពូក VI)
- យន្តការពិនិត្យរបាយការណ៍ជាសាកលតាមកាលកំណត់ (ជំពូក VIII) និង
- ការដាក់បណ្តឹងចោទប្រកាន់ការរំលោភសិទ្ធិមនុស្ស (ជំពូក VIII)។

ជំពូកចុងក្រោយផ្តល់ព័ត៌មានអំពីមូលនិធិ និងជំនួយឥតសំណង (ជំពូក IX) ដែលមានផ្នែកខ្លះត្រូវបានចាត់ចែងដោយការិយាល័យ OHCHR។

ដើម្បីឲ្យមិត្តអ្នកអានងាយស្រួលទទួលបានព័ត៌មាន ជំពូកនីមួយៗត្រូវបាននិពន្ធឡើងក្នុងលក្ខណៈដាច់ចេញពីជំពូកផ្សេងទៀត។ មិត្តអ្នកអានក៏អាចទាញយកជំពូកមួយៗពីគេហទំព័រនៃការិយាល័យ OHCHR រួមជាមួនឹងសៀវភៅណែនាំនេះទាំងមូលបាន។

វាមានសារសំខាន់គួរកត់សម្គាល់ថា *សៀវភៅណែនាំ*នេះមិនមែនជាគោលការណ៍ណែនាំថេរ ឬ អនុវត្តដាច់តែឯងនោះទេ។ ក្នុងករណីអាចធ្វើទៅបាន យើងខ្ញុំបានចង្អុលយោងគេហទំព័រនៃការិយាល័យ OHCHR និងឯកសារធនធានផ្សេងទៀតដើម្បីឲ្យមិត្តអ្នកអានមានលទ្ធភាពទទួលព័ត៌មានថ្មីៗ។ យើងខ្ញុំលើកទឹកចិត្តឲ្យមិត្តអ្នកអានប្រើប្រាស់ឯកសារធនធានបន្ថែមទាំងនេះ។

## ប្លង់សៀវភៅ

ជារួមមក ជំពូកទាំងឡាយត្រូវបានបែងចែកជាបីផ្នែកៈ

- និយមន័យនៃគណកម្មាធិការ/យន្តការ;
- របៀបគណកម្មាធិការ/យន្តការបំពេញការងារ; និង
- របៀបតួអង្គសង្គមស៊ីវិលទាក់ទង និងបំពេញការងារជាមួយនឹងគណកម្មាធិការ/យន្តការ។

ជំពូកនីមួយៗក៏មានរាយនាមអាសយដ្ឋានទំនាក់ទំនងនៅការិយាល័យ OHCHR និងបញ្ចូលទំព័រតភ្ជាប់ទៅកាន់ឯកសារធនធានដទៃទៀតផងដែរ។

## មតិយោបល់

*សៀវភៅណែនាំ*នេះគឺជាឧបករណ៍ដ៏មានឋាមភាពមួយ។ អង្គភាពសង្គមស៊ីវិលនៃការិយាល័យ OHCHR ស្វាគមន៍រាល់មតិយោបល់ផ្សេងៗពីមិត្តអ្នកអាន។ សូមផ្ញើរមតិយោបល់ និងសំណូមពរមកកាន់ៈ

**អង្គភាពសង្គមស៊ីវិល**

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

Palais des Nations

CH-1211 ទីក្រុងហ្សឺណែវ 10, ប្រទេសស្វីស

អ៊ីមែលៈ CivilSocietyUnit@ohchr.org

# I. សេចក្តីផ្តើមស្តីពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

## ក. កម្មវិធីសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ

កម្មវិធីសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិបង្កើតឡើងដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្សរបស់បុគ្គលគ្រប់រូបនៅគ្រប់ទីកន្លែង។ កម្មវិធីនេះត្រូវបានអនុវត្តតាមរយៈស្ថាប័ន និងភ្នាក់ងារសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិដោយឡែកៗពីគ្នា និងរួមបញ្ចូលគណកម្មាធិការ និងយន្តការសិទ្ធិមនុស្សដូចបានលើកឡើងនៅក្នុង*សៀវភៅណែនាំ*នេះ។ អង្គការស្ថាប័នទាំងអស់នេះមានគោលបំណងរួមមួយគឺលើកកម្ពស់ និងការពារសិទ្ធិមនុស្សដែលត្រូវបានព្រមព្រៀងជាអន្តរជាតិ ពោលគឺ សិទ្ធិពលរដ្ឋ វប្បធម៌ សេដ្ឋកិច្ច នយោបាយ និងសង្គមកិច្ច ដូចបានប្រកាសនៅក្នុងសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្សកាលពីជាង ៦០ ឆ្នាំមុន។

ក្នុងនាមជាស្ថាប័នមានអំណាចជាសាកលលើបញ្ហាសិទ្ធិមនុស្ស **ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (ការិយាល័យ OHCHR)** ទទួលខុសត្រូវលើការដឹកនាំកម្មវិធីសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ និងលើការលើកកម្ពស់ព្រមទាំងការពារសិទ្ធិមនុស្សទាំងអស់ដូចមានចែងស្របតាម**ធម្មនុញ្ញនៃអង្គការសហប្រជាជាតិ** និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

ការិយាល័យនេះមានចក្ខុវិស័យមួយគឺចង់បានពិភពលោកដែលមានការគោរពសិទ្ធិមនុស្សពេញលេញ។ ការិយាល័យ OHCHR ខិតខំប្រឹងប្រែងសម្រេចឲ្យបាននូវការការពារសិទ្ធិមនុស្សគ្រប់*បែបយ៉ាង*សម្រាប់មនុស្ស*គ្រប់ៗគ្នា*ដើម្បីផ្តល់អំណាចឲ្យប្រជាជនទទួលបានសិទ្ធិរបស់ពួកគេ និងជួយជ្រោមជ្រែងបុគ្គលដែលទទួលខុសត្រូវលើការប្រកាន់ខ្ជាប់នូវសិទ្ធិក្នុងគោលបំណងដើម្បីធ្វើយ៉ាងណាឲ្យមានការគោរពសិទ្ធិទាំងនេះ។

## ខ. ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

ការិយាល័យ OHCHR គឺជាផ្នែកមួយនៃលេខាធិការដ្ឋានរបស់អង្គការសហប្រជាជាតិ ហើយត្រូវបានដឹកនាំដោយឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សដែលជាតួនាទីមួយបង្កើតឡើងក្នុងឆ្នាំ១៩៩៣[27]។ ការិយាល័យនេះសហការជាមួយនឹងតួអង្គគ្រប់វិស័យរួមទាំងរដ្ឋាភិបាល ស្ថាប័នសិទ្ធិ

[27] សូមមើលសេចក្តីសម្រេចចិត្តនៃមហាសន្និបាតលេខ ៤៨/១៤១ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣។ ការងាររបស់ការិយាល័យ OHCHR អនុវត្តតាមការណែនាំដូចមានចែងនៅក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស និងលិខិតុបករណ៍សិទ្ធិមនុស្សនាពេលក្រោយៗមកទៀតរួមទាំងសេចក្តីប្រកាស

មនុស្សជាតិ (ស្ថាប័ន NHIRs) អង្គការមិនមែនរដ្ឋាភិបាល (NGOs) និងតួអង្គសង្គមស៊ីវិលផ្សេងទៀត ដើម្បីបំផុសឲ្យមានការប្តេជ្ញាលើបញ្ហាសិទ្ធិមនុស្សកាន់ទូលាយឡើង។

ក្នុងនាមជាមន្ត្រីចំបងទទួលបន្ទុកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ឧត្តមស្នងការគឺជាអាជ្ញាធរបំពេញការងារត្រឹមត្រូវតាមសីលធម៌ ហើយគឺជាសម្លេងសម្រាប់ជនរងគ្រោះ។ ឧត្តមស្នងការគឺជាមគ្គុទ្ទេសក៍លើបេសកកម្ម និងតម្លៃ កំណត់អាទិភាព និងដឹកនាំសកម្មភាពនានា។ ឧត្តមស្នងការធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈ និងអំពាវនាវអំពីស្ថានភាព និងវិបត្តិផ្នែកសិទ្ធិមនុស្ស ចូលរួមក្នុងកិច្ចសន្ទនាជាមួយនឹងរដ្ឋាភិបាលដើម្បីពង្រឹងការការពារសិទ្ធិមនុស្សថ្នាក់ជាតិ ហើយធ្វើដំណើរទៅគ្រប់ទីកន្លែងដើម្បីឲ្យសារស្តីពីសិទ្ធិមនុស្សបានឮសុះសាយនៅតាមគ្រប់បណ្តាប្រទេសក្នុងពិភពលោក ដើម្បីស្តាប់មតិយោបល់របស់អ្នកដែលត្រូវបានគេបដិសេធសិទ្ធិ និងដើម្បីចូលរួមសកម្មភាពការងារជាមួយនឹងអ្នកកាន់កាប់ភារកិច្ច។

ឧត្តមស្នងការធ្វើការបញ្ជ្រាបបទដ្ឋានសិទ្ធិមនុស្សនៅគ្រប់កម្មវិធីនៃអង្គការសហប្រជាជាតិដើម្បីធ្វើយ៉ាងណាឲ្យសរសេរស្តម្ភសំខាន់ទាំងបីនៃប្រព័ន្ធអង្គការសហប្រជាតិពោលគឺ សន្តិភាព និងសន្តិសុខ ការអភិវឌ្ឍ និងសិទ្ធិមនុស្សមានភាពពាក់ព័ន្ធគ្នា និងពង្រឹងគ្នាទៅវិញទៅមក ហើយនឹងដើម្បីឲ្យសិទ្ធិមនុស្សបង្កើតជាគ្រឹះសកម្មភាពនៃអង្គការសហប្រជាជាតិ។

ដោយហេតុថា ឧត្តមស្នងការថ្លែងដោយចំហ និងជាសាធារណៈអំពីស្ថានភាពសិទ្ធិមនុស្សជាសាកល និងប្រយុទ្ធប្រឆាំងនិទណ្ឌភាពតាមរយៈការចាប់បង្ខំឲ្យរដ្ឋទទួលខុសត្រូវលើសកម្មភាព និងភាពមិនអើពើរបស់ពួកគេ ឧត្តមស្នងការ និងការិយាល័យនេះត្រូវបានរំពឹងជានិច្ចជាកាលថានឹងទាក់ទាញនូវមតិរិះគន់ពីគ្រប់តំបន់។ អ្វីដែលសំខាន់ជាងនេះគឺ នៅពេលដាក់បញ្ចូលទស្សនវិស័យ និងវិធីសាស្ត្រសិទ្ធិមនុស្សទាំងឡាយនៅក្នុងកិច្ចដដែលវែកញែកដែលជាញឹកញាប់មានលក្ខណៈនយោបាយ វាបានជួយទ្រទ្រង់ការងាររបស់ការិយាល័យឲ្យមានភាពអព្យាក្រឹត្តយ ត្រឹមត្រូវ និងសាកលភាព។

លោកស្រី Navanethem Pillay គឺជាឧត្តមស្នងការនាពេលបច្ចុប្បន្នដែលបានចូលកាន់មុខតំណែងកាលពីខែកញ្ញា ឆ្នាំ២០០៨ បន្តពីលោកស្រី Louise Arbour (ឆ្នាំ២០០៤-ឆ្នាំ២០០៨) លោក

---

ទីក្រុងវីយែន និងផែនការសកម្មភាពឆ្នាំ១៩៩៣ ព្រមទាំងឯកសារលទ្ធផលនៃកិច្ចប្រជុំកំពូលសាកលលោកឆ្នាំ២០០៥ (សេចក្តីសម្រេចចិត្តនៃមហាសន្និបាតលេខ ៦០/១ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៥)។

Sergio Vieira de Mello (ឆ្នាំ២០០២-ឆ្នាំ២០០៣)[28] លោកស្រី Mary Robinson (ឆ្នាំ១៩៩៧-ឆ្នាំ២០០២ និងលោក José Ayala Lasso (ឆ្នាំ១៩៩៤-ឆ្នាំ១៩៩៧)។ លោក Bertrand G. Ramacharan គឺជាឧត្តមស្នងការស្តីទីចាប់តាំងពីឆ្នាំ២០០៣រហូតមកទល់ឆ្នាំ២០០៤។

ការិយាល័យ OHCHR មានទីស្នាក់ការកណ្តាលនៅ Palais Wilson ក្នុងទីក្រុងហ្សឺណែវ ប្រទេសស្វីស និងមានការិយាល័យមួយនៅទីស្នាក់ការកណ្តាលនៃអង្គការសហប្រជាជាតិនៅបុរីញូវយ៉ក។ ការិយាល័យនេះមានបុគ្គលិកជាង ៩០០ នាក់ ដែលបុគ្គលិកជាងពាក់កណ្តាលធ្វើការងារនៅតាមទីន្លែងផ្សេងៗ រួមមាន ក្រុម និងការិយាល័យប្រចាំប្រទេស ការិយាល័យប្រចាំតំបន់ ទីប្រឹក្សាសិទ្ធិមនុស្ស និងសមាសភាពសិទ្ធិមនុស្សបម្រើការងារនៅក្នុងបេសកកម្មរក្សាសន្តិភាពនៃអង្គការសហប្រជាជាតិ។

| i. អាណត្តិការងារនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស | | |
|---|---|---|
| អាណត្តិការងារនៃឧត្តមស្នងការត្រូវបានកំណត់ក្នុងសេចក្តីសម្រេចចិត្តនៃមហាសន្និបាតលេខ ៤៨/១៤១<br>• លើកកម្ពស់ និងការពារសិទ្ធិមនុស្សគ្រប់យ៉ាងសម្រាប់មនុស្សគ្រប់រូប;<br>• ផ្តល់អនុសាសន៍ជូនស្ថាប័នមានសមត្ថកិច្ចនៅក្នុងប្រព័ន្ធអង្គការសហប្រជាជាតិដើម្បីធ្វើបង្កើនប្រសិទ្ធភាព និងការពារសិទ្ធិមនុស្សគ្រប់បែប;<br>• លើកកម្ពស់ និងការពារសិទ្ធិទទួលបានការអភិវឌ្ឍ; | • ផ្តល់ជំនួយបច្ចេកទេសលើសកម្មភាពសិទ្ធិមនុស្ស;<br>• សម្របសម្រួលកម្មវិធីអប់រំ និងផ្តល់ព័ត៌មានដល់សាធារណជនអំពីសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ;<br>• ដើរតួនាទីសកម្មនៅក្នុងលុបបំបាត់ឧបសគ្គដើម្បីសម្រេចឲ្យបាននូវសិទ្ធិមនុស្ស;<br>• ដើរតួនាទីសកម្មនៅក្នុងការទប់ស្កាត់ការបន្តរំលោភសិទ្ធិមនុស្ស; | • ចូលរួមនៅក្នុងកិច្ចសន្ទនាជាមួយនឹងរដ្ឋាភិបាលក្នុងគោលបំណងធានាការគោរពសិទ្ធិមនុស្សគ្រប់យ៉ាង;<br>• លើកតម្កើងកិច្ចសហប្រតិបត្តិការអន្តរជាតិ,<br>• សម្របសម្រួលការលើកកម្ពស់ និងសកម្មភាពការពារសិទ្ធិមនុស្សនៅក្នុងប្រព័ន្ធអង្គការសហប្រជាជាតិទាំងមូល;<br>• ផ្តល់យុត្តិកម្ម សម្រប ពង្រឹង និងបញ្ចៀបយន្តការសិទ្ធិមនុស្សនៃអង្គការសិទ្ធិមនុស្ស |

## គ. ការងារ និងសកម្មភាពការិយាល័យ OHCHR

[28] នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៣ Sergio Vieira de Mello ត្រូវបានគេសម្លាប់រួមជាមួយនឹងបុគ្គលិកអង្គការសហប្រជាជាតិចំនួន ២១ នាក់ផ្សេងទៀតនៅក្នុងទីក្រុងបាងដាតដែលនៅទីនោះគាត់បានបម្រើការងារជូនអង្គការសហប្រជាជាតិក្នុងនាមជាអ្នកតំណាងពិសេសនៃអគ្គលេខាធិការក្នុងប្រទេសអ៊ីរ៉ាក់។

ការិយាល័យ OHCHR ស្នើសុំឲ្យអនុវត្តបទដ្ឋានសិទ្ធិមនុស្សនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់មនុស្សគ្រប់រូបនៅគ្រប់ទីកន្លែង។ ដើម្បីសម្រេចគោលបំណងនេះ ក្រៅពីដៃកិច្ចសហប្រតិបត្តិការជាមួយនឹងដៃគូនៃអង្គការសហប្រជាជាតិ ការិយាល័យ OHCHR ក៏សហការជាមួយសភា អាជ្ញាធរតុលាការ នគរបាល និងមន្ត្រីពន្ធនាគារ ស្ថាប័ន NHRIs អង្គការ NGOs និងតួអង្គសង្គមស៊ីវិលលើគ្រប់វិស័យដើម្បីលើកកម្ពស់ការយល់ដឹង និងការគោរពសិទ្ធិមនុស្ស។ ការិយាល័យ OHCHR ផ្តល់អំណាចឲ្យបុគ្គលអាចទាមទារសិទ្ធិរបស់ពួកគេ និងជួយរដ្ឋឲ្យគោរពតាមកាតព្វកិច្ចសិទ្ធិមនុស្ស។

អង្គការ NGOs សិទ្ធិមនុស្សថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់អន្តរជាតិគឺជាផ្នែកដ៏សំខាន់មួយនៃចលនាសិទ្ធិមនុស្សអន្តរជាតិ និងជាដៃគូរដ៏ចាំបាច់របស់ការិយាល័យ OHCHR។ អង្គការទាំងនេះញញ្ញាក់អារម្មណ៍ដល់សាកលលោកអំពីការរំលោភសិទ្ធិមនុស្សដោយធ្វើការការពារជនរងគ្រោះ លើកកម្ពស់សិទ្ធិតាមរយៈការអប់រំ និងយុទ្ធនាការកែលម្អ និងជម្រុញឲ្យសិទ្ធិមនុស្សមានភាពជឿនលឿន។ ការិយាល័យ OHCHR មានទំនាក់ទំនងយ៉ាងស្អិតរមួត និងយ៉ាងប្រកៀកប្រកើយគ្នាជាមួយនឹងសង្គមស៊ីវិលដែលបានដាក់បញ្ចូលនៅគ្រប់ផ្នែកនៃការិយាល័យ OHCHR។

គ្រប់វិស័យការងារនៃការិយាល័យ OHCHR គ្រប់ដណ្តប់លើគ្រប់ទិដ្ឋភាពសិទ្ធិមនុស្ស។ រាល់សកម្មភាពនីមួយៗមានភាពជាប់ពាក់ព័ន្ធគ្នា និងបំពេញគ្នាទៅវិញទៅមក ហើយបង្កើតបានជាផ្នែកចំបងមួយនៃបេសកកម្មរបស់ខ្លួន។

**ការងារតាមវិស័យ**នៃការិយាល័យនេះកំណត់ និងស្វែងរកគម្លាតនៅក្នុងប្រព័ន្ធសិទ្ធិមនុស្សដែលមានស្រាប់ក្នុងន័យសំដៅការការពារ ព្រមទាំងស្រាវជ្រាវ និងដោះស្រាយបញ្ហាបច្ចុប្បន្នដូចជាការប្រែប្រួលអាកាសធាតុ និងអំពើហិង្សាយេនឌ័រពីខាងក្នុងក្របខណ្ឌសិទ្ធិមនុស្ស។

នៅក្នុង**ការងារកំណត់បទដ្ឋាន** ការិយាល័យ OHCHR ចូលរួមចំណែកលើការបង្កើតនិយាមអន្តរជាតិថ្មីៗដើម្បីឈានទៅសម្រេចបានការការការពារ និងការគោរពសិទ្ធិមនុស្ស។

**ការងារឃ្លាំមើល**មានគោលបំណងធានាថា បទដ្ឋានទាំងនេះត្រូវបានអនុវត្តជាក់ស្តែងដើម្បីចូលរួមចំណែកលើការសម្រេចបានសិទ្ធិមនុស្ស។

តាមរយៈ**ការអនុវត្ត**ការងារនៅតាមទីកន្លែងនានា ការិយាល័យ OHCHR ស្វែងរកមើលសញ្ញាព្រមានជាមុនណាមួយដែលបង្ហាញវបត្តិ និងស្ថានភាពធ្លាក់ចុះផ្នែកសិទ្ធិមនុស្ស និងផ្តល់ជំនួយបច្ចេកទេសដល់រដ្ឋាភិបាល និងត្រៀមខ្លួនជាស្រេចក្នុងការបញ្ជូនបុគ្គលិក និងប្រើប្រាស់ធនធាននៅពេលវិបត្តិកើតឡើង។

ការិយាល័យ OHCHR ក៏ធ្វើការងារបង្កើន**ការអប់រំផ្នែកសិទ្ធិមនុស្ស** និងលើកកម្ពស់ការយល់ដឹងផងដែរ។ ការិយាល័យនេះព្យាយាមពង្រឹងអំណាចប្រជាជនដើម្បីឲ្យពួកគេទទួលបានសិទ្ធិ ហើយតាមរយៈការប្រើប្រាស់គណកម្មាធិការ និងយន្តការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិប្រកបដោយ

ប្រសិទ្ធភាពនោះប្រែក្លាយពួកគេឲ្យក្លាយជាភ្នាក់ងារនៃការផ្លាស់ប្តូរ។ គោលបំណងនេះហើយដែលជម្រុញដល់ការបង្កើត*សៀវភៅណែនាំ*នេះឡើង។

សកម្មភាពនៃការិយាល័យ OHCHR បានទទួលថវិកាអចិន្ត្រៃយ៍របស់អង្គការសហប្រជាជាតិ និងវិភាគទានស្ម័គ្រចិត្តពីរដ្ឋសមាជិក អង្គការអន្តររដ្ឋាភិបាល ស្ថាប័នមូលនិធិ និងបុគ្គលនានា។

## ការងារតាមវិស័យ

*ការិយាល័យ OHCHR ស្រាវជ្រាវវិស័យថ្មីៗស្តីពីការការពារសិទ្ធិមនុស្ស និងកំណត់បទដ្ឋានលើវិស័យ និងបញ្ហាធំៗតាមរយៈការផ្តល់យោបល់ប្រឹក្សាលើគោលនយោបាយ និងច្បាប់ ធ្វើការសិក្សាស្រាវជ្រាវលើខ្លឹមសារសំខាន់ៗ សម្របសម្រួលកិច្ចពិភាក្សា និងកិច្ចពិគ្រោះយោបល់លើបញ្ហា និងនិន្នាការដែលទើបលេចឡើងថ្មីៗ ហើយនឹងស្វែងរកភាពជាដៃគូដោយផ្អែកមូលដ្ឋានលើបញ្ហាទាំងនោះជាមួយនឹងភាគីពាក់ព័ន្ធលើវិស័យសិទ្ធិមនុស្សដែលធ្វើការងារលើកកម្ពស់បទដ្ឋានអនុវត្តដ៏ប្រសើរបំផុត។*

*វិស័យការងាររបស់ការិយាល័យនេះរួមមានៈ*

- ការប្រឆាំងនឹងការរើសអើង
- កុមារ
- ការប្រែប្រួលអាកាសធាតុ និងបរិស្ថាន
- សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងសិទ្ធិវប្បធម៌រួមទាំងសិទ្ធិទទួលបានការថែទាំសុខភាព ជម្រកស្បៀងអាហារ និងទឹក
- HIV/AIDS
- ការរៀបចំផែនការ និងការវាយតម្លៃសិទ្ធិមនុស្សក្នុងប្រទេសនីមួយៗ
- សិទ្ធិមនុស្ស និងធុរកិច្ច
- សិទ្ធិមនុស្ស និងការប្រឆាំងភាវរកម្ម
- សិទ្ធិមនុស្ស និងពិការភាព
- ការអប់រំ និងការបណ្តុះបណ្តាលសិទ្ធិមនុស្ស
- ការបញ្ជៀបសិទ្ធិមនុស្ស
- ការឃ្លាំមើល និងការស៊ើបអង្កេតសិទ្ធិមនុស្ស
- សិទ្ធិមនុស្សនៅក្នុងប្រតិបត្តិការរក្សាសន្តិភាព
- ជនជាតិដើមភាគតិច និងជនជាតិភាគតិច

- គោលដៅអភិវឌ្ឍសហសតវត្សរ៍ និងសិទ្ធិទទួលបានការអភិវឌ្ឍ រួមទាំងការកាត់បន្ថយភាពក្រីក្រ
- ការប្រកាន់ពូជសាសន៍
- នីតិរដ្ឋ និងប្រជាធិបតេយ្យរួមទាំងការស្វែងរកយុត្តិធម៌រួមទាំងដំណើរការស្វែងរកយុត្តិធម៌ អភិបាលកិច្ចល្អ គណេយន្យភាព និទណ្ឌភាព និងគំនិតផ្តួចផ្តើមប្រឆាំងនឹងអំពើពុករលួយ
- គោលនយោបាយសន្តិសុខ
- ពាណិជ្ជកម្ម និងសាកលភាវូបនីយកម្ម
- អំពើជួញដូរ
- យុត្តិធម៌អន្តរកាល
- សិទ្ធិមនុស្ស និងយេនឌ័រពាក់ព័ន្ធនឹងស្ត្រីភេទ

កម្មវិធីនេះព្យាយាមដាក់បញ្ចូលជំនាញ និងគំនិតថ្មីៗទៅក្នុងប្រធានបទប្រទាក់ក្រឡាគ្នាដែលត្រូវបានជ្រើសរើសឡើង និងមានសារសំខាន់ក្រៃលែងចំពោះកម្មវិធីសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ដូចជា សមភាព និងភាពពុំមានការរើសអើង។ កម្មវិធីទាំងអស់ធ្វើឡើងសម្រាប់ក្រុម និងបញ្ហានានាដែលសមនឹងទទួលបានការយកចិត្តទុកដាក់ខ្លាំង ដូចជា ជនរងគ្រោះនៃការរើសអើងពូជសាសន៍ ប្រជាជនភាគតិច និងប្រជាជនដើមភាគតិច សិទ្ធិស្ត្រី និងយេនឌ័រ ពិការភាព ការជួញដូរ និងប្រជាជនដែលរងប៉ះពាល់ដោយសារ HIV/AIDS។

| បំពេញការងាររួមគ្នាលើបញ្ហានិទណ្ឌភាព និងនីតិរដ្ឋ | | |
|---|---|---|
| **គោលការណ៍ដែលត្រូវបានធ្វើបច្ចុប្បន្នភាពដើម្បីប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាព និងគោលការណ៍មូលដ្ឋាន និងគោលការណ៍ណែនាំស្តីពីសិទ្ធិទទួលបានដំណោះស្រាយ និងសំណង** ត្រូវបានពិនិត្យសម្រេចចុងក្រោយនៅក្នុងឆ្នាំ២០០៥។<br><br>នៅពេលសេចក្តីព្រាងដំបូងត្រូវបានរៀបចំរួចរាល់ ការិយាល័យ OHCHR បានរៀបចំកិច្ចពិគ្រោះយោបល់ដើម្បីបើកឲ្យមានកិច្ច | មហាសន្និបាតបានអនុម័តគោលការណ៍មូលដ្ឋាន និងគោលការណ៍ណែនាំស្តីពីសិទ្ធិទទួលបានដំណោះស្រាយ និងសំណងនៅក្នុងឆ្នាំ២០០៥។ អតីតគណកម្មការសិទ្ធិមនុស្សក៏បានកត់សម្គាល់លើគោលការណ៍ដែលត្រូវបានធ្វើបច្ចុប្បន្នភាពដើម្បីប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាពផងដែរ។<br><br>ការិយាល័យ OHCHR បានរៀបចំកិច្ចសិក្ខាសាលាជាបន្តបន្ទាប់ដើម្បីផ្សព្វផ្សាយព័ត៌មានស្តីពីគោលការណ៍ | ការបំពេញការងារជាមួយនឹងរដ្ឋាភិបាលដើម្បីធានានូវការអនុវត្ត និងការពង្រឹងការអនុវត្តបទដ្ឋានទាំងនេះគឺជាតួនាទីសំខាន់មួយដែលអង្គការ NGOs គួរបន្តធ្វើឡើងដើម្បីធ្វើយ៉ាងណាសម្រេចឲ្យបាននូវសិទ្ធិទាំងឡាយដូចមានចែងនៅក្នុងឯកសារទាំងនេះ។ សម្រាប់ព័ត៌មានបន្ថែម សូមមើល៖<br>• គោលការណ៍ដែលត្រូវបានធ្វើបច្ចុប្បន្នភាពស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិមនុស្សតាមរយៈសកម្មភាព |

| | | |
|---|---|---|
| សន្ទនា និងការផ្តល់យោបល់ត្រឡប់មកវិញ។ អង្គការ NGOs អន្តរជាតិមួយចំនួនបានចូលរួមនៅក្នុងកិច្ចពិគ្រោះយោបល់ទាំងនេះ រួមមាន **គណៈកម្មការអ្នកច្បាប់អន្តរជាតិ អង្គការលើកលែងទោស អង្គការឃ្លាំមើលសិទ្ធិមនុស្ស និងមជ្ឈមណ្ឌលអន្តរជាតិដើម្បីយុត្តិធម៌អន្តរកាល**។ អង្គការ NGOs បានបង្ហាញទស្សនវិស័យនៃភ្នាក់ងាររដ្ឋជាតិ និងអន្តរជាតិដោយអនុញ្ញាតឲ្យដាក់បញ្ចូលតម្រូវការ និងបទពិសោធន៍ពីតាមទីកន្លែងនានាមកក្នុងសេចក្តីព្រាងនេះ។ | ទាំងពីរនេះព្រមទាំងដើម្បីពិភាក្សាយុទ្ធសាស្ត្រសម្រាប់ការអនុវត្តនៅថ្នាក់ជាតិ។ ក្រៅពីបុគ្គលិកមកពីទីកន្លែងនានានៃការិយាល័យ OHCHR និងបេសកកម្មសន្តិភាពនៃអង្គការសហប្រជាជាតិ, អង្គការ NGOs ជាច្រើនមកពីបណ្តាប្រទេសក្រោយជម្លោះបានចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចសិក្ខាសាលាទាំងនេះ។ អង្គការ NGOs ក្នុងស្រុកទាំងនេះបានចូលរួមចំណែកនៅក្នុងការផ្សព្វផ្សាយគោលការណ៍ និងធានាធ្វើយ៉ាងណាឲ្យគោលការណ៍ទាំងនេះអាចដំណើរការទៅបាន។ | ប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាព (E/CN.4/2005/102/Add.1) និង<br>• គោលការណ៍មូលដ្ឋាន និងគោលការណ៍ណែនាំស្តីពីសិទ្ធិទទួលបានដំណោះស្រាយ និងសំណងសម្រាប់ជនរងគ្រោះនៃការរំលោភធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ (សេចក្តីសម្រេចចិត្តនៃមហាសន្និបាតលេខ ៦០/១៤៧)។ |

## ការកំណត់បទដ្ឋាន និងការឃ្លាំមើល

*ការិយាល័យ OHCHR ព្យាយាមផ្តល់ការស្រាវជ្រាវ ជំនាញ យោបល់ និងសេវារដ្ឋបាលដែលមានគុណភាពខ្ពស់បំផុតជូនគណៈកម្មាធិការ និងយន្តការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិនៅពេលគណៈកម្មាធិការ និងយន្តការទាំងនេះបំពេញការងារកំណត់បទដ្ឋាន និងឃ្លាំមើលដើម្បីចូលរួមចំណែកនៅក្នុងការបង្កើតច្បាប់ និងយុត្តិសាស្ត្រសិទ្ធិមនុស្សអន្តរជាតិ និងដើម្បីធានាឲ្យមានការអនុវត្តបទដ្ឋានសិទ្ធិមនុស្សដែលមានការព្រមព្រៀងគ្នា។ គណៈកម្មាធិការ និងយន្តការទាំងនេះរួមមាន៖*

- *ក្រុមប្រឹក្សាសិទ្ធិមនុស្ស* និងយន្តការរបស់ក្រុមប្រឹក្សា ឧទាហរណ៍ យន្តការនីតិវិធីពិសេស និងយន្តការពិនិត្យរបាយការណ៍ជាសាកលតាមកាលកំណត់ យន្តការនីតិវិធីបណ្តឹង គណៈកម្មាធិការប្រឹក្សាយោបល់ វេទិកាសង្គម វេទិកាស្តីពីបញ្ហាជនជាតិភាគតិច និងយន្តការអ្នកជំនាញទទួលបន្ទុកសិទ្ធិជនជាតិដើមភាគតិច និង
- **គណៈកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស**

ការិយាល័យ OHCHR ប្តេជ្ញាពង្រឹងសមត្ថភាពរបស់សង្គមស៊ីវិលដើម្បីប្រើប្រាស់កម្មវិធីសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិឲ្យមានប្រសិទ្ធភាព។ ជំពូកនានាដូចខាងក្រោមបង្ហាញរបៀបដែលសង្គមស៊ីវិលអាចចូលរួមបំពេញការងារ និងចូលរួមចំណែកជាមួយនឹងគណៈកម្មាធិការ និងយន្តការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិតាមរយៈការិយាល័យ OHCHR៖

- ជំពូក IV គណៈកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស
- ជំពូក V ក្រុមប្រឹក្សាសិទ្ធិមនុស្ស និងយន្តការរបស់ក្រុមប្រឹក្សា រួមមាន គណៈកម្មាធិការប្រឹក្សាយោបល់ វេទិកាសង្គម វេទិកាស្តីពីបញ្ហាជនជាតិភាគតិច យន្តការអ្នកជំនាញទទួលបន្ទុកសិទ្ធិជនជាតិដើមភាគតិច ក្រុមការងារទូទៅ ទទួលបន្ទុកសិទ្ធិទទួលបានការអភិវឌ្ឍ និងយន្តការជាច្រើនទៀតពាក់ព័ន្ធនឹងសេចក្តីប្រកាស និងផែនការសកម្មភាពទីក្រុង Durban។
- ជំពូក VI យន្តការនីតិវិធីពិសេស
- ជំពូក VII យន្តការពិនិត្យរបាយការណ៍ជាសាកលតាមកាលវេលា និង
- ជំពូក VIII នីតិវិធីដាក់បណ្តឹងការចោទប្រកាន់ការរំលោភសិទ្ធិមនុស្ស

| |
|---|
| i. សម្រាប់ព័ត៌មានបច្ចុប្បន្នស្តីពី**ការងារកំណត់បទដ្ឋាន និងឃ្លាំមើល** សូមចូលទៅកាន់**គេហទំព័រនៃការិយាល័យ** OHCHR។ |

## ការអនុវត្តសិទ្ធិមនុស្ស

*បទដ្ឋានសិទ្ធិមនុស្សមានតម្លៃតិចតួចប្រសិនបើយើងពុំអនុវត្តវា។ រដ្ឋដែលទើបរើខ្លួនពីជម្លោះ ឬខ្វះធនធាន ឬ អ្នកជំនាញ ត្រូវការការជួយជ្រោមជ្រែងនានាដើម្បីបំពេញកាតព្វកិច្ចសិទ្ធិមនុស្សរបស់ពួកគេ។ ដូច្នេះ ការិយាល័យ OHCHR ផ្តល់ធនធានសន្ធឹកសន្ធាប់លើការគាំទ្រកិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិដើម្បីការពារសិទ្ធិមនុស្ស។ ការិយាល័យ OHCHR សហការជាមួយនឹងបណ្តាប្រទេសនានាដើម្បីព្យាយាមបំពេញចន្លោះប្រហោងជាច្រើននៅក្នុងការអនុវត្តរួមមានគម្លាតចំណេះដឹង សមត្ថភាព ការប្តេជ្ញា និងសន្តិសុខជាដើម។*

*តាមរយៈការអនុវត្តការងាររបស់ខ្លួននៅតាមទីខ្លែងនានា ការិយាល័យ OHCHR មានគោលបំណងចង់ឲ្យ៖*

- អាជ្ញាធរថ្នាក់ជាតិបានដឹងអំពីបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ និងវិធីក្នុងការធ្វើឲ្យវាទៅជាច្បាប់ បទដ្ឋានគតិយុត្តិ និងគោលនយោបាយផ្សេងៗ;
- មន្ត្រីរដ្ឋាភិបាល និងសង្គមស៊ីវិលមានសមត្ថភាពកាន់តែច្រើនជាងមុនដើម្បីដោះស្រាយកង្វល់ស្តីពីសិទ្ធិមនុស្ស;
- អាជ្ញារដ្ឋាភិបាលបានដឹងអំពីកាតព្វកិច្ចសិទ្ធិមនុស្សរបស់ពួកគេ និងអនុវត្តដំណោះស្រាយដ៏មាន ប្រសិទ្ធភាពដើម្បីជំនះឧបសគ្គនានាឈានទៅសម្រេចបាននូវសិទ្ធិមនុស្ស;
- អ្នកមានសិទ្ធិទទួលបានការការពារប្រសើរជាងមុនពីគោលនយោបាយនានាដែលគម្រាមសន្តិភាពផ្ទាល់ខ្លួនរបស់ពួកគេ និង
- ការិយាល័យ OHCHR ស្ថិតក្នុងលទ្ធភាពប្រសើរជាងមុននៅក្នុងការឆ្លើយតបទៅនឹងតម្រូវការសិទ្ធិមនុស្សជាក់ស្តែង។

វត្តមាននៃការិយាល័ OHCHR នៅតាមទីន្លែងនានាបង្កើតបានជាយន្តការឆ្លើយតបសមស្រប និងមានប្រសិទ្ធភាពចំពោះបញ្ហាប្រឈមផ្នែកសិទ្ធិមនុស្សតាមរយៈកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយ នឹងរដ្ឋាភិបាល ប្រព័ន្ធអង្គការសហប្រជាជាតិ និងអង្គការ NGOs និងសមាជិកសង្គមស៊ីវិលផ្សេងទៀត។ ឧទាហរណ៍ ការិយាល័យ OHCHR ជួយជ្រោមជ្រែងដល់កិច្ចខិតខំប្រឹងប្រែងក្នុងការច្របាច់បញ្ចូលបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិទៅក្នុងច្បាប់ជាតិ និងផ្តល់យោបល់ប្រឹក្សាស្តីពីការបង្កើត និងដំណើរការស្ថាប័ន NHRIs ឯករាជ្យ។ ការិយាល័យនេះក៏ផ្តល់ការបណ្តុះបណ្តាល និងធ្វើការងាររួមជាមួយប្រព័ន្ធតុលាការ កងរាជអាវុធហត្ថ និងសភាលើបទដ្ឋានអន្តរជាតិទាក់ទងនឹងការងាររបស់ពួកគេ ផ្តល់យោបល់ប្រឹក្សាលើគណកម្មាធិការសន្ធិសញ្ញា និងប្រព័ន្ធរបាយការណ៍នៃយន្តការពិនិត្យរបាយការណ៍ជាសាកលតាមកាលកំណត់ និងអភិវឌ្ឍកម្មវិធីអប់រំផ្នែកសិទ្ធិមនុស្ស។

សង្គមស៊ីវិលគឺជាដៃគូសំខាន់បំផុតនៅក្នុងគ្រប់សកម្មភាពរបស់ការិយាល័យ OHCHR នៅតាមទីកន្លែងនានា។ ខាងក្រោមនេះគឺជាឧទាហរណ៍ខ្លះៗនៃការចូលរួម និងកិច្ចសហការរវាងសង្គមស៊ីវិលជាមួយនឹងការិយាល័យ OHCHR នៅតាមទីកន្លែងនានាៈ

- ដាស់តឿនការិយាល័យ OHCHR អំពីការធ្លាក់ចុះនៃស្ថានភាពសិទ្ធិមនុស្ស និងនិន្នាការដែលទើបលេចឡើងថ្មីៗ;
- ផ្តល់ព័ត៌មានជូនការិយាល័យ OHCHR អំពីស្ថានភាពសិទ្ធិមនុស្ស ការអភិវឌ្ឍ និងការចោទប្រកាន់អំពីការបំពានទាំងនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ;
- បំពេញការងារជាដៃគូជាមួយការិយាល័យ OHCHR លើកម្មវិធីជួបជុំ និងសិក្ខាសាលា កម្មវិធីបណ្តុះបណ្តាលផ្នែកសិទ្ធិមនុស្ស និងគម្រោងនៅថ្នាក់ជាតិ និងតំបន់ដើម្បីលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិមនុស្ស និង
- បំពេញការងារជាមួយនឹងការិយាល័យ OHCHR ដើម្បីជម្រុញឲ្យមានការផ្តល់សច្ចាប័នលើសន្ធិសញ្ញាសិទ្ធិមនុស្ស និងការអនុវត្តសន្ធិសញ្ញាទាំងនេះ។

វត្តមាននៃការិយាល័យ OHCHR នៅតាមទីកន្លែងនានារួមមានការិយាល័យប្រចាំប្រទេស ការិយាល័យប្រចាំតំបន់ សមាសភាពសិទ្ធិមនុស្សនៃបេសកកម្មភាពរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ទីប្រឹក្សាសិទ្ធិមនុស្សនៅតាមក្រុមប្រចាំប្រទេសនៃអង្គការសហប្រជាតិ និងឆ្លើយតបយ៉ាងលឿនទៅនឹងវបត្តិសិទ្ធិមនុស្សនានាដែលទើបលេចឡើងថ្មីៗ។

## ១. ការិយាល័យប្រចាំប្រទេស

ការិយាល័យ OHCHR បានបង្កើតការិយាល័យប្រចាំប្រទេសកាន់តែច្រើនឡើងដើម្បីធ្វើសកម្មភាពឃ្លាំមើលសិទ្ធិមនុស្ស ធ្វើរបាយការណ៍ជាសាធារណៈ ផ្តល់ជំនួយបច្ចេកទេស និងជួយជ្រោមជ្រែងរដ្ឋាភិបាលដើម្បីបង្កើតគោលនយោបាយ និងគោលដៅសិទ្ធិមនុស្សចេរភាព និងរយៈពេលវែង។

| បំពេញការងារជាមួយនឹងការិយាល័យប្រចាំប្រទេសនៃការិយាល័យ OHCHR នៅប្រទេសអ៊ុយហ្គានដាដើម្បីការពារ និងលើកកម្ពស់សិទ្ធិជនពិការឲ្យកាន់តែប្រសើរឡើង | | |
|---|---|---|
| ការិយាល័យប្រចាំប្រទេសនៃការិយាល័យ OHCHR ប្រចាំប្រទេសអ៊ុយហ្គានដាបំពេញការងាររួមជាមួយនឹងសមាគមជនពិការដើម្បីលើកកម្ពស់ការយល់ដឹងអំពីពិការភាពដាក់បញ្ចូលជាបញ្ហាសិទ្ធិមនុស្ស បង្កើនការយល់ដឹងអំពីបទដ្ឋាននានាពាក់ព័ន្ធនឹងសិទ្ធិមនុស្ស និងជម្រុញឲ្យគោរពបទដ្ឋានទាំងនេះពេញលេញនៅក្នុងប្រព័ន្ធគតិយុត្ត គោលនយោបាយ និងផែនការក្នុងស្រុក។ ការិយាល័យប្រចាំប្រទេសអ៊ុយហ្គានដាបានចូលរួមការងារជាមួយនឹងអង្គការ NGOs ទៅតាមវិធីដូចខាងក្រោម៖<br><br>• រៀបចំកិច្ចពិគ្រោះយោបល់ប្រឹក្សាផ្នែកបច្ចេកទេសស្តីពីអនុលោមភាពនៃប្រព័ន្ធគតិយុត្ត និងគោលនយោបាយក្នុងស្រុកស្តីពីពិការភាពជាមួយនឹងបទដ្ឋានសិទ្ធិមនុស្ស; | • ធ្វើសកម្មភាពឃ្លាំមើល និងផ្តោតការពិភាក្សាជាក្រុមលើស្ថានភាពជនពិការ, ជម្រុញយ៉ាងសកម្មនៅតាមថ្នាក់ស្រុកឲ្យអង្គការ NGOs ដែលបំពេញការងារលើបញ្ហាពិការភាពចូលរួមនៅក្នុងយន្តការសម្រួលផ្នែកសិទ្ធិមនុស្ស;<br><br>• គាំទ្រសហជីពជាតិនៃជនពិការនៅក្នុងការប្រមូលហត្ថលេខាធ្វើញត្តិជម្រុញឲ្យរដ្ឋាភិបាលផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិជនពិការ។ សហជីពនេះប្រមូលបានហត្ថលេខាជាង ១០០០ ហត្ថលេខានៅទិវាសិទ្ធិមនុស្សអន្តរជាតិក្នុងឆ្នាំ២០០៧;<br><br>• ឧបត្ថម្ភការសាងសង់ច្រកផ្លូវជនពិការទៅកាន់អាគាររដ្ឋបាលធំក្នុងស្រុក Soroti ដើម្បីផ្តល់លទ្ធភាពឲ្យជនពិការចេញចូលអាគារសាធារណៈបាន។ បន្តការតស៊ូមតិដោយអង្គការ NGOs ឈានទៅដល់ការសាងសង់ច្រកជនពិការបន្ថែមទៀត | នៅតាមទីប្រជុំជន និង<br>• ផ្តល់ការបណ្តុះបណ្តាលដល់ជនពិការលើបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ និងបទដ្ឋានគតិយុត្ត និងគោលនយោបាយពាក់ព័ន្ធនៅក្នុងស្រុក បង្កើតសម្ភារៈឯកសារពាក់ព័ន្ធអាចរកមើលបាននៅក្នុងស្រុក Braille។ |

## ២. ការិយាល័យប្រចាំតំបន់

ការិយាល័យ OHCHR ព្យាយាមស្វែងរកកង្វល់ពាក់ព័ន្ធនឹងសិទ្ធិមនុស្សដែលមានសារសំខាន់ចំពោះបណ្តាប្រទេសនៅក្នុងតំបន់ដោយអាចផ្តល់ការជួយជ្រោមជ្រែងជូនទាំងតំបន់ និងប្រទេសតាមរយៈការលើកកម្ពស់ការចែករំលែក និងការផ្សព្វផ្សាយបទពិសោធន៍ និងបទដ្ឋានអនុវត្តល្អៗ។ ការិយាល័យប្រចាំតំបន់នៃការិយាល័យ OHCHR ក៏ជាស្ថាប័នជំនាញទៅតាមវិស័យមួយផងដែរ ហើយនឹងធ្វើការងារជិតស្និទ្ធជាមួយនឹងអង្គការស្ថាប័នថ្នាក់តំបន់ និងរដ្ឋាភិបាល ក្រុមប្រចាំប្រទេសនៃអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ និងតំបន់ ស្ថាប័ន NHRIs និងសង្គមស៊ីវិល។

## ៣. សមាសភាពសិទ្ធិមនុស្សនៃបេសកកម្មថែរក្សាសន្តិភាពនៃអង្គការសហប្រជាតិ

ការិយាល័យ OHCHR ចូលរួមនៅក្នុងការថែរក្សា និងការកសាងសន្តិភាពនៃអង្គការសហប្រជាជាតិ និងដើរតួនាទីដ៏សំខាន់នៅក្នុងសមាសភាពសិទ្ធិមនុស្សនៃដំណើរការប្រតិបត្តិការដ៏ស្មុគស្មាញនៅតាមទីកន្លែងនានាដែលដំណើរការដោយនាយកដ្ឋានអង្គការសហប្រជាជាតិទទួលបន្ទុកលើប្រតិបត្តិការថែរក្សាសន្តិភាព និងកិច្ចការនយោបាយ។ ការិយាល័យ OHCHR ក៏ចូលរួមចំណែកនៅក្នុងការងាររបស់ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាតិទទួលបន្ទុកសន្តិភាព និងសន្តិសុខអន្តរជាតិ។ តួនាទីទាំងនេះបង្ហាញ ឲ្យឃើញថាសិទ្ធិមនុស្សក្តោបក្តាប់លើគ្រប់ទិដ្ឋភាពនៃការងារអង្គការសហប្រជាតិជាតិ។

ការិយាល័យ OHCHR បានកំណត់អាទិភាពចំនួនបួនដែលការិយាល័យនេះមានបំណងច្របាច់បញ្ចូលនៅក្នុងបេសកកម្មថែរក្សាសន្តិភាព៖

- ធានាយុត្តិធម៌ និងគណនេយ្យភាពនៅក្នុងដំណើរការថែរក្សាសន្តិភាព;
- ទប់ស្កាត់ និងដោះស្រាយការរំលោភសិទ្ធិមនុស្ស;
- កសាងសមត្ថភាព និងពង្រឹងស្ថាប័នជាតិ និង
- បញ្ជ្រៀបសិទ្ធិមនុស្សនៅក្នុងគ្រប់កម្មវិធីនៃអង្គការសហប្រជាជាតិ

| ការបំពេញការងារជាមួយនឹងបេសកកម្មនៃអង្គការសហប្រជាជាតិនៅប្រទេសស៊ុយដង់ទទួលបន្ទុកសិទ្ធិស្ត្រី | | |
|---|---|---|
| ចាប់តាំងពីខែមីនា ឆ្នាំ២០០៨ រហូតមក ការិយាល័យសិទ្ធិមនុស្សនៃបេសកកម្មអង្គការសហប្រជាជាតិនៅក្នុងប្រទេសស៊ុយដង់ (ការិយាល័យ UNMIS) បានផលិត | ប្រតិបត្តិការជាមួយនឹងក្រុមស្ត្រីតស៊ូមតិនៅ Malakal និងស្ថានីយ៍វិទ្យុ Malakal (Radio Malakal) ដើម្បីលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិស្ត្រីជាពិសេសសិទ្ធិរបស់ពួកគេក្នុង | យែនឌ័រ។ សមាជិកនៃរដ្ឋសភាក្នុងរដ្ឋ Upper Nile និងសកម្មជនសង្គមស៊ីវិលបានចូលរួមក្នុងកម្មវិធីនេះ។ គំនិតផ្តួចផ្តើមនេះបានធ្វើឡើងរួមជាមួយនឹងកិច្ចសិក្ខាសាលាសម្រាប់ |

| | | |
|---|---|---|
| កម្មវិធីវិទ្យុមួយក្រោមកិច្ចសហ | ការរស់នៅដោយគ្មានអំពើហិង្សា | សហគមន៍មូលដ្ឋានផងដែរ។ |

## ៤. ទីប្រឹក្សាសិទ្ធិមនុស្សនៅតាមក្រុមប្រទេសអង្គការសហប្រជាជាតិ

ទីប្រឹក្សាសិទ្ធិមនុស្សគឺជាអ្នកជំនាញដែលការិយាល័យ OHCHR បានផ្តល់ជូនដើម្បីគាំទ្រក្រុមប្រចាំប្រទេសនៃអង្គការសហប្រជាជាតិទៅតាមសំណើសុំរបស់មន្ត្រីសម្របសម្រួលប្រចាំប្រទេស។ ទីប្រឹក្សាទាំងនេះផ្តល់យោបល់ប្រឹក្សាលើយុទ្ធសាស្ត្រក្នុងការកសាង និងពង្រឹងសមត្ថភាព និងស្ថាប័នប្រចាំប្រទេសដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស។ ទីប្រឹក្សាសិទ្ធិមនុស្សក៏ចូលរួមចំណែកជាមួយនឹងតួអង្គថ្នាក់ជាតិ (រដ្ឋាភិបាល និងសង្គមស៊ីវិល) លើរបៀបលើកកម្ពស់ និងអនុវត្តបទដ្ឋានសិទ្ធិមនុស្សឲ្យមានប្រសិទ្ធភាព។

## ៥. អង្គភាពឆ្លើយតបភ្លាមៗទៅនឹងវិបត្តិសិទ្ធិមនុស្សដែលទើបលេចឡើងថ្មីៗ

ក្រៅពីការចូលរួមជាមួយបណ្តាប្រទេសតាមរយៈការិយាល័យនៅតាមទីកន្លែងនានា អង្គភាពឆ្លើយតបភ្លាមៗនៃការិយាល័យ OHCHR បានបញ្ជូនបុគ្គលិកដែលទទួលបានការបណ្តុះបណ្តាលទៅជួយជ្រោមជ្រែងការទប់ស្កាត់ ឬ ការឆ្លើយតបទៅនឹងស្ថានភាពចុះដុនដាបផ្នែកសិទ្ធិមនុស្សនៅទូទាំងសាកលលោក។ ការិយាល័យ OHCHR អាចបំពេញ ឬ គាំទ្របេសកកម្មស្វែងរកការពិត និងគណកម្មការស្រាវជ្រាវដើម្បីស៊ើបអង្កេតការចោទប្រកាន់អំពីការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ។

អង្គភាពនេះដើរតួនាទីជាអង្គភាពសម្របសម្រួលសម្រាប់ការចូលរួមរបស់ការិយាល័យ OHCHR ជាមួយនឹងសមាសភាពសិទ្ធិមនុស្សនៃបេសកកម្មថែរក្សាសន្តិភាពដែលការិយាល័យ OHCHR បានគាំទ្រតាមរយៈការផ្តល់ការជួយជ្រោមជ្រែងលើការជ្រើសរើសបុគ្គលិក ការណែនាំ និងការបណ្តុះបណ្តាល ព្រមទាំងបានផ្តល់យោបល់ប្រឹក្សាលើកម្មវិធី និងគោលនយោបាយសំខាន់ៗផងដែរ។

### កម្មវិធីអាហារូបករណ៍ និងបណ្តុះបណ្តាលនៃការិយាល័យ OHCHR

ការិយាល័យ OHCHR បានបង្កើតកម្មវិធីអាហារូបករណ៍ និងបណ្តុះបណ្តាលដើម្បីជួយបង្កើនតួនាទី និងការចូលរួមរបស់សង្គមស៊ីវិលនៅក្នុងយន្តការសិទ្ធិមនុស្ស។ កម្មវិធីនេះរួមមានដូចជា៖

- **កម្មវិធីអាហារូបករណ៍សម្រាប់ជនជាតិដើមភាគតិច**
- **កម្មវិធីអាហារូបករណ៍សម្រាប់ជនជាតិភាគតិច**
- **កម្មវិធីអាហារូបករណ៍ LDC ផ្នែកសិទ្ធិមនុស្ស និង**
- **កម្មវិធីអាហារូបករណ៍សម្រាប់បុគ្គលិកនៃស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស**

> i. សម្រាប់ព័ត៌មានបន្ថែមស្តីកម្មវិធីអាហារូបករណ៍ និងបណ្តុះបណ្តាល សូមមើលជំពូក II នៅក្នុង*សៀវភៅណែនាំ*នេះ។

### ឯកសារបោះពុម្ពផ្សាយ និងឯកសារធនធាននៃការិយាល័យ OHCHR

ការិយាល័យ OHCHR ផលិតឯកសារបោះពុម្ពផ្សាយជាច្រើនពាក់ព័ន្ធនឹងសិទ្ធិមនុស្សដែលផ្តល់ព័ត៌មានគួរឲ្យចាប់អារម្មណ៍ជូនរដ្ឋាភិបាល ស្ថាប័ន NHRIs សង្គមស៊ីវិល សាធារណជន និងសារព័ត៌មាន។ ឯកសារបោះពុម្ពផ្សាយ និងធនធានជាច្រើនអាចរកមើលបានដោយទាញយកចេញពីគេហទំព័រនៃការិយាល័យ OHCHR ឬ អាចស្នើសុំពីបញ្ជរព័ត៌មាន **និងឯកសារបោះពុម្ពផ្សាយនៃ** ការិយាល័យ OHCHR បាន។

| |
|---|
| i. សម្រាប់ព័ត៌មានបច្ចុប្បន្នស្តីពី ***ឯកសារបោះពុម្ពផ្សាយ និងឯកសារធនធាននៃការិយាល័យ OHCHR*** *សូមមើលជំពូក III នៅក្នុងសៀវភៅណែនាំនេះ* និងទាក់ទង pubicaitons@ohchr.org ឬ library@ohchr.org។ |

## មូលនិធិ និងជំនួយឥតសំណង

មូលនិធិ និងជំនួយឥតសំណងនៃអង្គការសហប្រជាជាតិដែលមានមួយផ្នែកចាត់ចែងដោយការិយាល័យ OHCHR ផ្តល់ជាប្រយោជន៍ដោយផ្ទាល់ដល់អង្គការ NGOs អង្គការមូលដ្ឋាន សមាគមវិជ្ជាជីវៈ និងតួអង្គសង្គមស៊ីវិលផ្សេងទៀត។

មូលនិធិ និងជំនួយឥតសំណងដែលចាត់ចែងដោយការិយាល័យ OHCHR រួមមាន៖

- **មូលនិធីស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិសម្រាប់ជនរងគ្រោះនៃទារុណកម្ម**
- **មូលនិធីស្ម័គ្រចិត្តសម្រាប់ជនជាតិដើមភាគតិច**
- **មូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិស្តីពីទម្រង់បច្ចុប្បន្ននៃទាសភាព** និង
- គម្រោម "រួមគ្នាជួយសហគមន៍"

| |
|---|
| i. *សម្រាប់ព័ត៌មានបន្ថែមស្តីពី***មូលនិធិ និងជំនួយឥតសំណង** *សូមមើលជំពូក* IX *នៅក្នុងសៀវភៅណែនាំនេះ*។ |

## ឃ. រចនាសម្ព័ន្ធនៃការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិ មនុស្ស

ការិយាល័យ OHCHR ដឹកនាំដោយឧត្តមស្នងការមួយរូប និងឧត្តមស្នងការរងមួយរូប។ ឧត្តមស្នងការ និងឧត្តមស្នងការរងមានការគាំទ្រការងារពី**ការិយាល័យការងារប្រតិបត្តិ**ដែលជាផ្នែកមួយនៃ**សាខាគ្រប់គ្រង និងដឹកនាំការងារប្រតិបត្តិ**។

**សាខាគ្រប់គ្រង និងដឹកនាំការងារប្រតិបត្តិក៏រួមមាន៖**

- **ការិយាល័យប្រចាំបុរីញូវយ៉ក**ដែលបំពេញការងារធានានូវការច្របាច់បញ្ចូលសិទ្ធិមនុស្សឲ្យបានពេញលេញទៅក្នុងរបៀបវារៈនៃអង្គការសហប្រជាជាតិសម្រាប់ការអភិវឌ្ឍ និងសន្តិសុខ ហើយនឹងផ្តល់ការគាំទ្រសំខាន់លើបញ្ហាសិទ្ធិមនុស្សជូនដល់មហាសន្និបាត **ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម ក្រុមប្រឹក្សាសន្តិសុខ** និងអង្គការស្ថាប័នអន្តររដ្ឋាភិបាលផ្សេងទៀត;

- **ផ្នែកគោលនយោបាយ រៀបចំផែនការ ឃ្លាំមើល និងវាយតម្លៃ**ដែលបំពេញការងារជាមួយនឹងបុគ្គលិកនៃការិយាល័យ OHCHR ធ្វើយ៉ាងណាឲ្យទស្សនៈវិស័យយុទ្ធសាស្ត្រនៃការិយាល័យនេះប្រែក្លាយជាការងារអាទិភាពជាក់ស្តែង និងផែនការប្រតិបត្តិ ហើយនឹងធានានូវការវាយតម្លៃ និងឃ្លាំមើលលើផលប៉ះពាល់ប្រកបដោយប្រសិទ្ធភាព;
- **ផ្នែកគមនាគមន៍**ដែលបង្កើត និងអនុវត្តយុទ្ធសាស្ត្រដើម្បីលើកបង្កើនចំណេះដឹងទូទៅផ្នែកសិទ្ធិមនុស្ស និងជូនដំណឹងដល់សហគមន៍អន្តរជាតិអំពីការវិវឌ្ឍផ្នែកសិទ្ធិមនុស្ស និងការងាររបស់ការិយាល័យ OHCHR;
- **ផ្នែកម្ចាស់ជំនួយ និងទំនាក់ទំនងខាងក្រៅ**ដែលបំពេញការងារធ្វើយ៉ាងណាជូនដំណឹងពេញលេញដល់រដ្ឋសមាជិកអំពីផែនការ ការងារអាទិភាព និងតម្រូវការក្នុងការផ្តល់មូលនិធិ និងកៀរគងធនធាននានាដើម្បីគាំទ្រការអនុវត្តកម្មវិធីនៃការិយាល័យ OHCHR
- **ផ្នែកសន្តិសុខ និងសុវត្ថិភាពនៅតាមទីកន្លែង**សហការជាមួយនឹងនាយកដ្ឋានសុវត្ថិភាព និងសន្តិសុខនៃអង្គការសហប្រជាជាតិក្នុងការទទួលខុសត្រូវផ្នែកសន្តិសុខសម្រាប់បុគ្គលិក និងទីតាំងនៃការិយាល័យ OHCHR ទាំងអស់

**អង្គភាពសង្គមស៊ីវិល**ដែលទើបបង្កើតថ្មីគឺជាផ្នែកមួយនៃសាខាគ្រប់គ្រង និងដឹកនាំការងារប្រតិបត្តិ។ អង្គភាពនេះគឺជាចក្រចេញចូលចំបងសម្រាប់តួអង្គសង្គមស៊ីវិលដែលមានបំណងទាក់ទងការិយាល័យ OHCHR។ អង្គភាពសង្គមស៊ីវិលផ្តល់ព័ត៌មាន និងយោបល់ប្រឹក្សាលើគ្រប់វិស័យ ប្រឹក្សាយោបល់លើគោលនយោបាយ និងយុទ្ធសាស្ត្រដើម្បីធានាកិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍឧបករណ៍នានាដើម្បីជួយជ្រោមជ្រែងដល់សង្គមស៊ីវិលក្នុងការចូលរួមជាមួយនឹងគណកម្មាធិការ និងយន្តការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ។ *សៀវភៅណែនាំនេះ*គឺជាគម្រូចំបងនៃការងារនេះ។

**ផ្នែកសេវាគ្រប់គ្រង និងគាំទ្រកម្មវិធី**នៃការិយាល័យ OHCHR គាំទ្រការគ្រប់គ្រងថវិកា និងហិរញ្ញវត្ថុ ការជ្រើសរើស និងធនធានមនុស្ស លទ្ធកម្ម ការគ្រប់គ្រងទ្រព្យសម្បត្តិ និងការគាំទ្រផ្នែកសម្ភារៈភ័ស្តុភារទូទៅសម្រាប់សកម្មភាពនៅតាមទីកន្លែងនានា បច្ចេកវិទ្យាព័ត៌មាន ព្រមទាំងការអភិវឌ្ឍ និងការបណ្តុះបណ្តាលបុគ្គលិក។

ក្រៅពីសាខាគ្រប់គ្រង និងដឹកនាំការងារប្រតិបត្តិ និងសាខាសេវាគ្រប់គ្រង និងគាំទ្រកម្មវិធីការិយាល័យ OHCHR មានផ្នែកសំខាន់ៗបួនទៀតៈ

- **ផ្នែកសន្ធិសញ្ញា និងក្រុមប្រឹក្សាសិទ្ធិមនុស្ស**ធានាឲ្យដំណើរការក្រុមប្រឹក្សាសិទ្ធិមនុស្ស និងយន្តការរបស់ក្រុមប្រឹក្សា ព្រមទាំងគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សដំណើរការទៅដោយរលូន។ ផ្នែកនេះក៏គាំទ្រដល់សកម្មភាពនានាដែលត្រូវបានអនុវត្តតាមរយៈមូលនិធិស្ម័គ្រចិត្ត

សម្រាប់ជនរងគ្រោះនៃទារុណកម្ម និងសម្របសម្រួលការចងក្រងឯកសារផ្លូវការទាំងអស់ដែលត្រូវបានរៀបចំឡើងក្នុងគោលបំណងប្រើប្រាស់ដោយអង្គការស្ថាប័នអន្តររដ្ឋាភិបាល។

- **ផ្នែកនីតិវិធីពិសេស៖** គាំទ្រការងារនៃយន្តការនីតិវិធីពិសេសតាមរយៈការផ្តល់ការជួយជ្រោមជ្រែងផ្នែកភ័ស្តុភារ រដ្ឋបាល ការវិភាគ និងស្រាវជ្រាវ ជំនាញតាមវិស័យ ផ្នែកច្បាប់ និងការស្វែងរកការពិត។ ផ្នែកនេះក៏ជួយសម្រួលដល់កិច្ចសហប្រតិបត្តិការ និងកិច្ចប្រជុំរវាងមន្ត្រីកាន់កាប់អាណត្តិការងារ និងភាគីពាក់ព័ន្ធ រួមទាំង សង្គមស៊ីវិលផងដែរ។
- **ផ្នែកសហប្រតិបត្តិការបច្ចេកទេស និងប្រតិបត្តិការនៅតាមទីកន្លែង៖** សម្របសម្រួលការអភិវឌ្ឍ និងការអនុវត្តយុទ្ធសាស្ត្រចូលរួមរបស់ការិយាល័យប្រចាំប្រទេសនៃការិយាល័យ OHCHR ចាត់ចែងកម្មវិធីសហប្រតិបត្តិការបច្ចេកទេស និងបំពេញការងារជាច្រកចេញចូលសម្រាប់ការិយាល័យនៅតាមទីកន្លែងនានានៃការិយាល័យ OHCHR។
- **ផ្នែកស្រាវជ្រាវ និងសិទ្ធិទទួលបានការអភិវឌ្ឍ៖** អនុវត្តការស្រាវជ្រាវតាមវិស័យនៃការិយាល័យ OHCHR ស្តីពីសិទ្ធិមនុស្ស រួមទាំង តាមរយៈការផ្តល់ការគាំទ្របច្ចេកទេសទៅតាមទីកន្លែងនានា។ ផ្នែកនេះក៏ចាត់ចែងមជ្ឈមណ្ឌលឯកសារ និងកម្មវិធីបោះពុម្ពផ្សាយនៃការិយាល័យ OHCHR ដោយផលិតនូវឧបករណ៍វិធីសាស្ត្រ និងកញ្ចប់ការសិក្សាជាច្រើនសម្រាប់ប្រើប្រាស់នៅតាមបណ្តាប្រទេស និងទីស្នាក់ការកណ្តាលដើម្បីកសាងសមត្ថភាពរបស់ស្ថាប័នជាតិ សង្គមស៊ីវិល និងដៃគូផ្សេងទៀត។

## ង. ធនធាននៃការិយាល័យ OHCHR

### គេហទំព័រនៃការិយាល័យ OHCHR

គួរអង្គសង្គមស៊ីវិលត្រូវបានលើកទឹកចិត្តឲ្យមើលគេហទំព័រនៃការិយាល័យ OHCHR សម្រាប់ព័ត៌មានបច្ចុប្បន្នភាព និងព័ត៌មាននានាស្តីពីការងារ និងសកម្មភាពនៃការិយាល័យ OHCHR រួមទាំងព័ត៌មានស្តីពីយន្តការសិទ្ធិនានាផ្សេងៗទៀត។ **របាយការណ៍ប្រចាំឆ្នាំនៃការិយាល័យ OHCHR ស្តីពីលទ្ធផល និងសកម្មភាព និងផែនការយុទ្ធសាស្ត្រគ្រប់គ្រង នៃឧត្តមស្នងការ**ក៏អាចរកមើលបានតាមរយៈគេហទំព័រនៃការិយាល័យ OHCHR ផងដែរ។

| |
|---|
| i. សូមចូលទៅកាន់គេហទំព័រនៃការិយាល័យ OHCHR តាមរយៈ http://www.ohchr.org។ |

## ច. វិធីទាក់ទងការិយាល័យ OHCHR

## អាសយដ្ឋានទំនាក់ទំនង

Palais Wison:

52 rue des Pâquis

CH-1201 ទីក្រុងហ្សឺណែវ, ប្រទេសស្វីស

អាគារ Motta:

48 avenue Giuseppe Motta

CH-1202 ទីក្រុងហ្សឺណែវ, ប្រទេសស្វីស

### អាសយដ្ឋានប្រៃសណីយ៍

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិធានជាតិ

8–14, avenue de la Paix

CH–1211 ទីក្រុងហ្សឺណែវ 10

ទូរស័ព្ទ: +41 (0)22 917 90 00

អ៊ីមែល: InfoDesk@ohchr.org (សម្រាប់ព័ត៌មានទូទៅ)

គេហទំព័រ: http://www.ohchr.org

## II.កម្មវិធីអាហាររូបករណ៍ និងបណ្ដុះបណ្ដាលនៃការិយាល័យ OHCHR

កម្មវិធីអាហាររូបករណ៍ និងបណ្ដុះបណ្ដាលដូចបានពិភាក្សានៅក្នុងជំពូកនេះត្រូវបានការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (ការិយាល័យ OHCHR) បង្កើតឡើងដើម្បីបង្កើនតួនាទី និងការចូលរួមរបស់សង្គមស៊ីវិលនៅក្នុងយន្ដការសិទ្ធិមនុស្ស។ ការចូលរួមចំណែក និងការពាក់ព័ន្ធយ៉ាងសកម្មរបស់សង្គមស៊ីវិលបានធ្វើឲ្យសម្រេចបាននូវសិទ្ធិមនុស្សកាន់តែខ្លាំងឡើង។ ជំពូកនេះបង្ហាញព័ត៌មានសំខាន់ៗដែលតួអង្គសង្គមស៊ីវិលចាំបាច់ចូលរួមនៅក្នុងកម្មវិធីអាហាររូបករណ៍ និងសិក្ខាសាលាបណ្ដុះបណ្ដាលនានា។

**ឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សសេដ្ឋកិច្ច និងសង្គមនៃអង្គការសហប្រជាជាតិ (ក្រុមប្រឹក្សា ECOSOC) ពុំមែនជាលក្ខខណ្ឌទាមទាមឲ្យអង្គការ NGOs និងតួអង្គសង្គមស៊ីវិលផ្សេងទៀតចូលរួម ឬ ទទួលយកកម្មវិធី និងសិក្ខាសាលាដែលត្រូវបានពិភាក្សានៅក្នុងជំពូកនេះទេ។**

### ក. កម្មវិធីអាហាររូបករណ៍

**កម្មវិធីអាហាររូបករណ៍**ផ្ដល់ឱកាសឲ្យបុគ្គលដែលត្រូវបានជ្រើសរើសមួយចំនួនទទួលបានការសិក្សាអំពីយន្ដការសិទ្ធិមនុស្ស និងស្ថាប័នអន្ដរជាតិ។

ការិយាល័យ OHCHR ចាត់ចែងកម្មវិធីអាហាររូបករណ៍ចំនួនបួនដែលមានគោលបំណងពង្រឹងសមត្ថភាពរបស់ក្រុម ឬ បុគ្គលជាក់លាក់នៅក្នុងការងារសិទ្ធិមនុស្ស៖

- **កម្មវិធីអាហាររូបករណ៍សម្រាប់ជនជាតិដើមភាគតិច**គាំទ្រដល់សមាជិកក្រុមជនជាតិដើមភាគតិចចូលរួមនៅក្នុងកម្មវិធីបណ្ដុះបណ្ដាលសិទ្ធិមនុស្ស;
- **កម្មវិធីអាហាររូបករណ៍សម្រាប់ជនជាតិភាគតិច**គាំទ្រដល់បុគ្គលនៅក្នុងក្រុមជាតិសាសន៍ជនជាតិដើមភាគតិច ជាតិពិន្ទុ សាសនា និងភាសាចូលរួមនៅក្នុងកម្មវិធីបណ្ដុះបណ្ដាលសិទ្ធិមនុស្ស;
- **កម្មវិធីអាហាររូបករណ៍សិទ្ធិមនុស្សសម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួច**គាំទ្រដល់និស្សិតបញ្ចប់ការសិក្សាពីបណ្ដាប្រទេសអភិវឌ្ឍន៍តិចតួចចូលរួមនៅក្នុងកម្មវិធីបណ្ដុះបណ្ដាលស្ដីពីអង្គការសហប្រជាជាតិ និងសិទ្ធិមនុស្ស និង
- **កម្មវិធីអាហាររូបករណ៍សម្រាប់បុគ្គលិកស្ថាប័នសិទ្ធិមនុស្សជាតិ**គាំទ្រដល់បុគ្គលិកមកពីបណ្ដាស្ថាប័ន NHRIs នៅក្នុងកម្មវិធីបណ្ដុះបណ្ដាលស្ដីពីសិទ្ធិមនុស្សអន្ដរជាតិ និងការងារនៃការិយាល័យ OHCHR ជាមួយនឹង NHRIs។

សៀវភៅណែនាំនេះអាចរកមើលបានក្នុងទម្រង់ឌីជីថលនៅលើគេហទំព័រនៃការិយាល័យ OHCHR តាមរយៈ៖
http://www.ohchr.org/civilsocietyhandbook/ 
នៅលើគេហទំព័នេះ លោកអ្នកនឹងអាចទាញយកជំពូកទាំងឡាយនៅក្នុងសៀវភៅណែនាំនេះបានព្រមទាំងទំព័រតភ្ជាប់ទៅកាន់ឯកសារយោងទាំងអស់ដែលមាននៅក្នុងឯកសារបោះពុម្ពផ្សាយ។

## i. ព័ត៌មានទំនាក់ទំនងលម្អិតអំពីអាហារូបករណ៍

**កម្មវិធីអាហារូបករណ៍សម្រាប់ជនជាតិដើមភាគតិច**

**អង្គភាពជនជាតិដើមភាគតិច និងជនជាតិភាគតិច**

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

វិមានជាតិ

8–14, avenue de la Paix

CH–1211 ទីក្រុងហ្សឺណែវ 10 - ប្រទេសស្វីស

ទូរសារ: +41 (0)22 917 90 08 or +41 (0)22 928 90 66

អ៊ីមែល: fellowship@ohchr.org

**កម្មវិធីអាហារូបករណ៍សម្រាប់ជនជាតិភាគតិច**

**អង្គភាពជនជាតិដើមភាគតិច និងជនជាតិភាគតិច**

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

វិមានជាតិ

8–14, avenue de la Paix

CH–1211 ទីក្រុងហ្សឺណែវ 10 - ប្រទេសស្វីស

ទូរស័ព្ទ: +41 (0)22 928 98 45

ទូរសារ: +41 (0)22 928 90 10

អ៊ីមែល: minorities@ohchr.org

**កម្មវិធីអាហារូបករណ៍សិទ្ធិមនុស្សសម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួច**

**ស្ថាប័នអង្គការសហប្រជាជាតិទទួលបន្ទុកការបណ្តុះបណ្តាល និងការស្រាវជ្រាវ (ស្ថាប័ន UNITAR)**

វិមានជាតិ

8–14, avenue de la Paix

CH-1211 ទីក្រុងហ្សឺណែវ 10 - ប្រទេសស្វីស

ទូរស័ព្ទ: +41 (0)22 917 86 40

ទូរសារ: +41 (0)22 917 80 47

គេហទំព័រ: http://www.ohchr.org or http://www.unitar.org/diplomacy

**កម្មវិធីអាហារូបករណ៍សម្រាប់បុគ្គលិកនៃស្ថាប័ន NHRIs**

**អង្គភាពស្ថាប័នជាតិ**

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

វិមានជាតិ

8–14, avenue de la Paix

CH–1211 ទីក្រុងហ្សឺណែវ 10- ប្រទេសស្វីស

ទូរស័ព្ទ: + 41 (0)22 928 92 83 or + 41 (0)22 928 96 63

ទូរសារ: + 41 (0)22 928 90 18

អ៊ីមែល: niu@ohchr.org

## ១. កម្មវិធីអាហារូបករណ៍សម្រាប់ជនជាតិដើមភាគតិច

**កម្មវិធីអាហារូបករណ៍សម្រាប់ជនជាតិដើមភាគតិច**បានចាប់ផ្តើមឡើងនៅក្នុងឆ្នាំ១៩៩៧ ក្រោមគំនិតផ្តួចផ្តើមរបស់ការិយាល័យ OHCHR ដើម្បីអនុវត្តគោលបំណងនៃទសវត្សរ៍អន្តរជាតិស្តីពីជនជាតិដើមភាគតិចនៅលើសាកលលោក (១៩៩៥-២០០៤)។ កម្មវិធីនេះមានគោលដៅចំបងដើម្បីពង្រឹងអំណាចអ្នកតំណាងជនជាតិដើមភាគតិច និងសហគមន៍របស់ពួកគេតាមរយៈការពង្រឹងចំណេះដឹង និងសមត្ថភាពក្នុងការទាក់ទងជាមួយនឹងប្រព័ន្ធសិទ្ធិមនុស្សនៃអង្គការសហប្រជាតិ។

កម្មវិធីនេះមានគោបំណងផ្តល់ឱកាសឲ្យបុរស និងស្ត្រីជនជាតិដើមភាគតិចបង្កើនចំណេះដឹងសិទ្ធិមនុស្សអន្តរជាតិទូទៅ និងជាពិសេសសិទ្ធិជនជាតិដើមភាគតិចដើម្បីជួយអង្គការ និងសហគមន៍របស់ពួកគេក្នុងការការពារ និងលើកកម្ពស់សិទ្ធិរបស់ពួកគេកាន់តែប្រសើរឡើង។ នៅចុងបញ្ចប់កម្មវិធីអ្នកបញ្ចប់អាហារូបករណ៍នឹងមានសមត្ថភាពផ្តល់ការបណ្តុះបណ្តាលនៅក្នុងសហគមន៍ និងអង្គការរបស់ពួកគេអំពីសិទ្ធិមនុស្សអន្តរជាតិទូទៅ និងជាពិសេសសិទ្ធិជនជាតិដើមភាគតិច និងអាចផ្សព្វផ្សាយព័ត៌មាន និងចំណេះដឹងដែលទទួលបាននៅក្នុងអំឡុងពេលនៃអាហារូបករណ៍។ កម្មវិធីនេះមានគោលបំណងផ្តល់ផលប្រយោជន៍ដល់បុគ្គលទាំងនោះខ្លួនឯង អង្គការរបស់ពួកគេ និងសំខាន់បំផុតសហគមន៍របស់ពួកគេ។

កម្មវិធីអាហារូបករណ៍សម្រាប់ជនជាតិដើមភាគតិចរៀបចំឡើងជាបួនភាសា ពោលគឺ **ភាសាអង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ**។ ជារៀងរាល់ឆ្នាំ កម្មវិធីនេះនឹងជ្រើសរើសសិស្សអាហារូបករណ៍ប្រហែលជាប្រាំរូបសម្រាប់ភាសានីមួយៗនៅក្នុងកម្មវិធីរៀងៗខ្លួនៈ

- កម្មវិធីទីក្រុងហ្សឺណែវ (**ភាសាអង់គ្លេស**)
- កម្មវិធីទីក្រុង Deusto (**ភាសាអេស្ប៉ាញ**)
- កម្មវិធីទីក្រុង Dijon (**ភាសាបារាំង**)
- កម្មវិធីទីក្រុងមូស្គូ (**ភាសារុស្ស៊ី**)

**កម្មវិធីទីក្រុងហ្សឺណែវ**ត្រូវបានអនុវត្តដោយការិយាល័យ OHCHR នៅទីក្រុងហ្សឺណែវ។ កម្មវិធីនេះចាប់ផ្តើមនៅក្នុងខែឧសភាជារៀងរាល់ឆ្នាំ និងជាទូទៅមានរយៈពេលបួនខែដោយផ្តោតលម្អិតលើយន្តការ និងស្ថាប័នសិទ្ធិមនុស្ស។ កម្មវិធីនេះមានលក្ខណៈជាកម្មវិធីពិភាក្សាផ្លាស់ប្តូរយោបល់ និងរួមមានការណែនាំសង្ខេបអំពីប្រធានបទនានា ព្រមទាំងកិច្ចការជាលក្ខណៈបុគ្គល និងជាក្រុម។

**កម្មវិធីក្រុង Deusto** គឺជាកម្មវិធីផ្តួចផ្តើមរួមគ្នារវាងសាកលវិទ្យាល័យ Deusto ក្នុងទីក្រុងប៊ីលបាវ ប្រទេសអេស្ប៉ាញ និងការិយាល័យ OHCHR ដោយជាទូទៅមានរយៈពេលបួនខែ ហើយបែងចែកជាពីរវគ្គៈ វគ្គទី១ រៀបចំឡើងនៅសាកលវិទ្យាល័យ Deusto និងវគ្គទី២ នៅការិយាល័យ OHCHR ក្នុង

ទីក្រុងហ្សឺណែវ។ កម្មវិធីនេះមានលក្ខណៈស្រដៀងគ្នានឹងកម្មវិធីកម្មវិធីទីក្រុងហ្សឺណែវដោយព្យាយាមឲ្យមានការផ្លាស់ប្តូរយោបល់គ្នារវាងសិស្សអាហារូបករណ៍ និងអង្គការផ្សេងៗទៀតដែលបានចូលរួមដូចជា អង្គការ NGOs Basque និងរដ្ឋាភិបាល Basque។

**កម្មវិធីក្រុង** Dijon គឺជាកម្មវិធីផ្តួចផ្តើមរួមគ្នារវាងសាកលវិទ្យាល័យ Bourgogne ក្នុងទីក្រុង Dijon ប្រទេសបារាំង និងការិយាល័យ OHCHR ដោយផ្តោតលើជនជាតិដើមភាគតិចដែលមានភាសាបារាំងជាភាសាកំណើត និងភាសាទីពីរ។ កម្មវិធីនេះមានរយៈពេល ១០ សប្តាហ៍ (៤ សប្តាហ៍នៅសាកលវិទ្យាល័យក្នុងទីក្រុង Dijon ៤ សប្តាហ៍នៅការិយាល័យ OHCHR ក្នុងទីក្រុងហ្សឺណែវ និង ២ សប្តាហ៍នៅអង្គការអប់រំវិទ្យាសាស្រ្ត និងវប្បធម៌ (អង្គការយូណេស្កូ) ក្នុងទីក្រុងប៉ារីស។

**កម្មវិធីទីក្រុងមូស្គូ** គឺជាកម្មវិធីផ្តួចផ្តើមរួមគ្នារវាងសមាគមន៍ជនជាតិដើមភាគតិចរុស្សីភាគខាងជើង (សមាគម RAIPON) ក្នុងទីក្រុងមូស្គូ និងការិយាល័យ OHCHR។ វគ្គបណ្តុះបណ្តាលនៅទីក្រុងមូស្គូមានរយៈពេល ៤ សប្តាហ៍ជាមួយនឹងសមាគម RAIPON ការិយាល័យ OHCHR ប្រចាំទីក្រុងមូស្គូ និងការិយាល័យនៃអង្គការសហប្រជាជាតិផ្សេងទៀតនៅទីក្រុងមូស្គូ និង៤ សប្តាហ៍បន្ទាប់នៅការិយាល័យ OHCHR ក្នុងទីក្រុងហ្សឺណែវ។

**រាល់កម្មវិធីអាហារូបករណ៍ទាំងអស់ផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់ការស្នាក់នៅសមរម្យ ការធ្វើដំណើរ ការធានារ៉ាប់រងសុខភាព និងការចំណាយលើការរស់នៅផ្សេងទៀត។**

## លក្ខខណ្ឌចូលរួម

- បេក្ខជនត្រូវជាសមាជិកក្រុមជនជាតិដើមភាគតិច និងមានការគាំទ្រពីសហគមន៍ ឬ អង្គការជនជាតិដើមភាគតិចរបស់ពួកគេ;
- ទោះបីជាពុំមានការកម្រិតអាយុក៏ដោយ អាទិភាពត្រូវបានផ្តល់ជូនបេក្ខជនដែលមានអាយុចន្លោះពី ២៥ ដល់ ៣៥ ឆ្នាំ;
- ការពុំទទួលបានការអប់រំក្នុងប្រព័ន្ធពុំមែនជាលក្ខខណ្ឌកម្រិតក្នុងការចូលរួមនៅក្នុងកម្មវិធីអាហារូបករណ៍នេះឡើយដោយសារឧបសគ្គសេដ្ឋកិច្ចសង្គមរាំងការអប់រំប្រជាជនដើមភាគ តិច;
- បេក្ខជនត្រូវមានលទ្ធភាព និងឆន្ទៈបណ្តុះបណ្តាលជនជាតិដើមភាគតិចផ្សេងទៀតក្រោយពេលវិលត្រឡប់មកកាន់សហគមន៍/អង្គការរបស់ពួកគេ;
- ប្រសិនបើអាច អង្គការឧបត្ថម្ភគួរមានទីកន្លែង ឬ សមាជិកភាពជាក់លាក់;
- ការជ្រើសរើសបេក្ខជនធ្វើឡើងទៅតាមសមាមាត្រយេនឌ័រ និងតំបន់ និង

- បេក្ខជនត្រូវមានការយល់ដឹងច្បាស់លាស់លើភាសាដែលប្រើប្រាស់នៅក្នុងកម្មវិធីអាហាររូបករណ៍។

ភាសាទាំងបួននៅក្នុងកម្មវិធីនេះត្រូវបានរៀបចំឡើងប្រចាំឆ្នាំ ហើយការដាក់ពាក្យសុំមានកាលបរិច្ឆេទកំណត់ខុសៗគ្នា។ កម្មវិធីនេះនឹងពិចារណាលើពាក្យសុំអាហាររូបករណ៍ដែលបានបំពេញត្រឹមត្រូវតែប៉ុណ្ណោះ។ បេក្ខជនត្រូវបញ្ជូនពាក្យសុំតាមទូរសារ ឬ តាមប្រៃសណីយធម្មតា។ កម្មវិធីនឹងមិនពិចារណាពាក្យសុំទាំងឡាយណាដែលបានបញ្ជូនមកតាមរយៈអ៊ីមែលនោះឡើយលើកលែងតែពាក្យសុំ **ផ្នែកទីមួយ និងផ្នែកទីពីរត្រូវបានចុះហត្ថលេខា និងថតស្កេនត្រឹមត្រូវ។**

## i. ទីកន្លែងដាក់ពាក្យសុំ

**កម្មវិធីអាហាររូបករណ៍សម្រាប់ជនជាតិដើមភាគតិច**

**អង្គភាពជនជាតិដើមភាគតិច និងជនជាតិភាគតិច**

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

វិមានជាតិ

8–14, avenue de la Paix

CH–1211 ទីក្រុងហ្សឺណែវ 10 - ប្រទេសស្វីស

ទូរសារ: +41 (0)22 917 90 08 or +41 (0)22 928 90 66

អ៊ីមែល: fellowship@ohchr.org

ប្រសិនបើចង់ស្វែងយល់បន្ថែមអំពី**កម្មវិធីអាហាររូបករណ៍** និងដើម្បីទទួលបានពាក្យសុំទាំងបួនភាសា សូមចូលមកកាន់គេហទំព័ររបស់ការិយាល័យ OHCHR។

## ២. កម្មវិធីអាហាររូបករណ៍សម្រាប់ជនជាតិភាគតិច

តាមរយៈ**កម្មវិធីអាហាររូបករណ៍សម្រាប់ជនជាតិភាគតិច** ការិយាល័យ OHCHR មានគោលបំណងផ្តល់ឱកាសជូនបុគ្គលនៅក្នុង**ក្រុមជាតិសាសន៍ជនជាតិភាគតិច ឬ ជាតិពិន្ទុ សាសនា និងភាសា** ជាពិសេស បុរស និងស្ត្រីវ័យក្មេងដើម្បីបង្កើនចំណេះដឹងផ្នែកសិទ្ធិមនុស្សអន្តរជាតិទូទៅ និងជាពិសេសសិទ្ធិជនជាតិភាគតិច។ នៅចុងបញ្ចប់កម្មវិធី អ្នកបញ្ចប់អាហារូបករណ៍សង្ឃឹមថានឹងទទួលបានចំណេះដឹងអំពីយន្តការសិទ្ធមនុស្សនៃអង្គការសហប្រជាជាតិពីព្រោះពួកគេយល់ដឹងអំពីបញ្ហានានាដែលពាក់ព័ន្ធនឹងជនជាតិភាគតិច ហើយនឹងអាចផ្តល់ការបណ្តុះបណ្តាលនៅក្នុងសហគមន៍ និងអង្គការរបស់ពួកគេអំពីព័ត៌មាន និងចំណេះដឹងដែលបានទទួលនៅក្នុងអំឡុងពេលនៃអាហាររូបករណ៍។

| ការបណ្តុះបណ្តាលដឹកនាំដោយសហគមន៍នៅក្នុងប្រទេសប៊ុលហ្គារីដោយអតីតជនជាតិភាគតិចក្រោយបញ្ចប់អាហារូបករណ៍ | | |
|---|---|---|
| ការិយាល័យ OHCHR បានគាំទ្រគម្រោងដែលបានដាក់ជូនដោយអតីតអ្នកបញ្ចប់អាហារូបករណ៍មកពីសហគមន៍រ៉ូម៉ានៅក្នុង**ប្រទេសប៊ុលហ្គារី**ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលមួយនៅក្នុងក្រុង Polski Trambesh កាលពីខែធ្នូ ឆ្នាំ២០០៦។ គម្រោងនេះបានផ្តល់លទ្ធភាពឲ្យអង្គការរបស់គាត់ ពោលគឺ អង្គការ Roma Together រៀបចំសិក្ខាសាលាបណ្តុះបណ្តាលដើម្បីផ្តល់លទ្ធភាព និងផ្តល់ | ជំនាញដល់សហគមន៍មូលដ្ឋានរ៉ូម៉ាដើម្បីអនុវត្ត "Decade of Roma Inclusion" ឆ្នាំ២០០៥-ឆ្នាំ២០១៥ ដែលបានបង្កើតឡើងដោយប្រទេសចំនួន ៩ នៅក្នុងទ្វីបអឺរ៉ុបកណ្តាល និងអាគ្នេយ៍។ សិក្ខាកាមបានបង្កើតយុទ្ធសាស្ត្រដើម្បីបង្កើនការចូលរួមរបស់រ៉ូម៉ានៅក្នុងការធ្វើសេចក្តីសម្រេចផ្លូវការជាពិសេសនៅក្នុងវិស័យនានាដែលភាគច្រើន | ប៉ះពាល់លើសិទ្ធិ និងជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេ។ សិក្ខាកាមបានស្នើឲ្យក្រុមប្រឹក្សាក្រុងគួរបង្កើតគណកម្មាធិការអចិន្ត្រៃយ៍នៃអ្នកតំណាងជនជាតិភាគតិចមូលដ្ឋានមួយដើម្បីផ្តល់យោបល់លើគោលនយោបាយទាក់ទងនឹងបញ្ហាជនជាតិភាគតិច។ អភិបាលក្រុង និងអភិបាលក្រុមប្រឹក្សាក្រុងបានទទួលយកសំណើសុំនេះ។ |

ក្នុងពេលបច្ចុប្បន្ន ការិយាល័យ OHCHR មានកម្មវិធីអាហារូបករណ៍ជនជាតិភាគតិចចំនួនពីរភាសា ពោលគឺ ភាសាអង់គ្លេស និងភាសាអារ៉ាប់។ កម្មវិធីភាសាអង់គ្លេសត្រូវបានរៀបចំឡើងរយៈពេលបីខែនៅរៀងរាល់ខែមេសាដោយមានអ្នកចូលរួមចំនួនប្រាំរូប។ កម្មវិធីភាសាអារ៉ាប់ដែលជាកម្មវិធីសាកល្បងត្រូវបានរៀបចំឡើងជាលើកទីមួយនៅក្នុងឆ្នាំ២០០៧ដោយមានអ្នកចូលរួមចំនួន ៤ រូប នៅក្នុងការបណ្តុះបណ្តាលនៅការិយាល័យ OHCHR ក្នុងទីក្រុងហ្សឺណែវសម្រាប់រយៈពេលមួយខែ។ កម្មវិធីអាហារូបករណ៍ផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់ការស្នាក់នៅសមរម្យ និងការចំណាយលើការរស់នៅផ្សេងទៀត ការធ្វើដំណើរទៅមកទីក្រុងហ្សឺណែវ និងប្រាក់ធានារ៉ាប់រងសុខភាព។

## លក្ខខណ្ឌចូលរួម

- បេក្ខជនត្រូវជាសមាជិកក្រុមជាតិសាសន៍ជនជាតិភាគតិច ជាតិពន្ធុ សាសនា ឬ ភាសា;
- ទោះបីជាពុំមានការកម្រិតអាយុក៏ដោយ អាទិភាពត្រូវបានផ្តល់ជូនបេក្ខជនដែលមានអាយុចន្លោះពី ២៥ ដល់ ៣៥ ឆ្នាំ;
- ការពុំទទួលបានការអប់រំក្នុងប្រព័ន្ធពុំមែនជាលក្ខខណ្ឌកម្រិតក្នុងការចូលរួមនៅក្នុងកម្មវិធីអាហារូបករណ៍សម្រាប់ជនជាតិភាគតិចនេះឡើយដរាបណាបេក្ខជនអាចបង្ហាញនូវបទពិសោធន៍ពាក់ព័ន្ធ;

- ប្រសិនបើអាច អង្គការ ឬ សមាគមន៍ឧបត្ថម្ភគួរបំពេញការងារលើបញ្ហាជនជាតិភាគតិច និងរួមមានសាមាសភាពបុគ្គលសមាជិកជនជាតិភាគតិច;
- បេក្ខជនត្រូវមានលទ្ធភាព និងឆន្ទៈបណ្ដុះបណ្ដាលជនជាតិដើមភាគតិចផ្សេងទៀតក្រោយពេលវិលត្រឡប់មកកាន់សហាគមន៍/អង្គការរបស់ពួកគេ;
- បេក្ខជនត្រូវមានលិខិតគាំទ្រជាលាយលក្ខណ៍អក្សរពីសហាគមន៍ ឬ អង្គការរបស់ពួកគេ;
- បេក្ខជនត្រូវមានចំណេះដឹងច្បាស់លាស់លើភាសាដែលប្រើប្រាស់នៅក្នុងកម្មវិធី (ភាសាអារ៉ាប់ ឬ ភាសាអង់គ្លេស)

**កម្មវិធីនេះនឹងពិចារណាលើពាក្យសុំអាហារូបករណ៍ដែលបានបំពេញត្រឹមត្រូវតែប៉ុណ្ណោះ។ បេក្ខជនត្រូវបញ្ជូនពាក្យសុំតាមទូរសារ ឬ តាមប្រៃសណីយធម្មតា។ កម្មវិធីនឹងមិនពិចារណាពាក្យសុំទាំងឡាយណាដែលបានបញ្ជូនមកតាមរយៈអ៊ីមែលនោះឡើយលើកលែងតែពាក្យសុំផ្នែកទីមួយ និងផ្នែកទីពីរត្រូវបានចុះហត្ថលេខា និងថតស្កេនត្រឹមត្រូវ។**

### i. ទីកន្លែងដាក់ពាក្យសុំ

**កម្មវិធីអាហារូបករណ៍សម្រាប់ជនជាតិភាគតិច**
**អង្គភាពជនជាតិដើមភាគតិច និងជនជាតិភាគតិច**
ការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8–14, avenue de la Paix
CH–1211 ទីក្រុងហ្សឺណែវ 10 - ប្រទេសស្វីស
ទូរស័ព្ទ: +41 (0)22 928 98 45
ទូរសារ: +41 (0)22 928 90 10
អ៊ីមែល: minorities@ohchr.org

ប្រសិនបើចង់ស្វែងយល់បន្ថែមអំពី**កម្មវិធីអាហារូបករណ៍** និងទទួលបានពាក្យសុំទាំងបួនភាសា សូមចូលមកកាន់គេហទំព័ររបស់ការិយាល័យ OHCHR។

## ៣. កម្មវិធីអាហារូបករណ៍សិទ្ធិមនុស្សសម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួច

**កម្មវិធីអាហារូបករណ៍សិទ្ធិមនុស្សសម្រាប់និស្សិតមកពីបណ្ដាប្រទេសអភិវឌ្ឍន៍តិចតួច (ប្រទេស LDCs)** បានចាប់ផ្ដើមជាលើកទីមួយនៅក្នុងឆ្នាំ២០០៧ ក្រោមការរៀបចំឡើងរួមគ្នាពីការិយាល័យ OHCHR និងស្ថាប័នអង្គការសហប្រជាតិទទួលបន្ទុកការបណ្ដុះបណ្ដាល និងការស្រាវជ្រាវ (ស្ថាប័ន

UNITAR)។ កម្មវិធីនេះមានគោលបំណងបង្កើនការយល់ដឹងរបស់អ្នកបញ្ចប់អាហារូបករណ៍ LDCs អំពីបញ្ហាសិទ្ធិមនុស្សបច្ចុប្បន្ននៅកម្រិតអន្តរជាតិ ហើយផ្តល់ជូនពួកគេនូវចក្ខុវិស័យនៅក្នុងការងារអង្គការសហប្រជាជាតិ និងការិយាល័យ OHCHR ព្រមទាំងផ្តល់ការជួយជ្រោមជ្រែងដល់ការិយាល័យ OHCHR និងយន្តការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ និងការចូលរួមចំណែកពីនិស្សិត ឬ អ្នកបញ្ចប់ការសិក្សាផ្នែមពីប្រទេស LDCs។

កម្មវិធីនេះរៀបចំឡើងជាភាសាអង់គ្លេសនៅការិយាល័យ OHCHR នៅក្នុងទីក្រុងហ្សឺណែវ ដែលរួមមានទាំងការបណ្តុះបណ្តាល និងការអនុញ្ញាតឲ្យអនុវត្តការងារជាក់ស្តែងនៃការិយាល័យ OHCHR ក្នុងទម្រង់ជាកិច្ចសិក្ខាសាលា និងលំហាត់ជំនាញជាក់ស្តែងដោយបន្ទាប់មកនឹងការបញ្ជូនទៅបំពេញកិច្ចការនៅតាមសាខានៃការិយាល័យ OHCHR។ និរន្តភាពនៃកម្មវិធីអាហារូបករណ៍នេះនាឆ្នាំខាងមុខៗទៀតអាស្រ័យលើលទ្ធភាពនៃមូលនិធិ។

កម្មវិធីអាហារូបករណ៍ផ្នែកសិទ្ធិមនុស្សនេះបើកជូនដល់បេក្ខជនមកពីតាមបណ្តាលប្រទេស LDCs[29]។ បេក្ខជនត្រូវជានិស្សិតបញ្ចប់ការសិក្សា ឬ និស្សិតមានបរិញ្ញាប័ត្រជាន់ខ្ពស់នៅក្នុងជំនាញទាក់ទងនឹងការងារអង្គការសហប្រជាជាតិ (ឧ. ច្បាប់អន្តរជាតិ វិទ្យាសាស្ត្រនយោបាយ វិទ្យាសាស្ត្រសង្គម ឬ ប្រវត្តិសាស្ត្រ)។ បេក្ខជនត្រូវមានអាយុក្រោម ៣០ ឆ្នាំ នៅពេលដាក់ពាក្យសុំ។

កម្មវិធីនឹងផ្តល់ជូននូវការចំណាយលើការធ្វើដំណើររបស់អ្នកទទួលបានអាហារូបករណ៍ដែលនឹងទទួលបានប្រាក់ឧបត្ថម្ភជាប្រចាំដើម្បីចំណាយលើការរស់នៅក្នុងទីក្រុងហ្សឺណែវ។ កម្មវិធីនេះក៏ផ្តល់ជូនការរៀបចំទិដ្ឋាការ ការស្នាក់នៅ ការធានារ៉ាប់រងសុខភាព និងគ្រោះថ្នាក់ផ្សេងៗផងដែរ។

ដោយសារនិរន្តភាពនៃកម្មវិធីនេះអាស្រ័យលើការទទួលបានមូលនិធិគ្រប់គ្រាន់ដែរនោះ បេក្ខជនដែលមានចំណាប់អារម្មណ៍ត្រូវបានលើកទឹកចិត្តឲ្យមើលគេហទំព័រនៃការិយាល័យ OHCHR និងស្ថាប័ន UNITAR ឲ្យបានទៀងទាត់សម្រាប់ព័ត៌មានផ្សេងៗ។

i. របៀបទាក់ទងកម្មវិធីអាហារូបករណ៍សិទ្ធិមនុស្សសម្រាប់ប្រទេស LDCs

**ស្ថាប័នអង្គការសហប្រជាជាតិទទួលបន្ទុកការបណ្តុះបណ្តាល និងការស្រាវជ្រាវ (ស្ថាប័ន UNITAR)**

វិមានជាតិ

8–14, avenue de la Paix

CH-1211 ទីក្រុងហ្សឺណែវ 10 - ប្រទេសស្វីស

ទូរស័ព្ទ: +41 (0)22 917 86 40

---

[29] ដើម្បីស្វែងយល់បន្ថែមអំពីលក្ខខណ្ឌដែលត្រូវបានប្រើប្រាស់ដោយអង្គការសហប្រជាជាតិក្នុងការកំណត់ប្រទេសអភិវឌ្ឍន៍តិចតួច សូមចូលមកកាន់ http://www.unohrlls.org/។

ទូរសារ: +41 (0)22 917 80 47

គេហទំព័រ: http://www.ohchr.org or http://www.unitar.org/diplomacy

## ៩. កម្មវិធីអាហារូបករណ៍សម្រាប់បុគ្គលិកស្ថាប័នសិទ្ធិមនុស្សជាតិ

**អាហារូបករណ៍សម្រាប់បុគ្គលិកស្ថាប័នសិទ្ធិមនុស្សជាតិ**បានចាប់ផ្តើមជាលើកទីមួយនៅក្នុងឆ្នាំ២០០៨ ក្រោមការរៀបចំឡើងពី**អង្គភាពស្ថាប័នជាតិ**នៃការិយាល័យ OHCHR។ កម្មវិធីនេះមានគោលបំណងផ្តល់ឱកាសឲ្យសិក្ខាកាមចូលរួមបង្កើនចំណេះដឹង និងបទពិសោធន៍ជាក់ស្តែងជាមួយនឹងប្រព័ន្ធសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ការងារនៃការិយាល័យ OHCHR ជាមួយ និងសម្រាប់ស្ថាប័ន NHRIs ព្រមទាំងបញ្ហាបច្ចេកទេសសំខាន់ៗទាក់ទងនឹងស្ថាប័ន NHRIs។ កម្មវិធីរំពឹងថា អ្នកបញ្ចប់អាហារូបករណ៍នឹងវិលត្រឡប់មកស្ថាប័ន NHRIs របស់ពួកគេវិញដើម្បីពង្រឹងសមត្ថភាពអង្គការរបស់ពួកគេនៅក្នុងវិស័យសិទ្ធិមនុស្សអន្តរជាតិ។

កម្មវិធីនេះធ្វើឡើងនៅការិយាល័យ OHCHR ក្នុងទីក្រុងហ្សឺណែវ។ បេក្ខជនអាហារូបករណ៍ពីររូបនឹងត្រូវបានជ្រើសរើសជារៀងរាល់ឆ្នាំសម្រាប់រយៈពេលប្រាំមួយខែដោយវគ្គដំបូងចាប់ផ្តើមនៅក្នុងខែមករា និងវគ្គទីបន្ទាប់ចាប់ផ្តើមនៅក្នុងខែកក្កដា។ បេក្ខជនអាហារូបករណ៍នឹងទទួលបានការណែនាំបឋមតាមកាលកំណត់ស្តីពីប្រព័ន្ធសិទ្ធិមនុស្ស និងវិស័យពាក់ព័ន្ធ ហើយនឹងធ្វើកិច្ចការព្រមទាំងអនុញ្ញាតឲ្យចូលរួមនៅក្នុងគម្រោងផ្សេងៗទៀត។

បេក្ខជនត្រូវមានបទពិសោធន៍ដោយផ្ទាល់យ៉ាងហោចណាស់រយៈពេលបីឆ្នាំធ្វើការងារជាមួយនឹងស្ថាប័ន NHRI ណាមួយដែលបានបំពេញបទដ្ឋានទទួលស្គាល់ដោយអន្តរជាតិ ពោលគឺគោលការណ៍ទីក្រុងប៉ារីស[30] និងបទពិសោធន៍ពូកែធ្វើការងារលើប្រធានបទពាក់ព័ន្ធនឹងស្ថាប័ន NHRI នៅថ្នាក់ជាតិ តំបន់ និងអន្តរជាតិប្រសិនបើអាច។

បេក្ខជនត្រូវមានលិខិតគាំទ្រពីស្ថាប័ន NHRIs របស់ពួកគេ ហើយនឹងប្តេជ្ញាផ្ទេរចំណេះដឹង និងបទពិសោធន៍ដែលបានទទួលនៅក្នុងអំឡុងពេលនៃអាហារូបករណ៍ជូនទៅបុគ្គលិករួមអាជីពនៅក្នុងស្ថាប័ន NHRIs ក្រោយពេលវិលត្រឡប់មកវិញ។ លើសពីនេះ បេក្ខជនត្រូវចេះភាសាអង់គ្លេស និង/ឬបារាំងស្ទាត់ជំនាញផងដែរ។ ការិយាល័យ OHCHR ផ្តល់ការគាំទ្រហិរញ្ញវត្ថុជាប្រាក់ឧបត្ថម្ភប្រចាំខែនៅក្នុងអំឡុងពេលនៃអាហារូបករណ៍។

---

[30] សូមមើលសេចក្តីសម្រេចចិត្តនៃមហាសន្និបាតលេខ ៤៨/១៣៤ ឧបសម្ព័ន្ធ។

បេក្ខជនត្រូវបញ្ជូនពាក្យសុំ (លិខិតបញ្ជាក់ហេតុផល ប្រវត្តិរូបសង្ខេប លិខិតគាំទ្រពីស្ថាប័ន NHRIs) ដោយផ្ទាល់ទៅកាន់ការិយាល័យ OHCHR។ អង្គភាពស្ថាប័នជាតិជ្រើសរើសបេក្ខជនដោយមានការពិគ្រោះយោបល់ជាមួយនឹងការិយាល័យនៃគណកម្មាធិការសម្របសម្រួលអន្តរជាតិនៃស្ថាប័នជាតិទទួលបន្ទុកការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស (ការិយាល័យ ICC)។

## i. ទីកន្លែងបញ្ជូនពាក្យសុំ

**កម្មវិធីអាហារូបករណ៍សម្រាប់បុគ្គលិកនៃស្ថាប័ន NHRIs**

**អង្គភាពស្ថាប័នជាតិ**

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

វិមានជាតិ

8–14, avenue de la Paix

CH–1211 ទីក្រុងហ្សឺណែវ 10- ប្រទេសស្វីស

ទូរស័ព្ទ: + 41 (0)22 928 92 83 or + 41 (0)22 928 96 63

ទូរសារ: + 41 (0)22 928 90 18

អ៊ីមែល: niu@ohchr.org

សម្រាប់ព័ត៌មានបច្ចុប្បន្នស្តីពី**កម្មវិធីអាហារូបករណ៍សម្រាប់ស្ថាប័ន NHRIs** សូមចូលមកកាន់គេហទំព័រនៃការិយាល័យ OHCHR។

# ខ. សិក្ខាសាលាបណ្តុះបណ្តាល

**សិក្ខាសាលាបណ្តុះបណ្តាល**ផ្តល់ឱកាសដល់តួអង្គសង្គមស៊ីវិលសិក្សាអំពីយន្តការសិទ្ធិមនុស្សជាក់លាក់ និងវិធីពង្រឹងការចូលរួមរបស់ពួកគេជាមួយយន្តការទាំងនេះ។

សិក្ខាសាលាបណ្តុះបណ្តាលស្តីពីការបន្តតាមដានអនុសាសន៍នៃគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស

**សិក្ខាសាលាបណ្តុះបណ្តាលស្តីពីការបន្តតាមដានអនុសាសន៍នៃគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស**រៀបចំឡើងសម្រាប់តួអង្គសង្គមស៊ីវិលជាតិ និងមានគោលបំណងកសាងសមត្ថភាពរបស់ពួកគេដើម្បីចូលរួមជាមួយនឹងគណកម្មាធិការសន្ធិសញ្ញា។

ការិយាល័យ OHCHR រៀបចំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលទាំងនេះឡើងសម្រាប់តួអង្គជាតិនៅក្នុងប្រទេសរបស់ពួកគេដើម្បីពង្រឹងសមត្ថភាពក្នុងការចូលរួមចំណែកនៅក្នុងដំណើរការធ្វើរបាយការណ៍លើសន្ធិសញ្ញា និងការបន្តតាមដានអនុសាសន៍នៃគណកម្មាធិការសន្ធិសញ្ញា។ ការិយាល័យ OHCHR បំពេញការងារជាមួយនឹងស្ថាប័ន NHRIs អង្គការ NGOs និងតំណាង

សារព័ត៌មានថ្នាក់ជាតិនៅក្នុងសិក្ខាសាលាទាំងនេះដើម្បីកសាងសមត្ថភាព និងលើកទឹកចិត្តដល់ការបង្កើតបណ្តាញតួអង្គជាតិក្នុងគោលបំណងគាំទ្រលើការអនុវត្តអនុសាសន៍នៃគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សនីមួយៗ។

ចាប់តាំងពីឆ្នាំ២០០៣មក ការិយាល័យ OHCHR បានបើកសិក្ខាសាលាស្តីពីបន្តតាមដាននេះនៅគ្រប់តំបន់នានាក្នុងពិភពលោក។ កម្មវិធីបណ្តុះបណ្តាលនេះគឺជាក្របខណ្ឌសម្រាប់បង្កើតក្រុមបណ្តាញសង្គមស៊ីវិលជាតិដើម្បីបន្តតាមដានដំណើរការធ្វើរបាយការណ៍លើសន្ធិសញ្ញាសិទ្ធិមនុស្ស ព្រមទាំងជាកិច្ចសន្ទនាកែលម្អថ្នាក់ជាតិលើបញ្ហានានាពាក់ព័ន្ធនឹងការងារនៃគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស។ ការិយាល័យ OHCHR ក៏ផ្តល់ការណ្តុះបណ្តាលដោយផ្ទាល់ដល់រដ្ឋាភិបាលទាំងឡាយដែលមានការចាប់អារម្មណ៍តាមរយៈសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលនានា និងលើកទឹកចិត្តឲ្យសង្គមស៊ីវិលចូលរួមនៅក្នុងសកម្មភាពទាំងនេះ។

i. សម្រាប់ព័ត៌មានបន្ថែមស្តីពីសិក្ខាសាលាបណ្តុះបណ្តាលលើការសិក្សាតាមដាន សូមទាក់ទង៖

**សាខាទទួលបន្ទុកសន្ធិសញ្ញាសិទ្ធិមនុស្ស**

**អង្គភាពទទួលបន្ទុកឃ្លាំមើល និងសន្ធិសញ្ញា**

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8–14, avenue de la Paix
CH–1211 ទីក្រុងហ្សឺណែវ 10- ប្រទេសស្វីស
ទូរសារ: + 41 (0)22 917 90 22

ក្រៅពីកម្មវិធីបណ្តុះបណ្តាលដូចបានលើកឡើងខាងលើ ការិយាល័យ OHCHR តាមរយៈតំណាងវត្តមាននានានៅតាមទីកន្លែងនានាបានធ្វើការរៀបចំការបណ្តុះបណ្តាល និងសក្ខាសាលាយ៉ាងទៀងទាត់ស្តីពីការកសាងសមត្ថភាពសម្រាប់សង្គមស៊ីវិលលើបញ្ហា និងយន្តការសិទ្ធិមនុស្សអន្តរជាតិ។

i. សម្រាប់ព័ត៌មានលម្អិតស្តីពី**គណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស** សូមមើលជំពូក IV (**គណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស**) នៅក្នុងសៀវភៅណែនាំនេះ។

## III. ឯកសារបោះពុម្ពផ្សាយ និងឯកសារធនធាន

## ក. ឯកសារបោះពុម្ពផ្សាយនៃការិយាល័យ OHCHR

កម្មវិធីបោះពុម្ពផ្សាយនៃ**ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស** (ការិយាល័យ OHCHR) មានគោលបំណងលើកកម្ពស់ការដល់ដឹងសិទ្ធិមនុស្ស និងសេរីភាពជាសារវន្ត និងផ្សព្វផ្សាយជាសាធារណៈអំពីវិធីលើកតម្កើង និងការពារសិទ្ធិសេរីភាពទាំងនេះនៅជុំវិញពិភពលោក។ កម្មវិធីនេះក៏លើកទឹកចិត្តឲ្យមានការពិភាក្សាវែកញែកអំពីបញ្ហាសិទ្ធិមនុស្សដែលកំពុងស្ថិតនៅក្រោមការពិនិត្យមើលឡើងវិញនៅក្នុងអង្គការស្ថាប័នអង្គការសហប្រជាជាតិផងដែរ។ ឯកសារបោះពុម្ពផ្សាយមានប្រាំប្រភេទធំៗ៖

១. **តារាងព័ត៌មាន**ផ្តល់ព័ត៌មានអំពីសិទ្ធិមនុស្សច្រើនប្រធានបទ;

២. **អត្ថបទស្តីពីបញ្ហាពិសេស**សិក្សាស៊ីជម្រៅលើបញ្ហានានាដែលត្រូវបានជ្រើសរើស;

៣. **ឯកសារបណ្តុះបណ្តាល និងអប់រំនៃការិយាល័យ OHCHR** រួមមានសៀវភៅ។ មគ្គុទេសក៍ក្បួន និងសៀវភៅណែនាំសម្រាប់ជនជាតិដើមភាគតិច ជនជាតិភាគតិច ក្រុមវិជ្ជាជីវៈ និងស្ថាប័នអប់រំ;

៤. **ឯកសារយោង**បង្ហាញនូវលិខិតុបករណ៍ និងយុត្តិសាស្ត្រសំខាន់ៗស្តីពីសិទ្ធិមនុស្សដល់អ្នកអនុវត្តសិទ្ធិមនុស្ស និង

៥. **ឯកសារមូលដ្ឋានស្តីពីសិទ្ធិមនុស្ស**ជូនដំណឹងដល់សាធារណជនអំពីការងារសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ។

## ១. សលាកប័ត្រ

**សលាកប័ត្រ**នៃការិយាល័យ OHCHR ផ្តល់ព័ត៌មានអំពីសិទ្ធិមនុស្សជាមូលដ្ឋាន។ តារាងព័ត៌មានខ្លះលើកឡើងអំពីបញ្ហា ឬ ក្រុមជាក់លាក់ ហើយខ្លះទៀតពន្យល់អំពីអង្គការស្ថាប័នសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ និងនីតិវិធីនៃអង្គការស្ថាប័នទាំងនេះ។ សលាកប័ត្រក៏ផ្តល់ជាការណែនាំជាក់ស្តែងអំពីរបៀបបំពេញការងារជាមួយនឹងកម្មវិធីសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិផងដែរ។

## ២. អត្ថបទស្តីពីបញ្ហាជាក់លាក់

**អត្ថបទស្តីពីបញ្ហាជាក់លាក់**សិក្សាស៊ីជម្រៅលើបញ្ហានានាដែលត្រូវបានជ្រើសរើស។ ប្រធានបទទាំងឡាយត្រូវបានជ្រើសរើសទៅតាមតំបន់ ភាពបន្ទាន់ និងការវិវឌ្ឍថ្មីៗ។ អត្ថបទស្តីពីបញ្ហាពិសេសថ្មីៗខ្លះរួមមាន៖ *ការអនុវត្តនៃអភិបាលកិច្ចល្អសម្រាប់ការពារសិទ្ធិមនុស្ស ការអះអាងអំពីគោលដៅអភិវឌ្ឍន៍សហសវត្សរ៍៖ វិធីសាស្ត្រតាមបែបសិទ្ធិមនុស្ស ឧបករណ៍នៃវិធានគតិយុត្តសម្រាប់ប្រទេសក្រោយជម្លោះ ការវាយតម្លៃប្រកបដោយប្រសិទ្ធិភាពនៃស្ថាប័នសិទ្ធិមនុស្សជាតិ* (ដែលត្រូវបានបោះពុម្ព

*រួមគ្នាជាមួយនឹងក្រុមប្រឹក្សាអន្តរជាតិស្តីពីគោលនយោបាយសិទ្ធិមនុស្ស* និង*សិទ្ធិបុគ្គលដែលពុំមែនជាពលរដ្ឋ*។

## ៣. ឯកសារបណ្តុះបណ្តាល និងអប់រំ

**ឯកសារបណ្តុះបណ្តាល និងអប់រំ**នៃការិយាល័យ OHCHR បង្ហាញនូវទិដ្ឋភាពទូទៅអំពីប្រព័ន្ធសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិព្រមទាំងឧបករណ៍អនុវត្តជាក់ស្តែងក្នុងកម្មវិធីបណ្តុះបណ្តាល និងអប់រំសម្រាប់បុគ្គលនានា ដូចជា នគរបាល មន្ត្រីពន្ធនាគារ ចៅក្រម សមាជិកសភា អ្នកឃ្លាំមើលសិទ្ធិមនុស្ស អ្នកឃ្លាំមើលការបោះឆ្នោត និងអ្នកធ្វើការផ្នែកសង្គមកិច្ច ក្រុម ឬ បុគ្គលជាក់លាក់។

**សៀវភៅបណ្តុះបណ្តាលវិជ្ជាជីវៈ**រួមមានសៀវភៅណែនាំ និងក្បួនណែនាំដើម្បីបង្កើនការយល់ដឹងអំពីបទដ្ឋានអន្តរជាតិ និងផ្តោតលើបុគ្គលទាំងឡាយដែលអាចមានឥទ្ធិពលលើស្ថានភាពសិទ្ធិមនុស្សនៅថ្នាក់ជាតិ។ ទោះបីជាសៀវភៅទាំងនេះត្រូវបានរៀបចំជាចំបងដើម្បីគាំទ្រសកម្មភាពបណ្តុះបណ្តាលនៃការិយាល័យ OHCHR ក៏ដោយ ក៏ឯកសារបោះពុម្ពផ្សាយទាំងនេះគឺជាឧបករណ៍ជាក់ស្តែងសម្រាប់អង្គការដែលផ្តល់ការអប់រំផ្នែកសិទ្ធិមនុស្សដល់ក្រុមវិជ្ជាជីវៈ។ សៀវភៅក្បួនស្តីពីការបណ្តុះបណ្តាលត្រូវបានសម្របទៅតាមតម្រូវការ និងបទពិសោធន៍ផ្អែកតាមវប្បធម៌ ការអប់រំ និងប្រវត្តិសាស្ត្ររបស់អ្នកអាននៅក្នុងក្រុមគោលដៅ។ ក្នុងករណីសមស្រប ព័ត៌មានស្តីពីបច្ចេកទេសគរុកោសល្យក៏ត្រូវបានដាក់បញ្ចូលដើម្បីជួយជ្រោមជ្រែងដល់គ្រូបណ្តុះបណ្តាលក្នុងការប្រើប្រាស់សៀវភៅក្បួនទាំងនេះផងដែរ។

**សៀវភៅអប់រំផ្នែកសិទ្ធិមនុស្ស**រួមមានឯកសារគាំទ្រកិច្ចខិតខំប្រឹងប្រែងលើការអប់រំទូទៅផ្នែកសិទ្ធិមនុស្សដោយគ្រប់ដៃគូទាំងអស់។ សៀវភៅនេះរួមមានព័ត៌មានអំពីកម្មវិធីពិភពលោកស្តីពីការអប់រំផ្នែកសិទ្ធិមនុស្ស ការសិក្សាអំពីការអប់រំផ្នែកសិទ្ធិមនុស្ស និងសន្និសញ្ញាសិទ្ធិមនុស្ស កម្រងនៃបទប្បញ្ញត្តិស្តីពីលិខិតុបករណ៍អន្តរជាតិ និងតំបន់លើកឡើងអំពីការអប់រំផ្នែកសិទ្ធិមនុស្ស និងកូនសៀវភៅដែលផ្តល់នូវមតិប្រឹក្សាជាក់ស្តែងដល់គ្រូអប់រំ និងគ្រូបង្រៀន។

សៀវភៅចុងក្រោយនោះគឺ**សៀវភៅមគ្គុទេសក៍**ដែលរួមមានព័ត៌មានសម្រាប់ក្រុម ឬ បុគ្គលជាក់លាក់ស្តីពីវិធីស្វែងរកការពារសិទ្ធិតាមរយៈការប្រើប្រាស់នីតិវិធីអន្តរជាតិ និងតំបន់ផ្សេងៗគ្នា។ សៀវភៅនេះរួមមាន*សៀវភៅមគ្គុទេសក៍សម្រាប់ជនជាតិដើមភាគតិច* និង *សៀវភៅមគ្គុទេសក៍សម្រាប់ជនជាតិភាគតិច* ដែលរួមមានកូនសៀវភៅតូចៗចំនួន ១៤ ក្បាលស្តីពីវិធីដែលជនជាតិភាគតិចអាចប្រើប្រាស់យន្តការនីតិវិធីសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ និងយន្តការថ្នាក់តំបន់។

៤. ឯកសារយោង

**ឯកសារយោង**បង្ហាញអ្នកសិក្សាស្រាវជ្រាវ និងអ្នកអនុវត្តច្បាប់សិទ្ធិមនុស្សអំពីលិខិតុបករណ៍សិទ្ធិមនុស្សសំខាន់ៗ និងព័ត៌មានចាំបាច់ផ្សេងទៀត។ ឧទាហរណ៍នានាត្រូវបានដាក់បញ្ចូលនៅក្នុងកម្រងលិខិតុបករណ៍សិទ្ធិមនុស្សទាំងនេះ ដូចជា *សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិចំបងថ្មីៗ* និងយុត្តិសាស្ត្រនៃគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស ដូចជា *សេចក្តីសម្រេចដែលត្រូវបានជ្រើសរើសរបស់គណកម្មាធិការសិទ្ធិមនុស្សក្រោមពិធីសារបន្ថែម* ឬ *សេចក្តីសម្រេចដែលត្រូវបានជ្រើសរើសរបស់គណកម្មាធិការប្រឆាំងនឹងទារុណកម្ម*។

## ៥. ឯកសារមូលដ្ឋានស្តីពីសិទ្ធិមនុស្ស

ឯកសារដែលរួមមានផ្ទាំងស្តីពីប្រធានបទសិទ្ធិមនុស្សទាំងនេះមានគោលបំណងបង្ហាញដល់សាធារណជនអំពីការងារសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ និងផ្តល់ចម្លើយតបទៅនឹងសំនួរនានាដែលត្រូវបានសួរជាញឹកញាប់អំពីកម្មវិធីសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ។

*វិធីទទួលបានឯកសារបោះពុម្ពផ្សាយ*

ការិយាល័យ OHCHR ផ្តល់បច្ចុប្បន្នភាពញឹកញាប់លើ**បញ្ជីស្តីពីឯកសារបោះពុម្ពផ្សាយ**។ ឯកសារបោះពុម្ពផ្សាយភាគច្រើននៃការិយាល័យ OHCHR ត្រូវបានផលិតឡើងជាភាសាផ្លូវទាំង ៦ ភាសារបស់អង្គការសហប្រជាជាតិ រួមមាន ភាសាអារ៉ាប់ (A) ភាសាចិន (C) ភាសាអង់គ្លេស (E) ភាសាបារាំង (F) ភាសារុស្ស៊ី (R) និងភាសាអេស្ប៉ាញ (S)។

ឯកសារបោះពុម្ពផ្សាយដែលមានសញ្ញាសម្គាល់ (w) គឺសម្រាប់ទាញយកដោយមិនគិតថ្លៃពី**គេហទំព័រនៃការិយាល័យ OHCHR**។ ចំណងជើងនៃឯកសារបោះពុម្ពផ្សាយដែលមានសញ្ញាសម្គាល់ (*) គឺជា**ឯកសារបោះពុម្ពផ្សាយនៃអង្គការសហប្រជាជាតិទុកសម្រាប់លក់** និងអាចជាវបានពីតាមបណ្ណាបណ្ណាគារ និងសាខាចែកចាយនៅទូទាំងពិភពលោក។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រនៃបណ្ណាគាររបស់អង្គការសហប្រជាជាតិនៅបុរីញូវយ៉ក (អ្នកអាននៅក្នុងទ្វីបអាស៊ី និងប៉ាស៊ីហ្វិក អាមេរិកឡាទីន និងអាមេរិចខាងជើង) ឬក្នុងទីក្រុងហ្សឺណែវ (អ្នកអាននៅក្នុងទ្វីបអាហ្វ្រិក ទ្វីបអឺរ៉ុប និងមជ្ឈិមបូព៌ា)។

i. សម្រាប់ព័ត៌មានបច្ចុប្បន្នស្តីពីឯកសារបោះពុម្ពផ្សាយនៃការិយាល័យ OHCHR សូមចូលទៅកាន់គេហទំព័រនៃឯកសារបោះពុម្ពផ្សាយរបស់ការិយាល័យ OHCHR។

តួអង្គសង្គមស៊ីវិលដែលមានបំណងទទួលបានសារអេឡិចត្រូនិចនៅពេលមានឯកសារបោះពុម្ពផ្សាយថ្មីៗនោះ សូមសរសេរមកកាន់ publications@ohchr.org។

i. ឯកសារបោះពុម្ពផ្សាយភាគច្រើននៃការិយាល័យ OHCHR អាចរកបានតាមប្រព័ន្ធអនឡាញ។ លើសពីនេះទៀត ច្បាប់ថតចម្លងជាក្រដាសក្នុងចំនួនតិចតួចស្តីពីព័ត៌មានជាក់លាក់ និង សកម្មភាពបណ្តុះបណ្តាលអាចបញ្ជាទិញបានតាមរយៈ៖

បញ្ជរព័ត៌មាន និងឯកសារបោះពុម្ពផ្សាយ
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8–14, avenue de la Paix
CH–1211 ទីក្រុងហ្សឺណែវ 10
ប្រទេសស្វីស
ទូរស័ព្ទ: +41 (0)22 928 92 24
ទូរសារ: +41 (0)22 928 90 10
អ៊ីមែល: publications@ohchr.org

នៅពេលបញ្ជាទិញឯកសារបោះពុម្ពផ្សាយណាមួយនៃការិយាល័យ OHCHR សូមលោកអ្នកបញ្ជាក់ឲ្យបានច្បាស់៖

- គោលបំណងនៃការប្រើប្រាស់ឯកសារបោះពុម្ពផ្សាយទាំងនេះ។ សូមផ្តល់ព័ត៌មានអំពីវគ្គបណ្តុះបណ្តាល គោលបំណង កាលបរិច្ឆេទ អ្នកចូលរួម។ល។ លោកអ្នកក៏អាចផ្តល់មតិយោបល់ត្រឡប់មកវិញមកក្រោយវគ្គបណ្តុះបណ្តាល ឬ ព្រឹត្តិការណ៍បង្ហាញព័ត៌មានតាមរយៈប្រៃសណីយ ឬ តាមរយៈអ៊ីមែល
- ចំនួនច្បាប់ដែលស្នើសុំបញ្ជាទិញឯកសារបោះពុម្ពផ្សាយនីមួយៗ
- ឈ្មោះបុគ្គលសម្រាប់ទាក់ទង
- ឈ្មោះអង្គការ (ប្រសិនមាន)
- អាសយដ្ឋានប្រៃសណីយ៍
- ទូរស័ព្ទ
- ទូរសារ
- អ៊ីមែល

ដើម្បីទាញយកបែបបទបញ្ជាទិញឯកសារបោះពុម្ពផ្សាយ សូមចូលទៅកាន់ទំព័រឯកសារបោះពុម្ពផ្សាយនៃការិយាល័យ OHCHR។ ប្រសិនបើមាននៅក្នុងឃ្លាំង អ្នកបញ្ជាទិញអាចមកទទួលយកឯកសារបោះពុម្ពផ្សាយដែលបានបញ្ជាទិញនៅការិយាល័យអង្គការសហប្រជាជាតិដែលនៅក្បែរអ្នក

ប្រសិនបើអាច។ សូមបញ្ជាក់ថា ចំនួនមានកំណត់ ហើយកន្លែងដាក់ពណ៌ខ្មៅនៅលើបញ្ជីមានន័យថា ឯកសារបោះពុម្ពផ្សាយមិនមាននៅក្នុងឃ្លាំងនោះទេ។

អ្នកបោះពុម្ពផ្សាយក្នុងក្របខណ្ឌពាណិជ្ជកម្មដែលមានបំណងបោះពុម្ពឡើងវិញ ឬ ផលិតឡើងវិញចេញពីឯកសារបោះពុម្ពផ្សាយដោយការិយាល័យ OHCHR សូមបញ្ជូនសំណើសុំមកកាន់ការិយាល័យអង្គការសហប្រជាជាតិនៅទីក្រុងហ្សឺណែវ ផ្នែកលក់ Palais des Nations, 8–14, avenue de la Paix, CH–1211 ទីក្រុងហ្សឺណែវ 10, ប្រទេសស្វីស អ៊ីមែល: unpubli@unog.ch។

## ខ. បណ្ណាល័យនៃការិយាល័យ OHCHR

**បណ្ណាល័យនៃការិយាល័យ OHCHR** នៅក្នុងទីក្រុងហ្សឺណែវផ្តល់ព័ត៌មានលម្អិត និងឯកសារយោងដល់ដៃគូនៃការិយាល័យ OHCHR យន្តការ និងអ្នកជំនាញនៃអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងបុគ្គលិកនៃការិយាល័យ OHCHR។ បណ្ណាល័យនេះរួមមានកម្រងឯកសារដោយឡែកស្តីពីសិទ្ធិមនុស្ស ឯកសារបោះពុម្ពផ្សាយ និងឯកសារផ្សេងទៀតជាទម្រង់ក្រដាស និងអេឡិចត្រូនិច។ បណ្ណាល័យនេះដែលច្របាច់បញ្ចូលគម្រោងធនធានស្តីពីការអប់រំ និងការបណ្តុះបណ្តាលក៏ភ្ជាប់ទំនាក់ទំនងជាមួយនឹងអង្គការសហប្រជាជាតិ និងបណ្ណាល័យ ព្រមទាំងស្ថាប័នស្រាវជ្រាវធំៗផ្សេងទៀតនៅជុំវិញពិភពលោកដោយផ្តល់ឯកសារយោង និងការស្រាវជ្រាវជូនដល់អ្នកប្រើប្រាស់ផងដែរ។

បណ្ណាល័យនៃការិយាល័យ OHCHR បើកជូនសហគមន៍អន្តរជាតិ និងអ្នកវិជ្ជាជីវៈដែលមានការចាប់អារម្មណ៍ពីខាងក្រៅអង្គការផងដែរ។ អង្គការ NGOs ដែលមានមូលដ្ឋាននៅទីក្រុងហ្សឺណែវ និងដែលត្រូវបានទទួលសិទ្ធិពីការិយាល័យអង្គការសហប្រជាជាតិនៅទីក្រុងហ្សឺណែវហើយនោះត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់បណ្ណាល័យនេះ។ សមាជិកអង្គការ NGOs ផ្សេងទៀត និងតួអង្គសង្គមស៊ីវិលអាចទទួលបានស្លាកសិទ្ធិប្រើប្រាស់បណ្ណាល័យក្នុងរយៈពេលបណ្តោះអាសន្នបាន។

បណ្ណាល័យនេះបើកដំណើរការពីថ្ងៃចន្ទ ដល់ ថ្ងៃសុក្រ ពេលព្រឹកចាប់ផ្តើមពីម៉ោង ៩:៣០ ដល់ម៉ោង ១២:៣០ និងពេលរសៀលចាប់ផ្តើមពីម៉ោង ២:០០ ដល់ ម៉ោង ៥:០០។ អ្នកចូលទស្សនាត្រូវមានបណ្ណសម្គាល់ដែលមានបិទរូបថតត្រឹមត្រូវ (ស្លាកអង្គការសហប្រជាជាតិ លិខិតឆ្លងដែន អត្តសញ្ញាណបណ្ណ ឬ បណ្ណបើកបរ)។ សៀវភៅឯកសារយោងពុំអាចបើកឲ្យសាធារណជនខ្ចីបាននោះទេ ហើយត្រូវប្រើប្រាស់នៅក្នុងបណ្ណាល័យតែប៉ុណ្ណោះ។ សិទ្ធិប្រើប្រាស់បណ្ណាល័យត្រូវគោរពតាម**វិធាន និងបទបញ្ជានៃបណ្ណាល័យរបស់**ការិយាល័យ OHCHR។ ការិយាល័យ OHCHR សូមអធ្យាស្រ័យចំពោះការពុំអនុញ្ញាតឲ្យអនីតិជនដែលពុំមាននីតិជនមកជាមួយចូលបណ្ណាល័យ។

*វិធីទាក់ទងបណ្ណាល័យនៃការិយាល័យ OHCHR*

i. **បណ្ណាល័យនៃការិយាល័យ OHCHR មានទីតាំងនៅជាន់ផ្ទាល់ដីក្នុងអាគារ Guiseppe Motta** (48, Avenue Giuseppe Motta, ទីក្រុងហ្សឺណែវ)។

បណ្ណាល័យនេះបើកដំណើរការពីថ្ងៃចន្ទ ដល់ ថ្ងៃសុក្រ ពេលព្រឹកចាប់ផ្តើមពីម៉ោង ៩:៣០ ដល់ម៉ោង ១២:៣០ និងពេលរសៀលចាប់ផ្តើមពីម៉ោង ២:០០ ដល់ ម៉ោង ៥:០០។ អ្នកចូលទស្សនាត្រូវមានបណ្ណសម្គាល់ដែលមានបិទរូបថតត្រឹមត្រូវ (ស្លាកអង្គការសហប្រជាជាតិ លិខិតឆ្លងដែន អត្តសញ្ញាណបណ្ណ ឬ បណ្ណបើកបរ)។

ទូរស័ព្ទ: +41 (0)22 928 97 90
ទូរសារ: +41 (0)22 928 90 65
អ៊ីមែល: library@ohchr.org

## គ. ឯកសារធនធានផ្សេងទៀតនៃការិយាល័យ OHCHR

**គេហទំព័រនៃការិយាល័យ OHCHR** គឺជាធនធានដ៏មានប្រយោជន៍សម្រាប់ស្វែងរកឯកសារបោះពុម្ពផ្សាយ ឯកសារយោង និងឯកសារផ្សេងទៀតពាក់ព័ន្ធនឹងយន្តការសិទ្ធិមនុស្សអន្តរជាតិ និងសកម្មភាពនៃការិយាល័យ OHCHR។ ទំព័រដំបូងនៃគេហទំព័រ OHCHR មានប្រអប់សម្រាប់ស្វែងរកដែលនាំអ្នកប្រើប្រាស់ទៅរកព័ត៌មានស្តីពីសិទ្ធិមនុស្ស រួមទាំង ឯកសារផ្លូវការនានាទៅតាមប្រទេស បញ្ហា ឬ ចំណាប់អារម្មណ៍វិជ្ជាជីវៈ។

ឯកសារផ្លូវការទាំងអស់នៃអង្គការសហប្រជាជាតិក៏អាចប្រើប្រាស់ក្នុងប្រព័ន្ធអនឡាញតាមរយៈ**ប្រព័ន្ធឯកសារផ្លូវការ**នៃអង្គការសហប្រជាជាតិ។

មជ្ឈមណ្ឌលសារព័ត៌មាន

*សេចក្តីថ្លែងការណ៍ និងសេចក្តីប្រកាសព័ត៌មានពាក់ព័ន្ធនឹងសកម្មភាពនៃការិយាល័យ OHCHR និងយន្តការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិអាចប្រើប្រាស់ក្នុងប្រព័ន្ធអនឡាញតាមរយៈមជ្ឈមណ្ឌលសារព័ត៌មាន។ ព័ត៌មានថ្មីៗ ប្រតិទិននៃកិច្ចប្រជុំ និងព្រឹត្តិការណ៍នានា សេចក្តីថ្លែងការណ៍របស់ឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស និងសេចក្តីប្រកាសព័ត៌មានដែលបានដាក់នៅក្នុងបណ្ណាសារដ្ឋានអាចរកបានតាមរយៈគេហទំព័រនៃការិយាល័យ OHCHR។*

*អ្នកសារព័ត៌មានដែលមានបំណងស្នើសុំព័ត៌មាន កិច្ចសម្ភាសន៍ ឬ យោបល់ សូមទាក់ទងផ្នែកគមនាគមន៍តាមរយៈ៖*

អ៊ីមែល: press-info@ohchr.org

ទូរស័ព្ទ: +41 (0)22 917 97 67 (អ្នកនាំពាក្យនៃការិយាល័យ OHCHR)

+41 (0)22 917 93 83 (មន្ត្រីព័ត៌មាន)

i. **ដើម្បីទទួលបានសារប្រាប់ព័ត៌មានតាមរយៈអ៊ីមែល សូមបញ្ជូនសំណើសុំមកកាន់** press-info@ohchr.org។

សម្រាប់ព័ត៌មានស្តីពីធនធានជាក់លាក់នៃការិយាល័យ OHCHR ពាកព័ន្ធនឹងអង្គការស្ថាប័ន និងយន្តការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ សូមពិគ្រោះជំពូកពាក់ព័ន្ធនៅក្នុង*សៀវភៅណែនាំ*នេះ។

## IV. គណកម្មាធិការសិទ្ធិសញ្ញាសន្ធិមនុស្ស

## ទិដ្ឋភាពសង្ខេបនៃគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស

| | | |
|---|---|---|
| តើគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សជាអ្វី?<br><br>**គណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស** គឺជាគណកម្មាធិការអ្នកជំនាញដែលឃ្លាំមើលការអនុវត្តសន្ធិសញ្ញាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិដោយរដ្ឋភាគីតាមរយៈការពិនិត្យរបាយការណ៍ដែលបានដាក់តាមកាលកំណត់ដោយរដ្ឋភាគីស្តីពីដំណាក់កាលក្នុងការអនុវត្តបទប្បញ្ញត្តិនៃសន្ធិសញ្ញា។ គណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សភាគច្រើនមានសមត្ថភាពទទួល និងពិចារណាបណ្តឹងជាលក្ខណៈបុគ្គល ចំណែកគណកម្មាធិការខ្លះទៀតអាចធ្វើការស្រាវជ្រាវ។ **អនុគណកម្មាធិការទប់ស្កាត់ទារុណកម្ម**ត្រូវបានប្រគល់ភារកិច្ចឲ្យធ្វើទស្សនកិច្ចដល់ទីកន្លែងដែលអាចមានការដកហូតសេរីភាពរបស់ប្រជាពលរដ្ឋ ដើម្បីទប់ស្កាត់ទារុណកម្ម។ | តើគណកម្មាធិការទាំងនេះបំពេញការងារតាមវិធីណា?<br><br>ក្រៅពីកាតព្វកិច្ចអនុវត្តបទប្បញ្ញត្តិសំខាន់ៗនៅក្នុងសន្ធិសញ្ញាដែលខ្លួនជាភាគី រដ្ឋសមាជិកនីមួយៗត្រូវដាក់របាយការណ៍ទៀងទាត់ស្តីពីវិធីដែលខ្លួនបានអនុវត្តបទប្បញ្ញត្តិសន្ធិសញ្ញា។ គណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សពាក់ព័ន្ធពិចារណារបាយការណ៍ទាំងនេះ ដោយមានវត្តមានគណប្រតិភូនៃរដ្ឋសមាជិក និងដោយផ្អែកលើព័ត៌មានទាំងអស់រួមទាំងព័ត៌មានជាលាយលក្ខណ៍អក្សរបន្ថែមដែលផ្តល់ជូនដោយរដ្ឋភាគី ព្រមទាំងព័ត៌មានដែលផ្តល់ជូនដោយផ្ទាល់មាត់នៅក្នុងអំឡុងពេលពិចារណារបាយការណ៍។ គណកម្មាធិការទាំងនេះក៏ទទួលព័ត៌មានពីភ្នាក់ងារអង្គការសហប្រជាជាតិ ស្ថាប័នសិទ្ធិមនុស្សជាតិ (ស្ថាប័ន NHRIs) និងតួអង្គសង្គមស៊ីវិលជាពិសេស អង្គការមិនមែនរដ្ឋាភិបាល | (អង្គការ NGOs) សមាជិកវិជ្ជាជីវៈ និងស្ថាប័នសិក្សាស្រាវជ្រាវ។<br><br>ផ្អែកតាមដំណើរការនេះ គណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សប្រើប្រាស់នីតិវិធីទូទៅមួយពេលគឺ "សេចក្តីសង្កេតសរុប" ដែលបង្ហាញអំពីទិដ្ឋភាពវិជ្ជមាននៃការអនុវត្តសន្ធិសញ្ញាដោយរដ្ឋភាគី និងវិស័យនានាដែលគណកម្មាធិការផ្តល់អនុសាសន៍ដល់រដ្ឋភាគីដើម្បីចាត់វិធានការបន្ថែម។ |

សៀវភៅណែនាំនេះអាចរកមើលបានក្នុងទម្រង់ឌីជីថលនៅលើគេហទំព័រនៃការិយាល័យ OHCHR តាមរយៈ៖ http://www.ohchr.org/civilsocietyhandbook/
នៅលើគេហទំព័រនេះ លោកអ្នកនឹងអាចទាញយកជំពូកទាំងឡាយនៅក្នុងសៀវភៅណែនាំនេះបានព្រមទាំងទំព័រតភ្ជាប់ទៅកាន់ឯកសារយោងទាំងអស់ដែលមាននៅក្នុងឯកសារបោះពុម្ពផ្សាយ។

| | | |
|---|---|---|
| ក្រៅពីពិចារណាលើរបាយការណ៍របស់រដ្ឋភាគី គណកម្មាធិការសន្ធិសញ្ញាក៏បំពេញមុខងារផ្សេងទៀតដើម្បីពង្រឹងការអនុវត្តសន្ធិសញ្ញាផងដែរ៖<br><br>• **គណកម្មាធិការសិទ្ធិ មនុស្ស, គណកម្មាធិការទទួលបន្ទុកការលុបបំបាត់ការរើសអើងពូជសាសន៍, គណកម្មាធិការប្រឆាំងនឹងទារុណកម្ម, គណកម្មាធិការទទួលបន្ទុកការការពារសិទ្ធិពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ, គណកម្មាធិការស្តីពីសិទ្ធិជនពិការ** និងគណកម្មាធិការស្តីពីការបាត់ខ្លួនដោយបង្ខំ (មិនទាន់បានបង្កើតឡើងនៅឡើយគិតមកត្រឹមឆ្នាំ២០០៨) អាចពិចារណាបណ្តឹង ឬលិខិតឆ្លើយឆ្លងមកពីបុគ្គល (ឬ ក្រុម បុគ្គលនានាដូចក្នុងករណីគណកម្មាធិការស្តីពីការលុបបំបាត់រាល់ការរើសអើសពូជសាសន៍, គណកម្មាធិការស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ និង | គណកម្មាធិការស្តីពីសិទ្ធិជនពិការ) ដែលបានអះអាងថារដ្ឋភាគីបានរំលោភសិទ្ធិរបស់ពួកគេ។ នៅពេលចូលជាធរមាន ពិធីសារបន្ថែមនៃ **កតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នឹង** អនុញ្ញាតឲ្យដាក់បណ្តឹងជាលក្ខណៈបុគ្គល។ នៅក្នុងយន្តការដាក់បណ្តឹងទាំងនេះ គណកម្មាធិការសន្ធិសញ្ញាអាចអនុវត្តវិធានការបណ្តោះអាសន្ននៅក្នុងករណីបន្ទាន់ដើម្បីរក្សាស្ថានភាពដូចដើមរហូតពេលគណកម្មាធិការអាចធ្វើសេចក្តីសម្រេចស្ថាពរលើបញ្ហានោះ។<br><br>• គណកម្មាធិការប្រឆាំងនឹងទារុណកម្ម គណកម្មាធិការស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ គណកម្មាធិការស្តីពីសិទ្ធិជនពិការ និង គណកម្មាធិការស្តីពីការបាត់ខ្លួនដោយបង្ខំអាចផ្តួចផ្តើមការស្រាវជ្រាវបានប្រសិនបើខ្លួនបានទទួលព័ត៌មានអាចទុកចិត្តបានអំពី | • គណកម្មាធិការស្តីពីការលុបបំបាត់ការរើសអើងពូជសាសន៍, គណកម្មាធិការសិទ្ធិមនុស្ស, គណកម្មាធិការប្រឆាំងនឹងទារុណកម្ម, គណកម្មាធិការស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ និង គណកម្មាធិការស្តីពីពលករទេសន្តរប្រវេសន៍មាននីតិវិធីសម្រាប់ដោះស្រាយបណ្តឹង ឬជម្លោះអន្តររដ្ឋ និង<br><br>• គណកម្មាធិការស្តីពីការលុបបំបាត់រាល់ការរើសអើងពូជសាសន៍បានបង្កើតនីតិវិធីស្តីពីវិធានការដាស់តឿន និងចំណាត់ការបន្ទាន់។<br><br>គណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សអនុម័តសេចក្តីពន្យល់ទូទៅ និងកោះប្រជុំពិភាក្សាលើប្រធានបទជាក់លាក់ដើម្បីផ្តល់ការណែនាំសំខាន់ៗលើការអនុវត្ត។<br><br>តើប្រើប្រាស់ និងធ្វើការងារជាមួយនឹងគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សតាមរបៀបណា?<br><br>បំពេញការងារជាមួយនឹងគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សគឺជាវិធីដ៏មានប្រសិទ្ធភាពមួយសម្រាប់សង្គមស៊ីវិលក្នុងការចូលរួមចំណែកនៅក្នុងការ អនុវត្តសិទ្ធិមនុស្ស និងការអភិវឌ្ឍវិធានការសិទ្ធិ |

| | | |
|---|---|---|
| | សញ្ញាបញ្ជាក់ណាមួយ ដែលមានមូលដ្ឋានត្រឹមត្រូវអំពីការរំលោភធ្ងន់ធ្ងរ ហួសហេតុ ឬ ជាលក្ខណៈប្រព័ន្ធលើសន្ធិសញ្ញានៅក្នុងរដ្ឋភាគី។ | មនុស្ស។ មានវិធីជាច្រើនដែលសង្គមស៊ីវិលអាចចូលរួមធ្វើការងារជាមួយនឹងប្រព័ន្ធសន្ធិសញ្ញាសិទ្ធិមនុស្សខណៈពិចារណាលើការរៀបចំជាក់លាក់នៃគណកម្មាធិការសន្ធិសញ្ញានីមួយៗ |

| | | |
|---|---|---|
| ឧទាហរណ៍៖<br>• ជម្រុញការផ្តល់សច្ចាប័នលើសន្ធិសញ្ញា<br>• ឃ្លាំមើលអនុលោមភាពដោយរដ្ឋភាគីជាមួយនឹងកាតព្វកិច្ចធ្វើរបាយការណ៍របស់ពួកគេ<br>• ដាក់ព័ត៌មានជាលាយលក្ខណ៍អក្សរ និងសម្ភារៈនានាជូនគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សរួមទាំង តាមរយៈរបាយការណ៍ជាលាយលក្ខណ៍អក្សរ | • ផ្អែកមូលដ្ឋានលើវិធានស្តីពីគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សនីមួយៗ, ចូលរួមនៅក្នុងសម័យប្រជុំនៃគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សក្នុងនាមជាអ្នកសង្កេតការណ៍ ឬ តាមរយៈបទបង្ហាញផ្ទាល់មាត់<br>• បន្តតាមដានលើសេចក្តីសង្កេតការណ៍សរុបនៃគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស<br>• ដាក់បណ្តឹងជាលក្ខណៈបុគ្គលជូនគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស (គណកម្មាធិការសិទ្ធិមនុស្ស, គណកម្មាធិការស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ, គណកម្មាធិការប្រឆាំងនឹងទារុណកម្ម, គណកម្មាធិការស្តីពីការ | លុបបំបាត់ការរើសអើងពូជសាសន៍ និងគណកម្មាធិការស្តីពីពលករទេសន្តរប្រវេសន៍<br>• ផ្តល់ព័ត៌មានដើម្បីបង្កើតការស្រាវជ្រាវសម្ងាត់ (គណកម្មាធិការប្រឆាំងនឹងទារុណកម្ម និងគណកម្មាធិការស្តីពីការលុបបំបាត់ការរើសអើសប្រឆាំងនឹងស្ត្រីភេទ)<br>• ផ្តល់ព័ត៌មានសម្រាប់ការដាស់តឿន និងចំណាត់បន្ទាន់ (គណកម្មាធិការស្តីពីការរើសអើងពូជសាសន៍) និង<br>• ដាក់បទបង្ហាញជូនអន្តរគណកម្មាធិការប្រចាំឆ្នាំនៃគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស។ |

i. ទំនាក់ទំនងគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស

គ្រប់គណកម្មាធិការទាំងអស់អាចទាក់ទងបានតាមរយៈការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅទីក្រុងហ្សឺណែវនៅអាសយដ្ឋានៈ

**[ឈ្មោះគណកម្មាធិការ]**

c/o ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

8–14, avenue de la Paix

CH–1211 ទីក្រុងហ្សឺណែវ 10 - ប្រទេសស្វីស

ទូរសារ: +41 (0)22 917 90 29

## ក. តើអ្វីទៅដែលហៅថាគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស?

សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិចំនួន ៩ ដែលត្រូវបានឃ្លាំមើលដោយគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សបង្កើតកាតព្វកិច្ចផ្លូវច្បាប់លើរដ្ឋដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស។ នៅពេលរដ្ឋទទួលស្គាល់សន្ធិសញ្ញាសិទ្ធិមនុស្សតាមរយៈការផ្តល់សច្ចាប័ន[31] ឬ ការចូលជាសមាជិក[32] រដ្ឋនឹងក្លាយជារដ្ឋភាគីនៃសន្ធិសញ្ញានោះ ហើយត្រូវមានកាតព្វកិច្ចផ្លូវច្បាប់អនុវត្តសិទ្ធិនានាដូចមានចែងនៅក្នុងសន្ធិសញ្ញា[33]។ សន្ធិសញ្ញាទាំងឡាយមានបទប្បញ្ញត្តិចែងអំពីការបង្កើត**គណកម្មាធិការអន្តរជាតិនៃអ្នកជំនាញឯករាជ្យ** (គណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស) ដើម្បីឃ្លាំមើលការអនុវត្តបទប្បញ្ញត្តិនៅក្នុងបណ្តាប្រទេសដែលបានផ្តល់សច្ចាប័ន ឬ ចូលជាសមាជិកនៃសន្ធិសញ្ញា[34]។

---

31 ការផ្តល់សច្ចាប័ន ការទទួលស្គាល់ និងការទទួលយកសំដៅលើកិច្ចដែលរដ្ឋបានបង្ហាញការយល់ព្រមថានឹងគោរពតាមសន្ធិសញ្ញា។ នៅមុនពេលផ្តល់សច្ចាប័ន ហត្ថលេខាលើសន្ធិសញ្ញាក៏បង្កើតកាតព្វកិច្ចចំពោះរដ្ឋនៅក្នុងអំឡុងចន្លោះពេលចុះហត្ថលេខា និងផ្តល់សច្ចាប័ន ការទទួលស្គាល់ ឬ ការទទួលយកដើម្បីទប់ស្កាត់ក្នុងន័យសុចរិតពីសកម្មភាពដែលអាចប្រឆាំងនឹងកម្មវត្ថុ និងគោលបំណងនៃសន្ធិសញ្ញាណាមួយ (សូមមើលមាត្រា ១៨ **នៃអនុសញ្ញាទីក្រុងវីយ៉ែនឆ្នាំ១៩៦៩ស្តីពីច្បាប់សន្ធិសញ្ញា**)។

32 ការចូលជាភាគីគឺជាកិច្ចរបស់រដ្ឋពុំបានចុះហត្ថលេខាលើសន្ធិសញ្ញាបង្ហាញការយល់ព្រមក្លាយជាភាគីនៃសន្ធិសញ្ញានោះដោយតម្កល់ "លិខិតុបករណ៍នៃការចូលជាភាគី" នៅអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ។ ការចូលជាភាគីមានអានុភាពផ្លូវច្បាប់ដូចគ្នានឹងការផ្តល់សច្ចាប័ន ការទទួលស្គាល់ ឬ ការទទួលយក។

33 លើកលែងតែបទប្បញ្ញត្តិនៃសន្ធិសញ្ញាដែលរដ្ឋបានចុះឧប្បញ្ញត្តិព្យួរសិទ្ធិ។ ឧប្បញ្ញត្តិព្យួរសិទ្ធិគឺជាសេចក្តីថ្លែងការណ៍របស់រដ្ឋដោយអះអាងដកចេញ ឬ កែប្រែអានុភាពផ្លូវច្បាប់នៃបទប្បញ្ញត្តិនៃសន្ធិសញ្ញានៅក្នុងការអនុវត្តចំពោះរដ្ឋនោះ។ ឧប្បញ្ញត្តិព្យួរសិទ្ធិអាចឲ្យរដ្ឋចូលរួមនៅក្នុងសន្ធិសញ្ញាពហុភាគីដែលរដ្ឋមិនអាច ឬ មិនស្ម័គ្រចិត្តចូលរួម។ រដ្ឋអាចប្រកាសឧប្បញ្ញត្តិព្យួរសិទ្ធិនៅក្នុងសន្ធិសញ្ញាបាននៅពេលចុះហត្ថលេខា ផ្តល់សច្ចាប័ន ទទួលស្គាល់ ទទួលយក ឬ ចូលជាភាគីនៃសន្ធិសញ្ញា។ ឧប្បញ្ញត្តិព្យួរសិទ្ធិមិនអាចផ្ទុយពីកម្មវត្ថុ និងគោលបំណងនៃសន្ធិសញ្ញានោះឡើយ។

34 កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ពុំចែងច្បាស់លាស់អំពីការបង្កើតគណកម្មាធិការសន្ធិសញ្ញានោះទេ ក៏ប៉ុន្តែផ្តល់អាណត្តិការងារទូទៅជូនក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម (ក្រុមប្រឹក្សា ECOSOC) ក្នុងការឃ្លាំមើលការអនុវត្ត។ នៅក្នុងឆ្នាំ១៩៨៥ ក្រុមការងារសម័យប្រជុំដែលបានបង្កើតឡើងដោយក្រុមប្រឹក្សា ECOSOC ដើម្បីជួយជ្រោមជ្រែងការពិចារណារបាយការណ៍របស់រដ្ឋភាគីត្រូវបានបង្កើតឡើងវិញតាមគម្រូវនៃគណកម្មាធិការសន្ធិសញ្ញា ហើយដាក់ឈ្មោះថា "គណកម្មាធិការទទួលបន្ទុកសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌" (សេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សា ECOSOC

ប្រព័ន្ធគណកម្មាធិការសន្ធិសញ្ញានៃអង្គការសហប្រជាជាតិដើរតួនាទីយ៉ាងសំខាន់នៅក្នុងការពង្រឹងការការពារសិទ្ធិមនុស្សនៅថ្នាក់ជាតិ។ គណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សមានបេសកកម្មចំបងដូចគ្នា ពោលគឺ **ឃ្លាំមើលការអនុវត្តសន្ធិសញ្ញាពាក់ព័ន្ធ**តាមរយៈការពិនិត្យមើលរបាយការណ៍ដែលរដ្ឋភាគីបានដាក់ជូនតាមកាលកំណត់។

គណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សមានចំនួន ៩ គិតមកត្រឹមខែកញ្ញា ឆ្នាំ២០០៨៖

- **គណកម្មាធិការសិទ្ធិមនុស្ស៖** ឃ្លាំមើលការអនុវត្ត**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ** (ឆ្នាំ១៩៦៦) និងពិធីសារបន្ថែម។
- **គណកម្មាធិការស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌៖** ឃ្លាំមើលការអនុវត្តកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ឆ្នាំ១៩៦៦)។
- **គណកម្មាធិការស្តីពីការលុបបំបាត់ការរើសអើងពូជសាសន៍៖** ឃ្លាំមើលការអនុវត្តអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (ឆ្នាំ១៩៦៥)។
- **គណកម្មាធិការស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ៖** ឃ្លាំមើលការអនុវត្តកតិកាសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (ឆ្នាំ១៩៧៩)។
- **គណកម្មាធិការប្រឆាំងនឹងទារុណកម្ម៖** ឃ្លាំមើលការអនុវត្តអនុសញ្ញាប្រឆាំងនឹងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬ ទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬ បន្ថោកបន្ទាប (ឆ្នាំ២០០២)។
- **គណកម្មាធិការស្តីពីសិទ្ធិកុមារ៖** ឃ្លាំមើលការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ (ឆ្នាំ១៩៨៩) និងពិធីសារបន្ថែម។
- **គណកម្មាធិការស្តីពីពលករទេសន្តរប្រវេសន៍ ៖** តាមដានការអនុវត្តអនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ (ឆ្នាំ១៩៩០) និង
- **គណកម្មាធិការស្តីពីសិទ្ធិជនពិការ៖** ឃ្លាំមើលការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ (ឆ្នាំ២០០៦)[35]។

---

លេខ ១៩៨៥/១៧)។ គណកម្មាធិការនេះបានជួបប្រជុំលើកដំបូងនៅក្នុងឆ្នាំ១៩៨៧ ហើយត្រូវបានចាត់ទុកជាគណកម្មាធិការសន្ធិសញ្ញា។

[35] ការផ្តល់សច្ចាប័ន ឬ ការចូលជាភាគីនៃសន្ធិសញ្ញាសិទ្ធិមនុស្សដោយរដ្ឋបានកើនឡើងយ៉ាងខ្លាំងនៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។ គិតមកត្រឹមខែកញ្ញា ឆ្នាំ២០០៨ រដ្ឋភាគីចំនួន ១៦២ ជាភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ រដ្ឋភាគី ១៥៩ ជាភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង

គណៈកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សទី១០ ពោលគឺ គណៈកម្មាធិការស្ដីពីការបាត់ខ្លួនដោយបង្ខំនឹងត្រូវបានបង្កើតឡើងនៅពេលអនុសញ្ញាអន្តរជាតិស្ដីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ (ឆ្នាំ២០០៦) ចូលជាធរមាន[36]។

ដូចបានគូសបញ្ជាក់ខាងលើ សន្ធិសញ្ញាខ្លះត្រូវបានបំពេញបន្ថែមដោយពិធីសារបន្ថែមដែលរដ្ឋភាគីនៃសន្ធិសញ្ញាអាចផ្ដល់សច្ចាប័នបាន[37]។ ពិធីសារបន្ថែមចែងបន្ថែមអំពីសិទ្ធិសារធាតុ ឬ រួមបញ្ចូលនីតិវិធីឃ្លាំមើលបន្ត។ សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិមានពិធីសារបន្ថែមចំនួន ៧៖

- ពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។
- ពិធីសារបន្ថែមទីពីរនៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលមានគោលបំណងលុបបំបាត់ចោលទោសប្រហារជីវិត។
- ពិធីសារបន្ថែមនៃអនុសញ្ញាស្ដីពីការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ។
- ពិធីសារបន្ថែមនៃអនុសញ្ញាស្ដីពីសិទ្ធិកុមារពាក់ព័ន្ធនឹងការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ។
- ពិធីសារបន្ថែមនៃអនុសញ្ញាស្ដីពីសិទ្ធិកុមារលើការលក់កុមារ ពេស្យាកម្មកុមារ និងរូបភាព ឬសម្ភារៈអាសអាភាសលើកុមារ។
- ពិធីសារបន្ថែមនៃ អនុសញ្ញាប្រឆាំងនឹងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬ ទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬ បន្ថោកបន្ទាប និង
- ពិធីសារបន្ថែមនៃអនុសញ្ញាស្ដីពីសិទ្ធិជនពិការ[38]។

---

វប្បធម៌ រដ្ឋភាគី ១៧៣ ជាភាគីនៃអនុសញ្ញាអន្តរជាតិស្ដីពីការលុបបំបាត់រាល់ការរើសអើងពូជសាសន៍ រដ្ឋភាគី ១៨៥ ជាភាគីនៃអនុសញ្ញាស្ដីពីការលុបំបាត់រាល់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ រដ្ឋភាគី ១៤៥ ជាភាគីនៃអនុសញ្ញាប្រឆាំងនឹងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬ ទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ និងបន្ថោកបន្ទាប រដ្ឋភាគី ១៩៣ ជាភាគីនៃអនុសញ្ញាស្ដីពីសិទ្ធិកុមារ រដ្ឋភាគី ៣៩ ជាភាគីនៃអនុសញ្ញាអន្តរជាតិស្ដីពីការការពារពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ និងរដ្ឋភាគី ៤០ ជាភាគីនៃអនុសញ្ញាស្ដីពីសិទ្ធិជនពិការ។

[36] គិតមកត្រឹមខែកញ្ញា ឆ្នាំ២០០៨ រដ្ឋភាគីចំនួន ៥ ជាភាគីនៃអនុសញ្ញាអន្តរជាតិស្ដីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ។ សន្ធិសញ្ញានេះនឹងចូលជាធរមាននៅពេលមានរដ្ឋចំនួន ២០ បានផ្ដល់សច្ចាប័ន ឬ ចូលជាភាគី។

[37] រដ្ឋអាចផ្ដល់សច្ចាប័នលើពិធីសារបន្ថែមនៃអនុសញ្ញាស្ដីពីសិទ្ធិកុមារបានប្រសិនបើរដ្ឋជាភាគីហត្ថលេខីនៃអនុសញ្ញា ប៉ុន្តែពុំបានផ្ដល់សច្ចាប័ន ឬ ចូលជាភាគីនៃអនុសញ្ញានេះ។

ក្រុមប្រឹក្សាសិទ្ធិមនុស្សបានអនុម័តពិធីសារបន្ថែមនៃ**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌**នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៨[39]។

គណៈកម្មាធិការរួមមានអ្នកជំនាញឯករាជ្យចន្លោះពី ១០ ទៅ ២៣ នាក់ដែលមានជំនាញទទួលស្គាល់ខាងវិស័យសិទ្ធិមនុស្ស។ អ្នកជំនាញទាំងអស់នេះត្រូវបានជ្រើសតាំង និងបោះឆ្នោតជ្រើសរើសដោយរដ្ឋភាគីសម្រាប់រយៈពេល ៤ ឆ្នាំ ហើយនឹងអាចបន្តសមាជិកភាពបាន។ សន្ធិសញ្ញាថ្មីៗបានកម្រិតសមាជិកភាពនៃគណៈកម្មាធិការសន្ធិសញ្ញាត្រឹមតែពីរដងតែប៉ុណ្ណោះ។

គណៈកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សទាំងអស់ត្រូវបានផ្តល់សេវាដោយអង្គភាពសន្ធិសញ្ញា និងឃ្លាំមើលនៃ**សាខាសន្ធិសញ្ញាសិទ្ធិមនុស្សនៃការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស** (ការិយាល័យ OHCHR) ដែលទទួលឯកសារ របាយការណ៍ និងលិខិតឆ្លើយឆ្លងសម្រាប់ដាក់ជូនគណៈកម្មាធិការសន្ធិសញ្ញា រៀបចំរបាយការណ៍ ធ្វើការស្រាវជ្រាវ ផ្តល់កិច្ចសហប្រត្តិបត្តិការបច្ចេកទេស មគ្គុទេសក៍ និងយោបល់ប្រឹក្សាដល់រដ្ឋភាគី រៀបចំកិច្ចប្រជុំ និងបំពេញការងារលទ្ធកម្មផ្សេងទៀតទៅតាមតម្រូវការនៃគណៈកម្មាធិការសន្ធិសញ្ញា។

សម័យប្រជុំគណៈកម្មាធិការសន្ធិសញ្ញាទាំងអស់ត្រូវបានរៀបចំឡើងនៅក្នុងទីក្រុងហ្សឺណែវ ឬ ញូវយ៉ក[40] (ចំពោះនៅទីក្រុងហ្សឺណែវ ជាទូទៅ គឺនៅអាគារធំ Palais Wilson នៃការិយាល័យ OHCHR ហើយនឹងពេលខ្លះនៅអាគារ)។ ការិយាល័យ OHCHR កំពុងធ្វើច្រកចេញចូលចូលបន្ទប់ប្រជុំ ប្រើប្រាស់ឯកសារ និងបច្ចេកវិទ្យាដើម្បីឲ្យអ្នកជំនាញ គណៈប្រតិភូ និងតំណាងសង្គមស៊ីវិលដែលមានពិការភាពអាចមានលទ្ធភាពចូលរួមនៅក្នុងការងារនៃគណៈកម្មាធិការសន្ធិសញ្ញា។

---

[38] គិតមកត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៨ រដ្ឋភាគីចំនួន ១១១ ជាភាគីនៃពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ រដ្ឋភាគី ៦៨ ជាភាគីនៃពិធីសារបន្ថែមទីពីរនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលមានគោលបំណងលុបបំបាត់ចោលទោសប្រហារជីវិត រដ្ឋភាគី ៩២ ជាភាគីនៃពិធីសារបន្ថែមនៃអនុសញ្ញាអនុសញ្ញាស្តីពីការលុបំបាត់រាល់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ រដ្ឋភាគី ១២៣ ជាភាគីនៃពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារពាក់ព័ន្ធនឹងការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ រដ្ឋភាគី ១២៩ ជាភាគីនៃពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារលើការលក់កុមារ ពេស្យាកម្មកុមារ និងរូបភាព ឬ សម្ភារៈអាសអាភាសលើកុមារ រដ្ឋភាគី ៣៥ ជាភាគីនៃពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងនឹងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬ ទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ និងបន្ថោកបន្ទាប និងរដ្ឋភាគី ២៤ ជាភាគីនៃពិធីសារបន្ថែមនៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិជនពិការ។

[39] មហាសន្និបាតក៏រំពឹងថានឹងអនុម័តកតិកាសញ្ញានេះនៅក្នុងឆ្នាំ២០០៨ផងដែរ។

[40] សម័យប្រជុំ ("នានិទាឃរដូវ") នៃគណៈកម្មាធិការសិទ្ធិមនុស្សបានរៀបចំឡើងនៅញូវយ៉ក។ សម័យប្រជុំនៃគណៈកម្មាធិការស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទធ្វើឡើងនៅញូវយ៉ក និងទីក្រុងហ្សឺណែវ។

| ប្រព័ន្ធគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស | | |
|---|---|---|
| គណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស | សន្ធិសញ្ញាស្ថាបនិក | ពិធីសារបន្ថែមនៃសន្ធិសញ្ញាស្ថាបនិក |
| គណកម្មាធិការសិទ្ធិមនុស្ស បង្កើតឡើងនៅក្នុងឆ្នាំ១៩៧៧ | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (កតិកាសញ្ញាអន្តរជាតិ ICCPR) អនុម័តនៅក្នុងឆ្នាំ១៩៦៦ | ពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (អនុញ្ញាតបណ្តឹងជាលក្ខណៈបុគ្គលបាន) អនុម័តក្នុងឆ្នាំ១៩៦៦<br>ពិធីសារបន្ថែមទីពីរនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលមានគោលបំណងលុបបំបាត់ទោសប្រហារជីវិត អនុម័តក្នុងឆ្នាំ១៩៨៩ |
| គណកម្មាធិការទទួលបន្ទុកសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បង្កើតឡើងនៅក្នុងឆ្នាំ១៩៨៥ | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (កតិកាសញ្ញាអន្តរជាតិ ICESCR) បង្កើតឡើងនៅក្នុងឆ្នាំ១៩៦៦ | ពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ អនុម័តដោយក្រុមប្រឹក្សាសិទ្ធិមនុស្សនៅក្នុងខែមិថុនា ឆ្នាំ២០០៨។ ដោយសង្ឃឹមថាមហាសន្និបាតនឹងអនុម័តនៅក្នុងឆ្នាំ២០០៨ ពិធីសារបន្ថែមនេះអនុញ្ញាតបណ្តឹងជាលក្ខណៈបុគ្គលនៅពេលចូលជាធរមាន។ |
| គណកម្មាធិការទទួលបន្ទុកការលុបបំបាត់ការរើសអើងពូជសាសន៍ បង្កើតឡើងនៅក្នុងឆ្នាំ១៩៧០ | អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (អនុសញ្ញាអន្តរជាតិ ICERD) អនុម័តនៅក្នុងឆ្នាំ១៩៦៥ | គ្មានពិធីសារបន្ថែម |
| គណកម្មាធិការទទួលបន្ទុកការលុប | អនុសញ្ញាស្តីពីការលុបបំបាត់ | ពិធីសារបន្ថែមនៃ |

| | | |
|---|---|---|
| បំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ បង្កើតឡើងនៅក្នុងឆ្នាំ១៩៨២ | រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (អនុសញ្ញាអន្តរជាតិ CEDAW) អនុម័តនៅក្នុងឆ្នាំ១៩៧៩ | អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (ដែលអនុញ្ញាតឲ្យមានបណ្តឹងជាលក្ខណៈបុគ្គល និងការស្រាវជ្រាវ) អនុម័តនៅក្នុងឆ្នាំ១៩៩៩ |
| គណកម្មាធិការទទួលបន្ទុកប្រឆាំងនឹងទារុណកម្ម បង្កើតឡើងនៅក្នុងឆ្នាំ១៩៨៧ | អនុសញ្ញាប្រឆាំងនឹងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬ ទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ និងបន្ថោកបន្ទាប (អនុសញ្ញា CAT) អនុម័តនៅក្នុងឆ្នាំ១៩៨៤។ | សូមមើលប្រអប់បន្ទាប់ |
| អនុគណកម្មាធិការទទួលបន្ទុកការទប់ស្កាត់ទារុណកម្ម បង្កើតឡើងនៅក្នុងឆ្នាំ២០០៦ | ពិធីសារបន្ថែមនៃ អនុសញ្ញាប្រឆាំងនឹងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬ ទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ និងបន្ថោកបន្ទាប (ពិធីសារបន្ថែម OPCAT) (បង្កើតយន្តការឃ្លាំមើលថ្នាក់ជាតិ និងអន្តរជាតិ) អនុម័តនៅក្នុងឆ្នាំ២០០២។ | |
| គណកម្មាធិការទទួលបន្ទុកសិទ្ធិកុមារ បង្កើតឡើងនៅក្នុងឆ្នាំ១៩៩១ | អនុសញ្ញាស្តីពីសិទ្ធិកុមារ (អនុសញ្ញា CRC) អនុម័តនៅក្នុងឆ្នាំ១៩៨៩។ | ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារពាក់ព័ន្ធការចូលរួមនៅក្នុងជម្លោះប្រដាប់អាវុធអនុម័តនៅក្នុងឆ្នាំ២០០០<br><br>ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារលើការលក់កុមារ ពេស្យាកម្មកុមារ និងរូបថត និងសម្ភារៈ អាសអាភាសកុមារអនុម័តនៅក្នុងឆ្នាំ២០០០ |

| | | |
|---|---|---|
| គណៈកម្មាធិការទទួលបន្ទុកការការពារសិទ្ធិពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកក្រុមគ្រួសាររបស់ពួកគេ បង្កើតឡើងនៅក្នុងឆ្នាំ២០០៤ | អនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកក្រុមគ្រួសាររបស់ពួកគេ (អនុសញ្ញា ICRMW) អនុម័តនៅក្នុងឆ្នាំ១៩៩០។ | គ្មានពិធីសារបន្ថែម |
| គណៈកម្មាធិការទទួលបន្ទុកសិទ្ធិជនពិការបង្កើតឡើងនៅក្នុងឆ្នាំ២០០៨ | អនុសញ្ញាស្តីពីសិទ្ធិជនពិការអនុម័តនៅក្នុងឆ្នាំ២០០៦។ | ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិជនពិការ (ដែលអនុញ្ញាតបណ្តឹងជាលក្ខណៈបុគ្គល) អនុម័តនៅក្នុងឆ្នាំ២០០៦។ |
| គណៈកម្មាធិការទទួលបន្ទុកការបាត់ខ្លួនដោយបង្ខំ (មិនទាន់បង្កើតឡើងនៅឡើយត្រឹមខែកញ្ញា ឆ្នាំ២០០៨) | អនុសញ្ញាអន្តរជាតិស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ អនុម័តក្នុងឆ្នាំ២០០៦ (មិនទាន់អនុវត្តជាធរមានត្រឹមខែកញ្ញា ឆ្នាំ២០០៨) | គ្មានពិធីសារបន្ថែម |

i. ព័ត៌មាននៃការិយាល័យ OHCHR ស្តីពីគណៈកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស

លោកអ្នកអាចពិនិត្យមើលព័ត៌មានបន្ថែមអំពីសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ និងគណៈកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សបាននៅលើគេហទំព័រនៃការិយាល័យ OHCHR និងនៅក្នុងសលាកបត្រនៃការិយាល័យ OHCHR ដូចខាងក្រោម៖

- លេខ ១០ (វិ.លើកទី ១)៖ សិទ្ធិកុមារ
- លេខ ១២៖ គណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់ការរើសអើងពូជសាសន៍
- លេខ ១៥ (វិ.លើកទី ១)៖ សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖ គណៈកម្មាធិការសិទ្ធិមនុស្ស
- លេខ ១៦ (វិ.លើកទី ១) ៖ គណៈកម្មាធិការទទួលបន្ទុកសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- លេខ ១៧៖ គណៈកម្មាធិការទទួលបន្ទុកប្រឆាំងនឹងទារុណកម្ម
- លេខ ២២៖ ការរើសអើងប្រឆាំងនឹងស្ត្រីភេទ៖ អនុសញ្ញា និងគណៈកម្មាធិការ
- លេខ ២៤ (វិ.លើកទី ១)៖ អនុសញ្ញាអន្តរជាតិស្តីពីពលករទេសន្តរប្រវេសន៍ និងគណៈកម្មាធិការ
- លេខ ៣០៖ ប្រព័ន្ធសន្ធិសញ្ញាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ៖ សេចក្តីផ្តើមស្តីពីសន្ធិសញ្ញាសិទ្ធិមនុស្សសំខាន់ៗ និងគណៈកម្មាធិការសន្ធិសញ្ញា និង
- លេខ ៧ (វិ.លើកទី ១)៖ យន្តការនីតិវិធីបណ្តឹង

សូមចូលទៅកាន់គេហទំព័រនៃការិយាល័យ OHCHR សម្រាប់បញ្ជីថ្មីៗស្តីពីសលាកប័ត្រនៃការិយាល័យ OHCHR។

ដើម្បីស្វែងយល់បន្ថែមអំពីប្រព័ន្ធរបាយការណ៍របស់រដ្ឋភាគី សូមមើល*របាយការណ៍ស្តីពីវិធីបំពេញការងាររបស់គណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សពាក់ព័ន្ធនឹងដំណើរការធ្វើរបាយការណ៍របស់រដ្ឋភាគី* (HRI/MC/2008/4)។

## ខ. តើគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សបំពេញការងារយ៉ាងដូចម្តេច?

គណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សបំពេញមុខងារឃ្លាំមើលវិធីដែលរដ្ឋភាគីអនុវត្តសន្ធិសញ្ញា។ ទោះបីជាគណកម្មាធិការទាំងនេះសម្របសម្រួលសកម្មភាពរបស់ពួកគេក៏ដោយ នីតិវិធី និងការអនុវត្តរបស់ពួកគេមានលក្ខណៈខុសៗគ្នា។ ភាពខុសគ្នាសំខាន់ៗខ្លះដែលពាក់ព័ន្ធនឹងការងារសង្គមស៊ីវិលត្រូវបានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធនៅទំព័រចុងក្រោយក្នុងជំពូកនេះ។

### ១. កាតព្វកិច្ចធ្វើរបាយការណ៍របស់រដ្ឋភាគី

នៅពេលរដ្ឋមួយបានផ្តល់សច្ចាប័ន ឬ ចូលជាភាគីនៃសន្ធិសញ្ញារួចហើយ ក្រៅពីកាតព្វកិច្ចអនុវត្តបទប្បញ្ញត្តិសំខាន់ៗនៅក្នុងសន្ធិសញ្ញា រដ្ឋមានកាតព្វកិច្ចដាក់**របាយការណ៍តាមកាលកំណត់**ជូនទៅគណកម្មាធិការមានសមត្ថកិច្ចពាក់ព័ន្ធនឹងវិធានការនានាដែលរដ្ឋបានធ្វើឡើងដើម្បី អនុវត្តសន្ធិសញ្ញា។ របាយការណ៍ទាំងនេះត្រូវបញ្ចូលវិធានការច្បាប់ រដ្ឋបាល តុលាការ ឬ វិធានការផ្សេងៗទៀតដែលរដ្ឋបានអនុម័តសម្រាប់យកមកអនុវត្តបទប្បញ្ញត្តិនៃសន្ធិសញ្ញា និងផ្តល់ព័ត៌មានអំពីឧបសគ្គដែលរដ្ឋបានជួបប្រទះ។ របាយការណ៍ទាំងនេះនឹងយកមកពិនិត្យនៅដំណាក់កាលចុងក្រោយដោយគណកម្មាធិការពាក់ព័ន្ធដោយមានវត្តមានចូលរួមពីគណប្រតិភូតំណាងរដ្ឋនោះផងដែរ។

ជាធម្មតា **របាយការណ៍បឋម**ត្រូវដាក់ជូនក្នុងចន្លោះពេល ១ ឆ្នាំ ទៅ ២ ឆ្នាំក្រោយសន្ធិសញ្ញាចូលជាធរមាននៅក្នុងប្រទេសរបស់រដ្ឋភាគី។ របាយការណ៍ក្រោយៗទៀតត្រូវដាក់ជូនតាមកាលកំណត់ចន្លោះពី ២ ឆ្នាំ ទៅ ៥ ឆ្នាំអាស្រ័យទៅតាមបទប្បញ្ញត្តិនៃសន្ធិសញ្ញា និងសេចក្តីសម្រេចដែលបានធ្វើឡើងដោយគណកម្មាធិការ។ គណកម្មាធិការមួយចំនួនទទួលយករបាយការណ៍រួម ពោលគឺមានន័យថារដ្ឋភាគីមួយអាចដាក់របាយការណ៍តាមកាលកំណត់ចំនួន ២ ឬ ៣ ច្បាប់បញ្ចូលនៅក្នុងរបាយការណ៍រួមមួយតែម្តងជូនទៅគណកម្មាធិការ។ គណកម្មាធិការសន្ធិសញ្ញាភាគច្រើនកំណត់ពេលវេលាក្នុងការដាក់របាយការណ៍បន្ទាប់នៅក្នុងសេចក្តីសង្កេតសរុបរបស់ខ្លួន។

រដ្ឋភាគីត្រូវបានជម្រុញឲ្យមើលឃើញថា ការរៀបចំរបាយការណ៍របស់ពួកគេពុំមែនជាការបំពេញកាតព្វកិច្ចអន្តរជាតិប៉ុណ្ណោះនោះទេ វាគឺជាឱកាសក្នុងការវាយតម្លៃស្ថានភាពនៃការការពារសិទ្ធិមនុស្សនៅក្នុងប្រទេសរបស់គេក្នុងគោបំណងរៀបចំជាគោលនយោបាយ។

## ២. ការពិចារណានៃគណកម្មាធិការសន្ធិសញ្ញាលើរបាយការណ៍របស់រដ្ឋភាគី បញ្ជីស្តីពីបញ្ហា

នៅមុនសម័យប្រជុំដែលគណកម្មាធិការនឹងពិចារណាលើរបាយការណ៍របស់រដ្ឋភាគី គណកម្មាធិការរៀបចំ**បញ្ជីស្តីពីបញ្ហា** និងសំនួរដែលបញ្ជូនទៅរដ្ឋភាគី។ ជាធម្មតា រដ្ឋភាគីនឹងដាក់ចម្លើយតបរបស់ខ្លួនទៅនឹងបញ្ជីនេះជាលាយលក្ខណ៍អក្សរ។ ចម្លើយទាំងនោះត្រូវបានដាក់បង្ហាញនៅក្នុងគេហទំព័រនៃការិយាល័យ OHCHR។

ចម្លើយតបជាលាយលក្ខណ៍អក្សរទៅនឹងបញ្ជីស្តីពីបញ្ហាគឺជាការបំពេញបន្ថែមលើរបាយការណ៍របស់រដ្ឋភាគី ហើយមានសារសំខាន់ខ្លាំងណាស់នៅពេលមានការពន្យារពេលយូរនៅចន្លោះពេលដាក់របាយការណ៍តាមកាលកំណត់ និងពេលពិនិត្យមើលរបាយការណ៍។

គណកម្មាធិការទទួលបន្ទុកការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ គណកម្មាធិការទទួលបន្ទុកសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងគណកម្មាធិការទទួលបន្ទុកសិទ្ធិកុមារកោះប្រជុំក្រុមការងាររយៈពេលមួយសប្តាហ៍នៅមុនសម័យប្រជុំដើម្បីរៀបចំបញ្ជីស្តីពីបញ្ហា និងសំនួរពាក់ព័ន្ធនឹងរបាយការណ៍របស់រដ្ឋភាគីដែលនឹងត្រូវយកមកពិចារណានៅក្នុងពេលឆាប់ៗខាងមុខ។ គណកម្មាធិការសិទ្ធិមនុស្សចាត់តាំងការងារនេះទៅ**ក្រុមការងារទទួលបន្ទុករបាយការណ៍ប្រចាំប្រទេស**[41] ដែលជួបប្រជុំគ្នានៅមុនសម័យប្រជុំពិនិត្យមើលរបាយការណ៍របស់រដ្ឋ។

គណកម្មាធិការភាគីច្រើនតែងតាំងសមាជិកម្នាក់របស់ខ្លួនឲ្យបំពេញការងារជា**អ្នកធ្វើរបាយការណ៍ប្រចាំប្រទេស**ដើម្បីដឹកនាំនៅក្នុងការរៀបចំបញ្ជីស្តីពីបញ្ហាសម្រាប់ប្រទេសជាក់លាក់ណាមួយ។

ប្រភពព័ត៌មានផ្សេងទៀត

ក្រៅពីរបាយការណ៍របស់រដ្ឋភាគី គណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សអាចទទួលបានព័ត៌មានស្តីពីការអនុវត្តបទប្បញ្ញត្តិនៅក្នុងសន្ធិសញ្ញាពីភ្នាក់ងារនៃអង្គការសហប្រជាជាតិ មូលនិធិ និងកម្មវិធី អង្គការអន្តររដ្ឋាភិបាល ស្ថាប័នសិទ្ធិមនុស្សជាតិ (ស្ថាប័ន NHRIs) ព្រមទាំងសង្គមស៊ីវិលជាពិសេស អង្គការ NGOs (ទាំងជាតិ និងអន្តរជាតិ សមាគមវិជ្ជាជីវៈ និងស្ថាប័នសិក្សាអប់រំ។

ការពិចារណាលើរបាយការណ៍របស់រដ្ឋភាគី

[41] ក្រុមការងារទទួលបន្ទុករបាយការណ៍ប្រចាំប្រទេសរួមមានអ្នកធ្វើរបាយការណ៍ប្រចាំប្រទេស និងសមាជិកចំនួន ៤ ទៅ ៦ នាក់នៅក្នុងគណកម្មាធិការដែលត្រូវបានជ្រើសតាំងដោយប្រធាន។

រដ្ឋភាគីត្រូវបានអញ្ជើញឲ្យចូលរួមនៅក្នុងសម័យប្រជុំរបស់គណកម្មាធិការដើម្បីបង្ហាញរបាយការណ៍របស់ពួកគេ ដើម្បីឆ្លើយតបទៅនឹងសំនួររបស់សមាជិកគណកម្មាធិការ និងដើម្បីផ្តល់ព័ត៌មានបន្ថែមជូនគណកម្មាធិការ។ ក្រោយពីទទួលបានព័ត៌មានទាំងអស់រួចមក គណកម្មាធិការធ្វើការពិនិត្យរបាយការណ៍រួមគ្នាជាមួយនឹងតំណាងរដ្ឋាភិបាលក្នុងគោលបំណងចូលរួមក្នុងកិច្ចសន្ទនាក្នុងន័យស្ថាបនា និងជួយជ្រោមជ្រែងកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋក្នុងការអនុវត្តសន្ធិសញ្ញាឲ្យបានពេញលេញ និងប្រកបដោយប្រសិទ្ធភាព។ គណកម្មាធិការសន្ធិសញ្ញាពុំមែនជាស្ថាប័នតុលាការនោះទេ។ គណកម្មាធិការទាំងនេះគ្រាន់តែឃ្លាំមើលការអនុវត្ត និងផ្តល់ការលើកទឹកចិត្ត និងយោបល់ប្រឹក្សាជូនដល់រដ្ឋតែប៉ុណ្ណោះ។

i. ព័ត៌មានដែលត្រូវបានធ្វើបច្ចុប្បន្នភាពទៀងទាត់ស្តីពី**សម័យប្រជុំគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សនាពេលបន្តបន្ទាប់** និងរដ្ឋដែលគ្រោងនឹងចូលរួមនៅក្នុងសម័យប្រជុំទាំងនោះអាចពិនិត្យមើលបាននៅលើផ្នែកស្តីពីគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សក្នុងគេហទំព័រនៃការិយាល័យ OHCHR។

សេចក្តីសង្កេតសរុប និងអនុសាសន៍

ផ្អែកលើកិច្ចសន្ទនាជាមួយនឹងរដ្ឋ និងព័ត៌មានផ្សេងទៀតដែលទទួលបាន គណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សអនុវត្តនូវវិធីសាស្រ្តមួយដែលជាទូទៅហៅថា**សេចក្តីសង្កេតសរុប**[42]។ សេចក្តីសង្កេតសរុបនេះលើកឡើងទាំងផ្នែកវិជ្ជមាននៃការអនុវត្តសន្ធិសញ្ញាដោយរដ្ឋ និងចំណុចដែលគណកម្មាធិការសន្ធិសញ្ញាផ្តល់អនុសាសន៍ជូនរដ្ឋដើម្បីចាត់វិធានការបន្ថែម។ វាមានសារសំខាន់ណាស់ដែលរដ្ឋភាគីត្រូវធ្វើរបាយការណ៍តបជូនគណកម្មាធិការនៅក្នុងរបាយកាណ៍តាមកាលកំណត់នាពេលក្រោយដោយបង្ហាញអំពីវិធានការដែលរដ្ឋភាគីបានធ្វើឡើងដើម្បីអនុវត្តតាមអនុសាសន៍ទាំងនេះព្រមទាំងការអនុវត្តបទប្បញ្ញត្តិសន្ធិសញ្ញាផងដែរ។

## ការបន្តតាមដានអនុសាសន៍

ដើម្បីជួយរដ្ឋក្នុងការអនុវត្តអនុសាសន៍របស់ពួកគេ គណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សបានចាប់ផ្តើមណែនាំនីតិវិធីនានាដើម្បីធានានូវការបន្តតាមដានប្រកបដោយប្រសិទ្ធភាពលើសេចក្តីសង្កេតសរុបរបស់គណកម្មាធិការ។ គណកម្មាធិការខ្លះស្នើសុំនៅក្នុងសេចក្តីសង្កេតសរុបរបស់ពួកគេឲ្យរដ្ឋធ្វើរបាយការណ៍ត្រឡប់ទៅអ្នកធ្វើរបាយការណ៍ប្រចាំប្រទេស ឬ អ្នកធ្វើរបាយការណ៍បន្តតាមដាន នៅក្នុងរយៈពេលដែលបានឯកភាពណាមួយស្តីពីវិធានាការដែលបានធ្វើឡើងឆ្លើយតបទៅនឹងអនុសាសន៍

[42] គណកម្មាធិការខ្លះហៅថា "មតិយោបល់សរុប" ស្របទៅតាមពាក្យពេចន៍នៃសន្ធិសញ្ញារបស់ពួកគេ។

ជាក់លាក់ ឬ "កង្វល់អាទិភាព" នានា។ បន្ទាប់មក អ្នកធ្វើរបាយការណ៍នឹងដាក់របាយការណ៍តបជូនគណកម្មាធិការវិញ។

សមាជិកខ្លះនៃគណកម្មាធិការសន្ធិសញ្ញាបានធ្វើទស្សនកិច្ចនៅតាមបណ្តាប្រទេសនានាតាមការអញ្ជើញរបស់រដ្ឋភាគីដើម្បីបន្តតាមដានរបាយការណ៍ និងការអនុវត្តសេចក្តីសង្កេតសរុប។

## ៣. ការពិចារណាលើបណ្តឹងពីបុគ្គលដែលបានអះអាងថា រដ្ឋភាគីបានរំលោភសិទ្ធិរបស់ពួកគេ

ក្នុងករណីដែលលក្ខខណ្ឌមួយចំនួនត្រូវបានបំពេញ គណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សចំនួន ៧ ពិចារណាលើបណ្តឹង ឬ **លិខិតឆ្លើយឆ្លងពីបុគ្គល**ដែលបានអះអាងថា រដ្ឋភាគីបានរំលោភសិទ្ធិរបស់ពួកគេ។ គណកម្មាធិការទាំងនេះរួមមានគណកម្មាធិការទទួលបន្ទុកការលុបបំបាត់ការរើសអើងពូជសាសន៍ គណកម្មាធិការសិទ្ធិមនុស្ស គណកម្មាធិការទទួលបន្ទុកប្រឆាំងនឹងទារុណកម្ម គណកម្មាធិការទទួលបន្ទុកការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ គណកម្មាធិការទទួលបន្ទុកពលករទេសន្តរប្រវេសន៍ គណកម្មាធិការទទួលបន្ទុកសិទ្ធិជនពិការ និងគណកម្មាធិការទទួលបន្ទុកការបាត់ខ្លួនដោយបង្ខំ។ **គិតត្រឹមខែកញ្ញា ឆ្នាំ២០០៨ យន្តការបណ្តឹងនៃគណកម្មាធិការទទួលបន្ទុកពលករទេសន្តរប្រវេសន៍ពុំទាន់បានអនុវត្តនៅឡើយទេ ហើយយន្តការបណ្តឹងនៃគណកម្មាធិការទទួលបន្ទុកការបាត់ខ្លួនដោយបង្ខំក៏ពុំទាន់បានបង្កើតឡើងដែរ។** ក្រោយពេលចូលជាធរមាន ពិធីសារបន្ថែមនៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នឹងអនុញ្ញាតឲ្យបណ្តឹងជាលក្ខណៈផងដែរ។

គណកម្មាធិការសន្ធិសញ្ញាមិនអាចពិចារណាបណ្តឹងទាំងឡាយណាដែលពាក់ព័ន្ធនឹងរដ្ឋភាគីនោះទេលើកលែងតែរដ្ឋបានទទួលស្គាល់សមត្ថកិច្ចនេះយ៉ាងជាក់លាក់តាមរយៈការធ្វើសេចក្តីប្រកាសនៅក្នុងមាត្រានៃសន្ធិសញ្ញាពាក់ព័ន្ធ ឬ តាមរយៈការទទួលស្គាល់ពិធីសារបន្ថែមពាក់ព័ន្ធណាមួយ។

i. សម្រាប់ព័ត៌មានបន្ថែមស្តីពី**បណ្តឹងជាលក្ខណៈបុគ្គល** សូមអានជំពូក VIII **(ការដាក់បណ្តឹងចោទប្រកាន់អំពីការរំលោភសិទ្ធិមនុស្ស)** នៅក្នុងសៀវភៅណែនាំនេះ។

សម្រាប់ព័ត៌មានលម្អិតអំពីបណ្តឹងបុគ្គលដែលបានដាក់ប្តឹងទៅគណកម្មាធិការសិទ្ធិមនុស្ស (ក៏ត្រូវបានហៅថា ញត្តិផងដែរ) រួមមានយោបល់ប្រឹក្សា និងសេចក្តីណែនាំស្តីពីរបៀបដាក់បណ្តឹង លោកអ្នកអាចពិនិត្យមើលបាននៅក្នុងផ្នែកស្តីពីគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សក្នុងគេហទំព័រនៃការិយាល័យ OHCHR។

## ៤. បណ្តឹង និងវិវាទអន្តររដ្ឋ

សន្ធិសញ្ញាសិទ្ធិមនុស្សខ្លះរួមមានបទប្បញ្ញត្តិអនុញ្ញាតឲ្យរដ្ឋភាគីប្តឹងទៅគណកម្មាធិការសន្ធិសញ្ញាពាក់ព័ន្ធអំពីការចោទប្រកាន់ការរំលោភសន្ធិសញ្ញាដោយរដ្ឋភាគីមួយទៀត។ **គិតមកត្រឹមខែកញ្ញា ឆ្នាំ២០០៨ នីតិវិធីទាំងនេះពុំទាន់ត្រូវបានប្រើប្រាស់នៅឡើយនោះទេ។**

## ៥. កិច្ចស្រាវជ្រាវ

គណកម្មាធិការសន្ធិសញ្ញាចំនួន ៤ ពោលគឺ គណកម្មាធិការទទួលបន្ទុកប្រឆាំងនឹងទារុណកម្ម គណកម្មាធិការទទួលបន្ទុកការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ គណកម្មាធិការទទួលបន្ទុកសិទ្ធិជនពិការ និងគណកម្មាធិការទទួលបន្ទុកការបាត់ខ្លួនដោយបង្ខំ (ក្រោយពេលបង្កើតឡើង) អាចផ្តួចផ្តើមកិច្ចស្រាវជ្រាវសម្ងាត់ប្រសិនបើបានទទួលព័ត៌មានអាចទុកចិត្តបាន ដូចជា ការចង្អុលបង្ហាញដែលមានមូលដ្ឋានជាក់លាក់អំពីការរំលោភធ្ងន់ធ្ងរ ហួសហេតុ ឬ ជាលក្ខណៈប្រព័ន្ធលើអនុសញ្ញានានានៅក្នុងរដ្ឋភាគីណាមួយ។ កិច្ចស្រាវជ្រាវនេះមិនអាចធ្វើឡើងចំពោះរដ្ឋភាគីដែលពុំទទួលយកនីតិវិធីនេះ ហើយដែលបានដកចេញយ៉ាងច្បាស់នូវសមត្ថកិច្ចនៃគណកម្មាធិការពាក់ព័ន្ធក្នុងការបំពេញកិច្ចស្រាវជ្រាវ[43]។

ក្នុងករណីចាំបាច់ និងក្នុងករណីមានការយល់ព្រមពីរដ្ឋភាគី កិច្ចសាកសួរអាចរួមបញ្ចូលទស្សនកិច្ចទៅតាមរដ្ឋផងដែរ។ ក្រោយពីពិនិត្យរបកគំហើញនៃកិច្ចស្រាវជ្រាវនេះ គណកម្មាធិការដាក់របកគំហើញនេះជូនទៅរដ្ឋភាគីពាក់ព័ន្ធរួមជាមួយនឹងមតិយោបល់ និងអនុសាសន៍។

នីតិវិធីស្តីពីកិច្ចស្រាវជ្រាវត្រូវរក្សាការសម្ងាត់ ហើយគណកម្មាធិការត្រូវស្នើសុំកិច្ចសហការពីរដ្ឋភាគីនៅក្នុងអំឡុងពេលនៃកិច្ចដំណើរការស្រាវជ្រាវនេះ។

i. សម្រាប់ព័ត៌មានបច្ចុប្បន្នស្តីពី**កិច្ចស្រាវជ្រាវ** លោកអ្នករកមើលបាននៅក្នុង**សលាកប័ត្រលេខ ៣០ ស្តីពីប្រព័ន្ធសន្ធិសញ្ញាសន្ធិមនុស្សនៃអង្គការសហប្រជាជាតិ**។

## ៦. នីតិវិធីដាស់តឿនបឋម និងចំណាត់ការបន្ទាន់

ចាប់តាំងពីឆ្នាំ១៩៩៣មក គណកម្មាធិការស្តីពីការលុបបំបាត់ការរើសអើងពូជសាសន៍បានបង្កើតនីតិវិធីពាក់ព័ន្ធនឹង**ការដាស់តឿនបឋម និងចំណាត់ការបន្ទាន់**[44]។ នីតិវិធីដាស់តឿនបឋម

---

[43] នៅពេលផ្តល់សច្ចាប័ន ឬ ចូលជាភាគី រដ្ឋភាគីនៃអនុសញ្ញាប្រឆាំងនឹងទារុណកម្មអាចធ្វើសេចក្តីប្រកាសមិនទទួលស្គាល់សមត្ថកិច្ចមួយនេះអនុលោមតាមមាត្រា ២៨។ រដ្ឋភាគីនៃពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទអាចមិនដាក់បញ្ចូលសមត្ថកិច្ចស្រដៀងគ្នារបស់គណកម្មាធិការតាមរយៈសេចក្តីប្រកាសាអនុលោមតាមមាត្រា ១០។ រដ្ឋណាមួយដែលប្រកាសមិនទទួលស្គាល់នីតិវិធីនេះអាចសម្រេចទទួលយកនីតិវិធីវិញនាពេលក្រោយ។

[44] សូមមើល A/48/18 ឧបសម្ព័ន្ធ III។

មានគោលបំណងទប់ស្កាត់បញ្ហាដែលកើតមានស្រាប់នៅក្នុងរដ្ឋភាគីកុំឲ្យឈានទៅរកវិវាទថ្មីមួយ ឬ ដើម្បីទប់ស្កាត់កុំឲ្យវិវាទកើតឡើងវិញ។ នីតិវិធីចំណាត់ការបន្ទាន់មានគោលបំណងឆ្លើយតបទៅនឹងបញ្ហាដែលតម្រូវឲ្យមានការយកចិត្តទុកដាក់ភ្លាមៗដើម្បីទប់ស្កាត់ ឬ កម្រិតវិសាលភាព ឬ ចំនួននៃការរំលោភធ្ងន់ធ្ងរលើអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍។ តាមការអនុវត្តជាក់ស្តែង នីតិវិធីទាំងនេះត្រូវបានប្រើប្រាស់ដំណាលគ្នា ហើយអាចប្រើប្រាស់ដោយគណកម្មាធិការខ្លួនឯង ឬ ដោយភាគីមានប្រយោជន៍ដូចជាក្រុមជនជាតិដើមភាគតិច និងរួមទាំងតួអង្គសង្គមស៊ីវិលផងដែរ។

## ៧. សេចក្តីពន្យល់ទូទៅ

គណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សនីមួយៗបោះពុម្ពផ្សាយការបកស្រាយបញ្ញត្តិនៃសន្ធិសញ្ញាសិទ្ធិមនុស្សដែលខ្លួនតាមដានក្នុងទម្រង់ជា**សេចក្តីពន្យល់ទូទៅ** (គណកម្មាធិការទទួលបន្ទុកការលុបបំបាត់ការរើសអើងពូជសាសន៍ និងគណកម្មាធិការទទួលបន្ទុកការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទប្រើប្រាស់ពាក្យ "អនុសាសន៍ទូទៅ")។

សេចក្តីពន្យល់ទូទៅផ្តល់ការណែនាំស្តីពីការអនុវត្តអនុសញ្ញាដោយរួមបញ្ចូលប្រធានបទផ្សេងៗរាប់ទាំងការបកស្រាយលម្អិតលើបទបញ្ញត្តិសារធាតុរហូតដល់ការណែនាំទូទៅស្តីពីព័ត៌មានលើមាត្រាជាក់លាក់នៅក្នុងសន្ធិសញ្ញាដែលរដ្ឋគួរដាក់បញ្ចូលនៅក្នុងរបាយការណ៍របស់ពួកគេ។

i. **សេចក្តីពន្យល់ទូទៅ និងអនុសាសន៍ទូទៅ**ដែលបានប្រើប្រាស់ដោយគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សត្រូវបានចងក្រងជារៀងរាល់ឆ្នាំ។ ដើម្បីពិនិត្យមើលយោបល់ និងព័ត៌មានទាំងនេះស្តីពី**កាលបរិច្ឆេទនៃកិច្ចពិភាក្សានាពេលខាងមុខ** សូមចូលទៅកាន់ផ្នែក**ស្តីពីគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សនៃគេហទំព័ររបស់ការិយាល័យ OHCHR**។

## ៨. កាលបរិច្ឆេទនៃការពិភាក្សាទូទៅ/ការដេញដោលលើវិស័យប្រធានបទ

គណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សជាច្រើនបានកំណត់កាលបរិច្ឆេទនៃការពិភាក្សាទូទៅលើវិស័យប្រធានបទជាក់លាក់ ឬ បញ្ហាកង្វល់នានា។ ជាទូទៅ ការពិភាក្សាលើវិស័យប្រធានបទទាំងនេះបើកចំហឲ្យសាធារណជនចូលរួម ដូចជា ដៃគូអង្គការសហប្រជាជាតិ គណប្រតិភូមកពីរដ្ឋភាគី និងតួអង្គសង្គមស៊ីវិល ជាពិសេស អង្គការ NGOs គ្រឹះស្ថានអប់រំ សមាគមវិជ្ជាជីវៈ និងអ្នកជំនាញ។ លទ្ធផលនៃការពិភាក្សានេះអាចជួយជ្រោមជ្រែងដល់គណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សនៅក្នុងការធ្វើសេចក្តីព្រាងសេចក្តីពន្យល់ទូទៅថ្មីៗ ហើយវាក៏អាចជួយរដ្ឋ និងភាគីពាក់ព័ន្ធផ្សេងទៀតស្វែងយល់អំពីលក្ខខណ្ឌតម្រូវនៃសន្ធិសញ្ញា។

## ៩. កិច្ចប្រជុំប្រចាំឆ្នាំនៃប្រធានគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស និងកិច្ចប្រជុំអន្តរគណកម្មាធិការ

**កិច្ចប្រជុំប្រចាំឆ្នាំនៃប្រធានគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស និងកិច្ចប្រជុំអន្តរគណកម្មាធិការ**រៀបចំឡើងនៅទីក្រុងហ្សឺណែវ ហើយជាវេទិកាសម្រាប់សមាជិកគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សពិភាក្សាការងារ និងពិចារណាវិធីធ្វើយ៉ាងណាឲ្យប្រព័ន្ធគណកម្មាធិការសន្ធិសញ្ញាទាំងមូលកាន់តែមានប្រសិទ្ធភាពជាងមុន។ បញ្ហានានាដែលបានលើកឡើងនៅក្នុងកិច្ចប្រជុំទាំងនេះបានដាក់បញ្ចូលការបង្កើនជារួម និងការបញ្ជៀបបញ្ចូលនីតិវិធីធ្វើរបាយការណ៍ស្តីពីសិទ្ធិមនុស្ស សុខដុមរមនីយកម្មនៃនៃវិធីបំពេញការងាររបស់គណកម្មាធិការ ការបន្តតាមដានសន្និសីទពិភពលោក និងបញ្ហាហិរញ្ញវត្ថុ។ កិច្ចពិគ្រោះយោបល់ក្រៅផ្លូវការជាមួយនឹងរដ្ឋភាគីព្រមទាំងជាមួយនឹងដៃគូអង្គការសហប្រជាជាតិ និងអង្គការ NGOs ក៏ត្រូវបានបញ្ចូលនៅក្នុងកិច្ចប្រជុំរបស់ប្រធាននេះផងដែរ។

**កិច្ចប្រជុំអន្តរគណកម្មាធិការ**រួមបញ្ចូលប្រធាន និងសមាជិកពីររូបបន្ថែមទៀតមកពីគណកម្មាធិការនីមួយៗ។ តំណាងគណកម្មាធិការកាន់តែច្រើននៅក្នុងកិច្ចប្រជុំអន្តរគណកម្មាធិការនឹងធ្វើឲ្យការពិភាក្សាលើអនុសាសន៍អំពីបញ្ហានានាទាក់ទងនឹងវិធីសាស្រ្តបំពេញការងារកាន់តែក្បោះក្បាយ ហើយបញ្ហាផ្សេងៗទៀតអាចពិភាក្សាទៅបានផងដែរនៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់ប្រធាន។

i. សម្រាប់ព័ត៌មានបច្ចុប្បន្នស្តីពី**កិច្ចប្រជុំប្រចាំឆ្នាំនៃប្រធានគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស និងកិច្ចប្រជុំអន្តរគណកម្មាធិការ** សូមចូលទៅកាន់គេហទំព័រនៃការិយាល័យ OHCHR។

## ៩. កំណែទម្រង់គណកម្មាធិការសន្ធិសញ្ញា

នីតិវិធី និងវិធីបំពេញការងារនៃគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សត្រូវបានយកមកពិភាក្សាជាបន្តបន្ទាប់ ហើយនឹងត្រូវបានចាត់ទុកថាជាផ្នែកមួយនៃកំណែទម្រង់ប្រព័ន្ធឲ្យមានលក្ខណៈទូលំទូលាយដែលអង្គការសហប្រជាជាតិបានធ្វើឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ[45]។ មកទល់បច្ចុប្បន្ន

---

[45] នៅក្នុងរបាយការណ៍ឆ្នាំ២០០២ "ការពង្រឹងអង្គការសហប្រជាជាតិ៖ របៀបវារៈសម្រាប់ការផ្លាស់ប្តូរបន្ថែមទៀត" (A/57/387 និងកំណែលើកទី១) អតីតអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ លោក Kofi Anna បានអំពាវនាវឲ្យគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សឲ្យបង្កើតវិធីសាស្រ្តរួមគ្នាមួយអនុវត្តចំពោះសកម្មភាពរបស់គណកម្មាធិការ។ នៅក្នុងខែមីនា ឆ្នាំ២០០៥ នៅក្នុងរបាយការណ៍ "ក្នុងក្របខណ្ឌសេរីភាពធំធេងជាងមុន៖ ដំណើរឆ្ពោះទៅរកការអភិវឌ្ឍ សន្តិសុខ និងសិទ្ធិមនុស្សសម្រាប់យើងទាំងអស់គ្នា" អគ្គលេខាធិការបានស្នើសុំឲ្យ " ពិនិត្យសម្រេចចុងក្រោយ និងអនុវត្តគោលការណ៍រួមគ្នាស្តីពីការធ្វើរបាយការណ៍ជូនគណកម្មាធិការសន្ធិសញ្ញា

កំណែទម្រង់គណៈកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សបានផ្តោតលើការសម្របសម្រួល និងសុខដុមរមនីយកម្មលើវិធីបំពេញការងារ រួមទាំងការអនុម័ត "បទដ្ឋានអនុវត្តល្អៗ" និងការបញ្ចៀបចូលនៃលក្ខខណ្ឌធ្វើរបាយការណ៍របស់រដ្ឋភាគីតាមរយៈការប្រើប្រាស់**ឯកសារចំបងរួម** និងរបាយការណ៍ដែលផ្តោតលើសន្ធិសញ្ញាជាក់លាក់[46]។

លើសពីនេះ គណៈកម្មាធិការសិទ្ធិមនុស្សកំពុងធ្វើកិច្ចសហប្រតិបត្តិការឲ្យមានប្រសិទ្ធភាពរវាងគណៈកម្មាធិការខ្លួនឯងជាមួយនឹង**ក្រុមប្រឹក្សាសិទ្ធិមនុស្ស** ជាពិសេស ពាក់ព័ន្ធនឹង**យន្តការពិនិត្យមើលរបាយការណ៍ជាសកលតាមកាលកំណត់ថ្មីមួយ** ហើយនឹងបង្កើតទម្រង់បែបបទសម្រាប់លើកកម្ពស់ទំនាក់ទំនងជាមួយនឹងមន្ត្រីកាន់កាប់អាណត្តិនៃយន្តការនីតិវិធីពិសេស[47]។ ដោយហេតុត្រូវបង្កើនចំនួនគណៈកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស និងយន្តការនីតិវិធី កំណែទម្រង់រចនាសម្ព័ន្ធបន្ថែមក៏ត្រូវបានពិភាក្សាផងដែរដោយរួមទាំង ការបង្កើតគណៈកម្មាធិការសន្ធិសញ្ញាអចិន្ត្រៃយ៍រួមមួយ ដូចបានស្នើសុំនៅក្នុងឆ្នាំ២០០៥ ដោយអតីតឧត្តមស្នងការសិទ្ធិមនុស្សគឺលោកស្រី Louise Arbour។

---

ទាំងអស់ដើម្បីឲ្យគណៈកម្មាធិការទាំងនេះអាចដំណើរការជាប្រព័ន្ធឯកភាពរួមគ្នាមួយ" (A59/2005 កថាខណ្ឌ ១៤៧)។

[46] សូមមើល "គោលការណ៍ណែនាំស្តីពីការធ្វើរបាយការណ៍អនុលោមតាមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ រួមទាំង គោលការណ៍ណែនាំស្តីបីឯកសារចំបងរួម និងឯកសារដែលផ្តោតលើសន្ធិសញ្ញាជាក់លាក់" (HRI/MC/2005/3)។

[47] សូមមើល "ការអនុវត្តប្រកបដោយប្រសិទ្ធភាពលើលិខិតុបករណ៍អន្តរជាតិស្តីពីសិទ្ធិមនុស្ស រួមទាំង កាតព្វកិច្ចធ្វើរបាយការណ៍អនុលោមតាមលិខិតុបករណ៍អន្តរជាតិស្តីពីសិទ្ធិមនុស្ស" (A/62/224)។

## គ. របៀបប្រើប្រាស់ និងបំពេញការងារជាមួយនឹងគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស

ការបំពេញការងារជាមួយនឹងសន្ធិសញ្ញាសិទ្ធិមនុស្សបានបង្ហាញឲ្យឃើញថា វាជាវិធីដ៏មានប្រសិទ្ធភាពមួយសម្រាប់សង្គមស៊ីវិលក្នុងការចូលរួមចំណែកអនុវត្តសិទ្ធិមនុស្ស និងការបង្កើតគោលការណ៍ណែនាំជាក់ស្តែងស្តីពីសិទ្ធិមនុស្ស។ នៅក្នុងក្របខណ្ឌជាតិ សង្គមស៊ីវិលដើរតួនាទីយ៉ាងសំខាន់តាមរយៈសកម្មភាពឃ្លាំមើល លើកកម្ពស់ និងបន្តតាមដាននានាពាក់ព័ន្ធនឹងការងារនៃគណកម្មាធិការសន្ធិសញ្ញា។ ការងារនៃគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សបានចំណេញប្រយោជន៍ពីការចូលរួមយ៉ាងសកម្មរបស់តួអង្គសង្គមស៊ីវិលនៅក្នុងដំណាក់កាលនៃដំណើរការធ្វើរបាយការណ៍ និងនៅក្នុងដំណើរការនានាដូចជាការធ្វើបណ្តឹង កិច្ចស្រាវជ្រាវ និងការដាស់តឿនបឋមជាដើម។

តាំងពីដើមមក អង្គការ NGOs គឺជាតួអង្គសង្គមស៊ីវិលដែលចូលរួមការងារជាមួយនឹងគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស ជាពិសេស នៅក្នុងសម័យប្រជុំនានារបស់គណកម្មាធិការសន្ធិសញ្ញា។ តួអង្គសង្គមស៊ីវិលផ្សេងទៀត ដូចជា អ្នកជំនាញម្នាក់ៗ និងអ្នកការពារសិទ្ធិមនុស្ស អ្នកគ្រឹះស្ថានអប់រំ និងស្ថាប័នសិក្សាស្រាវជ្រាវ និងសមាជិកក្រុមវិជ្ជាជីវៈក៏ចូលរួមចំណែកយ៉ាងញឹកញាប់នៅក្នុងដំណើរការធ្វើរបាយការណ៍លើសន្ធិសញ្ញាផងដែរ។ ការចូលរួមរបស់ពួកគេ ជាពិសេស ការដាក់ព័ត៌មានជូនគណកម្មាធិការ ឬ ការចូលរួមសម័យប្រជុំ ជាធម្មតា ត្រូវបានសម្របសម្រួលដោយអង្គការ NGOs ដែលមានការយល់ដឹង និងសកម្មនៅក្នុងប្រព័ន្ធរាយការណ៍នៃគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស។

អនុសញ្ញាស្តីពីសិទ្ធិកុមារ អនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ និងអនុសញ្ញាស្តីពីសិទ្ធិជនពិការចែងប្រមើលទុកយ៉ាងច្បាស់អំពីតួនាទី "របស់ស្ថាប័នជំនាញ" នៅក្នុងការងារនៃគណកម្មាធិការសន្ធិសញ្ញានីមួយៗ។ យោងតាមអនុសញ្ញាចំនួនពីរខាងដើម ស្ថាប័នជំនាញនេះត្រូវបានគេបកស្រាយថាសំដៅលើអង្គការ NGOs។ម្យ៉ាងវិញទៀត គណកម្មាធិការទទួលបន្ទុកសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងគណកម្មាធិការស្តីពីសិទ្ធិកុមារបានអនុម័តគោលការណ៍ណែនាំពាក់ព័ន្ធនឹងការចូលរួមរបស់សង្គមស៊ីវិលនៅក្នុងការងារនៃគណកម្មាធិការ (នៅក្នុងករណីទាំងនេះ គឺសំដៅជាពិសេសលើអង្គការ NGOs)[48]។ គម្រូបែបបទ

---

[48] សូមមើល "ការចូលរួមរបស់ NGO នៅក្នុងសកម្មភាពនៃគណកម្មាធិការស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌" (E/C.12/2000/6) និងគោលការណ៍ណែនាំស្តីពីការចូលរួមរបស់ដៃគូ (អង្គការ NGOs និងអ្នកជំនាញ) នៅក្នុងក្រុមការងាររៀបចំសម័យប្រជុំនៃគណកម្មាធិការស្តីពីសិទ្ធិកុមារ (CRC/C/90 ឧបសម្ព័ន្ធ VIII)។

នៃការប្រាស្រ័យទាក់ទាក់គ្នារបស់តួអង្គសង្គមស៊ីវិលជាមួយនឹងគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស មានលក្ខណៈខុសៗគ្នាពីមួយទៅមួយ។ **គម្រូបែបបទទាំងនេះត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃជំពូកនេះ។**

## ១. ការជម្រុញការអនុម័តលិខិតុបករណ៍អន្តរជាតិថ្មីៗ និងការផ្តល់សច្ចាប័ន ឬ ការចូលជាភាគីនៃសន្ធិសញ្ញាដែលមានស្រាប់

សង្គមស៊ីវិលអាចដើរតួនាទីដ៏សំខាន់នៅក្នុងការបង្កើត និងការអនុម័តលិខិតុបករណ៍អន្តរជាតិថ្មីៗ។ តាមរយៈការតស៊ូមតិឲ្យរដ្ឋបង្កើត និងអនុម័តសន្ធិសញ្ញាថ្មីៗ តួអង្គសង្គមស៊ីវិលអាចជួយដល់ការពង្រឹងនិយាមអន្តរជាតិ និងការការពារសិទ្ធិមនុស្ស។

| តួនាទីសង្គមស៊ីវិលនៅក្នុងការបង្កើតបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិថ្មីៗ | | |
|---|---|---|
| អនុសញ្ញាស្តីពីសិទ្ធិជនពិការ និងពិធីសារបន្ថែម<br><br>នៅក្នុងខែធ្នូ ឆ្នាំ២០០៦ មហាសន្និបាតបានអនុម័តអនុសញ្ញាស្តីពីសិទ្ធិជនពិការ និងពិធីសារបន្ថែម។ សង្គមស៊ីវិល ជាពិសេស ជនពិការ និងអង្គការតំណាងពួកគេ បានដើរតួនាទីយ៉ាងសំខាន់នៅគ្រប់ដំណាក់ការដើម្បីឈានទៅរកការអនុម័តលិខិតុបករណ៍ទាំងនេះ។ តំណាងសង្គមស៊ីវិលបានចូលរួមនៅក្នុងការចរចាអត្ថបទ | ហើយបច្ចុប្បន្នធ្វើការងារយ៉ាងសកម្មនៅក្នុងការជម្រុញឲ្យរដ្ឋ ផ្តល់សច្ចាប័នលើសន្ធិសញ្ញាទាំងនេះ។<br><br>អនុសញ្ញាស្តីពីសិទ្ធិជនពិការត្រូវបានចរចានៅចន្លោះឆ្នាំ២០០២ រហូតដល់ឆ្នាំ២០០៦ ដូច្នេះ វាជាសន្ធិសញ្ញាសិទ្ធិមនុស្សមួយដែលត្រូវបានចរចាយ៉ាងលឿនបំផុត។ នៅក្នុងឱកាសអនុម័តអនុសញ្ញានេះ អតីតឧត្តមស្នងការលោកស្រី Louise Arbour បានកត់សម្គាល់អំពីកិច្ចសហប្រតិបត្តិការដែលពុំធ្លាប់មានពីមុនរវាងរដ្ឋ, អង្គការសហប្រជាជាតិ និងស្ថាប័ន NHRIs នៅក្នុងការព្រាងសន្ធិសញ្ញាថ្មីនេះ ដោយបានលើក | ឡើងថា៖<br><br>*ខ្ញុំសូមសម្តែងនូវការគោរព និងកោតសរសើរចំពោះសហគមន៍ជនពិការដែលបានផ្តល់កម្លាំងរុញច្រានគ្មានដាក់ររនៅក្នុងឱកាសដ៏សំខាន់នេះ។ ពួកគេមានតួនាទីនាំទៅរកការផ្លាស់ប្តូរមួយ។ អ្វីដែលច្បាស់ជាងនោះគឺ យោងតាមពាក្យពេចន៍គ្រប់ម៉ាត់នៅក្នុងសេចក្តីប្រកាស ឬ សេចក្តីថ្លែងការណ៍ ចលនាជនពិការបានបង្ហាញឲ្យឃើញនូវសមត្ថភាពក្នុងការប្រយុទ្ធប្រឆាំងនិច្ចលភាព ភាពព្រងើយកន្តើយ និងការតស៊ូដោយចំហដើម្បីទទួលបានសេចក្តីប្រាថ្នាតាមអំណាចផ្លូវច្បាប់នូវសមភាព និងយុត្តិធម៌។* |

<table>
<tr><th colspan="3">អនុសញ្ញាអន្តរជាតិស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ</th></tr>
<tr>
<td>តួអង្គសង្គមស៊ីវិលជាពិសេសសមាគមគ្រួសារជនរងគ្រោះនៃការបាត់ខ្លួនដោយបង្ខំគឺជាអ្នកចូលរួមយ៉ាងសកម្មនៅក្នុងសម័យប្រជុំរបស់ក្រុមការងារនៃអតីតគណកម្មការសិទ្ធិមនុស្សដែលបានព្រាងអនុសញ្ញានេះ។ លោកស្រី Marta Ocampo de Vásquez ដែលមានកូនស្រីជាជនរងគ្រោះម្នាក់នៃការបាត់ខ្លួនដោយបង្ខំនៅប្រទេសអាហ្សង់ទីនបានតស៊ូមតិឲ្យបញ្ចប់ប្រើប្រាស់ការបាត់ខ្លួនដោយបង្ខំ និងជម្រុញឲ្យអនុម័តលិខិតុបករណ៍អន្តរជាតិមួយដើម្បីលើកឡើងអំពីបញ្ហានេះអស់រយៈពេល ៣០ ឆ្នាំ។ លោកស្រីបានធ្វើជាតំណាងសហព័ន្ធអាមេរិកនៃសមាគមសាច់ញាតិជនជាប់ឃុំ-ជនបាត់ខ្លួន (សហព័ន្ធ FEDEFAM) នៅក្នុងសម័យប្រជុំក្រុមការងារ។</td>
<td>នៅសម័យបើកប្រជុំក្រុមប្រឹក្សាសិទ្ធិមនុស្សនាថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៦។ នៅមុនពេលអនុម័តអនុសញ្ញានេះ លោកស្រី de Vásquez បានលើកឡើងថា៖<br><br>នៅក្នុងខែឧសភា ឆ្នាំ១៩៧៧ ខ្ញុំបានចូលរួមចលនាមាតានៃ Plaza de Mayo...។ ខ្ញុំរួមជាមួយនឹងស្ត្រីទាំងឡាយបានចាប់ផ្តើមស្វែងយល់ ហើយបានដឹងថា ខ្ញុំមិនមែនត្រឹមតែស្វះស្វែងរកកូនស្រី និងកូនប្រសារខ្ញុំប៉ុណ្ណោះទេ ប៉ុន្តែកូនប្រុសស្រីនៃគ្រួសារអាហ្សង់ទីន និងអាមេរិកឡាទីនផ្សេងទៀតដែលបានបាត់ខ្លួន។ នៅក្នុងថ្ងៃនេះ ខ្ញុំកំពុងស្វែងរក "អ្នកទាំងអស់ដែលបានបាត់ខ្លួន" នៅជុំវិញពិភពលោក។<br><br>ខ្ញុំសូមឲ្យអស់លោកលោកស្រីជ្រាបថា ក្រោយហេតុការណ៍នៃការឃុំខ្លួន និងបាត់ខ្លួនអ្នកជាទីស្រលាញ់របស់យើង</td>
<td>យើងបានដឹងដោយក្តីឈឺចាប់ថា យើពុំអាចរកចម្លើយឃើញ។ គ្មានយន្តការដំណោះស្រាយមានសម្រាប់យើង ហើយក៏គ្មានការចេញដីកានាំខ្លួន ឬ ការការពារតាមផ្លូវតុលាការស្របច្បាប់សម្រាប់យើង។ ក្រោយមក ដោយសារសេចក្តីអស់សង្ឃឹមរបស់ពួកយើង ទើបយើងបានស្វះស្វែងទាក់ទងសហគមន៍អន្តរជាតិ ក៏ប៉ុន្តែ អ្វីដែលយើងបានដឹងនោះគឺថា គ្មានលិខិតុបករណ៍សមស្របណាមួយមានអត្ថិភាពសម្រាប់យើងប្រើប្រាស់។ ដូច្នេះហើយ ទើបយើងជួបជុំគ្នានៅថ្ងៃនេះម្តងទៀតស្នើសុំលោកស្រីប្រធាន និងគណប្រតិភូជាទីគោរពនៃក្រុមប្រឹក្សាសិទ្ធិមនុស្សឲ្យអនុម័តជាស្ថាព័រនូវអនុសញ្ញានេះ។ យើងបានធ្វើដំណើរលើផ្លូវដ៏វែងឆ្ងាយជាមួយនឹងសមិទ្ធផល និងសេចក្តីស្រងាកចិត្ត។ ប៉ុន្តែ</td>
</tr>
</table>

| | | |
|---|---|---|
| | | *ថ្ងៃនេះ យើងដាក់សំឡឹងមករកលោកលោកស្រី ស្នើសុំកុំឲ្យមានជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ពោលគឺការបាត់ខ្លួនដោយបង្ខំនេះតទៅទៀត។* |

ប្រសិនបើរដ្ឋពុំទាន់ផ្តល់សច្ចាប័ន ឬ ចូលជាភាគីនៃសន្ធិសញ្ញា ឬ ពិធីសារបន្ថែមនោះទេ តួអង្គសង្គមស៊ីវិលនៅថ្នាក់ជាតិអាចជម្រុញឲ្យរដ្ឋាភិបាលផ្តល់សច្ចាប័ន ឬ ចូលជាភាគីតាមរយៈកិច្ចប្រឹងប្រែងសម្របសម្រួលជាមួយនឹងស្ថាប័ន NHRIs និងសារព័ត៌មានជាតិ និង/ឬ តាមរយៈការលើកកម្ពស់ការយល់ដឹងអំពីបញ្ហានេះ។

i. ដើម្បីពិនិត្យមើលស្ថានភាពនៃការផ្តល់សច្ចាប័នលើសន្ធិសញ្ញាសិទ្ធិមនុស្ស និងពិធីសារបន្ថែម សូមចូលទៅកាន់គេហទំព័រនៃការិយាល័យ OHCHR។

## ២. ការឃ្លាំមើលកាតព្វកិច្ចធ្វើរបាយការណ៍របស់រដ្ឋភាគី

រដ្ឋភាគីមិនមែនតែងតែអាចបំពេញកាតព្វកិច្ចធ្វើរបាយការណ៍រហូតនោះទេ ដោយសារហេតុផលផ្សេងៗ។ សង្គមស៊ីវិលអាចជម្រុញឲ្យរដ្ឋាភិបាលគោរពកាលបរិច្ឆេទកំណត់នៃការធ្វើរបាយការណ៍ និងអាចលើកកម្ពស់ការយល់ដឹងដល់សាធារណជនអំពីកាតព្វកិច្ចរបស់រដ្ឋនៅក្នុងការដាក់របាយការណ៍ទៅតាមកាលកំណត់ណាមួយ។ តួអង្គសង្គមស៊ីវិលអាចផ្តល់ព័ត៌មានបន្ថែមជូនរដ្ឋអំពីការអនុវត្តសន្ធិសញ្ញាដែលពួកគេប្រមូលបាននៅក្នុងពេលពួកគេបំពេញសកម្មភាព ហើយនឹងអាចបំពេញការងារជាដៃគូជាមួយនឹងរដ្ឋដើម្បីឆ្ពោះទៅរកការអនុវត្តសន្ធិសញ្ញា។

ប្រសិនបើរដ្ឋភាគីមិនទាន់បានដាក់របាយការណ៍ទៅតាមកាលកំណត់ ហើយមិនបានឆ្លើយតបទៅតាមសំណើរបស់គណកម្មាធិការសុំរបាយការណ៍ គណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សអាចពិចារណាស្ថានភាពនៅក្នុងប្រទេសនោះនៅក្នុងសម័យប្រជុំណាមួយរបស់ខ្លួនបើទោះជាពុំមានរបាយការណ៍ពីរដ្ឋភាគីក៏ដោយ។ នីតិវិធីនេះត្រូវបានគេហៅថា**យន្តការនីតិវិធីសើរើ**។

**សង្គមស៊ីវិលរួមជាមួយនឹងអង្គការដៃគូនៃអង្គការសហប្រជាជាតិអាចចែករំលែកព័ត៌មានសម្រាប់ជូនយន្តការនីតិវិធីសើរើនេះ។ ផ្អែកលើព័ត៌មាន និងកិច្ចសន្ទនាជាមួយនឹងរដ្ឋភាគី គណកម្មាធិការនឹងចេញសេចក្តីសង្កេតសរុបរួមទាំងអនុសាសន៍ផងដែរ។**

## ៣. ការដាក់ព័ត៌មានជាលាយលក្ខណ៍អក្សរ

នៅក្នុងអំឡុងពេលនៃដំណើរការធ្វើរបាយការណ៍ គណកម្មាធិការស្វាគមន៍ព័ត៌មានបន្ថែមអំពីចំណុចគ្រប់បែបយ៉ាងដែលមានចែងនៅក្នុងសន្ធិសញ្ញាដើម្បីឃ្លាំមើលប្រកបដោយប្រសិទ្ធភាពលើការអនុវត្តរបស់រដ្ឋ។ វិធីដ៏មានប្រសិទ្ធភាពបំផុតសម្រាប់តួអង្គសង្គមស៊ីវិលក្នុងការដាក់ព័ត៌មានបន្ថែមគឺតាមរយៈ**របាយការណ៍ជាលាយលក្ខណ៍អក្សរ**។ ជារឿយៗ របាយការណ៍ដ៏មានប្រយោជន៍បំផុតគឺរបាយការណ៍ដែលបានបង្កើតឡើងនៅក្នុងអំឡុងពេលនៃកិច្ចសហប្រតិបត្តិការ និងកិច្ចសម្របសម្រួលរបស់តួអង្គសង្គមស៊ីវិលជាច្រើន។ ដូច្នេះ តួអង្គសង្គមស៊ីវិលត្រូវបានលើកទឹកចិត្តឲ្យដាក់ព័ត៌មានជាលាយលក្ខណ៍អក្សររួមគ្នាស្តីអំពីប្រទេសណាមួយជាក់លាក់។

គម្រូបែបបទសម្រាប់ដាក់ព័ត៌មានជូនគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សមានលក្ខណៈខុសៗគ្នាពីមួយទៅមួយ។ ជាទូទៅ តួអង្គសង្គមស៊ីវិលគួរដាក់ព័ត៌មាន និងឯកសារក្រោយរដ្ឋភាគីដាក់របាយការណ៍ជូនគណកម្មាធិការសន្ធិសញ្ញា និងនៅមុនពេលពិចារណារបាយការណ៍ទាំងនោះ។

គណកម្មាធិការទទួលបន្ទុកសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ គណកម្មាធិការទទួលបន្ទុកការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ និងគណកម្មាធិការទទួលបន្ទុកសិទ្ធិកុមារស្វាគមន៍ព័ត៌មានជាលាយលក្ខណ៍អក្សរពីអង្គការ NGOs ជាតិ និងអន្តរជាតិព្រមទាំងពីតួអង្គសង្គមស៊ីវិលផ្សេងទៀត (ជាពិសេស អ្នកជំនាញម្នាក់ៗ គ្រឹះស្ថានអប់រំ សមាគមវិជ្ជាជីវៈ និងសមាជិកសភា) នៅក្នុងកិច្ចប្រជុំរបស់ក្រុមការងារត្រៀមរៀបចំបញ្ជីបញ្ហានានា។ គណកម្មាធិការស្តីពីសិទ្ធិកុមារតម្រូវឲ្យដាក់ព័ត៌មានជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ២ ខែ នៅមុនកិច្ចប្រជុំរបស់ក្រុមការងារត្រៀមរៀបចំ។ តួអង្គសង្គមស៊ីវិលរួមទាំងគ្រឹះស្ថានអប់រំ និងសមាគមវិជ្ជាជីវៈក៏អាចដាក់ព័ត៌មានជាលាយលក្ខណ៍អក្សរជូនក្រុមការងារទទួលបន្ទុករបាយការណ៍ប្រចាំប្រទេសនៃគណកម្មាធិការប្រឆាំងនឹងទារុណកម្ម និងគណកម្មាធិការសិទ្ធិមនុស្សផងដែរ។

ជាទូទៅ របាយការណ៍ជាលាយលក្ខណ៍អក្សរដែលបានដាក់ជូនគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សត្រូវបានចាត់ទុកថាជាព័ត៌មានសាធារណៈ។ ទោះបីជាយ៉ាងនេះក្តី គណកម្មាធិការនឹងរក្សាព័ត៌មាននេះសម្ងាត់ជាពិសេសប្រសិនបើមានសំណើសុំ។

របាយការណ៍ជាលាយលក្ខណ៍អក្សរដែលតួអង្គសង្គមស៊ីវិលបានដាក់ជូនពុំក្លាយជាឯកសារផ្លូវការនៃអង្គការសហប្រជាជាតិ ហើយក៏ពុំមានការកែសម្រួល ឬ បកប្រែឡើយ។ ដូច្នេះ វាមានសារសំខាន់ដែលតួអង្គសង្គមស៊ីវិលត្រូវពិចារណាថាតើខ្លួនគួរដាក់ព័ត៌មានទាំងនេះជាភាសាណាមួយ ហើយនឹងត្រូវធានាថា ឯកសារដែលបានដាក់ជូនត្រូវតែជាភាសាការងារណាមួយនៃគណកម្មាធិការពាក់ព័ន្ធ។

លោកអ្នកចាំបាច់ត្រូវពិនិត្យមើលចំណុចខាងក្រោមនៅមុនពេលដាក់ព័ត៌មានជាលាយលក្ខណ៍អក្សរះ

- តើរដ្ឋបានផ្តល់**សច្ចាប័ន ឬ ចូលជាភាគី**នៃលិខិតុបករណ៍ពាក់ព័ន្ធដែរឬទេហើយប្រសិនបើបានផ្តល់សច្ចាប័ន ឬ ចូលជាភាគីហើយនោះ ត្រូវពិនិត្យមើលខព្យរបទប្បញ្ញត្តិចំពោះបទប្បញ្ញត្តិណាមួយដែលធ្វើឡើងដោយរដ្ឋ។ (ជាទូទៅ ខព្យរបទប្បញ្ញត្តិពុំបានរារាំងតួអង្គសង្គមស៊ីវិលពីការលើកឡើងបញ្ហាជាក់លាក់ និងដាក់បញ្ហាទាំងនេះជូនគណកម្មាធិការក្នុងក្របខណ្ឌជាការចំណាប់អារម្មណ៍នោះឡើយ)។
- **កាលបរិច្ឆេទដាក់របាយការណ៍បន្ទាប់ដោយរដ្ឋ** និងកាលបរិច្ឆេទកំណត់សម័យប្រជុំនាពេលបន្ទាប់របស់គណកម្មាធិការពាក់ព័ន្ធ។ កាលបរិច្ឆេទទាំងនេះអាចកែប្រែបានតាមរយៈការជូនដំណឹងក្នុងរយៈខ្លីមួយតែប៉ុណ្ណោះ ដូច្នេះ វាមានសារសំខាន់ត្រូវទាក់ទងជាប្រចាំជាមួយនឹងលេខាធិការដ្ឋាននៃគណកម្មាធិការពាក់ព័ន្ធនៅមុនពេលឈានទៅចូលរួមសម័យប្រជុំនីមួយៗ។
- បញ្ហាចំបងដែលកំពុង ឬ ត្រូវបានពិចារណាតាំងពីមុនរហូតមក។ វាមានសារសំខាន់ដែលតួអង្គសង្គមស៊ីវិលត្រូវសិក្សាស្វែងយល់ឲ្យបានច្បាស់អំពី**ខ្លឹមសារនៃរបាយការណ៍មុនៗរបស់រដ្ឋភាគីព្រមទាំងសេចក្តីសង្កេតសរុប និងបញ្ជីស្តីពីបញ្ហានានាពីមុនមក** និង
- **គោលការណ៍ណែនាំស្តីពីការធ្វើរបាយការណ៍**នៃគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស (ដើម្បីឲ្យតួអង្គសង្គមស៊ីវិលអាចជួយឃ្លាំមើលថាតើរបាយការណ៍របស់រដ្ឋភាគីមានភាពស៊ីសង្វាក់កម្រិតណា)។

i. ការដាក់របាយការណ៍ជាលាយលក្ខណ៍អក្សរ

វិធីដ៏ចាំបាច់ផុតសម្រាប់តួអង្គសង្គមស៊ីវិលក្នុងការដាក់ព័ត៌មានជូនគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សគឺតាមរយៈការបង្កើតរបាយការណ៍ជាលាយលក្ខណ៍អក្សរមួយរួមជាមួយនឹងរបាយការណ៍របស់រដ្ឋ។

នៅមុនពេលតួអង្គសង្គមស៊ីវិលចាប់ផ្តើមព្រាងរបាយការណ៍ តួអង្គសង្គមស៊ីវិលគួរសិក្សាស្វែងយល់អំពីគោលការណ៍ណែនាំជាក់លាក់ស្តីពីការធ្វើរបាយការណ៍នៃគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស។ របាយការណ៍ជាលាយលក្ខណ៍អក្សរគួរមានរចនាសម្ព័ន្ធស្រដៀងគ្នានឹងរបាយការណ៍ផ្លូវការរបស់រដ្ឋក្នុងគោលបំណងចង់ឲ្យមានការវិភាគជាលក្ខណៈប្រព័ន្ធថាតើ ច្បាប់ គោលនយោបាយ និងការអនុវត្តរបស់រដ្ឋភាគីបានគោរពតាមគោលការណ៍ និងបទដ្ឋាននៃសន្ធិសញ្ញាត្រឹមកម្រិតណា។

របាយការណ៍ជាលាយលក្ខណ៍អក្សរគួរៈ

- មានលក្ខណៈច្បាស់លាស់ ត្រឹមត្រូវ និងមានកម្មវត្ថុជាក់លាក់។

- គួសបញ្ជាក់បញ្ហានានាដែលអ្នកធ្វើរបាយការណ៍បានមើលឃើញនៅក្នុងការអនុវត្ត ហើយគួរផ្តល់អនុសាសន៍ជាក់លាក់ដើម្បីធ្វើឲ្យស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសមួយមានភាពប្រសើរឡើង និង
- ដាក់ជូនឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាននៅមុនពេលកាលបរិច្ឆេទពិនិត្យរបាយការណ៍របស់រដ្ឋដោយសារវានឹងផ្តល់លទ្ធភាពឲ្យគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សពិចារណាលើរបាយការណ៍ជាលាយលក្ខណ៍នេះនៅពេលរៀបចំបញ្ជីស្តីពីបញ្ហានានា រៀបចំសម័យប្រជុំ និងព្រាងសេចក្តីសង្កេតសរុប។

គោលការណ៍ណែនាំៈ

- ព័ត៌មានដែលតួអង្គសង្គមស៊ីវិលផ្តល់ជូនត្រូវផ្តោតលើប្រទេសជាក់លាក់ និងពាក់ព័ន្ធនឹងអាណត្តិការងារនៃគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សដែលរបាយការណ៍នោះដាក់ជូន។ ប្រសិនបើអាច របាយការណ៍គួរយោងដោយផ្ទាល់លើមាត្រានៃសន្ធិសញ្ញា ពោលគឺ សិទ្ធិជាក់លាក់ដែលត្រូវបានចោទប្រកាន់ថាមានការរំលោភ។
- ការចោទប្រកាន់អំពីការរំលោភសិទ្ធិមនុស្សគួរមានភ័ស្តុតាង និងឯកសារពាក់ព័ន្ធគាំទ្រជាមូលដ្ឋានជានិច្ច។
- ព័ត៌មានទាំងអស់គួរយោងឲ្យបានត្រឹមត្រូវ។ នៅពេលយោងលើឯកសារនៃអង្គការសហប្រជាជាតិ គួរមានការយោងលើលេខកថាខណ្ឌ និងលេខទំព័រទៅតាមសំណៅភាសាផ្សេងៗគ្នា ហើយគួរមានលេខយោងជាក់លាក់ដូចគ្នាចំពោះចំណុចដកស្រង់ចេញពីរបាយការណ៍របស់រដ្ឋដែលបានយោងចេញពីសំណៅផ្លូវការនៃអង្គការសហប្រជាជាតិ។
- សំណៅជាទម្រង់អេឡិចត្រូនិច និងសំណៅថតចម្លងជាក្រដាសគួរផ្តល់ជូនលេខាធិការនៃគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សពាក់ព័ន្ធដោយសារថា គណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សពុំមានសិទ្ធិថតចម្លងសម្ភារៈឯកសារពីសង្គមស៊ីវិលនោះឡើយ។
- ឯកសារទាំងឡាយណាដែលត្រូវបានរកឃើញថាបានប្រើប្រាស់ពាក្យពេចន៍ប្រមាថនឹងមិនទទួលយកឡើយ។

ចំពោះឯកសារជាលាយលក្ខណ៍អក្សររបស់សង្គមស៊ីវិលដែលបានដាក់ជូនសម័យប្រជុំនៃគណកម្មាធិការសន្ធិសញ្ញាជាក់លាក់ណាមួយ សូមលោកអ្នករកមើលក្នុងផ្នែកស្តីពីគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សក្នុងគេហទំព័រនៃ**ការិយាល័យ OHCHR** ឬ នៅលើគេហទំព័រនៃ**បណ្តាញព័ត៌មានស្តីពីសិទ្ធិកុមារ**ចំពោះករណីគណកម្មាធិការទទួលបន្ទុកសិទ្ធិកុមារ (**ក្រុមអង្គការ NGO ទទួលបន្ទុកអនុសញ្ញាស្តីពីសិទ្ធិកុមារ**)។

សូមមើលតារាងទាំងឡាយនៅទំព័រចុងក្រោយនៃជំពូកនេះសម្រាប់ព័ត៌មានស្តីពីការដាក់ពត៌មានជាលាយលក្ខណ៍អក្សរជូនគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សជាក់លាក់ណាមួយ។

| សិក្ខាសាលាបណ្តុះបណ្តាលស្តីពីការសរសេររបាយការណ៍អំពីការអនុវត្តកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | | |
|---|---|---|
| នៅក្នុងខែ មិថុនា ឆ្នាំ២០០៧ ការិយាល័យ OHCHR នៅក្នុងប្រទេសហុងគ្រីបានរៀបចំសិក្ខាសាលាមួយនៅទីក្រុងប៊ីលីស៊ីសម្រាប់អ្នកតំណាងអង្គការ NGO ចំនួន ២០ នាក់ទាក់ទងនឹងគណៈកម្មាធិការទទួលបន្ទុកសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ សិក្ខាសាលានេះត្រូវបានសម្របសម្រួលដោយសមាជិក ២ រូបមកពីគណ កម្មាធិការនេះ | ក្នុងគោលបំណង៖<br>• លើកកម្ពស់ការយល់ដឹងអំពីលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ យន្តការឃ្លាំមើល និងតួនាទីជាក់លាក់របស់អង្គការ NGOs។<br>• លើកកម្ពស់ការយល់ដឹងអំពីគោលការណ៍សមភាព ការមិនរើសអើង និងការចូលរួមនៅក្នុងការអនុវត្តកតិកាសញ្ញា | អន្តជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និង វប្បធម៌ និង<br>• បង្កើនការយល់ដឹងអំពីតួនាទីរបស់សង្គមស៊ីវិល នៅក្នុងដំណើរវិវឌ្ឍនៃការឃ្លាំមើលការអនុវត្តកតិកាសញ្ញា។<br>កិច្ចប្រជុំតុមូលបានរៀបចំឡើងជាមួយនឹងអង្គការ NGOs នៅតាមមូលដ្ឋាននៅក្នុងអំឡុងឆ្នាំ២០០៧ដើម្បីជាការបន្តតាមដានវគ្គបណ្តុះបណ្តាលកសាងសមត្ថភាពនេះ។ |

## ៤. ការចូលរួម និងការរួមចំណែកនៅក្នុងសម័យប្រជុំនៃគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស

### ការចូលរួមសម័យប្រជុំ

របាយការណ៍របស់រដ្ឋភាគីត្រូវបានពិចារណានៅក្នុងកិច្ចប្រជុំជាសាធារណៈដែលតួអង្គសង្គមស៊ីវិលអាចចូលរួមជាអ្នកសង្កេតការណ៍បាន។ ការចូលរួមសម័យប្រជុំនៃគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សអាចឲ្យតួអង្គសង្គមស៊ីវិល៖

- បង្ហាញព័ត៌មានសង្ខេបបឋមជូនគណកម្មាធិការទាំងមូល ឬ សមាជិកម្នាក់ៗ។
- សង្កេតកិច្ចសន្ទនារវាងគណកម្មាធិការ និងរដ្ឋ និង
- ទទួលបានព័ត៌មានដោយផ្ទាល់អំពីបញ្ហាដែលបានលើកឡើង និងអនុសាសន៍ដែលបានផ្តល់ជូនដោយគណកម្មាធិការ។

វិធាន និងបទដ្ឋានអនុវត្តចែងអំពីការចូលរួមរបស់សង្គមស៊ីវិលនៅក្នុងសម័យប្រជុំនៃគណកម្មាធិការព្រមទាំងនៅក្នុងសម័យប្រជុំរៀបចំមានលក្ខណៈខុសៗគ្នាពីគណកម្មាធិការមួយទៅគណកម្មាធិការមួយទៀត។

**សិទ្ធិចូលរួមសម័យប្រជុំនៃគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សនីមួយៗគួរស្នើសុំជាមុនពីលេខាធិការដ្ឋានពាក់ព័ន្ធ។**

ការរួមចំណែកនៅក្នុងសម័យប្រជុំ

តួអង្គសង្គមស៊ីវិលរួមទាំងអ្នកជំនាញម្នាក់ៗ អ្នកសិក្សាស្រាវជ្រាវ និងតំណាងក្រុមវិជ្ជាជីវៈអាចមានតួនាទីសកម្មនៅក្នុងសម័យប្រជុំនៃគណកម្មាធិការ។ ទោះបីជាពួកគេមិនចូលរួមក្នុងកិច្ចសន្ទនារវាងរដ្ឋភាគី និងគណកម្មាធិការក៏ដោយ ពួកគេអាចធ្វើបទបង្ហាញជូនសមាជិកគណកម្មាធិការអំពីបញ្ហានានាដែលរួមមាននៅក្នុងឯកសារដែលពួកគេបានដាក់។

គណកម្មាធិការភាគច្រើនលៃលកពេលវេលាសម្រាប់តួអង្គសង្គមស៊ីវិលធ្វើបទបង្ហាញដោយផ្ទាល់មាត់។ សូមមើលឧបសម្ព័ន្ធនៅក្នុងជំពូកនេះសម្រាប់ព័ត៌មានបន្ថែមស្តីពីបទបង្ហាញផ្ទាល់មាត់នៅសម័យប្រជុំនៃគណកម្មាធិការ និងសម័យប្រជុំនៃក្រុមងារត្រៀមរៀបចំ។

សម័យប្រជុំនៃគណកម្មាធិការ

គណកម្មាធិការសិទ្ធិមនុស្ស គណកម្មាធិការទទួលបន្ទុកសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ គណកម្មាធិការទទួលបន្ទុកប្រឆាំងនឹងទារុណកម្ម គណកម្មាធិការទទួលបន្ទុកការលុបបំបាត់ចោលការរើសអើងប្រឆាំងនឹងស្ត្រីភេទ និងគណកម្មាធិការទទួលបន្ទុកពលករទេសន្តរប្រវេសន៍បានផ្តល់ពេលវេលាសម្រាប់ការធ្វើបទបង្ហាញផ្ទាល់មាត់នៅក្នុងអំឡុងសម័យប្រជុំបង្ហាញរបាយការណ៍។ ពេលវេលានេះ ផ្តល់ឱកាសជូនតួអង្គសង្គមស៊ីវិលបង្ហាញជូនគណកម្មាធិការនូវបញ្ហាគន្លឹះនានានៅក្នុងរបាយការណ៍ជាលាយលក្ខណ៍អក្សរ។

សូមកត់សម្គាល់ថា ការបង្ហាញព័ត៌មានសង្ខេបបឋមដោយផ្ទាល់មាត់ពីតួអង្គសង្គមស៊ីវិលប្រព្រឹត្តទៅនៅក្នុងសម័យប្រជុំសម្ងាត់លើកលែងតែគណកម្មាធិការទទួលបន្ទុកសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងគណកម្មាធិការទទួលបន្ទុកការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ ដែលបើកកិច្ចប្រជុំចំហជូនសាធារណជន។

ក្រុមការងារមុនសម័យប្រជុំ

គណកម្មាធិការទទួលបន្ទុកសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ គណកម្មាធិការទទួលបន្ទុកការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ និងគណកម្មាធិការទទួលបន្ទុកសិទ្ធិកុមារបានបែងចែកពេលវេលាជាក់លាក់សម្រាប់តួអង្គសង្គមស៊ីវិលដើម្បីចូលរួមចំណែកនៅក្នុងក្រុមការងារមុនសម័យប្រជុំ។ ទោះបីជាគណកម្មាធិការផ្សេងទៀតមិនអាចផ្តល់ច្រកផ្លូវការសម្រាប់ការចូលរួមចំណែកបែប

នេះក៏ដោយ លោកលោកស្រីក៏នៅតែអាចរៀបចំកិច្ចប្រជុំក្រៅផ្លូវការជាមួយនឹងសមាជិកគណកម្មាធិការតាមរយៈការទាក់ទងលេខាធិការដ្ឋាននៃគណកម្មាធិការពាក់ព័ន្ធ។

ការរួមចំណែករបស់សង្គមស៊ីវិលជាមួយនឹងក្រុមការងារត្រៀមរៀបចំអាចយកមកដាក់បញ្ចូលនៅក្នុងបញ្ជីស្តីពីបញ្ហានានាដែលនឹងបញ្ជូនទៅរដ្ឋភាគី។ ក្រុមការងារត្រៀមរៀបចំនេះក៏ផ្តល់ឱកាសឲ្យតួអង្គសង្គមស៊ីវិលដាក់ព័ត៌មាន ឬ របាយការណ៍ជាលាយលក្ខណ៍អក្សរផងដែរ។ គណកម្មាធិការភាគច្រើនពុំអនុញ្ញាតឲ្យគណប្រតិភូរដ្ឋាភិបាលមានវត្តមានក្នុងកិច្ចប្រជុំត្រៀមរៀបចំនេះឡើយ។

i. គោលការណ៍ណែនាំស្តីពីការធ្វើបទបង្ហាញផ្ទាល់មាត់នៅសម័យប្រជុំនៃគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស និងសម័យប្រជុំក្រុមការងារត្រៀមរៀបចំ

- បទបង្ហាញផ្ទាល់មាត់ត្រូវពាក់ព័ន្ធនឹងសន្ធិសញ្ញាជាក់លាក់។
- សេចក្តីថ្លែងការណ៍ផ្ទាល់មាត់ត្រូវគោរពតាមពេលវេលាកំណត់ដោយគណកម្មាធិការ។
- ការជួយសម្រួលការបកប្រែផ្ទាល់មាត់ជាធម្មតាមានការផ្តល់ជូននៅក្នុងសម័យប្រជុំទាំងនេះ ហើយតំណាងសង្គមស៊ីវិលគួរធ្វើយ៉ាងណាផ្តល់ជូនអ្នកបកប្រែផ្ទាល់មាត់នូវអត្ថបទជាលាយលក្ខណ៍អក្សរនៃបទបង្ហាញផ្ទាល់មាត់របស់ពួកគេ។
- ក្រុមគណប្រតិភូមានចំនួនតិច ហើយដែលមានការសម្របសម្រួលគ្នាជាមុនរួចហើយនោះជាធម្មតាមានប្រសិទ្ធភាពជាងក្រុមគណប្រតិភូដែលមានចំនួនច្រើន ហើយដែលផ្តោតលើបញ្ហាតែមួយ និង
- ភាសាដែលត្រូវបានចាត់ទុកថាមានការប្រមាថ ឬ មានភាពអាម៉ាសនឹងមិនទទួលយកនោះទេ ហើយបុគ្គលដែលប្រើប្រាស់ភាសាបែបនេះអាចត្រូវបានដកចេញពីក្នុងសម័យប្រជុំ។

**អង្គការ NGOs និងតួអង្គសង្គមស៊ីវិលផ្សេងទៀតត្រូវបានរំលឹកឲ្យទាក់ទងជាមួយនឹងលេខាធិការដ្ឋាននៃគណកម្មាធិការពាក់ព័ន្ធជាមុនដើម្បីជម្រាបជូនលេខាធិការដ្ឋានជាផ្លូវការអំពីផែនការចូលរួមរបស់ពួកគេ។**

## ការបង្ហាញព័ត៌មានសង្ខេបបឋមក្រៅផ្លូវការ

ជាធម្មតា សម័យប្រជុំនៃគណកម្មាធិការផ្តល់ឱកាសឲ្យតួអង្គសង្គមស៊ីវិលជួបប្រជុំក្រៅផ្លូវការជាមួយនឹងសមាជិកនៃគណកម្មាធិការ។ **ការបង្ហាញព័ត៌មានសង្ខេបក្រៅផ្លូវការ** ដែលជាទូទៅរៀបចំដោយអង្គការ NGOs អាចត្រូវបានរៀបចំឡើងជាព្រឹត្តិការណ៍អមនឹងកិច្ចប្រជុំផ្លូវការ។ ការបង្ហាញព័ត៌មានសង្ខេបក្រៅផ្លូវការនេះជាធម្មតាបានធ្វើឡើងនៅក្នុងអំឡុងពេលនៃអាហារថ្ងៃត្រង់ចាប់ពីម៉ោង ១ ដល់ ម៉ោង ៣ រសៀល។ ចូរកត់សម្គាល់ថា ការជួយសម្រួលការបកប្រែផ្ទាល់មាត់មិនមានរៀបចំ

សម្រាប់ការបង្ហាញព័ត៌មានសង្ខេបក្រៅផ្លូវការនៅក្នុងអំឡុងពេលសម្រាក "អាហារថ្ងៃត្រង់" នោះឡើយ។

កិច្ចប្រជុំក្រៅផ្លូវការទាំងនេះផ្តោតសំខាន់លើបញ្ហានានា និងរដ្ឋដែលគណកម្មាធិការលើកឡើង។ ជាធម្មតា កិច្ចប្រជុំណែនាំបឋមរៀបចំឡើងមួយថ្ងៃមុន ឬ នៅថ្ងៃពិចារណារបាយការណ៍នៃប្រទេសពាក់ព័ន្ធ។ កិច្ចប្រជុំណែនាំបឋមដែលមានការសម្របសម្រួល និងរៀបចំឡើងត្រឹមត្រូវទំនងជាមានការចូលរួមពីសមាជិកគណកម្មាធិការ ហើយនឹងមានប្រសិទ្ធភាពជាងកិច្ចប្រជុំណែនាំបឋមលើបញ្ហាផ្សេងៗគ្នា។ ដូច្នេះ តួអង្គសង្គមស៊ីវិលត្រូវបានលើកទឹកចិត្តឲ្យសម្របសម្រួលសកម្មភាពរបស់ពួកគេជាមុន។

នៅក្នុងករណីខ្លះ លេខាធិការដ្ឋាននៃគណកម្មាធិការអាចជួយសម្រួលកិច្ចប្រជុំណែនាំបឋមតាមរយៈការផ្តល់បន្ទប់ និងឧបករណ៍ផ្សេងៗ និងតាមរយៈការជូនដំណឹងសមាជិកគណកម្មាធិការអំពីកិច្ចប្រជុំណែនាំបឋម។

## ៥. ការបន្តតាមដានសេចក្តីសង្កេតសរុបរបស់គណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស

នៅពេលសម័យប្រជុំនៃគណកម្មាធិការបានប្រព្រឹត្តទៅ ហើយសេចក្តីសង្កេតសរុបត្រូវបានអនុម័ត សង្គមស៊ីវិលអាចធ្វើសកម្មភាពបន្តតាមដាននៅថ្នាក់ជាតិដើម្បីលើកកម្ពស់ការយល់ដឹងអំពីអនុសាសន៍ និងដើម្បីលើកទឹកចិត្តឲ្យរដ្ឋភាគីអនុវត្តសេចក្តីសង្កេតសរុប។

ដូច្នេះ វាមានសារសំខាន់ដែលថា តួអង្គសង្គមស៊ីវិលគួរយល់ដឹងច្បាស់អំពីសេចក្តីសង្កេតសរុបដែលគណកម្មាធិការបានអនុម័ត។

i. សូមចូលទៅកាន់គេហទំព័រនៃការិយាល័យ OHCHR ដើម្បីទទួលយក**ការជូនដំណឹងតាមរយៈអ៊ីមែលអំពីអនុសាសន៍នៃគណកម្មាធិការសន្ធិសញ្ញា**។

សង្គមស៊ីវិលអាចធ្វើការបន្តតាមដានសេចក្តីសង្កេតសរុបរបស់គណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សតាមរយៈ៖

- **បំពេញការងារ**រួមជាមួយនឹងរដ្ឋាភិបាលដើម្បីជួយឲ្យរដ្ឋាភិបាលបំពេញតាមកាតព្វកិច្ច។ ជារឿយៗ សង្គមស៊ីវិលដើរតួនាទីជាចលករដើម្បីជម្រុញឲ្យមានការកែទម្រង់ច្បាប់នៅថ្នាក់ជាតិ និងដើម្បីបង្កើតគោលនយោបាយថ្នាក់ជាតិ។ តួអង្គសង្គមស៊ីវិលក៏អាចប្រើប្រាស់សេចក្តីសង្កេតសរុបរបស់គណកម្មាធិការដើម្បីធ្វើជាមូលដ្ឋានសម្រាប់កិច្ចសន្ទនាជាមួយនឹងរដ្ឋាភិបាល និងផែនការសកម្មភាពរបស់ខ្លួនផងដែរ។

- **ឃ្លាំមើល**ស្ថានភាពសិទ្ធិមនុស្សជាពិសេសនៅក្នុងប្រទេស និងវិធានការដែលបានធ្វើឡើងនៅក្នុងស្រុកដើម្បីអនុវត្តសេចក្តីសង្កេតសរុបរបស់គណកម្មាធិការ។
- **លើកកម្ពស់ការយល់ដឹង**អំពីកិច្ចដំណើរការនីតិវិធីនៃកិច្ចប្រជុំរបស់គណកម្មាធិការ អនុសាសន៍ដែលរដ្ឋភាគីតម្រូវឲ្យអនុវត្តតាម និងករណីថាតើសេចក្តីសង្កេតសរុបអាចត្រូវបានប្រើប្រាស់តាមវិធីណាដើម្បីពង្រឹងការទទួលបានការគោរពសិទ្ធិមនុស្សនៅថ្នាក់ជាតិ។ ករណីនេះអាចធ្វើឡើងតាមរយៈការរៀបចំកិច្ចពិភាក្សាលើប្រធានបទ កិច្ចពិភាក្សាតុមូល សិក្ខាសាលា និងកម្មវិធីបណ្តុះបណ្តាល តាមរយៈការបកប្រែ និងការបោះពុម្ពសេចក្តីសង្កេតបឋម ឬ តាមរយៈការសម្របសម្រួលជាមួយនឹងស្ថាប័ន NHRIs និងសារព័ត៌មានជាតិ។
- **ចូលរួមចំណែកលើការងារនៃគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស**តាមរយៈការជូនដំណឹងដល់គណកម្មាធិការអំពីវឌ្ឍនភាពរបស់រដ្ឋាភិបាលនៅក្នុងការអនុវត្តសេចក្តីសង្កេតសរុប និងអនុសាសន៍ ហើយនឹងផ្តល់ព័ត៌មានផ្តោតលើគោលដៅជាក់លាក់ជូនគណកម្មាធិការ។

៦. វិធីដាក់បណ្តឹងជាលក្ខណៈបុគ្គលទៅគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស

បុគ្គលណាម្នាក់ដែលចោទប្រកាន់ថា សិទ្ធិរបស់ខ្លួនដូចមានចែងនៅក្នុងសន្ធិសញ្ញាត្រូវបានរំលោភដោយរដ្ឋភាគីអាចបញ្ជូនបណ្តឹងមកគណកម្មាធិការពាក់ព័ន្ធបាន**ប្រសិនបើរដ្ឋភាគីបានទទួលស្គាល់សមត្ថកិច្ចរបស់គណកម្មាធិការក្នុងការទទួលបណ្តឹងបែបនេះ។** បណ្តឹងទាំងឡាយអាចដាក់ប្តឹងដោយ**ភាគីទីបី រួមទាំង** តួអង្គសង្គមស៊ីវិលក្នុងនាមបុគ្គល ប្រសិនបើបុគ្គលនោះបានផ្តល់ការយល់ព្រមជាលាយលក្ខណ៍អក្សរឲ្យប្តឹង ("លិខិតតំណាងដោយអាណត្តិ") ឬ ក្នុងករណីបុគ្គលនោះមិនអាចផ្តល់ការយល់ព្រមបែបនេះ។

**បណ្តឹងជាលក្ខណៈបុគ្គលអាចដាក់ប្តឹងបានក្នុងករណីដែលឧបាស្រ័យក្នុងស្រុកត្រូវបានប្រើប្រាស់អស់លទ្ធភាព និងក្រោយពីបានបំពេញលក្ខខណ្ឌប្តឹងរួចហើយ។**

i. សម្រាប់ព័ត៌មានបន្ថែមស្តីពី**បណ្តឹងជាលក្ខណៈបុគ្គល** សូមមើលឧបសម្ព័ន្ធនៅក្នុងជំពូកនេះ និងជំពូក VIII (**ការដាក់បណ្តឹងការចោទប្រកាន់ការរំលោភសិទ្ធិមនុស្ស**) នៅក្នុងសៀវភៅណែនាំនេះ។

## ៧. ការផ្តល់ព័ត៌មានសម្រាប់កិច្ចស្រាវជ្រាវសម្ងាត់

តួអង្គសង្គមស៊ីវិលតាមរយៈការផ្តល់ព័ត៌មានជូនទៅគណកម្មាធិការអាចមានឥទ្ធិពលលើសេចក្តីសម្រេចនៃគណកម្មាធិការក្នុងការបំពេញកិច្ចស្រាវជ្រាវសម្ងាត់ណាមួយដែលជាយន្តការសំខាន់អនុញ្ញាតឲ្យតួអង្គសង្គមស៊ីវិលពាំនាំការរំលោភ និងស្ថានភាពនៃក្តីបារម្ភជូនទៅគណកម្មាធិការចាប់អារម្មណ៍។

កិច្ចស្រាវជ្រាវសម្ងាត់ភាគច្រើនត្រូវបានជម្រុញដោយព័ត៌មានដែលអង្គការ NGOs បានដាក់ជូន។ ឧទាហរណ៍ កិច្ចស្រាវជ្រាវសម្ងាត់ចំនួន ៧ ដែលបានធ្វើឡើងដោយគណៈកម្មាធិការទទួលបន្ទុកប្រឆាំងនឹងទារុណកម្ម (នៅប្រេស៊ីល អេហ្ស៊ីប ម៉ិចស៊ិក ប៉េរ៉ូ សែបប៊ី និងម៉ុងតេណេក្រូ ស្រីលង្កា និងតួគី) ត្រូវបានផ្តួចផ្តើមឡើងដោយផ្អែកលើមូលដ្ឋាននៃព័ត៌មានដែលបានទទួលមកពីអង្គការ NGOs។ គណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទបានបញ្ចប់កិច្ចស្រាវជ្រាវមួយរួចហើយ (លើប្រទេសម៉ិចស៊ិក)។

តួអង្គសង្គមស៊ីវិលក៏អាចផ្តល់ជូនព័ត៌មានបន្ថែមនៅពេលកិច្ចស្រាវជ្រាវសម្ងាត់នោះកំពុងដំណើរការធ្វើឡើង។

| ការចូលរួមរបស់អង្គការ NGO នៅក្នុងការផ្តួចផ្តើមកិច្ចស្រាវជ្រាវសម្ងាត់ | | |
|---|---|---|
| កិច្ចស្រាវជ្រាវបឋមអនុលោមតាមមាត្រា ៨ នៅក្នុងពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទត្រូវបានផ្តួចផ្តើមឡើងដោយផ្អែកលើមូលដ្ឋាននៃព័ត៌មានដែលអង្គការ NGOs ចំនួន ៣ ពោលគឺ **អង្គការ** Equality Now **អង្គការ** Casa Amiga និង **គណៈកម្មាធិការម៉ិកស៊ិកទទួលបន្ទុកការការពារ និងការលើកកម្ពស់សិទ្ធិមនុស្ស** បានផ្តល់ជូនគណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទពី។ កិច្ចស្រាវជ្រាវនេះពាក់ព័ន្ធនឹងការកាប់សម្លាប់ និងការបាត់ខ្លួនស្ត្រីចំនួនជាង ២០០ នាក់ នៅ Ciudad Juarez ប្រទេស**ម៉ិកស៊ិក**។ អង្គការ NGOs បានដាក់ | ព័ត៌មានលម្អិតអំពីការចោទប្រកាន់ការចាត់ពង្រត់ ការរំលោភសេពសន្ថវៈ និងឃាតកម្មលើស្ត្រីចាប់តាំងពីឆ្នាំ១៩៩៣មក។ គណៈកម្មាធិការបានរកឃើញថា ព័ត៌មាននេះអាចទុកចិត្តបាន ហើយរួមមានការចង្អុលបង្ហាញដោយមានភ័ស្តុតាងអំពីការរំលោភធ្ងន់ធ្ងរ និងជាលក្ខណៈប្រព័ន្ធលើសិទ្ធិទាំងឡាយដូចមានចែងនៅក្នុងអនុសញ្ញា។<br><br>នៅក្នុងអំឡុងពេលបំពេញកិច្ចស្រាវជ្រាវដែលបានធ្វើឡើងនៅក្នុងខែតុលា ឆ្នាំ២០០៣ អង្គការ NGOs បានដាក់ព័ត៌មានបន្ថែម និងបានចូលរួមយ៉ាងសកម្មនៅក្នុងដំណើរទស្សនកិច្ចរបស់សមាជិកគណៈកម្មាធិការ ២ រូបទៅកាន់ប្រទេសម៉ិកស៊ិក។ ការចូលរួមយ៉ាងសកម្មរបស់អង្គការ NGOs និងរដ្ឋភាគីបានចេញ | របាយការណ៍លម្អិតមួយលើកឡើងអំពីការរំលោភ និងសាវតារសង្គមវប្បធម៌ដែលហេតុការណ៍ទាំងនោះបានកើតឡើងដោយផ្តោតលើឫសគល់ដែលនាំឲ្យកើតមានអំពើហិង្សាប្រឆាំងនឹងស្ត្រីភេទ ហើយបានផ្តល់អនុសាសន៍យ៉ាងរឹងម៉ាំដើម្បីធានាឲ្យសម្រេចបានសិទ្ធិទាំងឡាយដូចមានចែងនៅក្នុងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ។<br><br>របាយការណ៍ និងការឆ្លើយតបពីរដ្ឋាភិបាលម៉ិកស៊ិកត្រូវបានដាក់នៅលើ**គេហទំព័រនៃផ្នែកលើកកម្ពស់ការវិវឌ្ឍរីកចម្រើនរបស់ស្ត្រីភេទ**។ |

i. តួអង្គសង្គមស៊ីវិលដែលមានបំណងដាក់ព័ត៌មានជូន**កិច្ចស្រាវជ្រាវសម្ងាត់** សូមផ្ញើមកកាន់៖

[ឈ្មោះគណកម្មាធិការ]
c/o ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

8–14, avenue de la Paix
CH–1211 ទីក្រុងហ្សឺណែវ 10 – ប្រទេសស្វីស
ទូរសារ: +41 (0)22 917 90 29

## ៨. ការផ្តល់ព័ត៌មានសម្រាប់នីតិវិធីពាក់ព័ន្ធនឹងការដាស់តឿនបឋម និងចំណាត់ការបន្ទាន់

ព័ត៌មានដែលតួអង្គសង្គមស៊ីវិលបានដាក់ជូនអាចជួយជម្រុញឲ្យគណកម្មាធិការទទួលបន្ទុកការលុបបំបាត់ការរើសអើងពូជសាសន៍ចេញនូវការដាស់តឿនបឋម និងធ្វើចំណាត់ការបន្ទាន់។ នាពេលមុន នីតិវិធីទាំងនេះត្រូវបានផ្តួចផ្តើមឡើងផ្អែកលើព័ត៌មានដែលបានទទួលពីអង្គការ NGOs និងក្រុមជនជាតិដើមភាគតិច។

i. សម្រាប់ព័ត៌មានបន្ថែមស្តីពី**បណ្តឹងជាលក្ខណៈបុគ្គល** សូមមើល**ឧបសម្ព័ន្ធនៅក្នុងជំពូកនេះ** និងជំពូក VIII (ការដាក់បណ្តឹងការចោទប្រកាន់ការរំលោភសិទ្ធិមនុស្ស) នៅក្នុង*សៀវភៅណែនាំ*នេះ។

## ៩. ការចូលរួម និងការរួមចំណែកនៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់ប្រធាន និងសមាជិកអន្តរគណកម្មាធិការ

កិច្ចប្រជុំទាំងនេះបើកឲ្យតួអង្គសង្គមស៊ីវិលចូលរួមក្នុងនាមជា**អ្នកសង្កេតការណ៍**។

កិច្ចប្រជុំអន្តរគណកម្មាធិការមានរបៀបវារៈដែលអនុញ្ញាតឲ្យអង្គការ NGOs ប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយនឹងសមាជិកគណកម្មាធិការលើប្រធានបទទូទៅពាក់ព័ន្ធនឹងដំណើរការ នីតិវិធី និងវិធីសាស្ត្របំពេញការងាររបស់គណកម្មាធិការសន្ធិសញ្ញា។

# ឃ. ធនធាននៃការិយាល័យ OHCHR

# គេហទំព័រនៃគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សនៃការិយាល័យ OHCHR

ព័ត៌មាន និងឯកសារពាក់ព័ន្ធនឹងគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សអាចរកបានជាសាធារណនៅលើ**គេហទំព័រនៃការិយាល័យ OHCHR**។ គេហទំព័រនៃគណកម្មាធិការសន្ធិសញ្ញានីមួយៗមានទំព័របង្ហាញព័ត៌មានស្តីពីសន្ធិសញ្ញា ការផ្តល់សច្ចាប័នថ្មីៗ សម័យប្រជុំគណកម្មាធិការពីមុន និងនាពេលខាងមុខ វិធីបំពេញការងារ និងព័ត៌មានផ្សេងទៀត។

ម្យ៉ាងវិញទៀត **ប្រព័ន្ធមូលដ្ឋានទិន្នន័យនៃគណកម្មាធិការសន្ធិសញ្ញានៅលើគេហទំព័រ**នៃការិយាល័យ OHCHR អនុញ្ញាតឲ្យពិនិត្យមើលឯកសារជាច្រើនប្រភេទពាក់ព័ន្ធនឹងគណកម្មាធិការសន្ធិសញ្ញា រួមទាំង របាយការណ៍របស់រដ្ឋភាគី សេចក្តីសង្កេតសរុប សេចក្តីពន្យល់ទូទៅ និងសេចក្តីសម្រេចលើបណ្តឹងនីមួយៗ។

សលាកប័ត្រនៃការិយាល័យ OHCHR

សលាកប័ត្រនៃការិយាល័យ OHCHR ផ្តល់ព័ត៌មានស្តីពីសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ និងគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស។ បញ្ជីស្តីពីសលាកប័ត្រថ្មីៗ និងដែលត្រូវបានធ្វើបច្ចុប្បន្នភាពទៀងទាត់អាចរកមើលបាននៅលើទំព័របោះពុម្ពផ្សាយក្នុងគេហទំព័រនៃការិយាល័យ OHCHR។

ឌីវីឌីស្តីពី "ការបញ្ជ្រៀបសិទ្ធិមនុស្សនៅក្នុងប្រទេស (Bringing Human Rights Home)" របស់គណកម្មាធិការសន្ធិសញ្ញានៃការិយាល័យ OHCHR

ការិយាល័យ OHCHR បានផលិតឧបករណ៍បណ្តុះបណ្តាលស្តីពីការងារនៃគណកម្មាធិការក្នុងទម្រង់ជាឌីវីឌីដែលមានចំណងជើង "គណកម្មាធិការសន្ធិសញ្ញា៖ ការបញ្ជៀបសិទ្ធិមនុស្សនៅក្នុងប្រទេស"។ **បញ្ជរព័ត៌មាន និងឯកសារបោះពុម្ពផ្សាយនៃការិយាល័យ OHCHR** អាច ផ្តល់ជូនឌីវីឌីតាមសំណើសុំ។ សូមទាក់ទង publications@ohchr.org។

## ប្រព័ន្ធ Extranet

គណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សចំនួន ៣ ពោលគឺ គណកម្មាធិការទទួលបន្ទុកប្រឆាំងនឹងទារុណកម្ម គណកម្មាធិការទទួលបន្ទុកការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ និងគណកម្មាធិការទទួលបន្ទុកពលករទេសន្តរប្រវេសន៍មានទំព័រ Extranet របស់ខ្លួនរៀងៗខ្លួន។ ទំព័រ Extranet នីមួយៗបញ្ចូលព័ត៌មានលម្អិតអំពីរបាយការណ៍រដ្ឋ របាយការណ៍សង្គមស៊ីវិល ព័ត៌មានទាក់ទងនឹងកិច្ចប្រជុំគណកម្មាធិការ និងព័ត៌មានពាក់ព័ន្ធផ្សេងទៀត។

i. ដើម្បីចូលទៅកាន់ទំព័រ Extranet មានលេខកូដសម្ងាត់ សូមបំពេញទម្រង់បែបបទតាមប្រព័ន្ធអនឡាញដែលអាចរកបាននៅលើទំព័រនៃក្រុមប្រឹក្សាសិទ្ធិមនុស្សនៅក្នុងគេហទំព័រនៃការិយាល័យ OHCHR។ នៅពេលបំពេញទម្រង់បែបបទ លោកអ្នកនឹងទទួលបានឈ្មោះអ្នកប្រើប្រាស់ និងលេខកូដសម្ងាត់តាមរយៈអ៊ីមែល។

## លិបិក្រមសិទ្ធិមនុស្សសាកល (Index)

**លិបិក្រមសិទ្ធិមនុស្សសាកល** (Index) គឺជាឧបករណ៍ព័ត៌មានតាមប្រព័ន្ធអនឡាញដែលបានរៀបចំឡើងជាចំបងដើម្បីសម្រួលការចូលមើលឯកសារស្តីពីសិទ្ធិមនុស្សដែលបានចេញដោយគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស និងយន្តការនីតិវិធីពិសេសនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស។ គេហទំព័រ

ថ្មីនេះ (ដែលអាចចូលមើលបានតាមរយៈគេហទំព័រនៃការិយាល័យ OHCHR) រួមមានសេចក្តីសង្កេតសរុបទាំងអស់ដែលបានចេញដោយគណកម្មាធិការសន្ធិសញ្ញាចាប់តាំងពីឆ្នាំ២០០០ ព្រមទាំងសេចក្តីសន្និដ្ឋាន និងអនុសាសន៍នៃយន្តការនីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សស្តីពីប្រទេសជាក់លាក់ដែលបានអនុម័តអនុសញ្ញាចាប់តាំងពីឆ្នាំ២០០៦។ លិបិក្រមនេះនឹងបើកឲ្យមើលអនុសាសន៍ដែលបានធ្វើឡើងក្នុងក្របខណ្ឌនៃយន្តការពិនិត្យមើលរបាយការណ៍ជាសាកលតាមកាលកំណត់របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សក្នុងពេលឆាប់ៗខាងមុខនេះ។

ឧបសម្ព័ន្ធ៖ សារតារនៃគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស

ទោះបីជាគណកម្មាធិការមានសកម្មភាព នីតិវិធី និងការអនុវត្តដូចគ្នាក៏ដោយ ក៏គណកម្មាធិការនីមួយៗ មានលក្ខខណ្ឌតម្រូវរៀងៗខ្លួន។ ព័ត៌មានខាងក្រោមបង្ហាញព័ត៌មានសង្ខេបអំពីគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សនីមួយៗ។

<table>
<tr><td colspan="2">គណកម្មាធិការសិទ្ធិមនុស្ស</td></tr>
<tr><td>

*ឃ្លាំមើល*

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (កតិកាសញ្ញា ICCPR) និងពិធីសារបន្ថែម។

*សមាជិកភាព*

អ្នកជំនាញឯករាជ្យ ១៨ នាក់ដែលត្រូវបានជ្រើសតាំងសម្រាប់រយៈពេល ៤ ឆ្នាំ ហើយអាចបន្តសមាជិកភាពទៀតបាន។

*សម័យប្រជុំ*

គណកម្មាធិការជួបប្រជុំ ៣ ដង ក្នុងមួយឆ្នាំនៅក្នុងសម័យប្រជុំរយៈពេល ៣ សប្តាហ៍ ជាធម្មតា នៅក្នុងខែមីនា នៅទីស្នាក់ការកណ្តាលនៃអង្គការសហប្រជាជាតិនៅបុរីញូវយ៉ក និងនៅក្នុងខែកក្កដា និងតុលា/វិច្ឆិកានៅអង្គការសហប្រជាជាតិក្នុងទីក្រុងហ្សឺណែវ។

</td><td>

កំណត់បញ្ជីស្តីពីបញ្ហានានាដែលត្រូវលើកឡើងនៅក្នុងសម័យប្រជុំរបស់គណកម្មាធិការនាពេលក្រោយ។ ព័ត៌មានទាំងអស់ត្រូវដាក់ក្នុងទម្រង់អេឡិចត្រូនិក និងជាក្រដាស (យ៉ាងហោចណាស់ ២៥ ច្បាប់) ជូនលេខាធិការដ្ឋាន នៃគណកម្មាធិការតាមរយៈអាសយដ្ឋានខាងក្រោម។

*ការចូលរួមសម័យប្រជុំរបស់គណកម្មាធិការ*

អង្គការ NGOs និងតួអង្គសង្គមស៊ីវិលអាចចូលរួមកិច្ចប្រជុំរបស់គណកម្មាធិការក្នុងនាមជាអ្នកសង្កេតការណ៍បាន។ ប្រសិនបើចង់ចូលរួមប្រជុំ ជាដំបូង អង្គការ NGOs និងតួអង្គសង្គមស៊ីវិល ចាំបាច់ត្រូវសរសេរមកកាន់លេខាធិការដ្ឋានតាមរយៈអាសយដ្ឋានខាងក្រោមស្នើសុំសិទ្ធិចូលរួម។ នៅថ្ងៃប្រជុំដំបូងដែលពិចារណារបាយការណ៍របស់រដ្ឋភាគី គណកម្មាធិការកំណត់ពេលាសម្រាប់ តួអង្គសង្គមស៊ីវិល ជាពិសេស NGOs ដើម្បីផ្តល់ព័ត៌មានសង្ខេបបឋមដោយផ្ទាល់មាត់នៅក្នុងសម័យប្រជុំសម្ងាត់។ ការផ្តល់ព័ត៌មាន

</td></tr>
</table>

| | |
|---|---|
| *លក្ខខណ្ឌនៃរបាយការណ៍*<br><br>ដំបូង រដ្ឋភាគីត្រូវធ្វើរបាយការណ៍ក្នុងរយៈពេល ១ ឆ្នាំក្រោយក្លាយជាភាគីនៃកតិកាសញ្ញា និងបន្ទាប់មក នៅពេលគណកម្មាធិការស្នើសុំ (នៅចន្លោះរយៈពេល ៣ ទៅ ៥ ឆ្នាំ)។ ជាធម្មតា សេចក្តីសង្កេតសរុបនៃរបាយការណ៍មុនៗនឹងត្រូវបានបញ្ជាក់ទទួលយកនៅពេលដល់កាលបរិច្ឆេទដាក់របាយការណ៍បន្ទាប់។<br><br>*ការដាក់ព័ត៌មានជាលាយលក្ខណ៍អក្សរ*<br>អង្គការ NGOs និងតួអង្គសង្គមស៊ីវិលផ្សេងទៀត ដូចជា ស្ថាប័នស្រាវជ្រាវ និងសមាគមវិជ្ជាជីវៈអាចដាក់ព័ត៌មាន ឬ របាយការណ៍ជាលាយលក្ខណ៍អក្សរ ជូនលេខាធិការដ្ឋាននៃគណកម្មាធិការ។ ព័ត៌មាន និងរបាយការណ៍នេះអាចដាក់នៅពេលណាក៏បាន ក៏ប៉ុន្តែបើជាការល្អនោះនៅក្នុងរយៈពេល ២ សប្តាហ៍មុនសម័យប្រជុំពិនិត្យលើរបាយការណ៍របស់ប្រទេសណាមួយ និងក្នុងរយៈពេល ៦ សប្តាហ៍នៅមុនកិច្ចប្រជុំនៃក្រុមការងារទទួលបន្ទុករបាយការណ៍ប្រចាំប្រទេសដែលជាអ្នក | សង្ខេបបឋមនៅក្នុងម៉ោងអាហារពេលព្រឹក និងពេលថ្ងៃត្រង់ត្រូវបានរៀបចំឡើងជាទៀងទាត់ដើម្បីអនុញ្ញាតឲ្យអង្គការ NGOs និងតួអង្គសង្គមស៊ីវិលផ្សេងទៀតផ្តល់ព័ត៌មានចុងក្រោយអំពីប្រទេសណាមួយជាក់លាក់។<br><br>ក្រុមការងារទទួលបន្ទុករបាយការណ៍ប្រទេសជួបប្រជុំជាលក្ខណៈឯកជននៅក្នុងអំឡុងសម័យប្រជុំរបស់គណកម្មាធិការដើម្បីរៀបចំបញ្ជីស្តីពីបញ្ហានានាទាក់ទងនឹងរបាយការណ៍របស់រដ្ឋដែលនឹងត្រូវពិនិត្យនៅក្នុងសម័យប្រជុំលើកក្រោយរបស់គណកម្មាធិការ។ ដូច្នេះ តួអង្គសង្គមស៊ីវិលអាចរៀបចំកិច្ចប្រជុំផ្តល់ព័ត៌មានសង្ខេបបឋមជាមួយនឹងសមាជិកគណកម្មាធិការបាន។<br><br>*បណ្តឹងជាលក្ខណៈបុគ្គល*<br>**បណ្តឹងជាលក្ខណៈបុគ្គល**អនុលោមតាមពិធីសារបន្ថែមលើកទីមួយនៃកតិកាសញ្ញាអាចបញ្ជូនទៅកាន់៖ |

| | |
|---|---|
| **ក្រុមទទួលញត្តិ**<br>ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស<br><br>8–14, avenue de la Paix<br>CH–1211 ទីក្រុងហ្សឺណែវ 10 - ប្រទេសស្វីស<br>ទូរសារ: + 41 (0)22 917 90 22<br>(ជាពិសេសសម្រាប់បណ្ដឹងបន្ទាន់)<br><br>អ៊ីមែល: tb-petitions@ohchr.org<br><br>*អាស័យដ្ឋានទំនាក់ទំនងលម្អិតរបស់លេខាធិការដ្ឋាន*<br><br>គណកម្មាធិកាសិទ្ធិមនុស្ស<br>c/o ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស<br><br>8–14, avenue de la Paix | CH–1211 ទីក្រុងហ្សឺណែវ 10 - ប្រទេសស្វីស<br>ទូរសារ: + 41 (0)22 917 90 29<br>ទូរស័ព្ទ: +41 (0)22 917 93 32 ឬ<br>+41 (0)22 917 93 95<br><br>ដើម្បីស្វែងយល់បន្ថែមអំពីគណកម្មាធិការសិទ្ធិមនុស្ស សូមពិគ្រោះសលាកប័ត្រលេខ ១៥ (វិ.លើកទី១)។ ដើម្បីស្វែងយល់បន្ថែមអំពីពិធីសារបន្ថែមទីមួយនៃកតិកាសញ្ញា សូមចូលទៅកាន់ផ្នែកគណកម្មាធិការសន្ធិសញ្ញានៅលើគេហទំព័ររបស់ការិយាល័យ OHCHR។<br><br>**គម្រូទម្រង់បែបបទបណ្ដឹងមាននៅក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយនឹងជំពូក VIII (ការដាក់បណ្ដឹងចោទប្រកាន់ការរំលោភសិទ្ធិមនុស្ស)** នៅក្នុង*សៀវភៅណែនាំ*នេះ។ |

| គណកម្មាធិការស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | |
|---|---|
| *ឃ្លាំមើល*<br><br>កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (កតិកា ICESCR)។ ចូរកត់សម្គាល់ថាក្រុមប្រឹក្សាសិទ្ធិមនុស្សបានអនុម័តពិធីសារបន្ថែមនៃកតិកាសញ្ញានេះនៅក្នុងខែមិថុនា ឆ្នាំ២០០៨។ មហាសន្និបាតក៏រំពឹងថានឹងអនុម័តពិធីសារបន្ថែមនេះនៅក្នុងឆ្នាំ២០០៨។<br><br>*សមាជិកភាព* | តាមទម្លាប់ រដ្ឋភាគីផ្ដួចផ្ដើមធ្វើរបាយការណ៍ក្នុងរយៈពេល ២ ឆ្នាំ ក្រោយក្លាយជាភាគីនៃកតិកាសញ្ញា និងបន្ទាប់មករៀងរាល់ ៥ ឆ្នាំ ឬ បើមិនដូច្នោះទេ ទៅតាមសំណើសុំរបស់គណកម្មាធិការ។<br><br>*ការដាក់ព័ត៌មានជាលាយលក្ខណ៍អក្សរ*<br><br>អង្គការ NGOs និងតួអង្គសង្គមស៊ីវិលផ្សេងទៀត ដូចជា មូលនិធិស្រាវជ្រាវ និងសមាគមវិជ្ជាជីវៈ និងក្រុមជនជាតិដើមភាគតិចអាចដាក់ព័ត៌មាន ឬរបាយការណ៍ជាលាយលក្ខណ៍អក្សរជូនលេខាធិការ |

| | |
|---|---|
| អ្នកជំនាញឯករាជ្យ ១៨ នាក់ដែលត្រូវបានជ្រើសតាំងសម្រាប់រយៈពេល ៤ ឆ្នាំ ហើយអាចបន្តសមាជិកភាពទៀតបាន។<br><br>*សម័យប្រជុំ*<br><br>គណកម្មាធិការជួបប្រជុំ ២ ដង ក្នុងមួយឆ្នាំនៅក្នុងសម័យប្រជុំរយៈពេល ៣ សប្តាហ៍ ដោយមានកិច្ចប្រជុំត្រៀមរៀបចំរបស់ក្រុមការងាររយៈពេល ១ សប្តាហ៍ផងដែរ ជាធម្មតា នៅក្នុងខែឧសភា និងវិច្ឆិកានៅទីស្នាក់ការកណ្តាលនៃអង្គការសហប្រជាជាតិ នៅទីក្រុងហ្សឺណែវ។<br><br>*លក្ខខណ្ឌនៃរបាយការណ៍*<br><br>ទោះបីជាកតិកាសញ្ញាពុំចែងអំពីកាលកំណត់នៃការធ្វើរបាយការណ៍ក៏ដោយ | ដ្ឋាននៃគណកម្មាធិការសម្រាប់ទាំងសម័យប្រជុំពិនិត្យរបាយការណ៍ និងទាំងកិច្ចប្រជុំរៀបចំ។ ព័ត៌មាននេះអាចដាក់នៅពេលណាក៏បាន ក៏ប៉ុន្តែបើជាការល្អនោះនៅក្នុងរយៈពេល ១ សប្តាហ៍មុនក្នុងទម្រង់អេឡិចត្រូនិក និងជាក្រដាសជូនទៅអាសយដ្ឋានខាងក្រោម។ ឯកសារនេះយ៉ាងហោចណាស់ចំនួន ២៥ ច្បាប់ គួរដាក់ជូនសម័យប្រជុំពិនិត្យរបាយការណ៍ និងយ៉ាងហោចណាស់ចំនួន ១០ ច្បាប់គួរដាក់ជូនកិច្ចប្រជុំត្រៀមរៀបចំ។<br><br>ចូរកត់សម្គាល់ថា លេខាធិការដ្ឋាននឹងចែកចាយព័ត៌មានជាលាយលក្ខណ៍ដែលត្រូវបានដាក់ជាផ្លូវការដោយតួអង្គសង្គមស៊ីវិលពាក់ព័ន្ធនឹងការពិចារណាលើរបាយការណ៍របស់រដ្ឋភាគីជាក់លាក់ណាមួយជូនតំណាង |

| | |
|---|---|
| រដ្ឋឲ្យបានឆាប់តាមដែលអាចធ្វើទៅបានលើកលែងតែមានការដាក់លក្ខណៈសម្គាល់ជាក់លាក់ថា "សម្ងាត់"។<br><br>**អង្គការ NGOs ក្នុងឋានៈជាអង្គការពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម (ក្រុមប្រឹក្សា ECOSOC) (ឬក្នុងភាពជាដៃគូជាមួយនឹងអង្គការ NGO ណាមួយដែលមានឋានៈបែបនេះ) អាចដាក់សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរជូនលេខាធិការដ្ឋានសម្រាប់បោះពុម្ពផ្សាយជាភាសាការងារនៃគណកម្មាធិការនៅក្នុងសម័យប្រជុំពិនិត្យរបាយការណ៍។** សេចក្តីថ្លែងការណ៍របស់អង្គការ NGOs ត្រូវមានលក្ខណៈជាក់លាក់អំពីមាត្រា | *ការចូលរួមសម័យប្រជុំរបស់គណកម្មាធិការ*<br><br>តួអង្គសង្គមស៊ីវិលអាចចូលរួមកិច្ចប្រជុំរបស់គណកម្មាធិការក្នុងនាមជាអ្នកសង្កេតការណ៍។ ប្រសិនបើចង់ចូលរួមប្រជុំអង្គការ តួអង្គសង្គមស៊ីវិលចាំបាច់ត្រូវសរសេរមកកាន់លេខាធិការដ្ឋានតាមរយៈអាសយដ្ឋានខាងក្រោមស្នើសុំសិទ្ធិចូលរួម។ អង្គការ NGOs ស្ថាប័ន NHRIs និងអ្នកជំនាញម្នាក់ៗអាចធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់នៅវគ្គពេលព្រឹកដំបូងនៃកិច្ចប្រជុំរបស់ក្រុមការងារត្រៀមរៀបចំដែលជាធម្មតាបានរៀបចំឡើងនៅថ្ងៃចន្ទចាប់ពីម៉ោង ១០.៣០ ព្រឹកដល់ ម៉ោង ១ រសៀល ព្រមទាំងនៅក្នុងអំឡុងពេលនៃការស្តាប់អង្គការ NGO ដែលរៀបចំឡើងនៅថ្ងៃដំបូងនៃសម័យប្រជុំពិនិត្យរបាយការណ៍ចាប់ពីម៉ោង ៣ ដល់ ម៉ោង ៤ រសៀល។ សេចក្តីថ្លែងការណ៍នេះអនុញ្ញាតឲ្យធ្វើឡើងរយៈ |

| | |
|---|---|
| នៃកតិកាសញ្ញាដោយផ្តោតលើបញ្ហាបន្ទាន់ យោងតាមទស្សនវិស័យរបស់សង្គមស៊ីវិល និង ត្រូវបញ្ជូនមកដល់លេខាធិការដ្ឋានយ៉ាងយូរ បំផុតត្រឹមរយៈពេល ៣ ខែ នៅមុនសម័យប្រជុំ ដែលគ្រោងនឹងធ្វើឡើង។ | ពេល ១៥ នាទី។ |

| | |
|---|---|
| នៅរាល់សម័យប្រជុំ គណៈកម្មាធិការកំណត់រយៈពេល មួយថ្ងៃ ជាធម្មតា នៅថ្ងៃចន្ទនៃសប្តាហ៍ទី ៣ សម្រាប់ ពិភាក្សាលើប្រធានបទទូទៅអំពីសិទ្ធិជាក់លាក់ ឬ ទិដ្ឋភាពជាក់លាក់នៃកតិកាសញ្ញា។ អង្គការ NGOs និងអ្នកចូលរួមនៃសង្គមស៊ីវិលជំនាញៗ រួមទាំង អ្នក សិក្សាស្រាវជ្រាវ និងសមាជិកក្រុមវិជ្ជាជីវៈអាចដាក់ ឯកសារសារតារ ឬ អាចចូលរួមនៅក្នុងថ្ងៃពិភាក្សាលើ ប្រធានបទទូទៅបាន។<br>*អាស័យដ្ឋានទំនាក់ទំនងលម្អិតរបស់លេខាធិការដ្ឋាន*<br>**គណៈកម្មាធិការស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌**<br>c/o ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស<br>8–14, avenue de la Paix<br>CH–1211 ទីក្រុងហ្សឺណែវ 10 - ប្រទេសស្វីស<br>ទូរសារ: + 41 (0)22 917 90 29 | ដើម្បីស្វែងយល់បន្ថែមអំពី**គណៈកម្មាធិការទទួលបន្ទុក សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌** សូមពិគ្រោះ តារាងសលាកប័ត្រលេខ ១៦ (វិ.លើកទី១)។ ដើម្បី ស្វែងយល់បន្ថែមអំពីការចូលរួមរបស់សង្គមស៊ីវិល ជាមួយនឹងគណៈកម្មាធិការ សូមចូលទៅកាន់ផ្នែកគណៈ កម្មាធិការសន្ធិសញ្ញានៅលើគេហទំព័រនៃការិយាល័យ OHCHR។ |

| គណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់ការរើសអើងពូជសាសន៍ | |
|---|---|
| *ឃ្លាំមើល*<br>អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការ រើសអើងពូជសាសន៍ (អនុសញ្ញា ICERD)។ | *ការដាក់ព័ត៌មានជាលាយលក្ខណ៍អក្សរ*<br>អង្គការ NGOs និងតួអង្គសង្គមស៊ីវិល ផ្សេងទៀត ដូចជា សមាគមវិជ្ជាជីវៈ |

| | |
|---|---|
| *សមាជិកភាព*<br><br>អ្នកជំនាញឯករាជ្យ ១៨ នាក់ដែលត្រូវបានជ្រើសតាំងសម្រាប់រយៈពេល ៤ ឆ្នាំ ហើយអាចបន្តសមាជិកភាពទៀតបាន។<br><br>*សម័យប្រជុំ*<br><br>គណកម្មាធិការជួបប្រជុំនៅទីស្នាក់ការកណ្តាលនៃអង្គការសហប្រជាជាតិនៅទីក្រុងហ្សឺណែវ និងបើកកិច្ចប្រជុំរយៈពេល ៣ សប្តាហ៍ ចំនួន ២ នៅក្នុងខែកុម្ភៈ និងសីហាជារៀងរាល់ឆ្នាំ។<br><br>*លក្ខខណ្ឌនៃរបាយការណ៍*<br><br>ដំបូង រដ្ឋភាគីត្រូវធ្វើរបាយការណ៍ក្នុងរយៈពេល ១ ឆ្នាំក្រោយក្លាយជាភាគីនៃអនុសញ្ញា និងបន្ទាប់មករៀងរាល់ ២ ឆ្នាំម្តង។ ក៏ប៉ុន្តែ កថាខណ្ឌចុងក្រោយនៃសេចក្តីសង្កេតសរុបជាធម្មតាចែងបញ្ជាក់អំពីកាលបរិច្ឆេទកំណត់នៃការដាក់រាបាយការណ៍បន្ទាប់។ | ស្ថាប័នសិក្សាស្រាវជ្រាវ ក្រុមជនជាតិដើមភាគតិច និងស្ថាប័នជំនាញដែលធ្វើការងារលើបញ្ហានានាពាក់ព័ន្ធនឹងសកម្មភាពរបស់គណកម្មាធិការអាចដាក់ព័ត៌មាន ឬ របាយការណ៍ជាលាយលក្ខណ៍អក្សរជូនលេខាធិការដ្ឋាន។ ព័ត៌មាននេះអាចដាក់នៅពេលណាក៏បាន ក៏ប៉ុន្តែបើជាការល្អនោះនៅក្នុងរយៈពេល ២ ខែមុន សម័យប្រជុំពិនិត្យរបាយការណ៍។<br><br>សំណៅជាទម្រង់អេឡិកត្រូនិកនៃព័ត៌មានជាលាយលក្ខណ៍អក្សរមួយច្បាប់ និងសំណៅជាឯកសារក្រដាសចំនួន ៣៧ ច្បាប់ គួរដាក់ជូនលេខាធិការដ្ឋានតាមរយៈអាសយដ្ឋានខាងក្រោម។ តួអង្គសង្គមស៊ីវិលជាតិដែលមានធនធានមានកម្រិតអាចស្នើសុំការជួយជ្រោមជ្រែងពី**សេវាផ្តល់ព័ត៌មានប្រឆាំងនឹងការរើសអើង** (*សេវា* ARIS) ដែលជាអង្គការ NGO អន្តរជាតិនៅទីក្រុងហ្សឺណែវ។ អង្គការនេះអាចជួយបញ្ជូនព័ត៌មានមក និងពីគណកម្មាធិការបាន។ សេវា ARIS អាចផ្តល់សេវាជូនអង្គការ NGOs ថ្នាកជាតិ និងតំបន់ ក្រុម និងបុគ្គលធ្វើការងារលើសិទ្ធិមនុស្ស |
| ផ្សេងទៀត។<br><br>គណកម្មាធិការក៏ទទួលឯកសារជាលាយលក្ខណ៍អក្សរពីសង្គមស៊ីវិលទាក់ទងនឹងពិនិត្យសើរើនៃការអនុវត្តអនុសញ្ញាដោយរដ្ឋភាគីដោយពុំចាំបាច់មានរបាយការណ៍ ចំពោះរបាយការណ៍ | អំឡុងនៃម៉ោងកិច្ចប្រជុំផ្លូវនោះទេ ប៉ុន្តែតួអង្គសង្គមស៊ីវិលអាចរៀបចំកិច្ចប្រជុំបង្ហាញព័ត៌មានសង្ខេបក្រៅផ្លូវការនៅក្នុងអំឡុងម៉ោងអាហារថ្ងៃត្រង់នៅច |

| | |
|---|---|
| របស់រដ្ឋភាគីដែលបានពុំទាន់បានដាក់យ៉ាងហោចណាស់ក្នុងរយៈពេល ៥ ឆ្នាំមកហើយ ព្រមទាំងទាក់ទងនឹង**នីតិវិធីស្តីពីការដាស់តឿនបឋម និងចំណាត់ការបន្ទាន់**។ តួអង្គសង្គមស៊ីវិលជាពិសេសអង្គការ NGOs អាចផ្ញើព័ត៌មានមកកាន់គណកម្មាធិការស្នើសុំឲ្យដោះស្រាយស្ថានភាពដែលពួកគេយល់ឃើញថាមានលក្ខណៈបន្ទាន់អនុលោមតាម នីតិវិធីនេះ។<br><br>*ការចូលរួមសម័យប្រជុំរបស់គណកម្មាធិការ*<br><br>តួអង្គសង្គមស៊ីវិលអាចចូលរួមកិច្ចប្រជុំរបស់គណកម្មាធិការក្នុងនាមជាអ្នកសង្កេតការណ៍តែប៉ុណ្ណោះ។ ប្រសិនបើចង់ចូលរួមប្រជុំ តួអង្គសង្គមស៊ីវិលចាំបាច់ត្រូវសរសេរមកកាន់លេខាធិការដ្ឋានតាមរយៈអាសយដ្ឋានខាងក្រោមដើម្បីស្នើសុំសិទ្ធិចូលរួម។ គណកម្មាធិការពុំកោះប្រជុំជាមួយនឹងអង្គការ NGOs ឬ តួអង្គសង្គមស៊ីវិលដទៃទៀតនៅក្នុង | ន្លោះម៉ោង ១.៤៥ នាទី ដល់ ម៉ោង ២.៤៥ នាទីរសៀលនៅថ្ងៃទីមួយនៃការពិភាក្សារបាយការណ៍ ហើយក៏អាចអញ្ជើញសមាជិកគណកម្មាធិការឲ្យចូលរួមផងដែរ។ តួអង្គសង្គមស៊ីវិលក៏អាចស្នើសុំការជួយជ្រោមជ្រែងពីសេវា ARIS ដែលរៀបចំកិច្ចប្រជុំបង្ហាញពត៌មានសង្ខេបនេះបាន។<br><br>គណកម្មាធិការក៏អាចប្រជុំពិភាក្សាលើបញ្ហាប្រធានបទជាក់លាក់ទាក់ទងនឹងការរើសអើងពូជសាសន៍ និងអនុសញ្ញាផងដែរ ហើយក៏អាចអញ្ជើញតួអង្គសង្គមស៊ីវិល អ្នកសិក្សាស្រាវជ្រាវ អ្នកជំនាញម្នាក់ៗ អង្គការ NGOs និងស្ថាប័នជំនាញឲ្យចូលរួមបង្ហាញការយល់ឃើញរបស់ពួកគេលើប្រធានបទជាក់លាក់នោះ។<br><br>គណកម្មាធិការក៏អាចប្រជុំពិភាក្សាលើបញ្ហាប្រធានបទជាក់លាក់ទាក់ទងនឹងការរើសអើងពូជសាសន៍ និងអនុសញ្ញាផងដែរ ហើយក៏អាចអញ្ជើញតួអង្គសង្គមស៊ីវិល អ្នកសិក្សាស្រាវជ្រាវ អ្នកជំនាញម្នាក់ៗ អង្គការ NGOs |
| និងស្ថាប័នជំនាញឲ្យចូលរួមបង្ហាញការយល់ឃើញរបស់ពួកគេលើប្រធានបទជាក់លាក់នោះ។<br><br>*បណ្តឹងជាលក្ខណៈបុគ្គល*<br><br>**បណ្តឹងជាលក្ខណៈបុគ្គល**អនុលោមតាមមាត្រា ១៤ នៃអនុសញ្ញា | 8–14, avenue de la Paix<br>CH–1211 ទីក្រុងហ្សឺណែវ 10 - ប្រទេសស្វីស<br>ទូរសារ: + 41 (0)22 917 90 29 |

| | |
|---|---|
| អាចបញ្ជូនមកកាន់៖<br><br>**ក្រុមទទួលញត្តិ**<br>ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស<br><br>8–14, avenue de la Paix<br>CH–1211 ទីក្រុងហ្សឺណែវ 10 – ប្រទេសស្វីស<br>ទូរសារ: + 41 (0)22 917 90 22<br>(ជាពិសេសសម្រាប់បណ្តឹងបន្ទាន់)<br>អ៊ីមែល: tb-petitions@ohchr.org<br><br>*អាស័យដ្ឋានទំនាក់ទំនងលម្អិតរបស់លេខាធិការដ្ឋាន*<br><br>**គណកម្មាធិការទទួលបន្ទុកការលុបបំបាត់ការរើសអើងពូជសាសន៍**<br>c/o ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស | ព័ត៌មានបន្ថែមអំពីសេវា ARIS អាចរកបានតាមរយៈ៖<br><br>គេហទំព័រ៖ http://www.antiracism-info.org[49]<br><br>អ៊ីមែល៖ centre-docs@antiracism-info.org<br><br>ដើម្បីស្វែងយល់បន្ថែមអំពី **គណកម្មាធិការទទួលបន្ទុកការរើសអើងពូជសាសន៍** សូមពិគ្រោះសលាកប័ត្រលេខ ១២។<br><br>**គម្រូទម្រង់បែបបទបណ្តឹង** មាននៅក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយនឹងជំពូក VIII (**ការដាក់បណ្តឹងចោទប្រកាន់ការរំលោភសិទ្ធិមនុស្ស**) នៅក្នុង*សៀវភៅណែនាំ*នេះ។ |

[49] ការិយាល័យ OHCHR មិនទទួលខុសត្រូវលើខ្លឹមសារនៃគេហទំព័រពីខាងក្រៅ ហើយបទប្បញ្ញត្តិនៃទំព័រភ្ជាប់នៅលើទំព័រនេះពុំមានន័យថា ការិយាល័យ OHCHR មានការពាក់ព័ន្ធនឹងខ្លឹមសារទាំងនោះឡើយ។

### គណកម្មាធិការទទួលបន្ទុកការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ

*ឃ្លាំមើល*

អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (អនុសញ្ញាCEDAW) និងពិធីសារបន្ថែម

*សមាជិកភាព*

អ្នកជំនាញឯករាជ្យ ២៣ នាក់ដែលត្រូវបានជ្រើសតាំងសម្រាប់រយៈពេល ៤ ឆ្នាំ ហើយ អាចបន្តសមាជិកភាពទៀតបាន។

*សម័យប្រជុំ*

គណកម្មាធិការជួបប្រជុំចំនួន ២ ទៅ ៣ ដងក្នុងមួយឆ្នាំនៅទីក្រុងហ្សឺណែវ និងបុរីញូវយ៉ករយៈពេល ២ សប្តាហ៍ដែលជាធម្មតាសម័យប្រជុំនេះបំពេញបន្ថែមដោយកិច្ចប្រជុំរបស់ក្រុមត្រៀមរៀបចំរយៈពេល ១ សប្តាហ៍។

*លក្ខខណ្ឌនៃរបាយការណ៍*

ដំបូង រដ្ឋភាគីត្រូវធ្វើរបាយការណ៍ក្នុងរយៈពេល ១ ឆ្នាំក្រោយក្លាយជាភាគីនៃអនុសញ្ញា និងបន្ទាប់មកយ៉ាងហោចណាស់រៀងរាល់ ៤ ឆ្នាំម្តង និងនៅពេលណាដែលគណកម្មាធិការស្នើសុំ។

*ការដាក់ព័ត៌មានជាលាយលក្ខណ៍អក្សរ*

អង្គការ NGOs និងតួអង្គសង្គមស៊ីវិលផ្សេងទៀត ដូចជា ក្រុមស្ត្រី អង្គការជំនឿណាមួយ អ្នកជំនាញឯករាជ្យ សមាជិកសភាអាចដាក់ព័ត៌មាន ឬ របាយការណ៍ជាលាយលក្ខណ៍អក្សរជូនលេខាធិការដ្ឋាន។ ព័ត៌មាននេះអាចដាក់នៅពេលណាក៏បាន ក៏ប៉ុន្តែបើជាការល្អនោះនៅក្នុងរយៈពេល ២ សប្តាហ៍មុនកិច្ចប្រជុំត្រៀមរៀបចំ ឬ រយៈពេល ២ ខែនៅមុនសម័យប្រជុំពិនិត្យរបាយការណ៍។ សំណៅជាទម្រង់អេឡិកត្រូនិក និងសំណៅជាឯកសារក្រដាសយ៉ាងហោចណាស់ចំនួន ៣៥ ច្បាប់ គួរដាក់ជូនលេខាធិការដ្ឋានតាមរយៈអាសយដ្ឋានខាងក្រោម។ តួអង្គសង្គមស៊ីវិល ដូចជាស្ថាប័នស្រាវជ្រាវក៏អាចជ្រើសរើសបញ្ជូនច្បាប់ចម្លងនៃឯកសារដែលខ្លួនបានដាក់ទៅអង្គការអន្តរជាតិឃ្លាំមើលសកម្មភាពស្ត្រីភេទនៅតំបន់អាស៊ីប៉ាស៊ីហ្វិក (អង្គការ IWRAW-AP) ដែលជាអង្គការ NGO ជំនាញអាចជួយ

| | |
|---|---|
| បញ្ជូនព័ត៌មានមក និងពីគណកម្មាធិការបាន[50]។<br><br>*ការចូលរួមសម័យប្រជុំរបស់គណកម្មាធិការ*<br><br>តួអង្គសង្គមស៊ីវិលអាចចូលរួមកិច្ចប្រជុំរបស់គណកម្មាធិការក្នុងនាមជាអ្នកសង្កេតការណ៍។ ប្រសិនបើចង់ចូលរួមប្រជុំ តួអង្គសង្គមស៊ីវិលចាំបាច់ត្រូវសរសេរមកកាន់លេខាធិការដ្ឋានតាមរយៈអាសយដ្ឋានខាងក្រោមដើម្បីស្នើសុំសិទ្ធិចូលរួម។ តួអង្គសង្គមស៊ីវិលជាពិសេសអង្គការ NGOs អាចធ្វើបទបង្ហាញដោយផ្ទាល់មាត់ជូនកិច្ចប្រជុំរបស់ក្រុមការងារត្រៀមរៀបចំ (ជាទូទៅ នៅវគ្គប្រជុំព្រឹកដំបូង)។ កិច្ចប្រជុំរបស់ក្រុមការងារត្រៀមរៀបចំជួបប្រជុំគ្នានៅចុងសម័យប្រជុំនៅក្នុងមុនវគ្គពិនិត្យសើរើរបាយការណ៍របស់រដ្ឋាភិបាលណាមួយ។ អង្គការ NGOs ក៏អាចធ្វើបទបង្ហាញដោយផ្ទាល់មាត់ជូនគណកម្មាធិការនៅថ្ងៃដំបូងរៀងរាល់សប្តាហ៍នៃសម័យប្រជុំ។ កិច្ចប្រជុំក្រៅផ្លូវការជាមួយនឹងសមាជិកគណកម្មាធិការអាចពេលខ្លះត្រូវបានរៀបចំឡើងដោយធ្វើការទាក់ទងលេខាធិការដ្ឋានតាមរយៈអាសយដ្ឋានខាងក្រោម។ | *បណ្តឹងជាលក្ខណៈបុគ្គល*<br><br>**បណ្តឹងជាលក្ខណៈបុគ្គលអនុលោមតាមពិធីសារបន្ថែមនៃអនុសញ្ញាអាចបញ្ជូនមកកាន់៖**<br><br>**ក្រុមទទួលញត្តិ**<br>ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស<br><br>8–14, avenue de la Paix<br>CH–1211 ទីក្រុងហ្សឺណែវ 10 – ប្រទេសស្វីស<br>ទូរសារ: + 41 (0)22 917 90 22<br>(ជាពិសេសសម្រាប់បណ្តឹងបន្ទាន់)<br>អ៊ីមែល: tb-petitions@ohchr.org<br><br>**គោលការណ៍ណែនាំ**អនុលោមតាមពិធីសារបន្ថែមនៃអនុសញ្ញាមាននៅក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយនឹង**ជំពូក VIII (ការដាក់បណ្តឹងចោទប្រកាន់ការរំលោភសិទ្ធិមនុស្ស)** នៅក្នុង*សៀវភៅណែនាំ*នេះ។ គម្រូបែបបទលិខិតឆ្លើយឆ្លងអាចរកបានតាមប្រព័ន្ធអនឡាញក្នុងគ្រប់ភាសាទាំងអស់នៃអង្គការសហប្រជាជាតិតាមរយៈគេហទំព័រនៃផ្នែកទទួលបន្ទុកលើការវិវឌ្ឍរីកចម្រើននៃស្ត្រី។ |

| | |
|---|---|
| *កិច្ចស្រាវជ្រាវសម្ងាត់* | *អាសយដ្ឋានទំនាក់ទំនងលម្អិតរបស់លេខាធិការដ្ឋាន* |
| តួអង្គសង្គមស៊ីវិលជាពិសេសអង្គការ NGOs អាច | **គណកម្មាធិការទទួលបន្ទុកការលុបបំបាត់ការរើស** |

[50] ការិយាល័យ OHCHR មិនទទួលខុសត្រូវលើខ្លឹមសារនៃគេហទំព័រពីខាងក្រៅ ហើយបទប្បញ្ញត្តិនៃទំព័រភ្ជាប់នៅលើទំព័រនេះពុំមានន័យថា ការិយាល័យ OHCHR មានការពាក់ព័ន្ធនឹងខ្លឹមសារទាំងនោះឡើយ។

| | |
|---|---|
| ដាក់ព័ត៌មានជាលាយលក្ខណ៍ជូនលេខាធិការដ្ឋាន អំពីការរំលោភធ្ងន់ធ្ងរ ហួសហេតុ ឬ ជាលក្ខណៈប្រព័ន្ធលើអនុសញ្ញា។ ព័ត៌មាននេះធ្វើយ៉ាងណាអាចឲ្យទុកចិត្តបាន ហើយបញ្ជាក់ថា រដ្ឋភាគីកំពុងរំលោភជាលក្ខណៈប្រព័ន្ធលើសិទ្ធិទាំងឡាយដូចមានចែងនៅក្នុងអនុសញ្ញា។ | **អើងប្រឆាំងនឹងស្ត្រីភេទ**<br>c/o ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស<br><br>8–14, avenue de la Paix<br>CH–1211 ទីក្រុងហ្សឺណែវ 10 – ប្រទេសស្វីស<br>ទូរសារ: + 41 (0)22 917 90 29<br>អ៊ីមែល: cedaw@ohchr.org<br><br>ដើម្បីស្វែងយល់បន្ថែមអំពី**គណកម្មាធិការ** សូមពិគ្រោះ **សលាកប័ត្រលេខ ២២ និងសលាកប័ត្រលេខ ៧**។<br><br>សម្រាប់គោលការណ៍ណែនាំស្តីពីនីតិវិធីលើការបង្កើតរបាយការណ៍ជាលាយលក្ខណ៍អក្សរសម្រាប់គណកម្មាធិការ សូមមើលគេហទំព័ររបស់អង្គការ IWRAW-AP។ |

| គណកម្មាធិការទទួលបន្ទុកប្រឆាំងនឹងទារុណកម្ម | |
|---|---|
| *ឃ្លាំមើល*<br><br>អនុសញ្ញាប្រឆាំងនឹងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬ ទណ្ឌកម្មឯកទៀតដែលឃោរឃៅ អមនុស្សធម៌ ឬ បន្ថោកបន្ទាប (អនុសញ្ញា CAT)<br><br>*សមាជិកភាព*<br><br>អ្នកជំនាញឯករាជ្យ ១០ នាក់ដែលត្រូវបានជ្រើសតាំងសម្រាប់រយៈពេល ៤ ឆ្នាំ ហើយ អាចបន្តសមាជិកភាពទៀតបាន។<br><br>*សម័យប្រជុំ*<br><br>គណកម្មាធិការជួបប្រជុំនៅទីក្រុងហ្សឺណែវ និងជាធម្មតារៀបចំសម័យប្រជុំចំនួន ២ ក្នុងមួយឆ្នាំក្នុងនោះ | ឆ្នាំម្តង។<br><br>*ការដាក់ព័ត៌មានជាលាយលក្ខណ៍អក្សរ*<br><br>អង្គការ NGOs និងតួអង្គសង្គមស៊ីវិលផ្សេងទៀត ដូចជា ក្រុមជនរងគ្រោះ អង្គការជំនឿណាមួយតំណាងសហជីព និងសមាគមវិជ្ជាជីវៈអាចដាក់ព័ត៌មាន ឬ របាយការណ៍ជាលាយលក្ខណ៍អក្សរជូនលេខាធិការដ្ឋាន។ ព័ត៌មាននេះអាចដាក់នៅពេលណាក៏បាន ក៏ប៉ុន្តែបើជាការល្អនោះនៅក្នុងរយៈពេល ៦ សប្តាហ៍មុនសម័យប្រជុំរបស់គណកម្មាធិការ។ ធាតុចូលលើបញ្ជីស្តីពីបញ្ហានានាគួរដាក់ក្នុងរយៈពេល ៣ ខែមុនការកាលបរិច្ឆេទកំណត់ដាក់បញ្ជីសម្រាប់ពិនិត្យចុងក្រោយ។ ព័ត៌មានទាំងអស់ត្រូវដាក់ក្នុងទម្រង់ |

រួមមាន កិច្ចប្រជុំពេញអង្គ (រយៈពេល ៣ សប្ដាហ៍នៅក្នុងខែឧសភា និងរយៈពេល ២ សប្ដាហ៍នៅក្នុងខែវិច្ឆិកា) និងកិច្ចប្រជុំរបស់ក្រុមការងារត្រៀមរៀបចំរយៈពេល ១ សប្ដាហ៍។

*លក្ខខណ្ឌនៃរបាយការណ៍*

ដំបូង រដ្ឋភាគីត្រូវធ្វើរបាយការណ៍ក្នុងរយៈពេល ១ ឆ្នាំក្រោយក្លាយជាភាគីនៃអនុសញ្ញា និងបន្ទាប់មកយ៉ាងហោចណាស់រៀងរាល់ ៤

អេឡិកត្រូនិក និងសំណៅជាឯកសារក្រដាសយ៉ាងហោចណាស់ចំនួន ១៥ ច្បាប់ គួរដាក់ជូនលេខាធិការដ្ឋានតាមរយៈអាសយដ្ឋានខាងក្រោម។

ចូរកត់សម្គាល់ថា លេខាធិការដ្ឋាននឹងចែកចាយព័ត៌មានជាលាយលក្ខណ៍ដែលត្រូវបានដាក់ជាផ្លូវការដោយតួអង្គសង្គមស៊ីវិលពាក់ព័ន្ធនឹងការពិចារណាលើរបាយការណ៍របស់រដ្ឋភាគីជាក់លាក់ណាមួយ

ជូនតំណាង រដ្ឋឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន លើកលែងតែមានការដាក់លក្ខណៈសម្គាល់ជាក់លាក់ថា "សម្ងាត់"។

*ការចូលរួមសម័យប្រជុំរបស់គណកម្មាធិការ*

តួអង្គសង្គមស៊ីវិលអាចចូលរួមកិច្ចប្រជុំរបស់គណកម្មាធិការក្នុងនាមជាអ្នកសង្កេតការណ៍ ។ ប្រសិនបើចង់ចូលរួមប្រជុំ តួអង្គសង្គមស៊ីវិលចាំបាច់ត្រូវសរសេរមកកាន់លេខាធិការដ្ឋានតាមរយៈអាសយដ្ឋានខាងក្រោមដើម្បីស្នើសុំសិទ្ធិចូលរួម។ តួអង្គសង្គមស៊ីវិលជាពិសេសអង្គការ NGOs អាចបង្ហាញព័ត៌មានសង្ខេបជូនគណកម្មាធិការដោយផ្ទាល់មាត់នៅក្នុងសម័យប្រជុំ។ វត្តមាននៃជនរងគ្រោះនៅក្នុងកិច្ចប្រជុំបង្ហាញព័ត៌មានសង្ខេបជាធម្មតាសម្របសម្រួលដោយអង្គការ NGOs។ កិច្ចប្រជុំបង្ហាញព័ត៌មានសង្ខេបផ្ដោតលើប្រទេសមួយជាក់លាក់ម្ដងមួយៗ ហើយជាធម្មតាធ្វើឡើងចាប់ពីម៉ោង ៥ ដល់ ម៉ោង ៦ ល្ងាចនៅក្នុងថ្ងៃមុនកិច្ចសន្ទនារវាងរដ្ឋភាគីជាមួយនឹងគណកម្មាធិការ។

*បណ្ដឹងជាលក្ខណៈបុគ្គល*

**បណ្ដឹងជាលក្ខណៈបុគ្គលអនុលោមតាមមាត្រា ២២ នៃអនុសញ្ញាអាចបញ្ជូនមកកាន់៖**

**ក្រុមទទួលញត្តិ**
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

8–14, avenue de la Paix
CH–1211 ទីក្រុងហ្សឺណែវ 10 – ប្រទេសស្វីស
ទូរសារ: + 41 (0)22 917 90 22
(ជាពិសេសសម្រាប់បណ្ដឹងបន្ទាន់)
អ៊ីមែល: tb-petitions@ohchr.org

**គម្រូទម្រង់បែបបទបណ្ដឹងរួមមាននៅក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយនឹងជំពូក VIII (ការដាក់បណ្ដឹងចោទប្រកាន់ការរំលោភសិទ្ធិមនុស្ស)** នៅក្នុង*សៀវភៅណែនាំ*នេះ។

| | |
|---|---|
| *កិច្ចស្រាវជ្រាវសម្ងាត់*<br><br>តួអង្គសង្គមស៊ីវិលអាចដាក់ព័ត៌មានជូនលេខាធិការដ្ឋានអំពីការរំលោភធ្ងន់ធ្ងរ ហួសហេតុ ឬ ជាលក្ខណៈប្រព័ន្ធលើអនុសញ្ញា។ ព័ត៌មាននេះធ្វើយ៉ាងណាអាចឲ្យទុកចិត្តបាន និងមានការចង្អុលបង្ហាញដោយមានមូលដ្ឋានត្រឹមត្រូវថា រដ្ឋភាគីកំពុងប្រើប្រាស់ទារុណកម្មជាលក្ខណៈប្រព័ន្ធនៅក្នុងទឹកដីរបស់ខ្លួន។ | *អាស័យដ្ឋានទំនាក់ទំនងលម្អិតរបស់លេខាធិការដ្ឋាន*<br><br>**គណកម្មាធិការទទួលបន្ទុកប្រឆាំងនឹងទារុណកម្ម**<br>c/o ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស<br><br>8–14, avenue de la Paix<br>CH–1211 ទីក្រុងហ្សឺណែវ 10 – ប្រទេសស្វីស<br>ទូរសារ: + 41 (0)22 917 90 29<br><br>**ដើម្បីស្វែងយល់បន្ថែមអំពីគណកម្មាធិការ** សូមពិគ្រោះសលាកប័ត្រលេខ ១៧។ |

| អនុគណកម្មាធិការទទួលបន្ទុកការទប់ស្កាត់ទារុណកម្ម | |
|---|---|
| *ឃ្លាំមើល*<br><br>ពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងនឹងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬ ទណ្ឌកម្មឯកទៀតដែលឃោរឃៅ អមនុស្សធម៌ ឬ បន្ថោកបន្ទាប (ពិធីសារ OPCAT)។<br><br>*សមាជិកភាព*<br><br>អ្នកជំនាញឯករាជ្យ ១០ នាក់ដែលត្រូវបានជ្រើសតាំងសម្រាប់រយៈពេល ៤ ឆ្នាំ ហើយ អាចបន្តសមាជិកភាពបានម្តង។ សមាជិកភាពនឹងបង្កើនដល់ចំនួន ២៥ នាក់ក្រោយការផ្តល់សច្ចាប័នលើកទី ៥០ ឬ ក្រោយចូលជាភាគីនៃពិធីសារជម្រើស (សូមមើលមាត្រា ៥)។<br><br>*សម័យប្រជុំ*<br><br>អនុគណកម្មាធិការជួបប្រជុំចំនួន ៣ ដង ក្នុងមួយឆ្នាំ ម្តងៗរយៈពេល ១ សប្តាហ៍ នៅទីស្នាក់ការកណ្តាល | *លក្ខខណ្ឌតម្រូវចំពោះរដ្ឋ*<br><br>រដ្ឋភាគីត្រូវបង្កើត ចាត់តាំង ឬ រក្សាទុកនៅក្នុងរដ្ឋរបស់ខ្លួននូវស្ថាប័នទស្សនកិច្ចមួយ ឬ ច្រើន (ដែលអាចរួមទាំងស្ថាប័ន NHRIs ការិយាល័យពលរដ្ឋ (ombudsmen) គណកម្មការសភា ឬ អង្គការ NGOs ដើម្បីទប់ស្កាត់ទារុណកម្ម និងការប្រព្រឹត្ត ឬ ទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬ បន្ថោកបន្ទាប។ រដ្ឋភាគីត្រូវអនុញ្ញាតឲ្យអនុគណកម្មាធិការធ្វើទស្សនកិច្ចទៅតាមទីកន្លែងនានានៅក្រោមសមត្ថកិច្ច និងការគ្រប់គ្រងរបស់ខ្លួនដែលមានការដកហូត ឬ អាចមានការដកហូតសេរីភាព។ ទស្សនកិច្ចទាំងនេះត្រូវធ្វើឡើងក្នុងគោលបំណងពង្រឹង និងក្នុងករណីចាំបាច់ការការពារបុគ្គលទាំងនេះពីទារុណកម្ម និងការប្រព្រឹត្ត ឬ ទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬ បន្ថោកបន្ទាប។<br><br>**ដើម្បីស្វែងយល់បន្ថែមអំពីអនុគណកម្មាធិការទទួល** |

| | |
|---|---|
| ក្នុងទីក្រុងហ្សឺណែវ។ អនុគណកម្មាធិការក៏ធ្វើទស្សនកិច្ចទៀងទាត់ទៅតាមទីកន្លែងនានាដែលប្រជាជនត្រូវបានដកហូតសេរីភាពដើម្បីទប់ស្កាត់ទារុណកម្ម និងការប្រព្រឹត្ត ឬ ទណ្ឌកម្មឯទៀតដែលឃោរឃៅអមនុស្សធម៌ ឬ បន្ថោកបន្ទាប។ | **បន្ទុកការទប់ស្កាត់ទារុណកម្ម** សូមចូលទៅកាន់គេហទំព័រនៃការិយាល័យ OHCHR។ |

| គណកម្មាធិការទទួលបន្ទុកសិទ្ធិកុមារ | |
|---|---|
| *ឃ្លាំមើល*<br><br>អនុសញ្ញាស្តីពីសិទ្ធិកុមារ (អនុសញ្ញា CRC) និងពិធីសារបន្ថែម<br><br>*សមាជិកភាព*<br><br>អ្នកជំនាញឯករាជ្យ ១៨ នាក់ដែលត្រូវបានជ្រើសតាំងសម្រាប់រយៈពេល ៤ ឆ្នាំ ហើយអាចបន្តសមាជិកភាពទៀតបាន។<br><br>*សម័យប្រជុំ*<br><br>គណកម្មាធិការជួបប្រជុំចំនួន ៣ ដង ក្នុងមួយឆ្នាំ ដោយសម័យប្រជុំនីមួយៗមានរយៈពេល ៣ សប្តាហ៍ និងកិច្ចប្រជុំរបស់គ្រុមត្រៀមរៀបចំរយៈពេល ១ សប្តាហ៍ ក្នុងខែមករា ខែឧសភា និងខែកញ្ញា នៅអង្គការសហប្រជាជាតិនៅទីក្រុងហ្សឺណែវ។<br><br>*លក្ខខណ្ឌនៃរបាយការណ៍*<br><br>ដំបូង រដ្ឋភាគីត្រូវធ្វើរបាយការណ៍ក្នុងរយៈពេល ២ ឆ្នាំក្រោយពេលអនុសញ្ញាចូលជាធរមាន និងបន្ទាប់មករៀងរាល់ ៥ ឆ្នាំម្តង។ រដ្ឋភាគីនៃពិធីសារបន្ថែមក៏ត្រូវដាក់របាយការណ៍អនុលោមតាមលិខិតុបករណ៍ទាំងនេះ | ដោយដំបូង ក្នុងរយៈពេល ២ ឆ្នាំក្រោយចូលជាធរមាន និងបន្ទាប់មករួមជាមួយនឹងរបាយការណ៍ប្រចាំដែលត្រូវដាក់ជូនគណកម្មាធិការ (ឬ រៀងរាល់ ៥ ឆ្នាំម្តង ប្រសិនបើរដ្ឋគឺជាភាគីនៃពិធីសារជម្រើសណាមួយ ឬ ទាំងពីរ) ។<br><br>*ការដាក់ព័ត៌មានជាលាយលក្ខណ៍អក្សរ*<br><br>អង្គការ NGOs និងតួអង្គសង្គមស៊ីវិលផ្សេងទៀត ដូចជា អង្គការកុមារ អង្គការជំនឿណាមួយ សមាគមវិជ្ជាជីវៈ និងអង្គការសេវាសង្គមអាចដាក់ព័ត៌មាន ឬ របាយការណ៍ជាលាយលក្ខណ៍អក្សរជូនលេខាធិការដ្ឋាន។ ព័ត៌មាននេះអាចដាក់នៅពេលណាក៏បាន ក៏ប៉ុន្តែបើជាការល្អនោះនៅក្នុងរយៈពេល ២ ខែកិច្ចប្រជុំរបស់ក្រុមការងារត្រៀមរៀបចំពាក់ព័ន្ធ។ យ៉ាងហោចណាស់ សំណៅថតចម្លងជាក្រដាសចំនួន ២០ ច្បាប់បន្ថែមលើសំណៅជាទម្រង់អេឡិកត្រូនិកគួរដាក់ជូនលេខាធិការតាមរយៈអាសយដ្ឋានខាងក្រោម។ សង្គមស៊ីវិលអាចស្នើសុំឲ្យរក្សាការសម្ងាត់លើឯកសារជាលាយលក្ខណ៍ដែលខ្លួនដាក់បាន។ |

| | |
|---|---|
| អង្គការ NGO ដែលបានដាក់ព័ត៌មានជូនគណកម្មាធិការអាចទាក់ទង**ក្រុមអង្គការ NGO ទទួលបន្ទុកអនុសញ្ញាស្តីពីសិទ្ធិកុមារ**បាន។ ក្រុមអង្គការ NGO នេះគឺជាសម្ព័ន្ធអង្គការ NGO អន្តរជាតិដែលបំពេញការងារសម្រួលការអនុវត្តអនុសញ្ញា។ ក្រុម NGO មានអង្គភាពសម្របសម្រួលដែលគាំទ្រការចូលរួមរបស់អង្គការ NGO ជាពិសេស សម្ព័ន្ធថ្នាក់ជាតិនៅក្នុងដំណើរការធ្វើរបាយការណ៍។ តួអង្គសង្គមស៊ីវិលក្រៅពីអង្គការ NGOs ត្រូវបានលើកទឹកចិត្តឲ្យចែករំលែកព័ត៌មានដោយសម្របសម្រួលជាមួយនឹងសម្ព័ន្ធអង្គការអនុសញ្ញា CRC ថ្នាក់ជាតិប្រសិនបើមាន។<br><br>ក្រុមអង្គការ NGO អាចទាក់ទងបានតាមរយៈ៖<br><br>**ក្រុមអង្គការ NGO ទទួលបន្ទុកអនុសញ្ញាស្តីពីសិទ្ធិកុមារ**<br><br>**លេខាធិការដ្ឋាន**<br>1, rue de Varembé<br>CH-1202 ទីក្រុងហ្សឺណែវ – ប្រទេសស្វីស | ទូរស័ព្ទ: +41 (0)22 740 4730<br>ទូរសារ: +41 (0)22 740 1145<br>អ៊ីមែល: secretariat@childrightsnet.org<br>គេហទំព័រ: http://www.childrightsnet.org [51]<br><br>*ការចូលរួមសម័យប្រជុំរបស់គណកម្មាធិការ*<br>តួអង្គសង្គមស៊ីវិលអាចចូលរួមសម័យប្រជុំពិនិត្យរបាយការណ៍របស់គណកម្មាធិការក្នុងនាមជាអ្នកសង្កេតការណ៍តែប៉ុណ្ណោះ។ ប្រសិនបើចង់ចូលរួមប្រជុំ តួអង្គសង្គមស៊ីវិលចាំបាច់ត្រូវសរសេរមកកាន់លេខាធិការដ្ឋានតាមរយៈអាសយដ្ឋានខាងក្រោមដើម្បីស្នើសុំសិទ្ធិចូលរួម។ តួអង្គសង្គមស៊ីវិលក៏ត្រូវបានអញ្ជើញឲ្យចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមត្រៀមរៀបចំរយៈពេល ៣ ម៉ោង ដែលនៅក្នុងកិច្ចប្រជុំនោះដៃគូអាចផ្តល់ព័ត៌មានបន្ថែមបាន។ អ្នកជំនាញឯករាជ្យនិងសមាជិកអង្គការយុវជនគឺជាអ្នកចូលរួមចំណែកយ៉ាងសំខាន់នៅក្នុងកិច្ចប្រជុំរបស់ក្រុមការងារត្រៀមរៀបចំនៃគណកម្មាធិការ។ សំណើសុំចូលរួមគួរបញ្ជូនទៅកាន់លេខាធិការដ្ឋានយ៉ាងហោចណាស់រយៈពេល ២ ខែ នៅមុនពេលចាប់ផ្តើមកិច្ចប្រជុំរបស់ក្រុមការងារ |

| | |
|---|---|
| ត្រៀមរៀបចំពាក់ព័ន្ធ។ ផ្អែកលើព័ត៌មានជាលាយលក្ខណ៍អក្សរដែលបានដាក់ គណកម្មាធិការនឹងចេញលិខិតអញ្ជើញជាលាយលក្ខណ៍អក្សរដើម្បីជ្រើសរើសតួអង្គសង្គមស៊ីវិល ជាទូទៅ អង្គការ NGOs (ដែលមានព័ត៌មានពាក់ព័ន្ធនឹងការពិចារណាលើរបាយការណ៍របស់រដ្ឋ) ដើម្បីចូលរួមនៅក្នុងកិច្ចប្រជុំរបស់ក្រុមការងារត្រៀមរៀបចំ។ | *អាស័យដ្ឋានទំនាក់ទំនងលម្អិតរបស់លេខាធិការដ្ឋាន*<br><br>**គណកម្មាធិការស្តីពីសិទ្ធិកុមារ**<br>c/o ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស |

[51] ការិយាល័យ OHCHR មិនទទួលខុសត្រូវលើខ្លឹមសារនៃគេហទំព័រពីខាងក្រៅ ហើយបទប្បញ្ញត្តិនៃទំព័រភ្ជាប់នៅលើទំព័រនេះពុំមានន័យថា ការិយាល័យ OHCHR មានការពាក់ព័ន្ធនឹងខ្លឹមសារទាំងនោះឡើយ។

| | |
|---|---|
| ចំណាប់អារម្មណ៍ផ្តើមសេចក្តីរបស់អ្នកចូលរួម ត្រូវបានកម្រិតយ៉ាងច្រើនបំផុតត្រឹមរយៈពេល ១៥ នាទីសម្រាប់តួអង្គសង្គមស៊ីវិលមកពីប្រទេសពាក់ព័ន្ធ និង ៥ នាទី សម្រាប់តួអង្គផ្សេងទៀតដើម្បីផ្តល់ពេលវេលាសម្រាប់កិច្ចសន្ទនាក្នុងន័យស្ថាបនា។ ជារៀងរាល់ឆ្នាំ គណកម្មាធិការក៏រៀបចំថ្ងៃពិភាក្សាទូទៅដែលក្នុងថ្ងៃនោះតួអង្គសង្គមស៊ីវិលរួមទាំងកុមារ និងអ្នកជំនាញត្រូវបានស្វាគមន៍ឲ្យចូលរួម។ | 8–14, avenue de la Paix<br>CH–1211 ទីក្រុងហ្សឺណែវ 10 – ប្រទេសស្វីស<br>ទូរសារ: + 41 (0)22 917 90 29<br><br>សូមចូលទៅកាន់គេហទំព័ររបស់ក្រុមអង្គការ NGO ដើម្បីពិនិត្យមើល**គោលការណ៍ណែនាំស្តីពីរបៀបធ្វើរបាយការណ៍ជូនគណកម្មាធិការទទួលបន្ទុកសិទ្ធិកុមារ**។<br><br>ដើម្បីពិនិត្យមើល**គោលការណ៍ណែនាំរបស់គណកម្មាធិការស្តីពីការចូលរួមរបស់អង្គការ** NGOs **និងអ្នកជំនាញ**នៅក្នុងកិច្ចប្រជុំរបស់ក្រុមត្រៀមរៀបចំ សូមចូលទៅកាន់គេហទំព័រនៃការិយាល័យ OHCHR។<br><br>**ដើម្បីស្វែងយល់បន្ថែមអំពីគណកម្មាធិការទទួលបន្ទុកសិទ្ធិកុមារ** សូមពិគ្រោះ**សលាកប័ត្រលេខ ១០ (វិ.លើកទី១)**។ |

| គណកម្មាធិការទទួលបន្ទុកការការពារសិទ្ធិពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ | |
|---|---|
| *ឃ្លាំមើល*<br><br>អនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិពលករទេសន្តរប្រវេសន្តរគ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ (អនុសញ្ញា ICRMW)។<br><br>*សមាជិកភាព*<br><br>បច្ចុប្បន្ន អ្នកជំនាញឯករាជ្យចំនួន ១០ នាក់ដែលត្រូវបានជ្រើសតាំងសម្រាប់រយៈពេល ៤ ឆ្នាំ ហើយអាចបន្តសមាជិកភាពទៀតបាន។<br>សមាជិកភាពនេះនឹងបង្កើនទៅដល់ចំនួន ១៤ នាក់នៅពេលផ្តល់សច្ចាប័នលើអនុសញ្ញាដោយរដ្ឋភាគីទី៤១។ | អនុសញ្ញា និងបន្ទាប់មករៀងរាល់ ៥ ឆ្នាំម្តង។<br><br>*ការដាក់ព័ត៌មានជាលាយលក្ខណ៍អក្សរ*<br><br>អង្គការ NGOs និងតួអង្គសង្គមស៊ីវិលផ្សេងទៀត ដូចជា អង្គការសេវាសង្គម អ្នកជំនាញម្នាក់ៗ និងសហជីពអាចដាក់ព័ត៌មាន ឬ របាយការណ៍ជាលាយលក្ខណ៍អក្សរជូនលេខាធិការដ្ឋាននៅពេលណាក៏បាន។ ព័ត៌មានទាំងអស់គួរដាក់ក្នុងទម្រង់អេឡិកត្រូនិក ហើយយ៉ាងហោចណាស់សំណៅថតចម្លងជាទម្រង់ក្រដាសចំនួន ១៥ ច្បាប់គួរដាក់ជូនលេខាធិការដ្ឋានតាមរយៈអាសយដ្ឋានខាងក្រោម។ |

សម្រាប់ព័ត៌មានលម្អិតបន្ថែម សូមមើលមាត្រា ៧២។

*សម័យប្រជុំ*

គណកម្មាធិការបើកសម័យប្រជុំចំនួនពីរដងក្នុង ១ ឆ្នាំ នៅទីក្រុងហ្សឺណែវជាធម្មតាក្នុងខែមេសា និងវិច្ឆិកា។

*លក្ខខណ្ឌនៃរបាយការណ៍*

ដំបូង រដ្ឋភាគីត្រូវធ្វើរបាយការណ៍ក្នុងរយៈពេល ១ ឆ្នាំ ក្រោយពេលក្លាយជាភាគីនៃ

សង្គមស៊ីវិលដែលបានដាក់ព័ត៌មានជូនគណកម្មាធិការ អាចទាក់ទង**វេទិកាអង្គការ NGO អន្តរជាតិទទួលបន្ទុកអនុសញ្ញាស្តីពីពលករទេសន្តរប្រវេសន៍**ដែលជាសម្ព័ន្ធអង្គការ NGO អន្តរជាតិធ្វើការងាររួមគ្នាដើម្បីសម្រួលការលើកកម្ពស់ ការអនុវត្ត និងការឃ្លាំមើលអនុសញ្ញា។ វេទិកាអង្គការនេះអាចទាក់ទងបានតាមរយៈ៖

**វេទិកាអង្គការ NGO**
c/o December 18
Rue de Varembé 1
P.O. Box 96
CH–1211 ទីក្រុងហ្សឺណែវ 20 - ប្រទេសស្វីស
ទូរស័ព្ទ: +41 (0)22 919 10 42
ទូរសារ: +41 (0)22 919 10 48
អ៊ីមែល: ipmwc@december18.net
គេហទំព័រ: http://www.december18.net[52]

*ការចូលរួមសម័យប្រជុំរបស់គណកម្មាធិការ*

តួអង្គសង្គមស៊ីវិលអាចចូលរួមសម័យប្រជុំជាសាធារណៈរបស់គណកម្មាធិការក្នុងនាមជាអ្នកសង្កេតការណ៍តែប៉ុណ្ណោះ។ ប្រសិនបើចង់ចូលរួមប្រជុំ តួអង្គសង្គមស៊ីវិលចាំបាច់ត្រូវសរសេរមកកាន់លេខាធិការដ្ឋានតាមរយៈអាសយដ្ឋានខាងក្រោមដើម្បីស្នើសុំសិទ្ធិចូលរួម។

ដើម្បីធ្វើរបាយការណ៍ដោយផ្ទាល់មាត់អំពីស្ថានភាពពលករទេសន្តរប្រវេសន៍នៅក្នុងប្រទេសណាមួយ និងដើម្បីឆ្លើយតបទៅនឹងសំនួររបស់សមាជិក។ កិច្ចប្រជុំនេះធ្វើឡើងនៅសម័យប្រជុំមុនពេលគណកម្មាធិការពិនិត្យមើលរបាយការណ៍របស់រដ្ឋភាគី។

នៅក្នុងសម័យប្រជុំពិនិត្យរបាយការណ៍របស់រដ្ឋភាគី តួអង្គសង្គមស៊ីវិលដែលបានដាក់ព័ត៌មានជាលាយលក្ខណ៍អក្សរត្រូវបានផ្តល់ឱកាសឲ្យបង្ហាញព័ត៌មានដោយផ្ទាល់មាត់ជូនគណកម្មាធិការក្នុងកិច្ចប្រជុំជាសាធារណៈនៅមុនពេលគណកម្មាធិការពិនិត្យរបាយការណ៍របស់រដ្ឋភាគី។ អង្គការ NGOs អ្នកសិក្សាស្រាវជ្រាវ និងតំណាងក្រុមវិជ្ជាជីវៈ និងក្រុមដទៃទៀតត្រូវបានអញ្ជើញឲ្យចូលរួមនៅក្នុងថ្ងៃពិភាក្សាលើប្រធានបទទូទៅដែលគណកម្មាធិការបានរៀបចំឡើងតាមកាលកំណត់។

[52] ការិយាល័យ OHCHR មិនទទួលខុសត្រូវលើខ្លឹមសារនៃគេហទំព័រពីខាងក្រៅ ហើយបទប្បញ្ញត្តិនៃទំព័រភ្ជាប់នៅលើទំព័រនេះពុំមានន័យថា ការិយាល័យ OHCHR មានការពាក់ព័ន្ធនឹងខ្លឹមសារទាំងនោះឡើយ។

| | |
|---|---|
| នៅក្នុងការត្រៀមរៀបចំពិនិត្យរបាយការណ៍របស់ភាគីតួអង្គសង្គមស៊ីវិលជាពិសេសអង្គការ NGOs ត្រូវបានអញ្ជើញឲ្យចូលរួមក្នុងកិច្ចប្រជុំឯកជនជាមួយនឹងគណកម្មាធិការ | |

| | |
|---|---|
| *បណ្តឹងជាលក្ខណៈបុគ្គល* | *អាស័យដ្ឋានទំនាក់ទំនងលម្អិតរបស់លេខាធិការដ្ឋាន* |
| គណកម្មាធិការនឹងអាចពិចារណាបណ្តឹងជាលក្ខណៈបុគ្គល ឬ បណ្តឹងនានានៅពេលរដ្ឋភាគីបានទទួលស្គាល់នីតិវិធីនេះស្របតាមមាត្រា ៧៧ នៃអនុសញ្ញា។ | **គណកម្មាធិការទទួលបន្ទុកការការពារសិទ្ធិពលករទេសន្តរប្រវេសន៍ចំណាកស្រុកគ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ**<br>c/o ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស<br><br>8–14, avenue de la Paix<br>CH–1211 ទីក្រុងហ្សឺណែវ 10 – ប្រទេសស្វីស<br>ទូរសារ: + 41 (0)22 917 90 29<br>អ៊ីមែល: cmw@ohchr.org<br><br>ដើម្បីស្វែងយល់បន្ថែមអំពីគណកម្មាធិការនេះ សូមពិគ្រោះសលាកប័ត្រលេខ ២៤ (វិ.លើកទី១)។ |

| គណកម្មាធិការទទួលបន្ទុកសិទ្ធិជនពិការ | |
|---|---|
| *ឃ្លាំមើល*<br><br>អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិជនពិការ និងពិធីសារបន្ថែម។<br><br>*សមាជិកភាព*<br><br>ដំបូង គណកម្មការធិការមានអ្នកជំនាញឯករាជ្យចំនួន ១២ នាក់ដែលត្រូវបានជ្រើសតាំងសម្រាប់រយៈពេល ៤ | *លក្ខខណ្ឌនៃរបាយការណ៍*<br><br>ដំបូង រដ្ឋភាគីត្រូវធ្វើរបាយការណ៍ក្នុងរយៈពេល ២ ឆ្នាំក្រោយពេលក្លាយជាភាគីនៃអនុសញ្ញា និងបន្ទាប់មកយ៉ាងហោចណាស់ រៀងរាល់ ៤ ឆ្នាំម្តង ឬ នៅពេលណាដែលគណកម្មាធិការស្នើសុំ។<br><br>*បណ្តឹងជាលក្ខណៈបុគ្គល* |

| | |
|---|---|
| ឆ្នាំ ហើយអាចបន្តសមាជិកភាពបានម្តងដោយគួរបញ្ចូលអ្នកជំនាញជាជនពិការផងដែរ។ ក្រោយមានការផ្តល់សច្ចាប័ន និងចូលជាភាគីពីរដ្ឋបន្ថែមចំនួន ៦០ ទៀតនោះ សមាជិកភាពបានកើនរហូតដល់ចំនួន ១៨ នាក់។ រដ្ឋភាគីត្រូវបានអញ្ជើញឲ្យចូលរួមឲ្យបានសកម្មជាមួយនឹងជនពិការ និងអង្គការតំណាងពួកគេនៅពេលជ្រើសតាំងបេក្ខជនសម្រាប់តែងតាំងនៅក្នុងគណកម្មាធិការ។<br><br>*សម័យប្រជុំ*<br><br>គិតត្រឹមខែកញ្ញា ឆ្នាំ២០០៨ សមាជិកគណកម្មាធិការមិនទាន់ត្រូវបានតែងតាំងនៅឡើយទេ។ | គណកម្មាធិការនឹងអាចពិចារណាលើលិខិតឆ្លើយឆ្លងពីបុគ្គល ឬ ក្រុមបុគ្គលបាន។ **គម្រូទម្រង់បែបបទ** រួមមាននៅក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយនឹងជំពូក VIII **(ការដាក់បណ្តឹងចោទប្រកាន់លើការរំលោភសិទ្ធិមនុស្ស)** នៅក្នុង *សៀវភៅណែនាំ*នេះ។<br><br>*កិច្ចស្រាវជ្រាវសម្ងាត់*<br><br>តួអង្គសង្គមស៊ីវិល ជាពិសេស អង្គការ NGOs អាចដាក់ព័ត៌មានស្តីពីការរំលោភ ធ្ងន់ធ្ងរ ហួសហេតុ និងជាលក្ខណៈប្រព័ន្ធលើអនុសញ្ញាជូនគណកម្មាធិការបាន។ ព័ត៌មាននេះត្រូវអាចទុកចិត្តបាន និងបង្ហាញថា រដ្ឋភាគីកំពុងរំលោភជាលក្ខណៈប្រព័ន្ធលើសិទ្ធិទាំងឡាយដូចមានចែងនៅក្នុងអនុសញ្ញា។ |

| | |
|---|---|
| *មាត្រា ៣៣*<br><br>អនុសញ្ញារួមមានបទប្បញ្ញត្តិដោយឡែកទាក់ទងនឹងតួនាទីរបស់សង្គមស៊ីវិលនៅក្នុងការឃ្លាំមើលការអនុវត្តអនុសញ្ញា។ មាត្រា ៣៣ ចែងថា រដ្ឋភាគីត្រូវចូលរួមពេញលេញនៅក្នុងដំណើរការឃ្លាំមើលដែលបានបង្កើតឡើងដោយរដ្ឋភាគីដើម្បីផ្តល់តួនាទីចំបងដល់សង្គមស៊ីវិលនៅក្នុងការលើកកម្ពស់ការអនុវត្តអនុសញ្ញា។ | *អាសយដ្ឋានទំនាក់ទំនងលម្អិតរបស់លេខាធិការដ្ឋាន*<br><br>**គណកម្មាធិការទទួលបន្ទុកសិទ្ធិជនពិការ**<br>c/o ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស<br><br>8–14, avenue de la Paix<br>CH–1211 ទីក្រុងហ្សឺណែវ 10 – ប្រទេសស្វីស<br>ទូរសារ: + 41 (0)22 917 90 29<br>អ៊ីមែល: crpd@ohchr.org<br><br>សម្រាប់ព័ត៌មានបន្ថែមស្តីពី**ការងារនៃការិយាល័យ OHCHR លើអនុសញ្ញា និងបញ្ហាជនពិការជារួម** សូមចូលទៅកាន់គេហទំព័រនៃការិយាល័យ OHCHR។<br><br>**ដើម្បីស្វែងយល់បន្ថែមអំពីអនុសញ្ញា និងពិធីសារបន្ថែម** សូមមើលការបោះពុម្ពផ្សាយរបស់ការិយាល័យ |

| | |
|---|---|
| | OHCHR ចំណាងជើងថា *ពីការមិនដាក់បញ្ចូលរហូតដល់សមភាព៖ ការសម្រេចបានសិទ្ធិជនពិការ* (HR/PUB/07/6)។ |

| គណកម្មាធិការទទួលបន្ទុកការបាត់ខ្លួនដោយបង្ខំ | |
|---|---|
| *នឹងឃ្លាំមើល*<br><br>អនុសញ្ញាអន្តរជាតិស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ។<br><br>*សមាជិកភាព*<br><br>គណកម្មការធិការនឹងរួមមានអ្នកជំនាញឯករាជ្យចំនួន ១០ នាក់ដែលត្រូវបានជ្រើសតាំងសម្រាប់រយៈពេល ៤ ឆ្នាំ ហើយអាចបន្តសមាជិកភាពបានម្តង។<br><br>*លក្ខខណ្ឌនៃរបាយការណ៍*<br><br>ដំបូង រដ្ឋភាគីត្រូវធ្វើរបាយការណ៍ក្នុងរយៈពេល ២ ឆ្នាំក្រោយពេលក្លាយជាភាគីនៃ អនុសញ្ញា។<br><br>*ចំណាត់ការបន្ទាន់*<br><br>គណកម្មាធិការនឹងអាចទទួលសំណើសុំបន្ទាន់ពីបុគ្គលដែលស្នើសុំស្វែងរកជនដែលបានបាត់ខ្លួន។ ជនដែលបានបាត់ខ្លួននេះត្រូវស្ថិតនៅក្រោមយុត្តាធិការរបស់រដ្ឋភាគីនៃអនុសញ្ញា។<br><br>*បណ្តឹងជាលក្ខណៈបុគ្គល*<br><br>គណកម្មាធិការនឹងអាចពិចារណាលើលិខិត | ឆ្លើយឆ្លងរបស់បុគ្គលស្តីពីរដ្ឋភាគីដែលបានទទួលស្គាល់នីតិវិធីនេះអនុលោមតាមមាត្រា ៣១ នៃអនុសញ្ញា។<br><br>*កិច្ចស្រាវជ្រាវ*<br><br>តួអង្គសង្គមស៊ីវិល ជាពិសេស អង្គការ NGOs អាចដាក់ព័ត៌មានបង្ហាញថា រដ្ឋភាគីកំពុងរំលោភធ្ងន់ធ្ងរលើបទប្បញ្ញត្តិនៃអនុសញ្ញា អនុលោមតាមមាត្រា ៣៣។ លើសពីនេះ គណកម្មាធិការមានអំណាចដាក់ព័ត៌មានជូនមហាសន្និបាតជាបន្ទាន់បានដើម្បីបង្ហាញថា ការបាត់ខ្លួនដោយបង្ខំបានអនុវត្តយ៉ាងទូលំទូលាយ ឬជាលក្ខណៈប្រព័ន្ធនៅក្នុងរដ្ឋភាគី។<br><br>**ដើម្បីស្វែងយល់បន្ថែមអំពីការបាត់ខ្លួនដោយបង្ខំ ឬដោយពុំមានការស្ម័គ្រចិត្ត** *សូមពិគ្រោះសលាកប័ត្រ* **លេខ ៦ (វិ.លើកទី២)។** |

## V. ក្រុមប្រឹក្សាសិទ្ធិមនុស្ស

### ទិដ្ឋភាពសង្ខេបនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស

| | | |
|---|---|---|
| *តើក្រុមប្រឹក្សាសិទ្ធិមនុស្សជាអ្វី?*<br><br>ក្រុមប្រឹក្សាសិទ្ធិមនុស្សគឺជាស្ថាប័នអន្តររដ្ឋាភិបាលចំបងនៃអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស។ ក្រុមប្រឹក្សានេះបានបង្កើតឡើងតាមរយៈសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតលេខ ៦០/២៥១ ដើម្បីជំនួស និងទទួលអាណត្តិការងារ យន្តការ មុខងារ និងការទទួលខុសត្រូវស្ទើរតែទាំងអស់ដែលពីមុនប្រគល់ជូនគណកម្មការសិទ្ធិមនុស្ស។ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (ការិយាល័យ OHCHR) មានលេខាធិការដ្ឋានមួយជួយការងារដល់ក្រុមប្រឹក្សាសិទ្ធិមនុស្សដូចនឹងគណកម្មការសិទ្ធិមនុស្សពីមុនដែរ។ | *តើក្រុមប្រឹក្សាសិទ្ធិមនុស្សបំពេញការងារយ៉ាងដូចម្តេចដែរ?*<br><br>ក្រុមប្រឹក្សាសិទ្ធិមនុស្សគឺជាស្ថាប័នអន្តររដ្ឋាភិបាលដែលមានរដ្ឋសមាជិកចំនួន ៤៧ នៅទីក្រុងហ្សឺណែវ។ ក្រុមប្រឹក្សានេះជួបប្រជុំយ៉ាងហោចណាស់ ១០ សប្តាហ៍ក្នុងមួយឆ្នាំក្នុងសម័យប្រជុំមិនលើសពី ៣ ដង ហើយអាចបើកសម័យប្រជុំពិសេសផងដែរ។ គណកម្មការសិទ្ធិមនុស្សធ្លាប់ជាស្ថាប័នរណបនៃ**ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គម** (ក្រុមប្រឹក្សា ECOSOC) ក៏ប៉ុន្តែ ក្រុមប្រឹក្សាសិទ្ធិមនុស្សគឺជាស្ថាប័នរណបនៃ**មហាសន្និបាត**។ ក្រុមប្រឹក្សានេះមានតួនាទីដោះស្រាយការរំលោភសិទ្ធិមនុស្សរួមទាំងការរំលោភធ្ងន់ធ្ងរ និងជា | លក្ខណៈប្រព័ន្ធ និងការលើកកម្ពស់ការសម្របសម្រួលឲ្យមានប្រសិទ្ធភាព និងការបញ្ជ្រៀបសិទ្ធិមនុស្សនៅក្នុងប្រព័ន្ធអង្គការសហប្រជាជាតិ។<br><br>នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៧ មួយឆ្នាំក្រោយសម័យប្រជុំលើកដំបូង ក្រុមប្រឹក្សាសិទ្ធិមនុស្សបានឯកភាពបង្កើតនីតិវិធី យន្តការ និងរចនាសម្ព័ន្ធជាមូលដ្ឋានសម្រាប់ការងារនាពេលអនាគត។ នីតិវិធី យន្តការ និងរចនាសម្ព័ន្ធទាំងនេះត្រូវបានអនុម័តចេញជា**សេចក្តីសម្រេចចិត្តលេខ ៥/១** រួមមានរបៀបវារៈរបស់ក្រុមប្រឹក្សា កម្មវិធីការងារ និងវិធាននីតិវិធី ហើយបានធ្វើការកែប្រែប្រព័ន្ធនៃការផ្តល់យោបល់ប្រឹក្សារបស់អ្នកជំនាញ និងនីតិវិធីបណ្តឹងដែលអនុវត្តតាមគណកម្មការសិទ្ធិមនុស្សពីមុន។ សេចក្តីសម្រេចចិត្តលេខ ៥/១ |

សៀវភៅណែនាំនេះអាចរកមើលបានក្នុងទម្រង់ឌីជីថលនៅលើគេហទំព័រនៃការិយាល័យ OHCHR តាមរយៈ៖ http://www.ohchr.org/civilsocietyhandbook/

នៅលើគេហទំព័រនេះ លោកអ្នកនឹងអាចទាញយកជំពូកទាំងឡាយនៅក្នុងសៀវភៅណែនាំនេះបានព្រមទាំងទំព័រតភ្ជាប់ទៅកាន់ឯកសារយោងទាំងអស់ដែលមាននៅក្នុងឯកសារបោះពុម្ពផ្សាយ។

| | | |
|---|---|---|
| នេះថែងអំពីគម្រូបែបបទសម្រាប់ប្រតិបត្តិការយន្តការពិនិត្យរបាយការណ៍ជាសាកលតាមកាលកំណត់ថ្មីរបស់ក្រុមប្រឹក្សា | និងបានបង្កើតដំណើរការសម្រាប់សើរើ ផ្តល់យុត្តិកម្ម និងធ្វើឲ្យអាណត្តិការងារនៃយន្តការនីតិវិធី | ពិសេសទាំងអស់កាន់តែមានភាពប្រសើរឡើង។ |

| | | |
|---|---|---|
| **វិធីទាក់ទង និងធ្វើការងារជាមួយនឹងក្រុមប្រឹក្សាសិទ្ធិមនុស្ស អាណត្តិការងារ និងយន្តការរបស់ក្រុមប្រឹក្សា**<br><br>នៅក្នុងសេចក្តីសម្រេចចិត្តលេខ ៦០/២៥១ មហាសន្និបាតបានទទួលស្គាល់តួនាទីសំខាន់របស់អង្គការមិនមែនរដ្ឋាភិបាល (អង្គការ NGOs) និងតួអង្គសង្គមស៊ីវិលថ្នាក់ជាតិ តំបន់ និងអន្តរជាតិនៅក្នុងការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស។<br><br>ការចូលរួមរបស់អ្នកសង្កេតការណ៍ រួមទាំង អង្គការ NGOs នៅក្នុងសម័យប្រជុំ | ក្រុមប្រឹក្សាគឺផ្អែកលើការរៀបចំ និងការអនុវត្តដែលត្រូវបានគោរពដោយអតីតគណកម្មការសិទ្ធិមនុស្ស។ ការអនុវត្ត និងការរៀបចំទាំងនេះបន្តវិវឌ្ឍរីកចម្រើនដោយក្រុមប្រឹក្សាត្រូវធានាឲ្យ "ការចូលរួមចំណែករបស់អ្នកសង្កេតការណ៍កាន់តែមានប្រសិទ្ធភាពបំផុត"[53]។<br><br>ទោះបីក្នុង**ឋានៈជាអ្នកពិគ្រោះយោបល់**ជាមួយនឹងក្រុមប្រឹក្សា ECOSOC តម្រូវឲ្យអង្គការ NGO ស្នើសុំសិទ្ធិចូលរួមជាអ្នកសង្កេតការណ៍នៅក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សក៏ដោយ អង្គការ NGOs | ប្រសិនបើពុំមានឋានៈបែបនេះទេ ហើយនឹងតួអង្គសង្គមស៊ីវិលអាចចូលរួមចំណែកលើការងារទូទៅ និងយន្តការរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សបានក្នុងវិធីច្រើនយ៉ាង។ ម្យ៉ាងវិញទៀត កិច្ចប្រជុំត្រូវបានចាក់ផ្សាយផ្ទាល់**តាមកម្មវិធីផ្សាយផ្ទាល់លើគេហទំព័រ**នៃការិយាល័យ OHCHR ហើយឯកសារ និងព័ត៌មានជាច្រើនប្រភេទទៀតអាចរកបាននៅលើ**ទំព័រដើម និងទំព័រ** Extranet។ ព័ត៌មានអំពីសម័យប្រជុំជាក់លាក់ជាធម្មតាត្រូវបានផ្សាយនៅលើទំព័រដើមរយៈពេល ២ សប្តាហ៍នៅមុនសម័យប្រជុំសាមញ្ញនីមួយៗ។ |

i. អាសយដ្ឋានទំនាក់ទំនងសំខាន់ៗសម្រាប់ទាក់ទងក្រុមប្រឹក្សាសិទ្ធិមនុស្ស

**សាខាក្រុមប្រឹក្សាសិទ្ធិមនុស្ស**

---

[53] សូមមើលសេចក្តីសម្រេចចិត្តនៃមហាសន្និបាតលេខ ៦០/២៥១ និងសេចក្តីសម្រេចចិត្តនៃក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៥/១។

សាខាក្រុមប្រឹក្សាសិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

8–14, avenue de la Paix
CH–1211 ទីក្រុងហ្សឺណែវ 10 - ប្រទេសស្វីស
ទូរស័ព្ទ: +41 (0)22 917 92 56
ទូរសារ: +41 (0)22 917 90 11

**អង្គភាពសង្គមស៊ីវិល**
អង្គភាពសង្គមស៊ីវិលនៃការិយាល័យ OHCHR
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

8–14, avenue de la Paix
CH–1211 ទីក្រុងហ្សឺណែវ 10 - ប្រទេសស្វីស
ទូរស័ព្ទ: +41 (0)22 917 90 00
អ៊ីមែល: civilsocietyunit@ohchr.org

**សម្រាប់សំណើសុំ ឬ ព័ត៌មានទាក់ទងនឹងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សា ECOSOC**
*ទីស្នាក់ការកណ្តាលនៃអង្គការសហប្រជាជាតិ*
ផ្នែក NGO
ផ្នែកកិច្ចការសង្គម និងសេដ្ឋកិច្ចនៃនាយកដ្ឋានអង្គការសហប្រជាជាតិ
One UN Plaza, Room DC-1-1480
New York, NY 10017
ទូរស័ព្ទ: +1 212 963 8652
ទូរសារ: +1 212 963 9248
អ៊ីមែល: desangosection@un.org

*ការិយាល័យអង្គការសហប្រជាជាតិនៃទីក្រុងហ្សឺណែវ (UNOG)*
ការិយាល័យទំនាក់ទំនងអង្គការ NGO

ការិយាល័យអគ្គនាយក

Office 153,

8–14, avenue de la Paix

CH-1211 ទីក្រុងហ្សឺណែវ 10 - ប្រទេសស្វីស

ទូរស័ព្ទ: +41 (0)22 917 21 27

ទូរសារ: +41 (0)22 917 05 83

អ៊ីមែល: unទីក្រុងហ្សឺណែវ.ngoliaison@unog.ch

អាសយដ្ឋានសំខាន់ៗសម្រាប់ទាក់ទងយន្តការនៃក្រុមប្រឹក្សាសិទ្ធិមនុស្សនីមួយៗត្រូវបានដាក់បញ្ចូលនៅក្នុងផ្នែកពាក់ព័ន្ធក្នុងជំពូកនេះ។

# តើក្រុមប្រឹក្សាសិទ្ធិមនុស្សជាអ្វី?

## ការប្តូរពីគណកម្មការសិទ្ធិមនុស្សមកជាក្រុមប្រឹក្សាសិទ្ធិមនុស្ស

ក្រុមប្រឹក្សាសិទ្ធិមនុស្សដែលបានបង្កើតឡើងតាមរយៈ**សេចក្តីសម្រេចចិត្ត**នៃមហាសន្និបាត **លេខ ៦០/២៥១** នាថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៦ គឺជាស្ថាប័នអន្តររដ្ឋាភិបាលចំបងនៃអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស។ ក្រុមប្រឹក្សានេះជំនួស**គណកម្មការសិទ្ធិមនុស្ស**ដែលជាស្ថាប័នចំបងនៃប្រព័ន្ធសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិអស់ជាងរយៈពេល ៦០ ឆ្នាំមកហើយ។ គណកម្មការសិទ្ធិមនុស្សបានជួបប្រជុំគ្នាជាលើកចុងក្រោយនៅក្នុងខែមីនា ឆ្នាំ២០០៦ ក្នុងសម័យប្រជុំលើកទី៦២។ សមិទ្ធផលនៃការកំណត់បទដ្ឋាន និងនិយាមផ្សេងៗបានបង្កើតជាមូលដ្ឋានសម្រាប់ការបំពេញការងាររបស់ក្រុមប្រឹក្សា។

គណកម្មការសិទ្ធិមនុស្សគឺជាស្ថាប័នចំណុះ**ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម** (ក្រុមប្រឹក្សា ECOSOC)ក៏ប៉ុន្តែក្រុមប្រឹក្សាសិទ្ធិមនុស្សគឺជាស្ថាប័នចំណុះ**មហាសន្និបាត**។ ការលើកតម្កើងឋានៈនេះឡើងបង្ហាញឲ្យឃើញថា សិទ្ធិមនុស្សគឺជាសសរស្តម្ភដ៏ចាំបាច់មួយក្នុងចំណោមសសរស្តម្ភទាំងបីនៃអង្គការប្រជាជាតិរួមជាមួយនឹងការវិវឌ្ឍ សន្តិភាព និងសន្តិសុខ។ ការបង្កើតក្រុមប្រឹក្សាឡើងក៏បញ្ជាក់ឲ្យឃើញនូវការប្តេជ្ញារបស់មហាសន្និបាតក្នុងការពង្រឹងយន្តការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិក្នុងគោលបំណងធានាឲ្យបាននូវការទទួលបានប្រកបដោយប្រសិទ្ធភាពនូវសិទ្ធិមនុស្សទាំងអស់ ដូចជា សិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គមកិច្ច និងវប្បធម៌ រួមទាំងសិទ្ធិអភិវឌ្ឍន៍ផងដែរ។

នៅក្នុងសេចក្តីសម្រេចចិត្តលេខ ៦០/២៥១ មហាសន្និបាតបានផ្តល់ភារកិច្ចឲ្យក្រុមប្រឹក្សាសិទ្ធិមនុស្សសើរើ និងក្នុងករណីចាំបាច់ធ្វើឲ្យប្រសើរឡើង និងកែសម្រួលអាណត្តិការងារ យន្តការ មុខងារ និងការទទួលខុសត្រូវដែលក្រុមប្រឹក្សាបានទទួលបន្តពីគណកម្មការសិទ្ធិមនុស្ស។ ក្រុមប្រឹក្សានេះតម្រូវឲ្យបំពេញការងារនេះក្នុងរយៈពេល ១ ឆ្នាំនៅក្នុងសម័យប្រជុំលើកដំបូងរបស់ខ្លួន។ វិធីបំពេញការងាររបស់ក្រុមប្រឹក្សាទាមទារឲ្យៈ

- មានតម្លាភាព យុត្តិធម៌ និងមិនលម្អៀង
- ផ្តោតលើលទ្ធផល
- បើកឲ្យមានកិច្ចសន្ទនាពិតប្រាកដ
- អនុញ្ញាតឲ្យមានការពិភាក្សាបន្តតាមដានលើអនុសាសន៍របស់ក្រុមប្រឹក្សា និងការអនុវត្តអនុសាសន៍ទាំងនោះ និង
- អនុញ្ញាតឲ្យមានការប្រាស្រ័យទាក់ទងជាមួយនឹងយន្តការនៃក្រុមប្រឹក្សាឲ្យបានផុសផុល

មហាសន្និបាតនឹងសើរើឋានៈរបស់ក្រុមប្រឹក្សាក្នុងរយៈពេល ៥ ឆ្នាំម្តង[54]។

## ការកសាងស្ថាប័ននៃក្រុមប្រឹក្សាសិទ្ធិមនុស្ស (សេចក្តីសម្រេចចិត្តលេខ ៥/១)

នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៧ មួយឆ្នាំក្រោយសម័យប្រជុំលើកដំបូង និងក្រោយរយៈពេលដ៏មមាញឹកនៃ "ការកសាងស្ថាប័ន" ក្រុមប្រឹក្សាបានឯកភាពលើសេចក្តីសម្រេចចិត្តមួយដែលចែងអំពីនីតិវិធី យន្តការ និងរចនាសម្ព័ន្ធ។ សេចក្តីសម្រេចចិត្តនេះត្រូវបានអនុម័តជា**សេចក្តីសម្រេចលេខ ៥/១** ស្តីពីការកសាងស្ថាប័ននៃក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ[55]ដោយរួមមានដូចជាៈ

- របៀបវារៈថ្មី និងក្របខណ្ឌស្តីពីកម្មវិធីការងារ
- វិធីសាស្រ្តថ្មីក្នុងការបំពេញការងារ និងវិធាននីតិវិធីថ្មីដោយផ្អែកលើវិធាននានាដែលបានបង្កើតឡើងសម្រាប់គណកម្មាធិការនៃមហាសន្និបាត
- នីតិវិធីបណ្តឹង (ដែលបានជំនួសនីតិវិធីលេខ ១៥០៣)
- គណកម្មាធិការប្រឹក្សាយោបល់នៃក្រុមប្រឹក្សាសិទ្ធិមនុស្ស (ដែលជំនួសអនុគណកម្មការទទួលបន្ទុកលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស)
- គោលការណ៍ ដំណើរការ និងទម្រង់បែបបទណែនាំប្រតិបត្តិការនៃយន្តការពិនិត្យរបាយការណ៍ជាសាកលតាមកាលកំណត់ថ្មី (យន្តការ UPR) និង
- លក្ខណៈវិនិច្ឆ័យសម្រាប់បន្តយន្តការពិនិត្យសើរើ សនិទានកម្ម និងការធ្វើឲ្យអាណត្តិការងារនៃយន្តការនីតិវិធីពិសេសកាន់តែប្រសើរឡើង។

# តើក្រុមប្រឹក្សាសិទ្ធិមនុស្ស យន្តការ និងអាណត្តិការងារនៃក្រុមប្រឹក្សាបំពេញការងារដោយរបៀបណា?

## សមាជិកភាព

សមាជិកភាពនៃក្រុមប្រឹក្សាមានចំនួន ៤៧ រដ្ឋដែលត្រូវបានជ្រើសតាំងដោយផ្ទាល់ និងតាមរយៈការបោះឆ្នោតសម្ងាត់ជាលក្ខណៈបុគ្គលតាមសម្លេងភាគច្រើនរបស់សមាជិកនៃមហាសន្និបាត។ កំណត់ហេតុសិទ្ធិមនុស្ស និងការសន្យា ព្រមទាំង ការប្តេជ្ញាដោយស្ម័គ្រចិត្តលើសិទ្ធិមនុស្សរបស់រដ្ឋ

[54] សូមមើលសេចក្តីសម្រេចចិត្តនៃមហាសន្និបាតលេខ ៦០/២៥១ ដែលមហាសន្និបាតទាមទារឲ្យក្រុមប្រឹក្សាពិនិត្យសើរើការងារ និងការដំណើរការរបស់ក្រុមប្រឹក្សាក្នុងរយៈពេល ៥ ឆ្នាំ ក្រោយការបង្កើត និងធ្វើរបាយការណ៍ជូនមហាសន្និបាត ។

[55] សេចក្តីសម្រេចចិត្តលេខ ៥/១ ត្រូវបានអនុម័តដោយមហាសន្និបាតនៅក្នុងសេចក្តីសម្រេចចិត្តលេខ ៦២/២១៩។

បេក្ខភាពត្រូវបានយកមកពិចារណានៅពេលជ្រើសតាំងរដ្ឋសមាជិក។ រដ្ឋសមាជិកនៃក្រុមប្រឹក្សាបំពេញការងាររយៈពេល ៣ ឆ្នាំ ហើយពុំមានសិទ្ធិទទួលការបោះឆ្នោតជ្រើសតាំងសាជាថ្មីភ្លាមៗនោះទេក្រោយអាណត្តិការងារពីរដងជាប់ៗគ្នា។

ប្រសិនបើរដ្ឋសមាជិកនៃក្រុមប្រឹក្សាប្រព្រឹត្តការរំលោភធ្ងន់ធ្ងរ និងជាលក្ខណៈប្រព័ន្ធលើបញ្ហាសិទ្ធិមនុស្ស មហាសន្និបាតតាមសម្លេងបោះឆ្នោត ២/៣ នៃសមាជិកមានវត្តមានបោះឆ្នោតអាចព្យួរសិទ្ធិសមាជិកភាពនៅក្នុងក្រុមប្រឹក្សាបាន។

i. សម្រាប់បញ្ជីស្តីពី**រដ្ឋសមាជិកបច្ចុប្បន្ននៃក្រុមប្រឹក្សា** សូមចូលទៅកាន់គេហទំព័រនៃការិយាល័យ OHCHR។

## កិច្ចប្រជុំ

អតីតគណកម្មការជួបប្រជុំតែម្តងគត់ក្នុងមួយឆ្នាំរយៈពេលសរុប ៦ សប្តាហ៍ ក៏ប៉ុន្តែក្រុមប្រឹក្សាជួបប្រជុំនៅ ក្នុងទីក្រុងហ្សឺណែវប្រទេសស្វីសយ៉ាងហោចណាស់ក្នុងសម័យប្រជុំសាមញ្ញចំនួន ៣ ដងក្នុងមួយឆ្នាំសម្រាប់រយៈពេលសរុបមិនតិចជាង ១០ សប្តាហ៍។ សម័យប្រជុំធំរបស់ក្រុមប្រឹក្សា (រយៈពេល ៤ សប្តាហ៍) ជាធម្មតាបានរៀបចំឡើងនៅក្នុងខែមីនា។

ក្រុមប្រឹក្សាក៏អាចកោះប្រជុំពិសេសទៅតាមសំណើសុំរបស់រដ្ឋសមាជិកផងដែរក្នុងករណីសំណើសុំនោះមានការគាំទ្រយ៉ាងហោចណាស់ ១/៣ ពីរដ្ឋសមាជិកផ្សេងទៀត[56]។ គិតមកត្រឹមខែកញ្ញា ឆ្នាំ២០០៨ ក្រុមប្រឹក្សាបានរៀបចំកិច្ចប្រជុំពិសេសចំនួន ៧[57]។

ក្រុមប្រឹក្សាក៏រៀបចំការពិភាក្សារវាងវាគ្មិន និងព្រឹត្តិការណ៍ពិសេសនានាដើម្បីបង្កើនប្រសិទ្ធភាពកិច្ចសន្ទនា និងការយល់ពីគ្នាទៅវិញទៅមកលើបញ្ហាជាក់លាក់។ គិតមកត្រឹមខែកញ្ញា ឆ្នាំ២០០៨ ក្រុមប្រឹក្សាបានរៀបចំព្រឹត្តិការណ៍បែបនេះចំនួន ៦ លើក[58] រួមទាំងការពិភាក្សាប្រចាំឆ្នាំស្តីពីសិទ្ធិជនពិការ[59]

---

[56] វាតម្រូវឲ្យមានការគាំទ្រពីរដ្ឋមួយចំនួនតូចប៉ុណ្ណោះដើម្បីអាចកោះប្រជុំពិសេសនៅក្រុមប្រឹក្សាបើប្រៀបធៀបជាមួយនឹងគណកម្មការសិទ្ធិមនុស្ស (១/៣ នៃសមាជិកចំនួន ៤៧ ជាមួយនឹងសម្លេងភាគច្រើននៃរដ្ឋចំនួន ៥៣)។ គណកម្មការបានរៀបចំសម័យប្រជុំពិសេសចំនួន ៥ តែប៉ុណ្ណោះ។

[57] ចំនួនបីនៅលើទឹកដីប៉ាលេស្ទីនដែលត្រូវបានកាន់កាប់ (ខែកក្កដា និងវិច្ឆិកា ឆ្នាំ២០០៦ និងខែមករា ឆ្នាំ២០០៨) មួយនៅលីបង់ (ខែសីហា ឆ្នាំ២០០៦) មួយនៅ Darfur (ខែធ្នូ ឆ្នាំ២០០៦) មួយនៅភូមា (ខែតុលា ឆ្នាំ២០០៧) និងសម័យប្រជុំពិសេសលើប្រធានបទស្តីពីវិបត្តិស្បៀងអាហារពិភពលោក (ខែឧសភា ឆ្នាំ២០០៨)។

[58] ចំនួនពីរស្តីពីការអនុម័ត និងការចូលជាធរមាននៃអនុសញ្ញាស្តីពីសិទ្ធិជនពិការ (ខែមីនា ឆ្នាំ២០០៧ និងខែមិថុនា ឆ្នាំ២០០៨) មួយស្តីពី**សេចក្តីព្រាងគោលការណ៍ណែនាំនៃអង្គការសហប្រជាជាតិទទួលបន្ទុកការប្រើប្រាស់និងលក្ខខណ្ឌសមស្របនៃការថែទាំកុមារ** (ខែមិថុនា ឆ្នាំ២០០៨) មួយស្តីពីកិច្ចសន្ទនាអន្តរវប្បធម៌ស្តីពីសិទ្ធិមនុស្ស

និងការច្របាច់បញ្ចូលទស្សនវិស័យយេនឌ័រនៅក្នុងការងាររបស់ខ្លួន និងការងារនៃយន្តការរបស់ខ្លួន[60]។

## អាណត្តិការងារ និងយន្តការនានា

## ក. យន្តការពិនិត្យរបាយការណ៍ជាសាកលតាមកាលកំណត់

**យន្តការពិនិត្យរបាយការណ៍ជាសាកលតាមកាលកំណត់** (យន្តការ UPR) គឺជាយន្តការសិទ្ធិមនុស្សថ្មីមួយ។ តាមរយៈយន្តការនេះ ក្រុមប្រឹក្សាពិនិត្យតាមកាលកំណត់លើការបំពេញកាតព្វកិច្ច និងការប្តេជ្ញាអំពីបញ្ហាសិទ្ធិមនុស្សរបស់រដ្ឋសមាជិកនីមួយៗក្នុងចំណោមរដ្ឋសមាជិកទាំងអស់ចំនួន ១៩២ នៃអង្គការសហប្រជាជាតិ។ យន្តការ UPR គឺជាយន្តការសហប្រតិបត្តិការផ្អែកលើកិច្ចសន្ទនាឆ្លើយឆ្លងជាមួយនឹងរដ្ឋដែលស្ថិតនៅក្រោមការពិនិត្យសើរើ។ យន្តការនេះមានបំណងបំពេញបន្ថែមពុំមែនបំពេញការងារជាន់គ្នាលើការងារនៃគណកម្មាធិការសន្ធិសញ្ញានោះឡើយ។

យន្តការ UPR ត្រូវបានចាត់ទុកថាជាដំណើរការដែលរួមមានដំណាក់កាលផ្សេងៗគ្នាក្នុងវដ្តពេលវេលាចំនួន ៤ ឆ្នាំ៖

- ការរៀបចំព័ត៌មានសម្រាប់ជាមូលដ្ឋាននៃការសើរើ (រួមទាំង ព័ត៌មានដែលត្រូវបានរៀបចំឡើងដោយរដ្ឋដែលស្ថិតក្រោមការពិនិត្យសើរើ (របាយការណ៍ជាតិ) កម្រងព័ត៌មាននៃអង្គការសហប្រជាជាតិដែលត្រូវបានរៀបចំឡើងដោយ**ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស** (ការិយាល័យ OHCHR) និងសេចក្តីសង្ខេបនៃឯកសារដាក់ជូនដោយភាគីពាក់ព័ន្ធដែលត្រូវបានរៀបចំឡើងដោយការិយាល័យ OHCHR ផងដែរ

---

(ខែមីនា ឆ្នាំ២០០៨) មួយស្តីពីគោលបំណងស្ម័គ្រចិត្តលើបញ្ហាសិទ្ធិមនុស្ស (ខែមីនា ឆ្នាំ២០០៨) និងមួយស្តីពីបុគ្គលបាត់ខ្លួន (ខែកញ្ញា ឆ្នាំ២០០៨)។

[59] កិច្ចជជែកពិភាក្សាលើកទីមួយត្រូវបានរៀបចំឡើងនៅសម័យប្រជុំអចិន្ត្រៃយ៍លើកទី ១០ នៃក្រុមប្រឹក្សាដើម្បីផ្តោតលើវិធានការច្បាប់សម្រាប់ការផ្តល់សច្ចាប័ន និងការអនុវត្តប្រកបដោយប្រសិទ្ធភាពលើ**អនុសញ្ញាស្តីពីសិទ្ធិជនពិការ**។ ការិយាល័យ OHCHR ត្រូវបានស្នើសុំឲ្យរៀបចំការសិក្សាលើប្រធាននេះដោយពិគ្រោះយោបល់ជាមួយនឹងក្នុងចំណោមអង្គការសង្គមស៊ីវិល។

[60] សូមមើលសេចក្តីសម្រេចចិត្តលេខ ៦/៣០ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧។ កិច្ចប្រជុំដំបូងស្តីពីបញ្ហាហិង្សាប្រឆាំងនឹងសេចក្តីភេទត្រូវបានរៀបចំឡើងនៅក្នុងសម័យប្រជុំលើកទី ៨ និងរួមមានវាគ្មិនចំនួន ២ ក្រុម៖ មួយស្តីពីហិង្សាប្រឆាំងនឹងស្ត្រីភេទ និងមួយស្តីពីអាត្រាមរណនៃមាតា។ នៅក្នុងខែកញ្ញា ឆ្នាំ២០០០៨ ក្រុមប្រឹក្សាបានរៀបចំកិច្ចពិភាក្សារវាងវាគ្មិនស្តីពីការច្របាច់បញ្ចូលគ្នានៃទស្សនវិស័យយេនឌ័រនៅក្នុងការងាររបស់ក្រុមប្រឹក្សា។

- ការពិនិត្យសើរើដែលប្រព្រឹត្តទៅនៅក្នុងក្រុមការងារទទួលបន្ទុកយន្តការ UPR ក្នុងនោះរួមមានរដ្ឋសមាជិករបស់ក្រុមប្រឹក្សាចំនួន ៤៧ ដែលជួបប្រជុំចំនួន ៣ ដង រយៈពេល ២ សប្តាហ៍ជារៀងរាល់ឆ្នាំ[61]
- ការពិចារណា និងការអនុម័តឯកសារលទ្ធផលនៃការពិនិត្យសើរើដោយក្រុមប្រឹក្សានៅក្នុងសម័យប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា និង
- ការបន្តតាមដានការអនុវត្តលទ្ធផលនៃយន្តការ UPR ដោយរដ្ឋដែលស្ថិតនៅក្រោមការពិនិត្យសើរើ។

ភាគីពាក់ព័ន្ធរួមទាំងអង្គការមិនមែនរដ្ឋាភិបាលផងនោះ (អង្គការ NGOs) អ្នកការពារសិទ្ធិមនុស្ស គ្រឹះស្ថានអប់រំ និងស្ថាប័នសិក្សាស្រាវជ្រាវ អង្គការតំបន់ និងតំណាងសង្គមស៊ីវិលអាចចូលរួមនៅក្នុងដំណាក់កាលមួយចំនួនក្នុងចំណោមដំណាក់កាលទាំងនេះ។

i. សម្រាប់ព័ត៌មានស្តីពី**យន្តការពិនិត្យរបាយការណ៍ជាសាកលតាមកាលកំណត់** សូមមើលជំពូក VII **(យន្តការពិនិត្យរបាយការណ៍ជាសាកលតាមកាលកំណត់)** នៅក្នុង*សៀវភៅណែនាំ*។

## ខ. គណកម្មាធិការប្រឹក្សាយោបល់នៃក្រុមប្រឹក្សាសិទ្ធិមនុស្ស

គណកម្មាធិការប្រឹក្សាយោបល់គឺជាស្ថាប័នចំណុះក្រុមប្រឹក្សាសិទ្ធិមនុស្សដែលជំនួសអនុគណកម្មការស្តីពីការលើកកម្ពស់ និងការការពារសិទ្ធិមនុស្សនៃគណកម្មការសិទ្ធិមនុស្ស។ គណកម្មាធិការនេះបំពេញមុខងារជាក្រុមអ្នកជំនាញសម្រាប់ក្រុមប្រឹក្សាដោយផ្តោតជាចំបងលើការសិក្សា និងការផ្តល់យោបល់ប្រឹក្សាផ្អែកលើការស្រាវជ្រាវទៅតាមលក្ខណៈ និងទម្រង់ដែលស្នើសុំដោយក្រុមប្រឹក្សា។

ទោះបីជាមិនមានសិទ្ធិអនុម័តសេចក្តីសម្រេចចិត្ត ឬ សេចក្តីសម្រេចបង្កើតស្ថាប័នចំណុះប្រសិនបើពុំមានការអនុញ្ញាតពីក្រុមប្រឹក្សាក៏ដោយ ក៏គណកម្មាធិការប្រឹក្សាយោបល់អាចលើកជាសំណូមពរជូនក្រុមប្រឹក្សាៈ

- ដើម្បីបង្កើនប្រសិទ្ធភាពនីតិវិធីរបស់ខ្លួន និង
- ដើម្បីស្រាវជ្រាវបន្ថែមលើសំណើសុំដែលស្ថិតនៅក្នុងវិសាលភាពនៃការងាររបស់ខ្លួន។

គណកម្មាធិការប្រឹក្សាយោបល់រួមមានអ្នកជំនាញ ១៨ រូបដែលជ្រើសរើសចេញពីតំបន់ទាំង ៥ នៃអង្គការសហប្រជាជាតិតាមរូបភាពសមមាត្រ (អាហ្វ្រិក អាស៊ី អឺរ៉ុបខាងកើត អាមេរិកឡាទីន និងការ៉ាប៊ីន និងអឺរ៉ុបខាងលិច និងតំបន់ផ្សេងទៀត)។ សមាជិកទាំអនេះបំពេញការងារក្នុងរយៈពេល ៣

[61] ក្រុមការងារស្តីពីយន្តការ UPR ពិនិត្យសើរើរដ្ឋចំនួន ១៦ នៅក្នុងសម័យប្រជុំនីមួយៗ សរុបមកមានរដ្ឋសរុបចំនួន ៤៨ ជារៀងរាល់ឆ្នាំ។

ឆ្នាំ និងមានសិទ្ធិត្រូវបានជ្រើសតាំងម្តងទៀតតែប៉ុណ្ណោះ[62]។ គណកម្មាធិការប្រឹក្សាយោបល់ជួបប្រជុំនៅក្នុងសម័យប្រជុំចំនួនពីរដងជារៀងរាល់ឆ្នាំសម្រាប់រយៈពេលសរុបចំនួន ១០ ថ្ងៃនៃថ្ងៃធ្វើការងារ ហើយអាចរបៀបចំសម័យប្រជុំពិសេសបន្ថែមទៀតទៅតាមសំណើសុំរបស់ក្រុមប្រឹក្សា។

i. សម្រាប់ព័ត៌មានបច្ចុប្បន្នស្តីពី**គណកម្មាធិការប្រឹក្សាយោបល់** សូមចូលទៅកាន់គេហទំព័រនៃការិយាល័យ OHCHR។

## គ. នីតិវិធីបណ្តឹង

**នីតិវិធីបណ្តឹង**លើកឡើងអំពីបែបបទស៊ីសង្វាក់គ្នានៃការរំលោភធ្ងន់ធ្ងរ និងការតវ៉ាដែលអាចទុកចិត្តបានលើបញ្ហាសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តទាំងអស់ដែលបានកើតឡើងនៅគ្រប់កន្លែងនៅលើពិភពលោកទោះក្រោមកាលៈទេសៈណាក៏ដោយ។ នីតិវិធីនេះបានផ្អែកលើនីតិវិធីលេខ ១៥០៣ របស់អតីតគណកម្មការ ក៏ប៉ុន្តែត្រូវបានកែសម្រួលដើម្បីធានាថា នីតិវិធីនេះមានភាពអព្យាក្រឹត្យ មិនលម្អៀង មានប្រសិទ្ធភាព ផ្តោតលើជនរងគ្រោះ និងធ្វើឡើងទាន់ពេលវេលា។

នីតិវិធីបណ្តឹងផ្អែកលើបណ្តឹងដែលបានទទួលពីបុគ្គល ឬ ក្រុម ឬ អង្គការដែលអះអាងថាជាជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្ស ឬ ដែលបានដឹងដោយផ្ទាល់ និងអាចទុកចិត្តបានអំពីការរំលោភទាំងនេះ។ ក្រុមការងារពីរផ្សេងគ្នាគឺក្រុមការងារទទួលបន្ទុកលើលិខិតឆ្លើយឆ្លង និងក្រុមការងារទទួលបន្ទុកលើស្ថានភាពត្រូវទទួលខុសត្រូវដោយឡែកពីគ្នាលើការពិនិត្យបណ្តឹង និងដាក់ជូនបែបបទស៊ីសង្វាក់គ្នានៃការរំលោភធ្ងន់ធ្ងរ និងការតវ៉ាដែលអាចទុកចិត្តបានលើបញ្ហាសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តជូនក្រុមប្រឹក្សា។

ក្រុមប្រឹក្សាពិនិត្យរបាយការណ៍នៃក្រុមការងារទទួលបន្ទុកលើស្ថានភាពជាលក្ខណៈសម្ងាត់ (លើកលែងតែមានការសម្រេចផ្ទុយពីនេះ) និងអាចៈ

- បញ្ឈប់ការពិចារណារបស់ខ្លួនលើស្ថានភាពណាមួយនៅពេលពុំតម្រូវឲ្យមានការពិចារណា ឬចាត់វិធានការបន្ថែម
- រក្សាទុកសិទ្ធិសើរើលើស្ថានភាពណាមួយមួយអន្លើសិន និងស្នើសុំឲ្យរដ្ឋពាក់ព័ន្ធផ្តល់ព័ត៌មានបន្ថែមនៅក្នុងរយៈពេលមួយសមស្រប
- រក្សាទុកសិទ្ធិសើរើស្ថានភាពណាមួយមួយអន្លើសិន និងតែងតាំងអ្នកជំនាញឯករាជ្យ និងមានសមត្ថភាពខ្ពស់ឲ្យឃ្លាំមើលស្ថានភាព និងរាយការណ៍ជូនក្រុមប្រឹក្សាវិញ ឬ

---

[62] ទោះបីជាយ៉ាងនេះក្តី សេចក្តីសម្រេចចិត្តលេខ ៥/១ ចែងថា សម្រាប់អាណត្តិការងារលើកដំបូង សាមជិក ១/៣ នឹងបម្រើការងាររយៈពេល ១ ឆ្នាំ និង ១/៣ ទៀតនឹងបម្រើការងាររយៈពេល ២ ឆ្នាំដើម្បីរៀបចំសមាជិកភាព។

- ផ្តល់អនុសាសន៍ឲ្យការិយាល័យ OHCHR ផ្តល់កិច្ចសហប្រតិបត្តិការបច្ចេកទេស ការជួយជ្រោមជ្រែងការកសាងសមត្ថភាព ឬ សេវាប្រឹក្សាយោបល់ជូនរដ្ឋពាក់ព័ន្ធ

i. សម្រាប់ព័ត៌មានបន្ថែមស្តីពី**នីតិវិធីបណ្តឹង** សូមមើលជំពូក VIII (**ការដាក់បណ្តឹងចោទប្រកាន់ការរំលោភសិទ្ធិមនុស្ស**) នៅក្នុង*សៀវភៅណែនាំ*នេះ។

## ឃ. យន្តការនីតិវិធីពិសេស

"**យន្តការនីតិវិធីពិសេស**" គឺជាឈ្មោះទូទៅមួយដែលបានផ្តល់ជូនយន្តការដែលបានបង្កើតឡើងដោយអតីតគណកម្មការសិទ្ធិមនុស្ស ហើយត្រូវបានយកមកប្រើប្រាស់ដោយក្រុមប្រឹក្សាដើម្បីឃ្លាំមើល ផ្តល់យោបល់ប្រឹក្សា និងធ្វើរបាយការណ៍ជាសាធារណៈស្តីពីស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេស ឬ ទឹកដីជាក់លាក់ណាមួយ (**អណត្តិការងារតាមប្រទេស**) ឬ លើបាតុភាពធំៗនៃការរំលោភសិទ្ធិមនុស្សលើពិភពលោក (**អាណត្តិតាមវិស័យប្រធានបទ**)។

ចាប់តាំងពីខែមិថុនា ឆ្នាំ២០០៧ ក្រុមប្រឹក្សាបានចាប់ផ្តើមដំណើរការសើរើ កែសម្រួល និងបង្កើនប្រសិទ្ធភាពអាណត្តិការងារនៃយន្តការនីតិវិធីពិសេសនីមួយៗដែលប្រគល់ជូនខ្លួន។ ក្រុមប្រឹក្សាបានបញ្ឈប់ និងកែសម្រួលអាណត្តិការងារខ្លះ បានបង្កើតថ្មីឡើងវិញ បង្កើតដំណើរការជ្រើសរើស និងតែងតាំងថ្មីសម្រាប់មន្ត្រីកាន់កាប់អាណត្តិការងារ និងចងក្រង**ក្រមស្តីពីវិជ្ជាជីវៈនៃមន្ត្រីកាន់កាប់អាណត្តិការងារនៃយន្តការនីតិវិធីពិសេស** (សេចក្តីសម្រេចចិត្តលេខ ៥/២)។

មន្ត្រីកាន់កាប់អាណត្តិការងារ (អ្នករាយការណ៍ពិសេស តំណាងពិសេស តំណាងនានា អ្នកជំនាញឯករាជ្យ និងសមាជិកក្រុមការងារ) បំពេញការងារទៅតាមសមត្ថភាពរៀងៗខ្លួន។ សកម្មភាពរបស់ពួកគេរួមមាន៖

- ទទួល ចែករំលែក និងវិភាគព័ត៌មានស្តីពីស្ថានភាពសិទ្ធិមនុស្ស
- ឆ្លើយតបទៅនឹងបណ្តឹងជាលក្ខណៈបុគ្គល
- ធ្វើការសិក្សានានា
- ដាក់ការអំពាវនាវបន្ទាន់ ឬ លិខិតស្តីពីការចោទប្រកាន់ជូនរដ្ឋាភិបាល
- ធ្វើទស្សនកិច្ចផ្ទាល់ទៅតាមប្រទេសតាមការអញ្ជើញរបស់រដ្ឋាភិបាល និងចងក្រងរបកគំហើញ និងអនុសាសន៍ផ្អែកលើទស្សនកិច្ចទាំងនោះ
- ផ្តល់យោបល់ប្រឹក្សាលើកិច្ចសហប្រតិបត្តិការបច្ចេកទេសនៅត្រឹមកម្រិតជាតិ និង
- ចូលរួមនៅក្នុងការលើកកម្ពស់ទូទៅ

ការិយាល័យ OHCHR ផ្តល់បុគ្គលិក សម្ភារៈភ័ស្តុភារ និងការជួយជ្រោមជ្រែងស្រាវជ្រាវជូនមន្ត្រីកាន់កាប់អាណត្តិការងារនៃយន្តការនីតិវិធីពិសេសដើម្បីគាំទ្រលើអាណត្តិការងាររបស់ពួកគេ។

i. សម្រាប់ព័ត៌មានបន្ថែមស្តីពី**យន្តការនីតិវិធីពិសេស** សូមមើលជំពូក VI (**យន្តការនីតិវិធីពិសេស**) នៅក្នុង*សៀវភៅណែនាំ*នេះ។

## ង. ក្រុមការងារនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស

ក្រុមការងារទូទៅទទួលបន្ទុកលើសិទ្ធិទទួលបានការអភិវឌ្ឍ

**ក្រុមការងារទូទៅទទួលបន្ទុកលើសិទ្ធិទទួលបានការអភិវឌ្ឍ** ត្រូវបានបង្កើតឡើងដោយគណកម្មការសិទ្ធិមនុស្ស[63]។ នៅក្នុងខែមីនា ឆ្នាំ២០០៧ ក្រុមប្រឹក្សាសិទ្ធិមនុស្សបានបន្តអាណត្តិការងាររបស់ខ្លួនសាជាថ្មីសម្រាប់រយៈពេល ២ ឆ្នាំ (សេចក្តីសម្រេចចិត្តលេខ ៤/៤)។

ក្រុមការងារនេះកោះប្រជុំប្រចាំឆ្នាំរយៈពេល ៥ ថ្ងៃនៃថ្ងៃធ្វើការងារដោយមានបេសកកម្មៈ

- ឃ្លាំមើល និងពិនិត្យសើរើសវឌ្ឍនភាពនៅក្នុងការលើកកម្ពស់ និងការអនុវត្តសិទ្ធិទទួលបានការអភិវឌ្ឍ
- ពិនិត្យសើរើរបាយការណ៍ និងព័ត៌មានផ្សេងៗដែលបានដាក់ជូនដោយរដ្ឋ ភ្នាក់ងារនៃអង្គការសហប្រជាជាតិ និងអង្គការ NGOs ព្រមទាំងអង្គការអន្តរជាតិពាក់ព័ន្ធផ្សេងទៀត និង
- ធ្វើបទបង្ហាញរបាយការណ៍ប្រជុំស្តីពីការពិភាក្សាសម្រេចរបស់ក្រុមប្រឹក្សារួមទាំងផ្តល់យោបល់ប្រឹក្សាជូនការិយាល័យ OHCHR ពាក់ព័ន្ធនឹងការអនុវត្តសិទ្ធិទទួលបានការអភិវឌ្ឍ និងស្នើយោបល់អំពីកម្មវិធីជំនួយបច្ចេកទេសប្រសិនបើអាចទៅតាមសំណើសុំនៃប្រទេសដែលចាប់អារម្មណ៍។

នៅក្នុងសេចក្តីសម្រេចដដែលនេះ ក្រុមប្រឹក្សាក៏បានបន្តអាណត្តិការងាររយៈពេល ២ ឆ្នាំសម្រាប់**ក្រុមការងារជាន់ខ្ពស់ទទួលបន្ទុកលើការអនុវត្តសិទ្ធិទទួលបានការអភិវឌ្ឍ** ដែលបានបង្កើតឡើងនៅក្នុងក្របខណ្ឌនៃក្រុមកាងារទទួលបន្ទុកលើសិទ្ធិទទួលបានការអភិវឌ្ឍ។

ក្រុមការងារជាន់ខ្ពស់នេះមានគោលបំណងផ្តល់ជំនាញចាំបាច់ដល់ក្រុមការងារដើម្បីអាចឲ្យក្រុមការងារទូទៅមានលទ្ធភាពផ្តល់អនុសាសន៍សមស្របជូនតួអង្គនានាលើបញ្ហាដែលត្រូវបានរកឃើញសម្រាប់ការអនុវត្តសិទ្ធិទទួលបានការអភិវឌ្ឍ។ ក្រុមការងារជាន់ខ្ពស់នេះរួមមានអ្នកជំនាញ ៥ រូបដែលត្រូវបានជ្រើសតាំងដោយប្រធានក្រុមការងារទទួលបន្ទុកលើសិទ្ធិទទួលបានការអភិវឌ្ឍក្រោយពីមានការពិគ្រោះយោបល់ជាមួយនឹងក្រុមតំបន់នីមួយនៃអង្គការសហប្រជាជាតិ និងសមាជិកស្ថាប័នផ្សេងទៀតរួមទាំងតំណាងមកពីស្ថាប័នពាណិជ្ជកម្ម ហិរញ្ញវត្ថុ និងអភិវឌ្ឍអន្តរជាតិផងដែរ។ ក្រុមការ

[63] សូមមើលសេចក្តីសម្រេចចិត្តលេខ ១៩៩៨/៧២ និងសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សា ECOSOC លេខ ១៩៩៨/២៦៩។

ងារជាន់ខ្ពស់នេះកោះប្រជុំប្រចាំឆ្នាំរយៈពេល ៧ ថ្ងៃនៃថ្ងៃការងារ ហើយដាក់បង្ហាញរបាយការណ៍របស់ខ្លួនជូនក្រុមការងារទូទៅ។

## ច. វេទិកាសង្គម

នៅក្នុងឆ្នាំ២០០៧ ក្រុមប្រឹក្សាសិទ្ធិមនុស្សបានបន្តអាណត្តិការងារនៃវេទិកាសង្គមដោយរក្សាទុកវេទិកានេះជា "វេទិកាពិសេសសម្រាប់កិច្ចសន្ទនាឆ្លើយឆ្លងរវាងយន្តការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ និងភាគីពាក់ព័ន្ធផ្សេងទៀតរួមទាំងអង្គការមូលដ្ឋាន ហើយគូសបញ្ជាក់សារសំខាន់នៃកិច្ចសម្របសម្រួលនៅកម្រិតជាតិ កម្រិតតំបន់ និងកម្រិតអន្តរជាតិសម្រាប់លើកកម្ពស់ឯកភាពសង្គមដោយផ្អែកលើគោលការណ៍នៃយុត្តិធម៌សង្គម សមភាព និងសាមគ្គីភាព ព្រមទាំងលើកឡើងអំពីជ្រុងសង្គម និងបញ្ហាប្រឈមនៃសាកលភាវូបនីយកម្មដែលកំពុងដំណើរការ" (សេចក្តីសម្រេចចិត្តលេខ ៦/១៣)។

តាមគំនិតផ្តួចផ្តើមនៃអតីតអនុគណកម្មការ វេទិកាសង្គម[64]បានកើតចេញដំបូងជាវេទិកាមុនសម័យប្រជុំស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ដែលបានរៀបចំឡើងរយៈពេល ២ ថ្ងៃនៅមុនសម័យប្រជុំប្រចាំឆ្នាំនៃអនុគណកម្មការ។ ទោះបីជាវេទិកាសង្គមពីដើមឡើយត្រូវបានបង្កើតឡើងជាក្រុមតូចចំណុះអនុគណកម្មការក៏ដោយ បច្ចុប្បន្នវេទិកាសង្គមគឺជាយន្តការឯករាជ្យនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស។

វេទិកាសង្គមជួបប្រជុំរៀងរាល់ឆ្នាំរយៈពេល ៣ ថ្ងៃនៃថ្ងៃធ្វើការងារដើម្បីផ្តោតលើប្រធានបទជាក់លាក់ដែលក្រុមប្រឹក្សាប្រគល់ជូន។ វេទិកានេះបានជួបប្រជុំលើកទីមួយក្នុងនាមជាយន្តការនៃក្រុមប្រឹក្សានៅក្នុងខែកញ្ញា ឆ្នាំ២០០៨ ហើយនឹងពិភាក្សានីតិវិធីលើប្រធានបទជាក់លាក់មួយចំនួនតាមសំណើសុំរបស់ក្រុមប្រឹក្សាដោយមានការចូលរួមពីមន្ត្រីកាន់កាប់អាណត្តិការងារ។ វេទិកាពិសេសត្រូវបានស្នើសុំឲ្យរៀបចំសេចក្តីសន្និដ្ឋាន និងអនុសាសន៍ដើម្បីដាក់ជូនស្ថាប័នពាក់ព័ន្ធតាមរយៈក្រុមប្រឹក្សា និងផ្តោតលើ៖

- បញ្ហាចោទនានាទាក់ទងនឹងការលុបបំបាត់ភាពក្រីក្រនៅក្នុងបរិបទនៃសិទ្ធិមនុស្ស
- ការក្រេបជញ្ជក់យកបទដ្ឋានអនុវត្តល្អៗដើម្បីប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រតាមរយៈបទបង្ហាញរបស់ស្ថាប័នមូលដ្ឋានដាក់ជូនវេទិកាសង្គម និង
- ជ្រុងសង្គមនៃដំណើរការសាកលភាវូបនីយកម្ម

[64] សូមកុំច្រឡំនឹងវេទិកាសង្គមសាកលលោក។

វេទិកាសង្គមដឹកនាំប្រជុំដោយប្រធានអ្នកធ្វើរបាយការណ៍ ដែលត្រូវបានតែងតាំងដោយប្រធានក្រុមប្រឹក្សាជារៀងរាល់ឆ្នាំពីក្នុងចំណោមបេក្ខជនជ្រើសតាំងដែលបានដាក់ជូនដោយក្រុមតំណាងតំបន់។

i. សម្រាប់ព័ត៌មានបច្ចុប្បន្នស្តីពី**វេទិកាសង្គម** សូមចូលទៅកាន់គេហទំព័រនៃការិយាល័យ OHCHR។

## ឆ. វេទិកាស្តីពីបញ្ហាជនជាតិភាគតិច

**វេទិកាស្តីពីបញ្ហាជនជាតិភាគតិច**[65]ជំនួសអតីតក្រុមការងារនៃអនុគណកម្មការស្តីពីបញ្ហាជនជាតិភាគតិច។ វេទិកានេះផ្តល់ឱកាសដល់ការលើកកម្ពស់កិច្ចសន្ទនា និងកិច្ចសហប្រតិបត្តិការស្តីពីបញ្ហានានាពាក់ព័ន្ធនឹងបុគ្គលដែលស្ថិតនៅក្នុងក្រុមជាតិសាសន៍ ជាតិពិន្ទុ សាសនា និងភាសានៃជនជាតិភាគតិចតាមរយៈ៖

- ការចូលរួមចំណែកលើប្រធានបទ និងជំនាញជូនការងារនៃ**អ្នកជំនាញឯករាជ្យទទួលបន្ទុកបញ្ហាជនជាតិភាគតិច** និង
- កំណត់ និងវិភាគបទដ្ឋានអនុវត្តល្អៗ បញ្ហាប្រឈម ឱកាស និងគំនិតផ្តួចផ្តើមសម្រាប់ការពង្រឹងការអនុវត្ត**សេចក្តីប្រកាសស្តីពីសិទ្ធិបុគ្គលទាំងឡាយដែលស្ថិតនៅក្នុងក្រុមជាតិសាសន៍ ឬជាតិពិន្ទុ សាសនា និងភាសានៃជនជាតិភាគតិច**។

វេទិកានេះជួបប្រជុំជារៀងរាល់ឆ្នាំរយៈពេល ២ ថ្ងៃនៃថ្ងៃធ្វើការងារនៅទីក្រុងហ្សឺណែវដើម្បីពិភាក្សាលើប្រធានបទណាមួយ និងរំពឹងថានឹងចូលរួមចំណែកលើកិច្ចខិតខំរបស់ឧត្តមស្នងការក្នុងការធ្វើឲ្យកិច្ចសហប្រតិបត្តិការប្រសើរឡើងក្នុងចំណោមយន្តការនៃអង្គការសហប្រជាជាតិ អង្គការ និងស្ថាប័នជំនាញ មូលនិធិ និងកម្មវិធីស្តីពីសកម្មភាពពាក់ព័ន្ធនឹងការលើកកម្ពស់ និងការការពារសិទ្ធិបុគ្គលដែលស្ថិតនៅក្នុងក្រុមជនជាតិភាគតិចរួមទាំងនៅថ្នាក់តំបន់ផងដែរ[66]។

ខណៈប្រធានវេទិកា (ដែលត្រូវបានតែងតាំងជារៀងរាល់ឆ្នាំដោយប្រធានក្រុមប្រឹក្សាដោយផ្អែកលើមូលដ្ឋាននៃការផ្លាស់ប្តូរទៅតាមតំបន់) ទទួលខុសត្រូវលើការរៀបចំសេចក្តីសង្ខេបនៃកិច្ចពិភាក្សាសម្រាប់វេទិកានេះ **អ្នកជំនាញឯករាជ្យទទួលបន្ទុកបញ្ហាជនជាតិភាគតិច**ដឹកនាំការងារនៃវេទិកា និងរៀបចំកិច្ចប្រជុំប្រចាំឆ្នាំ។ អ្នកជំនាញឯករាជ្យក៏ត្រូវបានអញ្ជើញឲ្យដាក់បញ្ចូលរបាយការណ៍របស់ខ្លួនស្តីពីអនុសាសន៍លើប្រធានបទនានាជូនវេទិកា និងអនុសាសន៍នានាស្តីពីប្រធានបទណាមួយនាពេលអនាគតដើម្បីទុកជូនក្រុមប្រឹក្សាពិចារណា។

---

[65] បង្កើតឡើងដោយសេចក្តីសម្រេចនសក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៦/១៥ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០៧។

[66] នៅក្នុងសម័យប្រជុំសម្ពោធនាថ្ងៃទី១៥ និង១៦ ខែធ្នូ ឆ្នាំ២០០៨ វេទិកានេះត្រូវបានរំពឹងថានឹងពិចារណាលើបញ្ហាជនជាតិភាគតិច និងសិទ្ធិទទួលបានការអប់រំ។

ក្រុមប្រឹក្សានេះពិនិត្យសើរើការងាររបស់វេទិកាក្រោយរយៈពេល ៤ ឆ្នាំ ពោលគឺ នៅក្នុងឆ្នាំ២០១២។

i. សម្រាប់ព័ត៌មានបច្ចុប្បន្នពាក់ព័ន្ធ**វេទិកាសង្គមស្តីពីបញ្ហាជនជាតិភាគតិច** និងពាក់ព័ន្ធនឹង**អ្នកជំនាញឯករាជ្យទទួលបន្ទុកបញ្ហាជនជាតិភាគតិច** សូមចូលទៅកាន់គេហទំព័រនៃការិយាល័យ OHCHR។

## ជ. យន្តការអ្នកជំនាញទទួលបន្ទុកសិទ្ធិជនជាតិដើមភាគតិច

**យន្តការអ្នកជំនាញទទួលបន្ទុកជនជាតិដើមភាគតិច**[67]គឺជាយន្តការបន្តពីអតីតក្រុមការងារនៃអនុគណកម្មការទទួលបន្ទុកជនជាតិដើមភាគតិច។ ក្នុងនាមជាយន្តការចំណុះក្រុមប្រឹក្សាសិទ្ធិមនុស្ស យន្តការអ្នកជំនាញផ្តល់ជំនាញលើប្រធានបទស្តីពីសិទ្ធិជនជាតិដើមភាគតិចទៅតាមការស្នើសុំរបស់ក្រុមប្រឹក្សា។ យន្តការអ្នកជំនាញធ្វើរបាយការណ៍ប្រចាំឆ្នាំជូនក្រុមប្រឹក្សា ផ្តោតចំបងលើការសិក្សា និងយោបល់ប្រឹក្សាផ្អែកលើការស្រាវជ្រាវ និងអាចលើកសំណូមពរស្របតាមវិសាលភាពនៃការងាររបស់ខ្លួនជូនក្រុមប្រឹក្សាដើម្បីពិចារណា និងអនុម័ត។

យន្តការអ្នកជំនាញរួមមានអ្នកជំនាញឯករាជ្យ ៥ រូប ដែលបំពេញការងាររយៈពេល ៣ ឆ្នាំ ហើយអាចមានលទ្ធភាពត្រូវបានជ្រើសតាំងសាជាថ្មីសម្រាប់មួយអាណត្តិទៀត។ យន្តការនេះអាចជួបប្រជុំរហូតដល់ ៥ ថ្ងៃក្នុងមួយឆ្នាំក្នុងរូបភាពជាកិច្ចប្រជុំឯកជន និងសាធារណៈ ហើយមានសេរីភាពសម្រេចលើវិធីបំពេញការងាររបស់ខ្លួនទោះបីជាមិនមានសិទ្ធិចេញសេចក្តីសម្រេចចិត្ត ឬ សេចក្តីសម្រេចនានាក៏ដោយ។

**អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តនៃជនជាតិដើមភាគតិច** និងសមាជិកនៃ**វេទិកាអចិន្ត្រៃយ៍ស្តីបីបញ្ហាជនជាតិដើមភាគតិច**ក៏អាចមានវត្តមាន និងចូលរួមចំណែកនៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំនៃយន្តការអ្នកជំនាញផងដែរ។

i. សម្រាប់ព័ត៌មានបច្ចុប្បន្នស្តីពី**យន្តការអ្នកជំនាញ** និង**អ្នករាយការណ៍ពិសេសទទួលបន្ទុកស្ថានភាពសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តនៃជនជាតិដើមភាគតិច** សូមចូលទៅកាន់គេហទំព័រនៃការិយាល័យ OHCHR។

## I. សេចក្តីប្រកាស និងផែនការសកម្មភាពក្រុង Durban

នៅក្នុងឆ្នាំ២០០១ សន្និសីទពិភពលោកប្រឆាំងនឹងការប្រកាន់ពូជសាសន៍ ការរើសអើងពូជសាសន៍ ការរើសអើងជនបរទេស និងការរើសអើងពាក់ព័ន្ធនានាត្រូវបានរៀបចំឡើងនៅក្នុងក្រុង

---

[67] បង្កើតឡើងដោយសេចក្តីសម្រេចចិត្តនៃក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៦/៣៦ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧។

Durban ប្រទេសអាហ្វ្រិកខាងត្បូង។ **សេចក្ដីប្រកាស និងផែនការសកម្មភាពក្រុង Durban**ដែលត្រូវ បាន អនុម័តនៅក្នុងសន្និសីទនោះកត់ត្រាទុកការប្ដេជ្ញារបស់រដ្ឋក្នុងការបំពេញការងាររួមគ្នាដើម្បីលុបបំបាត់ ការប្រកាន់ពូជសាសន៍ ការរើសអើងពូជសាសន៍ ការរើសអើងជនបរទេស និងការរើសអើងពាក់ព័ន្ធ ផ្សេងទៀត។ សេចក្ដីប្រកាសនេះគឺជាផែនទីបង្ហាញផ្លូវលម្អិត និងផ្ដោលើសកម្មភាពនានាដែលបង្ហាញ នូវវិធីសាស្ត្រដំណើរការរួមមួយក្នុងគោលបំណងឈានទៅសម្រេចគោលការណ៍សមភាព និងភាព គ្មានការរើសអើង។

នៅក្នុងឆ្នាំ២០០៦ មហាសន្និបាតនៃអង្គការសហប្រជាជាតិបានសម្រេចកោះប្រជុំសន្និសីទមួយ នៅក្នុងឆ្នាំ២០០៩ដើម្បីសើរើការអនុវត្តសេចក្ដីប្រកាស និងផែនការសកម្មភាពក្រុង Durban។ មហា សន្និបាតបានស្នើសុំក្រុមប្រឹក្សាសិទ្ធិមនុស្សឲ្យរៀបចំព្រឹត្តិការណ៍នេះដើម្បីទាញប្រយោជន៍ពីយន្តការ បន្តតាមដានដែលមានស្រាប់ចំនួន ៣[68] ក្នុងគោលបំណងបង្កើតផែនការជាក់ស្ដែងមួយ និងក្នុងគោល បំណងផ្ដល់បច្ចុប្បន្នភាពប្រចាំឆ្នាំ និងធ្វើរបាយការណ៍ស្ដីពីបញ្ហានេះដោយចាប់ផ្ដើមក្នុងឆ្នាំ២០០៧[69]។ គណកម្មាធិការត្រៀមរៀបចំសន្និសីទសើរើនៃក្រុមប្រឹក្សាបានសម្រេចថា សន្និសីទនឹងរៀបចំឡើងនៅ ក្នុងទីក្រុងហ្សឺណែវក្នុងខែមេសា ឆ្នាំ២០០៩។

## ១. ក្រុមការងារអន្តររដ្ឋាភិបាលទទួលបន្ទុកការអនុវត្តប្រកបដោយប្រសិទ្ធិភាព នៃសេចក្ដីប្រកាស និងផែនការសកម្មភាពក្រុង Durban

**ក្រុមការងារអន្តររដ្ឋាភិបាលទទួលបន្ទុកការអនុវត្តប្រកបដោយប្រសិទ្ធិភាពនៃសេចក្ដីប្រកាស និងផែនការសកម្មភាពក្រុង Durban** ត្រូវបានបង្កើតឡើងដោយគណកម្មការសិទ្ធិមនុស្ស (សេចក្ដី សម្រេចចិត្តលេខ ២០០២/៦៨)។ នៅក្នុងខែមិថុនា ឆ្នាំ២០០៦ ក្រុមប្រឹក្សាសិទ្ធិមនុស្សបានបន្តអាណត្តិ ការងាររបស់ខ្លួនរយៈពេល ៣ ឆ្នាំបន្ថែមទៀត (សេចក្ដីសម្រេចចិត្តលេខ ១/៥)។ ក្រុមការងារអន្តរ រដ្ឋាភិបាលមានភារកិច្ច៖

- ផ្ដល់អនុសាសន៍ក្នុងគោលបំណងឲ្យការអនុវត្តសេចក្ដីប្រកាស និងផែនការសកម្មភាពក្រុង Durban មានប្រសិទ្ធភាព និង

---

[68] ក្រុមកាងារអន្តររដ្ឋាភិបាលទទួលបន្ទុកការអនុវត្តប្រកដដោយប្រសិទ្ធភាពនៃសេកច្ចីប្រកាស និងផែនការ សកម្មភាពក្រុង Durban ក្រុមអ្នកជំនាញល្បីៗទទួលបន្ទុកការអនុវត្តសេចក្ដីប្រកាស និងផែនការសកម្មភាពក្រុង Durban និងក្រុមការងារនៃអ្នកជំនាញទទួលបន្ទុកជនជាតិភាគតិចអាហ្វ្រិក។

[69] សូមមើលសេចក្ដីសម្រេចចិត្តនៃមហាសន្និបាតលេខ ៦១/១៤៩។

- រៀបចំបទដ្ឋានបំពេញបំពេញបន្ថែមអន្តរជាតិដើម្បីពង្រឹង និងធ្វើបច្ចុប្បន្នភាពលិខិតុបករណ៍អន្តរជាតិប្រឆាំងនឹងការប្រកាន់ពូជសាសន៍ ការរើងអើសពូជសាសន៍ ការរើសអើងជនបរទេស និងការរើសអើងពាក់ព័ន្ធផ្សេងទៀតនៅក្នុងគ្រប់រូបភាពទាំងអស់

i. ដើម្បីស្វែងយល់បន្ថែមអំពីក្រុម**ការងារអន្តររដ្ឋាភិបាល** សូមចូលទៅកាន់គេហទំព័រនៃការិយាល័យ OHCHR។

## ២. ក្រុមអ្នកជំនាញឯករាជ្យល្បីៗទទួលបន្ទុកការអនុវត្តសេចក្តីប្រកាស និងផែនការសកម្មភាពក្រុង Durban

សន្និសីទពិភពលោកបានស្នើសុំឧត្តមស្នងការឲ្យសហប្រតិបត្តិការជាមួយនឹងក្រុម**ការងារអ្នកជំនាញឯករាជ្យល្បីៗ**ចំនួន ៥ ដើម្បីបន្តតាមដានការអនុវត្តបទប្បញ្ញត្តិនៃសេចក្តីប្រកាស និងផែនការសកម្មភាពក្រុង Durban[70]។

នៅក្នុងឆ្នាំ២០០៣ អ្នកជំនាញឯករាជ្យល្បីៗ (មួយរូបមកពីក្រុមតំណាងតំបន់នីមួយៗ) ត្រូវបានអគ្គលេខាធិការ Kofi Annan តែងតាំងពីក្នុងចំណោមបេក្ខជនស្នើឡើងដោយប្រធានគណកម្មការសិទ្ធិមនុស្សក្រោយពីបានពិគ្រោះយោប់ជាមួយនឹងក្រុមតំបន់។

អ្នកជំនាញទាំងនេះមានភារកិច្ច[71]៖

- បន្តតាមដានការអនុវត្តបទប្បញ្ញត្តិនៃសេចក្តីប្រកាស និងផែនការសកម្មភាពក្រុង Durban ដោយសហការជាមួយនឹងឧត្តមស្នងការ និង
- ជួយឧត្តមស្នងការរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំដើម្បីដាក់ជូនក្រុមប្រឹក្សា និងមហាសន្និបាតដោយផ្អែកលើព័ត៌មាន និងការយល់ឃើញរបស់រដ្ឋ គណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សពាក់ព័ន្ធ យន្តការនីតិវិធីពិសេស និងយន្តការផ្សេងទៀតនៃក្រុមប្រឹក្សា អង្គការអន្តរជាតិ និងតំបន់ អង្គការ NGO និងស្ថាប័នសិទ្ធិមនុស្សជាតិ (ស្ថាប័ន NHRIs)។

i. ដើម្បីស្វែងយល់បន្ថែមអំពី**អ្នកជំនាញឯករាជ្យល្បីៗ** និងសម្រាប់ព័ត៌មានបច្ចុប្បន្នស្តីពីក្រុម**ការងារនៃអ្នកជំនាញទទួលបន្ទុកជនជាតិភាគតិចអាហ្វ្រិក** (Working Group of Experts on People of African Descent) សូមចូលទៅកាន់គេហទំព័រនៃការិយាល័យ OHCHR។

---

[70] សូមមើលកថាខណ្ឌ ១៩១ (ខ) នៃផែនការសកម្មភាព និងសេចក្តីសម្រេចចិត្តនៃមហាសន្និបាតលេខ ៥៦/២៦៦។

[71] សូមមើលសេចក្តីសម្រេចចិត្តនៃគណកម្មការលេខ ២០០៣/៣០។ សូមមើលផងដែរសេចក្តីសម្រេចចិត្តនៃមហាសន្និបាតលេខ ៥៩/១៧៧។

## ៣. ក្រុមការងារនៃអ្នកជំនាញទទួលបន្ទុកលើជនជាតិភាគតិចអាហ្វ្រិក

**ក្រុមការងារនៃអ្នកជំនាញទទួលបន្ទុកលើជនជាតិភាគតិចអាហ្វ្រិក**គឺជាយន្តការនីតិវិធីពិសេសនៃក្រុមប្រឹក្សាដែលត្រូវបានបង្កើតឡើងដោយគណកម្មការទៅតាមសំណើសុំរបស់សន្និសីទពិភពលោក។ ក្រុមការងារនេះរួមមានអ្នកជំនាញឯករាជ្យដែលត្រូវបានតែងតាំងឡើងដោយផ្អែកតាមតំណាងភូមិសាស្ត្រស្មើគ្នា។ ក្រុមការងាររៀបចំកិច្ចប្រជុំរយៈពេល ៥ ថ្ងៃជារៀងរាល់ឆ្នាំ និងធ្វើទស្សនកិច្ចទៅតាមប្រទេសនានាតាមការអញ្ជើញរបស់រដ្ឋាភិបាលដើម្បីសម្របសម្រួលការស្វែងយល់ស៊ីជម្រៅអំពីស្ថានភាពនៃជនជាតិភាគតិចអាហ្វ្រិកនៅតាមតំបន់នានាក្នុងពិភពលោក។ ក្រុមការងារនេះដាក់របាយការណ៍ប្រចាំឆ្នាំជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស និងមានភារកិច្ចដូចខាងក្រោម[72]៖

- សិក្សាបញ្ហានៃការរើសអើងពូជសាសន៍ដែលជួបប្រឈមដោយជនជាតិភាគតិចអាហ្វ្រិកដែលរស់នៅតាមទីកន្លែងនានានៅក្រៅប្រទេស និងប្រមូលព័ត៌មានពាក់ព័ន្ធពីរដ្ឋាភិបាល
- ស្នើសុំវិធានការធានាឲ្យជនជាតិភាគតិចអាហ្វ្រិកទទួលបានសិទ្ធិប្រើប្រាស់ប្រព័ន្ធយុត្តិធម៌ពេញលេញ និងប្រកបដោយប្រសិទ្ធភាព
- ដាក់អនុសាសន៍ស្តីពីការបង្កើត ការអនុវត្ត និងការពង្រឹងការអនុវត្តវិធានការដ៏មានប្រសិទ្ធភាពនានាដើម្បីលុបបំបាត់ការកំណត់សាវតារក្នុងន័យរើសអើងពូជសាសន៍លើជនជាតិភាគតិចអាហ្វ្រិក
- ពន្យល់លម្អិតអំពីសំណូមពររយៈពេលខ្លី មធ្យម និងរយៈពេលវែងដើម្បីលុបបំបាត់ការរើសអើងពូជសាសន៍ប្រឆាំងនឹងជនជាតិភាគតិចអាហ្វ្រិក
- លើកសំណូមពរស្តីពីការលុបបំបាត់ការរើសអើងពូជសាសន៍ប្រឆាំងនឹងប្រជាជនអាហ្វ្រិក និងជនជាតិភាគតិចអាហ្វ្រិកនៅតាមគ្រប់ទីកន្លែងក្នុងពិភពលោក និង
- លើកឡើងបញ្ហានានាពាក់ព័ន្ធនឹងសុខមាលភាពប្រជាជនអាហ្វ្រិក និងជនជាតិភាគតិចអាហ្វ្រិកដែលមានចែងនៅក្នុងសេចក្តីប្រកាស និងផែនការសកម្មភាពក្រុង Durban

## ៤. គណកម្មាធិការ*អាដហុក*ទទួលបន្ទុកពន្យល់បកស្រាយបទដ្ឋានបំពេញបន្ថែម

ក្រុមប្រឹក្សាសិទ្ធិមនុស្សបានបង្កើត**គណកម្មាធិការ*អាដហុក*ទទួលបន្ទុកពន្យល់បកស្រាយបទដ្ឋានបំពេញបន្ថែម** នៅក្នុងខែធ្នូ ឆ្នាំ២០០៦។ គណកម្មាធិការនេះមានភារកិច្ចបង្កើតបទដ្ឋានបំពេញបន្ថែមក្នុងទម្រង់ជាអនុសញ្ញា ឬ ពិធីសារបន្ថែមនៃ**អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់**

---

[72] សូមមើលសេចក្តីសម្រេចចិត្តនៃគណកម្មការទទួលបន្ទុកសិទ្ធិមនុស្សលេខ ២០០២/៦៨ និង ២០០៣/៣០។

**នៃការរើសអើងពូជសាសន៍** អនុលោមតាមអាទិភាព និងភាពបន្ទាន់។ បទដ្ឋានបំពេញបន្ថែមទាំងនេះមានគោលបំណង[73]៖

- បំពេញចន្លោះប្រហោងនៅក្នុងអនុសញ្ញា និង
- ផ្តល់បទដ្ឋាននិយាមថ្មីៗដែលមានគោលបំណងប្រយុទ្ធប្រឆាំងគ្រប់ទម្រង់នៃការរើសអើងនាពេលបច្ចុប្បន្ន រួមទាំង ការអុតអាលឲ្យមានការស្អប់ពូជសាសន៍ និងសាសនា

គណៈកម្មាធិការ*អាដហុក*កោះប្រជុំជារៀងរាល់ឆ្នាំរយៈពេល ១០ ថ្ងៃនៃថ្ងៃធ្វើការងារដើម្បីបង្កើតលិខិតុបករណ៍ច្បាប់ចាំបាច់។ គណៈកម្មាធិការនេះបានរៀបចំប្រជុំសម្ពោធដំបូងនៅក្នុងខែកុម្ភៈ ឆ្នាំ២០០៨ និងតម្រូវឲ្យធ្វើរបាយការណ៍ទៀងទាត់ជូនក្រុមប្រឹក្សាអំពីវឌ្ឍនភាព។

## ៥. គណៈកម្មាធិការត្រៀមរៀបចំសន្និសីទសើរើសេចក្តីប្រកាសក្រុង Durban និងក្រុមការងារអន្តររដ្ឋាភិបាលទូទៅនៃអន្តរសម័យប្រជុំទទួលបន្ទុកបន្តតាមដានការងារគណៈកម្មាធិការត្រៀមរៀបចំសន្និសីទសើរើសេចក្តីប្រកាសក្រុង Durban

នៅក្នុងឆ្នាំ២០០៧នាកិច្ចប្រជុំដែលត្រូវបានកំណត់ឡើងដោយមហាសន្និបាត[74] ក្រុមប្រឹក្សាសិទ្ធិមនុស្សបានបង្កើត**គណៈកម្មាធិការត្រៀមរៀបចំសន្និសីទសើរើសេចក្តីប្រកាសក្រុង Durban**[75]។ គណៈកម្មាធិការត្រៀមរៀបចំនេះបានកោះប្រជុំត្រៀមរៀបចំក្នុងខែសីហា ឆ្នាំ២០០៧ និងបន្ទាប់មកកិច្ចប្រជុំសំខាន់ចំនួន ២ ទៀត ចំនួនរយៈពេល ១០ ថ្ងៃនៃថ្ងៃធ្វើការងារនៅក្នុងខែមេសា និងតុលា ឆ្នាំ២០០៨ ដើម្បីសម្រេចទម្រង់បែបបទពាក់ព័ន្ធទាំងអស់សម្រាប់សន្និសីទសើរើសេចក្តីប្រកាសក្រុង Durban ដូចជា៖

- គោលបំណង
- រចនាសម្ព័ន្ធនៃឯកសារលទ្ធផល
- កម្រិតនៃប្រជុំថ្នាក់ណាដែលត្រូវរៀបចំឡើង
- កិច្ចប្រជុំត្រៀមរៀបចំនៅតាមតំបន់ និងគំនិតផ្តួចផ្តើមផ្សេងទៀតរួមទាំងនៅថ្នាក់ជាតិ និង
- កាលបរិច្ឆេទ និងទីតាំង

---

[73] សូមមើលសេចក្តីសម្រេចនៃគណៈកម្មការទទួលបន្ទុកសិទ្ធិមនុស្សលេខ ៣/១០៣ និងសេចក្តីសម្រេចចិត្តលេខ ៦/២១។

[74] សូមមើលសេចក្តីសម្រេចចិត្តនៃមហាសន្និបាតលេខ ៦១/១៤៩។

[75] សូមមើលសេចក្តីសម្រេចចិត្តលេខ ៣/២។ សូមមើលផងដែរសេចក្តីសម្រេចចិត្តលេខ ៦/២៣។

ក្រុមការងារអន្តររដ្ឋាភិបាលទូទៅនៃអន្តរសម័យប្រជុំទទួលបន្ទុកបន្តតាមដានការងារគណកម្មាធិការត្រៀមរៀបចំសន្និសីទសើរើសេចក្តីប្រកាសក្រុង Durban ត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាសិទ្ធិមនុស្សនៅក្នុងសម័យប្រជុំសំខាន់ដំបូងនៃគណកម្មាធិការត្រៀមរៀបចំក្នុងខែមេសា ឆ្នាំ២០០៨ ដោយមានភារកិច្ច[76]៖

- បន្តតាមដានការងារគណកម្មាធិការត្រៀមរៀបចំ រួមទាំង តាមរយៈការសើរើការចូលរួមចំណែក និងតាមរយៈការចាប់ផ្តើមចរចាសេចក្តីព្រាងឯកសារលទ្ធផល និង
- សើរើការរួមចំណែកជាលាយលក្ខណ៍អក្សរបន្ថែម និងរបាយការណ៍នានាដែលបានដាក់ជូនគណកម្មាធិការត្រៀមរៀបចំ

i. ដើម្បីស្វែងយល់បន្ថែមអំពី**គណកម្មាធិការត្រៀមរៀបចំសន្និសីទសើរើសេចក្តីប្រកាសក្រុង Durban និងក្រុមការងារអន្តររដ្ឋាភិបាលទូទៅ** សូមចូលទៅកាន់គេហទំព័រនៃការិយាល័យ OHCHR។

វិធីប្រើទាក់ទង និងបំពេញការងារជាមួយនឹងក្រុមប្រឹក្សាសិទ្ធិមនុស្ស អាណត្តិការងារ និងយន្តការនានា

ការរៀបចំ និងបទដ្ឋានអនុវត្តសម្រាប់ការចូលរួមរបស់អង្គការ NGOs នៅក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស

*"... ការចូលរួម និងការពិគ្រោះយោបល់ជាមួយនឹងអ្នកសង្កេតការណ៍រួមទាំងរដ្ឋដែលពុំមែនជាសមាជិកនៃក្រុមប្រឹក្សា ភ្នាក់ងារជំនាញ អង្គការអន្តររដ្ឋាភិបាល និងស្ថាប័នសិទ្ធិមនុស្សជាតិ ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាលផងនោះត្រូវផ្អែកលើការរៀបចំ រួមទាំងសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមលេខ ១៩៩៦/៣១ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៦ និងបទដ្ឋានអនុវត្តដែលត្រូវបានគោរពតាំងពីដើមមកដោយគណកម្មការសិទ្ធិមនុស្សក្នុងគោលបំណងនាំឲ្យការចូលរួមចំណែករបស់ស្ថាប័នទាំងអស់នេះមានប្រសិទ្ធភាពបំផុត"*[77]។

នៅក្នុងសេចក្តីសម្រេចចិត្តលេខ ៦០/២៥១ មហាសន្និបាតបានទទួលស្គាល់អំពីតួនាទីដ៏សំខាន់របស់អង្គការ NGOs និងតួអង្គសង្គមស៊ីវិលថ្នាក់ជាតិ តំបន់ និងអន្តរជាតិផ្សេងទៀតនៅក្នុងការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស។ មហាសន្និបាតក៏បានលើកឡើងថា ការចូលរួមរបស់អង្គការ NGOs ទាំងនេះនៅក្នុងក្រុមប្រឹក្សាសិទ្ធិមនុស្សនឹង៖

- ផ្អែកលើការរៀបចំ និងបទដ្ឋានអនុវត្តដែលគណកម្មការគោរពពីមុនមក (រួមទាំង **សេចក្តីសម្រេចចិត្តក្រុមប្រឹក្សា ECOSOC លេខ ១៩៩៦/៣១** ផងដែរ) និង

---

[76] សូមមើលសេចក្តីសម្រេចលេខ PC.២/៤។

[77] សូមមើលសេចក្តីសម្រេចចិត្តនៃមហាសន្និបាតលេខ ៦០/២៥១ និងសេចក្តីសម្រេចចិត្តនៃក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៥/១ ឧបសម្ព័ន្ធ។

- ធ្វើយ៉ាងណាធានាឲ្យការចូលរួមចំណែករបស់អង្គការ NGOs និងអ្នកសង្កេតការណ៍ផ្សេងទៀតមានប្រសិទ្ធភាពបំផុត

ការរៀបចំ និងបទដ្ឋានអនុវត្តនៃការចូលរួមរបស់អង្គការ NGO ដែលត្រូវបានគោរពតាំងពីមុនមកដោយគណកម្មការសិទ្ធិមនុស្សត្រូវបានផ្ទេរមកក្រុមប្រឹក្សាសិទ្ធិមនុស្សដើម្បីយកមកអនុវត្តឲ្យបានជោគជ័យ។ ដើម្បីឲ្យស្របតាមកាតព្វកិច្ចនៃក្រុមប្រឹក្សាក្នុងការធានាឲ្យ "ការចូលរួមចំណែករបស់អ្នកសង្កេតការណ៍មានប្រសិទ្ធភាពខ្ពស់បំផុតនោះ" បទដ្ឋានអនុវត្ត និងការរៀបចំទាំងនេះត្រូវបន្តកែសម្រួលដើម្បីឲ្យមានលក្ខណៈប្រសើរឡើង។

អង្គការ NGOs ក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សា ECOSOC ក្នុងនាមជាអ្នកសង្កេតការណ៍នៅក្នុងសម័យប្រជុំក្រុមប្រឹក្សាសិទ្ធិមនុស្ស

*អង្គការ NGOs មានតួនាទីសំខាន់ក្នុងការលើកកម្ពស់ និងការការពារសិទ្ធិមនុស្សគ្រប់យ៉ាងនៅថ្នាក់ជាតិ តំបន់ និងអន្តរជាតិ។ ការចូលរួមរបស់អង្គការ NGOs នៅក្នុងរយៈពេល ២ ឆ្នាំដំបូងក្រោយការបង្កើតក្រុមប្រឹក្សាសិទ្ធិមនុស្សគឺជាសមាសធាតុគន្លឹះមួយសម្រាប់លើកតម្កើងឲ្យកាន់តែមានភាពជឿជាក់លើអង្គការសហប្រជាជាតិ។ អង្គការ NGOs បានចូលរួមចំណែកយ៉ាងសំខាន់នៅក្នុងការកសាងស្ថាប័ននៃក្រុមប្រឹក្សាសិទ្ធិមនុស្សដោយបានផ្តល់ធាតុចូលចាំបាច់ និងមានតម្លៃព្រមទាំងមតិវែកញែកសំខាន់នានារួមទាំងការពិចារណាលើរបៀបវារៈទាំងអស់របស់ក្រុមប្រឹក្សា។*

*ម្យ៉ាងវិញទៀត ការងារបំពេញបន្ថែមរបស់អង្គការ NGOs នៅក្នុងវិស័យសិទ្ធិមនុស្សត្រូវបានមើលឃើញថាកំពុងធ្វើដំណើរចាកចេញជាបណ្តើរពីគោលនយោបាយ "មិនសូវទទួលជោគជ័យ" តាមបែបប្រពៃណីឆ្ពោះទៅរកការចូលរួមកាន់តែមានភាពសហការជាមួយនឹងរដ្ឋាភិបាល និងភាគីពាក់ព័ន្ធផ្សេងទៀត។ ការចូលរួមដ៏មានការទទួលខុសត្រូវបែបនេះមានគោលបំណងធ្វើឲ្យស្ថានភាពសិទ្ធិមនុស្សជាក់ស្តែងកាន់តែប្រសើរឡើង។*

*ដូច្នេះ ការចូលរួម និងធាតុចូលនៃអង្គការ NGOs នៅតាមមូលដ្ឋានមានសារសំខាន់ណាស់ជាពិសេសសម្រាប់ពេលបច្ចុប្បន្នដោយវាបានជម្រុញឲ្យក្រុមប្រឹក្សាជួបប្រជុំកាន់តែញឹកញាប់ជាងមុនដើម្បីពិចារណាធ្វើយ៉ាងណាឲ្យយន្តការពិនិត្យរបាយការណ៍ជាសាកលតាមកាលកំណត់ដំណើរការ។ សរុបមក បញ្ហាប្រឈមចំបងដែលក្រុមប្រឹក្សាសិទ្ធិមនុស្ស និងសហគមន៍អង្គការ NGOs កំពុងជួបប្រទះគឺធ្វើយ៉ាងណាមានការចូលរួមចំណែករបស់សង្គមស៊ីវិលនៅក្នុងការងាររបស់ក្រុមប្រឹក្សាកាន់តែខ្លាំងជាងមុន ពោលគឺ ធ្វើយ៉ាងណាឲ្យឈានទៅរកភាពជាដៃគូពិតប្រាកដរវាងរដ្ឋសមាជិក និងសង្គមស៊ីវិល។*

អគ្គរដ្ឋទូត Luis Alfonso de Alba នៃប្រទេសម៉ិកស៊ិក
ប្រធានដំបូងនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស (ឆ្នាំ២០០៦-២០០៧)

កម្រិតនៃការចូលរួមរបស់អង្គការ NGOs ជាមួយនឹងក្រុមប្រឹក្សាសិទ្ធិមនុស្សកើតមានតាំងពីមានគណកម្មការសិទ្ធិមនុស្សមកម្លេះដែលជាលក្ខណៈពិសេសមួយនៅក្នុងប្រព័ន្ធអង្គការសហប្រជាជាតិ។ ក្នុងនាមជាស្ថាប័នអន្តររដ្ឋាភិបាលមួយ ក្រុមប្រឹក្សាសិទ្ធិមនុស្សប្រមូលផ្តុំទៅដោយចំណេះដឹង និងជំនាញ សាក្សី និងភាពពាក់ព័ន្ធជាក់ស្តែងដែលអង្គការ NGOs បាននាំនាំមកចូលរួមជាមួយនឹងការងាររបស់ខ្លួន។

ចាប់តាំងពីសម័យប្រជុំដំបូងនៅក្នុងខែមិថុនា ឆ្នាំ២០០៦ អង្គការ NGOs បានអនុញ្ញាតឲ្យចូលរួមពេញលេញ និងប្រកបដោយអត្ថន័យនៅក្នុងក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នៅក្នុងសម័យប្រជុំអចិន្ត្រៃយ៍លើកទី ៧ ក្នុងខែមីនា ឆ្នាំ២០០៨ អង្គការ NGOs ចំនួន ១៨០ ត្រូវបានតំណាងសរុបដោយបុគ្គលចំនួន ១១១៦ នាក់។ នៅក្នុងសម័យប្រជុំនេះដែរ អង្គការ NGOs បានដាក់សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរចំនួន ៩៨ ធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់ចំនួន ២២៤ និងរៀបចំព្រឹត្តិការណ៍អមចំនួន ៦៩ លើក។ អធិបតីភាព និងលេខាធិការដ្ឋាននៃក្រុមប្រឹក្សាសិទ្ធិមនុស្សបានព្យាយាមកសាងបន្តពីបទពិសោធន៍ និងការរៀបចំនានាដែលត្រូវបានគោរពតាំងពីមុនមកដោយគណកម្មការសិទ្ធិមនុស្ស ព្រមទាំងទម្លាប់អនុវត្តល្អៗ ខណៈពិចារណាផងដែរថា ក្រុមប្រឹក្សា និងយន្តការសិទ្ធិមនុស្សត្រូវបន្តជួបប្រជុំនៅក្នុងវេទិកាជាច្រើនទៀតពេញរយៈពេល ១ ឆ្នាំ។

មានតែអង្គការ NGOs ក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សា ECOSOC អាចមានសិទ្ធិចូលរួមសម័យប្រជុំនៃក្រុមប្រឹក្សាសិទ្ធិមនុស្សក្នុងនាមជាអ្នកសង្កេតការណ៍ ហើយអង្គការទាំងនេះមានបុព្វសិទ្ធិសម្រេចកំណត់បុគ្គលតំណាងខ្លួន។

ក្រោយពេលទទួលបានសិទ្ធិចូលរួមក្នុងនាមអ្នកសង្កេតការណ៍ អង្គការ NGOs ក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សា ECOSOC ទទួលបានបុព្វសិទ្ធិ និងការរៀបចំនៅក្រុមប្រឹក្សាសិទ្ធិមនុស្ស។ អង្គការទាំងនេះអាចៈ

- ដាក់សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរជូនក្រុមប្រឹក្សាសិទ្ធិមនុស្សនៅមុនសម័យប្រជុំនីមួយៗ
- ធ្វើបទអន្តរាគមន៍ផ្ទាល់មាត់នៅក្នុងអំឡុងពេលនៃរបៀបវារៈដ៏សំខាន់ៗនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស
- ចូលរួមនៅក្នុងការជជែកវែកញែក កិច្ចសន្ទនាឆ្លើយឆ្លង និងកិច្ចពិភាក្សាវាគ្មិន និង
- រៀបចំ "ព្រឹត្តិការណ៍អម" លើបញ្ហានានាពាក់ព័ន្ធនឹងការងាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។

ទោះក្នុងពេលណាក៏ដោយ អង្គការ NGOs ក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សា ECOSOC ក៏ទទួលខុសត្រូវត្រូវគោរពតាមគោលការណ៍នានាដែលចែងអំពីការបង្កើត និងប្រភេទនៃទំនាក់ទំនងក្នុងឋានៈពិគ្រោះយោបល់។ ជាពិសេស សេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សា ECOSOC

លេខ ១៩៩៦/៣១ ចែងថា អង្គការ NGO អាចត្រូវបានព្យួរ ឬ ដកចេញពីការចូលរួមនៅក្នុងកិច្ចប្រជុំរបស់អង្គការសហប្រជាជាតិ ឬ ដកឋានៈពិគ្រោះយោបល់ក្នុងករណីដែលអង្គការនេះ (រួមទាំងសម្ព័ន្ធអង្គការ និងតំណាងអង្គការបំពេញការងារឲ្យខ្លួន) បំពានជាក់ស្តែងលើឋានៈរបស់ខ្លួនដោយចូលរួមនៅក្នុងសកម្មភាពនានាផ្ទុយនឹងគោលបំណង និងគោលការណ៍នៃធម្មនុញ្ញអង្គការសហប្រជាជាតិ។

សិទ្ធិចូលរួមប្រជុំ

តំណាងអង្គការ NGOs ក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សា ECOSOC គួរស្នើសុំសិទ្ធិចូលរួមក្នុងសម័យប្រជុំក្រុមប្រឹក្សាសិទ្ធិមនុស្សដែលពួកគេមានបំណងចង់ចូលរួម។

លិខិតស្នើសុំសិទ្ធិចូលរួមប្រជុំគួរ៖

- សរសេរក្នុងទម្រង់ផ្លូវការរបស់អង្គការដោយមានក្បាលទំព័រត្រឹមត្រូវ
- លើកឡើងឲ្យបានច្បាស់លាស់អំពីប្រធានបទប្រជុំ និងរយៈពេលប្រជុំដែលអង្គការមានបំណងចូលរួម
- ចុះហត្ថលេខាដោយប្រធាន ឬ ប្រធានតំណាងនៃអង្គការនៅទីក្រុងហ្សឺណែវ
- បញ្ជាក់ឈ្មោះបុគ្គលដែលនឹងតំណាងអង្គការនៅក្នុងសម័យប្រជុំក្រុមប្រឹក្សាសិទ្ធិមនុស្ស។ ចូរកត់សម្គាល់ថា ឈ្មោះបុគ្គលត្រូវសរសេរឲ្យបានច្បាស់ទៅតាមឈ្មោះនៅក្នុងឯកសារអត្តសញ្ញាណ និងនាមត្រកូលគួរសរសេរជាអក្សរធំ។

i. ដើម្បីទទួលបានសិទ្ធិចូលរួមប្រជុំ អង្គការ NGOs ក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សា ECOSOC គួរផ្ញើលិខិតតាមទូរសារនៅមុនសម័យប្រជុំណាមួយប្រសិនបើអាចធ្វើទៅបានដើម្បីស្នើសុំសិទ្ធិចូលរួមប្រជុំតាមរយៈ៖

**ទូរសារ: +41(0)22 917 9011**

## សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍

នៅមុនសម័យប្រជុំនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស អង្គការ NGOs ក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សា ECOSOC អាចដាក់សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរជូនក្រុមប្រឹក្សាសិទ្ធិមនុស្សជាលក្ខណៈបុគ្គល ឬ រួមគ្នាជាមួយនឹងអង្គការ NGOs ផ្សេងទៀត។ សេចក្តីថ្លែងការណ៍ទាំងនេះត្រូវបង្ហាញប្រធានបទដែលអង្គការ NGOs មានសមត្ថភាពពិសេស។ នៅក្រោយពេលទទួលបាន និងចាត់ចែងសេចក្តីថ្លែងការណ៍ទាំងនេះដោយលេខាធិការដ្ឋាននៃក្រុមប្រឹក្សាសិទ្ធិមនុស្សរួចរាល់ហើយ សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍របស់អង្គការ NGOs ក្លាយជាផ្នែកមួយនៃឯកសារផ្លូវការនៃសម័យប្រជុំក្រុមប្រឹក្សាសិទ្ធិមនុស្ស។

សូមកត់សម្គាល់ថា៖

- អង្គការ NGOs **ក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សា** ECOSOC អាចដាក់សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរមិនឲ្យលើសពី ២០០០ ពាក្យ និង
- អង្គការ NGOs **ក្នុងឋានៈពិគ្រោះយោបល់ពិសេសជាមួយនឹងក្រុមប្រឹក្សា** ECOSOC ឬនៅក្នុង**បញ្ជីសមាជិកត្រៀមផ្លាស់ប្តូរ**អាចដាក់សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរមិនឲ្យលើសពី ១៥០០ ពាក្យ

i. អង្គការ NGOs ត្រូវបានលើកទឹកចិត្តឲ្យមើល**កំណត់ត្រាព័ត៌មានទូទៅ**ដែលអាចរកបាននៅក្នុងផ្នែកក្រុមប្រឹក្សាសិទ្ធិមនុស្សនៅលើគេហទំព័រនៃការិយាល័យ OHCHR។

**សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរគួរដាក់ជូនលេខាធិការដ្ឋាននៃក្រុមប្រឹក្សាសិទ្ធិមនុស្ស** តាមរយៈ៖ hrcngo@ohchr.org។

## សេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់

អង្គការ NGOs ក្នុងឋានៈពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សា ECOSOC អាចធ្វើកិច្ចអន្តរាគមន៍ដោយផ្ទាល់មាត់នៅក្នុងអំឡុងពេលនៃរបៀបវារៈសំខាន់ៗទាំងនៅក្នុងកិច្ចពិភាក្សាវែកញែកទូទៅ និងនៅក្នុងកិច្ចសន្ទនាឆ្លើយឆ្លងនៅក្នុងសម័យប្រជុំក្រុមប្រឹក្សាសិទ្ធិមនុស្ស។ គម្រូបែបបទសម្រាប់កិច្ចអន្តរាគមន៍ដោយផ្ទាល់មាត់របស់អង្គការ NGO ដែលបន្តវិវឌ្ឍដោយសារ ក្រុមប្រឹក្សាសិទ្ធិមនុស្សបន្តជួបប្រជុំពេញមួយឆ្នាំអាចរកមើលបានតាមរយៈប្រព័ន្ធ Extranet នៃក្រុមប្រឹក្សាសិទ្ធិមនុស្សក្រោមទំព័រស្តីពីព័ត៌មានទំនាក់អង្គការ NGOs។

តំណាងអង្គការ NGOs ដែលមានបំណងធ្វើកិច្ចអន្តរាគមន៍ដោយផ្ទាល់មាត់គួរចុះឈ្មោះដោយផ្ទាល់នៅបញ្ជរ "បញ្ជីឈ្មោះវាគ្មិន" នៅក្នុងបន្ទប់ប្រជុំ (កិច្ចប្រជុំពេញអង្គ)។ ទម្រង់បែបបទចុះឈ្មោះធ្វើសេចក្តីថ្លែងការណ៍ជាលក្ខណៈបុគ្គល និងសេចក្តីថ្លែងការណ៍រួមអាចទាញយកបានពី**គេហទំព័រដើម**នៃក្រុមប្រឹក្សាសិទ្ធិមនុស្ស និងគួរយកទៅកាន់បញ្ជរនោះដោយផ្ទាល់នៅពេលចុះឈ្មោះ។

**សូមកត់សម្គាល់ថា អង្គការ NGOs ពុំត្រូវបានអនុញ្ញាតឲ្យចែកចាយឯកសារ បណ្ណផ្សព្វផ្សាយ ឬសម្ភារៈឯកសារផ្សេងៗនៅក្នុងបន្ទប់កិច្ចប្រជុំពេញអង្គនោះទេ។** ក៏ប៉ុន្តែ សំណៅចតចម្លងនៃសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់ដែលអង្គការ NGOs នឹងឡើងថ្លែងអាចដាក់នៅតុខាងក្រោយក្នុងបន្ទប់កិច្ចប្រជុំពេញអង្គ។ ឯកសារទាំងអស់របស់អង្គការ NGOs អាចដាក់នៅតាមតុដែលកំណត់សម្រាប់អង្គការ NGOs នៅក្រៅបន្ទប់កិច្ចប្រជុំពេញអង្គ។

## ព្រឹត្តិការណ៍អម

អង្គការ NGOs ក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សា ECOSOC នៅពេលទទួលបានសិទ្ធិចូលរួមសម័យប្រជុំនៃក្រុមប្រឹក្សាសិទ្ធិមនុស្សអាចរៀបចំព្រឹត្តិការណ៍ជាសាធារណៈដែលពាក់

ព័ន្ធនឹងការងារនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស។ ព្រឹត្តិការណ៍ទាំងនេះហៅថា "ព្រឹត្តិការណ៍អម" ដែលនឹងធ្វើឡើងនៅចុងម៉ោងប្រជុំ ជាធម្មតា នៅក្នុងពេលសម្រាកអាហារថ្ងៃត្រង់។

ជាធម្មតា ព្រឹត្តិការណ៍អមរួមបញ្ចូលបទបង្ហាញរបស់វាគ្មិនជាមួយនឹងការពិភាក្សាទូទៅផ្តល់ឱកាសឲ្យអង្គការ NGO ចែករំលែកបទពិសោធន៍ និងចូលរួមនៅក្នុងកិច្ចសន្ទនាជាមួយនឹងអង្គការ NGOs រដ្ឋ និងភាគីពាក់ព័ន្ធផ្សេងទៀត (រួមទាំងមន្ត្រីកាន់កាប់អាណត្តិការងារនៃយន្តការនីតិវិធីពិសេស) ទទួលបន្ទុកសិទ្ធិមនុស្ស និងស្ថានភាពពាក់ព័ន្ធ និងបញ្ហាសំខាន់ចំពោះក្រុមប្រឹក្សាសិទ្ធិមនុស្ស។

បន្ទប់ត្រូវបានផ្តល់ជូនដោយមិនគិតថ្លៃសម្រាប់រៀបចំព្រឹត្តិការណ៍អម ហើយការកក់បន្ទប់ត្រូវផ្តល់ជូនទៅតាមគោលការណ៍ "មកមុនបានមុន"។ អង្គការ NGOs ដែលមានបំណងចូលរួមឧបត្ថម្ភព្រឹត្តិការណ៍អមគួរបំពេញ "ទម្រង់បែបបទស្តីពីការចូលរួមឧបត្ថម្ភ"[78]។

អង្គការ NGOs ដែលរៀបចំព្រឹត្តិការណ៍អមអាចអញ្ជើញបុគ្គលដែលពុំបានទទួលសិទ្ធិចូលរួមសម័យប្រជុំក្រុមប្រឹក្សាសិទ្ធិមនុស្សឲ្យចូលរួមព្រឹត្តិការណ៍អមនេះបាន។ បញ្ជីឈ្មោះអ្នកចូលរួមត្រូវផ្តល់ជូនលេខាធិការដ្ឋាននៃក្រុមប្រឹក្សាសិទ្ធិមនុស្ស និងការិយាល័យសន្តិសុខ Pregny ២៤ ម៉ោងនៅមុនពេលព្រឹត្តិការណ៍ដើម្បីអាចរៀបចំសិទ្ធិប្រគល់ជូនអ្នកចូលរួមដែលត្រឹមតែមានសិទ្ធិចូលរួមព្រឹត្តិការណ៍អមនេះតែប៉ុណ្ណោះ។

អង្គការ NGOs ដែលរៀបចំព្រឹត្តិការណ៍អមត្រូវទទួលខុសត្រូវលើខ្លឹមសារ និងទង្វើរបស់អ្នកចូលរួមនៅក្នុងព្រឹត្តិការណ៍នេះ។ សូមកត់សម្គាល់ថា៖

- លេខាធិការដ្ឋានពុំផ្តល់សេវាបកប្រែផ្ទាល់មាត់ជូនព្រឹត្តិការណ៍អមរបស់អង្គការ NGOs នោះឡើយ។ អង្គការ NGOs អាចយកអ្នកបកប្រែផ្ទាល់មាត់របស់ខ្លួនមកជាមួយប្រសិនបើខ្លួនមានបំណងធ្វើដូច្នេះ ហើយគួរជូនដំណឹងដល់លេខាធិការដ្ឋានលើបញ្ហានេះជាមុន និង
- ការប្រើប្រាស់ម៉ាស៊ីនថតរូបភាព និងវីដេអូនៅក្នុងព្រឹត្តិការណ៍អមនេះពុំលើកទឹកចិត្តឲ្យប្រើប្រាស់នោះទេលើកលែងតែសម្រាប់អ្នកកាសែត និងបុគ្គលិកទទួលសិទ្ធិថតនៅក្នុងការិយាល័យនៃអង្គការសហប្រជាជាតិក្នុងទីក្រុងហ្សឺណែវ (ការិយាល័យ UNOG)។

i. ការកក់បន្ទប់សម្រាប់រៀបចំ**ព្រឹត្តិការណ៍អម**គួរបញ្ជូនតាមរយៈទូរសារទៅកាន់៖

ទូរសារ: +41 (0) 22 917 9011។

សម្រាប់ព័ត៌មានបច្ចុប្បន្នស្តីពី**សិទ្ធិចូលរួម សេចក្តីថ្លែងជាលាយលក្ខណ៍អក្សរ សេចក្តីថ្លែងការណ៍ផ្ទាល់មាត់ និងព្រឹត្តិការណ៍អម** សូមចូលទៅកាន់ទំព័រព័ត៌មានទំនាក់ទំនងរបស់អង្គការ NGO ក្នុងប្រព័ន្ធ Extranet។

---

[78] អាចរកមើលបាននៅលើគេហទំព័រនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស។

## ការចូលរួមនៅក្នុង និងជាមួយនឹងអាណត្តិការងារ និងយន្តការ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស

### ក. យន្តការពិនិត្យរបាយការណ៍ជាសាកលតាមកាលកំណត់

i. សម្រាប់ព័ត៌មានលម្អិតស្តីពីរបៀបទាក់ទង និងធ្វើការងារជាមួយនឹង**យន្តការពិនិត្យរបាយការណ៍ជាសាកលតាមកាលកំណត់** សូមមើលជំពូក VII (**យន្តការពិនិត្យរបាយការណ៍ជាសាកលតាមកាលកំណត់**) នៅក្នុង*សៀវភៅណែនាំ*។

### ខ. គណកម្មាធិការប្រឹក្សាយោបល់របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស

#### *វត្តមាន និងការចូលរួមចំណែកក្នុងការងារនៃគណកម្មាធិការប្រឹក្សាយោបល់*

បុព្វការីនៃគណកម្មាធិការប្រឹក្សាយោបល់ ពោលគឺ អតីតអនុគណកម្មការបានទទួលប្រយោជន៍យ៉ាងច្រើនពីការចូលរួមរបស់អង្គការ NGOs ក្នុងឋានៈពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សា ECOSOC។ គិតមកត្រឹមខែកញ្ញា ឆ្នាំ២០០៨ ទោះបីជាគណកម្មាធិការប្រឹក្សាយោបល់នៅកំពុងបង្កើតវិធាននីតិវិធី និងវិធីធ្វើការងាររបស់ខ្លួនក៏ដោយ ដើម្បីបំពេញអាណត្តិរបស់ខ្លួន ក្រុមប្រឹក្សាសិទ្ធិមនុស្សបានជម្រុញឲ្យគណកម្មាធិការប្រឹក្សាយោបល់ធ្វើការទាក់ទងគ្នាជាមួយនឹងអង្គការ NGOs និងតួអង្គសង្គមស៊ីវិលផ្សេងទៀត។ រដ្ឋក៏ត្រូវបានលើកទឹកចិត្តឲ្យពិគ្រោះយោបល់ជាមួយនឹងតួអង្គសង្គមស៊ីវិលនៅមុនពេលជ្រើសតាំងបេក្ខជនដើម្បីតែងតាំងសម្រាប់គណកម្មាធិការប្រឹក្សាយោបល់។

អង្គការ NGOs មានសិទ្ធិចូលរួមនៅក្នុងការងារនៃគណកម្មាធិការប្រឹក្សាយោបល់ដោយផ្អែកលើការរៀបចំ និងទម្លាប់អនុវត្តដែលត្រូវបានគោរពតាំងពីដើមមកដោយគណកម្មការសិទ្ធិមនុស្ស និងក្រុមប្រឹក្សាសិទ្ធិមនុស្ស រួមទាំង សេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សា ECOSOC លេខ ១៩៩៦/៣១ ផងដែរដោយត្រូវធ្វើយ៉ាងណាឲ្យការចូលរួមចំណែករបស់អង្គការ NGO មានប្រសិទ្ធភាព ពបំផុត។

អង្គការ NGOs ដែលចាប់អារម្មណ៍ចូលរួមក្នុងនាមជាអ្នកសង្កេតការណ៍នៅក្នុងសម័យប្រជុំនៃគណកម្មាធិការប្រឹក្សាយោបល់គួរទាក់ទងលេខាធិការដ្ឋាន។

i. សម្រាប់ព័ត៌មានបន្ថែមស្តីពីរបៀបចូលរួមចំណែកនៅក្នុងការងារនៃ**គណកម្មាធិការប្រឹក្សាយោបល់** សូមទាក់ទង៖

HRCAdvisoryCommittee@ohchr.org

### គ. នីតិវិធីបណ្តឹង

i. សម្រាប់ព័ត៌មានលម្អិតស្តីពីរបៀបចែករំលែកព័ត៌មានអំពី**នីតិវិធីបណ្តឹង** សូមអានជំពូក VIII **(ការដាក់បណ្តឹងចោទប្រកាន់ការរំលោភសិទ្ធិមនុស្ស)** នៅក្នុង*សៀវភៅណែនាំ*នេះ។ សូមទាក់ទង CP@ohchr.org។

## ឃ. នីតិវិធីពិសេស

i. សម្រាប់ព័ត៌មានលម្អិតស្តីពីរបៀបទាក់ទង និងចូលរួមជាមួយនឹង**យន្តការតិវិធីពិសេស** សូមអាន **ជំពូក VI (យន្តការនីតិវិធីពិសេស)** នៅក្នុង*សៀវភៅណែនាំ*នេះ។

## ង. ក្រុមការងារនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស

## ក្រុមការងារទូទៅទទួលបន្ទុកលើសិទ្ធិទទួលបានការអភិវឌ្ឍ

### *ការចូលរួមនៅក្នុងសម័យប្រជុំនៃក្រុមការងារ*

ដោយសារក្រុមការងារនេះជាក្រុមទូទៅ អង្គការ NGOs ក្នុងឋានៈពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សា ECOSOC អាចចូលរួមនៅក្នុងវគ្គសម័យប្រជុំជាសាធារណៈ។

អង្គការ NGOs ដែលចូលរួមកិច្ចប្រជុំនៃ**ក្រុមការងារជាន់ខ្ពស់ទទួលបន្ទុកការអនុវត្តសិទ្ធិទទួលបានការអភិវឌ្ឍ**មានឱកាសធ្វើសេចក្តីថ្លែងការណ៍ទូទៅបាន។

i. អង្គការ NGOs ក្នុងឋានៈពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សា ECOSOC ដែលចាប់អារម្មណ៍ចូលរួមនៅក្នុង**ក្រុមការងារ** ឬ **ក្រុមការងារជាន់ខ្ពស់**គួរបំពេញ**ទម្រង់បែបបទចុះឈ្មោះ** (ដែលអាចរកបានពីទំព័រនៅលើគេហទំព័រនៃការិយាល័យ OHCHR) និងបញ្ជូនទម្រង់បែបបទពាក្យសុំនេះរួមគ្នាជាមួយនឹងសំណើសុំសិទ្ធិចូលរួមដែលមានចុះហត្ថលេខាត្រឹមត្រូវមកកាន់៖

**មន្ត្រីទទួលបន្ទុកលើសិទ្ធិចូលរួមប្រជុំ**

ទូរសារ: +41 (0)22 928 9010

ទូរស័ព្ទ: +41 (0)22 928 9829

### *ការចូលរួមចំណែកនៅក្នុងការងារនៃក្រុមការងារ*

ការងារសំខាន់មួយដែលប្រគល់ជូនក្រុមការងារគឺសើរើរបាយការណ៍ និងព័ត៌មានផ្សេងទៀតដែលបានដាក់ជូនដោយអង្គការ NGOs ស្តីពីទំនាក់ទំនងរវាងសកម្មភាពនៃអង្គការ NGOs និងសិទ្ធិទទួលបានការអភិវឌ្ឍ។ ក្រុមការងារស្វាគមន៍ការចូលរួមចំណែករបស់អង្គការ NGOs និងតួអង្គសង្គមស៊ីវិលផ្សេងទៀតដែលជួយសម្រួលមួយផ្នែកដោយការងារនៃក្រុមការងារជាន់ខ្ពស់។ សម័យប្រជុំជាសាធារណៈរបស់ក្រុមងារងារជាន់ខ្ពស់នេះទូទៅជូនតួអង្គសង្គមស៊ីវិល និងអង្គការ NGOs ពីគ្រប់វិស័យចូលរួម។

អង្គការ NGOs និងតួអង្គសង្គមស៊ីវិលផ្សេងទៀតត្រូវបានលើកទឹកចិត្តឲ្យដាក់សេចក្ដីថ្លែងការណ៍ និងចូលរួមជាមួយនឹងសកម្មភាពនៃក្រុមការងារ ផែនការការងារ និងការអនុវត្តអនុសាសន៍នៃក្រុមការងារ។

## ច. វេទិកាសង្គម

### *ការចូលរួមនៅក្នុងកិច្ចប្រជុំនៃវេទិកាសង្គម*

វេទិកាសង្គមបើកចំហឲ្យភាគីពាក់ព័ន្ធចូលរួមរួមទាំង[79]៖

- អង្គការអន្តររដ្ឋាភិបាល
- សមាសភាពផ្សេងៗគ្នានៃប្រព័ន្ធអង្គការសហប្រជាជាតិ ជាពិសេស មន្ត្រីកាន់កាប់អាណត្តិការងារនៃយន្តការនីតិវិធីទទួលបន្ទុកតាមវិស័យ និងយន្តការសិទ្ធិមនុស្ស
- គណកម្មការសេដ្ឋកិច្ចតំបន់
- ភ្នាក់ជំនាញ និងអង្គការនានា ជាពិសេស កម្មវិធីអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ (អង្គការ UNDP) ធនាគារពិភពលោក មូលនិធិរូបិយវត្ថុអន្តរជាតិ និងអង្គការពាណិជ្ជកម្មពិភពលោក
- តំណាងដែលកំណត់ដោយស្ថាប័ន NHRIs និអង្គការ NGOs ក្នុងឋានៈពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សា ECOSOC និង
- អង្គការ NGOs ផ្សេងទៀត ជាពិសេស តួអង្គដែលទើបលេចឡើងថ្មីៗដូចជាក្រុមតូចៗ និងសមាគមតាមទីក្រុង និងជនបទពីប៉ូលខាងជើង និងខាងត្បូង ក្រុមប្រឆាំងភាពក្រីក្រ អង្គការកសិករ និងអ្នកចម្ការ និងសមាគមជាតិ និងអន្តរជាតិ អង្គការស្ម័គ្រចិត្ត សមាគមយុវជន អង្គការសហគមន៍ សហជីព និងសមាគមកម្មករនិយោជិត ព្រមទាំងតំណាងវិស័យឯកជន ធនាគារតំបន់ និងស្ថាប័នហិរញ្ញវត្ថុ និងភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ។

ការចូលរួមរបស់តួអង្គសង្គមស៊ីវិលនៅក្នុងវេទិកាសង្គមបានផ្អែកលើការរៀបចំ រួមទាំង សេចក្ដីសម្រេចចិត្តរបស់ក្រុមប្រឹក្សា ECOSOC លេខ ១៩៩៦/៣១ និងបទដ្ឋានអនុវត្តដែលបានគោរពជាយូរមកហើយដោយគណកម្មការសិទ្ធិមនុស្សខណៈត្រូវធានាឲ្យអង្គភាពដូចបានរៀបរាប់ខាងលើចូលរួមចំណែកឲ្យមានប្រសិទ្ធភាពបំផុត។ ក្រុមប្រឹក្សាសិទ្ធិមនុស្សបានស្នើសុំការិយាល័យ OHCHR ឲ្យស្វែងរកមធ្យោបាយដ៏មានប្រសិទ្ធភាពដើម្បីធានានូវកិច្ចពិគ្រោះយោបល់ និងការចូលរួមនៅក្នុងវេទិកាសង្គមឲ្យបានទូលំទូលាយបំផុតពីតំណាងគ្រប់តំបន់ជាពិសេសបុគ្គលដែលមកពីបណ្ដាប្រទេសកំពុងអភិវឌ្ឍ

[79] សូមមើលសេចក្ដីសម្រេចនៃក្រុមប្រឹក្សាលេខ ៦/១៣។

ដោយរួមបញ្ចូលទាំងតាមរយៈការបង្កើតភាពជាដៃគូជាមួយនឹងអង្គការ NGO វិស័យឯកជន និងអង្គការអន្តរជាតិ[80]។

i. តួអង្គសង្គមស៊ីវិលដែលចាប់អារម្មណ៍ចង់ចូលរួមនៅក្នុង**វេទិកាសង្គម**គួរទាក់ទងលេខាធិការដ្ឋាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

socialforum@ohchr.org

## ឆ. វេទិកាស្តីពីបញ្ហាជនជាតិភាគតិច

### *ការចូលរួមនៅក្នុងកិច្ចប្រជុំនៃវេទិកាស្តីពីបញ្ហាជនជាតិភាគតិច*

វេទិកាស្តីពីបញ្ហាជនជាតិភាគតិចបើកចំហឲ្យអង្គការ NGOs ចូលរួមក្នុងឋានៈពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សា ECOSOC និងអង្គការ NGOs ផ្សេងទៀតដែលមានគោលបំណង ស្របជាមួយនឹងស្មារតី គោលបំណង និងគោលការណ៍នៃរដ្ឋធម្មនុញ្ញអង្គការសហប្រជាជាតិ។ ការចូលរួមនេះក៏បើកចំហឲ្យតួអង្គសង្គមស៊ីវិលផ្សេងទៀតចូលរួមផងដែរ រួមទាំង អ្នកសិក្សាស្រាវជ្រាវ និងអ្នកជំនាញស្តីពីបញ្ហាជនជាតិភាគតិច។

i. តួអង្គសង្គមស៊ីវិលដែលចាប់អារម្មណ៍ចង់ចូលរួម ឬ ចែករំលែកលើការងារនៃ**វេទិកាស្តីពីបញ្ហាជនជាតិភាគតិច**គួរទាក់ទងលេខាធិការដ្ឋាន។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖ minorityforum@ohchr.org

### *ការជ្រើសតាំងបេក្ខជនដើម្បីតែងតាំងជាប្រធានវេទិកា*

អនុលោមតាមសេចក្តីសម្រេចចិត្តនៃក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៥/១ អង្គការ NGOs ក្នុងឋានៈពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សា ECOSOC និងអ្នកសង្កេតការណ៍នៃក្រុមប្រឹក្សាសិទ្ធិមនុស្សរួមជាមួយនឹងរដ្ឋសមាជិកក៏អាចស្នើបេក្ខជនសម្រាប់តែងតាំងជាប្រធាននៃវេទិកាស្តីពីបញ្ហាជនជាតិភាគតិច។

## ជ. យន្តការអ្នកជំនាញទទួលបន្ទុកលើសិទ្ធិជនជាតិដើមភាគតិច

### *ការចូលរួមនៅក្នុងកិច្ចប្រជុំនៃយន្តការអ្នកជំនាញ*

កិច្ចប្រជុំប្រចាំឆ្នាំនៃយន្តការអ្នកជំនាញទូទៅឲ្យតួអង្គសង្គមស៊ីវិលចូលរួម រួមទាំង អង្គការ NGOs និងអង្គការជនជាតិដើមភាគតិចផងដែរ។

### *មូលនិធិស្ម័គ្រចិត្តសម្រាប់ជនជាតិដើមភាគតិច*

[80] សូមមើលសេចក្តីសម្រេចលេខ ៦/១៣។

តួអង្គសង្គមស៊ីវិលគួរដឹងអំពី**មូលនិធិស្ម័គ្រចិត្តសម្រាប់ជនជាតិដើមភាគតិច**ដែលបានបង្កើតឡើងដើម្បីជួយជ្រោមជ្រែងផ្នែកហិរញ្ញវត្ថុដល់តំណាងសហគមន៍ជនជាតិដើមភាគតិច និងអង្គការនានាដើម្បីអាចចូលរួមនៅក្នុងយន្តការអ្នកជំនាញ និងវេទិកាអចិន្ត្រៃយ៍ស្តីពីបញ្ហាជនជាតិដើមភាគតិច។

i. តួអង្គសង្គមស៊ីវិលដែលចាប់អារម្មណ៍ចង់ចូលរួម ឬ ចែករំលែកលើការងារនៃ**យន្តការអ្នកជំនាញ** គួរទាក់ទងលេខាធិការដ្ឋាន៖

expertmechanism@ohchr.org

ដើម្បីស្វែងយល់បន្ថែមអំពី**មូលនិធិស្ម័គ្រចិត្តសម្រាប់ជនជាតិដើមភាគតិច** រួមទាំង លក្ខខណ្ឌសម្រាប់ជ្រើសរើសសិទ្ធិវ័ន្ត សូមអានជំពូក IX (**មូលនិធិ និងជំនួយឥតសំណង**) នៅក្នុង*សៀវភៅណែនាំ*នេះ។

## *ការជ្រើសតាំងបេក្ខជនដើម្បីតែងតាំងចូលក្នុងយន្តការអ្នកជំនាញ*

ដើម្បីឲ្យស្របតាមសេចក្តីសម្រេចចិត្តនៃក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៥/១ អង្គការ NGOs និងអង្គការសិទ្ធិមនុស្សផ្សេងទៀតអាចជ្រើសតាំងបេក្ខជនដើម្បីតែងតាំងជាអ្នកជំនាញឯករាជ្យចូលក្នុងយន្តការអ្នកជំនាញ។ បុគ្គលទាំងឡាយក៏អាចជ្រើសតាំងខ្លួនឯងជាបេក្ខជនផងដែរ។

លក្ខណៈវិនិច្ឆ័យសម្រាប់តែងតាំងជាអ្នកជំនាញឯករាជ្យរួមមានដូចជាជំនាញ បទពិសោធន៍ក្នុងវិស័យអាណត្តិការងារ ឯករាជ្យភាព អព្យាក្រឹត្យភាព សេចក្តីថ្លៃថ្នូរបុគ្គល និងភាពមិនលម្អៀង។ ការពិចារណាផ្សេងទៀតរួមមានតុល្យភាពយែនឌ័រ តំណាងភូមិសាស្ត្រស្មើគ្នា និងតំណាងសមស្របនៃប្រព័ន្ធច្បាប់ខុសៗគ្នា។

i. ដើម្បីស្វែងយល់បន្ថែមអំពីរបៀប**ជ្រើសតាំងបេក្ខជន** និងរបៀបតែងតាំង **សូមទាក់ទងលេខាធិការដ្ឋាននៃក្រុមប្រឹក្សាសិទ្ធិមនុស្ស**។

អ៊ីមែល: hrcexpertmechanism@ohchr.org

ទូរសារ: +41 (0)22 917 9011

ទូរស័ព្ទ: +41 (0)22 917 9223

## I. សេចក្តីប្រកាស និងផែនការសម្មភាពក្រុង Durban

i. សម្រាប់ព័ត៌មានអំពីរបៀបចូលរួម និងចែករំលែកនៅក្នុងការងារនៃ**យន្តការក្រុមប្រឹក្សាសិទ្ធិមនុស្សទាក់ទងនឹងសន្និសីទពិភពលោកនៅក្រុង** Durban សូមទាក់ទង៖

អង្គភាពប្រឆាំងនឹងការរើសអើង

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

8–14, avenue de la Paix

CH–1211 ទីក្រុងហ្សឺណែវ 10, ប្រទេសស្វីស
អ៊ីមែល: adusecretariat@ohchr.org
ទូរស័ព្ទ: +41 (0)22 928 92 08
ទូរសារ: +41 (0)22 928 90 50

## ១. ក្រុមការងារអន្តររដ្ឋាភិបាលទទួលបន្ទុកលើការអនុវត្តប្រកបដោយប្រសិទ្ធភាពលើសេចក្តីប្រកាស និងផែនការសកម្មភាពក្រុង Durban

ដោយសារក្រុមការងារគឺជាក្រុមការងារទូទៅ អង្គការ NGOs ក្នុងឋានៈពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សា ECOSOC និងអង្គការ NGOs ផ្សេងទៀតដែលបានទទួលសិទ្ធិចូលរួមសន្និសីទពិភពលោក អាចចូលរួមកិច្ចប្រជុំជាសាធារណៈបាន។ អង្គការ NGOs ដែលបានចូលរួមកិច្ចប្រជុំមានឱកាសធ្វើសេចក្តីថ្លែងការណ៍ផ្ទាល់មាត់ និងអាចដាក់សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរបាន។

## ២. ក្រុមអ្នកជំនាញឯករាជ្យល្បីៗ

អង្គការ NGOs ដែលចាប់អារម្មណ៍ចង់ដាក់របាយការណ៍ជូនក្រុមអ្នកជំនាញល្បីៗគួរទាក់ទង **អង្គភាពប្រឆាំងនឹងការរើសអើងនៃការិយាល័យ OHCHR។**

## ២. ក្រុមការងារនៃអ្នកជំនាញទទួលបន្ទុកលើជនជាតិភាគតិចអាហ្វ្រិក

អង្គការ NGOs ក្នុងឋានៈពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សា ECOSOC និងអង្គការ NGOs ដែលទទួលបានសិទ្ធិចូលរួមសន្និសីទពិភពលោកអាចចូលរួមនៅក្នុងសម័យប្រជុំនៃក្រុមការងារនេះបាន។ អង្គការ NGOs ដែលចូលរួមសម័យប្រជុំមានឱកាសដាក់សេចក្តីប្រកាសជាលាយលក្ខណ៍អក្សរ និងធ្វើបទបង្ហាញដោយផ្ទាល់មាត់។

i. សម្រាប់ព័ត៌មានបច្ចុប្បន្នស្តីពីការចូលរួមនៅក្នុងក្រុមការងារនេះ សូមចូលទៅកាន់គេហទំព័រនៃការិយាល័យ OHCHR។

អង្គការ NGOs និងតួអង្គសង្គមស៊ីវិលផ្សេងទៀតក៏ត្រូវបានអញ្ជើញឲ្យផ្តល់ព័ត៌មាន និងរបាយការណ៍ជូនក្រុមការងារដើម្បីអាចឲ្យក្រុមការងារបំពេញអាណត្តិការងាររបស់ខ្លួនបាន។ អង្គការ NGOs និងតួអង្គសង្គមស៊ីវិលផ្សេងទៀតអាចសហការជាមួយនឹងក្រុមការងារនេះនៅពេលចុះទស្សនកិច្ចដល់ទីកន្លែងតាមរយៈការផ្តល់ព័ត៌មាននៅតាមទីន្លែងនោះតែម្តង និងរៀបចំឲ្យមានតំណាងជជែកជាមួយនឹងសមាជិកក្រុមការងារ។

## ៤. គណកម្មាធិការ*អាដហុក*ទទួលបន្ទុកពន្យល់បកស្រាយលើបទដ្ឋានបំពេញបន្ថែម

អង្គការ NGOs ក្នុងឋានៈពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សា ECOSOC និងតួអង្គសង្គមស៊ីវិលផ្សេងទៀតដែលទទួលបានសិទ្ធិចូលរួមសន្និសីទពិភពលោកអាចចូលរួមកិច្ចប្រជុំជាសាធារណៈដែលក្រុមការងារបានរៀបចំឡើង ហើយក៏មានឱកាសធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់ផងដែរ។

តួអង្គសង្គមស៊ីវិលត្រូវបានអញ្ជើញឲ្យចែករំលែកព័ត៌មាន និងការសិក្សានានាជូនដល់គណកម្មាធិការ*អាដហុក*។ ប្រសិនបើចាប់អារម្មណ៍ តួអង្គសង្គមស៊ីវិលគួរទាក់ទង**អង្គភាពប្រឆាំងនឹងការរើសអើងនៃការិយាល័យ OHCHR**។

## ៥. គណកម្មាធិការត្រៀមរៀបចំសន្និសីទសើរើសេចក្តីប្រកាសក្រុង Durban និងក្រុមការងារអន្តររដ្ឋាភិបាលទូទៅនៃអន្តរសម័យប្រជុំទទួលបន្ទុកបន្តតាមដានការងារគណកម្មាធិការត្រៀមរៀបចំសន្និសីទសើរើសេចក្តីប្រកាសក្រុង Durban

គណកម្មាធិការត្រៀមរៀបចំ និងក្រុមការងារអន្តររដ្ឋាភិបាលទូទៅត្រូវបានបង្កើតឡើងដើម្បីត្រៀមរៀបចំសន្និសីទសើរើ។ លក្ខណៈវិនិច្ឆ័យ និងការរៀបចំខាងក្រោមត្រូវយកមកអនុវត្តចំពោះអង្គការ NGOs ដែលបានចូលរួមនៅក្នុងសម័យប្រជុំរបស់គណកម្មាធិការត្រៀមរៀបចំ។ អង្គការ NGOs ដែលបានទទួលសិទ្ធិចូលរួមនៅក្នុងសម័យប្រជុំទាំងនេះក៏អាចចូលរួមនៅក្នុងកិច្ចប្រជុំនៃក្រុមការងារអន្តររដ្ឋាភិបាលទូទៅ។

- អង្គការ NGOs ក្នុងឋានៈពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សា ECOSOC ត្រូវបានអញ្ជើញឲ្យចូលរួមពេញលេញនៅគ្រប់សម័យប្រជុំនៃគណកម្មាធិការរៀបចំអនុលោមតាមសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សា ECOSOC លេខ ១៩៩៦/៣១
- អង្គការ NGOs ដែលពុំមានឋានៈបែបនេះដែលបានទទួលសិទ្ធិចូលរួមនៅក្នុងសន្និសីទពិភពលោក ហើយនឹងនៅក្នុងយន្តការបន្តតាមដានត្រូវបានអញ្ជើញឲ្យចូលរួមពេញលេញនៅក្នុងសម័យប្រជុំលើកលែងតែរដ្ឋាភិបាលលើកបញ្ហាចោទនានាទាក់ទងនឹងសិទ្ធិចូលរួមប្រជុំរបស់ពួកគេ។ ប្រសិនបើមានការលើកបញ្ហាចោទអំពីសិទ្ធិចូលរួមប្រជុំរបស់អង្គការ NGO ណាមួយ អង្គការ NGO នោះត្រូវបានផ្តល់ឱកាសឲ្យឆ្លើយតប ហើយត្រូវរង់ចាំសេចក្តីសម្រេចចុងក្រោយពីគណកម្មាធិការត្រៀមរៀបចំស្របតាមដំណើរការបទដ្ឋានដែលបានបង្កើតឡើងនៅក្នុងសេចក្តីសម្រេចចិត្តលេខ ១៩៩៦/៣១

- អង្គការ NGOs ដែលពុំមានឋានៈពិគ្រោះយោបល់ ហើយពុំទទួលបានសិទ្ធិចូលរួមនៅក្នុងសន្និសីទពិភពលោក ហើយនឹងយន្តការបន្តតាមដានអាចដាក់ពាក្យសុំចូលរួមនៅសម័យប្រជុំនៃគណកម្មាធិការត្រៀមរៀបចំជូនលេខាធិការដ្ឋានបាន។ លេខាធិការដ្ឋាននឹងពិនិត្យមើលគ្រប់ពាក្យសុំទាំងអស់ដែលខ្លួនបានទទួលដើម្បីធានាថា ពាក្យសុំទាំងអស់នោះបានបំពេញតាមលក្ខខណ្ឌដែលបានបង្កើតឡើងនៅក្នុងសេចក្តីសម្រេចលេខ ១៩៩៦/៣១
- តំណាងជនជាតិដើមភាគតិចដែលបានទទួលសិទ្ធិចូលរួមប្រជុំស្របតាមសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សា ECOSOC លេខ ១៩៩៥/៣២ ដែលបង្ហាញឆន្ទៈចង់ចូលរួមសម័យប្រជុំរបស់គណកម្មាធិការត្រៀមរៀបចំនឹងទទួលបានសិទ្ធិចូលរួម។ តំណាងជនជាតិដើមភាគតិចដែលចាប់អារម្មណ៍ផ្សេងទៀតក៏អាចផ្តល់សិទ្ធិឲ្យចូលរួមផងដែរក្រោយពេលបំពេញបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងអនុលោមតាមសេចក្តីសម្រេចចិត្តលេខ ១៩៩៦/៣១ រួចរាល់

អង្គការ NGOs ដែលចូលរួមសម័យប្រជុំគណកម្មាធិការត្រៀមរៀបចំ និងក្រុមការងារអន្តររដ្ឋាភិបាលទូទៅមានឱកាសធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់ និងអាចដាក់សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរបាន។

អង្គការ NGOs ក្នុងឋានៈពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សា ECOSOC និងអ្នកទទួលបានសិទ្ធិចូលរួមសន្និសីទពិភពលោក និងយន្តការបន្តតាមដានរួមទាំងគណកម្មាធិការរៀបចំអាចចូលរួមនៅក្នុងសន្និសីទពិនិត្យសើរើ[81]។

អង្គការ NGOs ដែលពុំមានឋានៈបែបនេះ និងពុំទទួលបានសិទ្ធិចូលរួមសន្និសីទពិភពលោក និងយន្តការបន្តតាមដានត្រូវបានអញ្ជើញឲ្យដាក់ពាក្យសុំចូលរួមនៅក្នុងសន្និសីទពិនិត្យសើរើ។

[81] សូមមើល "របាយការណ៍នៃក្រុមប្រឹក្សាសិទ្ធិមនុស្សស្តីពីការរៀបចំសន្និសីទសើរើសេចក្តីប្រកាសក្រុង Durban: របាយការណ៍នៃគណកម្មាធិការត្រៀមរៀបចំនៅក្នុងសម័យប្រជុំលើកទី ១" (A/62/375 វិធាន ៦៦)។

## ធនធាននៃការិយាល័យ OHCHR

### គេហទំព័រនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស

តួអង្គសង្គមស៊ីវិលគួរមើលគេហទំព័រនៃក្រុមប្រឹក្សាសិទ្ធិមនុស្សដើម្បីទទួលបានព័ត៌មានបច្ចុប្បន្នភាព និងព័ត៌មានស្តីពីការចូលរួមនៅក្នុងសម័យប្រជុំនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស។ ជាធម្មតាព័ត៌មានជាក់លាក់ស្តីពីសម័យប្រជុំត្រូវបានដាក់នៅលើគេហទំព័រក្នុងរយៈពេល ២ សប្តាហ៍នៅមុនសម័យប្រជុំអចិន្ត្រៃយ៍នីមួយៗ។

### ប្រព័ន្ធ Extranet

ប្រព័ន្ធ Extranet ត្រូវបានតភ្ជាប់ជាមួយនឹងគេហទំព័រនៃក្រុមប្រឹក្សាសិទ្ធិមនុស្សដោយរួមមាន៖

- សេចក្តីព្រាងសេចក្តីសម្រេចចិត្ត និងសេចក្តីសម្រេចនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស
- ព័ត៌មានជាលាយលក្ខណ៍អក្សរក្រៅផ្លូវការដែលរដ្ឋ និងភាគីពាក់ព័ន្ធផ្សេងទៀតដាក់ជូន និង
- សេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់របស់រដ្ឋសមាជិក រដ្ឋសង្កេតការណ៍ អង្គការ NGOs និងអ្នកចូលរួមផ្សេងទៀតនៅក្នុងសម័យប្រជុំពិសេស និងអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាសិទ្ធិមនុស្ស និងកិច្ចប្រជុំរៀបចំ

ប្រព័ន្ធ Extranet ក៏មានទំព័រព័ត៌មានទំនាក់ទំនងអង្គការ NGOs ដោយដាក់បញ្ចូលព័ត៌មានបច្ចុប្បន្នភាពជាទៀងទាត់អំពីសម័យប្រជុំជាក់លាក់។

i. ដើម្បីចូលមើលទំព័រប្រព័ន្ធ Extranet ដែលមានលេខកូចសម្ងាត់ សូមបំពេញបែបបទតាមប្រព័ន្ធអនឡាញដែលអាចរកបានពីក្នុងទំព័រនៃក្រុមប្រឹក្សាសិទ្ធិមនុស្សលើគេហទំព័រនៃការិយាល័យ OHCHR។ នៅពេលលោកអ្នកបានបំពេញបែបបទហើយនោះ លោកអ្នកនឹងទទួលបានឈ្មោះប្រើប្រាស់ និងលេខកូដសម្ងាត់តាមរយៈអ៊ីមែល។

### កម្មវិធីចាក់ផ្សាយតាមគេហទំព័រ

កិច្ចប្រជុំជាសាធារណៈនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស និងយន្តការមួយចំនួនអាចមើលដោយផ្ទាល់នៅក្នុងកម្មវិធីចាក់ផ្សាយតាមគេហទំព័រ។ កម្មវិធីចាក់ផ្សាយតាមគេហទំព័រក៏រួមមានវីដេអូនៃកិច្ចប្រជុំនាពេលមុនៗផងដែរ។ ដើម្បីមើលកម្មវិធីនេះ លោកអ្នកចាំបាច់ត្រូវទាញយកកម្មវិធីសមស្របតែប៉ុណ្ណោះ។

i. កម្មវិធីចាក់ផ្សាយតាមគេហទំព័រអាចរកមើលបានតាមរយៈទំព័រនៃក្រុមប្រឹក្សាសិទ្ធិមនុស្សនៅលើគេហទំព័រនៃការិយាល័យ OHCHR ។


ក្រុមប្រឹក្សាសិទ្ធិមនុស្ស
យន្តការពិនិត្យសើរើជាសាកល
ក្រុមការងារទទួលបន្ទុកយន្តការពិនិត្យសើរើជាសាកល
គណកម្មាធិការប្រឹក្សាយោបល់នៃក្រុមប្រឹក្សាសិទ្ធិមនុស្ស
នីតិវិធីបណ្តឹង
ក្រុមការងារទទួលបន្ទុកការទំនាក់ទំនង
ក្រុមការងារទទួលបន្ទុកលើស្ថានភាព
នីតិវិធីពិសេស
អាណត្តិការងារប្រចាំប្រទេស
អាណត្តិការងារលើវិស័យ
ក្រុមការងារ
ក្រុមការងារចំបាទទួលបន្ទុកសិទ្ធិទទួលបានការអភិវឌ្ឍ
វេទិកាសង្គម
យន្តការអ្នកជំនាញទទួលបន្ទុកជនជាតិដើមភាគតិច
យន្តការអ្នកជំនាញពាក់ព័ន្ធនឹងសេចក្តីប្រកាសក្រុង Durban និងផែនការសកម្មភាព

ឧបសម្ព័ន្ធ៖ ការទាក់ទង និងការបំពេញការងារជាមួយនឹងក្រុមប្រឹក្សាសិទ្ធិ អាណត្តិការងារ និងយន្តការនៃក្រុមប្រឹក្សានេះ

| កិច្ចប្រជុំ/ យន្តការ | តើតួអង្គសង្គមស៊ីវិលណាមួយ ដែលអាចចូលរួមក្នុងកិច្ចប្រជុំនៃយន្តការទាំងនេះបាន? | តើតួអង្គសង្គមស៊ីវិលចូលរួមយ៉ាងដូចម្តេចនៅក្នុងកិច្ចប្រជុំនោះ? | តើតួអង្គសង្គមស៊ីវិលណាខ្លះដែលអាចចូលរួមចំណែកនៅក្នុងការងារនៃយន្តការនេះ (ក្រៅពីតាមរយៈការចូលរួមប្រជុំ)? | តើការចូលរួមចំណែកទាំងនេះធ្វើឡើងក្នុងទម្រង់បែបណា? |
|---|---|---|---|---|
| សម័យប្រជុំពិសេស និងអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាសិទ្ធិមនុស្ស | អង្គការ NGOs ក្នុងឋានៈពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សា ECOSOC នៅក្រោយពេលទទួលបានសិទ្ធិចូលរួមប្រជុំ | • ដាក់សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ<br>• សេចក្តីថ្លែងការណ៍ផ្ទាល់មាត់<br>• រៀបចំព្រឹត្តិការណ៍អម | មានតែអង្គការ NGOs ក្នុងឋានៈពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សា ECOSOC អាចដាក់សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរជូនសម័យប្រជុំពិសេស/អចិន្ត្រៃយ៍ | អង្គការ NGOs ក្នុងឋានៈពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សា ECOSOC គួរពិគ្រោះគោលការណ៍ណែនាំស្តីពីសេចក្តីថ្លែងកាណ៍ជាលាយលក្ខណ៍អក្សរ |
| យន្តការពិនិត្យរបាយការណ៍ជាសាកលតាមកាលកំណត់ | អង្គការ NGOs ក្នុងឋានៈពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាសិទ្ធិមនុស្សនៅក្រោយពេលទទួលបានសិទ្ធិចូលរួមប្រជុំ | • រៀបចំវេទិកាផ្តល់ព័ត៌មាន<br>• សេចក្តីពន្យល់ទូទៅសង្ខេបអាចលើកឡើងនៅមុនពេល | តួអង្គសង្គមស៊ីវិលពាក់ព័ន្ធ | • ធ្វើការងារជាមួយនឹងរដ្ឋាភិបាលដើម្បីត្រៀមរៀបចំរបាយកាណ៍ ជាតិ |

| | | | | |
|---|---|---|---|---|
| | | អនុម័ត ឯកសារលទ្ធផលនៅក្នុង សម័យប្រជុំអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាសិទ្ធិមនុស្ស | | • ចូលរួមចំណែកនៅក្នុងសេចក្តីសន្និដ្ឋានរបស់ភាគីពាក់ព័ន្ធសម្រាប់លទ្ធភាពដាក់បញ្ចូលនៅក្នុងសេចក្តីសង្ខេបនៃការិយាល័យ OHCHR<br>• ធ្វើការងារបន្តតាមដានលទ្ធផលនៃយន្តការ UPR (សេចក្តីសន្និដ្ឋានអនុសាសន៍ការសន្យា/ការប្តេជ្ញាដោយ |

| | | | | |
|---|---|---|---|---|
| | | | | ទស្ស័គ្រចិត្ត |
| **គណកម្មាធិការប្រឹក្សាយោបល់នៃក្រុមប្រឹក្សាសិទ្ធិមនុស្ស** | អង្គការ NGOs ក្នុងឋានៈពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាសិទ្ធិមនុស្សនៅក្រោយពេលទទួលបានសិទ្ធិចូលរួមប្រជុំ | • ដាក់សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ<br>• សេចក្តីថ្លែងការណ៍ផ្ទាល់មាត់ | **តួអង្គសង្គមស៊ីវិលពាក់ព័ន្ធ** | • ជ្រើសតាំងបេក្ខជនដើម្បីតែងតាំងសម្រាប់គណកម្មាធិការប្រឹក្សាយោបល់ |
| **នីតិវិធីបណ្តឹង** | តួអង្គសង្គមស៊ីវិលមិនអាចចូលរួមនៅក្នុងកិច្ចប្រជុំនៃនីតិវិធីបណ្តឹង ឬ ក្រុមការងារនៃនីតិវិធីបណ្តឹងបាននោះទេ។ កិច្ចប្រជុំទាំងនេះធ្វើឡើងជាលក្ខណៈឯកជន។ | មិនពាក់ព័ន្ធ | **តួអង្គសង្គមស៊ីវិលពាក់ព័ន្ធ** | • ដាក់បណ្តឹងអនុលោមតាមនីតិវិធីបណ្តឹង |

| កិច្ចប្រជុំ/យន្តការ | **តើតួអង្គសង្គមស៊ីវិលណាមួយដែលអាចចូលរួមក្នុងកិច្ចប្រជុំនៃយន្តការទាំងនេះបាន?** | **តើតួអង្គសង្គមស៊ីវិលចូលរួមយ៉ាងដូចម្តេចនៅក្នុងកិច្ចប្រជុំនោះ?** | **តើតួអង្គសង្គមស៊ីវិលណាខ្លះដែលអាចចូលរួមចំណែកនៅក្នុងការងារនៃយន្តការនេះ (ក្រៅពីតាមរយៈការចូលរួមប្រជុំ)?** | **តើការចូលរួមចំណែកទាំងនេះធ្វើឡើងក្នុងទម្រង់បែបណា?** |
|---|---|---|---|---|
| **នីតិវិធីពិសេស** | អង្គការ NGOs និងតួអង្គសង្គមស៊ីវិល | • កិច្ចសន្ទនាឆ្លើយឆ្លងជាមួយ | តួអង្គសង្គមស៊ីវិលពាក់ព័ន្ធ | • ការដាក់សេចក្តីអំពាវ |

| | | | | |
|---|---|---|---|---|
| | ផ្សេងទៀតអាចរៀបចំប្រជុំជាមួយនឹងមន្ត្រីកាន់កាប់អាណត្តិការងារនៅក្នុងអំឡុងសម័យប្រជុំប្រចាំឆ្នាំនៃយន្តការនីតិវិធីពិសេសទៅតាមការជ្រើសរើស | នឹងមន្ត្រីកាន់កាប់អាណត្តិការងារនៅក្នុងអំឡុងសម័យប្រជុំប្រចាំឆ្នាំនៃយន្តការនីតិវិធីពិសេសទៅតាមការជ្រើសរើស<br>• អង្គការ NGOs ក្នុងឋានៈពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សា ECOSOC អាចចូលរួមនៅក្នុងកិច្ចសន្ទនាឆ្លើយឆ្លងជាមួយនឹងកមន្ត្រីកាន់កាប់អាណត្តិការងារនៅសម័យប្រជុំអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាសិទ្ធិមនុស្ស | | នារី/ករណីបុគ្គលជាការប្រញាប់<br>• ផ្តល់ការគាំទ្រលើទស្សនកិច្ចតាមប្រទេស<br>• ធ្វើតស៊ូមតិផ្សព្វផ្សាយបន្តតាមដាននិងអនុវត្តការងារនៃយន្តការនីតិវិធីពិសេស<br>• ជួបជាមួយនឹងមន្ត្រីកាន់កាប់អាណត្តិការងារ<br>• ជ្រើសតាំងបេក្ខជនជាមន្ត្រីកាន់កាប់អាណត្តិការងារ |
| **ក្រុមការងារបើ** | អង្គការ NGOs ក្នុង | អង្គការ NGOs | តួអង្គសង្គមស៊ីវិលពាក់ | • ដាក់ |

| | | | | |
|---|---|---|---|---|
| **កចំហា ទទួលបន្ទុក លើសិទ្ធិ ទទួលបានការ អភិវឌ្ឍន៍** | ឋាន:ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សា ECOSOC នៅក្រោយពេលទទួលបានសិទ្ធិ អាចចូលរួមវគ្គប្រជុំជាសាធារណ:នៃកិច្ចប្រជុំរបស់ក្រុមការងារបាន។ តួអង្គសង្គមស៊ីវិលមកពីតាមវិស័យជាច្រើនចូលរួមសម័យប្រជុំជាសាធារណ:នៃក្រុមការងារជាន់ខ្ពស់។ | ដែលបានចូលរួមកិច្ចប្រជុំនៃ **ក្រុមការងារជាន់ខ្ពស់**មានឱកាសធ្វើសេកចក្ដីថ្លែងការណ៍បើក។ ក៏ប៉ុន្តែ ឱកាសនេះពុំផ្ដល់ជូនក្នុងកិច្ចប្រជុំនៃក្រុមការងារនោះឡើយ។ | ព័ន្ធ | សេចក្ដីថ្លែងការណ៍ជូនក្រុមការងារ<br>• ចូលរួមជាមួយនឹងក្រុមការងារ<br>• ធ្វើការងារអនុវត្តអនុសាសន៍របស់ក្រុមការងារ |
| **វេទិកាសង្គម** | តួអង្គសង្គមស៊ីវិលមកពីតាមវិស័យជាច្រើនអាចចូលរួមកិច្ចប្រជុំ។ | • ផ្ដល់ព័ត៌មានត្រឡប់ស្ដីពីការងារសិទ្ធិមនុស្សនៃយន្តការអន្តរជាតិនៅកនុងកិច្ចប្រជុំនានា<br>• ផ្លាស់ប្ដូរទម្លាប់ល្អៗនៅក្នុងកិច្ចប្រជុំ<br>• បទបង្ហាញជាលក្ខណ:ទូទៅនៅក្នុងកិច្ច | តួអង្គសង្គមស៊ីវិលពាក់ព័ន្ធ | • ដាក់ព័ត៌មានជូនវេទិកាសង្គម |

| | | | | |
|---|---|---|---|---|
| | | ប្រជុំ | | |

| កិច្ចប្រជុំ/យន្តការ | តើតួអង្គសង្គមស៊ីវិលណាមួយ ដែលអាចចូលរួមក្នុងកិច្ចប្រជុំនៃយន្តការទាំងនេះបាន? | តើតួអង្គសង្គមស៊ីវិលចូលរួមយ៉ាងដូចម្តេចនៅក្នុងកិច្ចប្រជុំនោះ? | តើតួអង្គសង្គមស៊ីវិលណាខ្លះដែលអាចចូលរួមចំណែកនៅក្នុងការងារនៃយន្តការនេះ (ក្រៅពីតាមរយៈការចូលរួមប្រជុំ)? | តើការចូលរួមចំណែកទាំងនេះធ្វើឡើងក្នុងទម្រង់បែបណា? |
|---|---|---|---|---|
| វេទិកាស្តីពីបញ្ហាជនជាតិភាគតិច | តួអង្គសង្គមស៊ីវិលមកពីវិស័យជាច្រើនរួមទាំង អង្គការ NGOs អ្នកសិក្សាស្រាវជ្រាវ និងអ្នកជំនាញស្តីពីបញ្ហាជនជាតិភាគតិច | • បទបង្ហាញ/សេចក្តីថ្លែងការណ៍ផ្ទាល់មាត់<br>• សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ | តួអង្គសង្គមស៊ីវិលពាក់ព័ន្ធ | • ដាក់ព័ត៌មានជូនវេទិកា<br>• អង្គការ NGOs ក្នុងឋានៈពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សា ECOSOC អាចជ្រើសតាំងបេក្ខជនដើម្បីតែងតាំងជាប្រធានវេទិកា |
| យន្តការអ្នកជំនាញទទួលបន្ទុកសិទ្ធិជនជាតិដើមភាគតិច | តួអង្គសង្គមស៊ីវិលមកពីវស័យជាច្រើនរួមទាំង អង្គការ NGOs ជនជាតិដើមភាគតិច និងអង្គការនានា | • បទបង្ហាញ/សេចក្តីថ្លែងការណ៍ផ្ទាល់មាត់<br>• សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ | តួអង្គសង្គមស៊ីវិលពាក់ព័ន្ធ | • ដាក់ព័ត៌មានជូនយន្តការអ្នកជំនាញ<br>• ជ្រើសតាំងបេក្ខជនដើម្បីតែងតាំងជាអ្នកជំនាញ |

| | | | | |
|---|---|---|---|---|
| | | | | ឯករាជ្យ |
| ក្រុមការងារអន្តររដ្ឋាភិបាលទទួលបន្ទុកការអនុវត្តប្រកបដោយប្រសិទ្ធភាពលើសេចក្តីប្រកាសនិងផែនការសកម្មភាពក្រុង Durban | អង្គការ NGOs ក្នុងឋានៈពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សា ECOSOC ដែលបានទទួលសិទ្ធិចូលរួមសន្និសីទពិភពលោកស្តីពីសេចក្តីប្រកាសក្រុង Durban | • បទបង្ហាញផ្ទាល់មាត់<br>• សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ | មានតែតួអង្គសង្គមស៊ីវិលដែលស្ថិតនៅក្នុងប្រភេទក្នុងតារាងខាងឆ្វេងដែលអាចចែករំលែកព័ត៌មានជូនក្រុមការងារអន្តររដ្ឋាភិបាល | • ដាក់ព័ត៌មានជូនក្រុមការងារ |
| ក្រុមអ្នកជំនាញឯករាជ្យល្បីៗ | ជាគោលការណ៍កិច្ចប្រជុំនេះជាកិច្ចប្រជុំបិទទ្វារ។ ក៏ប៉ុន្តែក្រុមអ្នកជំនាញអាចអញ្ជើញតួអង្គសង្គមស៊ីវិលផ្លាស់ប្តូរការយល់ឃើញជាមួយនឹងខ្លួន។ | • ការផ្លាស់ប្តូរការយល់ឃើញតាមការអញ្ជើញរបស់ក្រុមអ្នកជំនាញ | តួអង្គសង្គមស៊ីវិលពាក់ព័ន្ធ | • ដាក់ព័ត៌មានជូនក្រុមអ្នកជំនាញ |

| កិច្ចប្រជុំ/យន្តការ | តើតួអង្គសង្គមស៊ីវិលណាមួយដែលអាចចូលរួមក្នុងកិច្ចប្រជុំនៃយន្តការទាំងនេះបាន? | តើតួអង្គសង្គមស៊ីវិលចូលរួមយ៉ាងដូចម្តេចនៅក្នុងកិច្ចប្រជុំនោះ? | តើតួអង្គសង្គមស៊ីវិលណាខ្លះដែលអាចចូលរួមចំណែកនៅក្នុងការងារនៃយន្តការនេះ (ក្រៅពីតាមរយៈការចូលរួមប្រជុំ)? | តើការចូលរួមចំណែកទាំងនេះធ្វើឡើងក្នុងទម្រង់បែបណា? |
|---|---|---|---|---|
| ក្រុមការងារនៃអ្នកជំនាញទទួលបន្ទុកជនជាតិភាគតិចអាហ្វ្រិក | អង្គការ NGOs ក្នុងឋានៈពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សា ECOSOC<br><br>អង្គការ NGOs ដែលបានទទួលសិទ្ធិចូលរួមសន្និសីទពិភពលោកស្តីពីសេចក្តីប្រកាសក្រុង Durban | • បទបង្ហាញផ្ទាល់មាត់<br>• ដាក់សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ | តួអង្គសង្គមស៊ីវិលពាក់ព័ន្ធ | • ដាក់ព័ត៌មានជូនក្រុមការងារ<br>• ផ្តល់ព័ត៌មាននៅហ្នឹងកន្លែងក្នុងពេលក្រុមការងារចុះបេសកកម្មនៅតាមប្រទេស<br>• ជួបប្រជុំជាមួយនឹងសមាជិកនៃក្រុមការងារនៅក្នុងអំឡុងពេលចុះបេសកមម្មនៅតាមប្រទេស |
| គណកម្មាធិការត្រៀមរៀបចំ | • អង្គការ NGOs ក្នុងឋានៈ | • បទបង្ហាញផ្ទាល់មាត់ | មានតែតួអង្គសង្គមស៊ីវិលដែលស្ថិតនៅក្នុង | • ដាក់សេចក្តីថ្លែងការណ៍ |

| | | | | |
|---|---|---|---|---|
| សន្និសីទពិនិត្យសើរើសេចក្តីប្រកាសក្រុង Durban ក្រុមការងារអន្តររដ្ឋាភិបាលទូទៅនៃអន្តរសម័យប្រជុំដើម្បីបន្តតាមដានការងារនៃគណកម្មាធិការត្រៀមរៀបចំសន្និសីទពិនិត្យសើរើសេចក្តីប្រកាសក្រុង Durban | ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សា ECOSOC<br>• អង្គការ NGOs ដែលបានទទួលសិទ្ធិចូលរួមសន្និសីទពិភពលោកស្តីពីសេចក្តីប្រកាសក្រុង Durban<br>• អង្គការ NGOs (ដែលមិនមានឋានៈពិគ្រោះយោបល់ និងពុំបានចូលរួមសន្និសីទពិភពលោក) អាចដាក់ពាក្យសុំចូលរួមបាន<br>• តំណាងជនជាតិដើមភាគតិច | • ដាក់សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ | ប្រភេទក្នុងតារាងខាងឆ្វេងដែលអាចចែករំលែកព័ត៌មានជូនក្រុមការងារអន្តររដ្ឋាភិបាល | ជាលាយលក្ខណ៍អក្សរជូនក្រុមការងារទូទៅនៃអន្តរសម័យប្រជុំ |
| គណកម្មាធិការ*អាដហុក*ទទួលបន្ទុកពន្យល់បកស្រាយ | អង្គការ NGOs ក្នុងឋានៈពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សា | • បទបង្ហាញផ្ទាល់មាត់<br>• សេចក្តីថ្លែងការណ៍ជាលាយ | តួអង្គសង្គមស៊ីវិលពាក់ព័ន្ធ | • ដាក់ព័ត៌មាន និងការសិក្សាជូនគណក |

| | | | | |
|---|---|---|---|---|
| **បទដ្ឋានបំពេញបន្ថែម** | ECOSOC<br><br>អង្គការ NGOs ដែលបានទទួលសិទ្ធិចូលរួមសន្និសីទពិភពលោកស្តីពីសេចក្តីប្រកាសក្រុង Durban | លក្ខណ៍អក្សរ | | ម្ចាធិការ<br>*អាជហុក* |

# VI. យន្តការនីតិវិធីពិសេស

## ទិដ្ឋភាពសង្ខេបនៃយន្តការនីតិវិធីពិសេស

| | | |
|---|---|---|
| *តើយន្តការនីតិវិធីពិសេសជាអ្វី?*<br>"**យន្តការនីតិវិធីពិសេស**" គឺជាឈ្មោះទូទៅមួយដែលបានផ្តល់ឲ្យយន្តការដែលបានបង្កើតឡើងដោយ**គណកម្មការសិទ្ធិមនុស្ស និងក្រុមប្រឹក្សាសិទ្ធិមនុស្ស**ទទួលយកបន្ទុកអនុវត្តដើម្បីពិនិត្យ ឃ្លាំមើល ផ្តល់យោបល់ប្រឹក្សា និងធ្វើរបាយការណ៍ជាសាធារណៈអំពីស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេស ឬ ទឹកដីជាក់លាក់ណាមួយ (**អាណត្តិការងារតាមប្រទេស**) ឬ អំពីបាតុភាពធំៗនៃការរំលោភសិទ្ធិមនុស្សនៅទូទាំងពិភពលោក (**អាណត្តិការងារតាមវិស័យ**)។ គិតមកត្រឹមខែកញ្ញា ឆ្នាំ២០០៨ មាននីតិវិធីពិសេសចំនួន ៣៨ កំពុងដំណើរការ (៣០ ជាអាណត្តិការងារតាមវិស័យ និង ៨ ជាអាណត្តិការងារតាមប្រទេស)។ | បុគ្គលដែលត្រូវបានតែងតាំងនៅក្នុងយន្តការនីតិវិធីពិសេសគឺជាអ្នកជំនាញឯករាជ្យ (មន្ត្រីកាន់កាប់អាណត្តិការងារ) និងអាចគេហៅថាអ្នករាយការណ៍ពិសេស តំណាង តំណាងពិសេស អ្នកជំនាញឯករាជ្យ ឬ សមាជិកក្រុមការងារ។<br><br>**ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស** (OHCHR) ផ្តល់បុគ្គលិក ជំនួយសម្ភារៈ និងបច្ចេកទេសសម្រាប់គាំទ្រក្នុងពេលបំពេញអាណត្តិការងារ។<br>*តើយន្តការនេះបំពេញការងារតាមរបៀបណា?*<br><br>*នីតិវិធីពិសេសៈ*<br><br>• ជួបប្រាស្រ័យឆ្លើយឆ្លងប្រចាំថ្ងៃជាមួយនឹងជនរងគ្រោះជាក់ស្តែង និងអ្នកដែលអាចជាជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្ស និងតស៊ូមតិទាមទារឲ្យមានការការពារសិទ្ធិរបស់ជនទាំងនេះ | • ចាត់វិធានការលើកង្វល់ផ្នែកសិទ្ធិមនុស្សចំពោះករណីនីមួយៗ ឬ លើបញ្ហាទូទៅតាមរយៈការធ្វើទំនាក់ទំនងជាមួយនឹងរដ្ឋាភិបាល<br>• បំពេញបេសកកម្មស្វែងរកការពិតនៅតាមបណ្តាប្រទេស និងចេញរបាយការណ៍រួមជាមួយនឹងអនុសាសន៍<br>• រៀបចំការសិក្សាស្រាវជ្រាវតាមវិស័យដែលប្រើប្រាស់សម្រាប់ជាមគ្គុទេសក៍ស្តីពីនិយាម និង |

| | | |
|---|---|---|
| បទដ្ឋាន<br>• លើកកម្ពស់ការយល់ដឹងជាសាធារណៈតាមរយៈសារព័ត៌មានស្ដីពីបញ្ហានានាដែលស្ថិតនៅក្នុងអាណត្តិការងាររបស់ខ្លួន<br>• ខុសពីគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស យន្តការនីតិវិធីពិសេសអាចចាប់ផ្ដើមដំណើរការសូម្បីនៅក្នុងករណីដែលរដ្ឋពុំបានផ្ដល់សច្ចាប័នលើលិខិតុបករណ៍ ឬ សន្ធិសញ្ញាពាក់ព័ន្ធក៏ដោយ ហើយគេពុំចាំបាច់ត្រូវប្រើប្រាស់ឲ្យអស់លទ្ធភាពនូវយន្តការដោះស្រាយក្នុងស្រុកមុននឹងអាចប្រើប្រាស់យន្តការនីតិវិធីពិសេសនោះឡើយ។<br><br>*តើទាក់ទង និងបំពេញការងារជាមួយនឹង* | *យន្តការនីតិវិធីពិសេសនេះ*<br><br>*តាមវិធីណា?*<br><br>**តួអង្គសង្គមស៊ីវិលជាលក្ខណៈបុគ្គល ឬ រួមគ្នាអាចទាក់ទង និងបំពេញការងារជាមួយនឹងយន្តការនីតិវិធីពិសេសបាន។** ពួកគេអាចធ្វើឡើងតាមរយៈ៖<br><br>• ការដាក់ករណីនីមួយៗជូនយន្តការនីតិវិធីពិសេស<br><br>• ផ្ដល់ព័ត៌មាន និងការវិភាគលើកង្វល់អំពីសិទ្ធិមនុស្សជាក់លាក់<br><br>• ផ្ដល់ការគាំទ្រលើទស្សនកិច្ចតាមប្រទេសដោយយន្តការនីតិវិធីពិសេស<br><br>• បំពេញការងារនៅតាមមូលដ្ឋាន ឬ ថ្នាក់ជាតិ ដើម្បីតស៊ូមតិ ផ្សព្វផ្សាយ បន្តតាមដាន និងអនុវត្តការងារនៃនីតិវិធីពិសេស | • អញ្ជើញមន្ត្រីកាន់កាប់អាណត្តិការងារនៃយន្តការនីតិវិធីពិសេសចូលរួមនៅក្នុងគំនិតផ្ដួចផ្ដើមរបស់ខ្លួន<br><br>• ជួបប្រជុំជាមួយមន្ត្រីកាន់កាប់អាណត្តិការងារនីមួយៗពេញមួយឆ្នាំ និងចូលរួមនៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់មន្ត្រីកាន់កាប់អាណត្តិការងារនៃយន្តការនីតិវិធីពិសេស<br>តួអង្គសង្គមស៊ីវិលក៏អាចជ្រើសតាំងបេក្ខជនឲ្យបំពេញការងារជាមន្ត្រីកាន់កាប់អាណត្តិការងារនៃយន្តការនីតិវិធីពិសេសផងដែរ។ |

i. អាសយដ្ឋានទំនាក់ទំនងមន្ត្រីកាន់កាប់អាណត្តិការងារនៃយន្តការនីតិវិធីពិសេស

អ៊ីមែល: SPDInfo@ohchr.org (សម្រាប់ការសាកសួរ និងព័ត៌មានទូទៅ)

urgent-action@ohchr.org (សម្រាប់ករណី/បណ្ដឹងជាលក្ខណៈបុគ្គលតែប៉ុណ្ណោះ)

ទូរសារៈ +41 (0)22 917 90 06
ប្រៃសណីយ៍ៈ **បញ្ជូរឆ្លើយតបរហ័ស**
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

8–14, avenue de la Paix
CH–1211 ទីក្រុងហ្សឺណែវ 10 - ប្រទេសស្វីស

**គួរអង្គសង្គមស៊ីវិលគួរបញ្ជាក់នៅក្នុងកម្មវត្ថុនៃអ៊ីមែល ឬ ទូរសារ ឬ នៅលើស្រោមសំបុត្រស្តីពីយន្តការនីតិវិធីពិសេសណាមួយដែលខ្លួនមានបំណងប្រើប្រាស់។**

ដោយសារអាសយដ្ឋានទំនាក់ទំនងយន្តការនីតិវិធីពិសេសមានតែមួយ ការបញ្ជាក់ឲ្យបានច្បាស់លាស់អំពីកម្មវត្ថុចំបង ឬ គោលបំណងនៃលិខិតទំនាក់ទំនងនឹងអនុញ្ញាតឲ្យមានការឆ្លើយតបទាន់ពេលវេលា។

វាមានភាពចាំបាច់ណាស់ដែលត្រូវបញ្ជាក់ផងដែរថាតើលិខិតទំនាក់ទំនងនោះមានគោលបំណងចង់ដាក់ព័ត៌មានទូទៅស្តីពីបណ្តឹងជាលក្ខណៈបុគ្គល ឬ ថាតើវាជាប្រភេទសំណើផ្សេងទៀត (ឧ. លិខិតអញ្ជើញឲ្យចូលរួមសន្និសីទ សំណើសុំជួបប្រជុំជាមួយនឹងមន្ត្រីកាន់កាប់អាណត្តិការងារ និង/ឬ ជំនួយការរបស់ពួកគេ)។

តើយន្តការនីតិវិធីពិសេសជាអ្វី?

សេចក្តីផ្តើមស្តីពីយន្តការនីតិវិធីពិសេស

"**យន្តការនីតិវិធីពិសេស**" គឺជាឈ្មោះទូទៅដែលបានផ្តល់ឲ្យយន្តការដែលបានបង្កើតឡើងដោយ**គណកម្មការសិទ្ធិមនុស្ស** ហើយ**ក្រុមប្រឹក្សាសិទ្ធិមនុស្ស**បានយកមកអនុវត្តដើម្បីឆ្លើយតបទៅនឹងស្ថានភាពជាក់លាក់នៅតាមប្រទេសណាមួយ ឬ បញ្ហាវិស័យជាក់លាក់នៅគ្រប់ទីកន្លែងក្នុងពិភពលោក។ លក្ខណៈសំខាន់នៃយន្តការនីតិវិធីពិសេសគឺលទ្ធភាពឆ្លើយតបឲ្យបានលឿនទៅនឹងការចោទប្រកាន់ការរំលោភសិទ្ធិមនុស្សដែលបានកើតឡើងនៅគ្រប់ទីកន្លែងក្នុងពិភពលោកមិនថាក្នុងពេលណាមួយនោះឡើយ។

អាណត្តិការងារនៃយន្តការនីតិវិធីពិសេសជាធម្មតាតម្រូវឲ្យមន្ត្រីកាន់កាប់អាណត្តិការងារឃ្លាំមើល ផ្តល់យោបល់ប្រឹក្សា និងធ្វើរបាយការណ៍ជាសាធារណៈអំពីស្ថានភាពសិទ្ធិមនុស្សនៅតាមប្រទេស ឬ ទឹកដីណាមួយជាក់លាក់ (**អាណត្តិការងារតាមប្រទេស**) ឬ លើបាតុភាពចំបងនៃការរំលោភសិទ្ធិមនុស្សនៅលើពិភពលោក (**អាណត្តិការងារតាមវិស័យ**)។ អាណត្តិការងារនៃយន្តការនីតិវិធីពិសេសនីមួយៗត្រូវបានកំណត់និយមន័យនៅក្នុងសេចក្តីសម្រេចចិត្តដែលបង្កើតយន្តការនីតិវិធីពិសេសទាំងនោះ។ អាណត្តិការងារតាមវិស័យត្រូវបានបន្តអាណត្តិរៀងរាល់ ៣ ឆ្នាំ ម្តង

ហើយនឹង ១ ឆ្នាំម្តងសម្រាប់អាណត្តិការងារតាមប្រទេសលើកលែងតែក្រុមប្រឹក្សាសិទ្ធិមនុស្សមានការសម្រេចផ្សេងពីនេះ[118]។ គិតមកត្រឹមខែកញ្ញា ឆ្នាំ២០០៨ មានយន្តការនីតិវិធីពិសេសចំនួន ៣៨ កំពុងដំណើរការដោយក្នុងនោះ ៣០ ជាអាណត្តិការងារតាមវិស័យ និង ៨ ជាអាណត្តិការងារតាមប្រទេស (សូមមើលឧបសម្ព័ន្ធភ្ជាប់ជាមួយនឹងជំពូកនេះ)។

មន្ត្រីកាន់កាប់អាណត្តិការងារនៃយន្តការនីតិវិធីពិសេសគឺជាបុគ្គល (អ្នករាយការណ៍ពិសេស តំណាងពិសេសនៃអគ្គលេខាធិការ តំណាងនៃអគ្គលេខាធិការ ឬ អ្នកជំនាញឯករាជ្យ) ឬ ក្រុមបុគ្គល (ក្រុមការងារ)[119]។ មន្ត្រីកាន់កាប់អាណត្តិការងារបំពេញការងាររយៈពេល ៦ ឆ្នាំជាអតិបរិមា និងពុំទទួលបានប្រាក់ខែ ឬ ហិរញ្ញវត្ថុចំពោះការងាររបស់ខ្លួននោះឡើយ។ ឋានៈឯករាជ្យនៃមន្ត្រីកាន់កាប់អាណត្តិការងារមានសារសំខាន់ចំពោះការបំពេញមុខងារដោយមិនលម្អៀងរបស់ពួកគេ។

**ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស** (ការិយាល័យ OHCHR) ផ្តល់បុគ្គលិក ជំនួយសម្ភារៈ និងបច្ចេកទេសជូនមន្ត្រីកាន់កាប់អាណត្តិការងារនៅក្នុងពេលបំពេញការងារ។

មន្ត្រីកាន់កាប់អាណត្តិការងារនៃយន្តការនីតិវិធីពិសេស៖

- ទទួល និងវិភាគព័ត៌មានស្តីពីស្ថានភាពសិទ្ធិមនុស្សដែលជានិច្ចជាកាលទទួលមកពីប្រភពនានា
- បង្កើតបណ្តាញ និងចែករំលែកព័ត៌មានជាមួយនឹងដៃគូ ទាំងរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល ទាំងនៅក្នុង និងនៅក្រៅអង្គការសហប្រជាជាតិ
- ស្នើសុំ ជាទូទៅក្នុងលក្ខណៈបន្ទាន់ ការបញ្ជាក់បំភ្លឺពីរដ្ឋាភិបាលអំពីការចោទប្រកាន់ការរំលោភ និងក្នុងករណីចាំបាច់ស្នើសុំរដ្ឋាភិបាលឲ្យអនុវត្តវិធានការការពារដើម្បីធានា ឬ ស្តារឡើងវិញនូវការគោរពសិទ្ធិមនុស្ស
- លើកកម្ពស់ការយល់ដឹងអំពីស្ថានភាព និងបាតុភាពសិទ្ធិមនុស្សជាក់លាក់ និងគម្រាមកំហែងព្រមទាំងការរំលោភសិទ្ធិមនុស្សនានា
- នៅពេលកាលៈទេសៈជាក់លាក់តម្រូវ បញ្ជូនកង្វល់របស់ពួកគេតាមរយៈសារព័ត៌មាន និងសេចក្តីថ្លែងការណ៍ជាសាធារណៈ

---

[118] សូមមើលសេចក្តីសម្រេចចិត្តលេខ ៥/១ ឧបសម្ព័ន្ធ កថាខណ្ឌ ៦០ និង "លក្ខខណ្ឌការងារនៃមន្ត្រីកាន់កាប់អាណត្តិការងារនៃយន្តការពិសេស" (A/HRC/PRST/8/2)។

[119] សមាសភាពនៃក្រុមការងារជាធម្មតារួមមានសមាជិក ៦ រូប ដែលសមាជិកមួយរូបៗមកពីក្រុមតំណាងតំបន់នៃអង្គការសហប្រជាជាតិ៖ អាហ្វ្រិក អាស៊ី អាមេរិកឡាទីន និងការ៉ាប៊ីន; អឺរ៉ុបខាងកើត; និងអឺរ៉ុបខាងលិច និងតំបន់ផ្សេងទៀត។

- បំពេញទស្សនកិច្ចតាមប្រទេសដើម្បីវាយតម្លៃស្ថានភាពសិទ្ធិមនុស្សទាក់ទងនឹងអាណត្តិការងាររបស់ពួកគេរៀងៗខ្លួន និងផ្តល់អនុសាសន៍ជូនរដ្ឋាភិបាលក្នុងគោលបំណងធ្វើឲ្យស្ថានភាពទាំងនោះប្រសើរឡើង
- ធ្វើរបាយការណ៍ និងផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស និងក្នុងករណីពាក់ព័ន្ធនឹងអាណត្តិការងារជូនមហាសន្និបាត (និងនៅក្នុងករណីខ្លះជូនក្រុមប្រឹក្សាសន្តិសុខ) អំពីៈសកម្មភាពអចិន្ត្រៃយ៍ក្រោមអាណត្តិការងាររបស់ពួកគេ ទស្សនកិច្ចតាមទីកន្លែង និងនិន្នាការព្រមទាំងបាតុភាពលើវិស័យជាក់លាក់។
- ចូលរួមចំណែកការសិក្សាលើវិស័យនានាដើម្បីបង្កើតជាឯកសារមូលដ្ឋានស្តីពីនិយាម និងបទដ្ឋានសម្រាប់វិស័យនៃអាណត្តិជាក់លាក់របស់ពួកគេ និងអាចផ្តល់ជំនាញផ្លូវច្បាប់លើបញ្ហាជាក់លាក់។

ការពិនិត្យសើរើ សនិទានកម្ម និងការបង្កើនប្រសិទ្ធភាពលើប្រព័ន្ធនៃយន្តការនីតិវិធីពិសេស

នៅក្នុង**សេចក្តីសម្រេចចិត្តលេខ ៦០/២៥១** មហាសន្និបាតតម្រូវឲ្យក្រុមប៊ឹក្សាសិទ្ធិមនុស្សពិនិត្យសើរើ និងក្នុងករណីចាំបាច់បង្កើនប្រសិទ្ធភាព និងធ្វើសនិទានកម្មលើប្រព័ន្ធនៃយន្តការនីតិវិធីពិសេស។ នៅក្នុង**សេចក្តីសម្រេចចិត្តលេខ ៥/១** ស្តីពីការកសាងស្ថាប័ននៃក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ក្រុមប្រឹក្សាបានពន្យល់បកស្រាយលើនីតិវិធីជ្រើសរើស និងតែងតាំងថ្មីដែលអនុវត្តចំពោះមន្ត្រីកាន់កាប់អាណត្តិការងារនៃយន្តការនីតិវិធីពិសេស និងបានបង្កើតនីតិវិធីពិនិត្យសើរើ នីតិវិធីបង្ហាញសនិទានកម្ម និងនីតិវិធីបង្កើនប្រសិទ្ធភាពលើអាណត្តិការងារនៃយន្តការនីតិវិធីពិសេស។ ក្រុមប្រឹក្សាក៏បានអនុម័ត**សេចក្តីសម្រេចចិត្តលេខ ៥/២** កំណត់អំពីក្រមវិជ្ជាជីវៈអនុវត្តចំពោះមន្ត្រីកាន់កាប់អាណត្តិការងារនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស។

អាណត្តិការងារប្រចាំប្រទេសចំនួនពីរ (ប្រទេសប៊ែលរ៉ារុស និងប្រទេសគុយបា) ត្រូវបានបញ្ឈប់ក្រោយពេលអនុម័តសេចក្តីសម្រេចចិត្តលេខ ៥/១។ គិតមកត្រឹមពេលបញ្ចប់សម័យប្រជុំអចិន្ត្រៃយ៍ទី ៩ ក្រុមប្រឹក្សាបានបង្កើតអាណត្តិការងារតាមវិស័យចំនួនពីរ (**អ្នករាយការណ៍ពិសេសទទួលបន្ទុកទម្រង់នៃទាសភាពបច្ចុប្បន្ន រួមទាំង មូលហេតុ និងផលវិបាក និងអ្នកជំនាញឯករាជ្យទទួលបន្ទុកបញ្ហាស្តីពីកាតព្វកិច្ចសិទ្ធិមនុស្សទាក់ទងនឹងការទទួលបានទឹកស្អាតប្រើប្រាស់ និងអនាម័យ**) និងបានបញ្ឈប់អាណត្តិការងារប្រចាំប្រទេសចំនួនពីរទៀត (សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ និងប្រទេសលីប៊ី)។

i. សម្រាប់ព័ត៌មានលម្អិតស្តីពីក្រុមប្រឹក្សាសិទ្ធិមនុស្ស សូមអានជំពូក V (ក្រុមប្រឹក្សាសិទ្ធិមនុស្ស) នៅក្នុង*សៀវភៅណែនាំ*នេះ។

## ការជ្រើសរើស និងការតែងតាំងមន្ត្រីកាន់កាប់អាណត្តិការងារ

### លក្ខខណ្ឌទូទៅស្តីពីការតែងតាំង

អនុលោមតាមសេចក្តីសម្រេចចិត្តលេខ ៥/១ លក្ខខណ្ឌទូទៅដូចខាងក្រោមអនុវត្តចំពោះការជ្រើសតាំង ការជ្រើសរើស និងការតែងតាំងមន្ត្រីកាន់កាប់អាណត្តិការងារ៖

- ជំនាញ
- បទពិសោធន៍នៅក្នុងវិស័យនៃអាណត្តិការងារ
- ឯករាជ្យភាព
- អព្យាក្រឹត្យភាព
- សុចរិតភាពបុគ្គល និង
- ភាពមិនលម្អៀង

នៅពេលតែងតាំងមន្ត្រីកាន់កាប់អាណត្តិការងារ ការពិចារណាជាក់លាក់ក៏ផ្តោតលើតុល្យភាពយែនឌ័រ និងតំណាងភូមិសាស្ត្រស្មើគ្នា ព្រមទាំង តំណាងសមស្របនៃប្រព័ន្ធគតិយុត្តិផ្សេងៗគ្នា។

### តើបុគ្គលណាអាចមានសិទ្ធិត្រូវបានតែងតាំង?

បុគ្គលមានគុណវុឌ្ឍិខ្ពស់ សមត្ថភាព បទពិសោធន៍ពាក់ព័ន្ធ និងបទពិសោធន៍លើវិជ្ជាជីវៈស៊ីជម្រៅផ្នែកវិស័យសិទ្ធិមនុស្ស និងភាពបត់បែន/លទ្ធភាពនៃពេលវេលាត្រូវបានចាត់ទុកជាបេក្ខជនមានសិទ្ធិសម្រាប់ការតែងតាំងជាមន្ត្រីកាន់កាប់អាណត្តិការងារ[120]។

បុគ្គលដែលកាន់កាប់តួនាទីធ្វើសេចក្តីសម្រេចនៅក្នុងជួររដ្ឋាភិបាល អង្គការ ឬ អង្គភាពណាមួយផ្សេងទៀត (រួមទាំងអង្គការមិនមែនរដ្ឋាភិបាល (NGOs)) ស្ថាប័នសិទ្ធិមនុស្សជាតិ (ស្ថាប័ន NHRIs) និងអង្គការសិទ្ធិមនុស្សផ្សេងទៀត) ដែលអាចមានទំនាស់ផលប្រយោជន៍ចំពោះការទទួលខុសត្រូវលើអាណត្តិការងារមិនត្រូវបានយកមកពិចារណានោះទេ។

គោលការណ៍នៃការមិនកាន់កាប់មុខនាទីសិទ្ធិមនុស្សក៏ត្រូវបានគោរពផងដែរនៅពេលតែងតាំងមន្ត្រីកាន់កាប់អាណត្តិការងារ។ ករណីនេះមានន័យថា បុគ្គលទាំងនេះមិនគួរកាន់កាប់អាណត្តិការងារសិទ្ធិមនុស្សច្រើននៃអង្គការសហប្រជាជាតិនៅក្នុងពេលតែមួយ។

### តើបុគ្គលណាអាចជ្រើសតាំងបេក្ខជនបាន?

បុគ្គលខាងក្រោមអាចជ្រើសតាំងបេក្ខជនជាមន្ត្រីកាន់កាប់អាណត្តិការងារនៃយន្តការនីតិវិធីពិសេសបាន៖

---

[120] សូមមើលផងដែរសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាលេខ ៦/១០២។

- រដ្ឋាភិបាល
- ក្រុមតំណាងតំបន់ដែលប្រតិបត្តិការនៅក្នុងប្រព័ន្ធសិទ្ធិមនុស្សអ៊ឺរ៉ុប
- អង្គការអន្តរជាតិ និងការិយាល័យរបស់អង្គការទាំងនេះ (ឧទាហរណ៍ ការិយាល័យ OHCHR)
- អង្គការ NGOs
- គណកម្មាធិការសិន្ធិសញ្ញាសិទ្ធិមនុស្ស និង
- បុគ្គលម្នាក់ៗ

## ការបោះពុម្ពផ្សាយបញ្ជីបេក្ខជន និងបញ្ជីមុខតំណែងទំនេរ?

ផ្អែកលើការជ្រើសតាំង ការិយាល័យ OHCHR រៀបចំ រក្សាទុក និងធ្វើបច្ចុប្បន្នភាពតាមកាលកំណត់លើបញ្ជីជាសាធារណៈស្តីពីបេក្ខជនមានសិទ្ធិដោយមានរួមទាំងប្រវត្តិរូបរបស់បេក្ខជន វិស័យជំនាញ និងបទពិសោធន៍វិជ្ជាជីវៈ។ ការិយាល័យ OHCHR ក៏ផ្សព្វផ្សាយជាសាធារណៈនូវមុខតំណែងទំនេរទាំងអស់នៅពេលជ្រើសរើសមន្ត្រីកាន់កាប់អាណត្តិការងារផងដែរ។

i. **បញ្ជីជាសាធារណៈស្តីពីបេក្ខជនអាចរកបាននៅក្នុងផ្នែកស្តីពីយន្តការនីតិវិធីពិសេសលើប្រព័ន្ធ** Extranet របស់ក្រុមប្រឹក្សា។

## ក្រុមពិគ្រោះយោបល់

ក្រុមពិគ្រោះយោបល់ដោយមានសមាជិកម្នាក់ៗមកពីក្រុមតំណាងតំបន់ចំនួន ៥ ដែលបំពេញការងារទៅតាមសមត្ថភាពរបស់ខ្លួនពិនិត្យបញ្ជីជាសាធារណៈនៃការិយាល័យ OHCHR និងស្នើបញ្ជីឈ្មោះបេក្ខជនរបស់ខ្លួនដើម្បីដាក់ជូនប្រធានក្រុមប្រឹក្សាសិទ្ធិមនុស្សពិចារណា។ អនុសាសន៍របស់ក្រុមនេះត្រូវផ្សព្វផ្សាយជាសាធារណៈ និងមានហេតុផលសំអាង។

**នៅពេលកំណត់ជំនាញចាំបាច់ បទពិសោធន៍ ជំនាញ និងលក្ខខណ្ឌពាក់ព័ន្ធផ្សេងទៀតនៃអាណត្តិការងារទំនេរនីមួយៗ ក្រុមពិគ្រោះយោបល់ពិចារណាតាមការសមស្របលើការយល់ឃើញរបស់ភាគីពាក់ព័ន្ធ រួមទាំង មន្ត្រីកាន់កាប់អាណត្តិការងារបច្ចុប្បន្ន ឬ មន្ត្រីដែលកំពុងបំពេញភារកិច្ច។** ក្រុមពិគ្រោះយោបល់មានការិយាល័យ OHCHR ជួយជ្រោមជ្រែងការងារ។

## ការតែងតាំងមន្ត្រីកាន់កាប់អាណត្តិការងារ

ផ្អែកលើអនុសាសន៍នៃក្រុមពិគ្រោះយោបល់ និងក្រោយពីការពិគ្រោះយោបល់ដ៏ទូលំទូលាយប្រធានក្រុមប្រឹក្សាបង្កើតបញ្ជីឈ្មោះរបស់ខ្លួនផ្ទាល់មួយដែលកំណត់បេក្ខជនសមស្របសម្រាប់មុខតំណែងទំនេរ។ បញ្ជីនេះដាក់បង្ហាញជូនសមាជិកក្រុមប្រឹក្សា និងរដ្ឋសង្កេតការណ៍យ៉ាងហោចណាស់រយៈពេល ២ សប្តាហ៍មុនសម័យប្រជុំ និងក្នុងករណីចាំបាច់ប្រធាននឹងធ្វើការពិគ្រោះយោបល់បន្ថែម

ដើម្បីធានាថា បេក្ខជនដែលត្រូវបានស្នើឡើងនោះត្រូវបានទទួលយក។ ដំណើរការតែងតាំងត្រូវបានបំពេញក្រោយពេលមានការឯកភាពចប់សព្វគ្រប់លើបញ្ជីឈ្មោះរបស់ប្រធាន។

i. **បញ្ជីឈ្មោះបេក្ខជនរបស់ប្រធាន និងក្រុមពិគ្រោះយោបល់អាចរកបាននៅក្នុងផ្នែកស្តីពីយន្តការនីតិវិធីពិសេសលើប្រព័ន្ធ** Extranet របស់ក្រុមប្រឹក្សា។

## កិច្ចប្រជុំប្រចាំឆ្នាំ និងគណៈកម្មាធិការសម្របសម្រួលនៃយន្តការនីតិវិធីពិសេស

ចាប់តាំងពីឆ្នាំ១៩៩៤ កិច្ចប្រជុំប្រចាំឆ្នាំរបស់មន្ត្រីកាន់កាប់អាណត្តិការងារនៃយន្តការនីតិវិធីពិសេសដែលរៀបចំឡើងនៅទីក្រុងហ្សឺណែវត្រូវបានកោះប្រជុំជាកិច្ចប្រជុំបន្តតាមដាន**សន្និសីទពិភពលោកលើសេចក្តីប្រកាសទីក្រុងវីយែនស្តីពីសិទ្ធិមនុស្ស។ សេចក្តីប្រកាសទីក្រុងវីយែន និងផែនការសកម្មភាព** ដែលបានអនុម័តនៅក្នុងសិន្និសីទពិភពលោកនេះបានគូសបញ្ជាក់សារសំខាន់នៃការរក្សា និងពង្រឹងប្រព័ន្ធយន្តការនីតិវិធីពិសេស និងបានបញ្ជាក់ថា យន្តការនីតិវិធីពិសេសគួរមានលទ្ធភាពធ្វើសុខដុមរមនីយកម្ម និងបង្ហាញយុត្តិកម្មលើការងាររបស់ខ្លួនតាមរយៈកិច្ចប្រជុំទៀងទាត់។

**កិច្ចប្រជុំប្រចាំឆ្នាំក៏ផ្តល់ឱកាសឲ្យមន្ត្រីកាន់កាប់អាណត្តិការងារជួបគ្នាដើម្បីផ្លាស់ប្តូរការយល់ឃើញជាមួយនឹងរដ្ឋសមាជិក ការិយាល័យនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស គណៈកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស អង្គការ NGOs និងតួអង្គសង្គមស៊ីវិលផ្សេងទៀត និងតំណាងនានាមកពីភ្នាក់ងារ និងលេខាធិការដ្ឋាននៃអង្គការសហប្រជាជាតិ និងកម្មវិធីស្តីពីបញ្ហានានាដូចជាការបន្តតាមដានលើទស្សនកិច្ចទៅតាមប្រទេស និងអនុសាសន៍ជាដើម។**

i. សម្រាប់ព័ត៌មានបច្ចុប្បន្នស្តីពីកិច្ចប្រជុំប្រចាំឆ្នាំនៃយន្តការនីតិវិធីពិសេស សូមចូលមកកាន់គេហទំព័រនៃការិយាល័យ OHCHR។

**គណៈកម្មាធិការសម្របសម្រួលនៃយន្តការនីតិវិធីពិសេសត្រូវបានបង្កើតឡើងនៅក្នុងសម័យ**ប្រជុំប្រចាំឆ្នាំលើកទី១២នៃមន្ត្រីកាន់កាប់អាណត្តិការងារនៃយន្តការនីតិវិធីពិសេសនៅក្នុងឆ្នាំ២០០៥។ គណៈកម្មាធិការសម្របសម្រួលដឹកនាំការសម្របសម្រួលរវាងមន្ត្រីកាន់កាប់អាណត្តិការងារ និងធ្វើជាស្ពានចម្លងរវាងយន្តការនីតិវិធីពិសេស និងការិយាល័យ OHCHR ប្រព័ន្ធសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ និងតួអង្គសង្គមស៊ីវិល។

សមាសភាពនៃគណៈកម្មាធិការសម្របសម្រួលនៃយន្តការនីតិវិធីពិសេសរួមមានមន្ត្រីកាន់កាប់អាណត្តិការងារចំនួន ៦ នាក់ដែលត្រូវបានជ្រើសតាំងសម្រាប់រយៈពេល ១ ឆ្នាំ ដោយមានម្នាក់ជាប្រធាន[121]។ ការជ្រើសតាំងសមាជិកសម្រាប់គណៈកម្មាធិការនេះធ្វើឡើងនៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំដោយ

[121] អតីតប្រធាននៅបន្តអាណត្តិការងាររបស់ខ្លួននៅក្នុងគណៈកម្មាធិការរយៈពេល ១ ឆ្នាំទៀតផ្អែលើតួនាទីនេះ។

ត្រូវពិចារណាលើភាពចាំបាច់នៃតុល្យភាពតាមតំបន់ និងយេនឌ័រ និងភាពចាំបាច់ត្រូវមានតំណាងស្មើគ្នានៃមន្ត្រីកាន់កាប់អាណត្តិការងារនៃយន្តការនីតិវិធីពិសេសតាមវិស័យ និងតាមប្រទេស។ គណកម្មាធិការសម្របសម្រួលមានផ្នែកនីតិវិធីពិសេសនៃការិយាល័យ OHCHR ជួយគាំទ្រការងាររបស់ខ្លួន។

i. សម្រាប់ព័ត៌មានបច្ចុប្បន្នស្តីពីគណកម្មាធិការសម្របសម្រួលនៃយន្តការនីតិវិធីពិសេស សូមចូលមកកាន់គេហទំព័រនៃការិយាល័យ OHCHR។

## តើយន្តការនីតិវិធីពិសេសបំពេញការងារតាមវិធីណា?

មន្ត្រីកាន់កាប់អាណត្តិការងារនៃយន្តការនីតិវិធីពិសេសមានឧបករណ៍ជាច្រើនសម្រាប់ប្រើប្រាស់ដើម្បីបំពេញតាមលក្ខខណ្ឌនៃអាណត្តិការងាររបស់ខ្លួន ក្នុងនោះ រួមមាន៖

- បញ្ជូនបណ្តឹង
- ធ្វើទស្សនកិច្ចទៅតាមប្រទេសនានា
- បោះពុម្ពផ្សាយរបាយការណ៍
- រៀបចំការសិក្សាលើវិស័យនានា និង
- ចេញសេចក្តីប្រកាសព័ត៌មាន

មន្ត្រីកាន់កាប់អាណត្តិការងារនៅក្នុងការបំពេញការងាររបស់ខ្លួនក៏មាន**ក្បួនណែនាំស្តីពីនីតិវិធីពិសេស** និង**ក្រមវិជ្ជាជីវៈអនុវត្តចំពោះមន្ត្រីកាន់កាប់អាណត្តិការងារនៃយន្តការនីតិវិធីពិសេស**ផងដែរ។

## ក. ក្រមវិជ្ជាជីវៈ និងក្បួនណែនាំអនុវត្តចំពោះមន្ត្រីកាន់កាប់អាណត្តិការងារនៃយន្តការនីតិវិធីពិសេស

## ក្រមវិជ្ជាជីវៈអនុវត្តចំពោះមន្ត្រីកាន់កាប់អាណត្តិការងារនៃយន្តការនីតិវិធីពិសេស

**ក្រមវិជ្ជាជីវៈអនុវត្តចំពោះមន្ត្រីកាន់កាប់អាណត្តិការងារនៃយន្តការនីតិវិធីពិសេស**ត្រូវបានអនុម័តដោយក្រុមប្រឹក្សាសិទ្ធិមនុស្សនៅក្នុងឆ្នាំ២០០៧ ក្នុងគោលបំណងធ្វើឲ្យប្រព័ន្ធយន្តការនីតិវិធីពិសេសកាន់តែមានប្រសិទ្ធភាពឡើងដោយកំណត់និយមន័យលើបទដ្ឋាននៃឥរិយាបទថ្លៃថ្នូរ និងការបំពេញវិជ្ជាជីវៈដែលមន្ត្រីកាន់កាប់អាណត្តិការងារនៃយន្តការនីតិវិធីពិសេសត្រូវគោរពតាមនៅពេលបំពេញអាណត្តិការងាររបស់ខ្លួន។

## ក្បួនណែនាំស្តីពីនីតិវិធីពិសេស

**ក្បួនណែនាំស្តីពីនីតិវិធីពិសេសដែលបង្កើតឡើងដោយមន្ត្រីកាន់កាប់អាណត្តិការងារ** មានគោលបំណងផ្តល់ជាមគ្គុទេសក៍ជូនមន្ត្រីកាន់កាប់អាណត្តិការងារនៅក្នុងការបំពេញតួនាទីរបស់ខ្លួន។ ក្បួនណែនាំនេះក៏មានបំណងជួយសម្រួលឲ្យមានការយល់ដឹងថែមទៀតលើការងាររបស់ភាគីពាក់ព័ន្ធទាំងអស់ផ្សេងទៀត។ ក្បួនណែនាំនេះព្យាយាមឆ្លុះបញ្ចាំងការអនុវត្តល្អៗ និងជួយមន្ត្រីកាន់កាប់អាណត្តិការងារលើកិច្ចខិតខំប្រឹងប្រែងលើកកម្ពស់ និងការពារសិទ្ធិមនុស្ស។

ដំបូងឡើយ ក្បួនណែនាំនេះត្រូវបានអនុម័តនៅក្នុងកិច្ចប្រជុំលើកទី ៦ របស់មន្ត្រីកាន់កាប់អាណត្តិការងារនៃនីតិវិធីពិសេសនៅក្នុងឆ្នាំ១៩៩៩។ ចាប់តាំងពីពេលនោះមក ក្បួនណែនាំនេះត្រូវបានកែសម្រួលដើម្បីសម្របទៅតាមការប្រែប្រួលរចនាសម្ព័ន្ធនៅក្នុងយន្តការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ការវិវឌ្ឍថ្មីៗទាក់ទងនឹងអាណត្តិការងារ និងវិធីបំពេញការងាររបស់មន្ត្រីកាន់កាប់អាណត្តិការងារ។ ចំពោះសំណៅចុងក្រោយបំផុត មតិចូលបានទទួលមកពីរដ្ឋាភិបាល អង្គការ NGOs និងភាគីពាក់ព័ន្ធផ្សេងទៀត។ ក្បួនណែនាំនេះបើកឲ្យមានការពិនិត្យសើរើតាមកាលកំណត់ និងប្រតិបត្តិការស្របទៅតាមបទប្បញ្ញត្តិនៃក្រមវិជ្ជាជីវៈ។

i. សម្រាប់ព័ត៌មានបន្ថែមពាក់ព័ន្ធនឹង**ក្បួនណែនាំស្តីពីនីតិវិធីពិសេស** សូមចូលមកកាន់ទំព័រលើប្រព័ន្ធ **Extranet នៃនីតិវិធិពិសេស**។

## ខ. បណ្តឹង

សកម្មភាពចំបងមួយក្នុងចំណោមសកម្មភាពចំបងនានារបស់មន្ត្រីកាន់កាប់អាណត្តិការងារនៃយន្តការនីតិវិធីពិសេសគឺការចាត់វិធានការលើករណីនីមួយៗដោយផ្អែកលើព័ត៌មានដែលខ្លួនទទួលបានពីប្រភពពាក់ព័ន្ធ និងគួរឲ្យជឿជាក់បាន (ពោលគឺ តួអង្គសង្គមស៊ីវិល)។

ជាទូទៅ កិច្ចអន្តរាគមន៍រួមមានការបញ្ជូនលិខិតជូនទៅរដ្ឋាភិបាល (លិខិតចោទប្រកាន់) ដើម្បីស្នើសុំព័ត៌មាន និងការឆ្លើយតបចំពោះការចោទប្រកាន់ ហើយក្នុងករណីចាំបាច់ស្នើសុំរដ្ឋាភិបាលឲ្យចាត់វិធានការទប់ស្កាត់ ឬ ស៊ើបអង្កេត (សេចក្តីអំពាវនាវបន្ទាន់)។ កិច្ចអន្តរាគមន៍ទាំងអស់ត្រូវបានហៅថា "បណ្តឹង"។

| |
|---|
| បណ្តឹងនៅក្នុងឆ្នាំ២០០៧ |
| បណ្តឹងសរុបចំនួន **១០០៣** ត្រូវបានបញ្ជូនក្នុងឆ្នាំ២០០៧ |
| **៤៩ ភាគរយ**គឺជាបណ្តឹងរួមគ្នា |
| **២២៩៤** ករណីនីមួយៗត្រូវបានលើកឡើងដោយ **១៣ ភាគរយ**ពាក់ព័ន្ធនឹងស្ត្រី |
| រដ្ឋាភិបាលបានឆ្លើយតបទៅនឹងបណ្តឹងចំនួន **៥២** ភាគរយ |
| ប្រទេសសរុបចំនួន **១២៨** បានទទួលបណ្តឹងទាំងនេះ។ |

**សេចក្តីអំពាវនាវបន្ទាន់**ត្រូវបានបញ្ជូនចេញនៅពេលការចោទប្រកាន់ការរំលោភនានាត្រូវការដោះស្រាយបន្ទាន់ដោយសារវាពាក់ព័ន្ធនឹងការបាត់បង់ជីវិតមនុស្ស ស្ថានភាពគម្រាមកំហែងដល់អាយុជីវិត ឬ ការខូចខាតជាក់ស្តែង ឬ ដែលកំពុងបន្តកើតឡើងលើជនរងគ្រោះ។ **លិខិតចោទប្រកាន់**ត្រូវបានបញ្ជូនចេញនៅពេលនីតិវិធីស្តីពីសេចក្តីអំពាវនាវបន្ទាន់ពុំមានភាពពាក់ព័ន្ធដើម្បីបញ្ជូនព័ត៌មាន និងស្នើសុំការបញ្ជាក់បំភ្លឺអំពីការចោទប្រកាន់លើការរំលោភសិទ្ធិមនុស្ស។

មន្ត្រីកាន់កាប់អាណត្តិការងារអាចបញ្ជូនបណ្តឹងរួមគ្នានៅពេលករណីណាមួយស្ថិតនៅក្នុងវិសាលភាពនៃអាណត្តិការងារលើសពីមួយ។ សេចក្តីសម្រេចថាតើត្រូវអន្តរាគមន៍ជាមួយនឹងរដ្ឋាភិបាលដែរឬទេជាឆន្ទានុសិទ្ធិសម្រេចដោយមន្ត្រីកាន់កាប់អាណត្តិការងារនៃយន្តការនីតិវិធីពិសេស និងអាស្រ័យលើលក្ខណៈវិនិច្ឆ័យដែលបានបង្កើតឡើងដោយពួកគេ ព្រមទាំងលក្ខណៈវិនិច្ឆ័យដូចមានចែងនៅក្នុងក្រមវិជ្ជាជីវៈ។ មន្ត្រីកាន់កាប់អាណត្តិការងារក៏តម្រូវឲ្យពិចារណាឲ្យបានល្អិត និងទាន់ពេលវេលាលើព័ត៌មានដែលរដ្ឋពាក់ព័ន្ធបានផ្តល់ជូនអំពីស្ថានភាពពាក់ព័ន្ធនឹងអាណត្តិការងាររបស់ពួកគេ។

នៅពេលប្រមូលព័ត៌មាន មន្ត្រីកាន់កាប់អាណត្តិការងារត្រូវ៖

- ពិគ្រោះគោលការណ៍ណែនាំផ្អែកតាមគោលការណ៍ឆន្ទានុសិទ្ធិ តម្លាភាព អព្យាក្រឹត្យភាព និងការវិនិច្ឆ័យដោយយុត្តិធម៌
- រក្សាការសម្ងាត់លើប្រភពសក្ខីកម្មក្នុងករណីលាតត្រដាងសក្ខីកម្មទាំងនេះអាចបណ្តាលឲ្យប៉ះពាល់ដល់បុគ្គលពាក់ព័ន្ធ
- សំអាងលើអង្គហេតុមិនលម្អៀង និងអាចទុកចិត្តបានដោយផ្អែកលើបទដ្ឋានភ័ស្តុតាងដែលសមស្របនឹងរបាយការណ៍ក្រៅប្រព័ន្ធតុលាការ និងសេចក្តីសន្និដ្ឋានដែលតម្រូវឲ្យសរសេរឡើង និង
- ផ្តល់ឱកាសជូនតំណាងរដ្ឋពាក់ព័ន្ធផ្តល់យោបល់លើការវាយតម្លៃទាំងនេះ និងឆ្លើយតបទៅនឹងការចោទប្រកាន់ចំពោះរដ្ឋ។ ចម្លើយតបសង្ខេបជាលាយលក្ខណ៍អក្សររបស់រដ្ឋក៏ត្រូវដាក់ភ្ជាប់ជាឧបសម្ព័ន្ធនឹងរបាយការណ៍នៃមន្ត្រីកាន់កាប់អាណត្តិការងារផងដែរ។

## គ. ទស្សនកិច្ចតាមប្រទេស

**ទស្សនកិច្ចតាមប្រទេស ឬ ទស្សនកិច្ចតាមទីកន្លែង** (ឬ បេសកកម្មស្វែងរកការពិត) គឺជាឧបករណ៍សំខាន់មួយសម្រាប់មន្ត្រីកាន់កាប់អាណត្តិការងារនៃយន្តការនីតិវិធីពិសេសប្រើប្រាស់។ ជាពិសេស មន្ត្រីកាន់កាប់អាណត្តិការងារបញ្ជូនលិខិតជូនរដ្ឋាភិបាលស្នើសុំធ្វើទស្សនកិច្ចនៅក្នុងប្រទេសនោះផ្ទាល់ ហើយក្នុងករណីរដ្ឋាភិបាលយល់ព្រម លិខិតអញ្ជើញទស្សនកិច្ចនឹងធ្វើឡើង។

ប្រទេសខ្លះបានចេញ "**លិខិតអញ្ជើញអចិន្ត្រៃយ៍**" ពោលគឺ ជាគោលការណ៍ បណ្តាប្រទេសទាំងនេះត្រៀមខ្លួនទទួលទស្សនកិច្ចរបស់មន្ត្រីកាន់កាប់អាណត្តិការងារនៃយន្តការនីតិវិធីពិសេស។ ទស្សនកិច្ចនៅតាមប្រទេសត្រូវគោរពតាមបទប្បញ្ញត្តិដូចមានចែងនៅក្នុងក្រមវិជ្ជាជីវៈ និង**លក្ខខណ្ឌការងារស្តីពីបេសកម្មស្វែងរកការពិតជាធរមានចំពោះយន្តការនីតិវិធីពិសេស**[122]។

i. គិតត្រឹមខែកញ្ញា ឆ្នាំ២០០៨ រដ្ឋជាង ៦០ ប្រទេសបានចេញលិខិតអញ្ជើញអចិន្ត្រៃយ៍។ ដើម្បីពិនិត្យមើលបញ្ជីឈ្មោះរដ្ឋបច្ចុប្បន្នដែលបានចេញ**លិខិតអញ្ជើញអចិន្ត្រៃយ៍**ជូនយន្តការនីតិវិធីពិសេស សូមចូលទៅកាន់គេហទំព័រនៃការិយាល័យ OHCHR។

ទស្សនកិច្ចតាមប្រទេសផ្តល់លទ្ធភាពឲ្យមន្ត្រីកាន់កាប់អាណត្តិការងារវាយតម្លៃលើស្ថានភាពសិទ្ធិមនុស្ស និង/ឬ ស្ថានភាពស្ថាប័ន ច្បាប់ តុលាការ និងរដ្ឋបាលជាក់លាក់នៅក្នុងរដ្ឋមួយអនុលោមតាមអាណត្តិការងារ។ នៅក្នុងអំឡុងពេលទស្សនកិច្ច មន្ត្រីកាន់កាប់អាណត្តិការងារជួបប្រជុំជាមួយនឹងអាជ្ញាធរជាតិ តំណាងសង្គមស៊ីវិល ជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្ស ក្រុមតំណាងប្រចាំប្រទេសនៃអង្គការសហប្រជាជាតិ អ្នកសិក្សាស្រាវជ្រាវ សហគមន៍ការទូត និងសារព័ត៌មាន។

មន្ត្រីកាន់កាប់អាណត្តិការងារលើកអនុសាសន៍នៅក្នុងរបាយការណ៍ជាសាធារណៈផ្អែកលើរបកគំហើញរបស់ខ្លួន។ របាយការណ៍ទាំងនេះនឹងដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស។ មន្ត្រីកាន់កាប់អាណត្តិការងារមួយចំនួនបានរៀបចំសន្និសីទសារព័ត៌មាន និងចេញរបកគំហើញបឋមនៅពេលបញ្ចប់ទស្សនកិច្ចតាមប្រទេស។ ទស្សនកិច្ចតាមប្រទេសអាចទទួលជោគជ័យធំធេងប្រសិនបើមានការប្តេជ្ញាពីរដ្ឋាភិបាល និងមានការចូលរួមពីតួអង្គសង្គមស៊ីវិលនៅមុនពេល នៅក្នុងអំឡុងពេល និងក្រោយទស្សនកិច្ចដើម្បីគាំទ្រលើការងាររបស់មន្ត្រីកាន់កាប់អាណត្តិការងារ។

## ឃ. ការធ្វើរបាយការណ៍ និងការចូលរួមចំណែកជាមួយនឹងក្រុមប្រឹក្សា សិទ្ធិមនុស្ស

មន្ត្រីកាន់កាប់អាណត្តិការងារនៃនីតិវិធីពិសេសត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្សស្នើសុំឲ្យបង្ហាញរបាយការណ៍ប្រចាំឆ្នាំដែលក្នុងនោះពិពណ៌នាអំពីសកម្មភាពនានាដែលបានធ្វើឡើងនៅក្នុងអំឡុងពេលនៃឆ្នាំចាស់។ ក្នុងកាលៈទេសៈមួយចំនួន ក្រុមប្រឹក្សាអាចស្នើសុំមន្ត្រីកាន់កាប់អាណត្តិការងារឲ្យធ្វើរបាយការណ៍អំពីវិស័យជាក់លាក់ ឬ ប្រធានបទជាក់លាក់ណាមួយដែលក្រុមប្រឹក្សាចាប់

---

[122] លក្ខខណ្ឌនៃទស្សនកិច្ចតាមប្រទេសត្រូវបានអនុម័តនៅក្នុងសម័យប្រជុំលើកទី ៤ (ឆ្នាំ១៩៩៧) នៃយន្តការនីតិវិធីពិសេស (E/CN.4/1998/45) និងមានបំណងណែនាំរដ្ឋាភិបាលអំពីដំណើរការទស្សនកិច្ច។

អារម្មណ៍។ របាយការណ៍ទាំងនេះគឺជាឧបករណ៍សាធារណៈ និងជាឯកសារសំអាងសម្រាប់ការបន្តតាមដាន និងការតស៊ូមតិនៅក្នុងវិស័យនៃអាណត្តិការងារ។

របាយការណ៍ប្រចាំឆ្នាំរួមមានព័ត៌មានស្តីពីវិធីបំពេញការងារ ការវិភាគលើវិស័យនីមួយៗ និន្នាការ និងការវិវឌ្ឍទូទៅពាក់ព័ន្ធនឹងអាណត្តិការងារ និងអាចរួមមានអនុសាសន៍រួមផងដែរ។ របាយការណ៍ក៏អាចរួមមានសេចក្តីសង្ខេបអំពីបណ្តឹងដែលបានដាក់ជូនរដ្ឋាភិបាល និងចម្លើយតបដែលបានទទួលផងដែរ។ ជាទូទៅ របាយការណ៍ស្តីពីទស្សនកិច្ចនៅតាមប្រទេសត្រូវបានដាក់ជូនជាឧបសម្ព័ន្ធនៃរបាយការណ៍ប្រចាំឆ្នាំ។ យន្តការខ្លះបានស្នើសុំឲ្យធ្វើរបាយការណ៍ជូនមហាសន្និបាតនៃអង្គការសហប្រជាជាតិដែលជួបប្រជុំនៅបុរីញូវយ៉កចាប់ពីខែកញ្ញា ដល់ ខែធ្នូ ជារៀងរាល់ឆ្នាំ។

i. ដើម្បីចូលទៅអាន**របាយការណ៍ស្តីពីយន្តការនីតិវិធីពិសេសសម្រាប់ដាក់ជូនក្រុមប្រឹក្សា** សូមគេហទំព័រនៃការិយាល័យ OHCHR។

| សម័យប្រជុំពិសេសស្តីពីវិបត្តិស្បៀងអាហារពិភពលោក | | |
|---|---|---|
| នៅក្នុងខែឧសភា ឆ្នាំ២០០៨ **អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិទទួលបានស្បៀងអាហារ** លោក Olivier De Schutter បានអំពាវនាវឲ្យក្រុមប្រឹក្សាសិទ្ធិមនុស្សកោះសម័យប្រជុំពិសេសមួយស្តីពីវិបត្តិស្បៀងអាហារពិភពលោក។ ជាការ | ឆ្លើយតប ក្រុមប្រឹក្សាបានរៀបចំសម័យប្រជុំពិសេសមួយស្តីពី "ផលប៉ះពាល់អវិជ្ជមានស្តីពីការសម្រេចបាននៃសិទ្ធិទទួលបានស្បៀងអាហារចំពោះស្ថានភាពចុះដុនដាបនៃវិបត្តិស្បៀងអាហារពិភពលោក ដែលបានបណ្តាលមកពីការហក់ឡើង | នៃតម្លៃស្បៀងអាហារ" នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨។ អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិទទួលបានស្បៀងអាហារបានចូលរួមយ៉ាងសកម្មនៅក្នុងសម័យប្រជុំ ដែលត្រូវបានរៀបចំលើកដំបូងលើប្រធានបទមួយនេះ។ |

## ង. ការសិក្សាលើវិស័យ

មន្ត្រីកាន់កាប់អាណត្តិការងារនៃយន្តការនីតិវិធីពិសេសក៏អាចរៀបចំការសិក្សាលើវិស័យណាមួយជាក់លាក់ដែលជាឧបករណ៍ដ៏មានប្រយោជន៍សម្រាប់ជាមគ្គុទេសក៏ជូនរដ្ឋាភិបាល ព្រមទាំងសង្គមស៊ីវិលស្តីពីនិយាម និងការអនុវត្តនិយាម និងបទដ្ឋានសិទ្ធិមនុស្ស។ អ្នកកាន់កាប់អាណត្តិការងារក៏អាចរៀបចំ និងចូលរួមកិច្ចប្រជុំអ្នកជំនាញស្តីពីប្រធានបទលើវិស័យសិទ្ធិមនុស្សផងដែរ។

| សិក្ខាសាលាអ្នកជំនាញ - ការពង្រឹងការការពារស្ត្រីពីទារុណកម្ម | | |
|---|---|---|
| នៅក្នុងខែកញ្ញា ឆ្នាំ២០០៧ សិក្ខាសាលាអ្នកជំនាញស្តីពី | ឬ **ទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬ** | នាក់មកពីតាមតំបន់ផ្សេងៗ និងមកពីអង្គការមិនមែនរដ្ឋាភិបាល |

| | | |
|---|---|---|
| "ការពង្រឹងការការពារស្ត្រីពីទារុណកម្ម" ត្រូវបានរៀបចំឡើងដោយការិយាល័យ OHCHR ក្នុងនាមអ្នករាយការណ៍ពិសេសទទួលបន្ទុកអនុសញ្ញាទប់ស្កាត់ទារុណកម្ម និងការប្រព្រឹត្ត | **បន្ថោកបន្ទាប** ក្នុងគោលបំណងចូលរួមចំណែកលើការអនុវត្តក្នុងលក្ខណៈប្រព័ន្ធជាងមុនលើក្របខណ្ឌអន្តរជាតិស្តីពីទារុណកម្មចំពោះកង្វល់របស់ស្ត្រី និងការពង្រឹងយន្តការការពារពួកគេ។ អ្នកជំនាញ ២៥ | និងអន្តររដ្ឋាភិបាលពីគ្រប់វិស័យ (រួមទាំងយន្តការប្រឆាំងទារុណកម្មមកពីតាមតំបន់ និងអង្គការសហប្រជាជាតិ) បានចូលរួមក្នុងការពិភាក្សាទាំងនេះ។ |

## ច. សេចក្តីប្រកាសព័ត៌មាន

យន្តការនីតិវិធីពិសេសអាចចេញសេចក្តីប្រកាសព័ត៌មានជាលក្ខណៈបុគ្គល ឬ ជាសមូហភាព គូសបញ្ជាក់អំពីស្ថានភាពជាក់លាក់ ឬ និយាមអន្តរជាតិតាមការស្នើសុំរបស់រដ្ឋ។

i. សំណៅចតចម្លងនៃ**សេចក្តីប្រកាសព័ត៌មាន សេចក្តីថ្លែងការណ៍ និងឯសារផ្សេងទៀត** ដែលបានចេញដោយយន្តការនីតិវិធីពិសេសអាចចូលមើលបាននៅក្នុងផ្នែកស្តីពីនីតិវិធីពិសេសលើគេហទំព័រនៃការិយាល័យ OHCHR។

វិធីទាក់ទង និងបំពេញការងារជាមួយនឹងយន្តការនីតិវិធីពិសេស

*"ជាទូទៅ សង្គមស៊ីវិល និងអង្គការ NGOs អន្តរជាតិ តំបន់ និងជាពិសេសជាតិផ្តល់ការគាំទ្រដ៏មានតម្លៃលើប្រព័ន្ធយន្តការនីតិវិធីពិសេសនេះ។ ពួកគេផ្តល់ព័ត៌មាន និងការវិភាគនានាដើម្បីជួយផ្សព្វផ្សាយរបកគំហើញនៃយន្តការនីតិវិធីពិសេស និងជួយនៅក្នុងសកម្មភាពបន្តតាមដានព្រមទាំងបង្កើត និងអនុវត្តគោលនយោបាយ និងកម្មវិធីជាតិពាក់ព័ន្ធនឹងការអប់រំដើម្បីបង្កើនប្រសិទ្ធភាពលើបញ្ហានានានៅក្រោមយន្តការនីតិវិធីពិសេស។ កិច្ចប្រជុំជាមួយនឹងតំណាងនានាសមស្របត្រូវធ្វើឡើងនៅគ្រប់ទិដ្ឋភាពការងារនៃយន្តការនីតិវិធីពិសេស រួមទាំង សកម្មភាពនៅទីក្រុងហ្សឺណែវ និងញូវយ៉ក នៅតាមស្ថានបេសកកម្ម និងសកម្មភាពទូទៅផ្សេងទៀត។ ដូច្នេះ មន្ត្រីកាន់កាន់អាណត្តិការងារគួរពិចារណាដោយប្រុងប្រយ័ត្ន និងទាន់ពេលវេលាក្នុងការអញ្ជើញស្ថាប័នស្រាវជ្រាវ និងអង្គការ NGOs ឲ្យចូលរួមនៅក្នុងសកម្មភាពនានា ដូចជាសន្និសីទ ការជជែកវែកញែក សក្ខាសាលា និងកិច្ចពិគ្រោះយោបល់ថ្នាក់តំបន់។ ជាទូទៅការិយាល័យ OHCHR គួរទទួលបានជូនដំណឹងអំពីសកម្មភាពពាក់ព័ន្ធនៃមន្ត្រីកាន់កាប់អាណត្តិការងារដោយសារវាពាក់ព័ន្ធនឹងសង្គមស៊ីវិល។"*

សៀវភៅណែនាំស្តីពីប្រតិបត្តិការនីតិវិធីពិសេសនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស (កថាខណ្ឌ ១៣៣)

ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ នីតិវិធីពិសេសបានបង្កើតទំនាក់ទំនង និងសហប្រតិបត្តិការជាមួយនឹងតួអង្គសង្គមស៊ីវិលនានាដោយបានជួយពួកគេផ្តល់សេវាការពារជនរងគ្រោះជាក់ស្តែង និងអ្នកដែលអាចជាជនរងគ្រោះ និងដោយបានចូលរួមចំណែកលើការពង្រឹងអំណាចរបស់អ្នកទាំងអស់នេះ។

ប្រសិទ្ធភាពនៃប្រព័ន្ធយន្តការនីតិវិធីពិសេសនៅក្នុងការការពារសិទ្ធិមនុស្ស និងការទប់ស្កាត់ការរំលោភសិទ្ធិនានាគឺអាស្រ័យលើការចូលរួមដ៏សកម្មរបស់តួអង្គសិទ្ធិមនុស្សនានា ដូចជា សង្គមស៊ីវិលជាដើម។ អង្គការ NGOs អន្តរជាតិ តំបន់ និងជាតិ និងតួអង្គសង្គមស៊ីវិលផ្សេងទៀតគឺជាអ្នកចូលរួមយ៉ាងសំខាន់នៅក្នុងប្រព័ន្ធយន្តការនីតិវិធីពិសេស។ ម្យ៉ាងវិញទៀត សង្គមស៊ីវិលគឺជាស្ថាប័នជួរមុខធ្វើការកំណត់បទដ្ឋានសិទ្ធិមនុស្ស និងការតស៊ូមតិដើម្បីបង្កើតអាណត្តិការងារថ្មីៗ។

ប្រភេទតួអង្គសង្គមស៊ីវិលដែលចូលរួមនៅក្នុងយន្តការនីតិវិធីពិសេសរួមមាន៖

- អង្គការសិទ្ធិមនុស្ស (អង្គការ NGOs សមាគម ក្រុមជនរងគ្រោះ)
- អ្នកការពារសិទ្ធិមនុស្ស
- អង្គការផ្តោតលើបញ្ហាពាក់ព័ន្ធនានា
- សម្ព័ន្ធ និងបណ្តាញ (សិទ្ធិស្ត្រី សិទ្ធិកុមារ សិទ្ធិជនជាតិភាគតិច សិទ្ធិបរិស្ថាន)
- ជនពិការ និងអង្គការតំណាងពួកគេ
- ក្រុមសហគមន៍ (ក្រុមជនជាតិដើមភាគតិច ជនជាតិភាគតិច)
- ក្រុមជំនឿសាសនា (វិហារគ្រីស្ត ក្រុមសាសនា)
- សហជីព (សហជីព ព្រមទាំងសមាគមវិជ្ជាជីវៈ ដូចជា សមាគមអ្នកកាសែត គណមេធាវី សមាគមមន្ត្រីតុលាការ សហជីពនិស្សិត)
- ចលនាសង្គម (ចលនាសន្តិភាព ចលនានិស្សិត ចលនាគាំទ្រប្រជាធិបតេយ្យ)
- អ្នកវិជ្ជាជីវដែលចូលចំណែកដោយផ្ទាល់លើការគោរពសិទ្ធិមនុស្ស (បុគ្គលិកមនុស្សធម៌ មេធាវី បណ្ឌិត និងបុគ្គលិកពេទ្យ)
- សាច់ញាតិជនរងគ្រោះ និង
- ស្ថាប័នសាធារណៈដែលធ្វើសកម្មភាពលើកកម្ពស់សិទ្ធិមនុស្ស (សាលារៀន សាកលវិទ្យាល័យ ស្ថាប័នស្រាវជ្រាវ)




តួអង្គសង្គមស៊ីវិល ក្នុងលក្ខណៈជាបុគ្គល ឬ សមូហភាព អាចទាក់ទង និងបំពេញការងារជាមួយនឹងយន្តការនីតិវិធីពិសេសបាន។ ខុសពីគណកម្មាធិការសន្ធិសញ្ញានៃអង្គការសហប្រជាជាតិ យន្តការនីតិវិធីពិសេសអាចដាក់ឲ្យដំណើរការបានទោះបីក្នុងករណីរដ្ឋពុំទាន់ផ្តល់សច្ចាប័នលើលិខិតុបករណ៍ ឬ សន្ធិសញ្ញាពាក់ព័ន្ធក៏ដោយ ហើយវាពុំចាំបាច់ត្រូវប្រើប្រាស់យន្តការដោះស្រាយក្នុងស្រុកឲ្យអស់លទ្ធភាពសិនមុនពេលប្រើប្រាស់នីតិវិធីពិសេសនោះទេ។ ដូច្នេះ នីតិវិធីពិសេសអាចត្រូវបានប្រើប្រាស់សម្រាប់ប្រទេស ឬ បញ្ហាសិទ្ធិមនុស្សនៅក្នុងដែនកម្រិតនៃយន្តការដែលមានស្រាប់បាន។

តួអង្គសង្គមស៊ីវិលអាចចូលរួមចំណែកលើការងារនៃយន្តការនីតិវិធីពិសេសបានតាមរយៈ៖

- ការដាក់ការចោទប្រកាន់ជាលក្ខណៈបុគ្គលលើការរំលោភសិទ្ធិមនុស្សជូនមន្ត្រីកាន់កាប់អាណត្តិការងារនៃយន្តការនីតិវិធីពិសេសពាក់ព័ន្ធ
- ការផ្តល់ការគាំទ្រលើទស្សនកិច្ចតាមប្រទេស ព័ត៌មាន និងការវិភាគស្តីពីការរំលោភសិទ្ធិមនុស្សដល់មន្ត្រីកាន់កាប់អាណត្តិការងារនៃយន្តការនីតិវិធីពិសេស
- ការបំពេញតួនាទីទប់ស្កាត់ដោយផ្តល់ព័ត៌មានជូនយន្តការនីតិវិធីពិសេសស្តីពីការដាក់បញ្ចូលច្បាប់ថ្មីដែលអាចនាំឲ្យមានការរំលោភសិទ្ធិមនុស្ស
- ការបំពេញការងារបន្តតាមដានលើអនុសាសន៍នៃនីតិវិធីពិសេសទាំងក្នុងស្រុក និងជាតិ។ និយាយក្នុងន័យទូលាយជាងនេះ សង្គមស៊ីវិលអាចគាំទ្រការផ្សព្វផ្សាយការងារ និងរបកគំហើញរបស់មន្ត្រីកាន់កាប់អាណត្តិការងារនៃយន្តការនីតិវិធីពិសេសបាននៅក្នុងរង្វង់ដែនដីខ្លួនប្រតិបត្តិ។

ទំនាក់ទំនងដ៏សំខាន់រវាងនីតិវិធីពិសេស និងសង្គមស៊ីវិលបានបង្ហាញឲ្យឃើញនៅក្នុងអាណត្តិការងាររបស់អ្នករាយការណ៍ពិសេសទទួលបន្ទុកស្ថានភាពនៃអ្នកការពារសិទ្ធមនុស្ស។

## VII. យន្តការពិនិត្យរបាយការណ៍ជាសាកលតាមកាលកំណត់

| ទិដ្ឋភាពសង្ខេបនៃយន្តការពិនិត្យរបាយការណ៍ជាសាកលតាមកាលកំណត់ | | |
|---|---|---|
| *ដូចម្តេចដែលហៅថា យន្តការពិនិត្យរបាយការណ៍ ជាសកលតាមកាលកំណត់?*<br><br>យន្តការពិនិត្យរបាយការណ៍ ជាសាកលតាមកាលកំណត់ (យន្តការ UPR) ត្រូវបាន បង្កើតឡើងក្រោម**សេចក្តី សម្រេចចិត្តលេខ ៦០/២៥១** របស់មហា សន្និបាតអង្គការសហប្រជា ជាតិជាយន្តការសទ្ធិមនុស្សថ្មី មួយ។ តាមរយៈយន្តការនេះ **ក្រុមប្រឹក្សាសិទ្ធិមនុស្ស** ត្រួតពិនិត្យតាមកាលកំណត់ លើការបំពេញ កាតព្វកិច្ចរបស់រដ្ឋសមាជិក នីមួយៗក្នុងចំណោម រដ្ឋសមាជិកនៃ អង្គការសហប្រជាជាតិទាំង ១៩២ ព្រមទាំង ការ ប្តេជ្ញាចិត្តផ្នែកសិទ្ធិមនុស្ស។ យន្តការ UPR គឺ | *តើយន្តការពិនិត្យរបាយាករណ៍ ជាសាកលតាមកាលកំណត់ ដំណើរការដោយរបៀបណា?*<br><br>**សេចក្តីសម្រេចចិត្តលេខ ៥/១** របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សមាន ចែងអំពីកាលកំណត់ និងដំណើរការ។ យន្តការ UPR ដំណើរការក្នុងវដ្តបួនឆ្នាំ និងមាន ដំណាក់កាលជាច្រើន ដូចជា៖<br><br>• ការរៀបចំព័ត៌មានដែលជា មូលដ្ឋាននៃការត្រួតពិនិត្យ ឡើងវិញក្នុងនោះរួមមាន៖ ព័ត៌មាន ដែលត្រូវបានរៀបចំឡើង ដោយរដ្ឋដែលស្ថិតនៅក្រោម ការត្រួតពិនិត្យឡើងវិញ (របាយការណ៍ជាតិ) កម្រងព័ត៌មានរបស់ អង្គការសហប្រជាជាតិ ស្តីពីរដ្ឋដែលស្ថិតនៅក្រោម ការត្រួតពិនិត្យឡើងវិញ ដែលត្រូវបានរៀបចំឡើងដោយ | ទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) និង សេចក្តីសង្ខេបព័ត៌មាន ដែលត្រូវបានដាក់ជូនពិនិត្យ ដោយភាគីពាក់ព័ន្ធផ្សេងទៀត (រួមមាន តួអង្គសង្គម ស៊ីវិលផងដែរ) ដែលត្រូវបានរៀបចំឡើង ដោយ OHCHR។<br><br>• ការត្រួតពិនិត្យឡើងវិញ នោះប្រព្រឹត្តទៅនៅក្នុងទី ក្រុងហ្សឺណែវដោយក្រុម ការងារទទួលបន្ទុកយន្តការ UPR ដែលមាន សមាសភាពរដ្ឋជា សមាជិកទាំង ៤៧ របស់ក្រុមប្រឹក្សានេះ និង មានទម្រង់ជាការសន្ទនា ឆ្លើយឆ្លងរវាងរដ្ឋដែលស្ថិត នៅក្រោមការត្រួតពិនិត្យ ឡើងវិញ និងរដ្ឋសមាជិក សង្កេតការណ៍នៃក្រុម |

| | | |
|---|---|---|
| ជាយន្តការសហប្រតិបត្តិការ និងត្រូវបានរៀបចំឡើងដើម្បីបំពេញបន្ថែមលើការងាររបស់**គណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស** មិនមែនក្នុងគោលបំណងដើម្បីបំពេញការងារជាន់គ្នានោះទេ។ | **ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ** | ប្រឹក្សា។ ក្រុមការងារជួបប្រជុំគ្នានៅក្នុងសម័យប្រជុំ |

| | | |
|---|---|---|
| ពេញអង្គដែលមានរយៈពេលពីរសប្តាហ៍ចំនួនបីលើកក្នុងមួយឆ្នាំៗ និងត្រួតពិនិត្យឡើងវិញលើរដ្ឋចំនួន១៦ ក្នុងសម័យប្រជុំពេញអង្គពោលគឺ មានរដ្ឋសរុបមានចំនួន ៤៨ ក្នុងមួយឆ្នាំ។<br>• ក្រុមអ្នករាយការណ៍បីរូប ("ត្រីភាគី") ដែលត្រូវបានជ្រើសរើសចេញពីក្នុងចំណោមរដ្ឋសមាជិករបស់ក្រុមប្រឹក្សា សម្របសម្រួលដល់ការត្រួតពិនិត្យឡើងវិញលើរដ្ឋនីមួយៗ។<br>• ការអនុម័តរបស់ក្រុមការងារលើឯកសារលទ្ធផលនៅចុងបញ្ចប់នៃដំណើរការត្រួតពិនិត្យឡើងវិញមួយលើកៗ។<br>• ការពិចារណា និងការអនុម័តរបស់ក្រុមប្រឹក្សាលើឯកសារលទ្ធផលនៃយន្តការ UPR តាមធម្មតាត្រូវបានធ្វើឡើងនៅ | ក្នុងសម័យប្រជុំអចិន្ត្រៃយ៍លើកក្រោយរបស់ក្រុមប្រឹក្សានេះ និង<br>• ការបន្តអនុវត្តរបស់រដ្ឋដែលត្រូវបានត្រួតពិនិត្យឡើងវិញ និងភាគីពាក់ព័ន្ធផ្សេងទៀត ក្នុងនោះរួមមាន សង្គមស៊ីវិលផងដែរលើសេចក្តីសន្និដ្ឋាន និងអនុសាសន៍ ដែលត្រូវបានលើកឡើងនៅក្នុងឯកសារលទ្ធផល។<br>*វិធីចូលរួមជាមួយនឹងយន្តការពិនិត្យរបាយការណ៍ជាសាកលតាមកាលកំណត់*<br>សេចក្តីសម្រេចចិត្តលេខ ៥/១ អនុញ្ញាតឲ្យមានការចូលរួមរបស់ភាគីពាក់ព័ន្ធទាំងអស់ក្នុងដំណើរការ។ ហេតុដូច្នេះ ការចូលរួមរបស់អង្គការអន្តររដ្ឋាភិបាលប្រចាំតំបន់ ស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស (NHRI) ក៏ដូចជាតំណាងសង្គមស៊ីវិល | ក្នុងនោះរួមមាន អង្គការមិនមែនរដ្ឋាភិបាល (NGO) អ្នកការពារសិទ្ធិមនុស្ស គ្រឹះស្ថានសិក្សាអប់រំ និងវិទ្យាស្ថានស្រាវជ្រាវ ត្រូវបានប្រមើលមើលនៅក្នុងដំណាក់កាលពាក់ព័ន្ធ។<br>**ឋានៈពិគ្រោះយោបល់ជាមួយ** នឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) នៃអង្គការសហប្រជាជាតិ គឺជាលក្ខខណ្ឌតម្រូវក្នុងការចូលរួមសម័យប្រជុំរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ ប៉ុន្តែ តួអង្គសង្គមស៊ីវិលអាចរួមចំណែកដល់ការងាររបស់ UPR តាមរយៈ៖<br>• ការចូលរួមក្នុងកិច្ចពិគ្រោះយោបល់ដែលត្រូវបានធ្វើឡើងដោយរដ្ឋាភិបាល ដើម្បីរៀបចំរបាយការណ៍ជាតិរបស់ខ្លួនស្តីពីបញ្ហាសិទ្ធិមនុស្សនៅក្នុងប្រទេសរបស់ខ្លួន។ |

| | | |
|---|---|---|
| • ការរៀបចំឯកសារស្នើសុំពិនិត្យអំពីស្ថានភាពសិទ្ធិមនុស្សនៅក្នុងរដ្ឋដែលស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញ ដើម្បីបញ្ចូលជាសក្ខានុពលទៅក្នុងសេចក្តីសង្ខេបនៃខ្លឹមសារឯកសារស្នើសុំពិនិត្យរបស់ភាគីពាក់ព័ន្ធដែលរៀបចំឡើងដោយការិយាល័យ OHCHR។ សេចក្តីសង្ខេប | របស់ការិយាល័យ OHCHR ត្រូវបានក្រុមការងារយកមកពិចារណានៅពេលត្រួតពិនិត្យឡើងវិញលើរដ្ឋទាំងឡាយ។ និង<br>• ការចូលរួមចំណែកលើការបន្តអនុវត្តលទ្ធផលនៃការត្រួតពិនិត្យឡើងវិញ។<br>សម័យប្រជុំរបស់ក្រុមការងារត្រូវបានផ្សព្វ | ផ្សាយផ្ទាល់នៅក្នុង **កម្មវិធីផ្សាយលើគេហទំព័ររបស់**ការិយាល័យ OHCHR និងកម្រងឯកសារ និងសារព័ត៌មានជាច្រើនរបស់ UPR អាចរកមើលបានក្នុងផ្នែកនៃ UPR លើគេហទំព័ររបស់ OHCHR និងនៅលើទំព័រ UPR នៅក្នុងប្រព័ន្ធ Extranet នៃក្រុមប្រឹក្សាសិទ្ធិមនុស្ស។ |

i. អ្នកដែលអាចទំនាក់ទំនងបានសំខាន់ៗ ទាក់ទងនឹងការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល
សាខាក្រុមប្រឹក្សាសិទ្ធិមនុស្សនៃការិយាល័យឧត្តមស្នងការអង្គការសហប្រជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 ទីក្រុងហ្សឺណែវ 10 -ប្រទេសស្វីស
ទូរស័ព្ទលេខ៖ +៤១(0) ២២ ៩១៧ ៩២ ៦៩
ទូរសារលេខ៖ +៤១(0) ២២ ៩១៧ ៩0 ១១

អង្គភាពសង្គមស៊ីវិលនៃការិយាល័យឧត្តមស្នងការអង្គការសហប្រជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 ទីក្រុងហ្សឺណែវ 10 -ប្រទេសស្វីស

## អ្វីទៅជាយន្តការពិនិត្យរបាយការណ៍ជាសាកលតាមកាលកំណត់? ការបង្កើតឡើងនូវយន្តការពិនិត្យរបាយការណ៍ជាសាកលតាមកាលកំណត់

យន្តការពិនិត្យរបាយការណ៍ជាសាកលតាមកាលកំណត់ (UPR) ដែលត្រូវបានបង្កើតឡើងដោយ**សេចក្តីសម្រេចចិត្តលេខ ៦០/២៥១** ចុះថ្ងៃទី១៥ មីនា ឆ្នាំ២០០៦ របស់មហាសន្និបាតអង្គការសហប្រជាជាតិ និងដែលត្រូវបានអធិប្បាយលម្អិតនៅក្នុង**សេចក្តីសម្រេចចិត្តលេខ ៥/១** ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៧ របស់**ក្រុមប្រឹក្សាសិទ្ធិមនុស្ស** គឺជាយន្តការសិទ្ធិមនុស្សថ្មីមួយ។ តាមរយៈយន្តការនេះ ក្រុមប្រឹក្សាសិទ្ធិមនុស្ស ត្រូវបានប្រគល់កិច្ចការឲ្យត្រួតពិនិត្យឡើងវិញតាមកាលកំណត់លើការបំពេញកាតព្វកិច្ចរបស់រដ្ឋជាសមាជិកនីមួយៗនៅក្នុងចំណោមរដ្ឋជាសមាជិកទាំង ១៩២ នៃអង្គការសហប្រជាជាតិ និងការប្តេជ្ញាចិត្តផ្នែកសិទ្ធិមនុស្សរបស់រដ្ឋទាំងនេះ។ UPR គឺជាយន្តការ

សហប្រតិបត្តិការនិងមានមូលដ្ឋានលើការសន្ទនាឆ្លើយឆ្លងរវាងរដ្ឋនីមួយៗដែលស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញ និងរដ្ឋសមាជិក និងរដ្ឋសង្កេតការណ៍របស់ក្រុមប្រឹក្សា។ យន្តការនេះត្រូវបានរៀបចំឡើងដើម្បីបំពេញបន្ថែមលើការងាររបស់**គណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សនានា** មិនមែនក្នុងគោលបំណងបំពេញការងារជាន់គ្នានោះទេ។

ដោយដំណើរការនៅក្នុងវដ្តបួនឆ្នាំម្តង UPR មានដំណាក់កាលមួយចំនួន ក្នុងនោះរួមមានៈ ការរៀបចំឯកសារជាមូលដ្ឋាននៃការត្រួតពិនិត្យឡើងវិញ ការត្រួតពិនិត្យឡើងវិញ និងការបន្តអនុវត្តសេចក្តីសន្និដ្ឋាន និងអនុសាសន៍ដែលជាលទ្ធផលនៃការត្រួតពិនិត្យឡើងវិញ។ អង្គការអន្តររដ្ឋាភិបាលប្រចាំតំបន់ ស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស (NHRI) ក៏ដូចជា តំណាងសង្គមស៊ីវិល ក្នុងនោះរួមមាន អង្គការមិនមែនរដ្ឋាភិបាល (NGO) អ្នកការពារសិទ្ធិមនុស្ស គ្រឹះស្ថានសិក្សាអប់រំ និងវិទ្យាស្ថានស្រាវជ្រាវ ត្រូវបានរំពឹងទុកថានឹងចូលរួមនៅក្នុងដំណាក់កាលពាក់ព័ន្ធនៃដំណើរការត្រួតពិនិត្យឡើងវិញនេះ។

នៅចុងបញ្ចប់នៃខួបទីមួយនៃយន្តការពិនិត្យរបាយការណ៍ជាសាកលតាមកាលកំណត់ ក្រុមប្រឹក្សាសិទ្ធិមនុស្សអាចត្រួតពិនិត្យឡើងវិញលើទម្រង់បែបបទ និងកាលកំណត់នៃការត្រួតពិនិត្យឡើងវិញ ដោយឈរលើមូលដ្ឋាននៃទម្លាប់អនុវត្តន៍ត្រឹមត្រូវបំផុត និងបទពិសោធន៍កន្លងមក។

## គោលការណ៍ និងគោលបំណងណែនាំអំពីយន្តការពិនិត្យរបាយការណ៍ជាសាកលតាមកាលកំណត់

គោលការណ៍មួយចំនួនណែនាំអំពីយន្តការពិនិត្យរបាយការណ៍ជាសាកលតាមកាលកំណត់នេះ។ យន្តការពិនិត្យរបាយការណ៍ជាសាកលតាមកាលកំណត់ត្រូវតែៈ

- លើកកម្ពស់សកលភាព ភាពពឹងពាក់គ្នាទៅវិញទៅមក អវិភាគភាព និងភាពទាក់ទងគ្នាទៅវិញទៅមកនៃសិទ្ធិមនុស្សទាំងអស់។
- ធ្វើជាយន្តការសហប្រតិបត្តិការ ឈរលើមូលដ្ឋានព័ត៌មានមិនលម្អៀង និងដែលគួរទុកចិត្តបាន និងការសន្ទនាឆ្លើយឆ្លង។
- ធានាឲ្យមានវិសាលភាពសកល និងប្រព្រឹត្តកម្មស្មើភាពគ្នារបស់រដ្ឋទាំងអស់។
- ជាដំណើរការអន្តររដ្ឋាភិបាល ដែលជំរុញដោយសមាជិកអង្គការសហប្រជាជាតិ និងមានលក្ខណៈតម្រង់ទិសសកម្មភាព។

- ជំរុញឲ្យមានការចូលរួមដោយពេញលេញពីបណ្តារដ្ឋដែលស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញ។
- បំពេញបន្ថែម និងមិនមែនបំពេញការងារជាន់គ្នារបស់យន្តការសិទ្ធិមនុស្សផ្សេងទៀត ដូច្នេះវាជាការបន្ថែមគុណតម្លៃ។
- ត្រូវបានអនុវត្តដោយមិនលម្អៀង តម្លាភាព មិនរើសអើង មានលក្ខណៈស្ថាបនា គ្មានការប្រឈមមុខដាក់គ្នា និងមិនពាក់ព័ន្ធនយោបាយ។
- មិនមែនជាបន្ទុកធ្ងន់ធ្ងរហួសហេតុសម្រាប់រដ្ឋដែលពាក់ព័ន្ធ ឬ របៀបវារៈរបស់ក្រុមប្រឹក្សា។
- មិនពន្យារពេលហួសហេតុពេក។ វាគួរតែមានលក្ខណៈប្រាកដនិយម និងមិនស្រូបយកពេលវេលា ធនធានមនុស្សនិងធនធានហិរញ្ញវត្ថុ ក្នុលក្ខណៈវិសមាមាត្រឡើយ។
- មិនធ្វើឲ្យចុះខ្សោយសមត្ថភាពរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ក្នុងការឆ្លើយតមទៅនឹងស្ថានភាពបន្ទាន់នៃសិទ្ធិមនុស្ស ។
- ធ្វើសមាហរណកម្មដោយពេញលេញនូវទស្សនវិស័យយេនឌ័រ។
- ពិចារណាកម្រិតនៃការអភិវឌ្ឍ និងភាពជាក់លាក់របស់ប្រទេសនានា និង
- ធានាឲ្យមានការចូលរួមរបស់ភាគីពាក់ព័ន្ធដែពាក់ព័ន្ធទាំងអស់ ក្នុងនោះរួមមាន អង្គការមិនមែនរដ្ឋាភិបាល (NGO) ផងដែរ អនុលោមទៅតាមសេចក្តីសម្រេចចិត្តលេខ ៦០/២៥១ របស់មហាសន្និបាតអង្គការសហប្រជាជាតិ និង**សេចក្តីសម្រេចចិត្តលេខ ១៩៩៦/៣១** របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) ក៏ដូចជា សេចក្តីសម្រេចដែលក្រុមប្រឹក្សាសិទ្ធិមនុស្ស អាចធ្វើឡើង។

ទិសដៅនៃយន្តការពិនិត្យរបាយការណ៍ជាសាកលតាមកាលកំណត់គឺៈ

- ការកែលម្អស្ថានភាពសិទ្ធិមនុស្សនៅនឹងកន្លែង។
- ការបំពេញកាតព្វកិច្ច និងការប្តេជ្ញាចិត្តផ្នែកសិទ្ធិមនុស្សរបស់រដ្ឋ និងការវាយតម្លៃលើហេតុការវិវឌ្ឍថ្មីៗជាវិជ្ជមាន និងបញ្ហាប្រឈម ដែលយន្តការពិនិត្យរបាយការណ៍ជាសាកលតាមកាលកំណត់នេះប្រឈមមុខ។
- ការបង្កើនសមត្ថភាពរបស់រដ្ឋ និងការផ្តល់ជំនួយបច្ចេកទេស ដោយពិគ្រោះយោបល់ជាមួយ និងដោយមានការយល់ព្រមពីរដ្ឋពាក់ព័ន្ធ។
- ការចែករំលែកទម្លាប់អនុវត្តន៍ត្រឹមត្រូវនៅក្នុងចំណោមរដ្ឋទាំងឡាយ និងភាគីពាក់ព័ន្ធផ្សេងទៀត។

- ការគាំទ្រឲ្យមានកិច្ចសហប្រតិបត្តិការនៅក្នុងការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស។ និង
- ការជំរុញលើកទឹកចិត្តឲ្យមានសហប្រតិបត្តិការ និងការចូលរួមពាក់ព័ន្ធដោយពេញលេញជាមួយនឹងក្រុមប្រឹក្សាសិទ្ធិមនុស្ស ស្ថាប័នសិទ្ធិមនុស្សផ្សេងទៀត និង **ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស** (OHCHR)។

យន្តការហិរញ្ញវត្ថុពីរគឺ **មូលនិធិស្ម័គ្រចិត្តនៃយន្តការពិនិត្យរបាយការណ៍ជាសាកលតាមកាលកំណត់** និង**មូលនិធិស្ម័គ្រចិត្តសម្រាប់ជំនួយសហិរញ្ញវត្ថុ និងបច្ចេកទេស**[123] ត្រូវបានបង្កើតឡើងដើម្បីសម្របសម្រួលដល់ការចូលរួមរបស់ប្រទេសកំពុងអភិវឌ្ឍន៍ (ជាពិសេស ប្រទេសមានការអភិវឌ្ឍតិចតួចបំផុត) នៅក្នុងយន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល និងគាំទ្រការអនុវត្តបន្តរបស់ការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកលនេះ នៅថ្នាក់ជាតិរៀងៗខ្លួន។

## តើយន្តការពិនិត្យរបាយការណ៍ជាសាកលតាមកាលកំណត់ដំណើរការដោយរបៀបណា?

## ក. កាលកំណត់ លំដាប់លំដោយ និងមូលដ្ឋាននៃដំណើរការត្រួតពិនិត្យឡើងវិញកាលកំណត់

យន្តការពិនិត្យរបាយការណ៍ជាសាកលតាមកាលកំណត់នេះដំណើរការទៅនៅក្នុងវដ្តបួនឆ្នាំ។ នៅក្នុងសម័យប្រជុំលើកទីប្រាំមួយរបស់ខ្លួន ក្នុងខែកញ្ញា ឆ្នាំ២០០៧ ក្រុមប្រឹក្សា សិទ្ធិ មនុស្ស បានអនុម័តប្រតិទិនសម្រាប់ការត្រួតពិនិត្យឡើងវិញលើរដ្ឋជាសមាជិករបស់អង្គការសហប្រជាជាតិនៅក្នុងអំឡុងពេលនៃខួបទីមួយ។

| |
|---|
| i. ដើម្បីមើលលំដាប់លំដោយនៃរដ្ឋដែលត្រូវបានត្រួតពិនិត្យឡើងវិញនៅក្នុងអំឡុងពេលនៃខួបទីមួយ (២០០៨-២០១១) សូមមើលគេហទំព័ររបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)។ |

[123] សូមមើលសេចក្តីសម្រេចចិត្តលេខ ៦/១៧ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។

## លំដាប់លំដោយនៃការត្រួតពិនិត្យឡើងវិញ

លំដាប់លំដោយដែលនៅក្នុងនោះរដ្ឋនានាត្រូវបានត្រួតពិនិត្យឡើងវិញនោះ ត្រូវបាន ណែនាំដោយគោលការណ៍សកលភាព និងប្រព្រឹត្តិកម្មដោយស្មើគ្នា។ សេចក្តីសម្រេចចិត្តលេខ ៥/១ ក៏មានចែងផងដែរអំពីបទប្បញ្ញត្តិដូចខាងក្រោម ដើម្បីកំណត់អំពីលំដាប់លំដោយនៃការត្រួតពិនិត្យឡើងវិញ៖

- រដ្ឋជាសមាជិកទាំងអស់របស់ក្រុមប្រឹក្សា ត្រូវតែបានត្រួតពិនិត្យឡើងវិញនៅក្នុងរយៈពេល នៃសមាជិកភាពរបស់ខ្លួន។
- រដ្ឋជាសមាជិកដំបូងរបស់ក្រុមប្រឹក្សា ជាពិសេស រដ្ឋជាសមាជិកដែលត្រូវបានជ្រើសរើសសម្រាប់រយៈពេលមួយឆ្នាំ ឬ ពីរឆ្នាំ គួរត្រូវបានត្រួតពិនិត្យឡើងវិញមុនគេ។
- រដ្ឋជាសមាជិកចម្រុះ និងរដ្ឋជាសមាជិកបេក្ខភាពរបស់ក្រុមប្រឹក្សា គួរត្រូវបានត្រួតពិនិត្យឡើងវិញបន្ទាប់ និង
- របាយភូមិសាស្ត្រប្រកបដោយសមធម៌គួរត្រូវបានគោរព នៅក្នុងការជ្រើសរើសប្រទេសសម្រាប់ការត្រួតពិនិត្យឡើងវិញនេះ។

## មូលដ្ឋាននៃការត្រួតពិនិត្យឡើងវិញ

រដ្ឋនីមួយៗត្រូវបានត្រួតពិនិត្យឡើងវិញដោយឈរលើមូលដ្ឋានដូចខាងក្រោម៖

- ធម្មនុញ្ញនៃអង្គការសហប្រជាជាតិ។
- សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។
- លិខិតុបករណ៍សិទ្ធិមនុស្សដែលរដ្ឋជាភាគី។
- ការសន្យា និងការប្តេជ្ញាចិត្តដោយស្ម័គ្រចិត្តរបស់រដ្ឋ ក្នុងនោះរួមមាន (ក្នុងករណីពាក់ព័ន្ធ) ការសន្យា និងការប្តេជ្ញាចិត្តដែលត្រូវបានទទួលអនុវត្តនៅពេលដាក់ស្នើសុំយោបល់បេក្ខភាពរបស់រដ្ឋ សម្រាប់ការបោះឆ្នោតជាក្រុមប្រឹក្សា និង
- ច្បាប់មនុស្សធម៌អន្តរជាតិជាធរមាន។

# ខ. ដំណើរការត្រួតពិនិត្យឡើងវិញ

## ១. ការចងក្រងជាឯកសារ

ការរៀបចំព័ត៌មានសម្រាប់ការត្រួតពិនិត្យឡើងវិញ គឺជាដំណាក់កាលដំបូងនៃដំណើរការ។ ការត្រួតពិនិត្យឡើងវិញលើរដ្ឋ ត្រូវបានអនុវត្តដោយឈរលើមូលដ្ឋានព័ត៌មានដែលត្រូវបានលើកឡើងនៅក្នុងឯកសារបីប្រភេទ៖

- ព័ត៌មានដែលត្រូវបានរៀបចំដោយរដ្ឋដែលស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញ។

- កម្រងព័ត៌មានរបស់អង្គការសហប្រជាជាតិ ដែលត្រូវបានរៀបចំដោយ OHCHR និង
- សេចក្ដីសង្ខេបនៃឯកសារស្នើសុំការពិនិត្យរបស់ភាគីពាក់ព័ន្ធ (ដែលត្រូវបានរៀបចំដោយ OHCHR)។

ឯកសារបីប្រភេទទាំងនេះ ផ្ដល់នូវទស្សនវិស័យបំពេញបន្ថែមផ្សេងគ្នាស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅក្នុងរដ្ឋនីមួយៗ ដែលស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញ។ វាគួរតែត្រូវបានរៀបចំឲ្យមានក្នុងរយៈពេលយ៉ាងហោចណាស់ប្រាំមួយសប្ដាហ៍មុនពេលត្រួតពិនិត្យឡើងវិញ និងត្រូវបានដាក់ផ្សាយក្នុងផ្នែក UPR នៃគេហទំព័ររបស់ OHCHR។

(ក) **ព័ត៌មានរៀបចំដោយរដ្ឋស្ថិតក្រោមការត្រួតពិនិត្យឡើងវិញ (របាយការណ៍ជាតិ)**
រដ្ឋបង្ហាញព័ត៌មានដែលខ្លួនបានរៀបចំសម្រាប់ការត្រួតពិនិត្យឡើងវិញលើរដ្ឋខ្លួនឯង ដែលអាចមានទម្រង់ជារបាយការណ៍ជាតិ ជាលក្ខណៈផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ។ បទបង្ហាញជាលាយលក្ខណ៍អក្សរមិនត្រូវឲ្យលើសពី ២០ ទំព័រឡើយ។ **រដ្ឋទាំងឡាយត្រូវបានជំរុញលើកទឹកចិត្តឲ្យរៀបចំព័ត៌មាននេះ តាមរយៈដំណើរការពិគ្រោះយោបល់ដ៏ទូលំទូលាយថ្នាក់ជាតិជាមួយនឹងភាគីពាក់ព័ន្ធទាំងអស់ ក្នុងនោះរួមមានសង្គមស៊ីវិលផងដែរ។**

(ខ) **កម្រងព័ត៌មានអង្គការសហប្រជាជាតិ ដែលត្រូវបានរៀបចំដោយ OHCHR ៖**
OHCHR រៀបចំដោយមិនឲ្យលើសពី ២០ ទំព័រ នូវកម្រងព័ត៌មាន ដែលត្រូវបានបញ្ចូលទៅក្នុងរបាយការណ៍របស់គណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស និតិវិធីពិសេស និងឯកសារផ្លូវការដែលពាក់ព័ន្ធផ្សេងទៀតរបស់អង្គការសហប្រជាជាតិ។

(គ) **សេចក្ដីសង្ខេបឯកសារស្នើសុំពិនិត្យរបស់ភាគីពាក់ព័ន្ធ រៀចំឡើងដោយ OHCHR**

OHCHR ក៏រៀបចំផងដែរដោយមិនឲ្យលើសពី ១០ ទំព័រ នូវសេចក្ដីសង្ខេបឯកសារស្នើសុំពិនិត្យ ដែលត្រូវបានផ្ដល់ជូនដោយភាគីពាក់ព័ន្ធផ្សេងទៀតនៃ UPR (**ក្នុងនោះរួមមាន ស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស** (NHRI) **និងអង្គការមិនមែនរដ្ឋាភិបាល** (NGO) **និងតួអង្គសង្គមស៊ីវិលផ្សេងទៀត**)។ សេចក្ដីសង្ខេបរបស់ភាគីពាក់ព័ន្ធត្រូវបានពិនិត្យពិចារណានៅក្នុងអំឡុងពេលនៃការត្រួតពិនិត្យឡើងវិញ។

## គោលការណ៍ណែនាំទូទៅសម្រាប់ការរៀបចំព័ត៌មានសម្រាប់ការត្រួតពិនិត្យឡើងវិញ

នៅក្នុង**សេចក្តីសម្រេចចិត្តលេខ ៦/១២** ក្រុមប្រឹក្សាសិទ្ធិមនុស្សបង្ហាញអំពីគោលការណ៍ណែនាំទូទៅរបស់ខ្លួនសម្រាប់ការរៀបចំព័ត៌មាន នៅក្រោម UPR។ **គោលការណ៍ណែនាំនេះអនុវត្តចំពោះរដ្ឋ និងភាគីពាក់ព័ន្ធផ្សេងទៀត ក៏ដូចជាចំពោះការិយាល័យ OHCHR សម្រាប់ការរៀបចំឯកសារក្រោមការទទួលខុសត្រូវរបស់ខ្លួន** និងចែងថា ព័ត៌មានដែលត្រូវបានដាក់ជូនពិនិត្យសម្រាប់ការត្រួតពិនិត្យឡើងវិញគួររួមបញ្ចូល៖

- ការពិពណ៌នាអំពីវិធីសាស្ត្រ និងដំណើរការពិគ្រោះយោបល់ដ៏ទូលំទូលាយ ដែលត្រូវបានអនុវត្តតាមដើម្បីរៀបចំព័ត៌មានដែលត្រូវបានផ្តល់ជូន។
- សាវតារ និងក្របខ័ណ្ឌ (ជាពិសេស ដែលមានលក្ខណៈធម្មនិយាម និងជាស្ថាប័ន) សម្រាប់ការលើកកម្ពស់ និងការពារសិទ្ធិមនុស្សនៅក្នុងរដ្ឋ ដោយរួមមាន រដ្ឋធម្មនុញ្ញ ច្បាប់ វិធានការ គោលនយោបាយ យុត្តិសាស្ត្រជាតិ ហេដ្ឋារចនាសម្ព័ន្ធសិទ្ធិមនុស្ស (ឧទាហរណ៍ដូចជា៖ NHRI) និងវិសាលភាពនៃកាតព្វកិច្ចអន្តរជាតិ ដែលត្រូវបានកំណត់នៅក្នុង "មូលដ្ឋាននៃការត្រួតពិនិត្យឡើងវិញ" (សូមើលខាងលើ)។
- ការលើកកម្ពស់ និងការពារសិទ្ធិមនុស្សនៅនឹងកន្លែង ដែលរួមមាន ការអនុវត្តកាតព្វកិច្ចផ្នែកសិទ្ធិមនុស្សអន្តរជាតិ ដែលត្រូវបានកំណត់នៅក្នុង "មូលដ្ឋាននៃការត្រួតពិនិត្យឡើងវិញ" ច្បាប់ជាតិ និងការប្តេជ្ញាចិត្តដោយស្ម័គ្រចិត្ត សកម្មភាពរបស់ NHRI ការលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីសិទ្ធិមនុស្ស និងកិច្ចសហប្រតិបត្តិការជាមួយនឹងយន្តការសិទ្ធិមនុស្ស និង
- ការកំណត់អំពីសមិទ្ធផល វិធីអនុវត្តន៍ត្រឹមត្រូវ បញ្ហាប្រឈម និងលក្ខខណ្ឌកំណត់នានា។

រដ្ឋនីមួយៗក៏គួរតែកំណត់/ផ្តល់ជូនផងដែរនូវព័ត៌មានស្តីពី៖

- អាទិភាពជាតិ កិច្ចផ្តួចផ្តើម និងការប្តេជ្ញាចិត្តសំខាន់បំផុតដែលខ្លួនមានបំណងទទួលរ៉ាប់រងពុះពារជំនះបញ្ហាប្រឈម និងលក្ខខណ្ឌកំណត់ និងកែលម្អស្ថានភាពសិទ្ធិមនុស្សនៅនឹងកន្លែង។
- ការរំពឹងទុករបស់ខ្លួនចំពោះការកសាងសមត្ថភាព និងសំណើសុំជំនួយបច្ចេកទេសនានាប្រសិនបើមាន។
- ព័ត៌មានណាផ្សេងទៀត ដែលគេចាត់ទុកថាពាក់ព័ន្ធ និង
- ការអនុវត្តរបស់ខ្លួនចំពោះការត្រួតពិនិត្យឡើងវិញលើកមុន នៅក្នុងការត្រួតពិនិត្យឡើងវិញក្រោយមកទៀត។

២. ក្រុមការងារទទួលបន្ទុកយន្តការពិនិត្យរបាយការណ៍ជាសាកលតាមកាលកំណត់

ការត្រួតពិនិត្យឡើងវិញជាក់ស្តែងលើរដ្ឋនានា ប្រព្រឹត្តទៅនៅក្នុងក្រុមការងារទទួលបន្ទុក UPR។ ការត្រួតពិនិត្យឡើងវិញនេះត្រូវបានធ្វើជាអធិបតីដោយប្រធានក្រុមប្រឹក្សាសិទ្ធិមនុស្ស និងមានសមត្ថភាពចូលរួមពីរដ្ឋជាសមាជិកចំនួន ៤៧ របស់ក្រុមប្រឹក្សា។ ក្រុមការងារនេះជួបគ្នានៅក្នុងសម័យប្រជុំ ដែលមានរយៈពេលពីរសប្តាហ៍ចំនួនបីលើក ក្នុងមួយឆ្នាំៗ ដោយធ្វើការត្រួតពិនិត្យឡើងវិញលើរដ្ឋចំនួន ១៦ នៅក្នុងសម័យប្រជុំនីមួយៗ សរុបមានចំនួន ៤៨ រដ្ឋក្នុងមួយឆ្នាំ។ ក្រុមការងារនេះជួបជុំគ្នាជាលើកដំបូងនៅក្នុងខែមេសា ឆ្នាំ២០០៨។

ការសន្ទនាឆ្លើយឆ្លងរយៈពេលបីម៉ោង រវាងរដ្ឋដែលស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញ និងរដ្ឋជាសមាជិក និងរដ្ឋសង្កេតការណ៍របស់ក្រុមប្រឹក្សាត្រូវបានធ្វើឡើង។ នៅក្នុងអំឡុងពេលនៃកិច្ចសន្ទនានេះ រដ្ឋជាសមាជិក និងរដ្ឋសង្កេតការណ៍ មានពេលវេលាពីរម៉ោងដើម្បីសួរសំណួរ និងផ្តល់អនុសាសន៍ដល់រដ្ឋដែលស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញ។ បន្ទាប់មកទៀត រដ្ឋដែលស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញមានពេលវេលាចំនួនមួយម៉ោង ដើម្បីធ្វើបទបង្ហាញដល់ក្រុមការងារអំពីព័ត៌មានដែលខ្លួនបានរៀបចំសម្រាប់ត្រួតពិនិត្យឡើងវិញលើខ្លួន ដើម្បីឆ្លើយតបទៅនឹងសំណួរ និងអនុសាសន៍ដែលត្រូវបានធ្វើឡើងដោយរដ្ឋនានា មុន និងនៅក្នុងអំឡុងពេលនៃកិច្ចសន្ទនាឆ្លើយឆ្លង និងដើម្បីធ្វើសេចក្តីសង្កេតសន្និដ្ឋាននៅចុងបញ្ចប់នៃដំណើរការត្រួតពិនិត្យឡើងវិញនេះ[124]។

**អង្គការមិនមែនរដ្ឋាភិបាល ក្នុងឋានៈពិគ្រោះយោបល់ជាមួយ ECOSOC អាចចូលរួមក្នុងសម័យប្រជុំរបស់ក្រុមការងារទទួលបន្ទុក UPR ប៉ុន្តែមិនមានតួនាទីអ្វីនៅក្នុងកិច្ចសន្ទនាឆ្លើយឆ្លងនោះទេ។**

| |
|---|
| i. សម្រាប់ព័ត៌មានដែលត្រូវបានធ្វើបច្ចុប្បន្នភាពជាទៀតទាត់ស្តីពីសម័យប្រជុំរបស់ក្រុមការងារដែលរួមមាន ឯកសារផ្តល់ព័ត៌មានសម្រាប់អង្គការមិនមែនរដ្ឋាភិបាលផងដែរ សូមចូលមើលផ្នែករបស់ UPR នៃគេហទំព័ររបស់ OHCHR។ |

| |
|---|
| i. សម្រាប់ព័ត៌មានបន្ថែមស្តីពី **ឋានៈពិគ្រោះយោបល់ជាមួយនឹង ECSOC** សូមចូលមើលគេហទំព័ររបស់ផ្នែកកិច្ចការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិ។ |

---

[124] សូមមើល "ទម្រង់បែបបទ និងការអនុវត្តសម្រាប់ដំណើរការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល"-ឯកសារលេខ A/HCR/PRST/8/1 ។

## ក្រុមត្រីភាគី

ក្រុមអ្នករាយការណ៍បីរូប ("ក្រុមត្រីភាគី") សម្របសម្រួលដល់ការត្រួតពិនិត្យឡើងវិញលើរដ្ឋនីមួយៗ។ ក្រុមត្រីភាគីខុសៗគ្នាត្រូវបានបង្កើតឡើងសម្រាប់ការត្រួតពិនិត្យឡើងវិញលើរដ្ឋនីមួយៗ ដោយមានសមាជិកក្រុមត្រីភាគី (ដែលត្រូវបានជ្រើសរើសចេញពីក្រុមប្រចាំតំបន់ខុសៗគ្នារបស់អង្គការសហប្រជាជាតិ) ដែលត្រូវបានជ្រើសរើសតាមរយៈការចាប់ឆ្នោតពីក្នុងចំណោមរដ្ឋជាសមាជិករបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស[125]។ OHCHR ផ្តល់ជំនួយដល់សមាជិកក្រុមត្រីភាគីនៅក្នុងការបំពេញតួនាទីរបស់ពួកគេ។

រដ្ឋទាំងឡាយមានឱកាសលើកឡើងនូវសំណួរ/បញ្ហានានាជាលាយលក្ខណ៍អក្សរស្តីពីរដ្ឋដែលស្ថិតក្រោមការត្រួតពិនិត្យឡើងវិញ មុនពេលដំណើរការត្រួតពិនិត្យឡើងវិញរបស់គេ[126]។ ក្រុមត្រីភាគីទទួលខុសត្រូវចំពោះការទទួលសំណួរ/បញ្ហានានារបស់គេ និងប្រមូលចងក្រងវាជាក្រុមប្រសិនបើក្រុម[127]ត្រីភាគីនេះសម្រេចដូច្នេះ។ បន្ទាប់មក ក្រុមត្រីភាគីផ្ញើសំណួរ/បញ្ហានានាទៅលេខាធិការដ្ឋានរបស់ UPR ដែលបន្ទាប់មកទៀតផ្ញើវាទៅរដ្ឋដែលស្ថិតនៅក្រោមការពិនិត្យឡើងវិញ ដោយមិនឲ្យហួសពី១០ ថ្ងៃធ្វើការ មុនពេលដំណើរការត្រួតពិនិត្យឡើងវិញលើរដ្ឋនោះ។ សំណួរ/បញ្ហានានាក៏ត្រូវបានចែកផ្សាយក្នុងចំណោមរដ្ឋជាសមាជិក និងរដ្ឋសង្កេតការណ៍របស់ក្រុមប្រឹក្សាផងដែរ។

# ៣. ឯកសារលទ្ធផលរបស់ក្រុមការងារ ស្តីពីរដ្ឋដែលស្ថិតក្រោមការត្រួតពិនិត្យឡើងវិញ

[125] រដ្ឋដែលស្ថិតក្រោមការត្រួតពិនិត្យឡើងវិញ អាចស្នើថា សមាជិកម្នាក់ក្នុងចំណោមសមាជិកទាំងបីគួរតែមកពីក្រុមប្រចាំតំបន់ផ្ទាល់របស់គេ និងក៏អាចស្នើសុំផងដែរនូវការជំនួសមួយបានតែម្តងគត់។ សមាជិកក្រុមត្រីភាគី ក៏អាចស្នើសុំផងដែរឲ្យត្រូវបានរួចពីការចូលរួមនៅក្នុងដំណើរការត្រួតពិនិត្យឡើងវិញជាក់លាក់។

[126] សំណួរ/បញ្ហាទាំងនេះត្រូវបានផ្ញើទៅកាន់ក្រុមត្រីភាគី និងគួរតែត្រូវបានប្រើប្រាស់ដោយឈរលើមូលដ្ឋានភាគច្រើននៅលើឯកសាររបស់ UPR។

[127] ក្នុងការធ្វើដូច្នេះ ក្រុមត្រីភាគីមិនត្រូវប្តូរអត្ថន័យរបស់សំណួរ/បញ្ហា តាមរបៀបណាមួយទេ និងត្រូវតែបញ្ឈប់ការវាយតម្លៃសំណួរ/បញ្ហា ឬស្ថានភាពសិទ្ធិមនុស្ស នៅក្នុងរដ្ឋដែលស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញនោះ។

បន្ទាប់ពីកិច្ចសន្ទនាឆ្លើយឆ្លងស្តីពីរដ្ឋនីមួយៗ ក្រុមត្រីភាគីដែលត្រូវបានចាត់តាំងនោះ សម្របសម្រួលការរៀបចំឯកសារលទ្ធផល (របាយការណ៍) ស្តីពីការត្រួតពិនិត្យឡើងវិញ ដោយមានជំនួយពីលេខាធិការដ្ឋាននៃ UPR និងការចូលរួមពាក់ព័ន្ធយ៉ាងពេញលេញរបស់រដ្ឋដែលត្រូវបានត្រួតពិនិត្យឡើងវិញ។ ក្រុមការងារបែងចែកពេលវេលាជាអតិបរមា ៣០នាទី សម្រាប់ការពិចារណា និងការអនុម័តលើឯកសារលទ្ធផលនីមួយៗ ដោយមិនឲ្យលើសពី ៤៨ម៉ោង បន្ទាប់ពីការត្រួតពិនិត្យឡើងវិញ។ របាយការណ៍ប្រចាំប្រទេសរបស់ក្រុមការងារ ត្រូវបានអនុម័ត *ដោយសុំការឯកភាព* ដោយទុករយៈពេលពីរសប្តាហ៍សម្រាប់រដ្ឋនានាធ្វើការផ្លាស់ប្តូរយោបល់លើសេចក្តីថ្លែងការណ៍ផ្ទាល់របស់ខ្លួន។

ឯកសារលទ្ធផល រួមបញ្ចូលទាំងសេចក្តីសង្ខេបកិច្ចដំណើរការនីតិវិធីត្រួតពិនិត្យឡើងវិញ សេចក្តីសន្និដ្ឋាន និង/ឬ អនុសាសន៍ និងការប្តេជ្ញាចិត្ត និងការសន្យាដោយស្ម័គ្រចិត្តណាមួយ ដែលត្រូវបានធ្វើឡើងដោយរដ្ឋដែលស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញនោះ។

រដ្ឋដែលត្រូវបានត្រួតពិនិត្យឡើងវិញនីមួយៗ ទទួលបានឱកាសដើម្បីបង្ហាញថាតើខ្លួនគាំទ្រដល់សេចក្តីសន្និដ្ឋាន/អនុសាសន៍ ដែលត្រូវបានបញ្ចូលទៅក្នុងឯកសារលទ្ធផលដែរឬអត់។ គេអាចធ្វើកិច្ចការនេះ៖

- នៅក្នុងអំឡុងពេលនៃកិច្ចប្រជុំរបស់ក្រុមការងារ។
- នៅចន្លោះពេលនៃសម័យប្រជុំរបស់ក្រុមការងារ និងសម័យប្រជុំបន្ទាប់របស់ក្រុមប្រឹក្សា ឬ
- នៅក្នុងអំឡុងពេលនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ដើម្បីអនុម័តឯកសារលទ្ធផលរបស់ក្រុមការងារ។

អនុសាសន៍ដែលត្រូវបានគាំទ្រដោយរដ្ឋនោះ ត្រូវបានកំណត់បែបនោះនៅក្នុងឯកសារលទ្ធផល។ អនុសាសន៍ដែលមិនត្រូវបានគាំទ្រដោយរដ្ឋនោះ ត្រូវបានកត់សម្គាល់ទុកនៅក្នុងឯកសារលទ្ធផល រួមជាមួយនឹងសេចក្តីសង្កេតដែលរដ្ឋនោះអាចមានលើអនុសាសន៍ទាំងនោះ។

## ៤. ការអនុម័តឯកសារលទ្ធផលដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស

កាលណាត្រូវបានអនុម័តដោយក្រុមការងារទទួលបន្ទុក UPR ភ្លាម របាយការណ៍ស្តីពីប្រទេសដែលត្រូវបានត្រួតពិនិត្យឡើងវិញនីមួយៗត្រូវបានបញ្ជូនទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស។ តាមធម្មតា ក្រុមប្រឹក្សានេះពិចារណា និងអនុម័តឯកសារលទ្ធផលទាំងនេះនៅក្នុងសម័យប្រជុំធម្មតារបស់ខ្លួន ដោយផ្តល់ពេលវេលារហូតដល់ទៅមួយម៉ោងសម្រាប់ឯកសារលទ្ធផលនីមួយៗ។

ដោយអនុលោមតាមសេចក្ដីសម្រេចលេខ ៥/១ មុនពេលដែលឯកសារលទ្ធផលនីមួយត្រូវបាន អនុម័តៈ

- រដ្ឋដែលត្រូវបានត្រួតពិនិត្យឡើងវិញ ត្រូវបានផ្ដល់ឱកាសដើម្បីបង្ហាញអំពីមតិយោបល់របស់ខ្លួនលើសេចក្ដីសន្និដ្ឋាន/អនុសាសន៍ ការសន្យា និងការប្ដេជ្ញាចិត្តដោយស្ម័គ្រចិត្ត និងដើម្បីបង្ហាញអំពីចម្លើយទៅនឹងសំណួរ ឬបញ្ហាដែលមិនត្រូវបានដោះស្រាយពេញលេញនៅក្នុងអំឡុងពេលនៃកិច្ចសន្ទនាដែលមានលក្ខណៈទំនាក់ទំនងគ្នាទៅវិញទៅមករបស់ក្រុមការងារ។
- រដ្ឋដែលត្រូវបានត្រួតពិនិត្យឡើងវិញ និងរដ្ឋសមាជិក និងរដ្ឋសង្កេតការណ៍របស់ក្រុមប្រឹក្សាត្រូវបានផ្ដល់ឱកាសដើម្បីសម្ដែងមតិយោបល់របស់គេលើលទ្ធផល និង
- ភាគីពាក់ព័ន្ធដែលពាក់ព័ន្ធផ្សេងទៀត (ក្នុងនោះរួមមាន ស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹង ECSOC) ត្រូវបានផ្ដល់នូវឱកាសដើម្បីធ្វើសេចក្ដីសង្កេតទូទៅ។

នៅពេលអនុម័តឯកសារលទ្ធផល ក្រុមប្រឹក្សាក៏សម្រេចផងដែរថាតើ និងនៅពេលណាដែលការតាមដានបន្តជាក់លាក់ទៅនឹងការត្រួតពិនិត្យឡើងវិញមានលក្ខណៈចាំបាច់ដែរឬអត់។

## ៥. ការបន្តតាមដានចំពោះការត្រួតពិនិត្យឡើងវិញ

សេចក្ដីសន្និដ្ឋាន/អនុសាសន៍ដែលត្រូវបានបញ្ចូលទៅក្នុងឯកសារលទ្ធផលដែលទទួលបានការគាំទ្ររបស់រដ្ឋដែលត្រូវបានត្រួតពិនិត្យឡើងវិញ មានតួនាទីជាមូលដ្ឋានសម្រាប់ការបន្តតាមដានរបស់ UPR។

ជាបឋម វាជាការទទួលខុសត្រូវរបស់រដ្ឋដែលត្រូវបានត្រួតពិនិត្យឡើងវិញចំពោះការអនុវត្តលទ្ធផលរបស់ UPR (ក្នុងនោះរួមមាន សេចក្ដីសន្និដ្ឋាន និងអនុសាសន៍ និងការសន្យា និងការប្ដេជ្ញាចិត្តដោយស្ម័គ្រចិត្តផងដែរ)។ ទោះជាយ៉ាងណាក៏ដោយ **សេចក្ដីសម្រេចចិត្តលេខ ៥/១ ចែងថា ភាគីពាក់ព័ន្ធដែលពាក់ព័ន្ធផ្សេងទៀត រួមមាន តួអង្គសង្គមស៊ីវិលផងដែរ ក៏មានតួនាទីអនុវត្តផងដែរ។** សហគមន៍អន្តរជាតិជួយដល់រដ្ឋទាំងឡាយឲ្យអនុវត្តលទ្ធផលនៃការត្រួតពិនិត្យឡើងវិញទាក់ទងនឹងការកសាងសមត្ថភាព និងជំនួយបច្ចេកទេសនានា តាមរយៈការពិគ្រោះយោបល់ជាមួយនឹងរដ្ឋទាំងនោះ និងដោយមានការយល់ព្រមរបស់រដ្ឋទាំងនោះ។

ខួបនៃការត្រួតពិនិត្យឡើងវិញលើកក្រោយនឹងផ្ដោតជាអាទិ៍ទៅលើ ការអនុវត្តអនុសាសន៍របស់រដ្ឋនីមួយៗ និងដើម្បីសម្រេចគោលដៅនេះ ក្រុមប្រឹក្សាអាចដោះស្រាយតាមការចាំបាច់ ករណីនានា

ដែលគ្មានកិច្ចសហការដែលមានលក្ខណៈរឹងត្អឹងជាមួយនឹងយន្តការ UPR នេះ ក្នុងករណីដែលខ្លួនបាន ប្រើប្រាស់អស់នូវកិច្ចខិតខំប្រឹងប្រែងទាំងអស់ ដើម្បីជំរុញលើកទឹកចិត្តដល់រដ្ឋឲ្យធ្វើសហប្រតិបត្តិការ ជាមួយនឹងខ្លួន។

# ដំណើការ UPR

**ក. ការរៀបចំព័ត៌មានសម្រាប់ការត្រួតពិនិត្យឡើងវិញ**

រួមមាន៖

- ព័ត៌មានរបស់រដ្ឋ រួមមានតាមរយៈការពិគ្រោះយោបល់ដ៏ទូលំទូលាយ (របាយការណ៍ជាតិ)។
- កម្រងព័ត៌មានរបស់អង្គការសហប្រជាជាតិដែលត្រូវបានរៀបចំដោយ OHCHR។
- សេចក្តីសង្ខេបឯកសារស្នើសុំពិនិត្យរបស់អ្នកពាក់ព័ន្ធ (ដែលត្រូវបានរៀបចំដោយ OHCHR)។

- **ខ. ក្រុមការងារទទួលបន្ទុក UPR**
- ជួបប្រជុំគ្នានៅទីក្រុងហ្សឺណែវសម្រាប់វគ្គប្រជុំពេញអង្គដែលមានរយៈពេលពីរសប្តាហ៍ចំនួនបីលើករាងរាល់ឆ្នាំ។ ត្រួតពិនិត្យលើរដ្ឋចំនួន ១៦ ក្នុងមួយវគ្គប្រជុំពេញអង្គ (៤៨ រដ្ឋក្នុងមួយឆ្នាំ)។
- កិច្ចសន្ទនាដែលមានលក្ខណៈទំនាក់ទំនងគ្នាទៅវិញទៅមកដែលត្រូវបានរៀបចំឡើងជាមួយនឹងរដ្ឋដែលស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញ។
- អនុម័ត*ដោយការសុំការឯកភាព*លើរបាយការណ៍ដែលបានរួមបញ្ចូលអនុសាសន៍ សេចក្តីសន្និដ្ឋាន និងការសន្យាដោយស្ម័គ្រចិត្ត។
- រដ្ឋដែលត្រូវបានត្រួតពិនិត្យបង្ហាញនៅក្នុងដំណាក់កាលនេះនៅពេលក្រោយ (នៅពេលចុងក្រោយបំផុតនៅក្នុងអំឡុងពេលវគ្គប្រជុំពេញអង្គធម្មតា)

## ខួបបួនឆ្នាំ

**ឃ. ការអនុវត្តលទ្ធផល**

- ការទទួលខុសត្រូវរបស់រដ្ឋដែលពាក់ព័ន្ធ និងតាមការចាំបាច់ អ្នកពាក់ព័ន្ធដែលពាក់ព័ន្ធផ្សេងទៀត។
- សហគមន៍អន្តរជាតិដើម្បីជួយដល់ការកសាងសមត្ថភាព និងជំនួយបច្ចេកទេស។
- ក្រុមប្រឹក្សាសិទ្ធិមនុស្ស បន្ទាប់ពីប្រើប្រាស់អស់កិច្ចខិតខំប្រឹងប្រែងផ្សេងទៀតទាំងអស់ អាចដោះស្រាយបញ្ហាគ្មានកិច្ចសហប្រតិបត្តិការដែលមានលក្ខណៈរឹងត្អឹងជាមួយនឹង UPR។

**គ. វគ្គប្រជុំពេញអង្គធម្មតារបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស**

- ក្រុមប្រឹក្សាពិចារណាលើឯកសារនីមួយៗក្នុងរយៈពេលមួយម៉ោង។
- រដ្ឋដែលត្រូវបានត្រួតពិនិត្យឡើងវិញ រដ្ឋជាសមាជិក និងរដ្ឋសង្កេតការណ៍របស់ក្រុមប្រឹក្សានិងអ្នកពាក់ព័ន្ធផ្សេងទៀតត្រូវបានផ្តល់នូវឱកាសដើម្បីសម្តែងមតិយោបល់ មុនពេលអនុម័តលើឯកសារលទ្ធផល។
- ឯកសារលទ្ធផលត្រូវបានអនុម័តដោយក្រុមប្រឹក្សានេះ។

វិធីចូលរួមជាមួយនឹងយន្តយន្តការពិនិត្យរបាយការណ៍ជាសាកលតាមកាលកំណត់

សង្គមស៊ីវិលមានតួនាទីសំខាន់ត្រូវបំពេញក្នុងដំណាក់កាលដែលពាក់ព័ន្ធនៃដំណើរការ UPR - - ក្នុងការរៀបចំឯកសារស្នើសុំពិនិត្យ សម្រាប់ការត្រួតពិនិត្យឡើងវិញ ការចូលរួមក្នុងដំណើរការត្រួតពិនិត្យឡើងវិញ និងដោយរួមចំណែកដល់ការអនុវត្តបន្តទៅនឹងការអនុវត្តធម្មតានូវអនុសាសន៍ និងសេចក្តីសន្និដ្ឋានរបស់ UPR។

## ក. ការធ្វើការងារជាមួយនឹងរដ្ឋទាំងឡាយដើម្បីរៀបចំរបាយការណ៍ជាតិ

សេចក្តីសម្រេចិត្តលេខ ៥/១ ជំរុញលើកទឹកចិត្តដល់រដ្ឋទាំងឡាយឲ្យរៀបចំព័ត៌មានដែលគេដាក់ជូនពិនិត្យសម្រាប់ការត្រួតពិនិត្យឡើងវិញរបស់ខ្លួន តាមរយៈដំណើរការពិគ្រោះយោបល់ដ៏ទូលំទូលាយថ្នាក់ជាតិ ជាមួយនឹងភាគីពាក់ព័ន្ធដែលពាក់ព័ន្ធផ្សេងទៀត។ នេះអាចរួមបញ្ចូល NHRI ក៏ដូចជាតំណាងសង្គមស៊ីវិល ដូចជា NGO អ្នកការពារសិទ្ធិមនុស្ស គ្រឹះស្ថានសិក្សាអប់រំ និងវិទ្យាស្ថានស្រាវជ្រាវ។

បទពិសោធន៍របស់ UPR រហូតមកទល់ពេលនេះបង្ហាញអំពីភាពផ្សេងៗគ្នានានានៃគំរូ "វិធីអនុវត្តត្រឹមត្រូវ" សម្រាប់កិច្ចសហប្រតិបត្តិការរបស់សង្គមស៊ីវិល និងរដ្ឋាភិបាលនៅក្នុងការរៀបចំរបាយការណ៍ជាតិ។

| ការរួមចំណែកដល់ការរៀបចំព័ត៌មានរបស់រដ្ឋ | | |
|---|---|---|
| នៅក្នុងដំណើរការត្រៀម ពាក់ពន្ធនឹងការត្រួតពិនិត្យឡើងវិញលើប្រ**ទេស្វីស**នៅក្នុងសម័យប្រជុំលើកទីពីររបស់ក្រុមការងារទទួលបន្ទុក UPR ក្នុងខែឧសភា ឆ្នាំ២០០៨ សម្ព័ន្ធភាពចម្រុះនៃអង្គការមិនមែនរដ្ឋាភិបាលដែលមានមូលដ្ឋាននៅក្នុងប្រទេសស្វីសចំនួន ៣២ បានជួបប្រជុំដើម្បីសម្រប សម្រួលដល់ការរៀចំឯកសារស្នើសុំពិនិត្យរបស់ភាគីពាក់ព័ន្ធ។ ដោយត្រូវបានសម្របសម្រួលដោយ អង្គការមិនមែរដ្ឋាភិបាលចំនួនបី (**អង្គការលើកលែងទោសផ្នែកស្វីស អង្គការយូមែនរ៉ាយស៍ និងមជ្ឈមណ្ឌលអប់រំ** | **និងគាំទ្រផ្នែកសិទ្ធិមនុស្សសម្រាប់យុវជន** (CODAP)) "សម្ព័ន្ធភាពចម្រុះនៃអង្គការមិនមែនរដ្ឋាភិបាល" បានរៀបចំ និងបញ្ជូនសេចក្ដីព្រាងដំបូងនៃឯកសារស្នើសុំ ពិនិត្យរបស់ខ្លួនទៅរដ្ឋាភិបាលស្វីស។<br><br>រដ្ឋាភិបាលសហព័ន្ធស្វីស បានចែករំលែកសេចក្ដីព្រាង របាយការណ៍ជាតិរបស់ខ្លួនជាមួយនឹង សម្ព័ន្ធ NGO និងបានអញ្ជើញសមាជិករបស់ខ្លួនឲ្យចូលរួមកិច្ចពិភាក្សារយៈពេលមួយថ្ងៃជាមួយរដ្ឋាភិបាល។ នៅក្នុងកិច្ចប្រជុំនោះ សម្ព័ន្ធភាពចម្រុះ ផ្ដល់នូវយោបល់ | សំខាន់ៗលើ សេចក្ដីព្រាងរបាយការណ៍ជាតិរបស់រដ្ឋាភិបាល និងបានបង្ហាញអនុសាសន៍ជាច្រើន។ អនុសាសន៍មួយចំនួនរបស់ សហព័ន្ធភាពចម្រុះ ត្រូវបានដាក់បញ្ចូលទៅក្នុងសំណៅចុងក្រោយនៃរបាយការណ៍ជាតិ ដែលត្រូវបានដាក់ជូនទៅ UPR ដោយរដ្ឋាភិបាលក៏បានឧទិសផងដែរនូវរបាយការណ៍មួយផ្នែករបស់ខ្លួនទៅលើការកំណត់ និងការដោះស្រាយកង្វល់ចម្បងបំផុតមួយចំនួន ដែលត្រូវបានលើកឡើងដោយសម្ព័ន្ធភាពចម្រុះនោះ។ |

## ខ. ឯកសារស្នើសុំពិនិត្យរបស់ភាគីពាក់ព័ន្ធ

ស្របតាមសេចក្តីសម្រេចិត្តលេខ ៥/១ ភាគីពាក់ព័ន្ធក៏ត្រូវបានអញ្ជើញផងដែរឲ្យដាក់ជូន ពិនិត្យនូវឯកសារស្នើសុំពិនិត្យឡើងវិញ សម្រាប់ការដាក់បញ្ចូលជាសក្ខានុពលទៅក្នុងសេចក្តី សង្ខបនៃឯសារស្នើសុំពិនិត្យរបស់ភាគីពាក់ព័ន្ធ ដែលត្រូវបានរៀបចំដោយ OHCHR។ សេចក្តី សង្ខេបនៃឯកសារស្នើរសុំពិនិត្យរបស់ភាគីពាក់ព័ន្ធ ដែលត្រូវបានរៀបចំដោយ OHCHR គឺជាឯកសារមួយក្នុងចំណោមឯកសារចំនួនបី ដែលការត្រួតពិនិត្យឡើងវិញផ្អែកលើជាមូលដ្ឋាន។

ឯកសារស្នើសុំពិនិត្យរបស់ភាគីពាក់ព័ន្ធ គួរតែរួមបញ្ចូលព័ត៌មានដែលគួរឲ្យជឿជាក់ និង ជឿទុកចិត្តបាន ស្តីពីរដ្ឋដែលស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញ។

OHCHR ធ្វើសេចក្តីយោងលើឯកសារស្នើសុំពិនិត្យរបស់ភាគីពាក់ព័ន្ធ ដែលត្រូវបានបញ្ចូលទៅក្នុងឯកសារសង្ខេប។ ជាងនេះទៅទៀត ឯកសារស្នើសុំពិនិត្យរបស់ភាគីពាក់ព័ន្ធត្រូវ បានរៀបចំឲ្យមានជាទម្រង់ច្បាប់ដើមដូចដែលត្រូវបានទទួល តាមរយៈផ្នែករបស់យន្តយន្តការពិនិត្យរបាយការណ៍ជាសាកលតាមកាលកំណត់នៃវិបសាយរបស់ OHCHR ។

| ការរៀបចំ និងការដាក់ជូនពិនិត្យនូវឯកសារស្នើសុំពិនិត្យរបស់ភាគីពាក់ព័ន្ធ ទៅការិយាល័យ OHCHR | | |
|---|---|---|
| ក្រុមការងារសិទ្ធិមនុស្ស (HRWG)-ឥណ្ឌូនេស៊ី ដែលជាសម្ព័ន្ធភាពចម្រុះនៃអង្គការសិទ្ធិមនុស្សរបស់ឥណ្ឌូនេស៊ី បានរួមចំណែកដល់ឯកសារស្នើសុំពិនិត្យរបស់ភាគីពាក់ព័ន្ធសម្រាប់ការត្រួតពិនិត្យឡើងវិញរបស់ប្រទេសឥណ្ឌូនេស៊ី នៅក្នុងសម័យប្រជុំលើកទីមួយរបស់ក្រុមការងារទទួលបន្ទុក UPR ក្នុងខែមេសា ឆ្នាំ២០០៨។ នៅក្នុងការរៀបចំឯកសារស្នើសុំពិនិត្យរបស់ខ្លួន HRWG បានអនុវត្តដំណើរ | ការ "ពីក្រោមឡើងលើ" ដោយអញ្ជើញអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយចំនួន ដែលធ្វើការងារលើបញ្ហាគោលនានា ដើម្បីពិភាក្សាអំពីយន្តការ UPR និងដើម្បីបង្កើតគម្រោង និងរចនាសម្ព័ន្ធសម្រាប់ឯកសារស្នើសុំពិនិត្យ។ បន្ទាប់ពីការប្រជុំមក NGO នីមួយៗត្រូវបានចាត់តាំងការទទួលខុសត្រូវសម្រាប់ការរៀបចំព័ត៌មានពាក់ព័ន្ធទៅនឹងផ្នែកជំនាញមួយ (ឬច្រើន) របស់ខ្លួន ចំណែកឯ HRWG វិញទទួលការខុសត្រូវលើផ្នែកពិនិត្យផ្ទៀងផ្ទាត់ចំពោះឯក | សារស្នើសុំពិនិត្យ ដោយបញ្ជូនឯកសារនោះទៅលេខាធិការដ្ឋានរបស់ UPR នៃការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)។HRWG-ឥណ្ឌូនេស៊ីក៏បានសហការជាមួយ Komnas HAM ដែលជាវិទ្យាស្ថានសិទ្ធិមនុស្សជាតិឥណ្ឌូនេស៊ីផងដែរ និងបានចូលរួមក្នុងកិច្ចសន្ទនាជាមួយនឹងក្រសួងការបរទេសឥណ្ឌូនេស៊ី ក្នុងការរៀបចំឯកសារស្នើសុំពិនិត្យរបស់ភាគីពាក់ព័ន្ធរបស់ខ្លួន។ |

## ទម្រង់ និងឯកសារស្នើសុំពិនិត្យ

*ភាគីពាក់ព័ន្ធត្រូវបានស្នើសុំឲ្យផ្តល់ដល់ OHCHR នូវឯកសារស្នើសុំពិនិត្យដែល៖*

- អនុវត្តតាមរចនាសម្ព័ន្ធនៃគោលការណ៍ណែនាំទូទៅ សម្រាប់ការរៀបចំព័ត៌មានតាម UPR ដែលមានចែងនៅក្នុង**សេចក្តីសម្រេចចិត្តលេខ ៦/១០២** របស់ក្រុមប្រឹក្សា (សូមមើលផ្នែកពីមុន)។
- មិនត្រូវលើសពី ៥ទំព័រ ឬ នៅក្នុងករណីសម្ព័ន្ធភាពចម្រុះនៃភាគីពាក់ព័ន្ធមានទំហំធំ ត្រូវមាន ១០ ទំព័រ។
- មានរយៈពេលអតិបរមា បួនឆ្នាំ។
- ត្រូវបានសរសេរជាភាសាផ្លូវការរបស់អង្គការសហប្រជាជាតិ ដូចជាភាសាអង់គ្លេស បារាំង ឬ អេស្ប៉ាញ។
- ផ្តល់នូវព័ត៌មានជាកថាខណ្ឌខ្លីៗលើទិសដៅ និងការងាររបស់អង្គភាព ដែលដាក់ជូនពិនិត្យឯកសារស្នើសុំពិនិត្យនោះ។
- មានទម្រង់ជាការងារធម្មតាដោយមានលេខកថាខណ្ឌ និងលេខទំព័រ។
- រួមបញ្ចូលកថាខណ្ឌនាំមុខ ដែលសង្ខេបអំពីចំណុចសំខាន់ៗ។
- បញ្ជាក់អំពីពាក្យគន្លឹះនានាដែលពាក់ព័ន្ធនឹងឯកសារស្នើសុំពិនិត្យ (ឧទាហរណ៍ពាក្យ អំពើហិង្សាក្នុងគ្រួសារ)។
- ជៀសវាងការផលិតឡើងវិញនូវសេចក្តីសង្កេតសន្និដ្ឋាន និងអនុសាសន៍របស់គណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស ឬនីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ទោះបីជាវាអាចសំដៅទៅលើកម្រិតនៃការអនុវត្តក៏ដោយ[66] និង
- ជាសវាងការដកស្រង់ពាក្យ ឬការបញ្ចូលជាឧបសម្ព័ន្ធនូវរបាយការណ៍ពីអង្គការផ្សេងទៀត។

សូមកត់សម្គាល់ថា៖

- ឯកសារស្នើសុំពិនិត្យដែលលើសពីការតម្រិត ៥ ឬ១០ ទំព័រ នឹងមិនត្រូវបានពិចារណាឡើយ។

---

[66] អនុសាសន៍ និងសេចក្តីសង្កេតរបស់ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស និងនីតិវិធីពិសេស ត្រូវបានដាក់បញ្ចូលទៅក្នុងកម្រងព័ត៌មានរបស់អង្គការសហប្រជាជាតិ ដែលត្រូវបានរៀបចំដោយ OHCHR។

- ឯកសារស្នើសុំពិនិត្យដែលត្រូវបានទទួលជាភាសាណាមួយក្រៅពីភាសាផ្លូវការមួយក្នុងចំណោមភាសាផ្លូវការចំនួនប្រាំមួយរបស់អង្គការសហប្រជាជាតិ នឹងមិនត្រូវបានពិចារណាឡើយ។
- ឯកសារស្នើសុំពិនិត្យណាដែលត្រូវបានដាក់ជូនពិនិត្យក្រោយកាលបរិច្ឆេទកំណត់ឈប់ទទួល នឹងមិនត្រូវបានពិចារណាឡើយ និង
- ឯកសារស្នើសុំពិនិត្យណាដែលមានពាក្យរំលោភបំពានជាក់ស្តែង (ឧទាហរណ៍ដូចជាការញុះញង់ឲ្យមានហិង្សា ភាសាដែលមានជាប់ជាមួយនូវការប្រកាន់ពូជសាសន៍) នឹងមិនត្រូវបានពិចារណាឡើយ។

i. តួអង្គសង្គមស៊ីវិលត្រូវបានជំរុញលើកទឹកចិត្តឲ្យមើលជាទៀតទាត់នូវផ្នែករបស់ UPR ក្នុងគេហទំព័ររបស់ OHCHR សម្រាប់ការលបរិច្ឆេទផុតកំណត់ទទួលឯកសារស្នើសុំពិនិត្យដែលមានលក្ខណៈជាក់លាក់ចំពោះសម័យប្រជុំនីមួយៗរបស់ក្រុមការងារ។ **តាមធម្មតាព័ត៌មានរបស់អ្នកពាក់ព័ន្ធគួរតែត្រូវបានដាក់ជូនពិនិត្យទៅ OHCHR ក្នុងរយៈពេលប្រាំពីរខែមុនពេលសម័យប្រជុំរបស់ក្រុមការងារ។**

តួអង្គសង្គមស៊ីវិលដែលមានបំណងចង់ដាក់ជូនពិនិត្យនូវព័ត៌មានសម្រាប់ការពិចារណា និងដែលអាចឲ្យ OHCHR ដាក់បញ្ចូលទៅក្នុងកម្រងព័ត៌មានរបស់អ្នកពាក់ព័ន្ធគួរតែផ្ញើវិភាគទានរួមចំណែករបស់ខ្លួនទៅ៖ **UPRsubmissions@ohchr.org** ។

ទោះបីជាតួអង្គសង្គមស៊ីវិលមិនត្រូវបានជំរុញលើកទឹកចិត្តឲ្យផ្ញើតាមទូរសារ ឬប៉ុស្តិ៍ប្រៃសណីយ៍នូវច្បាប់ចម្លងឯកសារស្នើសុំពិនិត្យរបស់ខ្លួនទៅលេខាធិការដ្ឋានរបស់ OHCHR ក៏ដោយ ប្រសិនបើមានការលំបាកផ្នែកបច្ចេកទេសជាមួយនឹងសារតាមអេឡិចត្រូនិចនោះ គេអាចផ្ញើឯកសារស្នើសុំពិនិត្យរបស់គេទៅលេខ +៤១ (0)២២ ៩១៧ ៩0 ១១។

តួអង្គសង្គមស៊ីវិលក៏ត្រូវបានជំរុញលើកទឹកចិត្ត ឲ្យមើល**គោលការណ៍ណែនាំបច្ចេកទេសសម្រាប់ការដាក់ជូនពិនិត្យនូវព័ត៌មានរបស់អ្នកពាក់ព័ន្ធផងដែរ។**

## គ. ការចូលរួមសម័យប្រជុំរបស់ក្រុមការងារទទួលបន្ទុកយន្តការពិនិត្យរបាយការណ៍ជាសាកលតាមកាលកំណត់

អង្គការមិនមែនរដ្ឋាភិបាល ក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹង ECOSOC កាលណាទទួលបានការអនុញ្ញាតនោះ អាចចូលរួមក្នុងសម័យប្រជុំរបស់ក្រុមការងារទទួលបន្ទុកការងារ UPR បាន ប៉ុន្តែមិនអាចធ្វើសេចក្តីថ្លែងការដោយផ្ទាល់មាត់នៅក្នុងកិច្ចប្រជុំរបស់ក្រុមការងារបានទេ។

> សម្រាប់ព័ត៌មានស្តីពីវិធីសុំការអនុញ្ញាតចូលរួមក្នុងសម័យប្រជុំរបស់ក្រុមការងារទទួលបន្ទុក **UPR** សូមចូលមើលគេហទំព័ររបស់ OHCHR។

## វគ្គផ្សព្វផ្សាយព័ត៌មាន

អង្គការមិនមែនរដ្ឋាភិបាល ក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹង ECOSOC នៅពេលដែលពួកគេទទួលបានការអនុញ្ញាតឲ្យចូលរួមក្នុងសម័យប្រជុំរបស់ក្រុមការងារភ្លាម អាចរៀបចំត្រៀមដើម្បីរៀបចំវគ្គផ្សព្វផ្សាយព័ត៌មាននៅក្នុងអំឡុងពេលនៃសម័យប្រជុំរបស់ក្រុមការងារ។
អង្គការមិនមែនរដ្ឋាភិបាលដែលចាប់អារម្មណ៍ក្នុងការរៀបចំវគ្គប្រជុំពេញអង្គបែបនេះ គួរទាក់ទងទៅលេខាធិការដ្ឋានរបស់ UPR។

## ឃ. ការចូលរួមសម័យប្រជុំរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស

អង្គការមិនមែនរដ្ឋាភិបាល ក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹង ECOSOC នៅពេលដែលពួកគេទទួលបានការអនុញ្ញាតភ្លាម អាចចូលរួមក្នុងសម័យប្រជុំធម្មតារបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ដែលនៅក្នុងនោះឯកសារលទ្ធផលរបស់ UPR ត្រូវបានពិចារណា និងអនុម័ត។

**អង្គការមិនមែនរដ្ឋាភិបាល ក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹង ECOSOC ត្រូវបានផ្តល់ឱកាសឲ្យធ្វើសេចក្តីសង្កេតទូទៅយ៉ាងសង្ខេប មុនក្រុមប្រឹក្សាសិទ្ធិមនុស្សអនុម័តលើឯកសារលទ្ធផល។**

> i. សម្រាប់ព័ត៌មានស្តីពីវិធីសុំការអនុញ្ញាតចូលរួមក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស សូមមើលជំពូក V (ក្រុមប្រឹក្សាសិទ្ធិមនុស្ស) នៃ*សៀវភៅណែនាំ*នេះ។

## ង. ការអនុវត្តបន្តនូវលទ្ធផលនៃការត្រួតពិនិត្យឡើងវិញ

សេចក្តីសម្រេចចិត្តលេខ ៥/១ ចែងថា ជាបឋមវាជាការទទួលខុសត្រូវរបស់រដ្ឋទាំងឡាយក្នុងការអនុវត្តលទ្ធផលនៃដំណើរការត្រួតពិនិត្យឡើងវិញរបស់គេ (ក្នុងនោះមានដូចជា សេចក្តីសន្និដ្ឋាន និងអនុសាសន៍ និងការសន្យា និងការប្តេជ្ញាចិត្តដោយស្ម័គ្រចិត្ត)។ **សេចក្តីសម្រេចចិត្តលេខ ៥/១ ក៏ចែងផងដែរថា ភាគីពាក់ព័ន្ធដែលពាក់ព័ន្ធផ្សេងទៀត រួមមានតួអង្គសង្គមស៊ីវិលផងដែរ មានតួនាទីត្រូវបំពេញនៅក្នុងការអនុវត្តនេះ។**

តួអង្គសង្គមស៊ីវិល រួមមានអង្គការមិនមែនរដ្ឋាភិបាល គ្រឹះស្ថានសិក្សាអប់រំ ប្រព័ន្ធផ្សព្វផ្សាយសហជីព និងក្រុមអ្នកវិជ្ជាជីវៈ អាចអនុវត្តបន្តនូវលទ្ធផលរបស់ UPR តាមវិធីមួយចំនួនដូចខាងក្រោម៖

- ការធ្វើការងារជាមួយនឹងស្ថាប័នជាតិ រួមមាន (រដ្ឋាភិបាល រដ្ឋសភា តុលាការ និងស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស (NHRI) ដើម្បីជួយដល់រដ្ឋឲ្យបំពេញកាតព្វកិច្ចរបស់ខ្លួន។ សង្គមស៊ីវិល ជារឿយៗ បំពេញមុខងារជាកាតាលីករដើម្បីលើកកម្ពស់កំណែទម្រង់ច្បាប់ជាតិ និងបង្កើតគោលនយោបាយជាតិ។ សង្គមស៊ីវិល ក៏អាចប្រើប្រាស់លទ្ធផលរបស់ UPR ជាមូលដ្ឋានសម្រាប់ការសន្ទនាជាមួយនឹងស្ថាប័នរដ្ឋ និងសម្រាប់កំណត់កម្មវិធីសកម្មភាពផ្ទាល់របស់ខ្លួន។
- ការពិនិត្យតាមដានស្ថានភាពសិទ្ធិមនុស្ស និងជំហានដែលត្រូវបានប្រកាន់យកនៅក្នុងមូលដ្ឋានដើម្បីអនុវត្តលទ្ធផលរបស់ UPR។
- លើកកម្ពស់ការយល់ដឹងអំពី UPR លទ្ធផលដែលរដ្ឋទាំងឡាយត្រូវបានតម្រូវឲ្យអនុវត្ត និងថាតើលទ្ធផលអាចត្រូវបានប្រើប្រាស់ដើម្បីធ្វើឲ្យប្រសើរឡើងនូវការទទួលបានសិទ្ធិមនុស្សនៅក្នុងប្រទេសដោយរបៀបណា។ នេះអាចត្រូវបានធ្វើឡើងតាមរយៈការរៀបចំកិច្ចពិភាក្សាប្រធានបទទូទៅ កិច្ចប្រជុំតុមូល សិក្ខាសាលាធម្មតា និងសិក្ខាសាលាពិភាក្សា ការបកប្រែនិងការបោះពុម្ពផ្សាយលទ្ធផលរបស់ UPR និងដោយលើកកម្ពស់ការយល់ដឹងអំពីលទ្ធផលរបស់ UPR និងការធ្វើការងារជាមួយ NHRI និងប្រព័ន្ធផ្សព្វផ្សាយជាតិ និងដោយលើកកម្ពស់ការយល់ដឹងអំពីលទ្ធផលរបស់ UPR នៅក្នុងចំណោមសាធារណជនទូទៅ និងសង្គមស៊ីវិល។
- ការចូលរួមពាក់ព័ន្ធជាមួយនឹងស្ថាប័នជាតិ ឆ្ពោះទៅរកការរៀបចំព័ត៌មានសម្រាប់ការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលបន្ទាប់ទៀត និង

- កិច្ចសហការជាមួយនឹងតួអង្គសង្គមស៊ីវិលផ្សេងទៀត ក្នុងការរៀបចំ និងការដាក់ជូនពិនិត្យទៅកាន់ OHCHR នូវព័ត៌មានសម្រាប់ការអនុវត្តបន្តស្តីពីការអនុវត្តលទ្ធផលរបស់ UPR។

| ការអនុវត្តបន្តនូវលទ្ធផលរបស់ UPR | | |
|---|---|---|
| *ការអនុវត្តបន្តនូវរបាយការណ៍ដែលត្រូវបានអនុម័តដោយក្រុមការងារទទួលបន្ទុក UPR*<br>បន្ទាប់ពីដំណើរការត្រួតពិនិត្យឡើងវិញ និងការអនុម័តរបាយការណ៍ស្តីពីប្រទេសប្រេស៊ីលរបស់ក្រុមការងារនៅក្នុងខែ មេសា ឆ្នាំ២០០៨ រួចមក Conectas ដែលជាអង្គការសិទ្ធិមនុស្សរបស់ប្រេស៊ីល បានទទួលអនុវត្តសកម្មភាពដូចតទៅះ<br>• អង្គការនេះបកប្រែអនុសាសន៍ និងការប្តេជ្ញាចិត្តដោយស្ម័គ្រចិត្តដែលត្រូវបានបញ្ចូលក្នុងរបាយការណ៍ របស់ក្រុមការងារទៅ | • ដោយសហការជាមួយនឹងសម្ព័ន្ធភាពចម្រុះនៃអង្គការមិនមែនរដ្ឋាភិបាលរបស់ប្រេស៊ីល (**គណៈកម្មាធិការប្រេស៊ីលទទួលបន្ទុកសិទ្ធិមនុស្ស និងគោលនយោបាយបរទេស**) Connectas បានរៀបចំកិច្ចពិភាក្សាជាសាធារណៈស្តីពីដំណើរការ UPR ជាមួយនឹងគណកម្មការសិទ្ធិមនុស្សរបស់សភាប្រេស៊ីល។ ផ្នែកទាំងឡាយនៃកម្មវិធីផ្សាយលើគេហទំព័រស្តីពីដំណើរការត្រួតពិនិត្យឡើងវិញលើប្រទេសប្រេស៊ីលត្រូវបានបង្ហាញនៅក្នុងកិច្ចប្រជុំ។<br>*ការអនុវត្តបន្តនូវរបាយការណ៍នៃដំណើរការ UPR ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស* | • បានអនុវត្តបន្តនូវអនុសាសន៍ និងការប្តេជ្ញាចិត្តដោយស្ម័គ្រចិត្តរបស់ UPR ដោយបង្កើតឡើងនូវភាពជាដៃគូជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការងារលើបញ្ហាជាក់លាក់ ដើម្បីវាយតម្លៃវឌ្ឍនភាពរបស់ប្រទេសប្រេស៊ីល ក្នុងការអនុវត្តលទ្ធ UPR និង<br>• បានធ្វើការជាមួយរដ្ឋាភិបាល នៅក្នុងដំណើរការដែលកំពុងតែបន្តដើម្បីកំណត់អំពីវិធានការ និងគោលនយោបាយពិតជាក់ស្តែងឆ្ពោះទៅកាន់ការអនុវត្តអនុសាសន៍របស់ UPR និងការសម្រេចបាននូវការប្តេជ្ញាចិត្តដោយស្ម័គ្រចិត្ត។<br>Conectas បានចែករំលែកផងដែរនូវបទពិសោធន៍របស់ខ្លួនជាមួយនឹងអង្គការដៃគូនៅក្នុងប្រទេសអាហ្សង់ទីន ប៉េរូ ហ្វីលីពីន និងអាហ្វ្រិចខាងត្បូង ដើម្បីរួមចំណែកដល់ការត្រួតពិនិត្យឡើងវិញលើប្រទេសទាំងនេះ។ |

| | | |
|---|---|---|
| ជាភាសា ប៉ុទុយហ្គាល់។<br>• អង្គការនេះបានវិភាគខ្លឹមសារ នៃរបាយការណ៍របស់ក្រុមការងារ សេចក្តីសន្និដ្ឋានដែលខ្លឹមសារ របស់វាត្រូវបានជម្រាបជូនទៅ រដ្ឋាភិបាលប្រេស៊ីល និងត្រូវបានកំណត់ដោយ Conectas នៅក្នុង បទអន្តរាគមន៍ដោយផ្ទាល់មាត់ ដែលត្រូវបានធ្វើឡើងនៅក្នុង សម័យប្រជុំទីប្រាំបីរបស់ក្រុមប្រឹក្សា និង | ចាប់តាំងពីមានការអនុម័តលើ របាយការណ៍ចុងក្រោយរបស់ក្រុម ប្រឹក្សាសិទ្ធិមនុស្សមកលើប្រទេសប្រេស៊ីល Conectas៖ | |

## ធនធានរបស់ OHCHR

## គេហទំព័ររបស់យន្តការពិនិត្យរបាយការណ៍ជាសាកលតាមកាលកំណត់

តួអង្គសង្គមស៊ីវិលត្រូវបានជំរុញលើកទឹកចិត្តឲ្យមើលជាប្រចាំនូវផ្នែករបស់ UPR ក្នុងគេហទំព័ររបស់ OHCHR សម្រាប់ព័ត៌មានបច្ចុប្បន្នភាព និងព័ត៌មានស្តីពីវគ្គប្រជុំពេញអង្គរបស់ក្រុមការងារ។

គេហទំព័ររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស

តួអង្គសង្គមស៊ីវិលត្រូវបានជំរុញលើកទឹកចិត្តឲ្យមើលជាប្រចាំនូវផ្នែករបស់ក្រុមប្រឹក្សាក្នុងគេហទំព័ររបស់ OHCHR សម្រាប់ព័ត៌មានថ្មីៗបច្ចុប្បន្នភាព និងនិងព័ត៌មានស្ដីពីវគ្គប្រជុំពេញអង្គរបស់ក្រុមប្រឹក្សា។ តាមធម្មតា ព័ត៌មានជាក់លាក់ស្ដីពីសម័យប្រជុំត្រូវបានដាក់ផ្សាយនៅក្នុងគេហទំព័រក្នុងរយៈពេលពីរសប្ដាហ៍មុនសម័យប្រជុំធម្មតានីមួយៗ។

## ប្រព័ន្ធ Extranet

ប្រព័ន្ធ Extranet ត្រូវបានភ្ជាប់ទាំនាក់ទំនងទៅនឹងគេហទំព័រវិបសាយរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ វាមានផ្ទុកទៅដោយគេហទំព័ររបស់ UPR ដោយមានព័ត៌មានជាក់លាក់ចំពោះសម័យប្រជុំនីមួយៗរបស់ក្រុមការងារ ក្នុងនោះរួមមានៈ

- រដ្ឋ (ដែលត្រូវបាន) ត្រួតពិនិត្យឡើងវិញនៅក្នុងសម័យប្រជុំ។
- ឯកសារដែលដំណើរការត្រួតពិនិត្យឡើងវិញបានពឹងផ្អែកលើជាមូលដ្ឋាន។
- បញ្ហាដែលត្រូវបានដាក់ជូនពិនិត្យទៅរដ្ឋទាំងឡាយ ដែលស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញដោយរដ្ឋជាសមាជិករបស់ក្រុមប្រឹក្សា មុនពេលដំណើរការត្រួតពិនិត្យឡើងវិញ។
- សេចក្ដីថ្លែងការណ៍ផ្ទាល់មាត់ដែលបានធ្វើឡើងដោយរដ្ឋជាសមាជិក និងរដ្ឋសង្កេតការណ៍នៅក្នុងដំណើរការត្រួតពិនិត្យឡើងវិញ និង
- ឯកសារលទ្ធផល ដែលត្រូវបានអនុម័តដោយក្រុមការងារ។

| |
|---|
| i. ដើម្បីចូលមើលគេហទំព័រប្រព័ន្ធ Extranet ដែលត្រូវបានការពារដោយលេខកូដសម្ងាត់នោះ សូមបំពេញទម្រង់តាមបណ្ដាញអេឡិចត្រូនិចដែលមាន។ នៅពេលដែលបំពេញរួច អ្នកនឹងទទួលបានឈ្មោះអ្នកប្រើប្រាស់ និងលេខកូដសម្ងាត់តាមរយៈអ៊ីម៉ែល។ |

## កម្មវិធីផ្សាយនៅលើគេហទំព័រ

សម័យប្រជុំរបស់ក្រុមការងារអាចមើលដោយផ្ទាល់បាននៅក្នុងកម្មវិធីផ្សាយលើគេហទំព័ររបស់ក្រុមប្រឹក្សាសិទ្ធមនុស្ស។ ទីកន្លែងកម្មវិធីផ្សាយលើគេហទំព័រក៏មានវីដេអូដែលបានរក្សាទុកស្ដីពីសម័យប្រជុំមុនៗរបស់ក្រុមប្រឹក្សាផងដែរ។ ដើម្បីមើលកម្មវិធីផ្សាយលើគេហទំព័រ លោកអ្នកចាំបាច់ត្រូវទាញយកកម្មវិធីសមស្របមកប្រើ។

i. សេវាកម្មកម្មវិធីផ្សាយលើគេហទំព័រ អាចរកបានពីគេហទំព័ររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស
នៃគេហទំព័ររបស់ OHCHR។

| អ្នករាយការណ៍ពិសេសទទួលបន្ទុកលើស្ថានភាពរបស់អ្នកការពារសិទ្ធិមនុស្ស | | |
|---|---|---|
| **តើអ្នករាយការណ៍ពិសេសទទួលបន្ទុកលើស្ថានភាពរបស់អ្នកការពារសិទ្ធិមនុស្សជានរណា?**<br>អាណត្តិការងារនៃ**អ្នករាយការណ៍ពិសេសទទួលបន្ទុកលើស្ថានភាពរបស់អ្នកការពារសិទ្ធិមនុស្ស** (អតីតអ្នករាយការណ៍ពិសេសនៃអគ្គលេខាធិការទទួលបន្ទុកលើស្ថានភាពរបស់អ្នកការពារសិទ្ធិមនុស្ស) ត្រូវបានបង្កើតឡើងជាយន្តការពិសេសមួយនៅក្នុងឆ្នាំ២០០០ តាមរយៈ**សេចក្ដីសម្រេចចិត្តលេខ ២០០០/៦១**។ ការបង្កើតអាណត្តិការងារនេះគឺជាការទទួលស្គាល់តួនាទីរបស់អ្នកការពារសិទ្ធិមនុស្សដ៏សំខាន់ និងជារឿយៗមានភាពគ្រោះថ្នាក់។ "ការការពារ" អ្នកការពារសិទ្ធិមនុស្សគឺជាការព្រួយបារម្ភធំរបស់អ្នករាយការណ៍ពិសេសដោយរាប់បញ្ចូលទាំងការការពារអ្នកការពារ និងសិទ្ធិរបស់អ្នកការពារសិទ្ធិមនុស្ស។ តួនាទីចំបងរបស់អ្នករាយការណ៍ពិសេសគឺៈ<br>• ស្នើសុំ ទទួល ពិនិត្យ និងឆ្លើយតបទៅនឹងព័ត៌មានស្ដីពី | ស្ថានភាព និងសិទ្ធិបុគ្គលដែលបានបំពេញការងារជាលក្ខណៈ បុគ្គល ឬ ជាសមាគមជាមួយបុគ្គលផ្សេងដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស និងសេរីភាពជាសារវ័ន្ត<br>• បង្កើតកិច្ចសហប្រតិបត្តិការ និងកិច្ចសន្ទនាជាមួយនឹងរដ្ឋាភិបាល និងតួអង្គផ្សេងទៀតដែលចាប់អារម្មណ៍លើការលើកកម្ពស់ និងការអនុវត្តដ៏មានប្រសិទ្ធភាពនៃ**សេចក្ដីប្រកាសស្ដីពីសិទ្ធិ និងការទទួលខុសត្រូវបុគ្គល ក្រុម និងអង្គការសង្គមដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស និងសេរីភាពជាសារវ័ន្តដែលបានទទួលស្គាល់ជាសាកល** (ហៅជាទូទៅថា "សេចក្ដីប្រកាសស្ដីពីអ្នកការពារសិទ្ធិមនុស្ស") និង<br>• ផ្ដល់អនុសាសន៍លើយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពដើម្បីការពារអ្នកការ | ពារសិទ្ធិឲ្យកាន់តែប្រសើរឡើង និងបន្តតាមដានលើអនុសាសន៍ទាំងនេះ។<br>**តើអ្នកការពារសិទ្ធិមនុស្សជាអ្វីទៅ?**<br>អ្នកការពារសិទ្ធិមនុស្សគឺជាបុគ្គលដែលបានចូលរួមជាលក្ខណៈបុគ្គល ឬ ជាសមាគមជាមួយបុគ្គលផ្សេងក្នុងការលើកកម្ពស់ ការការពារ និងការសម្រេចឲ្យបាននូវសិទ្ធិនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ អ្នកការពារសិទ្ធិមនុស្សត្រូវទទួលស្គាល់សាកលភាពនៃសិទ្ធិមនុស្សដូចបានកំណត់នៅក្នុង**សេចក្ដីប្រកាសជាសាកលស្ដីពីសិទ្ធិមនុស្ស**។ បុគ្គលម្នាក់មិនអាចបដិសេធសិទ្ធិមនុស្សហើយអះអាងថាខ្លួនជាអ្នកការការពារសិទ្ធិមនុស្សនោះទេពីព្រោះខ្លួនជាអ្នកតស៊ូមតិឲ្យបុគ្គលដទៃ។<br>**តើតួអង្គសង្គមស៊ីវិលជាអ្នកការពារសិទ្ធិមនុស្សដែរឬទេ?**<br>បុគ្គលិក និងអ្នកស្ម័គ្រចិត្តជាតិ និងអន្តរជាតិដែលបម្រើការងារ |

| | | |
|---|---|---|
| ឲ្យសង្គមស៊ីវិល និងអង្គការ NGOs ស្ថាប័ន ឬ សមាគមនានាដែលឆ្លើយតបទៅនឹងការព្រួយបារម្ភអំពីសិទ្ធិមនុស្សនៅជុំវិញពិភពលោក អាចត្រូវបានចាត់ទុកជាអ្នកការពារសិទ្ធិមនុស្ស<br>**តើសេចក្តីប្រកាសស្តីពីអ្នកការការពារសិទ្ធិមនុស្សជាអ្វី?**<br>អនុម័តដោយមហាសន្និបាតនៅក្នុងខែធ្នូ ឆ្នាំ១៩៩៨ សេចក្តីប្រកាសស្តីពីអ្នកការការពារសិទ្ធិមនុស្សបានកំណត់និយមន័យនៃ “ការការពារ” សិទ្ធិមនុស្សថាជាសិទ្ធិ ហើយទទួលស្គាល់បុគ្គលដែលបំពេញការងារសិទ្ធិមនុស្សជា “អ្នកការពារសិទ្ធិមនុស្ស”។ សេចក្តីប្រកាសនេះផ្តល់ការគាំទ្រ និងការការពារជូនអ្នកការពារសិទ្ធិមនុស្សនៅក្នុងបរិបទនៃការងាររបស់ពួកគេ។ វាពុំបានបង្កើតសិទ្ធិថ្មីណាមួយនោះទេ ប៉ុន្តែចែងអំពីសិទ្ធិដែលមានស្រាប់នៅក្នុងលក្ខណៈមួយងាយស្រួលយល់ជាងមុនសម្រាប់អនុវត្តសិទ្ធិទាំងនេះលើតួនាទីជាក់លាក់ និងស្ថានភាពរបស់អ្នកការពារសិទ្ធិមនុស្សនៅ | គ្រប់ទីកន្លែងក្នុងពិភពលោក និងលើមធ្យោបាយនានាដើម្បីលើកតម្កើងការការពារពួកគេឲ្យស្របពេញលេញទៅតាមសេចក្តីប្រកាស។<br>**វិធីទាក់ទងអ្នករាយការណ៍ពិសេស ឬ ការបញ្ជូនការចោទប្រកាន់អំពីការរំលោភលើអ្នកការពារសិទ្ធិមនុស្ស**<br>តួអង្គសង្គមស៊ីវិលអាចទាក់ទងអ្នករាយការណ៍ពិសេសតាមរយៈអាសយដ្ឋានដូចខាងក្រោម (ចូរកត់សម្គាល់ថាលិខិតឆ្លើយឆ្លងគួរលើកលែងឲ្យបានច្បាស់សំដៅទៅអាណត្តិការងារណាមួយរបស់អ្នកការពារសិទ្ធិមនុស្ស។<br>**អ្នករាយការណ៍ពិសេសទទួលបន្ទុកលើស្ថានភាពរបស់អ្នកការការពារសិទ្ធិមនុស្ស**<br>ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស<br><br>8–14, avenue de la Paix CH–1211 ទីក្រុងហ្សឺណែវ 10 | អ៊ីមែល: សម្រាប់ដាក់ការចោទប្រកាន់អំពីការរំលោភណាមួយ៖ urgent-action@ohchr.org<br>ដើម្បីទាក់ទងអ្នកកាន់កាប់អាណត្តិការងារក្នុងគោលបំណងផ្សេង៖<br>defenders@ohchr.org<br>ទូរសារ: +41 (0)22 917 90 06<br>ទូរស័ព្ទ: +41 (0)22 917 12 34 - នេះគឺជាលេខតភ្ជាប់នៃអង្គការសហប្រជាជាតិនៅប្រទេសស្វីស។ អ្នកទូរស័ព្ទចូលគួរស្នើសុំជជែកជាមួយបុគ្គលិកនៃការិយាល័យ OHCHR ដែលធ្វើការងារលើយន្តការនីតិវិធីពិសេស និងជាពិសេសបុគ្គលិកគាំទ្រអាណត្តិការងាររបស់អ្នករាយការណ៍ពិសេសទទួលបន្ទុកលើសិទ្ធិរបស់អ្នកការពារសិទ្ធិមនុស្ស។ |

| អ្នកការពារសិទ្ធិមនុស្សជាស្ត្រីភេទ | | |
|---|---|---|
| នៅក្នុងឆ្នាំ២០០០ អតីតអ្នកតំណាងពិសេសនៃអគ្គលេខាធិការទទួលបន្ទុកលើស្ថានភាពរបស់អ្នកការពារសិទ្ធិមនុស្ស លោកស្រី Hina Jilani បានដឹកនាំយុទ្ធនាការអន្តរជាតិរយៈពេល ៣ ឆ្នាំ ដែលបានបញ្ចប់នៅសន្និសីទពិភពលោកស្តីពីអ្នកការការពារសិទ្ធិមនុស្សជាស្ត្រីភេទ។ សន្និសីទនេះបានរៀបចំឡើងនៅប្រទេសស្រីលង្កាដែលកោះប្រជុំអ្នកជំនាញយេនឌ័រល្បីៗ និងអ្នកការពារសិទ្ធិមនុស្សជាស្ត្រីភេទពីបណ្តាប្រទេសចំនួនជាង ៧០។ | នៅក្នុងអំឡុងអាណត្តិការងារ អ្នករាយការណ៍ពិសេសបានលើកឡើងបញ្ជាក់ដដែលៗថា អ្នកការពារជាស្ត្រីភេទប្រឈមនឹងគ្រោះថ្នាក់នៃអំពើហិង្សា និងការហាមឃាត់ក្នុងទម្រង់មួយចំនួន ហើយងាយរងគ្រោះនឹងការរើសអើង ការបណ្តេញចេញ និងបបហានកម្មដោយកងកម្លាំងរដ្ឋ និងតួអង្គសង្គម ជាពិសេស នៅពេលចូលរួមនៅក្នុងការការពារសិទ្ធិស្ត្រី[67]។ អ្នករាយការណ៍ពិសេសក៏បានចាត់វិធានការលើករណីនៃការរំលោភសិទ្ធិរបស់អ្នកការការពារសិទ្ធិមនុស្សជាស្ត្រីចំនួន | ៤៤៩ ករណីទាក់ទងនឹងអ្នកការពារសិទ្ធិចំនួន ១៣១៤ នាក់ នៅក្នុងអំឡុងអាណត្តិការងារ។ បណ្តឹងចំនួន ៦៥ ត្រូវបានបញ្ជូនរួមគ្នាជាមួយនឹង**អ្នករាយការណ៍ពិសេសទទួលបន្ទុកលើអំពើហិង្សាប្រឆាំងនឹងស្ត្រីភេទ មូលហេតុ និងផលវិបាក**។ |

## ក. ការដាក់ករណីជាលក្ខណៈបុគ្គលជូនមន្ត្រីកាន់កាប់អាណត្តិការងារនៃយន្តការនីតិវិធីពិសេស

រាល់បុគ្គលគ្រប់រូបអាចដាក់ព័ត៌មានដែលអាចជឿជាក់ និងទុកចិត្តបានស្តីពីការរំលោភសិទ្ធិមនុស្សជូនមន្ត្រីកាន់កាប់អាណត្តិការងារនៃយន្តការនីតិវិធីពិសេសដែលមានភារកិច្ចទទួលព័ត៌មានស្តីពី**ការរំលោភសិទ្ធិមនុស្ស**។ ការដាក់បណ្តឹងជាលក្ខណៈបុគ្គលជូនយន្តការនីតិវិធីពិសេសគឺជាវិធីដ៏មានប្រសិទ្ធភាពបំផុតក្នុងការស្វែងរកកិច្ចអន្តរាគមន៍ដោយផ្ទាល់នៅក្នុងករណីបុគ្គល។ ជារឿយៗ តួអង្គសង្គមស៊ីវិលអាចធ្វើជាច្រកសម្រាប់បុគ្គលស្នើសុំការការពារពីការបំពានសិទ្ធិមនុស្ស។

ជាធម្មតា លិខិតទំនាក់ទំនងដែលបានបញ្ជូនទៅ និងបានទទួលមានលក្ខណៈសម្ងាត់ និងនៅតែសម្ងាត់រហូតដល់ពេលរបាយការណ៍នៃមន្ត្រីកាន់កាប់អាណត្តិការងារដែលបានដាក់ជូនក្រុម

[67] សូមមើល E/CN.4/2002/106 កថាខណ្ឌ ៨០-៩៥។

ប្រឹក្សាសិទ្ធិមនុស្សត្រូវបានបង្ហាញជាសាធារណៈ។ ក៏ប៉ុន្តែ ករណីនេះលើកលែងតែមន្ត្រីកាន់កាប់អាណត្តិការងារសម្រេចចេញសេចក្តីថ្លែងការណ៍ជាសាធារណៈជាមុននៅក្នុងអំឡុងពេលដំណើរការនីតិវិធីនេះ។ របាយការណ៍នេះរួមមានព័ត៌មានស្តីពីលិខិតទំនាក់ទំនងដែលបានបញ្ជូនទៅ និងចម្លើយតបដែលបានទទួលពីរដ្ឋាភិបាលស្តីពីរឿងក្តីជាក់លាក់។ ចូរកត់សម្គាល់ថា អ្នកដែលចោទប្រកាន់ថាជាជនត្រូវគ្រោះត្រូវបានបញ្ចូលឈ្មោះនៅក្នុងរបាយការណ៍ លើកលែងតែកុមារ ឬ ប្រភេទជនរងគ្រោះជាក់លាក់ ដូចជា ជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ។

ដោយពិចារណាលើលក្ខណៈសាធារណៈនៃរបាយការណ៍របស់យន្តការនីតិវិធីពិសេស វាសំខាន់ណាស់ថា អង្គការនានាដែលតំណាងឲ្យជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្សត្រូវធានាថាជនរងគ្រោះដឹងថា រឿងក្តីរបស់ខ្លួនកំពុងត្រូវបានបញ្ជូនទៅយន្តការនីតិវិធីពិសេស ឈ្មោះរបស់ពួកគេនឹងបញ្ជូនទៅអាជ្ញាធរ ហើយឈ្មោះ (ឬ ឈ្មោះកាត់) នឹងបង្ហាញនៅក្នុងរបាយការណ៍នៃយន្តការនីតិវិធីពិសេសដែលបង្ហាញជាសាធារណៈ។ ក៏ប៉ុន្តែ យើងគួរកត់សម្គាល់ថា សិទ្ធិអនុញ្ញាតពីជនរងគ្រោះពុំមែនជាលក្ខខណ្ឌតម្រូវជានិច្ចជាកាលក្នុងការដាក់រឿងក្តីនោះឡើយ (ពោលគឺ ប្រសិនបើជនរងគ្រោះមិនអាចទាក់ទងបានដោយសារស្ថិតនៅក្នុងការឃុំខ្លួន ឬ កាលៈទេសៈផ្សេងទៀត)។ អាណត្តិការងារខ្លះបានបង្កើតកម្រងសំនួរពិសេសសម្រាប់ប្រើប្រាស់នៅពេលដាក់ព័ត៌មានស្តីពីការរំលោភសិទ្ធិមនុស្ស។

**យន្តការនីតិវិធីពិសេសនីមួយៗបង្កើតលក្ខខណ្ឌខុសៗគ្នាសម្រាប់ដាក់លិខិតទំនាក់ទំនង។** ក៏ប៉ុន្តែ ព័ត៌មានបឋមដូចខាងក្រោមត្រូវដាក់បញ្ចូលក្នុងលិខិតទំនាក់ទំនងសម្រាប់ការវាយតម្លៃ៖

- អត្តសញ្ញាណអ្នកដែលត្រូវបានចោទប្រកាន់ថាជាជនរងគ្រោះ
- អត្តសញ្ញាណអ្នកដែលត្រូវបានចោទប្រកាន់ថាជាចារីនៃការរំលោភនានា
- អត្តសញ្ញាណបុគ្គល ឬ អង្គការដែលដាក់លិខិតទំនាក់ទំនង (ព័ត៌មាននេះនឹងរក្សាការសម្ងាត់)
- កាលបរិច្ឆេទ និងទីកន្លែងកើតហេតុការណ៍ និង
- ការពិពណ៌នាលម្អិតអំពីកាលៈទេសៈដែលការចោទប្រកាន់ថាមានការរំលោភនានាបានកើតឡើង

i. **កម្រងសំនួរ**មូលដ្ឋានសម្រាប់អាណត្តិការងារជាក់លាក់អាចរកមើលបាននៅលើគេហទំព័រនៃការិយាល័យ OHCHR នៅក្រោមផ្នែកស្តីពីអាណត្តិការងារមួយចំនួនទទួលបន្ទុករាយការណ៍អំពីការចោទប្រកាន់លើការរំលោភនានា។

តួអង្គសង្គមស៊ីវិលអាចដាក់**ព័ត៌មានបន្តតាមដាន**ជូនមន្ត្រីកាន់កាប់អាណត្តិការងារអំពីករណីថាតើបញ្ហា/ស្ថានភាពសិទ្ធិមនុស្សដែលបានបង្ហាញនៅក្នុងឯកសារដំបូងមានភាពប្រសើរឡើងដែរឬទេ។ ព័ត៌មានបន្តតាមដានមានប្រយោជន៍ខ្លាំងណាស់សម្រាប់មន្ត្រីកាន់កាប់អាណត្តិការងារ។ មន្ត្រីទាំងនេះ

មួយចំនួនបានផ្អែកសំណើសុំទស្សនកិច្ចតាមប្រទេសលើនិន្នាការដែលបានកំណត់តាមរយៈយន្តការនីតិវិធីនៃបណ្តឹង។

ព័ត៌មានដែលបានផ្តល់ជូនយន្តការនីតិវិធីពិសេសមិនគួរធ្វើឡើងក្នុងន័យនយោបាយ បំពាន ឬផ្អែកតែលើរបាយការណ៍សារព័ត៌មានប៉ុណ្ណោះនោះទេ។

i. ករណី/បណ្តឹងជាលក្ខណៈបុគ្គលអាចដាក់ជូនតាមរយៈ៖

អ៊ីមែល: urgent-action@ohchr.org

ទូរសារ: +41 (0)22 917 90 06 ឬ

អាសយដ្ឋានប្រៃសនីយ៍: OHCHR-UNOG, 8-14 avenue de la Paix, CH–1211 ទីក្រុងហ្សឺណែវ 10, ប្រទេសស្វីស.

**នៅពេលបញ្ជូនបណ្តឹង សូមបញ្ជាក់យន្តការនីតិវិធីដែលចង់បញ្ជូនពត៌មាននៅក្នុងផ្នែកកម្មវត្ថុនៃអ៊ីមែល ឬសារទូរសារ ឬ នៅលើស្រោមសំបុត្រ។**

សម្រាប់ព័ត៌មានបន្ថែមស្តីពីរបៀបដាក់ព័ត៌មានអំពីការចោទប្រកាន់លើការរំលោភនានាជូនយន្តការនីតិវិធីពិសេស សូមអានជំពូក VIII (ការដាក់បណ្តឹងចោទប្រកាន់ការរំលោភសិទ្ធិមនុស្ស) នៅក្នុង*សៀវភៅណែនាំ*នេះ និងសូមទាក់ទង SPDInfo@ohchr.org។

## ខ. ការផ្តល់ការគាំទ្រលើទស្សនកិច្ចតាមប្រទេស

ទស្សនកិច្ចតាមប្រទេសរបស់មន្ត្រីកាន់កាប់អាណត្តិនៃយន្តការនីតិវិធីពិសេសមានសារសំខាន់ក្នុងការប្រមូលព័ត៌មានផ្ទាល់ដោយសារព័ត៌មានទាំងនេះអាចជួយដល់ការសង្កេតផ្ទាល់លើស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសមួយជាក់លាក់។ អង្គការ NGOs អន្តរជាតិ និងជាតិ សាមជិកនៃសង្គមស៊ីវិល និងចលនាមូលដ្ឋានបានចូលរួមចំណែកយ៉ាងសំខាន់នៅដំណាក់កាលខុសៗគ្នានៃបេសកកម្ម។

### ១. សំណើសុំទស្សនកិច្ចតាមប្រទេស

តួអង្គសង្គមស៊ីវិលអាចជម្រុញឲ្យរដ្ឋាភិបាលអញ្ជើញមន្ត្រីកាន់កាប់អាណត្តិការងារមកធ្វើទស្សនកិច្ចក្នុងប្រទេស ឬ ចេញលិខិតអញ្ជើញអចិន្ត្រៃយ៍ជូនយន្តការនីតិវិធីពិសេស។ ការពញ្ញាក់ស្មារតីមន្ត្រីកាន់កាប់អាណត្តិការងារអំពីបញ្ហានានានៅក្នុងរដ្ឋអាចកំណត់ថាតើថាមន្ត្រីកាន់កាប់អាណត្តិការងារស្នើសុំទស្សនកិច្ចជាក់លាក់ដែរឬទេដោយសារមន្ត្រីកាន់កាប់អាណត្តិការងារខ្លះផ្អែកសំណើសុំទស្សនកិច្ចតាមប្រទេសលើព័ត៌មាន (បណ្តឹង/ករណីជាបុគ្គល) ដែលពួកគេបានទទួល។ មន្ត្រីកាន់កាប់អាណត្តិការងារបានធ្វើទស្សនកិច្ចតាមប្រទេសរួមគ្នា។

### ២. នៅពេលសំណើសុំទស្សនកិច្ចត្រូវបានទទួលយក

នៅពេលសំណើសុំទស្សនកិច្ចតាមប្រទេសត្រូវបានទទួលយក (នៅពេលរដ្ឋបានយល់ព្រមតាមសំណើរបស់មន្ត្រីកាន់កាប់អាណត្តិសុំធ្វើទស្សនកិច្ច ហើយកាលបរិច្ឆេទនៃទស្សនកិច្ចត្រូវបានឯកភាព) តួអង្គសង្គមស៊ីវិលអាចលើកកម្ពស់ការយល់ដឹងដល់សាធារណជនអំពីទស្សនកិច្ចនេះ។

តួអង្គសង្គមស៊ីវិលក៏អាចបញ្ជូនព័ត៌មានពាក់ព័ន្ធ និងលើកយកកង្វល់មួយចំនួនជូនមន្ត្រីកាន់កាប់អាណត្តិការងារនៅមុនពេលធ្វើទស្សនកិច្ចតាមប្រទេស។ ដូច្នេះ វាអាចឲ្យមន្ត្រីកាន់កាប់អាណត្តិការងារលើកបញ្ហាជាក់លាក់ជូនអាជ្ញាធរជាមុន និងប្រសិនបើចាំបាច់ធ្វើការរៀបចំនានាដើម្បីដាក់បញ្ចូលព័ត៌មាននេះនៅក្នុងកម្មវិធីទស្សនកិច្ចផ្លូវការ (ឧ. ដោយស្នើសុំពិនិត្យមន្ទីរឃុំឃាំងជាក់លាក់ ឬជំរំជនភៀសខ្លួន ឬ ដោយរៀបចំកិច្ចប្រជុំជាមួយនឹងអាជ្ញាធរជាតិ ឬ មូលដ្ឋាន ឬ បុគ្គលឯកជនជាក់លាក់)។

| ការសម្របសម្រួលថ្នាក់ជាតិក្នុងចំណោមអង្គការ NGOs នៅប្រទេសប្រេស៊ីល | | |
|---|---|---|
| ក្រុមអង្គការ NGOs នៅប្រទេសប្រេស៊ីល (**អង្គការ** Plataforma Dehesc) បានបង្កើតប្រព័ន្ធឃ្លាំមើលសិទ្ធិមនុស្សយកគម្រូតាមយន្តការនីតិវិធីពិសេស។ បុគ្គលទំនាក់ទំនងចំនួន ៦ មួយ ដោយមួយរូបៗធ្វើការងារលើបញ្ហាសេដ្ឋកិច្ច | សង្គមកិច្ច និងវប្បធម៌ ពោលគឺ សិទ្ធិទទួលបានលំនៅដ្ឋានសមស្រប ការអប់រំ បរិស្ថាន ស្បៀងអាហារ សុខភាព ឬ ការងារ និងបង្កើតរបាយការណ៍ជាតិលើបញ្ហាដែលត្រូវបានបញ្ជូនទៅមន្ត្រីកាន់កាប់អាណត្តិការងារនៃយន្តការនីតិវិធីពិសេស។ ការបែងចែកបញ្ហាណាមួយទៅបុគ្គលទំនាក់ទំនងម្នាក់ៗបានប្រើប្រាស់ | ធនធាន និងជំនាញក្នុងកម្រិតអតិបរិមា ហើយបានបន្ថយកុំឲ្យបំពេញការងារជាន់គ្នា ដែលធ្វើឲ្យការចូលរួមចំណែកលើការងារនៃយន្តការនីតិវិធីពិសេសកាន់តែមានប្រសិទ្ធភាព។ |

## ៣. ក្នុងអំឡុងពេលទស្សនកិច្ចតាមប្រទេស

ក្នុងអំឡុងពេលទស្សនកិច្ចតាមប្រទេស តួអង្គសង្គមស៊ីវិលអាចស្នើសុំជួបជាមួយនឹងមន្ត្រីកាន់កាប់អាណត្តិការងារដោយទាក់ទងផ្ទាល់ទៅមន្ត្រីទាំងនោះ ឬ បុគ្គលិកពាក់ព័ន្ធនៃការិយាល័យ OHCHR នៅទីក្រុងហ្សឺណែវ ឬ នៅក្នុងប្រទេសផ្ទាល់តែម្តងតាមរយៈទូរសារ ប្រៃសនីយ៍ ឬ អ៊ីមែល។

i. សូមចូលទៅកាន់គេហទំព័រនៃការិយាល័យ OHCHR សម្រាប់អាសយដ្ឋានទំនាក់ទំនង**ការិយាល័យប្រចាំប្រទេស ឬ មន្ត្រីព័ត៌មាន។**

## ៤. ក្រោយទស្សនកិច្ចតាមប្រទេស

សង្គមស៊ីវិលអាចដើរតួនាទីសំខាន់នៅក្នុងការបន្តតាមដានសេចក្តីសន្និដ្ឋាន និងអនុសាសន៍ក្រោយទស្សនកិច្ចតាមប្រទេសតាមរយៈ៖

- ចែកផ្សាយអនុសាសន៍ជូនការិយាល័យមូលដ្ឋានរបស់ខ្លួន
- ផ្សព្វផ្សាយការងារនៃយន្តការនីតិវិធីពិសេស និងលើកកម្ពស់ការយល់ដឹង
- បង្កើតផែនការសកម្មភាព និងវិធានការដើម្បីបន្តការងារដែលបានផ្តួចផ្តើមឡើងតាមរយៈទស្សនកិច្ចតាមប្រទេស
- ចែករំលែកមតិចូលនៅក្នុងរបាយការណ៍បន្តតាមដានដែលបានចេញដោយមន្ត្រីកាន់កាប់អាណត្តិការងារ និង
- ឃ្លាំមើលវិធានការដែលរដ្ឋាភិបាលបានធ្វើឡើងដើម្បីបំពេញតាមអនុសាសន៍ និងបន្តជូនដំណឹងដល់មន្ត្រីកាន់កាប់អាណត្តិការងារអំពីវឌ្ឍនភាពរបស់រដ្ឋចំពោះការអនុវត្តអនុសាសន៍។

| ការបង្កើតបណ្តាញដើម្បីបំពេញការងារទាក់ទងនឹងការអនុវត្តអនុសាសន៍នៃយន្តការនីតិវិធីពិសេស | | |
|---|---|---|
| ក្រោយទស្សនកិច្ចរបស់លោក Doudou Diène ដែលជាអតីត**អ្នករាយការណ៍ពិសេសទទួលបន្ទុកលើទម្រង់បច្ចុប្បន្ននៃការប្រកាន់ពូជសាសន៍ ការរើសអើងពូជសាសន៍ និងការរើសអើងផ្សេងទៀត** ទៅកាន់ប្រទេសជប៉ុនក្នុងឆ្នាំ២០០៥ **ចលនាអន្តរជាតិប្រឆាំងនឹងគ្រប់ទម្រង់នៃការប្រកាន់ពូជសាសន៍** (ចលនា IMADR) និងក្រុមសិទ្ធិមនុស្ស និងជនជាតិភាគតិច ចំនួន ៨៥ ក្រុមបានបង្កើតបណ្តាញអង្គការ NGOs ទទួលបន្ទុកលុបបំបាត់ការរើសអើង | ពូជសាសន៍ដោយផ្អែកលើមូលដ្ឋាននៃរបាយការណ៍ទស្សនកិច្ច។ បណ្តាញអង្គការនេះគឺជាមធ្យោបាយចំបងមួយសម្រាប់អង្គការ NGOs មូលដ្ឋានចែករំលែកព័ត៌មានទាក់ទងនឹងការប្រកាន់ពូជសាសន៍ និងការរើសអើងនានានៅក្នុងប្រទេសជប៉ុន និងចូលរួមជាមួយនឹងយន្តការអន្តរជាតិ។ អ្នករាយការណ៍ពិសេសបានស្វាគមន៍ការបង្កើតបណ្តាញអង្គការនេះព្រមទាំងកិច្ចសន្ទនាក្នុងន័យស្ថាបនាដែលបានបង្កើតឡើងរវាងអាជ្ញាធរ អង្គការ NGOs និងសមាជិកសហគមន៍ដែលរងប៉ះពាល់បំផុតដោយសារការប្រកាន់ពូជសាសន៍ និងការរើសអើងជនបរទេស រួមទាំង ក្រុម Ainu (ដែលត្រូវបានទទួលស្គាល់ជា | ផ្លូវការដោយប្រទេសជប៉ុនថាជាក្រុមជនជាតិដើមភាគតិចនៅក្នុងឆ្នាំ២០០៨) ក្រុមជនជាតិភាគតិចនៅក្នុងប្រទេស (ប្រជាជាតិ Buraku និងប្រជាជាតិ Okinawa) មនុស្សជំនាន់ក្រោយនៃប្រជាជាតិក្រោយអតីតអាណានិគមនិយមជប៉ុន (កូរ៉េ និងចិន) និងប្រជាជនអន្តោប្រវេសន៍មកពីប្រទេសក្នុងតំបន់អាស៊ី អាហ្វ្រិក អាមេរិកខាងត្បូង និងមជ្ឈិមបូព៌ា។ |

## គ. ការផ្តល់ព័ត៌មានជូនមន្ត្រីកាន់កាប់អាណត្តិការងារនៃនីតិវិធីពិសេស

អង្គការ NGOs អាចពាំនាំព័ត៌មានស្តីពីស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសមួយជាក់លាក់ ឬ ស្តីពីច្បាប់ និងការអនុវត្តដែលមានអានុភាពលើសិទ្ធិមនុស្សជូនយន្តការនីតិវិធីពិសេសដើម្បីជាការចាប់អារម្មណ៍។ ពេលខ្លះ មន្ត្រីកាន់កាប់អាណត្តិការងារអាចស្នើសុំព័ត៌មានជាក់លាក់លើប្រធានបទដែលស្ថិតក្រោមអាណត្តិការងាររបស់ខ្លួន ឬ រៀបចំកិច្ចពិគ្រោះយោបល់ពិសេសជាមួយនឹងអង្គការ NGOs និងតួអង្គសង្គមស៊ីវិលផ្សេងទៀត រួមទាំង ស្ថាប័នអប់រំ និងស្រាវជ្រាវ។

| ការប្រតិបត្តិការរបស់សង្គមស៊ីវិលជាមួយនឹងអ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិទទួលការអប់រំ នៅក្នុងការផ្តើតរបាយការណ៍ស្តីពីសិទ្ធិទទួលបានការអប់រំរបស់ជនពិការ | | |
|---|---|---|
| នៅក្នុងឆ្នាំ២០០៧ **អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិទទួលការអប់រំ** លោក Vernor Muñoz Villalobos បានដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំលើកទីបីរបស់គាត់ស្តីពីសិទ្ធិទទួលការអប់រំរបស់ជនពិការ ដោយហេតុថា ពួកគេស្ថិតនៅក្នុងក្រុមដែលរងប៉ះពាល់ខ្លាំងដោយសារការដកចេញពីការអប់រំ។ របាយការណ៍នេះវិភាគស៊ីជម្រៅអំពីក្របខណ្ឌច្បាប់ និងស្ថាប័ននៃសិទ្ធិទទួលការអប់រំជនពិការ ហើយក៏បានពិនិត្យមើលផលប៉ះពាល់លើ "ការអប់រំទូទៅ" ដែលជាសមាសធាតុមូលដ្ឋាននៃសិទ្ធិទទួលការអប់រំ ហើយបាន | លើកឡើងឧបសគ្គ និងបញ្ហាប្រឈមចំបងៗដែលគម្រាមកំហែងការសម្រេចបានទាំងស្រុងលើសិទ្ធិទទួលការអប់រំជនពិការ។ នៅពេលបង្កើតរបាយការណ៍ អ្នករាយការណ៍ពិសេសបានពិគ្រោះយោបល់ជាមួយនឹងអង្គការថ្នាក់ជាតិ និងតំបន់ រួមទាំង អង្គការជនពិការ ហើយបានទទួលព័ត៌មានផ្ទាល់ (រួមទាំង ការសិក្សាស្ថិតិ និងទស្សនវិស័យនានា) ពីអង្គការមូលដ្ឋាន និងក្នុងតំបន់ល្បីៗ។ ព័ត៌មាននេះបានជួយឲ្យអ្នករាយការណ៍ពិសេសកំណត់បញ្ហាប្រឈម និងឧបសគ្គដែលរាំងស្ទះដល់ការសម្រេចបាននូវសិទ្ធិទទួលការអប់រំជនពិការ និងដាក់ចេញអនុសាសន៍នានា។ ការិយាល័យ OHCHR ក្រោមកិច្ចសហការជាមួយនឹងអ្នករាយការណ៍ពិសេសក៏បានរៀបចំសិក្ខាសាលាអ្នកជំនាញរយៈពេល | ២ ថ្ងៃ ស្តីពីសិទ្ធិទទួលការអប់រំជនពិការ ដែលបើកឲ្យជនពិការ និងអ្នកធ្វើការងារលើជនពិការចូលរួមយ៉ាងសកម្ម។ ការចូលរួមចំណែករបស់តំណាងសង្គមស៊ីវិលបានដាក់បញ្ចូលនៅក្នុងរបាយការណ៍របស់អ្នករាយការណ៍ពិសេសដែលបានផ្សព្វផ្សាយយ៉ាងទូលំទូលាយជូនជនពិការ អង្គការតំណាង សាកលវិទ្យាល័យ ភ្នាក់ងាររដ្ឋាភិបាល និងក្រុមសង្គមស៊ីវិលផ្សេងទៀត។ |

| ការចូលរួមចំណែករបស់គ្រឹះស្ថានអប់រំនៅក្នុងអាណត្តិការងារនៃអ្នករាយការណ៍ពិសេសរបស់អគ្គលេខាធិការទទួលបន្ទុកបញ្ហាសិទ្ធិមនុស្ស និងសារជីវកម្មឆ្លងព្រំដែន និងសហគ្រាសអាជីវកម្មផ្សេងទៀត | | |
|---|---|---|
| គ្រឹះស្ថានអប់រំលើវិស័យជាច្រើនពីជុំវិញពិភពលោកបានចូលរួមចំណែកនៅក្នុងការងាររបស់**អ្នករាយការណ៍ពិសេសនៃអគ្គលេខាធិការទទួលបន្ទុកបញ្ហាសិទ្ធិមនុស្ស និងសារជីវកម្មឆ្លងព្រំដែន និងសហគ្រាសអាជីវកម្ម**ផ្សេងទៀត។ | ការចូលរួមចំណែកនេះធ្វើឡើងក្នុងទម្រង់ជាការស្រាវជ្រាវស្តីពីប្រធានបទជាក់លាក់ដែលបានស្នើសុំ ឬ យល់ព្រមដោយតំណាងពិសេស ការចូលរួមនៅក្នុងកិច្ចពិគ្រោះយោបល់ និងកិច្ចប្រជុំអ្នកជំនាញដែលអ្នករាយការណ៍ពិសេសបានកោះប្រជុំ និងឯកសារដាក់ជូនអ្នកតំណាងពិសេសលើបញ្ហាផ្សេងៗដែលស្ថិត | នៅក្រោមអាណត្តិការងាររបស់ខ្លួន។ ការចូលរួមចំណែកទាំងអស់ដែលបានផ្តល់ជូនអ្នករាយការណ៍ពិសេសអាចរកមើលបាននៅលើគេហទំព័ររបស់មជ្ឈមណ្ឌលធនធានស្តីពីអាជីវកម្ម និងសិទ្ធិមនុស្ស[68]។ |

## ឃ. ការបំពេញការងារថ្នាក់មូលដ្ឋាន ជាតិ ឬ តំបន់ដើម្បីតស៊ូមតិ ផ្សព្វផ្សាយ បន្តតាមដាន និងអនុវត្តការងារនៃយន្តការនីតិវិធីពិសេស

ការងាររបស់មន្ត្រីកាន់កាប់អាណត្តិការងារនៃយន្តការនីតិវិធីពិសេសដែលកំពុងបន្តធ្វើឡើង រួមទាំង របាយការណ៍ អនុសាសន៍ គឺជាព័ត៌មានដ៏មានតម្លៃដែលតួអង្គសង្គមស៊ីវិលអាចច្របាច់បញ្ចូលនៅក្នុងការងារតស៊ូមតិដែលពួកគេកំពុងធ្វើឡើង។ ការងារនេះរួមមានដូចជា៖

### ១. ការអនុវត្តអនុសាសន៍នៃយន្តការនីតិវិធីពិសេសនៅថ្នាក់ជាតិ

ការតស៊ូមតិដែលកំពុងបន្តតាមដានទាមទារឲ្យរដ្ឋាភិបាលអនុវត្តអនុសាសន៍នៃយន្តការនីតិវិធីពិសេស ជាពិសេស ក្រោយទស្សនកិច្ចតាមប្រទេស គឺជាតួនាទីសំខាន់មួយដែលសង្គមស៊ីវិលអាចធ្វើឡើងដើម្បីរុញច្រានសិទ្ធិមនុស្សឲ្យដំណើរការទៅមុខ។ តួអង្គសង្គមស៊ីវិលអាចចាត់វិធានការឃ្លាំមើល

68 ការិយាល័យ OHCHR ពុំទទួលខុសត្រូវលើខ្លឹមសារនៃគេហទំព័រខាងក្រៅនោះឡើយ ហើយការផ្តល់តំណភ្ជាប់នៅលើទំព័រនេះពុំមានន័យថា ការិយាល័យ OHCHR មានការពាក់ព័ន្ធលើខ្លឹមសារនោះទេ។

វឌ្ឍនភាពរបស់រដ្ឋាភិបាលនៅក្នុងការអនុវត្តអនុសាសន៍ ឬ អាចស្នើសុំឲ្យអនុវត្តអនុសាសន៍ដោយខ្លួនឯងប្រសិនបើអនុសាសន៍ទាំងនេះត្រូវបានលើកបង្ហាញសង្គមស៊ីវិល។

## ២. ការកំណត់បទដ្ឋានថ្នាក់ជាតិ ឬ ថ្នាក់មូលដ្ឋាន

បទដ្ឋានអន្តរជាតិ ច្បាប់គម្រូ ឬ ទម្លាប់អនុវត្តល្អៗដែលមន្ត្រីកាន់កាប់អាណត្តិការងារនៃយន្តការនីតិវិធីពិសេសបានចងក្រងជាឯកសារអាចត្រូវបានប្រើប្រាស់ដោយតួអង្គសង្គមស៊ីវិលដើម្បីលើកកម្ពស់ការយល់ដឹងលើបញ្ហាជាក់លាក់ណាមួយ ដើម្បីធ្វើយុទ្ធនាការបង្កើនប្រសិទ្ធភាពបទដ្ឋានថ្នាក់ជាតិ ឬ មូលដ្ឋាន ឬ ដើម្បីជារង្វាស់ក្នុងការបកស្រាយច្បាប់ជាតិ។

តួអង្គសង្គមស៊ីវិលអាចរៀបចំព្រឹត្តិការណ៍ និងកម្មវិធីបណ្តុះបណ្តាលដើម្បីបង្កើតការកំណត់បទដ្ឋាន និងដើម្បីកសាងសមត្ថភាពតួអង្គសង្គមស៊ីវិលផ្សេងទៀតឲ្យចេះប្រើប្រាស់ និងចូលរួមជាមួយនឹងនីតិវិធីពិសេស។ ជារឿយៗ មន្ត្រីកាន់កាប់អាណត្តិការងារចូលរួមចំណែកលើសកម្មភាពកសាងសមត្ថភាពបែបនេះ។

## ៣. ឧបករណ៍សម្រាប់បង្កើតគោលការណ៍ណែនាំប្រតិបត្តិ

ការងាររបស់មន្ត្រីកាន់កាប់អាណត្តិការងារនៃយន្តការនីតិវិធីពិសេសអាចផ្តល់ជាព័ត៌មានលម្អិតស្តីពីសិទ្ធិ និងកាតព្វកិច្ចដែលតួអង្គសង្គមស៊ីវិលអាចប្រើប្រាស់ដើម្បីបង្កើតគោលការណ៍ណែនាំប្រត្តិបត្តិផ្ទៃក្នុង ឧទាហរណ៍៖

- ការងាររបស់**អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិទទួលការអប់រំ**ផ្តល់នូវគោលការណ៍ណែនាំដ៏មានតម្លៃជូនដល់គ្រឹះស្ថានអប់រំ
- ការងាររបស់**អ្នករាយការណ៍ពិសេសទទួលបន្ទុកទារុណកម្ម និងការប្រព្រឹត្ត ឬ ទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ និងបន្ថោកបន្ទាប**អាចត្រូវបានប្រើប្រាស់ដោយមន្ទីរឃុំឃាំង និងពន្ធនាគារនៅក្នុងការបង្កើតការបណ្តុះបណ្តាលផ្ទៃក្នុង និងបទដ្ឋានប្រតិបត្តិការ ហើយនឹង
- ការងាររបស់**អ្នករាយការណ៍ពិសេសទទួលបន្ទុកអំពើហិង្សាប្រឆាំងនឹងស្ត្រីភេទ មូលហេតុ និងផលវិបាក** អាចផ្តល់និយមន័យដ៏មានតម្លៃអំពីអំពើហិង្សាប្រឆាំងនឹងស្ត្រីភេទ មូលហេតុ និងការអនុវត្តល្អៗសម្រាប់លុបចោលអំពើហិង្សាទាំងនេះ។ គោលការណ៍ណែនាំ និយមន័យ និងនីតិវិធីអាចយកប្រើប្រាស់នៅតាមសាលារៀន ពន្ធានាគារ ជម្រកសម្រាប់ស្ត្រីភេទ ឬ អង្គការផ្សេងទៀតដែលព្យាយាមបង្កើតលក្ខខណ្ឌសុវត្ថិភាពជូនស្ត្រីភេទ។

## ៤. កិច្ចប្រជុំជាមួយមន្ត្រីកាន់កាប់អាណត្តិការងារនៃនីតិវិធីពិសេស

មន្ត្រីកាន់កាប់អាណត្តិការងារនៃយន្តការនីតិវិធីពិសេសអាចជួបប្រជុំជាមួយនឹងតួអង្គសង្គមស៊ីវិលក្នុងក្របខណ្ឌជាកិច្ចពិគ្រោះយោបល់នៅទីក្រុងហ្សឺណែវ ញូវយ៉ក (សម្រាប់អ្នកដែល

ចូលរួមមហាសន្និបាត) និងនៅក្នុងអំឡុងពេលនៃទស្សនកិច្ចតាមប្រទេស។ កិច្ចប្រជុំទាំងនេះមានសារសំខាន់ខ្លាំងណាស់ក្នុងការជួយបន្តកសាងភាពជាដៃគូរវាងអ្នកកាន់កាប់អាណត្តិការងារ និងសង្គមស៊ីវិល។ បុគ្គលិកដែលផ្តល់សេវាជូនមន្ត្រីកាន់កាប់អាណត្តិការងារនៅការិយាល័យ OHCHR អាចទាក់ទងបានពេញមួយឆ្នាំដើម្បីរៀបចំកិច្ចប្រជុំទាំងនេះ។

ធនធាននៃការិយាល័យ OHCHR

## គេហទំព័រនៃយន្តការនីតិវិធីពិសេស

តួអង្គសង្គមស៊ីវិលគួរពិនិត្យមើលផ្នែកនីតិវិធីពិសេសលើគេហទំព័រនៃការិយាល័យ OHCHR ឲ្យបានទៀងទាត់ដើម្បីទទួលបានព័ត៌មានថ្មីចុងក្រោយអំពីនីតិវិធីពិសេស។ គេហទំព័រនេះមានជាភាសាអង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ ហើយភាសាអារ៉ាប់ និងភាសាចិនកំពុងបង្កើតឡើង។

## គេហទំព័រនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស

តួអង្គសង្គមស៊ីវិលគួរពិនិត្យមើលផ្នែកក្រុមប្រឹក្សាសិទ្ធិមនុស្សលើគេហទំព័រនៃការិយាល័យ OHCHR ឲ្យបានទៀងទាត់ដើម្បីទទួលបានព័ត៌មានថ្មីចុងក្រោយស្តីពីការចូលរួមនៅក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សា ហើយនឹងព័ត៌មានអំពីការដាក់បង្ហាញរបាយការណ៍នៃយន្តការនីតិវិធីពិសេស។

ប្រព័ន្ធ Extranet

ព័ត៌មានស្តីពីទិដ្ឋភាពផ្សេងៗនៃប្រព័ន្ធយន្តការនីតិវិធីពិសេសអាចមើលបាននៅលើៈ

- ផ្នែកស្តីពីយន្តការនីតិវិធីពិសេសក្នុងប្រព័ន្ធ Extranet **របស់ក្រុមប្រឹក្សាសិទ្ធិកមនុស្ស** និង
- ប្រព័ន្ធ **Extranet នៃនីតិវិធីពិសេស**

ព្រឹត្តិបត្តិព័ត៌មាននៃយន្តការនីតិវិធីពិសេស

ការិយាល័យ OHCHR បានបង្កើតព្រឹត្តិបត្តិប្រចាំត្រីមាសលើកឡើងអំពីសកម្មភាពរបស់យន្តការនីតិវិធីពិសេស។ ព្រឹត្តិបត្តិនេះអាចមើលបាននៅលើគេហទំព័ររបស់យន្តការនីតិវិធីពិសេសនៃការិយាល័យ OHCHR។

i. ដើម្បីចូលមើលទំព័រប្រព័ន្ធ **Extranet នៃក្រុមប្រឹក្សាសិទ្ធិមនុស្ស** ដែលមានលេខកូដសម្ងាត់ការពារ សូមបំពេញទម្រង់បែបបទតាមប្រព័ន្ធអនឡាញ។ ក្រោយពេលបំពេញបែបបទរួចហើយ លោកអ្នកនឹងទទួលបានឈ្មោះប្រើប្រាស់ និងលេខកូដសម្ងាត់តាមរយៈអ៊ីមែល។

ដើម្បីចូលមើលទំព័រប្រព័ន្ធ Extranet នៃក្រុមប្រឹក្សាសិទ្ធិមនុស្ស ដែលមានលេខសម្ងាត់ការពារ សូមបំពេញបែបបទតាមប្រព័ន្ធអនឡាញ។

## អង្គហេតុ និងតួលេខប្រចាំឆ្នាំអំពីនីតិវិធីពិសេស

ការិយាល័យ OHCHR បានផលិតធនធានប្រចាំឆ្នាំស្តីពីអង្គហេតុ និងតួលេខនៃយន្តការនីតិវិធីពិសេសដោយរួមបញ្ចូលព័ត៌មាន និងស្ថិតិលើបណ្តឹង ទស្សនកិច្ចតាមប្រទេស របាយការណ៍ សេចក្តីប្រកាសព័ត៌មាន ការសម្របសម្រួល និងព្រឹត្តិការណ៍លើវិស័យនានា។ ធនធានបង្ហាញអំពីអង្គហេតុ និងតួលេខអាចរកមើលបាននៅក្នុងផ្នែកស្តីពីយន្តការនីតិវិធីពិសេសលើគេហទំព័រនៃការិយាល័យ OHCHR។

## កម្រងអនុសាសន៍ប្រចាំឆ្នាំនៃយន្តការនីតិវិធីពិសេស

ការិយាល័យ OHCHR បានផលិតកម្រងអនុសាសន៍ប្រចាំឆ្នាំនៃយន្តការនីតិវិធីពិសេសដែលរៀបចំឡើងទៅតាមប្រទេស។ កម្រងនេះអាចរកមើលបាននៅក្នុងផ្នែកស្តីពីយន្តការនីតិវិធីពិសេសលើគេហទំព័រនៃការិយាល័យ OHCHR។

## លិបិក្រមស្តីពីសិទ្ធិមនុស្សជាសាកល

**លិបិក្រមស្តីពីសិទ្ធិមនុស្សជាសាកល** (លិបិក្រម) គឺជាឧបករណ៍ព័ត៌មានតាមប្រព័ន្ធអនឡាញដែលបានបង្កើតឡើងជាចំបងដើម្បីសម្រួលការប្រើប្រាស់ឯកសារពាក់ព័ន្ធនឹងសិទ្ធិមនុស្សដែលចេញដោយ**គណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស និងយន្តការនីតិវិធីពិសេសនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស**។ គេហទំព័រថ្មីមួយនេះ (ដែលអាចមើលតាមរយៈគេហទំព័រនៃការិយាល័យ OHCHR) រួមមានសេចក្តីសង្កេតសរុបដែលបានចេញដោយគណកម្មាធិការសន្ធិសញ្ញាតាំងពីឆ្នាំ២០០០ ព្រមទាំង សេចក្តីសន្និដ្ឋាន និងអនុសាសន៍របស់យន្តការនីតិវិធីពិសេសនៃក្រុមប្រឹក្សាសិទ្ធិមនុស្សពាក់ព័ន្ធនឹងប្រទេសជាក់លាក់ដែលបានអនុម័តតាំងពីឆ្នាំ២០០៦។ លិបិក្រមនេះនឹងផ្តល់លទ្ធភាពឲ្យពិនិត្យមើលអនុសាសន៍លើកឡើងនៅក្នុងក្របខណ្ឌនៃយន្តការពិនិត្យរបាយការណ៍ជាសាកលតាមកាលកំណត់នៃក្រុមប្រឹក្សាសិទ្ធិមនុស្ស។

ឧបសម្ព័ន្ធ

គិតត្រឹមខែកញ្ញា ឆ្នាំ២០០៨ មានយន្តការនីតិវិធីពិសេសចំនួន ៣៨ កំពុងដំណើរការ (៣០ ជាអាណត្តិការងារតាមវិស័យ និង ៨ ជាអាណត្តិការងារតាមប្រទេស)។

i. សម្រាប់បញ្ជីបច្ចុប្បន្នស្តីពីយន្តការនីតិវិធីពិសេស សូមចូលមកកាន់ផ្នែកស្តីពីយន្តការនីតិវិធីពិសេសនៅលើគេហទំព័រនៃការិយាល័យ OHCHR។

## ក. តារាងបង្ហាញអំពីអាណត្តិការងារតាមវិស័យ

| ឈ្មោះ/អាណត្តិការងារ | អាណត្តិការងារបានបង្កើតឡើង | | អាណត្តិការងារបានបន្តការងារ | |
|---|---|---|---|---|
| | ក្នុងឆ្នាំ | តាមរយៈ | ក្នុងឆ្នាំ | តាមរយៈ |
| **អ្នករាយការណ៍ពិសេសទទួល** | ២០០០ | សេចក្តីសម្រេចចិត្តនៃ | ២០០៧ | សេចក្តីសម្រេចចិត្ត |

| | | | | |
|---|---|---|---|---|
| បន្ទុកសិទ្ធិលំនៅដ្ឋានសមស្រប ដែលជាសមាសធាតុមួយនៃ សិទ្ធិទទួលបានកម្រិតជីវភាព រស់នៅសមរម្យ | | គណកម្មការសិទ្ធិ មនុស្សលេខ ២០០០/៩ | | នៃក្រុមប្រឹក្សា សិទ្ធិមនុស្សលេខ ៦/២៧ (រយៈពេល ៣ ឆ្នាំ) |
| ក្រុមការងារអ្នកជំនាញទទួល បន្ទុកជនជាតិភាគតិចអាហ្វ្រិក | ២០០២ | សេចក្តីសម្រេចចិត្តនៃ គណកម្មការសិទ្ធិ មនុស្សលេខ ២០០២/៦៨ | ២០០៨ | សេចក្តីសម្រេចចិត្ត នៃក្រុមប្រឹក្សា សិទ្ធិមនុស្សលេខ ៩/១៤ (រយៈពេល ៣ ឆ្នាំ) |
| ក្រុមការងារទទួលបន្ទុកការឃុំ ឃាំងតាមទំនើងចិត្ត | ១៩៩១ | សេចក្តីសម្រេចចិត្តនៃ គណកម្មការសិទ្ធិ មនុស្សលេខ ១៩៩១/៤២ | ២០០៧ | សេចក្តីសម្រេចចិត្ត នៃក្រុមប្រឹក្សាសិទ្ធិ មនុស្សលេខ ៦/៤ (រយៈពេល ៣ ឆ្នាំ) |
| អ្នករាយការណ៍ពិសេសទទួល បន្ទុកការលក់កុមារ ពេស្យាកម្ម កុមារ និងរូប ឬ សម្ភារៈអាស អាភាសកុមារ | ១៩៩០ | សេចក្តីសម្រេចចិត្តនៃ គណកម្មការសិទ្ធិ មនុស្សលេខ ១៩៩០/៦៨ | ២០០៨ | សេចក្តីសម្រេច ចិត្តនៃក្រុមប្រឹក្សា សិទ្ធិមនុស្សលេខ ៧/៣ (រយៈពេល ៣ ឆ្នាំ) |

| ឈ្មោះ/អាណត្តិការងារ | អាណត្តិការងារបានបង្កើតឡើង | | អាណត្តិការងារបានបន្តការងារ | |
|---|---|---|---|---|
| | ក្នុងឆ្នាំ | តាមរយៈ | ក្នុងឆ្នាំ | តាមរយៈ |
| **អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិទទួលការអប់រំ** | ១៩៩៨ | សេចក្តីសម្រេចចិត្តនៃគណកម្មការសិទ្ធិមនុស្សលេខ ១៩៩៨/៣៣ | ២០០៨ | សេចក្តីសម្រេចចិត្តនៃក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៨/៤ (រយៈពេល ៣ ឆ្នាំ) |
| **ក្រុមការងារទទួលបន្ទុកការបាត់ខ្លួនដោយបង្ខំ ឬ ដោយមិនស្ម័គ្រចិត្ត** | ១៩៨០ | សេចក្តីសម្រេចចិត្តនៃគណកម្មការសិទ្ធិមនុស្សលេខ ២០ (XXXVI) | ២០០៧ | សេចក្តីសម្រេចចិត្តនៃក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៧/១២ (រយៈពេល ៣ ឆ្នាំ) |
| **អ្នករាយការណ៍ពិសេសទទួលបន្ទុកការសម្លាប់ក្រៅប្រព័ន្ធតុលាការ ឬ ការពិឃាតតាមទំនើងចិត្ត** | ១៩៨២ | សេចក្តីសម្រេចចិត្តនៃគណកម្មការសិទ្ធិមនុស្សលេខ ១៩៨២/៣៥ | ២០០៨ | សេចក្តីសម្រេចចិត្តនៃក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៨/៣ (រយៈពេល ៣ ឆ្នាំ) |
| **អ្នកជំនាញឯករាជ្យទទួលបន្ទុកបញ្ហាសិទ្ធិមនុស្ស និងភាពក្រីក្រធ្ងន់ធ្ងរ** | ១៩៩៨ | សេចក្តីសម្រេចចិត្តគណកម្មការសិទ្ធិមនុស្សលេខ ១៩៩៨/២៥ | ២០០៨ | សេចក្តីសម្រេចចិត្តនៃក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៨/១១ (រយៈពេល ៣ ឆ្នាំ) |
| **អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិស្តីពីស្បៀងអាហារ** | ២០០០ | សេចក្តីសម្រេចចិត្តនៃគណកម្មការសិទ្ធិមនុស្សលេខ ២០០០/១០ | ២០០៧ | សេចក្តីសម្រេចចិត្តនៃក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៦/២ (រយៈពេល ៣ ឆ្នាំ) |
| **អ្នករាយការណ៍ពិសេសទទួល** | ១៩៩៣ | សេចក្តីសម្រេចចិត្តនៃ | ២០០៨ | សេចក្តីសម្រេចចិត្ត |

| | | | | |
|---|---|---|---|---|
| បន្ទុកការលើកកម្ពស់ និងការការពារសិទ្ធិទទួលបានសេរីភាពនៃការសម្តែងមតិ | | គណកម្មការសិទ្ធិមនុស្សលេខ ១៩៩៣/៤៥ | | នៃក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៧/៣៦ (រយៈពេល ៣ ឆ្នាំ) |

| ឈ្មោះ/អាណត្តិការងារ | អាណត្តិការងារបានបង្កើតឡើង | | អាណត្តិការងារបានបន្តការងារ | |
|---|---|---|---|---|
| | ក្នុងឆ្នាំ | តាមរយៈ | ក្នុងឆ្នាំ | តាមរយៈ |
| អ្នករាយការណ៍ពិសេសទទួលបន្ទុកសេរីភាពនៃសាសនា និងជំនឿ | ១៩៨៦ | សេចក្តីសម្រេចចិត្តនៃគណកម្មការសិទ្ធិមនុស្សលេខ ១៩៨៦/២០ | ២០០៧ | សេចក្តីសម្រេចចិត្តនៃក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៦/៣៧ (រយៈពេល ៣ ឆ្នាំ) |
| អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិរបស់បុគ្គលគ្រប់រូបក្នុងការទទួលបានសុខភាពផ្លូវកាយ និងផ្លូវចិត្តក្នុងកម្រិតខ្ពស់ | ២០០២ | សេចក្តីសម្រេចចិត្តនៃគណកម្មការសិទ្ធិមនុស្សលេខ ២០០២/៣១ | ២០០៧ | សេចក្តីសម្រេចចិត្តនៃក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៦/២៩ (រយៈពេល ៣ ឆ្នាំ) |
| អ្នករាយការណ៍ពិសេសទទួលបន្ទុកស្ថានភាពរបស់អ្នកការពារសិទ្ធិមនុស្ស (អតីតអ្នកតំណាងពិសេសនៃអគ្គលេខាធិការ) | ១៩៩៩ | សេចក្តីសម្រេចចិត្តនៃគណកម្មការសិទ្ធិមនុស្សលេខ ២០០០/៦១ | ២០០៨ | សេចក្តីសម្រេចចិត្តនៃក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៧/៨ (រយៈពេល ៣ ឆ្នាំ) |
| អ្នករាយការណ៍ពិសេសទទួលបន្ទុកឯករាជ្យភាពចៅក្រម និងមេធាវី | ១៩៩៤ | សេចក្តីសម្រេចចិត្តនៃគណកម្មការសិទ្ធិមនុស្សលេខ ១៩៩៤/៤១ | ២០០៨ | សេចក្តីសម្រេចចិត្តនៃក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៨/៦ (រយៈពេល ៣ ឆ្នាំ) |
| អ្នករាយការណ៍ពិសេសទទួលបន្ទុកស្ថានភាពសិទ្ធិមនុស្សនិង | ២០០១ | សេចក្តីសម្រេចចិត្តនៃគណកម្មការសិទ្ធិ | ២០០៧ | សេចក្តីសម្រេចចិត្តនៃក្រុមប្រឹក្សា |

| | | | | |
|---|---|---|---|---|
| **សេរីភាពជាសារវន្តរបស់ជនជាតិដើមភាគតិច** | | មនុស្សលេខ ២០០១/៥៧ | | សិទ្ធិមនុស្សលេខ ៦/១២ (រយៈពេល ៣ ឆ្នាំ) |

| ឈ្មោះ/អាណត្តិការងារ | អាណត្តិការងារបានបង្កើតឡើង | | អាណត្តិការងារបានបន្តការងារ | |
|---|---|---|---|---|
| | ក្នុងឆ្នាំ | តាមរយៈ | ក្នុងឆ្នាំ | តាមរយៈ |
| តំណាងអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សរបស់បុគ្គលដែលបាត់បង់លំនៅដ្ឋានក្នុងស្រុក | ២០០៤ | សេចក្តីសម្រេចចិត្តនៃគណកម្មការសិទ្ធិមនុស្សលេខ ២០០៤/៥៥ | ២០០៧ | សេចក្តីសម្រេចចិត្តនៃក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៦/៣២ (រយៈពេល ៣ ឆ្នាំ) |
| ក្រុមការងារទទួលបន្ទុកការប្រើប្រាស់ទាហានស៊ីឈ្នួលជាមធ្យោបាយនៃការរំលោភសិទ្ធិមនុស្ស និងការរាំងការអនុវត្តសិទ្ធិស្វ័យសម្រេច | ២០០៥ | សេចក្តីសម្រេចចិត្តនៃគណកម្មការសិទ្ធិមនុស្សលេខ ២០០៥/២ | ២០០៨ | សេចក្តីសម្រេចចិត្តនៃក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៧/២១ (រយៈពេល ៣ ឆ្នាំ) |
| អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិជនទេសន្តរប្រវេសន៍ | ១៩៩៩ | សេចក្តីសម្រេចចិត្តនៃគណកម្មការសិទ្ធិមនុស្សលេខ ១៩៩៩/៤៤ | ២០០៨ | សេចក្តីសម្រេចចិត្តនៃក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៨/១០ (រយៈពេល ៣ ឆ្នាំ) |
| អ្នកជំនាញឯករាជ្យទទួលបន្ទុកបញ្ហាជនជាតិភាគតិច | ២០០៥ | សេចក្តីសម្រេចចិត្តនៃគណកម្មការសិទ្ធិមនុស្សលេខ ២០០៥/៧៩ | ២០០៨ | សេចក្តីសម្រេចចិត្តនៃក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៧/៦ (រយៈពេល ៣ ឆ្នាំ) |
| អ្នករាយការណ៍ពិសេសទទួលបន្ទុកទម្រង់បច្ចុប្បន្ននៃការប្រកាន់ពូជសាសន៍ ការរើសអើងពូជសាសន៍ ការរើសអើងជនបរទេស និងការរើសអើងពាក់ព័ន្ធផ្សេងទៀត | ១៩៩៣ | សេចក្តីសម្រេចចិត្តនៃគណកម្មការសិទ្ធិមនុស្សលេខ ១៩៩៣/២០ | ២០០៨ | សេចក្តីសម្រេចចិត្តនៃក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៧/៣៤ (រយៈពេល ៣ ឆ្នាំ) |

| ឈ្មោះ/អាណត្តិការងារ | អាណត្តិការងារបានបង្កើតឡើង | | អាណត្តិការងារបានបន្តការងារ | |
|---|---|---|---|---|
| | ក្នុងឆ្នាំ | តាមរយៈ | ក្នុងឆ្នាំ | តាមរយៈ |
| អ្នករាយការណ៍ពិសេសទទួលបន្ទុកទម្រង់បច្ចុប្បន្ននៃទាសភាព រួមទាំង មូលហេតុ និងផលវិបាក | ២០០៧ | សេចក្តីសម្រេចចិត្តនៃក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៦/១៤ (រយៈពេល ៣ ឆ្នាំ) | | |
| អ្នកជំនាញឯករាជ្យទទួលបន្ទុកសិទ្ធិមនុស្ស និងសាមគ្គីភាពអន្តរជាតិ | ២០០៥ | សេចក្តីសម្រេចចិត្តនៃគណកម្មការសិទ្ធិមនុស្សលេខ ២០០៥/៥៥ | ២០០៨ | សេចក្តីសម្រេចចិត្តនៃក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៧/៥ (រយៈពេល ៣ ឆ្នាំ) |
| អ្នកជំនាញឯករាជ្យទទួលបន្ទុកផលប៉ះពាល់នៃបំណុលបរទេស និងកាតព្វកិច្ចហិរញ្ញវត្ថុអន្តរជាតិពាក់ព័ន្ធផ្សេងទៀតរបស់រដ្ឋលើការទទួលបានពេញលេញនូវសិទ្ធិមនុស្ស ជាពិសេស សិទ្ធសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ២០០០ | សេចក្តីសម្រេចចិត្តនៃគណកម្មការសិទ្ធិមនុស្សលេខ ២០០០/៨២ | ២០០៨ | សេចក្តីសម្រេចចិត្តនៃក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៧/៤ (រយៈពេល ៣ ឆ្នាំ) |
| អ្នកជំនាញឯករាជ្យទទួលបន្ទុកបញ្ហាកាតព្វកិច្ចសិទ្ធិមនុស្សក្នុងការទទួលបានទឹកស្អាតហូប និងអនាម័យ | ២០០៨ | សេចក្តីសម្រេចចិត្តនៃក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៧/២២ (រយៈពេល ៣ ឆ្នាំ) | | |

| ឈ្មោះ/អាណត្តិការងារ | អាណត្តិការងារបានបង្កើតឡើង | | អាណត្តិការងារបានបន្តការងារ | |
|---|---|---|---|---|
| | ក្នុងឆ្នាំ | តាមរយៈ | ក្នុងឆ្នាំ | តាមរយៈ |
| អ្នករាយការណ៍ពិសេសទទួលបន្ទុកការលើកកម្ពស់ និងការការពារសិទ្ធិមនុស្សខណៈប្រឆាំងអំពើភារវកម្ម | ២០០៥ | សេចក្តីសម្រេចចិត្តគណកម្មការសិទ្ធិមនុស្សលេខ ២០០៥/៨០ | ២០០៧ | សេចក្តីសម្រេចចិត្តនៃក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៦/២៨ (រយៈពេល ៣ ឆ្នាំ) |
| អ្នករាយការណ៍ពិសេសទទួលបន្ទុកទារុណកម្ម និងការប្រព្រឹត្ត ឬ ទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ និងការបន្ថោកបន្ទាបផ្សេងទៀត | ១៩៨៥ | សេចក្តីសម្រេចចិត្តនៃគណកម្មការសិទ្ធិមនុស្សលេខ ១៩៨៥/៣៣ | ២០០៨ | សេចក្តីសម្រេចចិត្តនៃក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៨/៨ (រយៈពេល ៣ ឆ្នាំ) |
| អ្នករាយការណ៍ពិសេសទទួលបន្ទុកផលប៉ះពាល់គ្រោះថ្នាក់នៃការបម្លាស់ទីទំនិញហាមឃាត់ខុសច្បាប់ និងការចាក់ចោលផលិតផល និងសម្រាមមានជាតិពុល និងគ្រោះថ្នាក់លើការទទួលបានសិទ្ធិមនុស្ស | ១៩៩៥ | សេចក្តីសម្រេចចិត្តនៃគណកម្មការសិទ្ធិមនុស្សលេខ ១៩៩៥/៨១ | ២០០៨ | សេចក្តីសម្រេចចិត្តនៃក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៩/១ (រយៈពេល ៣ ឆ្នាំ) |
| អ្នករាយការណ៍ពិសេសទទួលបន្ទុកទិដ្ឋភាពសិទ្ធិនៃការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ | ២០០៤ | សេចក្តីសម្រេចចិត្តនៃគណកម្មការសិទ្ធិមនុស្សលេខ ២០០៤/១១០ | ២០០៨ | សេចក្តីសម្រេចចិត្តនៃក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៨/១២ (រយៈពេល ៣ ឆ្នាំ) |

| ឈ្មោះ/អាណត្តិការងារ | អាណត្តិការងារបានបង្កើតឡើង | | អាណត្តិការងារបានបន្តការងារ | |
|---|---|---|---|---|
| | ក្នុងឆ្នាំ | តាមរយៈ | ក្នុងឆ្នាំ | តាមរយៈ |
| **តំណាងពិសេសនៃអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្ស និងសារជីវកម្មឆ្លងព្រំដែន និងសហគ្រាសអាជីវកម្ម** | ២០០៥ | សេចក្តីសម្រេចចិត្តនៃគណកម្មការសិទ្ធិមនុស្សលេខ ២០០៥/៦៩ | ២០០៨ | សេចក្តីសម្រេចចិត្តនៃក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៨/៧ (រយៈពេល ៣ ឆ្នាំ) |
| **អ្នករាយការណ៍ពិសេសទទួលបន្ទុកលើអំពើហិង្សាប្រឆាំងនឹងស្ត្រីភេទ មូលហេតុ និងផលវិបាក** | ១៩៩៤ | សេចក្តីសម្រេចចិត្តនៃគណកម្មការសិទ្ធិមនុស្សលេខ ១៩៩៤/៤៥ | ២០០៨ | សេចក្តីសម្រេចចិត្តនៃក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៧/២៤ (រយៈពេល ៣ ឆ្នាំ) |

## ខ. តារាងបង្ហាញអំពីអាណត្តិការងារប្រចាំប្រទេស

| ឈ្មោះ/អាណត្តិការងារ | អាណត្តិការងារបានបង្កើតឡើង | | អាណត្តិការងារបានបន្តការងារ | |
|---|---|---|---|---|
| | ក្នុងឆ្នាំ | តាមរយៈ | ក្នុងឆ្នាំ | តាមរយៈ |
| អ្នកជំនាញឯករាជ្យទទួលបន្ទុកសិទ្ធិមនុស្សនៅ Burndi | ២០០៤ | សេចក្តីសម្រេចចិត្តនៃគណកម្មការសិទ្ធិមនុស្សលេខ ២០០៤/៨២ (រយៈពេលនៃអាណត្តិការងារពុំបានបញ្ជាក់ | ២០០៨ | សេចក្តីសម្រេចចិត្តនៃក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៩/១៩ (រយៈពេលនៃអាណត្តិការងារពុំបានបញ្ជាក់) |
| តំណាងពិសេសនៃអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា | ១៩៩៣ | សេចក្តីសម្រេចចិត្តនៃគណកម្មការសិទ្ធិមនុស្សលេខ ១៩៩៣/៦ | ២០០៨ | សេចក្តីសម្រេចចិត្តនៃក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៩/១៥ (រយៈពេល ១ ឆ្នាំ) |
| អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិមនុស្សប្រចាំសាធារណរដ្ឋប្រជាធិបតេយ្យកូរ៉េ | ២០០៤ | សេចក្តីសម្រេចចិត្តនៃគណកម្មការសិទ្ធិមនុស្សលេខ ២០០៤/១៣ | ២០០៨ | សេចក្តីសម្រេចចិត្តនៃក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៧/១៥ (រយៈពេល ១ ឆ្នាំ) |
| អ្នកជំនាញឯករាជ្យដែលត្រូវបានតែងតាំងដោយអគ្គលេខាធិការទទួលបន្ទុកស្ថានភាពសិទ្ធិមនុស្សនៅហាទី | ១៩៩៥ | សេចក្តីសម្រេចចិត្តនៃគណកម្មការសិទ្ធិមនុស្សលេខ ១៩៩៥/៧០ | ២០០៨ | សេចក្តីថ្លែងការណ៍របស់ប្រធានក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ A/HCR/PRST/9/1 (រយៈពេល ២ ឆ្នាំ) |
| អ្នករាយការណ៍ពិសេសទទួលបន្ទុកស្ថានភាពសិទ្ធិមនុស្សនៅភូមា | ១៩៩២ | សេចក្តីសម្រេចចិត្តនៃគណកម្មការសិទ្ធិមនុស្សលេខ ១៩៩២/៥៨ | ២០០៨ | សេចក្តីសម្រេចចិត្តនៃក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៧/៣២ (រយៈពេល ១ ឆ្នាំ) |

| ឈ្មោះ/អាណត្តិការងារ | អាណត្តិការងារបានបង្កើតឡើង | | អាណត្តិការងារបានបន្តការងារ | |
|---|---|---|---|---|
| | ក្នុងឆ្នាំ | តាមរយៈ | ក្នុងឆ្នាំ | តាមរយៈ |
| អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិមនុស្សនៅលើទឹកដីប៉ាលេស្ទីនដែលបានកាន់កាប់តាំងពីឆ្នាំ១៩៦៧ | ១៩៩៣ | សេចក្តីសម្រេចចិត្តនៃគណកម្មការសិទ្ធិមនុស្សលេខ ១៩៩៣/២ A ("រហូតដល់ពេលបញ្ចប់ការកាន់កាប់របស់អ៊ីស្រាអែល") | | |
| អ្នកជំនាញឯករាជ្យដែលត្រូវបានតែងតាំងឲ្យទទួលបន្ទុកស្ថានភាពសិទ្ធិមនុស្សនៅសូម៉ាលី | ១៩៩៣ | សេចក្តីសម្រេចចិត្តនៃគណកម្មការសិទ្ធិមនុស្សលេខ ១៩៩៣/៨៦ | ២០០៨ | សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៧/៣៥ (រយៈពេល ១ ឆ្នាំ) |
| អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិមនុស្សនៅស៊ុយដង់ | ២០០៥ | សេចក្តីសម្រេចចិត្តនៃគណកម្មការសិទ្ធិមនុស្សលេខ ២០០៥/៨២ | ២០០៨ | សេចក្តីសម្រេចចិត្តនៃក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៩/១៧ (រយៈពេល ៩ ខែ) |

## VIII. ការដាក់បណ្ដឹងចោទប្រកាន់ការរំលោភសិទ្ធិមនុស្ស

| ទិដ្ឋភាពសង្ខេបនៃយន្តការនីតិវិធីបណ្ដឹង | | |
|---|---|---|
| *ដូចម្ដេចដែលហៅថាយន្តការនីតិវិធីបណ្ដឹង?*<br>យន្តការនីតិវិធីបណ្ដឹងផ្នែកសិទ្ធិមនុស្សគឺជាយន្តការដាក់បណ្ដឹងជូនទៅអង្គការសហប្រជាជាតិ អំពីការចោទប្រកាន់ការរំលោភសិទ្ធិមនុស្ស។ យន្តការបែបនេះមានចំនួនបីប្រភេទ៖<br>• បណ្ដឹងជាលក្ខណៈបុគ្គល ដូចដែលមានចែងនៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្ស (ញត្តិតវ៉ា)។<br>• បណ្ដឹងជាលក្ខណៈបុគ្គលក្រោម**យន្តការនីតិវិធីពិសេសនៃ**ក្រុមប្រឹក្សាសិទ្ធិមនុស្ស និង<br>• **យន្តការនីតិវិធីបណ្ដឹងរបស់**ក្រុមប្រឹក្សាសិទ្ធិមនុស្ស។<br>*តើយន្តការនីតិវិធីបណ្ដឹងដំណើរការដោយរបៀបណា?*<br>យន្តការនីតិវិធីនីមួយៗមានលក្ខខណ្ឌតម្រូវ អត្ថប្រយោជន៍ និងដែនកំណត់ផ្ទាល់របស់វា | • បណ្ដឹងជាលក្ខណៈបុគ្គលើការរំលោភសិទ្ធិមនុស្សអាចត្រូវបានដាក់ជូនពិនិត្យអនុលោមតាម**សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ**ចំបងចំនួនប្រាំ។<br>• បណ្ដឹងជាលក្ខណៈបុគ្គលដំណើរការអនុលោមតាមអាណត្តិការងារតាមវិស័យ និងភូមិសាស្ត្ររបស់យន្តការនិតិវិធីពិសេសនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស ។ និង<br>• យន្តការនីតិវិធីបណ្ដឹងរបស់ក្រុមប្រឹក្សាផ្ដោតទៅលើគំរូសង្គតិភាពនៃការរំលោភបំពានដ៏ធ្ងន់ធ្ងរ និងដែលមានទឡ្ហីករណ៍គួរឲ្យជឿទុកចិត្តបានលើសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តនៅតាមទីកន្លែងនានាក្នុងពិភពលោក និងក្រោមកាលៈទេសៈនានា។<br>*វិធីទាក់ទង និងបំពេញការងារជាមួយនឹងយន្តការនីតិវិធីបណ្ដឹង*<br>តួអង្គសង្គមស៊ីវិលណាមួយក៏ដោយ ក្រោយពីពិចារណាត្រឹមត្រូវលើតម្រូវការជាក់លាក់នៃនីតិវិធីនីមួយៗ | អាចប្រើប្រាស់យន្តការទាំងនេះ ទោះបីមានឋានៈយ៉ាងដូចម្ដេចជាមួយនឹងអង្គការសហប្រជាជាតិក៏ដោយ។ បណ្ដឹងក្រោមយន្តការនីតិវិធីនីមួយៗអាចត្រូវបានដាក់ជូនពិនិត្យដោយបុគ្គល ដែលទទួលរងការរំលោភសិទ្ធិមនុស្ស ឬដោយភាគីទីបីក្នុងនាមបុគ្គលនោះ ឧទាហរណ៍ អង្គការមិនមានរដ្ឋាភិបាល (NGO)។ ជារើយៗ តួអង្គសង្គមស៊ីវិល អាចបំពេញតួនាទីជាអ្នករាយការណ៍សម្រាប់បុគ្គលដែលស្វែងរកសំណងពីការរំលោភសិទ្ធិមនុស្ស តាមរយៈការដាក់បណ្ដឹងក្នុងនាម |

| | | |
|---|---|---|
| ដែល ត្រូវយកមកពិចារណាដោយប្រុងប្រយ័ត្ន មុននឹងសម្រេចថាតើត្រូវប្រើយន្តការនីតិវិធីណាមួយៈ | | ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ បុគ្គលណាដែលបានដាក់បណ្តឹងក្នុងនាមបុគ្គលផ្សេង គួរសុំការយល់ព្រមពីបុគ្គលនោះ ហើយធ្វើយ៉ាងណាឲបុគ្គលនោះបានដឹងអំពីផលប៉ះពាល់នៃការប្តឹង។ អ្នកដាក់បណ្តឹងគួរគោរពតាមលក្ខខណ្ឌនៃយន្តការនីតិវិធីនីមួយៗដោយប្រុងប្រយ័ត្ន ដើម្បីធានាថាពាក្យបណ្តឹងនោះអាចទទួលយក។ |

i. អាសយដ្ឋានទំនាក់ទំនងនៃយន្តការបណ្តឹងផ្នែកសិទ្ធិមនុស្ស
បណ្តឹងដូចមានចែងនៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្ស
(ដាក់ជូន គណៈកម្មាធិការសិទ្ធិមនុស្ស គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម គណៈកម្មាធិការទទួលបន្ទុកលុបបំបាត់ការរើសអើងចំពោះស្ត្រីភេទ គណៈកម្មាធិការទទួលបន្ទុកលុបបំបាត់ការរើសអើងពូជសាសន៍ ឬគណៈកម្មាធិការទទួលបន្ទុកសិទ្ធិជនពិការ)

ក្រុមទទួលបណ្តឹង
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-4, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរសារលេខ៖ +៤១ (០)២២ ៩១៧ ៩០ ២២
អ៊ីម៉ែល៖ tb-petitions@ohchr.org

បណ្តឹងអនុលោមតាមយន្តការនីតិវិធីពិសេស
ផ្នែកនីតិវិធីពិសេស
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-4, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរសារលេខ៖ +៤១ (០)២២ ៩១៧ ៩០ ០៦
អ៊ីម៉ែល៖ urgent-action@ohchr.org

យន្តការនីតិវិធីបណ្តឹងរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស
សាខាក្រុមប្រឹក្សាសិទ្ធិមនុស្ស (យន្តការនីតិវិធីបណ្តឹង)
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-4, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរសារលេខ៖ +៤១ (០)២២ ៩១៧ ៩០ ១១
អ៊ីម៉ែល៖ CP@ohchr.org

## អ្វីទៅជាយន្តការនីតិវិធីបណ្តឹង?

ប្រព័ន្ធអង្គការសហប្រជាជាតិ ផ្តោតភាគច្រើនទៅលើកាតព្វកិច្ចរបស់រដ្ឋ និងដំណើរការនៅកម្រិតរដ្ឋាភិបាល។ ទោះជាយ៉ាងណាក៏ដោយ ប្រព័ន្ធសិទ្ធិមនុស្សរបស់ខ្លួន ក៏រួមបញ្ចូលផងដែរនូវនីតិវិធីខុសៗគ្នា ដែលបើកជូនបុគ្គល និងក្រុមមនុស្សដែលស្វែងរកវិធានការរបស់អង្គការសហប្រជាជាតិលើស្ថានភាពសិទ្ធិមនុស្សដែលជាកង្វល់ចំពោះពួកគេ។ ទាំងនេះ ត្រូវបានហៅថា យន្តការនីតិវិធីបណ្តឹងផ្នែកសិទ្ធិមនុស្ស។

តាមរយៈយន្តការនីតិវិធីទាំងនេះ បុគ្គលិក្ខទាំងឡាយអាចជម្រាបជូនអង្គការសហប្រជាជាតិអំពីកង្វល់ផ្នែកសិទ្ធិមនុស្ស។ មនុស្សរាប់ពាន់នាក់នៅជុំវិញពិភពលោកធ្វើដូច្នេះរាងរាល់ឆ្នាំ។

បណ្តឹងផ្នែកសិទ្ធិមនុស្ស អាចត្រូវបានដាក់ជូនពិនិត្យក្រោមយន្តការទាំងបីនេះ៖

- **សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ** (ញត្តិតវ៉ា)។
- **យន្តការនីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស** និង
- **យន្តការនីតិវិធីបណ្តឹងរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស**។

ក្រោមកាលៈទេសៈខ្លះ យន្តការនីតិវិធីខុសៗគ្នាអាចបំពេញគ្នាទៅវិញទៅមក ហើយយន្តការនីតិវិធីលើសពីមួយអាចត្រូវបានប្រើប្រាស់។

## តើយន្តការនីតិវិធីបណ្តឹងដំណើរការដោយរបៀបណា?

វាមានលក្ខណៈសំខាន់ក្នុងការពិចារណាដោយប្រុងប្រយ័ត្ន ថាតើយន្តការនីតិវិធីបណ្តឹងណាសមស្របបំផុតចំពោះករណីពិសេសណាមួយ។ យន្តការនីតិវិធីបណ្តឹងនីមួយៗមានចំណុចខ្លាំង លក្ខខណ្ឌតម្រូវជាក់លាក់ និងការកម្រិតរបស់វា។ យនត្តារនីតិវិធីបណ្តឹងទាំងនេះចាំបាច់ត្រូវពិចារណាជាប្រយោជន៍ដល់ជនរងគ្រោះ និងបុគ្គល ឬអង្គការមួយ ដែលដាក់បណ្តឹងនោះ។

## ក. បណ្តឹងជាលក្ខណៈបុគ្គល ដូចដែលមានចែងនៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ

សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិចំនួនប្រាំពីរ អនុញ្ញាតឲ្យមានបណ្តឹងជាលក្ខណៈបុគ្គលជូនទៅគណកម្មាធិការសិទ្ធិមនុស្ស៖

- **កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស និងសិទ្ធិនយោបាយ ក្រោមពិធីសារបន្ថែមទីមួយរបស់វា**។

- **អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅអមនុស្សធម៌ ឬបន្ថោកបន្ទាប** ដូចដែលមានចែងនៅក្នុងមាត្រា ២២។
- **អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងចំពោះស្ត្រីភេទ** ក្រោមពិធីសារបន្ថែមរបស់វា (សន្ធិសញ្ញានេះ ក៏អនុញ្ញាតផងដែរឲ្យដាក់បណ្តឹងពីក្រុមបុគ្គល)។
- **អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍** ដូចដែលមានចែងនៅក្នុងមាត្រា ១៤ (សន្ធិសញ្ញានេះ គ៏អនុញ្ញាតឲ្យដាក់មានបណ្តឹងពីក្រុមបុគ្គល)។
- **អនុសញ្ញាអន្តរជាតិស្តីពីកិច្ចការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍ និងសមាជិកទាំងអស់របស់គ្រួសារពួកគេ** ដូចដែលមានចែងនៅក្នុងមាត្រា ៧៧។ ទោះជាយ៉ាងណាក៏ដោយ បទបញ្ញត្តិនេះ នឹងចូលជាធរមាន តែនៅពេលបន្ទាប់ពីភាគីរដ្ឋចំនួន ១០ បានធ្វើសេចក្តីប្រកាសទទួលស្គាល់។[69]
- **អនុសញ្ញាស្តីពីសិទ្ធិរបស់ជនពិការ** ក្រោមពិធីសារបន្ថែមរបស់វា (សន្ធិសញ្ញានេះ ក៏អនុញ្ញាតផងដែរឲ្យមានបណ្តឹងពីក្រុមបុគ្គល) និង
- **អនុសញ្ញាអន្តរជាតិដើម្បីកិច្ចការពារមនុស្សទាំងអស់ពីការបាត់ខ្លួនដោយបង្ខំ** ដូចដែលមានចែងនៅក្នុងមាត្រា ១៣។ នៅត្រឹមខែ កញ្ញា ឆ្នាំ២០០៨ អនុសញ្ញានេះ មិនទាន់ចូលជាធរមាននៅឡើយទេ។

នៅពេលចូលជាធរមាន **ពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌**[70] ក៏នឹងអនុញ្ញាតឲ្យមានបណ្តឹងជាលក្ខណៈបុគ្គលផងដែរ។

ចំណុចខ្លាំង

- អត្ថប្រយោជន៍សំខាន់នៃការដាក់បណ្តឹងទៅគណកម្មាធិការ គឺថា កាលណាភាគីរដ្ឋបានធ្វើសេចក្តីប្រកាសដែលពាក់ព័ន្ធភ្លាម ដូចដែលមានចែងនៅក្នុងសន្ធិសញ្ញា **ភាគីរដ្ឋនោះគួរតែអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួន** ដូចដែលមានចែងនៅក្នុងសន្ធិសញ្ញា ក្នុងនោះរួមមានកាតព្វកិច្ចក្នុងការផ្តល់ឧបាស្រ័យប្រកបដោយប្រសិទ្ធភាព ចំពោះការបំពានសន្ធិសញ្ញា។

---

[69] នៅត្រឹមខែកញ្ញា ឆ្នាំ២០០៨ រដ្ឋតែមួយប៉ុណ្ណោះបានធ្វើសេចក្តីប្រកាសបែបនេះ។

[70] ពិធីសារបន្ថែមត្រូវបានអនុម័តដោយក្រុមប្រឹក្សា នៅថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ២០០៨ និងត្រូវបានរំពឹងទុកថានឹងបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅពេលបន្ទាប់មក នៅក្នុងឆ្នាំ២០០៨។

គណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សដែលពាក់ព័ន្ធ តាមរយៈបណ្តឹងជាលក្ខណៈបុគ្គល កំណត់ដោយអាជ្ញាព្រឹត្តថាតើមានការរំលោភបំពាន ហើយរដ្ឋដែលពាក់ព័ន្ធមានកាតព្វកិច្ចអនុវត្តរបកគំហើញរបស់គណកម្មាធិការ ឬអត់។

- គណកម្មាធិការសិទ្ធិមនុស្សអាចចេញវិធានការបណ្តោះអាសន្ននៅក្នុងករណីបន្ទាន់ ដើម្បីរក្សាស្ថានភាពដូចដើមរហូតដល់គណកម្មាធិការសិទ្ធិមនុស្សទាំងនេះ ធ្វើសេចក្តីសម្រេចជាស្ថាពរលើបញ្ហានេះ។ វិធានការបណ្តោះអាសន្ននឹងនៅជាធរមានរហូតដល់សេចក្តីសម្រេចត្រូវបានធ្វើឡើង។
- សេចក្តីសម្រេចរបស់គណកម្មាធិការសិទ្ធិមនុស្ស អាចមានប្រសិទ្ធភាពហួសពីកាលៈទេសៈនៃករណីជាលក្ខណៈបុគ្គល និងផ្តល់នូវគោលការណ៍ណែនាំសកម្មជាងមុនដើម្បីទប់ស្កាត់ការរំលោភបំពានស្រដៀងគ្នានេះដែលនឹងកើតមានឡើងនៅពេលអនាគត។
- គណកម្មាធិការសិទ្ធិមនុស្សក៏អាចពិចារណាផងដែរ លើពាក្យបណ្តឹងដែលកំពុងត្រូវបាន ឬត្រូវបានដោះស្រាយដោយយន្តការនីតិវិធីពិសេស។

លក្ខខណ្ឌតម្រូវជាក់លាក់ និងដែនកំណត់

- បណ្តឹងរបស់ម្ចាស់បណ្តឹង ត្រូវតែស្ថិតនៅក្នុងវិសាលភាពនៃការអនុវត្តសន្ធិសញ្ញាមួយក្នុងចំណោមសន្ធិសញ្ញាជាច្រើនដែលអនុញ្ញាតឲ្យមានបណ្តឹងជាលក្ខណៈបុគ្គល។
- រដ្ឋដែលត្រូវបានប្តឹងត្រូវតែជាភាគីនៃសន្ធិសញ្ញានេះ និងត្រូវតែផ្តល់សច្ចាប័នលើពិធីសារបន្ថែមពាក់ព័ន្ធ ឬ បានទទួលយកសមត្ថកិច្ចរបស់គណកម្មាធិការសិទ្ធិមនុស្សជាក់លាក់ដើម្បីទទួលពាក្យបណ្តឹងបាន។
- នៅពេលដាក់ការចោទប្រកាន់ទៅកាន់គណកម្មាធិការសិទ្ធិមនុស្ស លក្ខខណ្ឌតម្រូវមួយចំនួនត្រូវតែបំពេញ ក្នុងនោះរួមមាន ការយល់ព្រម ឬការអនុញ្ញាតរបស់ជនរងគ្រោះផងដែរ។ ប្រសិនបើលក្ខខណ្ឌតម្រូវណាមួយក្នុងចំណោមលក្ខខណ្ឌតម្រូវទាំងនេះមិនត្រូវបានបំពេញ ឬបាត់នោះ ពាក្យបណ្តឹងអាចមិនត្រូវយកមកពិចារណា។

- ដូចដែលមានចែងនៅក្នុងអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ បណ្តឹងត្រូវធ្វើឡើងនៅក្នុងរយៈពេលប្រាំមួយខែ បន្ទាប់ពីសេចក្តីសម្រេចចុងក្រោយរបស់អាជ្ញាធរជាតិលើករណីណាមួយ។

- ម្ចាស់បណ្តឹងត្រូវប្រើប្រាស់ឲ្យអស់នូវឧបាស្រ័យប្រកបដោយប្រសិទ្ធភាពក្នុងស្រុកជាធរមានឲ្យអស់មុនពេលដាក់បណ្តឹងជូនទៅគណកម្មាធិការ --ឧបាស្រ័យត្រូវបានចាត់ទុកថាមានប្រសិទ្ធិភាព ប្រសិនបើឧបាស្រ័យនោះផ្តល់នូវទិដ្ឋភាពសមស្របនៃសំណងសម្រាប់ម្ចាស់បណ្តឹង។

- វាត្រូវការរយៈពេលជាមធ្យមពីពីរទៅបីឆ្នាំ សម្រាប់ការធ្វើសេចក្តីសម្រេចចុងក្រោយលើបណ្តឹងមួយ។

- ជាទូទៅ បណ្តឹងដែលដាក់ជូនគណកម្មាធិការសិទ្ធិមនុស្ស មិនទាក់ទងទៅនឹងបែបផែនដ៏ទូលំទូលាយនៃការរំលោភសិទ្ធិមនុស្សទេ។

- គណកម្មាធិការសិទ្ធិមនុស្សអាចមិនពិចារណាលើករណីដែលកំពុងត្រូវបានពិចារណាដោយយន្តការនីតិវិធីបណ្តឹងតាមផ្លូវតុលាការមួយផ្សេងទៀតនៅថ្នាក់អន្តរជាតិ ឬថ្នាក់តំបន់រួចហើយ[71]។

| |
|---|
| i. សម្រាប់ព័ត៌មានពិស្តារស្តីពី**គណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស** សូមមើលជំពូក IV (**គណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស**) នៃ*សៀវភៅណែនាំ*នេះ។ |

## ខ. បណ្តឹងក្រោមយន្តការពិសេស

នីតិវិធីពិសេសមួយចំនួនអនុញ្ញាតឲ្យមានការធ្វើការការចោទប្រកាន់នានា ពាក់ព័ន្ធនឹងករណីជាលក្ខណៈបុគ្គល ឬបែបផែននៃការរំលោភសិទ្ធិមនុស្សដែលមានទម្រង់លើសពីលក្ខណៈទូទៅ។ បុគ្គលទាំងអស់ ឬអ្នកដ៏ទៃទៀតដែលបំពេញមុខងារក្នុងនាមបុគ្គល អាចដាក់ ករណីជាលក្ខណៈបុគ្គលទៅមន្ត្រីកាន់កាប់អាណត្តិការងារនៃយន្តការនីតិវិធីពិសេស ប្រសិនបើអាណត្តិការងារនោះ

[71] នេះអាចជាស្ថាប័នសន្ធិសញ្ញាមួយផ្សេងទៀត តុលាការសិទ្ធិមនុស្សរបស់អឺរ៉ុប ឬតុលាការសិទ្ធិមនុស្សអន្តរអាមេរិក ប៉ុន្តែមិនរួមបញ្ចូលយន្តការពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សទេ។

អនុញ្ញាត។ ជារឿយៗ តួអង្គសង្គមស៊ីវិលអាចគាំទ្រដល់បុគ្គលទាំងឡាយដែលស្វែងរកកិច្ចការពារការរំលោភសិទ្ធិមនុស្ស។

ចំណុចខ្លាំង

- បណ្តឹងជាលក្ខណៈបុគ្គលក្រោមនីតិវិធីពិសេសគឺជានីតិវិធីដែលអាចត្រូវបានប្រើប្រាស់សម្រាប់ករណីជាលក្ខណៈបុគ្គល ក៏ដូចជាបែបផែននៃការរំលោភបំពានក្នុងទម្រង់លើសពីលក្ខណៈទូទៅ។
- នីតិវិធីទាំងនេះអាចជាឧបករណ៍មានប្រយោជន៍នៅក្នុងករណីបន្ទាន់ ដោយហេតុថា វាអនុញ្ញាតឲ្យមានវិធានការបន្ទាន់ ឬទប់ស្កាត់ (ដែលត្រូវបានគេស្គាល់ថាជា **ការអំពាវនាវបន្ទាន់**)។
- ករណីនានាអាចត្រូវបាននាំយកមកជំនុំជម្រះទោស **ដោយមិនគិតដល់រដ្ឋដែលកើតមាន** ករណីទាំងនេះឡើយ និងដោយមិនគិតថាតើរដ្ឋនោះបានផ្តល់សច្ចាប័នលើសន្ធិសញ្ញាសិទ្ធមនុស្សណាមួយ ក្នុងចំណោមសន្ធិសញ្ញាសិទ្ធិមនុស្សជាច្រើនដែរឬអត់។
- វាមិនចាំបាច់ប្រើប្រាស់ឲ្យអស់នូវឧបាស្រ័យក្នុងស្រុកទាំងអស់ មុននឹងប្រើប្រាស់នីតិវិធីនេះទេ។
- ពាក្យបណ្តឹងមិនត្រូវចាំបាច់តែធ្វើឡើងដោយជនរងគ្រោះនោះទេទោះបីជាយ៉ាងណាប្រភពនៃបណ្តឹងត្រូវតែជឿទុកចិត្តបាន និង
- បណ្តឹងអាចធ្វើឡើងនៅពេលជាមួយគ្នា នៅចំពោះមុខគណកម្មាធិការសិទ្ធិមនុស្ស និងនីតិវិធីពិសេស (ប្រសិនបើមានអាណត្តិកាងារមានលក្ខណៈពាក់ព័ន្ធគ្នា)។

ដែនកំណត់

- ត្រូវតែមាននីតិវិធីពិសេសដែលរួមបញ្ចូលបញ្ហាសិទ្ធិមនុស្សជាក់លាក់ ឬប្រទេសជាក់លាក់ (មិនមែនមន្ត្រីកាន់កាប់អាណត្តិការងារនៃនីតិវិធីពិសេសទាំងអស់សុទ្ធតែអាចអនុវត្តវិធានការផ្អែកតាមករណីជាលក្ខណៈបុគ្គលនោះទេ)។
- នីតិវិធីពិសេសមិនមែនជានីតិវិធីដែលភ្ជាប់កាតព្វកិច្ចផ្លូវច្បាប់នោះទេ៖ វាជាឆន្ទានុសិទ្ធិរបស់រដ្ឋនីមួយៗក្នុងការអនុវត្តតាមអនុសាសន៍របស់មន្ត្រីកាន់កាប់អាណត្តិការងារនៃនីតិវិធីពិសេស និង
- នីតិវិធីនានាប្រែប្រួលទៅតាមអាណត្តិនោះ។

i. សម្រាប់ព័ត៌មានពិស្តារស្តីពី**នីតិវិធីពិសេស** សូមមើលជំពូក VI (**នីតិវិធីពិសេស**) នៃ*សៀវភៅណែនាំ*នេះ។

## គ. នីតិវិធីបណ្ដឹងរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស

បុគ្គល ឬក្រុមណាមួយដែលអះអាងថាជាជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្ស អាចបណ្ដឹងដូចដែលមានចែងនៅក្នុងនីតិវិធីនេះ ហើយមនុស្ស ឬក្រុមណាមួយផ្សេងទៀតដែលបានដឹងព័ត៌មានដោយផ្ទាល់ និងដែលគួរឲ្យជឿទុកចិត្តបានស្ដីពីការរំលោភបែបនេះ ក៏អាចដាក់បណ្ដឹងដូចដែលមានចែងនៅក្នុងនីតិវិធីនេះបានដែរ។ នីតិវិធីបណ្ដឹងរបស់ក្រុមប្រឹក្សាគឺជានីតិវិធីបណ្ដឹងជាសកលតែមួយគត់ ដែលរួមបញ្ចូលសិទ្ធិមនុស្ស និងសេរីភាពជាសារវ័ន្តនៅក្នុងរដ្ឋទាំងអស់។

ចំណុចខ្លាំង

- នីតិវីធីនេះអាចដោះស្រាយបញ្ហាការរំលោភសិទ្ធិមនុស្ស និងសេរីភាពជាសារវ័ន្ត។ រដ្ឋមិនចាំបាច់ក្លាយជាភាគីនៃសន្ធិសញ្ញាចំពោះបណ្ដឹងប្រឆាំងនឹងរដ្ឋដែលបានដាក់ក្រោមនីតិវិធីនេះទេ។
- បណ្ដឹងអាចធ្វើឡើងចំពោះរដ្ឋណាក៏បាន។
- បណ្ដឹងអាចដាក់ជូនដោយជនរងគ្រោះ ឬ នរណាម្នាក់ដែលបំពេញមុខងារក្នុងនាមជនរងគ្រោះ និងមិនចាំបាច់តម្រូវឲ្យមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីជនរងគ្រោះនោះទេ។
- ម្ចាស់បណ្ដឹង (ម្ចាស់បណ្ដឹង) ត្រូវបានជូនដំណឹងអំពីសេចក្ដីសម្រេចដែលត្រូវបានធ្វើឡើងនៅក្នុងដំណាក់កាលសំខាន់បំផុតផ្សេងៗនៃដំណើរការនេះ និង
- ជាទូទៅលក្ខខណ្ឌនៃភាពអាចទទួលយកបាន មិនសូវតឹងរ៉ឹងដូចយន្តការបណ្ដឹងផ្សេងទៀតនោះឡើយ។

ដែនកំណត់ដែលអាចមាន

- ដំណើរការនេះអាចអូសបន្លាយពេលយូរ ដោយហេតុថាបណ្ដឹងត្រូវឆ្លងកាត់ដំណាក់កាលមួយចំនួនសម្រាប់ការពិចារណា ហើយហេតុដូច្នេះ យន្តការនេះ មិនសមប្រើប្រាស់សម្រាប់ករណីបន្ទាន់នោះទេ។
- ម្ចាស់បណ្ដឹងត្រូវតែប្រើប្រាស់ឲ្យអស់នូវឧបាស្រ័យប្រកបដោយប្រសិទ្ធិក្នុងស្រុកជាធរមានទាំងអស់មុនពេលធ្វើព័ត៌មានអនុលោមតាមនីតិវិធីនេះ។
- មិនមានបទប្បញ្ញត្តិចែងអំពីវិធានការការពារបណ្ដោះអាសន្នជាបន្ទាន់នោះទេ។
- ជាទូទៅ បណ្ដឹងត្រូវតែរៀបចំផ្អែកតាមគំរូសង្គតិភាពនៃការរំលោភសិទ្ធិមនុស្ស ពោលគឺការរំលោភដែលប៉ះពាល់លើមនុស្សជាច្រើន ពុំមែនករណីបុគ្គលម្នាក់ៗនោះទេ ។

- ដោយសារតែភាពសម្ងាត់ នីតិវិធីនេះមិនអាចទាញការចាប់អារម្មណ៍ជាសាធារណៈ លើស្ថានភាពសិទ្ធិមនុស្សនៅក្នុងរដ្ឋណាមួយជាក់លាក់នោះទេ និង
- ករណីដែលហាក់ដូចជាបង្ហាញបែបផែនសង្គតិភាពនៃការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ដែលត្រូវបានដោះស្រាយរួចហើយដោយនីតិវិធីពិសេស គណកម្មាធិការ ឬ អង្គការសហប្រជាជាតិផ្សេងទៀត ឬនីតិវិធីបណ្ដឹងផ្នែកសិទ្ធិមនុស្សថ្នាក់តំបន់ស្រដៀងគ្នានេះ មិនអាចទទួលយកក្រោមនីតិវិធីនេះទេ។

i. សម្រាប់ព័ត៌មានបន្ថែមស្ដីពី**និតិវិធីបណ្ដឹង** សូមមើលជំពូក V (ក្រុមប្រឹក្សាសិទ្ធិមនុស្ស) នៃ*សៀវភៅណែនាំ*នេះ។

## វិធីប្រើប្រាស់ និងបំពេញការងារជាមួយនឹងនិតិវិធីបណ្ដឹង

តួអង្គសង្គមស៊ីវិលណាមួយ ក្រោយពីបានគោរពលក្ខខណ្ឌតម្រូវជាក់លាក់របស់នីតិវិធីនីមួយៗ អាចប្រើប្រាស់នីតិវិធីបណ្ដឹងបាន។ ពាក្យបណ្ដឹងតាមនីតិវិធីនីមួយៗ អាចដាក់ជូនដោយបុគ្គលដែលទទួលរងការរំលោភសិទ្ធិមនុស្ស ឬ ដោយភាគីទីបីក្នុងនាមបុគ្គលនោះ ឧទាហរណ៍៖ អង្គការមិនមែនរដ្ឋាភិបាល។

ជារឿយៗ តួអង្គសង្គមស៊ីវិលបំពេញតួនាទីជាអ្នករាយការណ៍សម្រាប់បុគ្គលដែលស្វែងរកសំណងពីការរំលោភសិទ្ធិមនុស្ស តាមរយៈការរៀបចំ ការដាក់បណ្ដឹងក្នុងនាមបុគ្គលទាំងនោះ។ ទោះជាយ៉ាងណាក៏ដោយ អ្នកណាក៏ដោយដែលដាក់បណ្ដឹងក្នុងនាមបុគ្គល គួរតែ ទទួលបានការយល់ព្រមពីបុគ្គលនោះ និងធានាថាបុគ្គលនោះដឹងអំពីផលប៉ះពាល់ពីដំណើរនេះ។ ឧទាហរណ៍៖ នៅពេលដាក់ព័ត៌មាន ជូននីតិវិធីពិសេស មន្ត្រីកាន់កាប់អាណត្តិការងារបញ្ជូនបណ្ដឹងទៅរដ្ឋដែលពាក់ព័ន្ធនឹងករណីនេះ។ នៅទីបំផុត ករណីនេះនឹងត្រូវបញ្ចូលទៅក្នុងរបាយការណ៍ជាសាធារណៈ។ នៅពេលដែលដាក់បណ្ដឹងទៅគណកម្មាធិការសិទ្ធិមនុស្ស អត្តសញ្ញាណរបស់បុគ្គលនឹងត្រូវបានបញ្ចេញឲ្យរដ្ឋាភិបាលបានដឹង។ ហេតុដូច្នេះ វាមានលក្ខណៈសំខាន់ជាសារវន្តសម្រាប់ជនរងគ្រោះដែលចោទប្រកាន់នោះត្រូវដឹងច្បាស់អំពីរបៀបដែលនីតិវិធីបណ្ដឹងនីមួយៗដំណើរការ។

តម្រូវការសម្រាប់នីតិវិធីនីមួយៗក៏គួរតែត្រូវបានអនុវត្តតាមដោយប្រុងប្រយ័ត្ន ដើម្បីធានាថាបណ្ដឹងអាចទទួលយកបាន។

## ក. បណ្ដឹងជាលក្ខណៈបុគ្គលអនុលោមតាមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ

ការប្ដឹងអាចត្រូវបានធ្វើឡើងដោយបុគ្គល ឬភាគីទីបីដែលត្រូវបានអនុញ្ញាតដោយត្រឹមត្រូវ ឧទាហរណ៍៖ អ្នកច្បាប់ អង្គការមិនមែនរដ្ឋាភិបាល (NGO) ឬក្រុមអ្នកវិជ្ជាជីវៈ ក្នុងនាមបុគ្គលដែលបានអះអាងថាជាជនរងគ្រោះដោយការរំលោភបំពានលើសិទ្ធិមនុស្ស។ ផ្នែកនេះត្រួតពិនិត្យលើលក្ខខណ្ឌតម្រូវ និងធាតុផ្សំសំខាន់បំផុតនៃបណ្ដឹងជាលក្ខណៈបុគ្គល។

## លក្ខខណ្ឌតម្រូវ

### ១. ការផ្ដល់សច្ចាប័នរបស់ភាគីរដ្ឋ

បណ្ដឹងលើការរំលោភសិទ្ធិមនុស្សដូចដែលមានចែងនៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្ស អាចត្រូវបានធ្វើឡើងចំពោះរដ្ឋមួយប្រសិនបើ៖

- រដ្ឋនោះគឺជាភាគីនៃសន្ធិសញ្ញា ក្រោយពីបានផ្ដល់សច្ចាប័ន ឬបើមិនដូច្នោះទេបានទទួលយក និង
- ភាគីរដ្ឋបានទទួលស្គាល់សមត្ថកិច្ចរបស់គណកម្មាធិការសិទ្ធិមនុស្ស ដែលត្រូវបានកំណត់នៅក្នុងសន្ធិសញ្ញានោះ ក្នុងការពិចារណាលើបណ្ដឹងបែបនេះ។ អាស្រ័យតាមសន្ធិសញ្ញានីមួយៗ ពេលខ្លះ វាតម្រូវឲ្យរដ្ឋក្លាយជាភាគីនៃពិធីសារបន្ថែមពាក់ព័ន្ធ ឬក៏ធ្វើសេចក្ដីប្រកាសចាំបាច់ណាមួយដូចមានចែងនៅក្នុងសន្ធិសញ្ញា។

ចូរកត់សម្គាល់ ថា ភាគីរដ្ឋមួយចំនួនអាចធ្វើឧព្យូបញ្ញត្តិ ឬសេចក្ដីប្រកាសសំខាន់ណាមួយដែលកម្រិតលក្ខខណ្ឌវិសាលភាពនៃកាតព្វកិច្ចផ្នែកសិទ្ធិមនុស្ស ដូចមានចែងនៅក្នុងសន្ធិសញ្ញានានា។ ករណីទាំងអស់នេះគួរត្រួតពិនិត្យឡើងវិញនៅពេលកំណត់ថាតើបណ្ដឹងអាចធ្វើឡើងបានដែរឬអត់ អនុលោមតាមផ្នែកជាក់លាក់ណាមួយមួយនៃសន្ធិសញ្ញា[72]។

### ២. ការរំលោភបំពានជាលក្ខណៈបុគ្គល

បណ្ដឹងជាលក្ខណៈបុគ្គលនៅក្រោមគណកម្មាធិការ អាចត្រូវបានប្រើប្រាស់សម្រាប់តែ**ករណីនៃការរំលោភសិទ្ធិមនុស្សពាក់ព័ន្ធនឹងបុគ្គលម្នាក់ ឬច្រើននាក់**។ តាមធម្មតា បណ្ដឹងប្រភេទនេះមិនសមនឹងប្ដឹងចំពោះបែបផែននៃការរំលោភសិទ្ធិមនុស្សចំពោះករណីទូទៅចំពោះអញ្ញត្តិជននោះទេ។

### ៣. ឧបាស្រ័យក្នុងស្រុក

[72] ដើម្បីរកបានព័ត៌មានបន្ថែមស្ដីពីទាំងស្ថានភាពផ្ដល់សច្ចាប័ន និងសេចក្ដីប្រកាស/ឧព្យូបញ្ញត្តិចំពោះសន្ធិសញ្ញានីមួយៗ និងពិធីសារបន្ថែមដែលពាក់ព័ន្ធ សូមចុចត្រង់នេះ។

បណ្តឹងជាលក្ខណៈបុគ្គលដូចដែលមានចែងនៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិអាចដាក់ជូនពិនិត្យ តែនៅពេលដែល**ឧបាស្រ័យក្នុងស្រុកប្រកបដោយប្រសិទ្ធភាពត្រូវបាន ប្រើប្រាស់អស់**ប៉ុណ្ណោះ បានន័យ នៅពេលករណី/បណ្តឹងបានឆ្លងកាត់គ្រប់ដំណាក់កាលផ្សេងៗនៃប្រព័ន្ធតុលាការក្នុងស្រុក ឬតាមរយៈដំណាក់កាលនៃដំណើរការនីតិវិធីរដ្ឋបាលមួយចំនួន ដែលអនុវត្តចំពោះឧបាស្រ័យប្រកបដោយប្រសិទ្ធភាព និងជាធរមាន នៅក្នុងរយៈពេលសមស្រប។ វិធាននេះមិនអនុវត្តចំពោះឧបាស្រ័យក្នុងស្រុកដែល**មិនមានប្រសិទ្ធិភាព ឬ ត្រូវបានអូសបន្លាយពេលយូរជ្រុលហួសហេតុ**។ ជាទូទៅ អ្វីដែលជា "ការអូសបន្លាយពេលយូរជ្រុលហួសហេតុ" មិនអាចកំណត់ក្នុងលក្ខណៈទូទៅទេ តែត្រូវវាយតម្លៃជាក់ស្តែងទៅតាមករណីនីមួយៗ។

## ៤. ការដាក់បណ្តឹងក្នុងនាមជនរងគ្រោះ

បុគ្គល ឬ អង្គការអាចដាក់បណ្តឹងក្នុងនាមបុគ្គលម្នាក់ផ្សេងទៀតបានឲ្យតែជនរងគ្រោះនោះផ្តល់**ការយល់ព្រមជាលាយលក្ខណ៍អក្សរ** ក្នុងទម្រង់ "លិខិតតំណាងដោយអាណត្តិ" ឬ "លិខិតប្រតិភូកម្មសិទ្ធិអំណាច"[73]។

## ៥. ដំណើរការនីតិវិធីបណ្តឹងផ្សេងទៀត

ប្រសិនបើករណីមួយ **កំពុងត្រូវបានពិចារណាដោយនីតិវិធីបណ្តឹងតាមផ្លូវតុលាការរបស់ស្ថាប័នមួយផ្សេងទៀតនៃអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ ឬតំបន់រួចហើយ** ជាទូទៅ វាមិនអាចត្រូវបានពិចារណាដោយគណកម្មាធិការរបស់អង្គការសហប្រជាជាតិផ្សេងទៀតឡើយ។ ប្រសិនបើករណីនោះត្រូវបានពិចារណា និងច្រានចោលដោយ**តុលាការសិទ្ធិមនុស្សអន្តរអាមេរិក ឬតុលាការសិទ្ធិមនុស្សអឺរ៉ុប**រួចហើយ បណ្តឹងដដែល ជួនកាលអាចមានសិទ្ធិដាក់ឲ្យពិចារណា ដោយគណកម្មាធិការផ្សេងទៀតបាន។ ករណីនានា ដែលបានដាក់ក្រោមអាណត្តិការងារនៃនិតិវិធីពិសេសក៏អាចត្រូវបានដាក់ជូនគណកម្មាធិការសន្ធិសញ្ញាពិនិត្យផងដែរ។

## ៦. ទម្រង់បែបបទនៃបណ្តឹង

ទោះបីជាម្ចាស់បណ្តឹងត្រូវបានលើកទឹកចិត្តឲ្យប្រើប្រាស់គំរូបែបបទនៃបណ្តឹង (ចូរមើលឧបសម្ពន្ធ I និង II នៃជំពូកនេះ) ក៏ដោយ ក៏ជាគោលការណ៍ទម្រង់ណាមួយនៃលិខិតឆ្លើយឆ្លង

---

[73] ការយល់ព្រមបែបនេះមិនមានលក្ខណៈចាំបាច់ទេ ប្រសិនបើមានមូលដ្ឋានរឹងមាំ ដើម្បីជឿថា វាមិនអាចទទួលយកបានក្រោមកាលៈទេសៈនោះទេ។

ដែលរួមបញ្ចូលព័ត៌មានពាក់ព័ន្ធ ជាគោលការណ៍ មានលក្ខណៈគ្រប់គ្រាន់។ បណ្ដឹងគួរដាក់ ជាភាសាការងារណាមួយក្នុងចំណោមភាសារការងារជាច្រើនរបស់គណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សពាក់ព័ន្ធ[74]។

i. តើព័ត៌មានអ្វីខ្លះគួរដាក់បញ្ចូលនៅក្នុងបណ្ដឹងជាលក្ខណៈបុគ្គលក្រោមគណកម្មាធិការសន្ធិសញ្ញា ?

- **ព័ត៌មានផ្ទាល់ខ្លួនទូទៅ**ស្ដីពីបុគ្គលដែលចោទប្រកាន់ថាសិទ្ធិមនុស្សរបស់ខ្លួនត្រូវបានរំលោភ (ឈ្មោះ សញ្ជាតិ ថ្ងៃខែឆ្នាំកំណើត)។
- ឈ្មោះរបស់**រដ្ឋភាគី** ដែលបណ្ដឹងនេះប្ដឹង។
- ប្រសិនបើបណ្ដឹងបានធ្វើឡើងក្នុងនាមបុគ្គលម្នាក់ផ្សេង **តឹកតាង**ដែលបញ្ជាក់អំពី**ការយល់ព្រម** ឬ ការអនុញ្ញាតពីបុគ្គលនោះ ("លិខិតតំណាងដោយអាណត្តិ" ជាទម្រង់ក្រដាស) ឬ បើមិនដូច្នោះទេ យុត្តិកម្មអំពីមូលហេតុដែលយល់ព្រម ឬការអនុញ្ញាតបែបនេះមិនអាចរកបាន ឬមិនអាចត្រូវបានផ្ដល់ជូន។
- **ការអធិប្បាយល្អិតល្អន់អំពីអង្គហេតុ**ដែលបណ្ដឹងនេះបានសំអាង ដោយត្រូវបង្ហាញយ៉ាងច្បាស់លាស់ទៅតាមលំដាប់កាលប្បវត្តិ។
- សេចក្ដីពិស្ដារនៃជំណាក់កាលដែលត្រូវបានអនុវត្ត**ដើម្បីប្រើប្រាស់ឲ្យអស់នូវឧបាស្រ័យផ្នែកតុលាការទាំងអស់ជាធរមាននៅក្នុងតុលាការក្នុងស្រុក ក៏ដូចជាឧបាស្រ័យរដ្ឋបាលប្រកបដោយប្រសិទ្ធិភាពខ្លះទៀត** ដែលមាននៅក្នុងរដ្ឋដែលពាក់ព័ន្ធ។
- សេចក្ដីពិស្ដារអំពីព័ត៌មាន**នៃករណី ឬអង្គហេតុពាក់ព័ន្ធ** នឹងមធ្យោបាយមួយផ្សេងទៀតនៃការស៊ើបអង្កេត ឬ ការដោះស្រាយជាលក្ខណៈអន្តរជាតិ ប្រសិនបើមាន។
- ការអធិប្បាយអំពី**ទឡ្ហីករណ៍អំពីមូលហេតុដែលអង្គហេតុនៅក្នុងករណីនេះនាំឲ្យមានការ** រំលោភសិទ្ធិមនុស្សដូចមានចែងនៅក្នុងសន្ធិសញ្ញា ហើយដែលនាំឲ្យប្រើប្រាស់បទប្បញ្ញត្តិក្នុង នោះ។ វាមានប្រយោជន៍ត្រូវបង្ហាញ**មាត្រាពាក់ព័ន្ធនៅក្នុងសន្ធិសញ្ញា** ។
- **ឯកសារពាក់ព័ន្ធទាំងអស់**នឹងសេចក្ដីអះអាង និងទឡ្ហីករណ៍ (សេចក្ដីសម្រេចរបស់តុលាការ ។ល។)។
- ច្បាប់ចម្លងនៃ**ច្បាប់ជាតិពាក់ព័ន្ធ**ក្នុងករណីដែលអាចរកបាន។

[74] តាមធម្មតា ភាសាទាំងនេះគឺភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ ប៉ុន្តែម្ចាស់បណ្ដឹងត្រូវបានណែនាំ ឲ្យមើលវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ដើម្បីបញ្ជាក់អំពីភាសាការងាររបស់ស្ថាប័ននីមួយៗ។

## ៧. កម្រិតពេលវេលា

អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ គឺជាសន្ធិសញ្ញាសិទ្ធិមនុស្សតែមួយគត់ដែលបានកំណត់អំពីកាលបរិច្ឆេទកំណត់ផ្លូវការក្នុងការទទួលបណ្ដឹង។ ទោះបីជាដូច្នេះក៏ដោយ ជាគោលការណ៍ បណ្ដឹង ត្រូវដាក់**ឲ្យឆាប់តាមដែលអាចធ្វើទៅបាន**បន្ទាប់ពីមានការចោទប្រកាន់ការរំលោភបំពាន និងឧបាស្រ័យក្នុងស្រុកត្រូវបានប្រើប្រាស់អស់។ បណ្ដឹង និងឯកសារដែលដាក់ហួសពេលកំណត់អាចធ្វើឲ្យរដ្ឋភាគីពិបាកក្នុងការឆ្លើយតបដោយសមស្រប និងពិបាកឲ្យគណកម្មាធិការវាយតម្លៃលើសារតារអង្គហេតុឲ្យបានហ្មត់ចត់។ បណ្ដឹងពាក់ព័ន្ធនឹងការរំលោភដែលបានកើតឡើងមុនការចូលជាធរមាននៃយន្តការបណ្ដឹងសម្រាប់រដ្ឋភាគីពាក់ព័ន្ធ នឹងមិនត្រូវបានត្រួតពិនិត្យឡើយ (លើកលែងតែ វាមានផលប៉ះពាល់បន្តបន្ទាប់លើការរំលោភលើសន្ធិសញ្ញា)។ បណ្ដឹងដែលបានដាក់ជូនអនុលោមតាមអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ ត្រូវដាក់ជូនពិនិត្យ **នៅក្នុងរយៈពេលប្រាំមួយខែ** បន្ទាប់ពីមានសេចក្ដីសម្រេចចុងក្រោយរបស់អាជ្ញាធរជាតិនៅក្នុងករណីនេះ។

## ៨. វិធានការបន្ទាន់

គណៈកម្មាធិការនីមួយៗអាចអនុវត្តវិធានការបន្ទាន់តាមវិធានការបណ្ដោះអាសន្នបានប្រសិនព្យសនកម្មដែលមិនអាចជួសជុលបានរងគ្រោះថ្នាក់នៅមុនពេលដែលករណីណាមួយត្រូវបានត្រួតពិនិត្យនៅដំណើរការធម្មតា។ ជាតួយ៉ាង គំនិតផ្ដួចផ្ដើមបែបនេះ ត្រូវបានទទួលអនុវត្តដើម្បីទប់ស្កាត់សកម្មភាពដែលមិនអាចដូចដើម ឧទាហរណ៍៖ ការអនុវត្តទោសប្រហារជីវិត ឬ ការបណ្ដេញចេញដោយបង្ខំនូវបុគ្គលដែលប្រឈមមុខនឹងគ្រោះថ្នាក់នៃការធ្វើទារុណកម្ម។ **បុគ្គល ឬអង្គការដែលស្នើសុំគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សពិចារណាលើការទទួលអនុវត្តវិធានការបណ្ដោះអាសន្នត្រូវបានលើកទឹកចិត្តឲ្យលើកឡើងដោយច្បាស់លាស់នូវករណីនេះនៅក្នុងពាក្យបណ្ដឹងរបស់ពួកគេ។**

## ៩. បញ្ហារសើប

ប្រសិនបើមានបញ្ហារសើបប្រភេទឯកជន ឬផ្ទាល់ខ្លួនលេចឡើងនៅក្នុងពាក្យបណ្ដឹង គេអាចស្នើសុំទៅគណៈកម្មាធិការកុំឲ្យបង្ហាញឈ្មោះរបស់ជនរងគ្រោះនៅក្នុងសេចក្ដីសម្រេចចុងក្រោយរបស់គណៈកម្មាធិការនោះដើម្បីកុំឲ្យអត្តសញ្ញាណរបស់គេត្រូវបានបញ្ចេញជាសាធារណៈ។

## ធាតុផ្សំនានានៃនីតិវិធី

ប្រសិនបើពាក្យបណ្ដឹងមានធាតុផ្សំសំខាន់ជាសារវន្ត ដូចដែលបានលើកឡើងខាងលើករណីនេះត្រូវបានចុះទៅក្នុងបញ្ជីសម្រាប់ការពិចារណា (នោះគឺ **ត្រូវបានចុះបញ្ជី**) ដោយគណកម្មាធិការសិទ្ធិមនុស្សដែលពាក់ព័ន្ធ។

បន្ទាប់មក ករណីនេះនឹងត្រូវបានបញ្ជូនទៅរដ្ឋភាគីពាក់ព័ន្ធដើម្បីផ្ដល់ដល់រដ្ឋភាគីនូវឱកាសដើម្បីផ្ដល់យោបល់។ កាលណារដ្ឋភាគីឆ្លើយតបភ្លាមៗ ម្ចាស់បណ្ដឹងត្រូវបានផ្ដល់ឱកាសឲ្យផ្ដល់យោបល់លើចម្លើយតបរបស់រដ្ឋនោះ។ នៅពេលនោះ ករណីនេះអាចយកមក ធ្វើសេចក្ដីសម្រេចដោយគណកម្មាធិការសិទ្ធិមនុស្សបាន។ ប្រសិនបើរដ្ឋនោះមិនបានឆ្លើយតបទេ ទោះបីជាមានលិខិតរំលឹកមួយ ឬច្រើនក៏ដោយ គណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សនឹងធ្វើសេចក្ដីសម្រេចលើករណីនោះដោយឲ្យទម្ងន់ត្រឹមត្រូវទៅលើសេចក្ដីអះអាងរបស់ម្ចាស់បណ្ដឹង។

ដំណាក់កាលសំខាន់ពីរនៃដំណើរការពិនិត្យឡើងវិញរបស់គណកម្មាធិការសិទ្ធិមនុស្សត្រូវបានស្គាល់ថាជាដំណាក់កាលលើ "ភាពអាចទទួលយកបាន" និងដំណាក់កាលពិនិត្យលើ "អង្គសេចក្ដី"។ នៅក្នុងដំណាក់កាលពិនិត្យលើភាពអាចទទួលយកបាន គណកម្មាធិការសន្ធិសញ្ញាពិចារណាថាតើបណ្ដឹងបានបំពេញលក្ខខណ្ឌនៃនីតិវិធីដែរ ឬអត់។ ប្រសិនបើគណកម្មាធិការកំណត់ករណីនោះថាអាចទទួលយកបាន គណកម្មាធិការពិចារណាលើអង្គសេចក្ដីនៃបណ្ដឹង។ ទោះបីជាដំណាក់កាលទាំងនេះត្រូវបានពិចារណារួមគ្នាក៏ដោយ ក៏វាអាចត្រូវបានបំបែកចេញពីគ្នាតាមការស្នើសុំរបស់ភាគីរដ្ឋ។ ប្រសិនបើករណីនេះមិនអាចទទួលយកបាន អង្គសេចក្ដីនៃករណីនោះអាចមិនត្រូវបានពិចារណាផងដែរ។

គណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សពិចារណាលើករណីនីមួយៗនៅក្នុងកិច្ចប្រជុំសម្ងាត់។ កាលណាគណកម្មាធិការសិទ្ធិមនុស្សបានធ្វើសេចក្ដីសម្រេចលើករណីមួយភ្លាម សេចក្ដីសម្រេចនោះត្រូវបញ្ជូនទៅម្ចាស់បណ្ដឹង និងរដ្ឋនៅក្នុងពេលជាមួយគ្នា។ ប្រសិនបើគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សសម្រេចថា ម្ចាស់បណ្ដឹងពិតជាជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្សដោយរដ្ឋភាគីដូចដែលមានចែងនៅក្នុងសន្ធិសញ្ញាពាក់ព័ន្ធមែន ជាទូទៅ គណកម្មាធិការសិទ្ធិមនុស្សកំណត់អំពីឧបាស្រ័យដែលគួរផ្ដល់ឲ្យ និងអញ្ជើញរដ្ឋភាគីផ្ដល់ព័ត៌មានស្ដីពីការបន្តតាមដាន នៅក្នុង រយៈពេល ជាក់លាក់ (តាមធម្មតាប្រាំមួយខែ) លើដំណាក់កាលដែលរដ្ឋភាគីនោះប្រកាន់យកដើម្បីអនុវត្តសេចក្ដីសម្រេចរបស់គណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស។

អត្ថបទនៃសេចក្តីសម្រេចចុងក្រោយណាមួយលើអង្គសេចក្តីនៃករណី ឬ សេចក្តីសម្រេចលើភាពមិនអាចទទួលយកបានត្រូវបានដាក់ផ្សាយលើគេហទំព័ររបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ជាផ្នែកមួយនៃយុត្តិសាស្ត្ររបស់គណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្ស។

i. ទីកន្លែងដាក់បណ្តឹងជាលក្ខណៈបុគ្គលដូចដែលមានចែងនៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ

បណ្តឹងគួរផ្ញើទៅកាន់៖

ក្រុមទទួលបន្ទុកញត្តិតវ៉ា

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

វិមានជាតិ

8-14, avenue de la Paix

CH- 1211 Geneva 10 -ប្រទេស្វីស

ទូរសារលេខ៖ +៤១ (0)២២ ៩១៧ ៩០ ២២(ជាពិសេស សម្រាប់បញ្ហាបន្ទាន់ គួរតែដាក់បញ្ជូលឯកសារពាក់ព័ន្ធទាំងអស់ជាទម្រង់ក្រដាស)

អ៊ីម៉ែល៖ tb-petitions@ohchr.org

**ចូរបញ្ជាក់ជានិច្ចថាតើគណកម្មាធិការសន្ធិសញ្ញាសិទ្ធិមនុស្សណាមួយដែលអ្នកដាក់បណ្តឹង។**

## ខ. បណ្តឹងតាមយន្តការនីតិវិធីពិសេស

យន្តការនេះអនុញ្ញាតឲ្យធ្វើបណ្តឹងពាក់ព័ន្ធនឹងករណីជាលក្ខណៈបុគ្គល ឬក៏បែបផែននៃការបំពារបំពានសិទ្ធិមនុស្សក្នុងក្របខណ្ឌលើសលក្ខណៈទូទៅ។ បុគ្គល ក្រុមណាមួយ ឬ អង្គការដែលបំពេញតួនាទីក្នុងនាមបុគ្គល អាចដាក់ ករណីនានាទៅមន្ត្រីកាន់កាប់អាណត្តិការងារនៃយន្តការនីតិវិធីពិសេស។

ជារឿយៗ តួអង្គសង្គមស៊ីវិលអាចបំពេញតួនាទីជាអ្នករាយការណ៍សម្រាប់បុគ្គលដែលស្វែងរកការការពារពីការបំពារបំពានសិទ្ធិមនុស្ស។ បុគ្គល ឬ អង្គការដែលមានបំណងដាក់ករណីណាមួយក្រោមអាណត្តិការងារនៃយន្តការនីតិវិធីពិសេស គួរតែពិនិត្យមើលជាដំបូងថាតើមានអាណត្តិការងារប្រចាំប្រទេស ឬ តាមវិស័យប្រធានបទពាក់ព័ន្ធនឹងករណីនេះដែរឬអត់។ លើសពីនេះទៀត គេគួរ

តែអានដោយប្រុងប្រយ័ត្នលើលក្ខណៈវិនិច្ឆ័យនៃអាណត្តិការងារ ដែលត្រូវតែបំពេញមុនពេលដែលបណ្ដឹងអាចត្រូវបានទទួលយក។ ជាពិសេស **ក្រុមការងារទទួលបន្ទុកការឃុំឃាំងតាមទំនើងចិត្ត** និង **ក្រុមការងារទទួលបន្ទុកការបាត់ខ្លួនដោយបង្ខំ ឬដោយគ្មានការស្ម័គ្រចិត្ត** មានលក្ខណៈវិនិច្ឆ័យជាក់លាក់ខុសពីលក្ខណៈវិនិច្ឆ័យនៃអាណត្តិការងារផ្សេងទៀត។

ក្រោយទទួលបានបណ្ដឹងជាលក្ខណៈបុគ្គល សេចក្ដីសម្រេចអន្តរាគមន៍ គឺជាឆន្ទានុសិទ្ធិរបស់មន្ត្រីកាន់អាណត្តិការងារនៃនីតិវិធីពិសេស។ វាអាស្រ័យលើលក្ខណៈវិនិច្ឆ័យ ដែលមន្ត្រីកាន់កាប់អាណត្តិការងារបានបង្កើតឡើង ហើយគួរតែស្របនឹង**ក្រមសីលធម៌សម្រាប់មន្ត្រីកាន់កាប់អាណត្តិការងារនៃយន្តការនីតិវិធីពិសេសនោះ**។ ជាទូទៅ លក្ខណៈវិនិច្ឆ័យត្រូវទាក់ទងនឹង៖

- ភាពដែលគួរឲ្យជឿទុកចិត្តបានលើប្រភព ដែលមិនគួរត្រូវបានផ្អែកជាមូលដ្ឋានទាំងស្រុងលើរបាយការណ៍របស់ប្រព័ន្ធផ្សព្វផ្សាយ។
- ភាពអាចជឿជាក់បានលើព័ត៌មានដែលទទួលបាន ដែលមិនគួរត្រូវបានជំរុញដោយផ្នែកនយោបាយ។
- សេចក្ដីពិស្ដារដែលត្រូវបានផ្ដល់ជូន និង
- វិសាលភាពនៃអាណត្តិការងារនោះផ្ទាល់។

ដើម្បីសម្រួលដល់ការត្រួតពិនិត្យលើការរំលោភបំពានដែលបានរាយការណ៍ **កម្រងសំណួរ**ទាក់ទងនឹងអាណត្តិការងារមួយចំនួនតូចត្រូវបានរៀបចំឡើងតាមប្រព័ន្ធអនឡាញសម្រាប់បុគ្គលដែលមានបំណងចង់ធ្វើសេចក្ដីរាយការណ៍លើការចោទប្រកាន់អំពីការរំលោភបំពាន (ចូរមើលខាងក្រោម)។ ទោះជាយ៉ាងណា គួរកត់សម្គាល់ថា បណ្ដឹងពីបុគ្គលទាំងឡាយ ឬ ម្ចាស់បណ្ដឹងដទៃទៀត ត្រូវបានពិចារណា សូម្បីតែនៅពេលដែលបណ្ដឹងនោះត្រូវបានដាក់ជូនពិនិត្យជាទម្រង់កម្រងសំណួរក្ដី។ ម្ចាស់បណ្ដឹងត្រូវបានលើកទឹកចិត្តឲ្យដាក់ព័ត៌មានបច្ចុប្បន្នភាពជាទៀតទាត់ដែលពួកគេបានដាក់ជូន។

i. ទីកន្លែងដាក់បណ្ដឹងជាលក្ខណៈបុគ្គលក្រោមយន្តការនិតិវិធីពិសេស
ផ្នែកនីតិវិធីពិសេស
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរសារលេខ៖ +៤១(០)២២ ៩១៧ ៩០ ០៦
អ៊ីម៉ែល៖ urgent-action@ohchr.org

សូមបញ្ជាក់អំពីនីតិវិធីពិសេសណាមួយ ដែលដាក់បណ្ដឹងនេះនៅក្នុងទីកន្លែងកម្មវត្ថុនៃអ៊ីម៉ែល ឬ ទូរសារ ឬ នៅលើស្រោមសំបុត្រ។ ចូរកត់សម្គាល់ថា អាណត្តិការងារនៃយន្តការនិតិវិធីពិសេសបានកំណត់អំពីលក្ខខណ្ឌតម្រូវជាក់លាក់ដែលបណ្ដឹងត្រូវតែគោរពតាម។ សេចក្ដីពិស្ដារនៃលក្ខខណ្ឌតម្រូវទាំងនេះអាចរកឃើញនៅក្នុងគេហទំព័ររបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ក្រោមអាណត្តិការងារនីមួយៗ។

i. តើព័ត៌មានអ្វីខ្លះដែលបណ្ដឹងជាលក្ខណៈបុគ្គលក្រោមយន្តការនីតិវិធីពិសេសរួមបញ្ចូល?

- ការកំណត់អត្តសញ្ញាណអ្នកដែលត្រូវបានអះអាងថាជា**ជនរងគ្រោះ**។
- ការកំណត់អត្តសញ្ញាណអំពីអ្នកត្រូវបានចោទប្រកាន់ថាជា**ចារី**នៃការរំលោភបំពាន។
- ការកំណត់អត្តសញ្ញាណអំពី**បុគ្គលម្នាក់ ឬ អង្គការដែលដាក់បណ្ដឹង** (ព័ត៌មាននេះនឹងត្រូវរក្សាការសម្ងាត់)។
- **កាលបរិច្ឆេទ និងទីកន្លែង**ដែលកើតមានឧប្បត្តិហេតុ និង
- **សេចក្ដីពិពណ៌នាពិស្ដារអំពីកាលៈទេសៈ**នៃការការចោទប្រកាន់អំពីការរំលោភបំពាន។

**កំណត់សម្គាល់៖**

- ជាទូទៅពាក្យបណ្ដឹងដែលមានភាសាប្រមាថ**មិនត្រូវបានពិចារណាឡើយ**។
- បណ្ដឹងគួរតែមានលក្ខណៈ**ច្បាស់លាស់ និងចំៗ**។
- ជានិច្ចកាល**ចូរបញ្ជាក់ថាតើនីតិវិធីពិសេសណាមួយ**ដែលបណ្ដឹងនោះដាក់ជូន។
- ជានិច្ចកាល**ចូរមើលលក្ខខណ្ឌតម្រូវដែលត្រូវបានកំណត់តាមអាណត្តិការងារនីមួយៗ** សម្រាប់ការដាក់បណ្ដឹងជាលក្ខណៈបុគ្គល និង
- ពាក្យបណ្ដឹងអាចត្រូវបានសរសេរជាភាសាអង់គ្លេស បារាំង ឬអេស្ប៉ាញ។

ដោយឈរលើមូលដ្ឋានព័ត៌មានដ៏គួរឲ្យជឿជាក់បាន និងទុកចិត្តបានដែលទទួលបានពីជនរងគ្រោះនៃការរំលោភ សិទ្ធិមនុស្សដែលត្រូវបានចោទប្រកាន់នោះ មន្ត្រីកាន់កាប់អាណត្តិការងារនៃយន្តការនីតិវិធីពិសេសអាចបញ្ជូន**បណ្តឹងទៅរដ្ឋាភិបាល**។ បណ្តឹងទាំងនេះត្រូវបានបញ្ជូនតាមរយៈការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) និងអាចមានទម្រង់ជា**សេចក្តីអំពាវនាវបន្ទាន់** ប្រសិនបើការរំលោភធ្ងន់ធ្ងរហាក់ដូចជាកំពុងតែបន្ត ឬ បម្រុងនឹងកើតមានឡើង ឬ **លិខិតចោទប្រកាន់** ប្រសិនបើការចោទប្រកាន់ពីការរំលោភ បានកើតមានឡើងរួចស្រេចទៅហើយ។ តាមរយៈបណ្តឹង មន្ត្រីកាន់កាប់អាណត្តិការងារសុំឲ្យរដ្ឋាភិបាល ពាក់ព័ន្ធផ្តល់ការបំភ្លឺលើករណីជាក់លាក់ និង/ឬ វិធានការឧបាស្រ័យពេញលេញ។ មន្ត្រីកាន់កាប់អាណត្តិការងារ ក៏អាចស្នើសុំឲ្យរដ្ឋាភិបាលផ្សព្វផ្សាយអំពីលទ្ធផលនៃការស៊ើបអង្កេត និងសកម្មភាពរបស់ពួកគេផងដែរ។

អាស្រ័យលើការឆ្លើយតបដែលទទួលបាន គេអាចសម្រេចធ្វើការស៊ើបសួរតទៅទៀត ឬ ផ្តល់អនុសាសន៍ជាក់លាក់។ ក្នុងករណីខ្លះ គេក៏អាចសម្រេចចេញសេចក្តីថ្លែងការណ៍សាធារណៈលើករណីនេះផងដែរ។

ដូចដែលមានចែងនៅក្នុងវិធានរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស នីតិវិធីពិសេសទាំងអស់តម្រូវឲ្យ**ធ្វើសេចក្តីរាយការណ៍**ស្តីពីសកម្មភាពរបស់ខ្លួន នៅក្នុងសម័យប្រជុំប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនេះ។ តាមធម្មតាពាក្យបណ្តឹងដែលត្រូវបានផ្ញើចេញ និងទទួលមានលក្ខណៈសម្ងាត់ និងនៅតែមានលក្ខណៈសម្ងាត់ដូច្នេះរហូតដល់របាយការណ៍ប្រចាំឆ្នាំរបស់និតិវិធីពិសេសពាក់ព័ន្ធត្រូវបានផ្សព្វផ្សាយជាសាធារណៈ លុះត្រាតែមន្ត្រីកាន់កាប់អាណត្តិការងារសម្រេចចិត្តចេញសេចក្តីប្រកាសព័ត៌មាន[75]។

សូមកត់សម្គាល់ថា អ្នកដែលត្រូវបានអះអាងជាជនរងគ្រោះត្រូវបានដាក់ឈ្មោះនៅក្នុងរបាយការណ៍របស់មន្ត្រីកាន់កាប់អាណត្តិនៃយន្តការនីតិវិធីពិសេស លើកលែងតែក្នុងករណីពាក់ព័ន្ធនឹងកុមារ ឬ កាលៈទេសៈជាក់លាក់។ ដោយពិចារណាថា របាយការណ៍របស់យន្តការនីតិវិធីពិសេសមានលក្ខណៈជាសាធារណៈ វាមានលក្ខណៈសំខាន់ដែលថាបុគ្គល ឬ អង្គការដែល

---

[75] ដោយរួមទាំងរបាយការណ៍ប្រចាំឆ្នាំ អ្នកមានអាណត្តិខ្លះដាក់ចេញនូវឯកសារផ្សេងទៀតដែលជួយពន្យល់អំពីការងាររបស់គេ និងវិសាលភាពនៃអាណត្តិរបស់គេ។ ជាពិសេស ក្រុមការងារទទួលបន្ទុកការឃុំឃាំងដោយបំពាន ដាក់ចេញនូវ "សេចក្តីពិគ្រោះយោបល់ផ្លូវការ" ស្តីពីបញ្ហា និង "មតិ" ទូទៅលើបណ្តឹងជាលក្ខណៈបុគ្គល និងក្រុមការងារទទួលបន្ទុកការបាត់ខ្លួនដោយបង្ខំ ឬគ្មានការស្ម័គ្រចិត្ត ដាក់ចេញនូវ"សេចក្តីសង្កេតទូទៅ" លើសេចក្តីប្រកាសស្តីពីកិច្ចការពារមនុស្សទាំងអស់ពីការបាត់ខ្លួនដោយបង្ខំ។

បំពេញតួនាទីក្នុងនាមជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្សត្រូវធ្វើយ៉ាងណាឲ្យជនរងគ្រោះដឹងថា ករណីរបស់គេកំពុងតែត្រូវបានបញ្ជូនទៅយន្តការនីតិវិធីពិសេស ឈ្មោះរបស់គេអាចត្រូវបានផ្សព្វផ្សាយទៅអាជ្ញាធរពាក់ព័ន្ធ និងឈ្មោះរបស់គេ (ឬ អក្សរកាត់) អាចបង្ហាញឲ្យឃើញនៅក្នុងរបាយការណ៍សាធារណៈរបស់យន្តការនីតិវិធីពិសេស។

i. **កម្រងបទដ្ឋានសំណួរ** ត្រូវបានរៀបចំឲ្យមានសម្រាប់ធ្វើជាសេចក្តីរាយការណ៍អំពីការចោទប្រកាន់ការរំលោភបំពាន ក្រោមអាណត្តិការងារដូចតទៅៈ

- ក្រុមការងារទទួលបន្ទុកការឃុំឃាំងតាមទំនើងចិត្ត។
- ក្រុមការងារទទួលបន្ទុកការបាត់ខ្លួនដោយបង្ខំ ឬ គ្មានការស្ម័គ្រចិត្ត។
- ក្រុមការងារប្រឆាំងនឹងការប្រើប្រាស់ទាហានស៊ីឈ្នួលជាមធ្យោបាយរារាំងការប្រើប្រាស់សិទ្ធិស្វ័យសម្រេចរបស់ប្រជាជន។
- អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីការប្រហារជីវិតក្រៅតុលាការដោយគ្មានដំណើរការត្រឹមត្រូវតាមច្បាប់ ឬ ដោយបំពាន។
- អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីការលើកកម្ពស់ និងការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិយោបល់។
- អ្នករាយការព៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្សរបស់ប្រជាជនទេសន្តរប្រវេសន៍។
- អ្នករាយការព៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីការលក់កុមារ ពេស្យាកម្មកុមារ និងព័ត៌មាន ឬ សម្ភារៈអាសអាភាសលើកុមារ។
- អ្នករាយការព៍ពិសេសរបស់អង្គការសហប្រជាជាតិប្រឆាំងនឹងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មងទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប។
- អ្នករាយការព៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ។
- អ្នករាយការព៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពី អំពើហិង្សាចំពោះស្ត្រីភេទ បុព្វហេតុ និងផលវិបាករបស់វា និង
- អ្នករាយការព៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីស្ថានភាពអ្នកការពារសិទ្ធិមនុស្ស។

ទោះជាយ៉ាងណាក៏ដោយ ពាក្យបណ្តឹងពីបុគ្គល និងប្រភពផ្សេងទៀត នឹងត្រូវបានពិចារណា សូម្បីតែនៅពេលដែលវាមិនត្រូវបានដាក់ជូនពិនិត្យជាទម្រង់នៃកម្រងសំណួរក្តី។

## គ. នីតិវិធីបណ្ដឹងរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស

ក្រោមនីតិវិធីបណ្ដឹងរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស បណ្ដឹងអាចត្រូវបានដាក់ជូនពិនិត្យដោយ បុគ្គល ឬ ក្រុម ដែលអះអាងថាជាជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្ស ឬ មានចំណេះដឹងផ្ទាល់ដែលគួរឲ្យជឿទុកចិត្តបានអំពីការរំលោភបំពាននេះ។ ធាតុផ្សំសំខាន់ៗនៃយន្តការនេះ ត្រូវបានចែងដូចខាងក្រោម។

i. ព័ត៌មានអ្វីខ្លះ ដែលពាក្យបណ្ដឹងក្រោមនីតិវិធីបណ្ដឹងរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សរួមបញ្ចូល?

- ការកំណត់អំពីបុគ្គម្នាក់ (ឬច្រើននាក់) ឬអង្គការមួយ (ឬច្រើន) **ដែលដាក់ជូនពិនិត្យពាក្យបណ្ដឹង** (ព័ត៌មាននេះនឹងត្រូវបានរក្សាការសម្ងាត់ ប្រសិនបើត្រូវបានស្នើសុំ)។ ពាក្យបណ្ដឹងអនាមិកមិនត្រូវបានទទួលយកឡើយ។
- ការពិពណ៌នាអំពីអង្គហេតុដែលពាក់ព័ន្ធឲ្យបានពិស្តារដូចដែលអាចធ្វើបាន ដោយផ្ដល់នូវឈ្មោះរបស់អ្នកដែលបានអះអាងថាជា**ជនរងគ្រោះ កាលបរិច្ឆេទ ទីតាំង និងភ័ស្ដុតាងផ្សេងទៀត**។
- គោលបំណងនៃពាក្យបណ្ដឹង និង**សិទ្ធិដែលត្រូវបានរំលោភបំពាន**ដូចត្រូវបានចោទប្រកាន់ ។
- ការពន្យល់ថាតើករណីនេះអាចបញ្ចេញឲ្យដឹងនូវ**គំរូនៃការរំលោភបំពានលើសិទ្ធិមនុស្សធ្ងន់ធ្ងរ និងដែលត្រូវបានផ្ដល់នូវភ័ស្ដុតាងដ៏គួរឲ្យជឿទុកចិត្តបាន** ដោយរបៀបណា ជាជាងការរំលោភបំពានជាលក្ខណៈបុគ្គល និង
- សេចក្ដីពិស្តារអំពីថាតើ**ឧបាស្រ័យក្នុងស្រុកត្រូវបានប្រើប្រាស់**អស់ដោយរបៀបណា ឬការពន្យល់អំពីថាតើឧបាស្រ័យបែបនេះ នឹងមិនមានប្រសិទ្ធិភាព ឬត្រូវបានអូសបន្លាយពេលយូរដោយមិនសមហេតុផលដោយរបៀបណា។

កំណត់សម្គាល់៖

- ពាក្យបណ្ដឹងទាំងអស់ត្រូវតែមានលក្ខណៈជាលាយលក្ខណ៍អក្សរ។ សូមកត់សម្គាល់ថា វាមិនមានលក្ខណៈពេញលេញដែលត្រូវពឹងពាក់លើរបាយការណ៍របស់ប្រព័ន្ធឃោសនាមហាជននោះទេ។ ប្រសិនបើអ្នកមានបំណងដាក់ជូនរបាយការណ៍សិទ្ធិមនុស្សជាភ័ស្ដុតាង ចូរដាក់ភ្ជាប់លិខិតអមដោយកំណត់អំពីខ្លួនអ្នកផ្ទាល់ ពន្យល់អំពីករណីដែលអ្នកចង់ប្ដឹង និងដែលអ្នកមានបំណងចង់ឲ្យបណ្ដឹងត្រូវបានដោះស្រាយ ក្រោមយន្តការបណ្ដឹងរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។
- ជាការណែនាំត្រូវកម្រិតពាក្យបណ្ដឹងត្រឹមតែ ១០-១៥ ទំព័រ។ ព័ត៌មានបន្ថែមអាចត្រូវបានដាក់ជូនពិនិត្យនៅក្នុងដំណាក់កាលក្រោយ។
- ពាក្យបណ្ដឹងអាចត្រូវបានសរសេរជាភាសាអង់គ្លេស បារាំង រុស្ស៊ី ឬអេស្ប៉ាញ។ កសារជាភាសាផ្សេងទៀតគួរតែត្រូវបានបកប្រែ ឬសង្ខេបទៅជាភាសាមួយក្នុងចំណោមភាសាទាំងនេះ និង
- ពាក្យបណ្ដឹងដែលមានភាសាដែលត្រូវបានចាត់ទុកថារំលោភបំពាន ឬដែលធ្វើឲ្យមានការមើលងាយនឹងមិនត្រូវបានពិចារណាឡើយ។

បែបបទ និងនីតិវិធីដែលមានលក្ខណៈពិស្តារនៃយន្តការបណ្តឹងនេះ ត្រូវបាន បង្ហាញនៅក្នុងសេចក្តីសម្រេចចិត្តលេខ ៥/១ របស់ក្រុមប្រឹក្សា។ ព័ត៌មានដែលត្រូវបានផ្តល់ជូននៅក្នុងផ្នែកនេះ មានមូលដ្ឋាននៅលើបទប្បញ្ញត្តិនៃសេចក្តីសម្រេចនោះ។ វាត្រូវបានរំពឹងទុកថា បទប្បញ្ញត្តិ និងវិធីសាស្ត្រការងារដំបូងទាំងនេះ ជាពិសេស ទាក់ទងនឹងការចែករំលែកព័ត៌មានត្រឡប់ជាមួយនឹងម្ចាស់បណ្តឹងតាមរយៈដំណាក់កាលផ្សេងៗនៃដំណើរការនឹងត្រូវបានរៀបចំបន្ថែមទៀត។

នីតិវិធីបណ្តឹងមានដំណាក់កាលដូចខាងក្រោម៖

**ដំណាក់កាលទីមួយ៖ ការពិនិត្យមើលបឋម**

លេខាធិការនៃការិយាល័យ OHCHR រួមជាមួយនឹងប្រធាន**ក្រុមការងារទទួលបន្ទុកបណ្តឹង** ពិនិត្យគ្រប់បណ្តឹង (បណ្តឹង) ដែលបានដាក់ដោយផ្អែកលើមូលដ្ឋាននៃលក្ខខណ្ឌស្តីពីភាពអាចទទួលយកបាន ហើយច្រានចោលបណ្តឹងទាំងឡាយណាដែលរកឃើញថាគ្មានមូលដ្ឋានយ៉ាងច្បាស់ក្រឡែត ឬ បណ្តឹងអនាមិក។ ប្រសិនបើបណ្តឹងត្រូវបានទទួលយកមកពិចារណាក្នុងដំណាក់កាលបន្ទាប់ អ្នករៀបចំបណ្តឹងនឹងទទួលបានលិខិតទទួលយកបណ្តឹងជាលាយលក្ខណ៍មួយច្បាប់ ហើយបណ្តឹងនឹងបញ្ជូនទៅរដ្ឋាភិបាលពាក់ព័ន្ធឲ្យដាក់ចម្លើយតប។

**ដំណាក់កាលទីពីរ៖ ក្រុមការងារទទួលបន្ទុកបណ្តឹង**

**ក្រុមការងារទទួលបន្ទុកបណ្តឹង**រួមមានសមាជិកប្រាំរូបដែលត្រូវបានតែងតាំងមកពី **គណកម្មាធិការប្រឹក្សាយោបល់នៃក្រុមប្រឹក្សាសិទ្ធិមនុស្ស** ហើយមានភារកិច្ចជួបប្រជុំយ៉ាងយោចណាស់ ២ ដងក្នុងមួយឆ្នាំនៅរៀងរាល់សម័យប្រជុំរយៈពេល៥ថ្ងៃ។ ក្រុមការងារនេះពិនិត្យបណ្តឹងដែលបានឆ្លងកាត់ដំណាក់កាលពីនិត្យបឋមរួចហើយ ហើយនឹងពិនិត្យចម្លើយតបមកពីរដ្ឋាភិបាលក្នុងគោលបំណងដាក់ជូនក្រុមការងារទទួលបន្ទុកលើស្ថានការណ៍ ដើម្បីពិនិត្យលើស្ថានការណ៍ជាក់លាក់ណាមួយដែលទំនងជាបង្ហាញនូវបែបផែនសង្គតិភាពនៃការរំលោភសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តធ្ងន់ធ្ងរ និងជាក់ស្តែង។

**ដំណាក់កាលទីបី៖ ក្រុមការងារទទួលបន្ទុកស្ថានការណ៍**

**ក្រុមការងារទទួលបន្ទុកស្ថានការណ៍**រួមមានសមាជិក ៥ រូបមកពីក្រុមប្រឹក្សាសិទ្ធិមនុស្សដែលបម្រើការងារ និងមានភារកិច្ចជួបប្រជុំយ៉ាងហោចណាស់ ២ ដងក្នុងរៀងរាល់សម័យប្រជុំរយៈពេល ៥ ថ្ងៃដើម្បីពិចារណាស្ថានការណ៍ដែលបានដាក់ជូនដោយក្រុមប្រឹក្សាទទួលបន្ទុកបណ្តឹង។ ក្រុមការងារនេះវាយតម្លៃលើករណីដែលខ្លួនបានទទួល និងរៀបចំរបាយការណ៍ដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្សដោយរួមបញ្ចូលអនុសាសន៍ស្តីពីវិធានការដែលត្រូវធ្វើឡើងពាក់ព័ន្ធនឹងស្ថានការណ៍ណាមួយដែល

បង្ហាញនូវបែបផែនសង្គតិភាពនៃការរំលោភបំពានធ្ងន់ធ្ងរ ឬ បើមិនដូច្នោះទេ ក្រុមប្រឹក្សានេះអាចសម្រេចរក្សាទុកស្ថានការណ៍នោះយកមកពិនិត្យឡើងវិញ ឬ ច្រានចោលករណីនោះតែម្តង

| |
|---|
| សម្រាប់ព័ត៌មានបន្ថែមស្តីពី**គណកម្មាធិការប្រឹក្សាយោបល់នៃក្រុមប្រឹក្សាសិទ្ធិមនុស្ស** សូមមើលជំពូក V (ក្រុមប្រឹក្សាសិទ្ធិមនុស្ស) នៅក្នុង*សៀវភៅណែនាំ*នេះ។ |

**ដំណាក់កាលទីបួន៖ ក្រុមប្រឹក្សាសិទ្ធិមនុស្ស**

ក្រុមប្រឹក្សាសិទ្ធិមនុស្សពិចារណាក្នុងកិច្ចប្រជុំពេញអង្គលើស្ថានការណ៍នានាដែលក្រុមការងារទទួលបន្ទុកស្ថានការណ៍បានដាក់ជូនខ្លួនជារឿយៗទៅតាមភាពចាំបាច់ ប៉ុន្តែក្រុមប្រឹក្សានេះត្រូវជួបប្រជុំយ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ។ ក្រុមប្រឹក្សាសិទ្ធិមនុស្សពិនិត្យរបាយការណ៍របស់ក្រុមការងារទទួលបន្ទុកស្ថានការណ៍ដាក់ជូនខ្លួនក្នុងលក្ខណៈសម្ងាត់លើកលែងតែក្រុមប្រឹក្សានេះសម្រេចផ្ទុយពីនេះ។ ផ្អែកលើការពិចារណានៃស្ថានការណ៍ ក្រុមប្រឹក្សាអាចចាត់វិធានការជាធម្មតានៅក្នុងទម្រង់ជាសេចក្តីសម្រេចចិត្ត ឬ សេចក្តីសម្រេច។ ក្រុមប្រឹក្សាអាចសម្រេចលើវិធានការដូចខាងក្រោម៖

- បញ្ឈប់ពិចារណាលើស្ថានការណ៍ក្នុងករណីពុំចាំបាច់ពិចារណាបន្ថែម ឬ ចាត់វិធានការណាមួយឡើង
- រក្សាស្ថានការណ៍ទុកយកមកពិនិត្យឡើងវិញ និងស្នើសុំរដ្ឋពាក់ព័ន្ធឲ្យផ្តល់ព័ត៌មានបន្ថែមក្នុងរយៈពេលមួយសមស្រប
- រក្សាទុកស្ថានការណ៍ទុកយកមកពិនិត្យឡើងវិញ ហើយតែងតាំងអ្នកជំនាញឯករាជ្យ និងមានគុណវឌ្ឍិខ្ពស់ឲ្យតាមដានស្ថានការណ៍ និងធ្វើរបាយការណ៍ត្រឡប់មកវិញ
- បញ្ឈប់ការពិនិត្យឡើងវិញលើបញ្ហាណាមួយក្រោមនីតិវិធីបណ្តឹងសម្ងាត់ដើម្បីយកមកពិចារណាបញ្ហានេះក្នុងរូបភាពសាធារណៈវិញ
- ផ្តល់អនុសាសន៍ថាតើការិយាល័យ OHCHR គួរផ្តល់សហប្រតិបត្តិការបច្ចេកទេស ជំនួយឥតសំណងកសាងសមត្ថភាព ឬ សេវាប្រឹក្សាយោបល់ជូនរដ្ឋពាក់ព័ន្ធ

សម្ភារៈព័ត៌មានទាំងអស់ដែលបានផ្តល់ជូនដោយបុគ្គលនានា និងរដ្ឋាភិបាលពាក់ព័ន្ធនឹងស្ថានការណ៍ស្ថិតក្រោមការពិចារណាព្រមទាំងសេចក្តីសម្រេចដែលធ្វើឡើងនៅដំណាក់កាលនីតិវិធីខុសៗគ្នានៅតែរក្សាជា**ការសម្ងាត់ដដែល**។ ករណីនេះក៏អនុវត្តចំពោះស្ថានការណ៍ទាំងឡាយដែលត្រូវបានបញ្ឈប់ការពិចារណាផងដែរ។

i. ទីកន្លែងដាក់បណ្តឹងជាលក្ខណៈបុគ្គលក្រោមយន្តការនិតិវិធីពិសេស

ផ្នែកនីតិវិធីពិសេស

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

វិមានជាតិ

8-14, avenue de la Paix

CH- 1211 Geneva 10 - ប្រទេសស្វីស

ទូរសារលេខ៖ +៤១(០)២២ ៩១៧ ៩០ ១១

អ៊ីម៉ែល៖ CP @ohchr.org

ឧបសម្ព័ន្ធ I - ទម្រង់គំរូនៃពាក្យបណ្តឹងសម្រាប់ដាក់ជូនក្រោម៖

- ពិធីសារជម្រើសនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ
- អនុសញ្ញាប្រឆាំងនឹងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ឬ
- អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍

**សូមបង្ហាញថា តើនីតិវិធីមួយណាខាងលើដែលអ្នកកំពុងប្រើប្រាស់?**

កាលបរិច្ឆេទ៖ _______________

**I. ព័ត៌មានស្តីពីអ្នកដាក់ពាក្យបណ្តឹង៖**

- នាមត្រកូល
- នាមខ្លួន
- សញ្ជាតិ
- កាលបរិច្ឆេទ និងទីកន្លែងកំណើត
- អាសយដ្ឋានទំនាក់ទំនងលើពាក្យបណ្តឹងនេះ
- សូមបញ្ជាក់ថាតើអ្នកកំពុងដាក់ពាក្យបណ្តឹងនេះ៖
    - ក្នុងនាមរូបអ្នកផ្ទាល់
    - ក្នុងនាមអ្នកដទៃ

[*ប្រសិនបើពាក្យបណ្តឹងនេះកំពុងធ្វើឡើងក្នុងនាមអ្នកដទៃ៖*]

- សូមផ្តល់ព័ត៌មានផ្ទាល់ខ្លួនលម្អិតនៃបុគ្គលនោះដូចខាងក្រោម៖
- នាមត្រកូល
- នាមខ្លួន
- សញ្ជាតិ
- កាលបរិច្ឆេទ និងទីកន្លែងកំណើត
- អាសយដ្ឋាន ឬ កន្លែងស្នាក់នៅបច្ចុប្បន្ន

ប្រសិនបើអ្នកកំពុងដាក់បណ្តឹងនេះដោយមានការដឹងឮ និងការយល់ព្រមពីបុគ្គលនោះ សូមផ្តល់លិខិតប្រគល់សិទ្ធិរបស់បុគ្គលនោះ ដើម្បីអ្នកអាចដាក់ពាក្យបណ្តឹងនេះ។

ឬ

ប្រសិនបើអ្នកមិនបានទទួលសិទ្ធិនោះទេ សូមពន្យល់អំពីទំនាក់ទំនងរបស់អ្នកជាមួយបុគ្គលនោះ និងពន្យល់លម្អិត ហេតុអ្វីអ្នកគិតថា វាសមស្របក្នុងការដាក់ពាក្យបណ្ដឹងនេះក្នុងនាមរូបបុគ្គលនោះ។

## II. រដ្ឋពាក់ព័ន្ធ/មាត្រាដែលត្រូវបានបំពាន

- ឈ្មោះរដ្ឋដែលជាភាគីនៃពិធីសារបន្ថែម (ក្នុងករណីបណ្ដឹងមួយដែលដាក់ជូនទៅគណៈកម្មាធិការសិទ្ធិមនុស្ស) ឬ បានធ្វើសេចក្ដីប្រកាសពាក់ព័ន្ធ (ក្នុងករណីបណ្ដឹងដាក់ជូនទៅគណៈកម្មាធិការប្រឆាំងនឹងទារុណកម្ម ឬ គណៈកម្មាធិការលុបបំបាត់ការរើសអើងពូជសាសន៍។
- មាត្រានៃកាតិកាសញ្ញា ឬ អនុសញ្ញាដែលត្រូវបានអះអាងថាត្រូវបានបំពាន។

## III. ការប្រើអស់មធ្យោបាយផ្លូវច្បាប់ក្នុងស្រុក/ពាក្យស្នើសុំនីតិវិធីអន្តរជាតិផ្សេងទៀត

- ជំហានដែលអនុវត្តដោយ ឬ ក្នុងនាមជាជនរងគ្រោះដែលដាក់ពាក្យបណ្ដឹងដើម្បីទទួលបានដំណោះស្រាយពីការរំលោភបំពានដែលបានដាក់បណ្ដឹងក្នុងរដ្ឋពាក់ព័ន្ធ -សេចក្ដីលម្អិតអំពីការអនុវត្តនីតិវិធី រួមទាំង ឧបាស្រ័យនៅតុលាការ និង អាជ្ញាធរសាធារណៈផ្សេងទៀត សេចក្ដីលម្អិតនៃបណ្ដឹងរបស់អ្នក ដែលធ្វើឡើងនៅពេលណាមួយ និងមានលទ្ធផលណាមួយ។
- ប្រសិនបើអ្នកមិនទាន់ប្រើអស់នូវមធ្យោបាយផ្លូវច្បាប់ទាំងនេះ ដោយសារពាក្យស្នើសុំនឹងត្រូវបានពន្យារពេលយូរពេក មធ្យោបាយផ្លូវច្បាប់ទាំងនេះមិនមានប្រសិទ្ធភាព មិនមានទៀតសម្រាប់អ្នក ឬ ប្រសិនបើមានហេតុផលផ្សេងទៀត សូមជួយពន្យល់ហេតុផលរបស់អ្នកឲ្យបានលម្អិត។
- តើអ្នកបានដាក់ពាក្យបណ្ដឹងក្នុងរឿងដូចគ្នា ដើម្បីសុំធ្វើការពិនិត្យពិច័យក្រោមនីតិវិធីមួយផ្សេងទៀតនៃការស៊ើបអង្កេត ឬ ដំណោះស្រាយជាអន្តរជាតិដែរឬទេ (ឧទាហរណ៍ គណៈកម្មការអន្តរអាមេរិកាំងស្ដីពីសិទ្ធិមនុស្ស តុលាការសិទ្ធិមនុស្សអឺរ៉ុប ឬ គណៈកម្មការអាហ្វ្រិកស្ដីពីសិទ្ធិមនុស្ស និងពលរដ្ឋ) ?
- ប្រសិនបើមាន សូមពន្យល់លម្អិតថាតើនីតិវិធីមួយណាដែលបានអនុវត្ត ឬ កំពុងប្រើប្រាស់ ពាក្យបណ្ដឹងមួយណាអ្នកបានធ្វើឡើងនៅពេលណាមួយ និងទទួលបានលទ្ធផលបែបណា?

IV. អង្គហេតុនៃពាក្យបណ្តឹង

- សូមពន្យល់លម្អិតតាមលំដាប់លំដោយនូវអង្គហេតុ និងកាលៈទេសៈនៃពាក្យបណ្តឹងអំពីការរំលោភបំពាន។ សូមបញ្ចូលរាល់បញ្ហាទាំងអស់ ដែលអាចពាក់ព័ន្ធនឹងការវាយតម្លៃ និងការពិចារណាលើករណីពិសេសរបស់អ្នក។ សូមពន្យល់តើអ្នកមានការពិចារណាដូចម្តេច នៅពេលអង្គហេតុ និងកាលទេសៈដែលបានពណ៌នា បំពានលើសិទ្ធរបស់អ្នក?
- ហត្ថលេខារបស់អ្នករៀបចំពាក្យបណ្តឹង។

V. បញ្ជីត្រួតពិនិត្យឯកសារគាំទ្រ (ច្បាប់ថតចម្លង មិនងមិនមែនច្បាប់ដើម ដែលត្រូវភ្ជាប់ជាមួយពាក្យបណ្តឹងរបស់អ្នក)៖

- លិខិតផ្តល់សិទ្ធិលាយលក្ខណ៍អក្សរ (ប្រសិនបើអ្នកដាក់ពាក្យបណ្តឹងក្នុងនាមឲ្យអ្នកដទៃផ្សេងទៀត ឬ បើមិនដូច្នោះទេ មិនបានបង្ហាញភស្តុតាងត្រឹមត្រូវអំពីការមិនមានលិខិតផ្តល់សិទ្ធិជាក់លាក់)។
- សេចក្តីសម្រេចរបស់តុលាការ និងអាជ្ញាធរក្នុងស្រុកលើពាក្យបណ្តឹងរបស់អ្នក (ច្បាប់ចម្លងនៃច្បាប់ជាតិដែលពាក់ព័ន្ធក៏មានប្រយោជន៍ដែរ)។
- ពាក្យបណ្តឹង និងសេចក្តីសម្រេចដែលអនុវត្តតាមនីតិវិធីផ្សេងទៀតនៃការស៊ើបអង្កេត ឬដំណោះស្រាយជាអន្តរជាតិ។
- ឯកសារណាមួយ ឬ ភស្តុតាងច្បាស់លាស់ដទៃទៀតដែលអ្នកមាន ដែលជាភស្តុតាងគាំទ្រការពណ៌នារបស់អ្នកក្នុងផ្នែក IV (ខាងលើ) នៃអង្គហេតុពាក្យបណ្តឹងរបស់អ្នក និង/ឬទទ្បីករណ៍របស់អ្នកដែលអង្គហេតុបានរៀបរាប់អំពីចំនួនដងនៃការរំលោភបំពានសិទ្ធិរបស់អ្នក។

ប្រសិនបើអ្នកមិនបានភ្ជាប់ព័ត៌មាននេះមកជាមួយ ហើយចាំបាច់ត្រូវស្វែងរកព័ត៌មាននេះជាពិសេសពីអ្នក ឬ ប្រសិនបើឯកសារភ្ជាប់មកជាមួយមិនត្រូវបានផ្តល់ឲ្យក្នុងភាសាការងារនៃលេខាធិការដ្ឋាន ការពិចារណាលើពាក្យបណ្តឹងរបស់អ្នកអាចត្រូវពន្យារពេល។

ឧបសម្ព័ន្ធ II - គោលការណ៍ណែនាំនៃពាក្យបណ្តឹងសម្រាប់ដាក់ជូនក្រោម៖

- ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ

| ១. ព័ត៌មានទំនាក់ទំនងពាក់ព័ន្ធនឹងអ្នករៀបចំពាក្យបណ្តឹង |
|---|

- នាមត្រកូល
- នាមខ្លួន
- កាលបរិច្ឆេទ និងទីកន្លែងកំណើត
- សញ្ជាតិ
- លេខលិខិតឆ្លងដែន/អត្តសញ្ញាណប័ណ្ណ (ប្រសិនបើមាន)
- ភេទ
- ស្ថានភាពគ្រួសារ/កូន
- មុខរបរ
- ប្រវត្តិជាតិពន្ធុ ទំនាក់ទំនងសាសនា ក្រុមសង្គម (ប្រសិនបើពាក់ព័ន្ធ)
- អាសយដ្ឋានបច្ចុប្បន្ន
- អាសយដ្ឋានប្រៃសណីយ៍សម្រាប់ទំនាក់ទំនងជាសម្ងាត់ (ប្រសិនបើមានក្រៅពីអាសយដ្ឋានបច្ចុប្បន្ន)
- ទូរសារ/ទូរស័ព្ទ/អ៊ីម៉ែល
- សូមបញ្ជាក់ថាតើអ្នកកំពុងដាក់ពាក្យបណ្ដឹងនេះក្នុងទំនាក់ទំនងជា៖
- ជនរងគ្រោះដាក់ពាក្យបណ្ដឹង ប្រសិនបើមានក្រុមជនរងគ្រោះដាក់ពាក្យបណ្ដឹងមួយក្រុមផ្ដល់ព័ត៌មានមូលដ្ឋានអំពីរឿងរបស់ពួកគេម្នាក់ៗ។
- អ្នកតំណាងឲ្យជនរងគ្រោះដាក់ពាក្យបណ្ដឹង។ ផ្ដល់ភស្តុតាងដែលបង្ហាញនូវការយល់ព្រមពីជនរងគ្រោះ ឬ ហេតុផលត្រឹមត្រូវដែលដាក់ជូនសម្រាប់ទំនងទំនងដោយគ្មានការយល់ព្រមពីយល់ជនរងគ្រោះ។

**២. ព័ត៌មានទាក់ទងនឹងជនរងគ្រោះដាក់ពាក្យបណ្ដឹង (ប្រសិនបើមានក្រៅពីអ្នករៀបចំពាក្យបណ្ដឹង**

- នាមត្រកូល
- នាមខ្លួន
- កាលបរិច្ឆេទ និងទីកន្លែងកំណើត
- សញ្ជាតិ
- លេខលិខិតឆ្លងដែន/អត្តសញ្ញាណប័ណ្ណ (ប្រសិនបើមាន)
- ភេទ
- ស្ថានភាពគ្រួសារ/កូន
- មុខរបរ

- ប្រវត្តិជាតិពន្ធុ ទំនាក់ទំនងសាសនា ក្រុមសង្គម (ប្រសិនបើពាក់ព័ន្ធ)
- អាសយដ្ឋានបច្ចុប្បន្ន
- អាសយដ្ឋានប្រៃសណីយ៍សម្រាប់ទំនាក់ទំនងជាសម្ងាត់ (ប្រសិនបើមានក្រៅពីអាសយដ្ឋានបច្ចុប្បន្ន)
- ទូរសារ/ទូរស័ព្ទ/អ៊ីម៉ែល

**៣.ព័ត៌មានស្តីពីភាគីរដ្ឋពាក់ព័ន្ធ**

- ឈ្មោះរដ្ឋភាគី (ប្រទេស)

**៤. លក្ខណៈនៃពាក្យបណ្តឹងលើការរំលោភបំពាន**

ផ្តល់ព័ត៌មានលម្អិត ដើម្បីជាភស្តុតាងគាំទ្រពាក្យបណ្តឹងរបស់អ្នក រួមទាំង៖

- ការពណ៌នាអំពីពាក្យបណ្តឹងលើការរំលោភបំពាន និងចារីដែលត្រូវបានចោទប្រកាន
- កាលបរិច្ឆេទ
- ទីកន្លែង
- បទប្បញ្ញត្តិនៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ ដែលត្រូវបានបញ្ជាក់ថាទទួលរងការរំលោភបំពាន។ ប្រសិនបើការទំនាក់ទំនងសំដៅលើបទប្បញ្ញត្តិច្រើនលើសពីមួយ សូមពណ៌នាអំពីបញ្ហានីមួយៗដាច់ដោយឡែក។

**៥. ជំហានដែលបានអនុវត្តដើម្បីប្រើឲ្យអស់នូវមធ្យោបាយផ្លូវច្បាប់ក្នុងស្រុក**

ពណ៌នាអំពីសកម្មភាពដែលបានអនុវត្ត ដើម្បីប្រើឲ្យអស់នូវមធ្យោបាយផ្លូវច្បាប់ក្នុងស្រុក ឧទាហរណ៍ គោលបំណងក្នុងការទទួលបានដំណោះស្រាយផ្លូវច្បាប់ រដ្ឋបាល នីតិបញ្ញត្តិ គោលនយោបាយ ឬ កម្មវិធីមធ្យោបាយផ្លូវច្បាប់ រួមទាំង៖

- ប្រភេទនៃមធ្យោបាយផ្លូវច្បាប់ដែលរកឃើញ
- កាលបរិច្ឆេទ
- ទីកន្លែង
- អ្នកផ្តួចផ្តើមសកម្មភាព
- អាជ្ញាធរ ឬ អង្គភាពដោះស្រាយ
- ឈ្មោះតុលាការកាត់ក្តីករណីបណ្តឹង (ប្រសិនបើមាន)
- ប្រសិនបើមធ្យោបាយផ្លូវច្បាប់ក្នុងស្រុកមិនទាន់ត្រូវបានប្រើឲ្យអស់ សូមជួយពន្យល់អំពី

មូលហេតុ។

**សម្គាល់៖** សូមភ្ជាប់ជាមួយនូវច្បាប់ឯកសារពាក់ព័ន្ធទាំងអស់។

**៦. នីតិវិធីអន្តរជាតិដទៃទៀត**

តើបញ្ហាដូចគ្នាតែមួយត្រូវបានដាក់ឲ្យពិនិត្យពិច័យ ឬ កំពុងត្រូវបានដាក់ឲ្យពិនិត្យពិច័យក្រោមនីតិវិធីផ្សេងទៀតនៃការស៊ើបអង្កេត ឬ ដំណោះស្រាយជាអន្តរជាតិដែរឬទេ? ប្រសិនបើមាន សូមពន្យល់៖

- ប្រភេទនៃនីតិវិធី
- កាលបរិច្ឆេទ
- ទីកន្លែង
- លទ្ធផល (ប្រសិនបើមាន)

**សម្គាល់៖** សូមភ្ជាប់ជាមួយច្បាប់ចម្លងឯកសារពាក់ព័ន្ធទាំងអស់។

**៧. កាលបរិច្ឆេទ និងហត្ថលេខា**

កាលបរិច្ឆេទ/ទីកន្លែង៖ ____________________

ហត្ថលេខារបស់អ្នករៀបចំពាក្យបណ្ដឹហ និង/ឬ ជនរងគ្រោះ ____________________

**៨. បញ្ជីឯកសារភ្ជាប់ (សុំកុំ ផ្ញើឯកសារច្បាប់ដើម សូមផ្ញើតែឯកសារច្បាប់ចម្លងប៉ុណ្ណោះ)**

## IX. មូលនិធិ និងជំនួយឥតសំណងឥតសំណង

មានមូលនិធិ និងជំនួយឥតសំណងឥតសំណងជាច្រើន ក្នុងនោះមានមូលនិធិ និងជំនួយឥតសំណងឥតសំណងខ្លះត្រូវបានចាត់ចែងផ្ទាល់ដោយ**ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស** (OHCHR ដែលផ្តល់នូវអត្ថប្រយោជន៍ផ្ទាល់ដល់តួអង្គសង្គមស៊ីវិល រួមទាំង អង្គការមិនមែនរដ្ឋាភិបាល អង្គការថ្នាក់មូលដ្ឋាន សមាគមវិជ្ជាជីវៈ និងបុគ្គលនានា។ មូលនិធិ និងជំនួយឥតសំណងទាំងនេះអាចផ្តល់ជាការគាំទ្រហិរញ្ញវត្ថុសម្រាប់សកម្មភាពសង្គមស៊ីវិលក្នុងផ្នែកសិទ្ធិមនុស្សមួយចំនួន។

**មូលនិធិ** ផ្តល់ជាជំនួយឥតសំណងផ្នែកហិរញ្ញវត្ថុសម្រាប់គាំទ្រសកម្មភាពក្នុងអាណត្តិការងាររបស់ខ្លួន។ ការិយាល័យ OHCHR និងការិយាល័យអង្គការសហប្រជាជាតិដទៃទៀតគ្រប់គ្រងមូលនិធិ និងជំនួយឥតសំណងសម្រាប់គាំទ្រដល់តួអង្គសង្គមស៊ីវិលក្នុងកាលៈទេសៈមួយចំនួន។ មូលនិធិទាំងនេះទទួលបានពីវិភាគទានចូលរួមចំណែកដោយស្ម័គ្រចិត្តពីរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នឯកជន ឬ សាធារណៈដទៃទៀត និងបុគ្គលនានាសម្រាប់បែកចែកស្របតាមអាណត្តិការងារនៃការិយាល័យ។

អង្គការសង្គមស៊ីវិល ដូចជា អង្គការមិនមែនរដ្ឋាភិបាល អង្គការតាមមូលដ្ឋាន ក្រុមសហគមន៍ និងសមាគមវិជ្ជាជីវៈ ជាទូទៅ មានសិទ្ធិស្នើសុំមូលនិធិ និងជំនួយឥតសំណង។ ក្នុងករណីមួយចំនួនបុគ្គលក៏អាចស្នើសុំមូលនិធិបានដែរ។ តួអង្គសង្គមស៊ីវិលដែលមានបំណងស្នើសុំគួរត្រួតពិនិត្យគោលការណ៍ណែនាំឲ្យបានហ្មត់ចត់ និងធានាថា ខ្លួនឆ្លើយតបនឹងលក្ខខណ្ឌរដ្ឋបាល និងលក្ខខណ្ឌដទៃទៀត។

**ឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ចនៃអង្គការសហប្រជាជាតិ (ក្រុមប្រឹក្សា ECOSOC) ពុំមែនជាលក្ខខណ្ឌទាមទាមឲ្យអង្គការមិនមែនរដ្ឋាភិបាល និងតួអង្គសង្គមស៊ីវិលផ្សេងទៀតចូលរួម ឬទទួលបានមូលនិធិ ឬ ជំនួយឥតសំណងទាំងនេះឡើយ។**

## ក. តើអ្វីខ្លះជាមូលនិធិ ឬ ជំនួយឥតសំណង?

មូលនិធិ និងជំនួយឥតសំណងដែលគ្រប់គ្រងដោយការិយាល័យ OHCHR មាន៖

- **មូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិសម្រាប់ជនរងគ្រោះនៃទារុណកម្ម** ផ្តល់ជំនួយឥតសំណងដល់តួអង្គសង្គមស៊ីវិលដែលផ្តល់សេវាវេជ្ជសាស្ត្រ ចិត្តសាស្ត្រ សង្គមកិច្ច សេដ្ឋកិច្ច ច្បាប់ មនុស្សធម៌ ឬ ទម្រង់ជំនួយឥតសំណងផ្សេងទៀតដល់ជនរងគ្រោះនៃទារុណកម្ម និងសមាជិកគ្រួសាររបស់ជនរងគ្រោះទាំងនេះ។ តួអង្គសង្គមស៊ីវិលដែលមានសិទ្ធិទទួលបាន

មូលនិធិ ឬ ជំនួយឥតសំណង រួមមានជាពិសេស អង្គការមិនមែនរដ្ឋាភិបាល មជ្ឈមណ្ឌលស្តារនិតិសម្បទាជំនាញ សមាគមជនរងគ្រោះ អង្គការមូលនិធិ និងមន្ទីរពេទ្យ និងតួអង្គដែលមិនទទួលបានញឹកញាប់នោះគឺបុគ្គលអ្នកការពារសិទ្ធិនុស្ស ឧទាហរណ៍ មេធាវីតំណាងឲ្យជនរងគ្រោះ។

- **មូលនិធិស្ម័គ្រចិត្តសម្រាប់ប្រជាជនជនជាតិដើមភាគតិច** ផ្តល់ជំនួយឥតសំណងសម្រាប់ការធ្វើដំណើរដើម្បីជួយសម្របសម្រួលការចូលរួមរបស់អ្នកតំណាងសហគមន៍ និងអង្គការជនជាតិដើមភាគតិចក្នុងកិច្ចប្រជុំរបស់អង្គការសហប្រជាជាតិពាក់ព័ន្ធនឹងបញ្ហាជនជាតិដើមភាគតិច។
- **មូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិស្តីពីទម្រង់នៃទាសភាពនាសម័យបច្ចុប្បន្ន** ផ្តល់ជំនួយឥតសំណងសម្រាប់គម្រោងខ្នាតតូច ជាពិសេស ដល់អង្គការសង្គមស៊ីវិល ដូចជាអង្គការមិនមែនរដ្ឋាភិបាល សហគមន៍ និងក្រុមយុវជន សហជីព ឬ សមាគមវិជ្ជាជីវៈ ដែលជួយដល់ជនរងគ្រោះនៃទាសភាពសម័យមុន និង
- គម្រោង"**រួមគ្នាជួយសហគមន៍**" ផ្តល់ជំនួយឥតសំណងខ្នាតតូច ដើម្បីគាំទ្រការបណ្តុះបណ្តាលសិទ្ធិមនុស្សតាមមូលដ្ឋាន និងគំនិតផ្តួចផ្តើមការអប់រំ។

មូលនិធិពីរផ្សេងទៀត ដែលគាំទ្រសកម្មភាពសង្គមស៊ីវិលស្តីពីបញ្ហាសំខាន់ៗ ក៏ត្រូវបានបង្ហាញក្នុងជំពូកនេះដែរ៖

- **មូលនិធិនៃអង្គការសហប្រជាជាតិដើម្បីលិទ្ធិប្រជាធិបតេយ្យ** ផ្តល់មូលនិធិសម្រាប់គម្រោងកសាង និងពង្រឹងស្ថាប័នប្រជាធិបតេយ្យ លើកកម្ពស់សិទ្ធិមនុស្ស និងធានានូវការចូលរួមគ្រប់ក្រុមទាំងអស់ក្នុងដំណើរការលទ្ធិប្រជាធិបតេយ្យ និង
- **មូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិសម្រាប់ជនពិការ** ផ្តល់ជំនួយឥតសំណងខ្នាតតូចសម្រាប់គាំទ្រសកម្មភាពដែលមានគោលដៅកសាងសមត្ថភាពរបស់អង្គការសង្គមស៊ីវិលក្នុងការចូលរួមអនុវត្ត**អនុសញ្ញាស្តីពីសិទ្ធិជនពិការ**។

ទោះបីជាត្រូវបានគ្រប់គ្រងដោយការិយាល័យអង្គការសហប្រជាជាតិដទៃទៀតក៏ដោយ ការិយាល័យ OHCHR នៅតែមានតួនាទីដែលត្រូវបានផ្តល់ជូនខ្លួនក្នុងមូលនិធិទាំងនេះដដែល។

**ព័ត៌មានទំនាក់ទំនង**

*មូលនិធិគ្រប់គ្រងដោយការិយាល័យ OHCHR*

**មូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិសម្រាប់ជនរងគ្រោះនៃទារុណកម្ម**

មូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិសម្រាប់ជនរងគ្រោះនៃទារុណកម្ម
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

៨-១៤, ផ្លូវ de la Paix
CH-១២១១ ហ្សឺណែវ ១០ - ប្រទេសស្វីស
ទូរស័ព្ទ៖ +៤១ (០)២២ ៩១៧ ៩៣ ១៥
ទូរសារ៖ +៤១ (០)២២ ៩១៧ ៩០ ១៧
អ៊ីម៉ែល៖ unvfvt@ohchr.org

**មូលនិធិស្ម័គ្រចិត្តសម្រាប់ប្រជាជនជនជាតិដើមភាគតិច**

មូលនិធិស្ម័គ្រចិត្តសម្រាប់ប្រជាជនជនជាតិដើមភាគតិច
ការិយាល័យឧត្តមស្នងការអង្គសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

៨-១៤, ផ្លូវ de la Paix
CH-១២១១ ហ្សឺណែវ ១០ - ប្រទេសស្វីស
ទូរស័ព្ទ៖ +៤១ (០)២២ ៩២៨ ៩១ ៦៤ ឬ +៤១ (០)២២ ៩២៨ ៩១ ៤២
ទូរសារ៖ +៤១ (០)២២ ៩២៨ ៩០ ៦៦
អ៊ីម៉ែល៖ IndigenousFunds@ohchr.org

**មូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិស្តីពីទម្រង់នៃទាសភាពសម័យមុន**

មូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិស្តីពីទម្រង់នៃទាសភាពសម័យមុន
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

៨-១៤, ផ្លូវ de la Paix
CH-១២១១ ហ្សឺណែវ ១០ - ប្រទេសស្វីស
ទូរស័ព្ទ៖ +៤១ (០)២២ ៩២៨ ៩៣ ៨១ ឬ +៤១ (០)២២ ៩២៨ ៩១ ៦៤
ទូរសារ៖ +៤១ (០)២២ ៩២៨ ៩០ ៦៦
អ៊ីម៉ែល៖ SlaveryFunds@ohchr,org

**គម្រោង "រួមគ្នាជួយសហគមន៍(ACT)"**

គម្រោង ACT
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

៨-១៤, ផ្លូវ de la Paix
CH-១២១១ ហ្សឺណែវ ១០ - ប្រទេសស្វីស

ទូរសារ៖ +៤១ (០)២២ ៩២៨ ៩០ ៦១
អ៊ីម៉ែល៖ ACTProject@ohchr.org
*មូលនិធិគ្រប់គ្រងដោយការិយាល័យអង្គការសហប្រជាជាតិផ្សេងទៀតដែលក្នុងនោះការិយាល័យ OHCHR ត្រូវបានកំណត់នូវតួនាទី។*

**មូលនិធិនៃអង្គការសហប្រជាជាតិសម្រាប់ប្រជាធិតេយ្យ**

មូលនិធិនៃអង្គការសហប្រជាជាតិដើម្បីលទ្ធិប្រជាធិបតេយ្យ (UNDEF)
អង្គការសហប្រជាជាតិ
One UN Plaza, Room DC1-១៣៣០
ញ៉ូវយ៉ក NY 10017
សហរដ្ឋអាមេរិក
ទូរស័ព្ទ៖ +១ ៩១៧ ៣៦៧ ៤២ ១០ ឬ +១ ៩១៧ ៣៦៧ ៨០ ៦២
ទូរសារ៖ +១ ២១២ ៩៦៣ ១៤ ៨៦
អ៊ីម៉ែល៖ democracyfund@un.org

**មូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិស្តីពីពិការភាព**

លេខាធិការដ្ឋានសម្រាប់អនុសញ្ញាស្តីពីសិទ្ធិជនពិការ
នាយកដ្ឋានកិច្ចការសេដ្ឋកិច្ច និងសង្គម
អង្គការសហប្រជាជាតិ
Two UN Plaza, DC2-1372
ញ៉ូវយ៉ក NY 10017
សហរដ្ឋអាមេរិក
ទូរសារ៖ +១ ២១២១ ១១
អ៊ីម៉ែល៖ enable@un.org

## ខ. តើមូលនិធិ និងជំនួយឥតសំណងមានប្រតិបត្តិការដូចម្តេច?

### ១. មូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិសម្រាប់ជនរងគ្រោះនៃទារុណកម្ម

អាណត្តិការងារនៃមូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិសម្រាប់ជនរងគ្រោះនៃទារុណកម្ម គឺដើម្បីផ្តល់ជំនួយឥតសំណងដល់គម្រោងសម្រាប់ជំនួយឥតសំណងមនុស្សធម៌ (វេជ្ជសាស្ត្រ ចិត្តសាស្ត្រ ច្បាប់ សង្គម និងហិរញ្ញវត្ថុ) ជនរងគ្រោះនៃទារុណកម្ម និងសមាជិកគ្រួសាររបស់

ជនរងគ្រោះ តាមរយៈប្រព័ន្ធជំនួយឥតសំណងដែលបានបង្កើតឡើង ជាធម្មតា តាមរយៈតួអង្គសង្គមស៊ីវិល ដូចជា អង្គការមិនមែនរដ្ឋាភិបាល មជ្ឈមណ្ឌលស្តារនីតិសម្បទាជំនាញ សមាគមជនរងគ្រោះ អង្គការមូលនិធិ និងមន្ទីរពេទ្យ និងតួអង្គមិនទទួលបានញឹកញាប់ ពោលគឺ បុគ្គលអ្នកការពារសិទ្ធិមនុស្ស។ ពាក្យសុំមូលនិធិ ឬ ជំនួយឥតសំណងពីរដ្ឋាភិបាល ព្រឹទ្ធសភា ឬ ស្ថាប័នរដ្ឋបាល គណៈបក្សនយោបាយ ឬ ចលនាសេរីជាតិ មិនទទួលយកបានឡើយ។

មូលនិធិស្ម័គ្រចិត្តសម្រាប់ជនរងគ្រោះនៃទារុណកម្ម គឺជាមូលនិធិដែលត្រូវបានគ្រប់គ្រងធំបំផុតដោយការិយាល័យ OHCHR ដែលចូលរួមចំណែកដល់គម្រោងអនុវត្តដោយតួអង្គសង្គមស៊ីវិលក្នុងប្រទេសច្រើនជាង៦០ប្រទេស។ មូលនិធិនេះត្រូវបានគ្រប់គ្រងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិតាមការប្រឹក្សាយោបល់របស់ក្រុមប្រឹក្សាភិបាល។ ក្រុមប្រឹក្សាភិបាលនេះ ជួបប្រជុំគ្នាពីរដងក្នុងមួយឆ្នាំ ក្នុងខែកុម្ភៈស្តីពីបញ្ហាគោលនយោបាយ និងខែតុលាស្តីពីការផ្តល់ជំនួយឥតសំណង។ កិច្ចប្រជុំនេះធ្វើការត្រួតពិនិត្យនូវរបាយការណ៍ស្តីពីការប្រើប្រាស់ជំនួយឥតសំណងកន្លងមក និងអនុម័តនូវអនុសាសន៍ស្តីពីជំនួយឥតសំណងថ្មី និងជាកិច្ចប្រជុំជាមួយម្ចាស់ជំនួយឥតសំណងក្នុងការផ្តល់មូលនិធិ ក៏ដូចជា ម្ចាស់ជំនួយឥតសំណងតាមស្ថានប័នដទៃទៀត និងពិភាក្សាអំពីបញ្ហាគោលនយោបាយពាក់ព័ន្ធនឹងជំនួយឥតសំណងដល់ជនរងគ្រោះនៃទារុណកម្ម។ លេខាធិការដ្ឋាន និងក្រុមប្រឹក្សាភិបាលរបស់មូលនិធិ មានទីតាំងស្ថិតនៅការិយាល័យ OHCHR ក្នុងទីក្រុងហ្សឺណែវ។ លេខាធិការដ្ឋានជាអ្នកកំណត់អំពីលទ្ធភាពនៃពាក្យស្នើសុំជំនួយឥតសំណងសម្រាប់គម្រោង ចំណែកក្រុមប្រឹក្សាភិបាលមានតួនាទីជាអ្នកវិនិច្ឆ័យលើពាក្យសុំ។ ក្រុមប្រឹក្សាភិបាលពិចារណាលើធាតុផ្សំជាច្រើនរួមទាំង៖

- ចំនួនជនងរងគ្រោះនៃទារុណកម្ម និងសមាជិកគ្រួសាររបស់ជនរងគ្រោះ ដែលនឹងទទួលបានជំនួយឥតសំណងពីគម្រោង។
- ប្រភេទនៃទារុណកម្មដែលជនរងគ្រោះបានទទួលរង និងផលប៉ះពាល់នៃការឈឺចាប់បន្ទាប់ពីទទួលរងការធ្វើទារុណកម្ម
- ប្រភេទជំនួយឥតសំណងចាំបាច់
- បទពិសោធន៍វិជ្ជាជីវៈរបស់បុគ្គលិកគម្រោងក្នុងការជួយដល់ជនរងគ្រោះនៃទារុណកម្ម
- ករណីសិក្សារបស់ជនរងគ្រោះដែលត្រូវផ្តល់ជំនួយឥតសំណង និង
- តម្រូវការក្នុងការផ្តល់ជំនួយឥតសំណងដល់គម្រោងខ្នាតតូចសម្រាប់ជំនួយឥតសំណងមនុស្សធម៌ដល់ជនរងគ្រោះនៃទារុណកម្ម ដែលភាគច្រើនមានមូលនិធិតិចតួចក្នុងតំបន់អាទិភាព៖ អាហ្វ្រិក អាស៊ី អាស៊ីកណ្តាល និងអឺរ៉ុបខាងកើត។

ជំនួយឥតសំណងបានមកពីមូលនិធិគ្របដណ្តប់សម្រាប់រយៈពេល១២ខែ។ ពាក្យសុំថ្មីសម្រាប់ការបន្តគម្រោងអាចរៀបចំដាក់បាន ហើយជំនួយឥតសំណងនឹងត្រូវបានផ្តល់អនុសាសន៍ផ្តល់ជូនឬកិអត់ ក្រោយពីក្រុមប្រឹក្សាទទួលបាន**របាយការណ៍ហិរញ្ញវត្ថុ និងសនវកម្មមានការពន្យល់លម្អិតប្រកបដោយការពេញចិត្តស្តីពីការប្រើប្រាស់ជំនួយឥតសំណងកន្លងមក។**

វដ្តជំនួយឥតសំណងនៃឆ្នាំនីមួយៗបង្ហាញដូចខាងក្រោម៖

- កាលបរិច្ឆេទកំណត់សម្រាប់ការទទួលពាក្យសុំ និងរបាយការណ៍ស្តីពីការប្រើប្រាស់ជំនួយឥតសំណងកន្លងមក៖ **ថ្ងៃទី១ ខែមេសា**
- ការវិភាគរបស់លេខាធិការដ្ឋានលើពាក្យសុំ ក៏ដូចជា ការចុះពិនិត្យជ្រើសរើសជាមុននូវអ្នកដាក់ពាក្យសុំដែលអាចទទួលយកបាន៖ **ខែមេសាដល់ខែកញ្ញា**
- កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល៖ **ខែតុលា**
- ព័ត៌មានសម្រាប់អ្នកដាក់ពាក្យសុំស្តីពីអនុសាសន៍របស់ក្រុមប្រឹក្សាភិបាល៖ **ខែវិច្ឆិកា**
- ការផ្តល់ជំនួយឥតសំណង៖ **ខែមករានៃឆ្នាំបន្ទាប់ពីការដាក់ពាក្យស្នើសុំ។**

# តើត្រូវធ្វើដូចម្តេចដើម្បីទទួលបានមូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិសម្រាប់ជនរងគ្រោះនៃទារុណកម្ម?[76]

### តើអ្នកណាមានសិទ្ធិធ្វើការស្នើសុំជំនួយឥតសំណង?

- មានតែស្ថាប័នមិនមែនរដ្ឋាភិបាលប៉ុណ្ណោះអាចស្នើសុំបាន រួមមានដូចជា អង្គការមិនមែនរដ្ឋាភិបាល មជ្ឈមណ្ឌលស្តារនីតិសម្បទាជំនាញ សមាគមជនរងគ្រោះ អង្គការមូលនិធិ និងមន្ទីរពេទ្យ និងតួអង្គមិនទទួលបានញឹកញាប់គឺ អ្នកការពារសិទ្ធិមនុស្ស ឧទាហរណ៍ មេធាវីតំណាងឲ្យជនរងគ្រោះ។
- ពាក្យសុំមកពីរដ្ឋាភិបាល ចលនាជាតិសេរី ឬ គណៈបក្សនយោបាយ មិនទទួលយកបាននោះឡើយ។
- អ្នកទទួលផលផ្ទាល់ពីគម្រោង ត្រូវតែជាជនរងគ្រោះនៃទារុណកម្ម ដូចបានលើកឡើងក្នុងមាត្រា១នៃសេចក្តីប្រកាសស្តីពីការការពារមនុស្សទាំងអស់ ឬ សមាជិកគ្រួសាររបស់ជនរងគ្រោះពីទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬ ទណ្ឌកម្មឯកទៀតដែលឃោរឃៅ អមនុស្សធម៌ ឬ បន្ថោកបន្ទាប ។

[76] រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នឯកជន ឬ សាធារណៈ អាចចូលរួមវិភាគទានក្នុងមូលនិធិបាន។ សម្រាប់ព័ត៌មានស្តីពីការចូលរួមវិភាគទាន សូមទាក់ទងលេខាធិការដ្ឋាន។

- បុគ្គលិកដែលពាក់ព័ន្ធក្នុងគម្រោង គួរមានបទពិសោធន៍ក្នុងការផ្តល់ជំនួយឥតសំណងផ្ទាល់ដល់ជនរងគ្រោះនៃទារុណកម្ម ហើយគម្រោងគួរមានជាស្រេចក្នុងពេលដាក់ពាក្យសុំជំនួយឥតសំណង។
- ពាក្យសុំជំនួយឥតសំណង ត្រូវរៀបចំឡើងដោយប្រើនូវទម្រង់បែបបទពាក្យស្នើសុំតាមប្រព័ន្ធអនឡាញរបស់មូលនិធិ ដែលអាចរកបាននៅលើគេហទំព័ររបស់ការិយាល័យ OHCHR ។
- ពាក្យសុំត្រូវដាក់ជូនលេខាធិការដ្ឋានមូលនិធិ មុនថ្ងៃទី១ ខែមេសាជារៀងរាល់ឆ្នាំ។

អ្នកដាក់ពាក្យសុំលើកទីមួយមកកាន់មូលនិធិគួរៈ

- ផ្តល់ព័ត៌មានមូលដ្ឋានស្តីពីអង្គការរបស់ខ្លួន
- បង្ហាញថា បុគ្គលិករបស់ខ្លួនមានបទពិសោធន៍ពាក់ព័ន្ធក្នុងការផ្តល់ជំនួយឥតសំណងផ្ទាល់ដល់ជនរងគ្រោះនៃទារុណកម្ម (គួរភ្ជាប់មកជាមួយនូវប្រវត្តិរូបសង្ខេប)
- ពន្យល់អំពីគោលបំណង និងហេតុផលអាចទទួលយកបាននៃគម្រោង និង
- ផ្តល់លក្ខន្តិកៈរបស់អង្គការ។

**តើគម្រោងប្រភេទណាខ្លះត្រូវបានទទួលយក?**

- ពាក្យសុំសម្រាប់ជំនួយឥតសំណង គួរមានគោលដៅផ្តល់នូវជំនួយឥតសំណងវេជ្ជសាស្ត្រ ចិត្តសាស្ត្រ សង្គម សេដ្ឋកិច្ច ច្បាប់ មនុស្សធម៌ ឬ ជាទម្រង់ជំនួយឥតសំណងផ្សេងទៀតជូនដល់ជនរងគ្រោះនៃទារុណកម្ម និងសមាជិកគ្រួសាររបស់ជនរងគ្រោះ។
- ពាក្យសុំសម្រាប់គម្រោងពាក់ព័ន្ធនឹងការស្តារសង្គម ឬ សេដ្ឋកិច្ចឡើងវិញសម្រាប់ជនរងគ្រោះនៃទារុណកម្មនៅក្នុងសង្គម រួមទាំង ការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ជនរងគ្រោះ គឺជាពាក្យសុំអាចទទួលយកបាន។
- ផ្អែកទៅតាមមូលនិធិដែលមាន ជំនួយឥតសំណងដែលមានចំនួនកម្រិត ក៏អាចផ្តល់សម្រាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈ ឬ សម្រាប់ការរៀបចំសន្និសីទ និងសិក្ខាសាលា ដោយមានការផ្តោតជាពិសេសលើការប្រព្រឹត្តចំពោះជនរងគ្រោះនៃទារុណកម្ម។
- ពាក្យសុំសម្រាប់គម្រោងដែលមានគោលដៅធ្វើយុទ្ធនាការប្រឆាំងនឹងការធ្វើទារុណកម្ម ការពារការធ្វើទារុណកម្ម ឬ ការផ្តល់ជំនួយឥតសំណងហិរញ្ញវត្ថុដល់គម្រោងដទៃទៀត នឹងមិនទទួលយកឡើយ។
- ពាក្យសុំសម្រាប់គម្រោងពាក់ព័ន្ធនឹងការស៊ើបអង្កេត ការសិក្សា ការស្រាវជ្រាវ ការបោះពុម្ពផ្សាយព្រឹត្តិប័ត្រព័ត៌មាន ឬ សកម្មភាពស្រដៀងគ្នា នឹងមិនទទួលយកឡើយ។
- ជាវិធាន ពាក្យសុំសម្រាប់គម្រោងដែលមានគោលដៅផ្តល់មូលនិធិសម្រាប់បង្កើតអង្គការមិនមែនរដ្ឋាភិបាល ឬ អង្គការសង្គមមស៊ីវិលដទៃទៀត នឹងមិនទទួលយកឡើយ។

- អង្គការមិនមែនរដ្ឋាភិបាល និងតួអង្គសង្គមស៊ីវិលដទៃទៀតដែលដាក់ពាក្យសុំសម្រាប់គម្រោងដើម្បីផ្តល់ជំនួយឥតសំណងផ្លូវច្បាប់ផ្ទាល់ដល់ជនរងគ្រោះនៃទារុណកម្ម គួរដាក់ជូនព័ត៌មានថាតើតុលាការអាចផ្តល់ជំនួយឥតសំណងផ្លូវច្បាប់ដោយឥតគិតថ្លៃ ដើម្បីការពារជនរងគ្រោះស្របតាមច្បាប់ក្នុងស្រុកដែរឬទេ? បញ្ជីឈ្មោះជនរងគ្រោះដែលត្រូវផ្តល់ជំនួយឥតសំណងក្រោមជំនួយឥតសំណងផ្លូវច្បាប់ គួរភ្ជាប់មកជាមួយទម្រង់បែបបទពាក្យស្នើសុំ។
- មូលនិធិមិនផ្តល់សំណងហិរញ្ញវត្ថុដល់ជនរងគ្រោះឡើយ។

### ជំនួយឥតសំណងបន្ទាន់

តួអង្គសង្គមស៊ីវិល អាចដាក់សំណើជាករណីពិសេសស្នើសុំជំនួយឥតសំណងបន្ទាន់នៅចន្លោះកិច្ចប្រជុំពីរនៃក្រុមប្រឹក្សាភិបាលសម្រាប់គម្រោងគាំទ្រដោយមូលនិធិដែលជួបប្រទះបញ្ហាហិរញ្ញវត្ថុ។ តួអង្គសង្គមស៊ីវិល គួរធ្វើសំណើសុំជំនួយឥតសំណងបន្ទាន់របស់ពួកគេដោយបំពេញតាមទម្រង់បែបបទពាក្យសុំរបស់លេខាធិការដ្ឋាន ព្រមទាំងលិខិតលម្អិតមួយច្បាប់ដែលពន្យល់អំពីមូលហេតុដែលពួកគេត្រូវការជំនួយឥតសំណងហិរញ្ញវត្ថុបន្ទាន់។ ពាក្យសុំនឹងអាចទទួលយកបាន តែក្នុងករណីមានហេតុការណ៍មិនអាចស្មានបានដែលបណ្តាលឲ្យមានការកើនឡើងយ៉ាងគំហុកនូវចំនួនជនរងគ្រោះដែលត្រូវការជំនួយឥតសំណង (ឧទាហរណ៍ ការបណ្តាលមកពីការកើនឡើងចំនួនជនរងគ្រោះនៃទារុណកម្ម ដោយសារតែវិបត្តិមនុស្សធម៌)។

### របៀបដាក់ពាក្យសុំទៅកាន់មូលនិធិ

តាមវិធាន ពាក្យសុំទាំងឡាយគួរធ្វើឡើងតាមរយៈប្រព័ន្ធគ្រប់គ្រងជំនួយឥតសំណងតាមអ៊ីនធើណែត។ ក្នុងករណីពិសេស ពាក្យសុំក៏អាចបញ្ជូនជាទម្រង់ឯកសារក្រដាស ដោយផ្ញើតាមប្រៃសណីយ៍ផ្លូវអាកាស ឬតាមអ៊ីមែល។ ទម្រង់ពាក្យសុំអាចរកបាន បន្ទាប់ពីមានសំណើពីលេខាធិការដ្ឋាន។

### ទីកន្លែងដែលត្រូវដាក់ពាក្យស្នើសុំ

**មូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិសម្រាប់ជនរងគ្រោះនៃទារុណកម្ម**

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

Palise des Nations

៨-១៤, ផ្លូវ de la Paix

CH-១២១១, ហ្សឺណែវ ១០ - ប្រទេសស្វីស

ទូរស័ព្ទ៖ +៤១  (០)២២ ៩១៧ ៩៣ ១៥
ទូរសារ៖ +៤១ (០)២២ ៩១៧ ៩០ ១៧
អ៊ីមែល៖ unvfvt@ohchr.org

**នៅពេលដាក់ពាក្យសុំ សូមកត់សម្គាល់ថា៖**

- លេខាធិការដ្ឋានរបស់មូលនិធិ នឹងមិនទទួលពាក្យសុំដែលមិនប្រើប្រាស់ទម្រង់ពាក្យសុំរបស់មូលនិធិ ពាក្យសុំដែលមិនផ្តល់ព័ត៌មានបានស្នើសុំទាំងអស់ ពាក្យសស្នើសុំដែលមិនមានចុះហត្ថលេខា និងកាលបរិច្ឆេទដោយប្រធានគម្រោង ឬ មិនអនុវត្តតាមគោលការណ៍ណែនាំរបស់មូលនិធិ។
- ពាក្យសុំអាចជាភាសាអង់គ្លេស បារាំង ឬ អេស្ប៉ាញ។

**សម្រាប់ព័ត៌មានបន្ថែមអំពីមូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិសម្រាប់ជនរងគ្រោះនៃទារុណកម្ម** សូមចូលទៅកាន់គេហទំព័រការិយាល័យ OHCHR។

## ២. មូលនិធិស្ម័គ្រចិត្តសម្រាប់ប្រជាជនជនជាតិដើមភាគតិច

**មូលនិធិស្ម័គ្រចិត្តសម្រាប់ប្រជាជនជនជាតិដើមភាគតិច** ស្វែងរកការសម្របសម្រួលដល់ការចូលរួមរបស់តំណាងសហគមន៍ និងអង្គការជនជាតិភាគតិចនៅក្នុងស្ថាប័នពីររបស់អង្គការសហប្រជាជាតិដែលធ្វើការទាក់ទងនឹងសិទ្ធិជនជាតិដើមភាគតិច៖

- **យន្តការជំនាញទាក់ទងនឹងសិទ្ធិរបស់ប្រជាជនជនជាតិដើមភាគតិច** និង
- **វេទិកាអចិន្ត្រៃយ៍ស្តីពីបញ្ហាជនជាតិដើមភាគតិច។**

យន្តការជំនាញទាក់ទងនឹងសិទ្ធិរបស់ប្រជាជនជនជាតិដើមភាគតិច ជាជាយន្តការថ្មីមួយរបស់**ក្រុមប្រឹក្សាសិទ្ធិមនុស្ស**[77] ដែលជំនួសឲ្យ**ក្រុមការងារស្តីពីប្រជាជនជនជាតិដើមភាគតិច**នៃអតីតអនុគណៈកម្មការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស។
សម្រាប់ព័ត៌មានបន្ថែមទាក់ទងនឹង**យន្តការជំនាញ** សូមអានជំពូក V (**ក្រុមប្រឹក្សាសិទ្ធិមនុស្ស**) នៃ *សៀវភៅណែនាំ* នេះ។

---

[77]បង្កើតឡើងដោយសេចក្តីសម្រេច ៦/៣៦ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧។

វេទិកាអចិន្ត្រៃយ៍ស្តីពីសិទ្ធិជនជាតិដើមភាគតិច ដែលជាស្ថាប័នប្រឹក្សាយោបល់ដល់**ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមអង្គការសហប្រជាជាតិ** គឺជាស្ថាប័នកម្រិតខ្ពស់មួយមានមូលដ្ឋាននៅទីក្រុងញូវយ៉ក ដែលបានរួមចំណែកដល់កិច្ចសហប្រតិបត្តិការអន្តរទីភ្នាក់ងារលើបញ្ហាជនជាតិដើមភាគតិច។ មូលនិធិស្ម័គ្រចិត្តសម្រាប់ប្រជាជនជនជាតិដើមភាគតិច ដែលគ្រប់គ្រងដោយការិយាល័យ OHCHR ផ្តល់នូវ**ជំនួយឥតសំណងសម្រាប់ការធ្វើដំណើរ** សម្រាប់តំណាងប្រជាជន និងអង្គការជនជាតិដើមភាគតិច ដែលធ្វើការជាមួយពួកគេ ដើម្បីចូលរួមក្នុងស្ថាប័នទាំងនេះ។ តាមរយៈវិធីនេះ តួអង្គសង្គមស៊ីវិលជនជាតិដើមភាគតិច អាចចូលរួមចែករំលែកនូវជំនាញរបស់ពួកគេ និងយកទៅវិញនូវមេរៀនជាបទពិសោធន៍។

មូលនិធិត្រូវបានគ្រប់គ្រងដោយអគ្គលេខាធិការដ្ឋានអង្គការសហប្រជាជាតិស្របតាមតាមបទប្បញ្ញត្តិហិរញ្ញវត្ថុ និងវិធាននានារបស់អង្គការសហប្រជាជាតិ ជាមួយនឹងការផ្តល់ប្រឹក្សាយោបល់ពីក្រុមប្រឹក្សាភិបាល ដែលសុទ្ធសឹងតែជាអ្នកមានបទពិសោធន៍លើបញ្ហាជនជាតិដើមភាគតិច។

## ការទទួលបានមូលនិធិស្ម័គ្រចិត្តសម្រាប់ប្រជាជនជនជាតិដើមភាគតិច[78]

ការរួមចំណែក និងការចូលរួមយ៉ាងសកម្មពីសំណាក់តួអង្គសង្គមស៊ីវិលក្នុងស្រុក ថ្នាក់ជាតិ និងអន្តរជាតិបានជួយនាំមកនូវការរីកចម្រើនគួរឲ្យកត់សម្គាល់លើបញ្ហាជនជាតិដើមភាគតិចនៅលើឆាកអន្តរជាតិ។ អង្គភាពនានារបស់អង្គការសហប្រជាជាតិដែលធ្វើការទាក់ទងនឹងប្រជាជនជនជាតិដើមភាគតិច គឺជាឧបករណ៍សកម្មភាពដ៏សំខាន់សម្រាប់តួអង្គសង្គមស៊ីវិលដែលធ្វើការជាមួយជនជាតិដើមភាគតិច និងសម្រាប់ក្រុមសង្គមស៊ីវិលជនជាតិដើមភាគតិចផ្ទាល់។ ជំនួយឥតសំណងសម្រាប់ការធ្វើដំណើររបស់មូលនិធិមានគោលដៅបង្កើនចំនួន និងភាពចម្រុះនៃប្រជាជនជនជាតិដើមភាគតិចដែលចូលរួមក្នុងអង្គភាពទាំងនេះ។

### តើនរណាខ្លះមានសិទ្ធិទទួលបានជំនួយឥតសំណង?

តំណាងដែលជាជនជាតិដើមភាគតិចនៃអង្គការ និងសហគមន៍ប្រជាជនជនជាតិដើមភាគតិច៖

- អ្នកដែលមិនអាចចូលរួមកិច្ចប្រជុំរបស់យន្តការជំនាញ ឬ វេទិកាអចិន្ត្រៃយ៍ និង

[78] រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងអង្គភាពឯកជន ឬសាធារណៈផ្សេងទៀតអាចផ្តល់វិភាគទានដល់មូលនិធិបាន។ សម្រាប់ព័ត៌មានបន្ថែមទាក់ទងនឹងការផ្តល់វិភាគទាន សូមទាក់ទងលេខាធិការដ្ឋានរបស់មូលនិធិ។

- អ្នកដែលអាចចែករំលែកចំណេះដឹងកាន់តែស៊ីជម្រៅអំពីផ្នែកយន្តការជំនាញ ឬ វេទិកាសាធារណៈលើបញ្ហាទាំងឡាយដែលប៉ះពាល់ដល់ប្រជាជនជនជាតិដើមភាគតិច និងអ្នកដែលនឹងអាចធានាបាននូវការតំណាងតាមភូមិសាស្ត្រកាន់តែទូលំទូលាយ។

លក្ខខណ្ឌចាំបាច់នៃពាក្យសុំ

- ជំនួយឥតសំណងសម្រាប់ការធ្វើដំណើរត្រូវផ្តល់ជូនផ្អែកលើមូលដ្ឋានបុគ្គល- អង្គការ ឬ អ្នកទទួលផលមិនអាចស្នើសុំឲ្យមានការជំនួសអ្នកទទួលផលម្នាក់ដោយអ្នកទទួលផលម្នាក់ទៀតនោះទេ។
- ពាក្យសុំពីសំណាក់បុគ្គល ត្រូវតែមានអមជាមួយនូវលិខិតឧទ្ទេសនាមមួយច្បាប់ដែលចុះហត្ថលេខាដោយនាយកប្រតិបត្តិនៃនៃអង្គការជនជាតិដើមភាគតិចរបស់ពួកគេ។ ក្រុមប្រឹក្សាភិបាល នឹងមិនពិនិត្យលិខិតដែលចុះហត្ថលេខាដោយអ្នកដាក់ពាក្យស្នើសុំខ្លួនឯងផ្ទាល់ឡើយ។
- ជាអតិបរមា អ្នកដាក់ពាក្យសុំតែពីរនាក់ប៉ុណ្ណោះក្នុងមួយអង្គការអាចដាក់ពាក្យស្នើសុំជំនួយឥតសំណងបាន។
- អ្នកដាក់ពាក្យសុំត្រូវបានស្នើឲ្យដាក់ទម្រង់បែបបទពាក្យសុំ និងលិខិតឧទ្ទេសនាមដោយប្រើភាសាដែលលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាភិបាលប្រើប្រាស់ (ភាសាអង់គ្លេស បារាំង ឬ អេស្ប៉ាញ)។
- អ្នកដាក់ពាក្យស្នើសុំ ត្រូវបានស្នើឲ្យបញ្ជាក់អំពីការទទួលខុសត្រូវរបស់ពួកគេនៅក្នុងអង្គការ ឬ សហគមន៍របស់ខ្លួន។
- អនុសាសន៍របស់ក្រុមប្រឹក្សាភិបាលគាំទ្រដល់អ្នកដាក់ពាក្យសុំចូលរួមកិច្ចប្រជុំរបស់វេទិការសាធារណៈ មិនត្រូវរាប់បញ្ចូលជាអនុសាសន៍មួយផ្សេងទៀតដើម្បីចូលរួមក្នុងយន្តការជំនាញឡើយ ហើយដូចគ្នានេះដែរអនុសាសន៍របស់ក្រុមប្រឹក្សាភិបាលគាំទ្រដល់អ្នកដាក់ពាក្យសុំចូលរួមយន្តការជំនាញក៏មិនត្រូវរាប់បញ្ចូលជាអនុសាសន៍មួយផ្សេងទៀតដើម្បីចូលរួមក្នុងកិច្ចប្រជុំរបស់វេទិកាសាធារណៈផងដែរ។

**ទីកន្លែងដែលត្រូវដាក់ពាក្យសុំ**

ទម្រង់បែបបទពាក្យសុំជំនួយឥតសំណង អាចរកបាននៅលើគេហទំព័ររបស់ការិយាល័យ OHCHR និងគួរដាក់ពាក្យស្នើសុំនេះត្រឹម**ថ្ងៃទី០១ ខែតុលា** ជារៀងរាល់ឆ្នាំទៅកាន់៖

**មូលនិធិស្ម័គ្រចិត្តសម្រាប់ប្រជានជនជាតិដើមភាគតិច**

**ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស**

Palise des Nations
៨-១៨, ផ្លូវ de la Paix
CH-១២១១, ទីក្រុងហ្សឺណែវ ១០-ប្រទេសស្វីស
ទូរស័ព្ទ៖ +៤១ (0)២២ ៩២៨ ៩១ ៦៤ ឬ +៤១ (0)២២ ៩២៨ ៩១ ៤២
ទូរសារ៖ +៤១ (0)២២ ៩២៨ ៩០ ៦៦
**អ៊ីមែល៖** indigenousFunds@ohchr.org

**ដើម្បីស្វែងយល់បន្ថែមអំពីការងាររបស់ការិយាល័យ OHCHR ទាក់ទងនឹងប្រជានជនជនជាតិដើម ភាគតិច** សូមចូលទៅកាន់គេហទំព័ររបស់ការិយាល័យ OHCHR។

**៣. មូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាតិស្តីពីទម្រង់នៃទាសភាពសម័យបច្ចុប្បន្ន**

**មូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាតិស្តីពីទម្រង់នៃទាសភាពសម័យបច្ចុប្បន្ន** ផ្តល់ជំនួយឥតសំណងសម្រាប់គម្រោងខ្នាតតូច ជាពិសេស សម្រាប់អង្គការសង្គមស៊ីវិល ដូចជា អង្គការមិនមែនរដ្ឋាភិបាល សហគមន៍ និងក្រុមយុវជន សហជីព ឬ សមាគមវិជ្ជាជីវៈ ដែលជួយជនរងគ្រោះនៃទម្រង់ទាសភាពសម័យបច្ចុប្បន្ន (ឧទាហរណ៍ ពលកម្មកុមារ ការជួញដូរ និងពលកម្មដោយបង្ខំ)។ គោលដៅនៃជំនួយឥតសំណងគាំទ្រគម្រោង គឺដើម្បីពង្រីកជំនួយឥតសំណងមនុស្សធម៌ ផ្លូវច្បាប់ និងហិរញ្ញវត្ថុ តាមរយៈប្រព័ន្ធជំនួយឥតសំណងដែលបានបង្កើតឡើង ដើម្បីផ្តល់ជូនបុគ្គលនានាដែលសិទ្ធិរបស់ពួកគេត្រូវបានរំលោភបំពានយ៉ាងធ្ងន់ធ្ងរបណ្តាលមកពីទម្រង់ទាសភាពសម័យបច្ចុប្បន្ន។ មូលនិធិនេះផ្តល់ឱកាសដល់តួអង្គសង្គមស៊ីវិល ដែលជាញឹកញាប់ បំពេញការងារនៅថ្នាក់មូលដ្ឋាន ដើម្បីជួយជនរងគ្រោះមួយភាគធំដោយផ្ទាល់ជាមួយនឹងមូលនិធិតិចតួច។

## ការទទួលបានមូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិស្តីពីទម្រង់នៃទាសភាពសម័យបច្ចុប្បន្ន

បច្ចុប្បន្ន តួអង្គសង្គមស៊ីវិលជាច្រើន កំពុងប្រយុទ្ធប្រឆាំង និងការពារជនរងគ្រោះនៃទម្រង់ទាសភាពសម័យមុន នៅតំបន់នានានៅជុំវិញពិភពលោក។ ជាញឹកញាប់ អំពើទាសភាពមានលក្ខណៈលួចលាក់ ហើយមានតែតួអង្គសង្គមស៊ីវិលអាចមានតួនាទីសំខាន់ក្នុងការលាតត្រដាងពីការរំលោភសិទ្ធិមនុស្សពាក់ព័ន្ធនឹងទម្រង់ទាសភាពសម័យបច្ចុប្បន្ន។ ពាក្យ "ទាសភាព" នាពេលបច្ចុប្បន្ន គ្របដណ្តប់នូវទម្រង់នៃការរំលោភសិទ្ធិមនុស្សជាច្រើនខុសៗគ្នា។ បន្ថែមលើទាសភាពជាលក្ខណៈ

ប្រពៃណី និងការជួញដូរទាសករ ការបំពានទាំងនេះរួមបញ្ចូលទាំងការលក់ដូរកុមារ ពេស្យាចារកុមារ រូបអាសអាភាសកុមារ និងការកេងប្រវ័ញ្ចពលកម្មកុមារ ការកាត់អវយវៈភេទកុមារី ការប្រើកុមារនៅក្នុងជំលោះប្រដាប់អាវុធ ទាសភាពបំណុល ការជួញដូរមនុស្ស និងលក់គ្រឿងក្នុងមនុស្ស និងការកេងប្រវ័ញ្ចនៃពេស្យាចារ និងការអនុវត្តមួយចំនួនក្រោមរបបរស់នៅតាមតំបន់តាមជាតិសាសន៍មួយៗ និងអាណានិគម។

**ជំនួយឥតសំណងគាំទ្រគម្រោង** ជាពិសេសសម្រាប់អង្គការសង្គមស៊ីវិល ដូចជាអង្គការមិនមែនរដ្ឋាភិបាល សហគមន៍ និងក្រុមយុវជន សហជីព និងសមាគមវិជ្ជាជីវៈ មានគោលដៅបង្កើនការចូលរួមរបស់សង្គមស៊ីវិលក្នុងការលុបបំបាត់ទាសភាពនៅជុំវិញពិភពលោក។

## តើនរណាខ្លះមានសិទ្ធិទទួលបានជំនួយឥតសំណងគាំទ្រគម្រោង?

- អង្គការដែលផ្តល់ជំនួយឥតសំណងដោយផ្ទាល់ទៅឲ្យបុគ្គលដែលសិទ្ធិរបស់ពួកគេត្រូវបានរំលោភបំពាន ដោយសារតែទម្រង់ទាសភាពសម័យមុន។ ជំនួយឥតសំណងដោយផ្ទាល់នេះគ្របដណ្តប់លើជំនួយឥតសំណងគាំទ្រមួយភាគធំដែលបានផ្តល់ឲ្យ។ មូលនិធិត្រូវបញ្ជូនបន្តទៅឲ្យអ្នកទទួលតាមរយៈអង្គការសង្គមស៊ីវិល និងបណ្តាញថ្នាក់មូលដ្ឋាននានាដែលត្រូវបានបង្កើតឡើង និងទទួលបានការឯកភាពក្នុងការផ្តល់នូវជំនួយឥតសំណងមនុស្សធម៌ ផ្លូវច្បាប់ និងហិរញ្ញវត្ថុដល់ជនរងគ្រោះ។
- អង្គការដែលផ្តល់ជំនួយឥតសំណងដោយប្រយោលដល់ជនរងគ្រោះតាមរយៈវិធានការបង្ការ និងការបណ្តុះបណ្តាល។ គម្រោងជាច្រើនដែលត្រូវបានជ្រើសរើសគឺមានការពាក់ព័ន្ធនឹងកម្មវិធីស្តារនីតិសម្បទា និងកម្មវិធីអប់រំ ដើម្បីជួយជនរងគ្រោះឲ្យមានជំហរឹងប៉ឹងខ្លួនឯង និងកាត់បន្ថយភាពងាយរងគ្រោះពីការកេងប្រវ័ញ្ច។

## លក្ខខណ្ឌចាំបាច់នៃការដាក់ពាក្យសុំជំនួយឥតសំណង

- ទម្រង់បែបបទពាក្យស្នើសុំច្បាប់ដើមដែលមាននៅលើអ៊ីនធើណិត ត្រូវតែដាក់ជូនមកតាមប្រៃសណីយ៍ផ្លូវអាកាស និងគួរមានចុះហត្ថលេខា និងកាលបរិច្ឆេទ។ ពាក្យសុំអាចរៀបចំជាភាសាអង់គ្លេស បារាំង ឬ អេស្ប៉ាញ។
- អង្គការមួយអាចស្នើសុំជំនួយឥតសំណងជាអតិបរមារហូតដល់ ១៥០០០ ដុល្លារអាមេរិកក្នុងជំនួយឥតសំណងមួយពីមូលនិធិ។

- គម្រោងនឹងត្រូវបានជ្រើសរើសពីតំបន់ភូមិសាស្ត្រទាំងអស់ ដើម្បីផ្តល់នូវទិដ្ឋភាពកាន់តែទូលំទូលាយតាមដែលអាចទៅរួចនៃទម្រង់ទាសភាពសម័យបច្ចុប្បន្ននៅក្នុងពិភពលោក។
- គម្រោងគួរតែពិចារណាទៅលើសមភាពយេនឌ័រ។
- ជំនួយឥតសំណងគាំទ្រគម្រោងគួរតែត្រូវបានចាត់ចែងសម្រាប់ជំនួយឥតសំណងផ្ទាល់ដល់ជនរងគ្រោះ និងដល់អង្គការសង្គមស៊ីវិលក្នុងស្រុកនានា។ ជំនួយឥតសំណងអាចផ្តល់ឲ្យបានតាមរយៈអង្គការអន្តរជាតិមួយ ដរាបណាមិនមានរក្សាទុកចំណែកណាមួយនៃជំនួយឥតសំណងនោះសម្រាប់សកម្មភាពផ្ទាល់ខ្លួន។
- ក្រុមប្រឹក្សាភិបាលនឹងមិនពិចារណាលើពាក្យសុំមួយដែលលេខាធិការដ្ឋានមិនទាន់បានទទួលព័ត៌មានបន្ថែមគ្រប់គ្រាន់ បន្ទាប់ពីការក្រើនរំឭកលើកទីពីរ។

| គម្រោងដែលទទួលប្រយោជន៍ពីមូលនិធិស្ម័គ្រចិត្តស្តីពីទម្រង់នៃទាសភាពសម័យមុន | | |
|---|---|---|
| Mahilla Seva Samithi ប្រទេសឥណ្ឌា៖ នៅឆ្នាំ២០០៥ ជំនួយឥតសំណងចំនួន ២០០០ ដុល្លារបានជួយជនរងគ្រោះនៃពលកម្មកុមារចំនួន ៨៨ នាក់ ឲ្យចូលរៀននៅសាលាបឋមសិក្សា និងផ្គត់ផ្គង់ដល់ការសិក្សារបស់ពួកគេ | គម្រោងធានាឲ្យបាននូវការវាយតម្លៃតាមដានរៀងរាល់បួនខែម្តងដើម្បីធ្វើការតាមដានពីការវិវឌ្ឍទៅមុខរបស់កុមារ។ | Jadakris, ប្រទេសនីហ្សេរីយ៉ា៖ នៅឆ្នាំ២០០៦ ជនរងគ្រោះពីការជួញដូរមនុស្សចំនួន ៣០នាក់បានទទួលជំនួយឥតសំណងគាំទ្រ ៦,៤០០ដុល្លារអាមេរិក សម្រាប់ការស្តារនីតិសម្បទា និងការបណ្តុះបណ្តាលឡើងវិញដើម្បីជួយជំរុញដល់ពួកគេក្នុងការស្វែងរកប្រាក់ផ្គត់ផ្គង់ជីវភាព។ |

**ទីកន្លែងដែលត្រូវដាក់ពាក្យសុំ**

ទម្រង់បែបបទពាក្យស្នើសុំជំនួយឥតសំណង គួរតែដាក់ត្រឹម**ថ្ងៃទី១៥ ខែកញ្ញា ជារៀងរាល់ឆ្នាំ** ទៅកាន់៖

**មូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិស្តីពីទម្រង់នៃទាសភាពសម័យមុន**

**ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស**

Palise des Nations

៨-១៤, ផ្លូវ de la Paix
CH-១២១១, ទីក្រុងហ្សឺណែវ ១០-ប្រទេសស្វីស
ទូរស័ព្ទ៖ +៤១ (០)២២ ៩២៨ ៩៣ ៨១ ឬ +៤១ (០)២២ ៩២៨ ៩១ ៦៤
ទូរសារ៖ +៤១ (០)២២ ៩២៨ ៩០ ៦៦
អ៊ីមែល៖ SlaveryFunds@ohchr.org

**អ្នកដាក់ពាក្យសុំ គួរដាក់ទម្រង់បែបបទពាក្យសុំដែលបានបំពេញរួចរាល់ដែលមាននៅលើគេហទំព័រការិយាល័យ OHCHR។**

**គម្រោង "រួមគ្នាជួយសហគមន៍"**

នៅឆ្នាំ ១៩៩៨ ការិយាល័យ OHCHR និងកម្មវិធីអភិវឌ្ឍអង្គការសហប្រជាជាតិ បានបង្កើតគម្រោង **"រួមគ្នាជួយសហគមន៍" (គម្រោង ACT)** ដែលផ្តល់ជំនួយឥតសំណងខ្នាតតូចដល់តួអង្គសង្គមស៊ីវិល ដូចជា អង្គការមិនមែនរដ្ឋាភិបាល សមាគមតាមមូលដ្ឋាន គ្រឹះស្ថានអប់រំ និងក្រុមវិជ្ជាជីវៈដែលអនុវត្ត **សកម្មភាពអប់រំ និងបណ្តុះបណ្តាលអំពីសិទ្ធិមនុស្សនៅក្នុងសហគមន៍មូលដ្ឋាន។** ឆ្លងកាត់រយៈពេលជាច្រើនឆ្នាំ គម្រោងនេះបានផ្តោតទៅលើសកម្មភាពគាំទ្រនានាក្នុងបរិបទនៃកម្មវិធីអប់រំសិទ្ធិមនុស្សប្រចាំទសវត្សរ៍សហប្រជាជាតិ (១៩៩៥-២០០៤) និងកម្មវិធីអប់រំសិទ្ធិមនុស្សសកល (២០០៥-បច្ចុប្បន្ន)។ ចាប់តាំងពីឆ្នាំ ១៩៩៨ មកការិយាល័យ OHCHR និង UNDP បានផ្តល់ជំនួយឥតសំណងគាំទ្រដល់គម្រោងជាង ៨០០ គម្រោង នៅ ៧៣ ប្រទេស។

ការគ្រប់គ្រងជារួមនៃគម្រោង ACT ត្រូវបានសម្របសម្រួលដោយទីស្នាក់ការកណ្តាលការិយាល័យរបស់ OHCHR។ នៅក្នុងប្រទេសចូលរួមនីមួយៗ "ក្រុមការងារគម្រោង ACT" ក្នុងស្រុក ដែលមានសមាសភាពបុគ្គលិករបស់ការិយាល័យ UNDP ប្រចាំប្រទេស និងបុគ្គលិកតាមមូលដ្ឋានរបស់ការិយាល័យ OHCHR (ប្រសិនបើមាន) ព្រមទាំងអង្គភាពអង្គការសហប្រជាជាតិ ធ្វើការចែកចាយទម្រង់បែបបទពាក្យសុំ ជ្រើសរើសកម្មភាពដែលត្រូវទទួលបានជំនួយឥតសំណង និងទទួលខុសត្រូវត្រួតពិនិត្យការអនុវត្តសកម្មភាពទាំងឡាយតាមរយៈការប្រាស្រ័យទាក់ទងផ្ទាល់ជាមួយអ្នកទទួលជំនួយឥតសំណង។

គម្រោង ACT ប្រើវិធីសាស្រ្តចាប់ផ្តើមពីក្រោមឡើងលើ ដោយលើកទឹកចិត្តចំពោះចំណាត់ការនៅថ្នាក់សហគមន៍ ក្នុងគោលដៅបង្កើនការគោរពសិទ្ធិមនុស្សតាមវិធីជាក់ស្តែងនានាពាក់ព័ន្ធនឹងលក្ខខណ្ឌជាក់លាក់របស់ប្រជាជន។ គម្រោង ACT មានគោលបំណងចម្បងធ្វើការពង្រឹងសមត្ថភាពក្នុងស្រុក

សម្រាប់ការអប់រំ ការបណ្តុះបណ្តាល និងព័ត៌មានសារធាណៈស្តីពីសិទ្ធិមនុស្ស។ ឧទាហរណ៍ គម្រោងនេះបានផ្តល់មូលនិធិដល់៖

- សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលស្តីពីសិទ្ធិមនុស្សសម្រាប់ក្រុមផ្សេងៗ រួមទាំងគ្រូបង្រៀន ស្ត្រី អ្នកធ្វើការសង្គម និងមន្ត្រីសាធារណៈ និងប្រជាជនភាគតិច។
- យុទ្ធនាការយល់ដឹងពីសិទ្ធិមនុស្សជាមួយនឹងព្រឹត្តិការណ៍វប្បធម៌ ដូចជាការសំដែងនៅមហោស្រព ការតាំងពិពរណ៌សិល្បៈ និងការប្រគុំតន្ត្រីរ៉ក់ជាដើម។
- ការផលិត/បកប្រែឯកសារសិទ្ធិមនុស្ស និងការផ្សព្វផ្សាយឯកសារទាំងនោះតាមរយៈសារព័ត៌មាន។
- ការបង្កើតមជ្ឈមណ្ឌលព័ត៌មាននានាសម្រាប់ការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស។
- កម្មវិធីអប់រំសម្រាប់ក្រុមងាយទទួលរងគ្រោះមួយចំនួន ដូចជាទណ្ឌិត អ្នកបម្រើសេវាផ្លូវភេទ អ្នកផ្ទុកមេរោគអេដស៍ កុមារកំព្រា និងអ្នកដែលបាត់បង់ទីលំនៅក្នុងស្រុក។ និង
- សកម្មភាពអប់រំស្តីពីសិទ្ធិមនុស្សសម្រាប់កុមារ និងយុវជន ដូចជាការប្រកួតនៅតាមសាលា និងការបង្កើតក្លឹបយុវជនសិទ្ធិមនុស្សជាដើម។

ការទទួលបានគម្រោង ACT

គម្រោង ACT ផ្តល់នូវការគាំទ្រហិរញ្ញវត្ថុដល់តួអង្គសង្គមស៊ីវិលថ្នាក់មូលដ្ឋាន ជាពិសេស អង្គការមិនមែនរដ្ឋាភិបាល គ្រឹះស្ថានអប់រំ ក្រុមវិជ្ជាជីវៈ សារព័ត៌មានក្នុងស្រុក និងអង្គការស្ត្រីនានាដែលអនុវត្តសកម្មភាពអប់រំស្តីពីសិទ្ធិមនុស្ស។

**លក្ខខណ្ឌចាំបាច់នៃការដាក់ពាក្យសុំ**

- អ្នកដាក់ពាក្យសុំ ត្រូវតែជាអង្គការសង្គមស៊ីវិល ឬ សមាគមដែលមានសមត្ថភាពក្នុងការអនុវត្តគម្រោងដែលខ្លួនកំពុងស្នើសុំ។
- គម្រោងដែលបានស្នើឡើង គួរមានភាពច្នៃប្រឌិតបង្កើតថ្មី អាចអនុវត្តតាមបាន និងរៀបចំឡើងដើម្បីផ្តល់ឥទ្ធិពលដែលមាននិរន្តរភាពជាអតិបរមាក្នុងស្រុក។
- គម្រោងគួរតែមានរយៈពេលលើសប្រាំមួយខែ និងមានកញ្ចប់ថវិកាអតិបរមាចំនួន ៥០០០ដុល្លារអាមេរិក។
- ពាក្យសុំគម្រោងត្រូវបានចែកចាយ និងប្រមូលដោយជនបង្គោលជាតិរបស់អង្គការសហប្រជាជាតិសម្រាប់គម្រោង ACT ក្នុងប្រទេសដែលចូលរួម ដែលមានកាលបរិច្ឆេទកំណត់ពីថ្នាក់ជាតិ។ អ្នកផ្តល់ជំនួយឥតសំណងចុះកិច្ចព្រមព្រៀងផ្តល់ជំនួយឥតសំណងជាមួយការិយាល័យប្រចាំប្រទេស UNDP ឬ ជាមួយការិយាល័យ OHCHR។

- ពាក្យសុំជំនួយឥតសំណង និងរបាយការណ៍នានាអាចដាក់ជាភាសាអង់គ្លេស បារាំង ឬ អេស្ប៉ាញ។

ឧទាហរណ៍នៃការផ្តល់មូលនិធិរបស់គម្រោង ACT

| | | |
|---|---|---|
| នៅប្រទេសម៉ាដាហ្គាស្កា គម្រោង ACT បានគាំទ្រដល់គំនិតផ្តួចផ្តើមដែលផ្តល់លើសិទ្ធិកុមារពិការ ដែលរួមបញ្ចូលទាំងការសំដែងរូបអាយ៉ង និងការរៀបចំ ក៏ដូចជា ការចែកចាយសៀវភៅណែនាំពាក់ព័ន្ធមួយក្បាល។ គម្រោងបានទទួលកុមាររហូតជាង ៦០០០នាក់ នៅសាលារៀនចំនួន ១៤។ នាយកសាលា បាន ផ្តល់អនុសាសន៍ថា ព្រឹត្តិការណ៍នេះគួរតែរៀបចំម្តងទៀតនៅដើមឆ្នាំសិក្សានីមួយៗ។ | **វេទិកាសារព័ត៌មានរបស់ស្ត្រីភាគខាងត្បូង** នៅតំបន់ Gaza Strip ដែលជាដែនដីគ្រប់គ្រងដោយជនជាតិប៉ាឡេស្ទីន ត្រូវបានបង្កើតឡើងនៅឆ្នាំ ២០០៥ ដើម្បីស្ត្រីវ័យក្មេង ជាពិសេសស្ត្រីដែលធ្វើការនៅក្នុងបណ្តាញសារព័ត៌មាន។ ម្ចាស់មូលនិធិបានជឿជាក់ថា វាមានសារៈសំខាន់ក្នុងការផ្តល់វេទិកាមួយសម្រាប់ស្ត្រីបម្រើការងារក្នុងបណ្តាញសារព័ត៌មានដែលមានការលំបាកជាងមិត្តរួមការងាររបស់ពួកគេជាបុរស ក្នុងការជួបជុំ បង្កើតបណ្តាញ និងចែករំលែកគំនិតនានាទាក់ទងនឹងការងាររបស់ | ពួកគេ និងទទួលស្គាល់ថាសិទ្ធិរបស់ស្ត្រីមិនត្រូវបានផ្សព្វផ្សាយឲ្យបានគ្រប់គ្រាន់នៅក្នុងបណ្តាញសារព័ត៌មាននោះទេ។ ជំនួយឥតសំណងនៃគម្រោង ACT បានផ្តល់ការបណ្តុះបណ្តាលស្តីពីសិទ្ធិមនុស្ស សម្រាប់អ្នកកាសែតជាស្ត្រីចំនួន ១៥ នាក់ ពីតំបន់ Gaza Strip និងការផលិតទស្សនាវដ្តីលេខទីមួយសម្រាប់ស្ត្រីនៅក្នុងបណ្តាញសារព័ត៌មានដែលផ្តោតលើសិទ្ធិមនុស្ស និងសិក្ខាសាលាចំនួនប្រាំសម្រាប់ស្ត្រីពីតំបន់ផ្សេងៗនៅក្នុងតំបន់ Gaza Strip ភាគខាងត្បូង។ |

**ការទាក់ទងទៅកាន់គ្រោង ACT**

**គម្រោង ACT**

**ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស**

Palise des Nations

៨-១៤, វុក្ខវិថី de la Paix

CH-១២១១, ទីក្រុងហ្សឺណែវ ១០ ប្រទេសស្វីស

ទូរសារៈ +៤១ (0)២២ ៩២៨ ៩០ ៦1

អ៊ីមែល៖ SlaveryFunds@ohchr.org

សម្រាប់ព័ត៌មានបន្ថែមទាក់ទងនឹងគម្រោង ACT សូមប្រឹក្សាជាមួយ*គម្រោង ACT* សៀវភៅស្តីពី *"រួមគ្នាជួយសហគមន៍"* សម្រាប់ដំណាក់កាល I និង II របស់គម្រោងនៅលើគេហទំព័រការិយាល័យ OHCHR។

## ៥. មូលនិធិនៃអង្គការសហប្រជាជាតិដើម្បីលិទ្ធិប្រជាធិបតេយ្យ

មូលនិធិអង្គការសហប្រជាជាតិដើម្បីលិទ្ធិប្រជាធិបតេយ្យ ត្រូវបានបង្កើតឡើងនៅ ខែកក្កដា ឆ្នាំ ២០០៥ ដែលជាលទ្ធផលកើតចេញពីកិច្ចប្រជុំថ្នាក់កំពូលពិភពលោកឆ្នាំ ២០០៥។[79] គោលដៅចម្បងនៃមូលនិធិនេះគឺផ្តល់ការគាំទ្រដល់ការធ្វើប្រជាធិបតេយ្យនីយកម្មទៅទូទាំងពិភពលោកតាមរយៈ ការផ្តល់ជំនួយឥតសំណងដល់អង្គការរដ្ឋាភិបាល មិនមែនរដ្ឋាភិបាល អង្គការជាតិ អង្គការតំបន់ និងអង្គការអន្តរជាតិនានា រួមទាំងនាយកដ្ឋាន ការិយាល័យ មូលនិធិ កម្មវិធី និងទីភ្នាក់ងារពាក់ព័ន្ធនានារបស់អង្គការសហប្រជាជាតិ ។ UNDEF បានផ្តល់ហិរញ្ញប្បទានដល់គម្រោងនានាដែលកសាង និងពង្រឹងស្ថាប័នប្រជាធិបតេយ្យ លើកកម្ពស់សិទ្ធិមនុស្ស និងធានាឲ្យបាននូវការចូលរួមពីក្រុមទាំងអស់នៅក្នុងដំណើរការប្រជាធិបតេយ្យ។ សកម្មភាពនានាដែលមានសិទ្ធិទទួលជំនួយឥតសំណងរួមមាន៖

- ការសន្ទនាបែបប្រជាធិបតេយ្យ និងការគាំទ្រសម្រាប់ដំណើរការរដ្ឋធម្មនុញ្ញ។
- ការផ្តល់អំណាចដល់សង្គមស៊ីវិល។
- ការអប់រំស៊ីវិល ការចុះឈ្មោះបោះឆ្នោត និងការពង្រឹងគណបក្សនយោបាយ។
- លទ្ធភាពទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋ។
- សិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន និង
- គណនេយ្យភាព តម្លាភាព និងសុចរិតភាព។

UNDEF ត្រូវបានគ្រប់គ្រងដោយ **ការិយាល័យអង្គការសហប្រជាជាតិសម្រាប់ភាពជាដៃគូ** នៅឯទីស្នាក់ការកណ្តាលអង្គការសហប្រជាជាតិនៅទីក្រុងញូវយ៉ក។ ក្រុមប្រឹក្សាភិបាលផ្តល់ប្រឹក្សាយោបល់ដែលមានសមាជិកចំនួន ១៩ នាក់ ត្រូវបានបង្កើតឡើងដើម្បីផ្តល់ការណែនាំគោលនយោបាយ និងដើម្បីផ្តល់អនុសាសន៍លើសំណើសុំមូលនិធិសម្រាប់ការអនុម័តពីអគ្គលេខាធិការ។ ក្រុមប្រឹក្សាភិបាលផ្តល់ប្រឹក្សាយោបល់ត្រូវមានសមាភាពរដ្ឋសមាជិក តំណាងពីអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងតំណាងផ្ទាល់ខ្លួនរបស់អគ្គលេខាធិការ។ នៅក្នុង

[79] សូមអានសេចក្តីសម្រេចរបស់មហាសន្និបាត ៦០/១ នៅក្នុងលទ្ធផលកិច្ចប្រជុំកំពូលពិភពលោកឆ្នាំ២០០៥។

ការជ្រើសរើសគម្រោងជុំទីមួយ និងការបង្វិលថវិកានៅឆ្នាំ ២០០៦ ដែលកាលនោះ លោកអតីតអគ្គលេខាធិ Kofi Anna បានអនុម័តគម្រោង ១២៥ ដែលមានតម្លៃ ៣៦ លានដុល្លារ គ្របដណ្តប់លើតំបន់ទាំងអស់។

UNDEF អាចទទួលពាក្យសុំសម្រាប់ការផ្តល់មូលនិធិដល់គម្រោងពីស្ថាប័នប្រជាធិបតេយ្យ និងអភិបាលកិច្ចជាច្រើន រួមមានស្ថាប័នសិទ្ធិមនុស្សជាតិ (NHRIs) ដោយផ្តោតសំខាន់ទៅលើ អង្គការសង្គមស៊ីវិល ដូចជា អង្គការជាតិ និងអន្តរជាតិ វិទ្យាស្ថានស្រាវជ្រាវ និងគោលនយោបាយ និង សមាគមវិជ្ជាជីវៈនានា។

លក្ខខណ្ឌតម្រូវមួយចំនួនដែលគម្រោងគាំទ្រហិរញ្ញប្បទានដោយ UNDEF ត្រូវបំពេញតាម មានដូចជា៖

- ជាទូទៅគម្រោងត្រូវតែអនុវត្តលើរយៈពេលពីរឆ្នាំ។
- ជាគោលការណ៍ជំនួយឥតសំណងមិនមានចំនួនលើសពី ៥០០០០០ ដុល្លារអាមេរិកសម្រាប់ គម្រោងណាមួយ ហើយជាធម្មតាមានចំនួនអតិបរមា ៥០០០០ ដុល្លារអាមេរិក។
- ការដាក់ពាក្យសុំពីប្រទេសទាំងអស់ ព្រមទាំងគំនិតផ្តួចផ្តើមក្នុងតំបន់ និងសកល ត្រូវបាន ពិចារណា។
- អាទិភាពនឹងត្រូវបានផ្តល់ទៅឲ្យអ្នកដាក់ពាក្យសុំពីប្រទេស និងតំបន់នានាដែលបញ្ហាលំបាកនៃ លិទ្ធិប្រជាធិបតេយ្យកាន់តែមានភាពចាំបាច់ និងមានលក្ខណៈរាលដាល ដូចជាប្រទេសដែល ទើបនឹងងើបចេញពីជម្លោះ ប្រទេសប្រជាធិបតេយ្យថ្មីថ្មោងនិងប្រជាធិបតេយ្យស្តារឡើងវិញ និងប្រទេសអភិវឌ្ឍតិចតួចនិងប្រទេសមានចំណូលទាបនិងមធ្យម។

UNDEF មានគោលដៅគាំទ្រគម្រោងនានាដែលលើកកម្ពស់ប្រជាធិបតេយ្យ និងដែលលទ្ធផលរបស់គម្រោងទាំងនោះនឹងពង្រឹងទំនាក់ទំនងរវាងសង្គមស៊ីវិល និងស្ថាប័នរដ្ឋាភិបាល ការបញ្ចូល និងការចូលរួមពីក្រុមសង្គមមួយភាគតូច និងក្រុមងាយទទួលរងគ្រោះ ឬពង្រឹងកិច្ចសហប្រតិបត្តិការ South-South។

**ការដាក់ពាក្យសុំទៅកាន់ UNDEF**

អង្គការនានាដែលមានបំណងដាក់ពាក្យសុំពី UNDEF គួរចូលទៅកាន់គេហទំព័ររបស់អង្គការនេះ ដែលពួកគេនឹងត្រូវបានជំរុញឲ្យបំពេញពាក្យសុំតាមអ៊ីនធើណិត ដែលអាចបំពេញជាភាសាអង់គ្លេស ឬ បារាំង។ មូលនិធិនឹងមិនទទួលសំណើសុំដែលដាក់តាមអ៊ីមែល ប្រៃសណីយ៍ធម្មតា ទូរសារ ការបញ្ជូនដោយផ្ទាល់ដៃ ឬ តាមអ្នកបញ្ជូនលិខិត ឬ តាមវិធីណាមួយផ្សេងទៀតនោះទេ។

**ការទាក់ទងទៅកាន់ UNDEF**

មូលនិធិអង្គការសហប្រជាជាតិដើម្បីលិទ្ធិប្រជាធិបតេយ្យ (UNDEF)

**អង្គការសហប្រជាជាតិ**

១ UN Plaza, បន្ទប់ DC1 (UNDEF)

ទីក្រុងញូវយ៉ក, NY ១០០១៧

សហរដ្ឋអាមេរិក

ទូរស័ព្ទ៖ +១ ៩១៧ ៣៦៧ ៤២ ១០ ឬ +១ ៩១៧ ៣៦៧ ៨០ ៦២

ទូរសារ៖ +១ ២១២ ៩៦៣ ១៤ ៨៦

អ៊ីមែល៖ democracyfund@un.org

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ UNDEF។

## ៦. មូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាតិសម្រាប់ជនពិការ

មូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាតិសម្រាប់ជនពិការ ត្រូវបានបង្កើតឡើងដោយយោងតាម សេចក្តីសម្រេចនៃមហាសន្និបាត ៣២/១៣៣ ពាក់ព័ន្ធនឹងការរៀបចំសម្រាប់ទិវាជនពិការអន្តរជាតិឆ្នាំ ១៩៨១។ ចាប់តាំងពីពេលនោះមក មហាសន្និបាទបានសម្រេចថា មូលនិធិគួរតែបន្តទៅមុខទៀត ហើយនៅពេលនេះមូលនិធិផ្តល់ជំនួយឥតសំណងខ្នាតតូចដើម្បីគាំទ្រសកម្មភាពនានាដែលមាន គោលដៅកសាងសមត្ថភាពអង្គការសង្គមស៊ីវិលដើម្បីចូលរួមអនុវត្តក**តិកាសញ្ញាស្តីពីសិទ្ធិជនពិការ**។

មូលនិធិផ្តល់នូវជំនួយឥតសំណងខ្នាតតូចដើម្បីគាំទ្រសកម្មភាពដែលជាកាតាលីករ និងប្រកប ដោយគំនិតបង្កើតថ្មីនានាដើម្បី ៖

- លើកកម្ពស់ការយល់ដឹងឲ្យបានកាន់តែច្រើនពីកាតិកាសញ្ញានេះ និងបញ្ហាពិការភាព និងគាំទ្រ ការអនុវត្តកតិកាសញ្ញានេះ។
- អនុញ្ញាតឲ្យមានការផ្លាស់ប្តូរចំណេះដឹង និងបទពិសោធន៍ ព្រមទាំងផ្សព្វផ្សាយ គោលនយោបាយ និងការអនុវត្តបែបរួមបញ្ចូលគ្នា និងដែលអាចស្វែងរកបាន។
- លើកកម្ពស់ការបញ្ជ្រាបពិការភាពចូលទៅក្នុងរបៀបវារៈនៃការអភិវឌ្ឍ និង
- កសាងសមត្ថភាពរបស់ភាគីពាក់ព័ន្ធក្នុងការកែលម្អជីវភាព និងសុខមាលភាពរបស់ជនពិការ នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍ និងដើម្បីអនុវត្តកតិកាសញ្ញា (ភាគីពាក់ព័ន្ធនានាអាច រាប់បញ្ចូលទាំងអង្គការនានារបស់ជនពិការ អង្គការសង្គមស៊ីវិលនានា រដ្ឋាភិបាល អង្គការ វិស័យឯកជន និងម្ចាស់ជំនួយឥតសំណងអភិវឌ្ឍអន្តរជាតិ)។

មូលនិធិនេះត្រូវបានគ្រប់គ្រងដោយ**នាយកដ្ឋានកិច្ចការសេដ្ឋកិច្ច និងសង្គម**នៅទីស្នាក់ការកណ្តាល អង្គការសហប្រជាជាតិនៅទីក្រុងញូវយ៉ក។

## ការទទួលបានមូលនិធិស្ម័គចិត្តនៃអង្គការសហប្រជាជាតិសម្រាប់ជនពិការ

ចាប់តាំងពីបង្កើតឡើងនៅឆ្នាំ១៩៨១ មូលនិធិនេះបានគាំទ្រសកម្មភាពនានាដែលមាន គោលដៅកសាងសមត្ថភាពជាតិ និងស្ថាប័ន ដើម្បីកែលម្អជីវភាព និងសុខមាលភាពរបស់ជនពិការ នៅក្នុងប្រទេសកំពុងអភិវឌ្ឍនានា។ មូលនិធិនេះក៏បានគាំទ្រផងដែរដល់ការលើកកម្ពស់ការយល់ដឹង ទាក់ទងនឹងកតិកាសញ្ញាស្តីពីសិទ្ធិជនពិការ ដូចជាការបណ្តុះបណ្តាល ការគាំទ្រផ្នែកគមនាគមន៍ និង សកម្មភាពព័ត៌មានសាធារណៈ។ មូលនិធិក៏មានសម្រាប់ផ្តល់ជូនទាំងអង្គការសង្គមស៊ីវិល និង រដ្ឋាភិបាលផងដែរ ប៉ុន្តែមិនគ្របដណ្តប់លើបុគ្គលនោះទេ។

សំណើសុំគម្រោងអាចទទួលយកបានពេញមួយឆ្នាំ។ អង្គការសង្គមស៊ីវិលដែលមានបំណងដាក់ពាក្យសុំលើកតំបូងត្រូវតែស្វែងរកលិខិតយល់ព្រម/គ្មានការជំទាស់ពីមន្ត្រីរដ្ឋាភិបាលពាក់ព័ន្ធនានាមុនពេលដាក់ពាកយស្នើសុំជំនួយឥតសំណងទៅកាន់មូលនិធិ។ អង្គការសង្គមស៊ីវិលនានាអាចប្រឹក្សាជាមួយការិយាល័យ UNDP ក្នុងស្រុកទាក់ទងនឹងនីតិវិធីសម្រាប់ស្វែងរកលិខិតនោះ ។

**ការដាក់ពាក្យសុំទៅកាន់មូលនិធិស្ម័គចិត្តនៃអង្គការសហប្រជាជាតិសម្រាប់ជនពិការ**

គំរូពាក្យស្នើសុំ អាចរកបានសម្រាប់ប្រើប្រាស់នៅពេលដាក់ពាក្យសុំជំនួយឥតសំណងសម្រាប់គម្រោង។ ពាក្យសុំគម្រោងនឹងត្រូវបានទទួលយកក្នុងទម្រង់ផ្សេងៗទៀត ដរាបណាព័ត៌មានចាំបាច់ទាំងអស់ត្រូវបានរួមបញ្ចូល។ ពាក្យស្នើសុំអាចដាក់ជាភាសាអង់គ្លេស បារាំង ឬ អេស្ប៉ាញ។ គំរូពាក្យស្នើសុំអាចរកបាននៅលើគេហទំព័រ United Nations Enables។

ពាក្យស្នើសុំ គួរផ្ញើតាមអ៊ីមែល ទូរសារ ឬ ប្រៃសណីយ៍ (ជាការប្រសើរគួរផ្ញើតាមអ៊ីមែល) ទៅកាន់៖

**លេខាធិការដ្ឋានសម្រាប់កតិកាសញ្ញាស្តីពីសិទ្ធិជនពិការ**

**នាយកដ្ឋានកិច្ចការសេដ្ឋកិច្ច និងសង្គម**

**អង្គការសហប្រជាជាតិ**

Two UN Plaza, DC២-១៣៧២

ទីក្រុងញូវយ៉ក. NY ១០០១៧

សហរដ្ឋអាមេរិក

ទូរសារ៖ +១ ២១២ ៩៦៣ ០១ ១១

អ៊ីមែល៖ enable@un.org

**សម្រាប់ព័ត៌មានបន្ថែមទាក់ទងនឹងមូលនិធិនៃកតិការសញ្ញាស្តីពីសិទ្ធិជនពិការ ក៏ដូចជាទាក់ទងនឹងការងាររបស់អង្គការសហប្រជាជាតិលើបញ្ហាពិការភាព សូមចូលទៅកាន់គេហទំព័រ United Nations Enable។**

i. ទីកន្លែងដាក់បណ្ដឹងជាលក្ខណៈបុគ្គលក្រោមយន្តការនិតិវិធីពិសេស
ផ្នែកនីតិវិធីពិសេស
ការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរសារលេខ៖ +៤១(០)២២ ៩១៧ ៩០ ០៦
អ៊ីម៉ែល៖ urgent-action@ohchr.org

សូមបញ្ជាក់អំពីនីតិវិធីពិសេសណាមួយ ដែលពាក្យបណ្ដឹងត្រូវបានផ្ញើទៅ នៅក្នុងទីកន្លែងកម្មវត្ថុនៃអ៊ីម៉ែល ឬទូរសារ ឬនៅលើស្រោមសំបុត្រ។ ចូរកត់សម្គាល់ថា អាណត្តិនៃនិតិវិធីពិសេសបានកំណត់អំពីលក្ខខណ្ឌតម្រូវជាក់លាក់ដែលពាក្យបណ្ដឹងត្រូវតែបំពេញ។ សេចក្ដីពិស្ដារនៃលក្ខខណ្ឌតម្រូវទាំងនេះអាចរកឃើញនៅក្នុងវិបសាយរបស់ការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ក្រោមអាណត្តិនីមួយៗ។